# អដ្ឋកថា ទីឃនិកាយ មហាវគ្គ

## នៃព្រះសុត្តន្តបិដក

## ឈ្មោះ សុមង្គលវិលាសិនី

## តតិយភាគ

## ភាគ ១៦

អធិប្បាយ

មហាបទានសូត្រ-មហានិទានសូត្រ-មហាបរិនិព្វានសូត្រ

ពុទ្ធសករាជ ២៥៥៣

# អដ្ឋកថា ទីឃនិកាយ មហាវគ្គ

## នៃព្រះសុត្តន្តបិដក

### តតិយភាគ

### ភាគ ១៦

ឈ្មោះ

# សុមង្គលវិលាសិនី

ពុទ្ធសករាជ ២៥៥៣

អធិប្បាយ

**មហាបទានសូត្រ-មហានិទានសូត្រ-មហាបរិនិព្វានសូត្រ**

# ពាក្យផ្ដើម

*ព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក ជាសាសនធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធជាម្ចាស់មានអង្គ ៩ គឺ ៖*

***សុត្ត*** *បានដល់ ឧភតោវិភង្គ និទ្ទេសៈ ខន្ធកៈ បរិវារៈ ព្រះសូត្រផ្សេង ៗ មានមង្គលសូត្រជាដើម ។*

***គេយ្យ*** *បានដល់ ព្រះសូត្រដែលប្រកបដោយគាថាទាំងអស់ ។*

***វេយ្យាករណ*** *គឺ ព្រះអភិធម្មបិដកទាំងអស់ ព្រះសូត្រដែលមិនមានគាថា និងពុទ្ធវចនៈដែលមិនបានចាត់ចូលក្នុងអង្គ ៨ ឈ្មោះថា វេយ្យាករណៈទាំងអស់ ។*

***គាថា*** *គឺ ព្រះធម្មបទ ថេរគាថា ថេរីគាថា និងគាថាសុទ្ធ ៗ ដែលមិនមានឈ្មោះ ពោលដល់ ព្រះសូត្រក្នុងសុត្តនិបាត ។*

***ឧទាន*** *គឺ ព្រះសូត្រ ៨២ សូត្រ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់សម្ដែងដោយសោមនស្សញ្ញាណ ។*

*ឥតិវុត្តក គឺ ព្រះសូត្រ ១១០ សូត្រ ដែលផ្ដើមឡើងដោយពាក្យថា សេចក្ដីនេះ សមដូចពាក្យដែលព្រះមានព្រះភាគត្រាស់ទុក ។*

***ជាតក*** *គឺ ជាការសម្ដែងរឿងក្នុងអតីតជាតិរបស់ព្រះពុទ្ធជាម្ចាស់ មានអបណ្ណកជាតកជាដើម មានទាំងអស់ ៥៥០ រឿង ។*

***អព្ភូតធម៌*** *គឺ ព្រះសូត្រដែលបដិសំយុត្តដោយអច្ឆរិយព្ភូតធម៌ទាំងអស់ ។*

***វេទល្ល*** *គឺ លំដាប់ពាក្យដែលអ្នកសួរបានយល់ច្បាស់ ព្រមទាំងបាននូវសេចក្ដី*

វិកកាយ និងសួរជាបន្ត ៗ ទៅ ។

ព្រះពុទ្ធវចនៈទាំងឡាយនេះ ដោយសភាវធម៌ គឺ ជាសច្ចធម៌ដែលទ្រង់ត្រាស់សម្តែងថា ៖

**ជាធម៌ដ៏ជ្រាលជ្រៅ ដឹងបានដោយលំបាក ដឹងតាម**

**ឃើញតាមបានដោយលំបាក ស្ងប់ ប្រណីត ល្អិត**

**មិនអាចដឹងបានដោយការត្រិះរិះ ប៉ុន្តែជាធម៌ដែល**

**បណ្ឌិតគប្បីដឹងបាន ។**

ព្រោះសភាវៈនៃធម៌មានលក្ខណៈដូចពោលមកហើយនេះ ទើបត្រូវធ្វើឲ្យជាក់ច្បាស់ ឲ្យកើតការយល់ចូលចិត្តទាំងអត្ថ និងព្យញ្ជនៈ ដើម្បីញ៉ាំងការយល់ដឹងនូវធម៌ទាំងឡាយតាមសេចក្តីពិតក្នុងរឿងនោះ ៗ ។

ស្របតាមអធ្យាស្រ័យផ្សេងគ្នា របស់មនុស្សផ្សេងគ្នា ក្នុងទឹកដីផ្សេង ៗ ដែលទ្រង់ឧបមាទុកដូចជាផ្កាឈូក ៤ ពួក ព្រះពុទ្ធជាម្ចាស់ព្រះអង្គឈ្លាសក្នុងវិធីសម្តែងព្រះធម៌ តាមការបង្រៀនព្រះធម៌របស់ព្រះមានព្រះភាគ មាន ៣ ប្រការ គឺ ៖

**១ ទ្រង់បង្រៀនឲ្យយល់ដឹងដ៏ក្រៃលែង** ឃើញពិតក្នុងវត្ថុដែលគួរដឹង គួរឃើញ ។

**២ ទ្រង់សម្តែងធម៌មានហេតុផល** ដែលអ្នកស្តាប់អាចពិចារណាឃើញតាមសេចក្តីពិតបាន ។

**៣ ទ្រង់សម្តែងធម៌ដ៏អស្ចារ្យ** គឺ អ្នកប្រតិបត្តិតាមនឹងបានទទួលនូវប្រយោជន៍សមគួរដល់ការប្រព្រឹត្តប្រតិបត្តិ ។

ព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រកបដោយបាដិហារ្យ ទ្រង់ឆ្លាតក្នុងវោហារ ព្រោះទ្រង់ជាម្ចាស់នៃព្រះធម៌ មុននឹងទ្រង់សម្តែងនូវព្រះធម៌ដល់បុគ្គលណា ទ្រង់បានពិចារណាមើលនូវឧបនិស្ស័យរបស់បុគ្គលនោះ ដោយព្រះញាណ ទ្រង់ជ្រាបថា ការបានស្តាប់នូវពុទ្ធវាទ តែងនាំមកនូវប្រយោជន៍ ទើបទ្រង់សម្តែង ។

ក្រោយពីព្រះមានព្រះភាគជាម្ចាស់ទ្រង់បរិនិព្វានទៅ ទ្រង់បានតាំងព្រះធម៌-វិន័យទុកជាសាស្តាជំនួសព្រះអង្គ ។ តែការមិនមានសតិបញ្ញាបារមី ការយល់ខុសក្នុងធម៌របស់បុគ្គលនោះ បានធ្វើការអធិប្បាយសេចក្តីនៃព្រះធម៌វិន័យ តាមការយល់ឃើញរបស់ខ្លួនឯង ជាហេតុធ្វើឲ្យមានការបដិបត្តិផ្សេង ៗ គ្នា មានសីល និងទិដ្ឋិផ្សេង ៗ គ្នា រហូតមាននិកាយដល់ទៅ ១៨ ។

ព្រះអដ្ឋកថាចារ្យ ជ្រាបពុទ្ធាធិប្បាយទាំងដោយអត្ថ និងព្យញ្ជនៈនៃព្រះពុទ្ធ-វចនៈ ព្រោះការសិក្សាចាំស្ទាត់តគ្នាមកតាមលំដាប់ មានឆន្ទៈ និងឧស្សាហៈដ៏ខ្លាំងក្លា បានអធិប្បាយព្រះពុទ្ធវចនៈក្នុងព្រះត្រៃបិដកនូវសេចក្តីដែលលំបាកយល់ ឲ្យកើតការងាយយល់សម្រាប់អ្នកសិក្សា និងបដិបត្តិ ទើបសេចក្តីសំខាន់នៃគម្ពីរក្នុងព្រះពុទ្ធសាសនា ខាងក្រោយតគ្នារហូតមក មាន ៖

**១ ព្រះសូត្រ** គឺ ព្រះពុទ្ធវចនៈ ដែលហៅថា ព្រះត្រៃបិដក ទាំងព្រះវិនយ-បិដក ព្រះសុត្តន្តបិដក និងព្រះអភិធម្មបិដក ។

**២ សុត្តានុលោម** គឺ គម្ពីរដែលព្រះអដ្ឋកថាចារ្យរចនាឡើង អធិប្បាយ

សេចក្តីដែលលំបាកក្នុងព្រះត្រៃបិដក ។

**៣ អាចរិយវាទ** វាទៈរបស់អាចារ្យផ្សេង ៗ តាំងអំពីថ្នាក់ដីកា អនុដីកា និង បុព្វាចារ្យជំនាន់ក្រោយ ៗ ។

**៤ អត្តនោមតិ** ការគិតឃើញរបស់អ្នកនិយាយ អ្នកសម្តែងធម៌ក្នុងព្រះពុទ្ធ-សាសនា ។

ក្នុងកាលតមក មានការអធិប្បាយធម៌ប្រភេទអាចរិយវាទ គឺ កាន់តាម អាចារ្យរបស់ខ្លួន ទូន្មានទុកជាមួយអត្តនោមតិ ទៅតាមមតិរបស់ខ្លួនឯង ដោយ ច្រើន ទាំងនេះអាចនឹងមាន ព្រោះគម្ពីរព្រះពុទ្ធសាសនា ដែលមានគោល សំខាន់ គឺ ព្រះត្រៃបិដក និងអដ្ឋកថាមិនទាន់បានប្រែ អដ្ឋកថាចំណែកច្រើន នៅជាភាសាបាលី បុគ្គលដែលមានឆន្ទៈក្នុងភាសាបាលីតិចតួច សំនួនភាសា បាលីដែលប្រែចេញមកហើយ លំបាកដល់ការយល់របស់អ្នកដែលមិនបានសិក្សា ភាសាបាលីជាមុន ព្រោះខ្វះកល្យាណមិត្ត ខ្វះសប្បុរស ដែលមានការចេះដឹង ក្នុងព្រះពុទ្ធសាសនាជាដើម ។

ការអធិប្បាយធម៌ ដែលជាផលនៃការត្រាស់ដឹងរបស់ព្រះអរហន្តសម្មា-សម្ពុទ្ធជាម្ចាស់មានអន្តរាយច្រើន ព្រោះឱកាសដែលយល់ខុស និយាយខុស បដិបត្តិខុស ។ ព្រះត្រៃបិដក ប្រៀបដូចជារដ្ឋធម្មនុញ្ញ ច្បាប់ទូទៅនឹងជំទាស់ ដល់ច្បាប់រដ្ឋធម្មនុញ្ញមិនបាន យ៉ាងណា ការអធិប្បាយធម៌ជំទាស់នឹងព្រះត្រៃបិដក ពុទ្ធសាសនិកជនដែលល្អប្រកាន់ថាធ្វើមិនបានដូចគ្នា ដូច្នោះ ។

សូមអានុភាពនៃព្រះរតនត្រ័យ ប្រតិស្ឋានក្នុងហឫទ័យ
របស់ពុទ្ធសាសនិកជនទាំងឡាយ សូមបានជួបប្រសព្វ
សេចក្ដីចម្រើនក្នុងព្រះធម៌ ដែលព្រះមានព្រះភាគទ្រង់
ប្រកាសទុកល្អហើយបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ។

ក្រុមរៀបរៀងព្រះអដ្ឋកថា

# និទានកថា

សេចក្ដីសង្ខេបថា ក្នុងទីបំផុតនៃការសម្ដែងយមកបាដិហារ្យ ព្រះមានព្រះភាគជាម្ចាស់ ស្ដេចចូលចាំវស្សានៅលើផ្ទាំងបណ្ឌុកម្ពលសិលាសនៈ ក្រោមដើមបារិច្ឆត្តកព្រឹក្សក្នុងទេវនគរ ទ្រង់ធ្វើព្រះមាតាឲ្យជាអង្គសាក្សី ត្រាស់ព្រះអភិធម្មកថាដល់ទេវបរិស័ទ លុះទ្រង់សម្ដែងបករណ៍ធម្មសង្គណី បាន ១០០ ឆ្នាំកន្លងទៅ ពួកភិក្ខុវជ្ជីបុត្រសម្ដែងវត្ថុ ១០ ប្រការ ដែលប្រាសចាកព្រះធម៌-វិន័យ គឺ ៖

១ ភិក្ខុទុកដាក់អំបិលក្នុងក្អក់សម្រាប់ឆាន់ជាមួយអាហារថា គួរ ។

២ ភិក្ខុឆាន់អាហារពេលព្រះអាទិត្យជ្រេទៅ ២ ធ្នាប់ គួរ ។

៣ ភិក្ខុហាមភត្តហើយ ចូលទៅក្នុងចន្លោះស្រុក ហើយឆាន់ភត្តដែលមិនបានធ្វើវិនយកម្មមុន ឬ មិនជាដែនរបស់ភិក្ខុឈឺ គួរ ។

៤ ភិក្ខុនៅក្នុងអាវាសជាមួយគ្នា បំបែកគ្នាធ្វើសង្ឃកម្ម គួរ ។

៥ ភិក្ខុធ្វើឧបោសថកម្មមិនរង់ចាំឆន្ទានុមតិ គួរ ។

៦ ប្រការបដិបត្តិដែលឧបជ្ឈាយ៍ អាចារ្យធ្លាប់ប្រព្រឹត្តមកខុសត្រូវ យ៉ាងណាប្រព្រឹត្តតាម គួរ ។

៧ ភិក្ខុហាមភត្តហើយ ឆាន់ទឹកដោះស្រស់ដែលមិនទាន់ប្រែជាទឹកដោះជូរ គួរ ។

៨ ភិក្ខុផឹកស្រាខ្សោយ ៗ គួរ ។

៩ ភិក្ខុក្រាលសំពត់និសីទនៈដែលមិនមានជាយ គួរ ។

១០ ភិក្ខុទទួល ឬត្រេកអរចំពោះមាស និងប្រាក់ ដែលគេទុកដាក់ដើម្បីខ្លួន គួរ ។

ព្រះយសត្ថេរដែលជាបុត្ររបស់ព្រាហ្មណ៍ ឈ្មោះថា កាកណ្ឌកៈ បានស្ដាប់វត្ថុ ១០ ប្រការនោះហើយបានកាន់យកព្រះចៅអសោករាជដែលជា ព្រះឱរសរបស់ ព្រះចៅសុសុនាគៈធ្វើជាសម្ចាញ់ ហើយជ្រើសរើសព្រះថេរៈ ៧០០ អង្គក្នុងចំណោម ភិក្ខុ ១.២០០.០០០ អង្គ គឺ ( ដប់ពីរសែន ) ញុំាញីវត្ថុ ១០ប្រការទាំងនោះ ហើយលើកសរីរៈ គឺ ព្រះធម៌វិន័យឡើងសង្គាយនា ។

ភិក្ខុវជ្ជីបុត្រមានប្រមាណ ១០.០០០ អង្គ ត្រូវព្រះធម្មសង្គាហកត្ថេរទាំងឡាយគ្របសង្កត់ហើយ គឺ ទិតៀនហើយ ទើបស្វែងរកពួកគណៈ គ្រាបានពួកដែលជាទុព្វលវៈដ៏សមគួរដល់ខ្លួន ក៏ចាត់តាំងសម្នាក់ត្រកូលអាចារ្យថ្មី ឈ្មោះថា មហាសង្ឃិកៈ និងឯកព្យោហារិកៈ ដែលបែកចេញមកពីត្រកូលអាចារ្យសង្ឃិកៈនោះ ។ ត្រកូលអាចារ្យពីរពួកដទៃទៀត គឺ បញ្ញត្តិវាទៈ និងពហុលិយៈ ដែលមានឈ្មោះម្យ៉ាងទៀតថា ពហុស្សុតិកៈ ដែលបែកចេញមកពីនិកាយគោកុលិកៈ ។ អាចរិយវាទដទៃទៀតឈ្មោះថា ចេតិយវាទ កើតឡើងហើយក្នុងរវាងនិកាយពហុលិយៈនោះ នោះឯង ។ ក្នុងរយៈនៃឆ្នាំទីពីរ គឺ ក្នុងព្រះពុទ្ធសករាជ ២០០ ត្រកូលអាចារ្យទាំងប្រាំ បានកើតឡើងពីត្រកូលអាចារ្យមហាសង្ឃិកៈដោយប្រការដូច្នេះ ។

ត្រកូលអាចារ្យទាំងប្រាំនោះ រួមជាមួយមហាសង្ឃិកៈដើមមួយ ក៏បាន

បានជាប្រាំមួយត្រកូល ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ អាចរិយវាទទាំងពីរ គឺ មហិសាសកៈ និងវជ្ជីបុត្តកៈកើតឡើង ដែលបែកចេញមកពីថេរវាទ ។ ក្នុងបណ្តាអាចរិយវាទទាំងពីរនោះ អាចរិយវាទទាំងបួន គឺ ធម្មុត្តរិយៈ ១ ភទ្រយានិកៈ ១ ឆន្នាគារិកៈ ១ សម្មិតិយៈ ១ កើតឡើង ព្រោះបែកចេញមកពីនិកាយវជ្ជីបុត្តកៈ ។ ក្នុងពុទ្ធសករាជ ២០០ ឆ្នាំ នោះឯង អាចរិយវាទពីរពួក គឺ សព្វត្ថិកវាទ និងធម្មគុត្តិកៈកើតឡើង ព្រោះការបែកចេញពីត្រកូលអាចារ្យមហិសាសកៈទៀត ។ កាលនិកាយកស្សបិកៈទាំងឡាយបែកគ្នាហើយ ក៏ជាហេតុឲ្យនិកាយឈ្មោះថា សង្កន្តិកៈផ្សេងទៀតកើតឡើង កាលនិកាយ-សង្កន្តិកៈទាំងឡាយបែកគ្នាហើយ និកាយឈ្មោះថា សុត្តវាទក៏កើតឡើង ។ អាចរិយវាទ ១១ និកាយនេះ កើតឡើងហើយ ព្រោះបែកចេញមកពីថេរវាទយ៉ាងនេះ ដោយប្រការដូច្នេះ ។ អាចរិយវាទ ១១ និកាយនេះ រួមនឹងថេរវាទដើមក៏ជា ១២ និកាយ ។

ក្នុងពុទ្ធសករាជ ២០០ អាចរិយវាទ គឺ លទ្ធិនៃអាចារ្យទាំងអស់ រួម ១៨ និកាយ គឺ ១២ និកាយបែកចេញអំពីថេរវាទនេះ និងនិកាយអាចរិយវាទ ៦ បែកចេញមកពីត្រកូលអាចារ្យមហាសង្ឃិកៈទាំងឡាយ ដូច្នេះឯង ។

ពាក្យថា និកាយ ១៨ ក្តី ត្រកូលអាចារ្យ ១៨ ក្តី ជាឈ្មោះរបស់និកាយ ដែលពោលមកហើយទាំងនោះឯង ។ ម្យ៉ាងទៀត បណ្តានិកាយទាំង ១៨ នោះ បណ្ឌិតគប្បីជ្រាបថា ជានិកាយដែលបែកចេញពីគ្នា , ចំណែកថេរវាទបណ្ឌិតគប្បីជ្រាបថា ជានិកាយដែលមិនបែកគ្នា គឺ តាំងនៅដូចដើម ។

# តារាងសម្ដែងនិកាយសង្ឃក្នុងសតវត្ស ទី ៣




ភិក្ខុដ៏លាមកទាំងឡាយ ដែលជាពួកវជ្ជីបុត្តជាអធម្មវាទី ត្រូវព្រះថេរៈជាធម្មវាទីទាំងឡាយបានបណ្ដេញចេញហើយ បានពួកដទៃទៀត ទើបផ្ដើមតាំងជាគណាចារ្យថ្មី ៗ

( ស្រង់ចេញពីអដ្ឋកថា បរមត្ថទីបនី អដ្ឋកថាអភិធម្មបិដក កថាវត្ថុ )

# ប្រវត្តិអ្នកតែងព្រះអដ្ឋកថា

ព្រះពុទ្ធឃោសត្ថេរ ដែលយើងនិយមហៅថា **ព្រះពុទ្ធឃោសាចារ្យ** បានប្រាប់ទុកខាងក្រោយនៃអារម្ភកថា ព្រះគម្ពីរអដ្ឋកថាអដ្ឋសាលិនីថា ព្រះភិក្ខុមាននាមថា ពុទ្ធឃោសៈដូចគ្នា បានអារាធនាលោកឲ្យតែងព្រះគម្ពីរនេះឡើង ( គម្ពីរអដ្ឋសាលិនី ) ។ ទាំងនេះឃើញថា នាមព្រះពុទ្ធឃោសៈមានច្រើន ដូចក្នុងសម័យនោះ ក៏នៅមានព្រះពុទ្ធឃោសៈអារាធនាឲ្យព្រះ ពុទ្ធឃោសៈតែងគម្ពីរនេះជាដើម ។

កិត្តិសព្ទរបស់ព្រះពុទ្ធឃោសៈ ជាមង្គលដ៏អង្វែង ព្រោះលោកបានធ្វើការកសាងព្រះគម្ពីរទុកយ៉ាងច្រើនសន្ធឹកសន្ធាប់ ។ ព្រះពុទ្ធាឃោសាចារ្យជាអ្នកស្រុកជម្ពូទ្វីប គឺ ប្រទេសឥណ្ឌាប៉ែកខាងត្បូង មានជីវិតរស់នៅក្នុងរវាងពុទ្ធសករាជ ៩៤៥ ដល់ ១.០០០ ឆ្នាំ កើតក្នុងត្រកូលព្រាហ្មណ៍នាតំបន់ពុទ្ធគយាដែនមគធៈ ជិតស្ថានទីត្រាស់ដឹង ។ មុនចូលមកបួសក្នុងព្រះពុទ្ធសាសនា បានសិក្សាសិល្ប៍សាស្ត្រទាំងពួង រៀនចប់ត្រៃវេទ បានត្រាច់ទៅកាន់ទីផ្សេង ៗ ក្នុងជម្ពូទ្វីប បានឆ្លើយបញ្ហាជាមួយសមណៈ និងព្រាហ្មណ៍ទាំងឡាយ ប្រាកដជាអ្នមានសតិបញ្ញាច្រើន ។ សមណព្រាហ្មណ៍ និងបណ្ឌិតដទៃ ៗ មិនអាចឆ្លើយដោះស្រាយបញ្ហាព្រាហ្មណ៍កំលោះនេះបាន ។ តែព្រាហ្មណ៍កំលោះនេះ អាចដោះស្រាយបញ្ហាដែលសមណព្រាហ្មណ៍ និង

បណ្ឌិតសួរបាន ដូច្នោះ ព្រាហ្មណ៍កំលោះ ទើបមានឈ្មោះបោះសំឡេងខ្ទរខ្ទារ គ្របសង្កត់រហូតសកលជម្ពូទ្វីប ។

គ្រាមួយ ព្រាហ្មណ៍កំលោះដើរផ្លូវ មកដល់វត្តមួយដែលជាស្ថានទី ពុទ្ធគយា បានជួបជាមួយព្រះរេវតត្ថេរ ដែលជាព្រះមហាខីណាស្រពសម្រេច បដិសម្ភិទា ៤ ។

ថ្ងៃមួយព្រាហ្មណ៍កំលោះ បានស្វាធ្យាយមន្តក្នុងគម្ពីរបតញ្ជលី យ៉ាង ត្រឹមត្រូវ ពីរោះគួរចាប់ចិត្តរហូតដល់យប់ ព្រះថេរៈបានឮសំឡេងព្រាហ្មណ៍ នោះស្វាធ្យាយហើយ ក៏ដឹងថាជាអ្នកមានសតិបញ្ញាច្រើន ទើបហៅព្រាហ្មណ៍ នោះមកដើម្បីបានសន្ទនាគ្នា ព្រាហ្មណ៍កំលោះបានសួរបញ្ហាផ្សេង ៗ ក្នុងគម្ពីរ ត្រៃវេទដែលខ្លួននៅមានការសង្ស័យមិនយល់ ចំពោះព្រះថេរៈ ព្រះថេរៈក៏ឆ្លើយ អធិប្បាយបានទាំងអស់ ក្រោយមកព្រះថេរៈទើបសួរបញ្ហាក្នុងព្រះអភិធម្មខ្លះ ៗ ព្រាហ្មណ៍កំលោះ ឆ្លើយមិនបាន ទើបសួរថា នេះឈ្មោះថាអ្វី ព្រះថេរៈឆ្លើយថា ឈ្មោះថា **ពុទ្ធមន្ត** ទើបសូមរៀនពុទ្ធមន្ត ហើយក៏បានបព្វជ្ជាឧបសម្បទាក្នុង ព្រះពុទ្ធសាសនា បានរៀនព្រះពុទ្ធវចនៈ គឺ ព្រះត្រៃបិដក បានប្រាកដឈ្មោះថា ព្រះពុទ្ធឃោសៈ ។

កាលព្រះពុទ្ធឃោសៈ គង់នៅក្នុងវត្ត នាតំបន់ពុទ្ធគយានោះ បានរចនា បករណ៍ឈ្មោះ **ញាណោទ័យ** ទុកក្នុងវត្ត ហើយផ្តើមរចនាគម្ពីរអដ្ឋកថា ឈ្មោះ អដ្ឋសាលិនី ដែលជាអដ្ឋកថាព្រះគម្ពីរធម្មសង្គណីបករណ៍ និងគម្ពីរបរិត្តដ្ឋកថា គឺ អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ព្រះរេវតមហាថេរៈ បានឃើញអដ្ឋកថា

ដែលលោកបានរចនាហើយ ទើបណែនាំលោកថា ក្នុងជម្ពូទ្វីបមានតែព្រះបាលីព្រះត្រៃបិដកប៉ុណ្ណោះ មិនមានអដ្ឋកថាបាលីព្រះត្រៃបិដកនៅឡើយ តែក្នុងលង្កាទ្វីបនៅមាន ដោយព្រះថេរៈទាំងឡាយមានព្រះ សារីបុត្ត (ឈ្មោះដូចអគ្គសាវក) ជាដើម បានរចនាទុក និងតមកព្រះមហិន្ទត្ថេរៈបានត្រួតពិនិត្យ ហើយរចនាទុកជាភាសាសីហឡៈ សូមឲ្យព្រះពុទ្ធឃោសៈទៅលង្កាទ្វីប ត្រួតពិនិត្យមើលអដ្ឋកថាទាំងនេះ ហើយប្រែមកជាភាសាមគធៈវិញ នឹងបានជាប្រយោជន៍ និងសេចក្ដីចម្រើនដល់មនុស្សលោកទាំងពួង កាលព្រះថេរៈបានណែនាំយ៉ាងនេះហើយ ព្រះពុទ្ធឃោសៈ ក៏មានបីតិសោមនស្ស ក្រាបបង្គំលាព្រះឧបជ្ឈាយ៍ និងព្រះភិក្ខុសង្ឃ ហើយធ្វើដំណើរទៅកាន់លង្កាទ្វីបតាមទូក បានជួបព្រះពុទ្ធទត្តត្ថេរៈ ដែលបាននិមន្តជួសផ្លូវគ្នានៅកណ្ដាលសមុទ្រ បានសន្ទនាគ្នា និងប្រាស្រ័យទាក់ទងរឿងប្រែគម្ពីរជាភាសាមគធៈ ហើយធ្វើដំណើរតទៅរហូតដល់កំពង់ផែក្រុងលង្កា សម័យនោះ គឺ ជាកាលរបស់ក្សត្រលង្កាទ្រង់ព្រះនាមថា មហានាម មាននាមដទៃទៀតថា ( សិរិនិវាស ) ខ្វះ ( សិរិកុថៈ ) ខ្វះ ( សិរិកូដ្ឋៈ ) ខ្វះ ពុទ្ធសករាជ ( ៩៥២-៩៧៤ ) ។

កាលដែលព្រះពុទ្ធឃោសៈទៅដល់លង្កា បានទៅជួបព្រះភិក្ខុសង្ឃក្នុងមហាវិហារនាក្រុងអនុរាធបុរៈ ហើយបានទៅកាន់សម្នាក់របស់ព្រះសង្ឃបាលត្ថេរៈ ដែលជាព្រះសង្ឃរាជនៅក្នុងក្រុងអនុរាធបុរៈ នៃសម្នាក់មហាបធាន បានស្ដាប់អដ្ឋកថាជាភាសាសីហឡៈ និងថេរវាទទាំងអស់ហើយ បានធ្វើទុកក្នុងចិត្តថា ជាពុទ្ធាធិប្បាយរបស់ព្រះមានព្រះភាគពិត ទើបបានសុំការអនុមតិ អំពីសង្ឃ

ដើម្បីបានឱកាសរចនា អដ្ឋកថាព្រះត្រៃបិដក ជាភាសាមគធៈ ។ ដើម្បីផ្ទៀងផ្ទាត់ការចេះដឹង និងសមត្ថភាពរបស់ព្រះពុទ្ធឃោសៈ គណៈសង្ឃលង្កា ដែលមានព្រះសង្ឃបាលត្ថេរៈជាប្រធាន បានប្រគល់ព្រះគាថា ២ ព្រះគាថាឲ្យលោករចនាសិន ទើបអនុញ្ញាតឲ្យលោកត្រួតពិនិត្យគម្ពីរទាំងអស់ ។ ព្រះពុទ្ធឃោសៈបានរចនាបករណ៍ឈ្មោះ វិសុទ្ធិមគ្គឡើង មានសេចក្តីយ៉ាងល្អប្រសើរ រហូតដល់ព្រះសង្ឃលង្កាទទួលស្គាល់នូវសេចក្តីជំនាញរបស់លោក តាមប្រវត្តិបាននិយាយថា ដើម្បីនឹងប្រកាសនូវភាពជំនាញរបស់ព្រះពុទ្ធឃោសៈនោះឲ្យប្រាកដ ទេវតាបានបណ្តាលឲ្យគម្ពីរដែលរចនាស្រេចហើយ បាត់ទៅ ព្រះពុទ្ធឃោសៈក៏បានរចនាជាថ្មីម្តងទៀត ទេវតាក៏បណ្តាលឲ្យបាត់ទៀត លោកក៏បានរចនាឡើងម្តងទៀតគម្រប់ ៣ ដង បន្ទាប់មក ក៏ថ្វាយគម្ពីរដែលបានរចនាទាំងពីរគម្ពីរនោះវិញវេលានោះ ទើបបានគម្ពីរវិសុទ្ធិមគ្គ ជា ៣ ចប់ ព្រះពុទ្ធឃោសៈក៏បាននាំគម្ពីរទាំង ៣ ចប់នោះ ថ្វាយដល់ព្រះភិក្ខុសង្ឃ ព្រះភិក្ខុសង្ឃបានអានទាំងបីគម្ពីរប្រៀបធៀបគ្នាហើយ មិនមានការខុសគ្នាទាំងដោយព្រះគម្ពីរ ឬអក្ខរៈ ឬដោយបទ ឬដោយព្យញ្ជនៈ ឬដោយអត្ថ ឬដោយបទដើម បទចុងឬ ដោយថេរវាទ ឬដោយព្រះបាលី ទាំងឡាយក្នុងកន្លែងណាទីមួយឡើយ ទាំងបីច្បាប់ដូចគ្នា ដើម្បីសម្តែងសេចក្តីអង់អាចយ៉ាងក្រៃលែងរបស់លោក ទេវតាទាំងឡាយបានសាធុការ ព្រះសង្ឃប្រមាណ ១.០០០ អង្គ ប្រជុំគ្នាក្នុងមហាវិហារបានឃើញសេចក្តីអស្ចារ្យ នាំគ្នាត្រេកអរ កោតសរសើរ សោមនស្ស សាធុការ បានប្រកាសថា លោកអង្គនេះជាព្រះមេត្តេយ្យពោធិសត្វ ពិតប្រាកដ និងបានអនុមតិ

ឲ្យលោកប្រែគម្ពីរ ពីភាសាសីហឡ:មកជាភាសាមគធ: ។

ក្នុងគ្រានោះ ព្រះចៅមហានាមក្សត្រនៃលង្កា ទ្រង់បានស្ដាប់កិត្តិគុណរបស់លោក ស្ដេចបានចេញចាកពីព្រះនគរទៅដល់មហាវិហារ ទ្រង់នមស្ការព្រះសង្ឃហើយនមស្ការព្រះពុទ្ធឃោស:និមន្តឲ្យគង់នៅក្នុងប្រាសាទមួយ ឈ្មោះ **បធានឃរ** នាទិសទក្សិណរបស់មហាវិហារ បានប្រែអដ្ឋកថាភាសាសីហឡ:ជាអដ្ឋកថាព្រះត្រៃបិដកភាសាមគធ: ។

អដ្ឋកថាក្នុងភាសាសីហឡ:ពីបុរាណនោះមាន ៣ យ៉ាង គឺ ៖

១ មហាអដ្ឋកថា

២ បច្ចរិយអដ្ឋកថា

៣ កុរុន្ទីអដ្ឋកថា អដ្ឋកថាដែលបានលើកឡើងកាន់សង្គាយនា

ព្រះមហិន្ទត្ថេរ:នាំមកពីជម្ពូទ្វីប ហើយរចនាទុកជាភាសាសីហឡ:ឈ្មោះ **មហាអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុទាំងឡាយប្រជុំគ្នារចនានៅក្នុងផែ ( ផ្ទះទឹក ) ដែលក្នុងភាសាសីហឡ:ហៅថា បច្ចរិយ: ឈ្មោះថា **បច្ចរិយអដ្ឋកថា** ។

អដ្ឋកថា ដែលព្រះភិក្ខុសង្ឃទាំងឡាយប្រជុំគ្នារចនា ក្នុងកុរុន្ទវេឡុវិហារ ឈ្មោះថា **កុរុន្ទីអដ្ឋកថា** ។

វាទ:ដែលអាចារ្យទាំងឡាយក្នុងកាលមុន មានព្រះអាចារ្យថ្នាក់ព្រះថេរ:ជាដើម បានរចនាទុកដោយកាន់យកន័យព្រះបាលីឈ្មោះថា **ថេរវាទ** ។

គម្ពីរអដ្ឋកថាភាសាសីហឡ: ដែលព្រះពុទ្ធឃោស:បានប្រែមកជាអដ្ឋ-

កថាព្រះត្រៃបិដកជាភាសាមគធៈ  មានច្រើនជាងពាក់កណ្ដាលនៃគម្ពីរអដ្ឋកថាទាំងអស់ មានរាយនាមព្រះគម្ពីរដូច្នេះ ៖

១ សមន្តបា្បសាទិកា អដ្ឋកថាព្រះវិន័យបិដក

២ កង្ខាវិតរណី ឬមាតិកដ្ឋកថា អដ្ឋកថាព្រះបាតិមោក្ខ

៣ សុមង្គលវិលាសនី អដ្ឋកថាទីឃនិកាយ

៤ បបញ្ចសូទនី អដ្ឋកថាមជ្ឈិមនិកាយ

៥ សារត្ថប្បកាសិនី អដ្ឋកថាសំយុត្តនិកាយ

៦ មនោរថបូរណី អដ្ឋកថាអង្គុត្តរនិកាយ

៧ បរមត្ថជោតិកា អដ្ឋកថាខុទ្ទកបាឋៈ និងសុត្តនិបាត

៨ ធម្មបទដ្ឋកថា អដ្ឋកថាធម្មបទ

៩ ជាតកដ្ឋកថា អដ្ឋកថាជាតក

១០ អដ្ឋសាលិនី អដ្ឋកថាធម្មសង្គណីបករណ៍

១១ សម្មោហវិនោទនី អដ្ឋកថាវិភង្គបករណ៍

១២ បញ្ចករណដ្ឋកថា ឈ្មោះបរមត្ថទីបនី ជាព្រះអដ្ឋកថាព្រះអភិធម្មទាំងប្រាំគម្ពីរ គឺ ធាតុកថា កថាវត្ថុ បុគ្គលប្បញ្ញត្តិ យមក និងបដ្ឋាន ។

១៣ វិសុទ្ធិមគ្គ បករណ៍វិសេសពោលដោយ សីល សមាធិ បញ្ញា ។

១៤ ញាណោទ័យ តែងមុនកាលទៅឥណ្ឌា ច្បាប់ដើមអន្តរធានហើយ ។

១៥ បរិត្តដ្ឋកថា អដ្ឋកថាព្រះត្រៃបិដកច្បាប់សង្ខេប ច្បាប់ដើមអន្តរធានហើយ ។

ព្រះគម្ពីរទាំងនេះ បានជាប្រយោជន៍ដ៏ក្រៃលែង ចំពោះមនុស្សក្នុងប្រទេសផ្សេង ៗ លោកពោលទុកថា គម្ពីរទាំងអស់ប្រើពេលវេលាត្រឹមតែ ១ ឆ្នាំ ក៏បានសម្រេច បានកើតសេចក្តីអស្ចារ្យ សូម្បីផែនដីក៏កម្រើកញាប់ញ័រ ។

លទ្ធផលការងារ វណ្ណកម្មរបស់ព្រះពុទ្ធឃោសៈ អ្នកសិក្សាភាសាបាលីទូទៅ បានសរសើរ និងរាប់អានលោកថា ជាបោរាណាចារ្យយ៉ាងសំខាន់ក្រៃ-លែងរបស់លោក ។

# រាយនាមលោកអ្នកមានឧបការៈ

លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

លោកគ្រូធម្មបណ្ឌិត រស់ សុផាត

ឧបាសក ក្អាត ហ៊ាន

ឧបាសក ទុំ ទូន

ឧបាសក ជឹម ជំនិត

ឧបាសក សន ម៉ារឌី

ឧបាសក អ៊ឹម រ៉ៃយ៉ា

ឧបាសក សំ ឆាយ

ឧបាសិកា ហាយ សារ៉ាត់

ឧបាសិកា យស សម្បត្តិ

ឧបាសក នាក់ ម៉ៅ

ឧបាសក ហុក សឹងហួត

ឧបាសក កើត ទិត្យ

ឧបាសក ហាយ ចំរើន

ឧបាសក សុក្រ ហ៊ត

ឧបាសិកា ថាប់ លឿម

ឧបាសិកា ប៊ុត សុម៉ាលី

ឧបាសិកា ពូ ហ៊ាង

ព្រមទាំងពុទ្ធបរិស័ទក្នុង និងក្រៅប្រទេស

# រាយនាមអ្នកប្រែសម្រួល

## ព្រះសង្ឃអាស្រមព្រះគន្ធកុដិ

ព្រះភិក្ខុអគ្គទិន្នោ នូវ ប៊ូរ៉ា ប្រធានអាស្រម

ព្រះភិក្ខុចិត្តរក្ខិតោ សំ សម្បត្តិ ធម្មាចារ្យ

ព្រះភិក្ខុវរធម្មោ ផុត តៅ ធម្មាចារ្យ

ព្រះភិក្ខុសារញ្ញាណោ ស សត្ថា ធម្មាចារ្យ

ព្រះភិក្ខុកល្យាណធម្មោ យឿន កល្យាណ វិនយាចារ្យ

ព្រះភិក្ខុយន្តទិន្នោ ផល សុភ័ណ សមណសិស្ស សាលាសតិប្បដ្ឋាន

ព្រះភិក្ខុបវរធម្មោ អ៊ុល សុធា សមណសិស្ស សាលាសតិប្បដ្ឋាន

សាមណេរ អគ្គកាមោ អ៊ឹម សុជាន សមណសិស្ស សាលាសតិប្បដ្ឋាន

សាមណេរ កោវិនោ ឡោះ សូវៀត សមណសិស្ស សាលាសតិប្បដ្ឋាន

សាមណេរ កោវិនោ ចាន់ បូណា សមណសិស្ស សាលាសតិប្បដ្ឋាន

## ផ្នែកឧបាសក

ឧបាសក ក្លាត ហ៊ន ឧបាសក ហាយ ចំរើន

ឧបាសក សន ម៉ារឌី ឧបាសក អ៊ឹម រ៉ៃយ៉ា

ឧបាសក ទុំ ទូន ឧបាសក ហុក សីងហួត

# បត្តិទានកថា

ការរៀបរៀង ប្រែសម្រួលអដ្ឋកថាព្រះត្រៃបិដកជាខេមរភាសា ដើម្បីបូជាចំពោះព្រះរតនត្រៃ ម្យ៉ាងទៀតដើម្បីតម្កល់ទុកជាសម្បត្តិវប្បធម៌ជាតិ និងជាចំណែកចូលរួមក្នុងការតាំងនៅនៃព្រះសទ្ធម្មគម្រប់ ៥.០០០ ព្រះវស្សា ។

យើងខ្ញុំជាក្រុមប្រែសម្រួលអដ្ឋកថា សូមលើកនូវបុណ្យកុសលដែលកើតឡើងអំពីការងារនេះ ៖-

ឧទ្ទិសថ្វាយ និងគោរពជូន:

-ព្រះមហាវីរក្សត្រ និងមហាវីរក្សត្រិយានី

-ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

-សម្តេចព្រះសង្ឃរាជទាំងពីរគណៈ

-មាតាបិតានៃយើងខ្ញុំទាំងអស់គ្នា

-លោកគ្រូអគ្គបណ្ឌិតធម្មាចារ្យ ប៊ុត សាវង្ស

-លោកគ្រូធម្មបណ្ឌិត រស់ សុផាត

-សព្វមុខមន្រ្តីរាជការ និងប្រជានុរាស្រ្តនៃកម្ពុជរដ្ឋ

-សព្វសត្វទាំងអស់ក្នុងត្រ័យភព

សូមលោកត្រេកអរ អនុមោទនានូវចំណែកបុណ្យនេះបានស្មើ ៗ គ្នា

សូមអនុមោទនា !.....

ក្រុមរៀបរៀង និងប្រែសម្រួល

# មាតិកាធម៌

ឈ្មោះធម៌ | ទំព័រ


## អដ្ឋកថា មហាបទានសូត្រ ទី១

មហាបទាន ១

ពណ៌នា ការកំណត់អាយុ ១៤

ពណ៌នា ការកំណត់ដើមពោធិព្រឹក្ស ១៩

ពណ៌នា ការកំណត់គូសាវក ២២

ពណ៌នា ការប្រជុំសាវក ២៥

ពណ៌នា ការកំណត់ឧបដ្ឋាក ២៧

ពណ៌នា បុគ្គល និងវត្ថុ ៤០

ពណ៌នា លក្ខណៈ ៣២ ប្រការ ៧៤

ពណ៌នា ប្រវត្តិព្រះវិបស្សីកុមារ ៩៤

ការទតឃើញ បុរសចាស់ ១០១

ការទតឃើញ បុរសឈឺ ១០៣

ការទតឃើញ បុរសស្លាប់ ១០៣

ការទតឃើញ បព្វជិត ១០៥

ពណ៌នា អភិសម្ពោធិ ១១០

ភាណវារៈ ទី ៣ ១២០

ពណ៌នា ពុទ្ធកិច្ច ១៣៧

ពណ៌នាបព្វជ្ជាឧបសម្បទារបស់ពួកមហាជន ១៤៤

ពុទ្ធានុញ្ញាត ការចារិករបស់ភិក្ខុ ១៤៤

## អដ្ឋកថា មហានិទានសូត្រ ទី ២

ពណ៌នា សុត្តនិទាន ១៥៧

ពោលអំពី ហេតុបច្ច័យនៃអកុសលធម៌ ១៩៤
ពោលអំពី ហេតុបច្ច័យនៃធម៌ទាំងឡាយ........ ១៩៧
ពោលអំពី ហេតុបច្ច័យនៃវេទនា....... ១៩៧
ពោលអំពី ការបញ្ញត្តិខ្លួន ២០៥
ពោលអំពី ការមិនបញ្ញត្តិខ្លួន ២០៨
ពោលអំពី ការពិចារណាខ្លួន ២០៩
ពោលអំពី ការមិនពិចារណានូវវេទនាថាខ្លួន ២១៤
ពោលអំពី វិញ្ញាណដ្ឋិតិទាំង ៧ ២១៦
ពោលអំពី វិមោក្ខ ៨ ២១៤

## អដ្ឋកថា មហាបរិនិព្វានសូត្រ ទី ៣

និទានរឿង ២៣១
អបរិហានីយធម៌ ៧ របស់ពួកវជ្ជីក្សត្រ ២៣៣
ទ្រង់ឲ្យប្រជុំភិក្ខុទាំងឡាយ ២៤៨
អបហានីយធម៌ ៧ របស់ភិក្ខុ ២៥០
អបហានីយធម៌ ៦ របស់ភិក្ខុ ២៦៤
សារាណិយធម៌បែក ២៦៨
សារាណិយធម៌ពេញ ២៧០
ព្រះមានព្រះភាគស្តេចយាងកាន់អម្ពលដ្ឋិកាឧទ្យាន ២៧៧
ពោលអំពី ការសាកសួរពុទ្ធគុណ ២៧៨
ពោលអំពី ការសាងក្រុងក្នុងបាដលិគ្រាម ២៨២
រឿងសុនីតៈ និងវស្សាការព្រាហ្មណ៍ ២៨៥
អនុមោទនាកថា ២៨៦
ទ្រង់សម្តែងចតុរារិយសច្ច ២៨៩
ពោលអំពី ផ្លូវទៅកាន់នាទិកគ្រាម ២៩០

ទ្រង់សម្ដែងធម្មបរិយាយឈ្មោះ ធម្មាទាស: ២៩២
ទ្រង់សម្ដែងសតិប្បដ្ឋាន ៤ ២៩៤
ព្រះមានព្រះភាគទ្រង់មានអាពាធខ្លាំងក្លា ២៩៧
ពោលអំពី អគ្គសាវកនិព្វាន ៣០៤
ការអារាធនារបស់មារឲ្យព្រះសាស្ដាបរិនិព្វាន ៣១៧
ទ្រង់ដាក់អាយុសង្ខារ ៣២០
ពោលអំពី ហេតុកក្រើកផែនដី ៣២៣
ពោលអំពី បរិសទ្យ ៨ ពួក ៣២៧
ពោលអំពី អភិភាយតនៈ ៨ ៣៣០
ពោលអំពី វិមោក្ខ ៨ ៣៣៥
ទ្រង់ទតក្រុងវេសាលីជាបច្ឆិមទស្សនៈ ៣៣៨
ពោលអំពី មហាបទេសទាំង ៤ ៣៣៩
រឿងនាយចុន្ទកម្មារបុត្ត ៣៤៦
ការសម្ដែងជាឧបាសកនៃបុក្កុសមល្លបុត្រ ៣៤៨
ពោលអំពី សាលៈទាំងគូ ៣៥៨
រឿងឧបវាណភិក្ខុ ៣៧០
ពោលអំពី សំវេជនីយដ្ឋាន ៤ កន្លែង ៣៧៥
ពោលអំពី ការបដិបត្តិចំពោះមាតុគ្រាម ៣៧៨
ពោលអំពី ថូបារហបុគ្គល ៤ ពួក ៣៨០
ពោលអំពី គុណរបស់ព្រះអានន្ទ ៣៨១
ពោលអំពី រាជធានីឈ្មោះកុសាវតី ៣៨៦
រឿងសុភទ្ទបរិព្វាជក ៣៨៩
ព្រះបច្ឆិមវាចាព្រះមានព្រះភាគ ៤០១
ព្រះតថាគតសរសើរការបដិបត្តិ ៤០៦
រឿងព្រះមហាកស្សបត្ថេរ ៤១០

| | |
|---|---|
| រឿងព្រះបាទអជាតសត្តុជាដើម..... | ៤២៦ |
| ការចែកព្រះបរមធាតុរបស់ព្រះមានព្រះភាគ | ៤៣១ |
| ពុទ្ធសារីរិកគាថា | ៤៣៥ |

# អដ្ឋកថាឈ្មោះ សុមង្គលវិលាសិនី

# អដ្ឋកថា ទីឃនិកាយ

# នៃព្រះសុត្តន្តបិដក

# មហាវគ្គវណ្ណនា

# លេខ ១៦

## ១. មហាបទានសូត្រទី ១

[១] *មហាបទានសូត្រ មានបទផ្ដើមខាងដើមថា ៖*

***ខ្ញុំបានស្ដាប់មកហើយយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគទ្រង់ប្រថាប់នៅក្នុងករេរិកុដិ នាវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ក្នុងព្រះនគរសាវត្ថី*** ។

*តទៅនេះជាការពណ៌នាបទតាមលំដាប់ ក្នុងមហាបទានសូត្រនោះ បទថា* ***ក្នុងករេរិ*** *ក្នុងបទថា ករេរិកុដិកាយំ ជាឈ្មោះដើមថ្ងាន់ ករេរិមណ្ឌបតាំងនៅជិតទ្វារកុដិនោះ ព្រោះដូច្នោះ លោកទើបហៅថា* ***ករេរិកុដិ*** *ដូចលោកហៅថា កោសម្ពកុដិ ព្រោះមានដើមកោសម្ពៈ ( ដើមក្រចក*

ស្នាំង ) តាំងនៅជិតទ្វារ ។

ន័យថា ខាងក្នុងព្រះវិហារជេតពន មានកុដិធំ ៤ ខ្នង គឺ ករេរិកុដិ កោសម្ពកុដិ គន្ធកុដិ សឡលឃរៈកុដិ ( កុដិឈើស្រល់ ) ។ មួយខ្នង ៗ សម្រេចដោយការបរិច្ចាគទ្រព្យ ១ សែន ៗ ។ ទាំង ៤ ខ្នង នោះ ព្រះបាទបសេនទិទ្រង់សាងសឡលឃរៈកុដិ ដ៏សេសអនាថបិណ្ឌិកសេដ្ឋីជាអ្នកសាង ។ ព្រោះហេតុនេះ ព្រះមានព្រះភាគ ទើបប្រថាប់នៅក្នុងករេរិកុដិ ដែលអនាថបិណ្ឌិកគហបតីបានសាងទិព្វព្រឹក្ស ដូចទេវវិមាន តម្កល់ទុកលើសសរទាំងឡាយ ។

បទថា បច្ឆាភត្តំ សេចក្តីថា កាលភិក្ខុឆាន់អាហារដៃតែមួយ និងមិនមែនឆាន់ខាងក្រោយអាហារ ឆាន់ពីព្រឹកព្រលឹម សូម្បីឆាន់ខាងក្នុងថ្ងៃត្រង់ ក៏ឈ្មោះថា បច្ឆាភត្តដូចគ្នា ។ តែក្នុងទីនេះលោកបំណងយកបច្ឆាភត្តក្រោយអាហារតាមប្រក្រតី ។

បទថា បិណ្ឌបាតប្បដិក្កន្តានំ សេចក្តីថា កាលភិក្ខុត្រឡប់អំពីបិណ្ឌបាត ឆាន់អាហាររួចហើយក្រោកឡើង ។ បទថា ករេរិមណ្ឌលមាឡេ សេចក្តីថា ក្នុងសាលានោះ ដែលសាងទុកមិនឆ្ងាយពីករេរិមណ្ឌបនុ៎ះឯង ។

បានឮថា ករេរិមណ្ឌបនោះ នៅក្នុងចន្លោះព្រះគន្ធកុដិនិងសាលា ។ ព្រោះដូច្នោះ គន្ធកុដិខ្វះ ករេរិកុដិខ្វះ សាលាខ្វះ លោកហៅថា រោងករេរិមណ្ឌល ។

បទថា បុព្វេនិវាសបដិសំយុត្តា សេចក្តីថា ធម្មីកថាប្រកបដោយបុព្វេសន្និវាស ពោលគឺ ខន្ធសន្តាន ដែលអាស្រ័យនៅក្នុងជាតិមុន ចែកចេញយ៉ាងនេះ គឺ មួយជាតិខ្លះ ពីរជាតិខ្លះ ដែលប្រព្រឹត្តទៅហើយ ។ បទថា ធម្មី គឺ ប្រកបដោយធម៌ ។ បទថា ឧទបាទិ សេចក្តីថា បុព្វេនិវាសញ្ញាណរបស់ព្រះទសពល គួរអស្ចារ្យពិត ។ សួរថា ឈ្មោះថាបុព្វេនិវាសនរណារឭកបាន នរណារឭកមិនបាន ឆ្លើយថា តិរ្ថិយរឭកបាន ព្រះសាវក ព្រះបច្ចេកពុទ្ធរឭកបាន ។ តិរ្ថិយពួកណារឭកបាន ។ តិរ្ថិយពួកណាដល់ភាពជាអ្នកប្រសើរ ជាកម្មវាទី តិរ្ថិយសូម្បីទាំងនោះ ក៏រឭកបានរហូតដល់ត្រឹម ៤០ កប្បប៉ុណ្ណោះ ក្រៅលែងជាងនោះមិនបាន ។ ព្រះសាវករឭកបាន ១ សែនកប្ប ។ ព្រះអគ្គសាវកទាំងពីររឭកបាន ១ អសង្ខេយ្យ និង ១ សែនកប្ប ។ ព្រះបច្ចេកពុទ្ធ រឭកបានពីរអសង្ខេយ្យ និង ១ សែនកប្ប ។ តែព្រះពុទ្ធទាំងឡាយ មិនមានកំណត់ប៉ុណ្ណោះប៉ុណ្ណេះ ។ ព្រះពុទ្ធទាំងឡាយ ទ្រង់រឭកតាមដែលទ្រង់ប្រាថ្នា តិរ្ថិយទាំងឡាយរឭកបានតាមលំដាប់ខន្ធ ក៏ដល់ភាពជាអ្នកមិនមានសេចក្តីរឭកដឹង រមែងមិនឃើញការប្រព្រឹត្តទៅរបស់ខន្ធ ដូចសត្វធ្លាក់ចុះក្នុងក្រឡាសំណាញ់ និងអ្នកពិការធ្លាក់ចុះទៅក្នុងរណ្តៅ ។ គេទាំងនោះ ធ្លាក់ហើយក្នុងទីនោះ រមែងឃើញត្រឹមប៉ុណ្ណោះឯង ក្រៅលែងជាងនេះមិនមាន ។ ដោយហេតុនេះ ការរឭកដល់បុព្វេសន្និវាសរបស់ពួកតិរ្ថិយ ក៏ដូចជាអ្នកខ្វាក់ក្អែក ហើយដើរទៅដោយ

ចុងឈើប្រត់ ។ ធម្មតាអ្នកខ្វាក់ក្អែក កាលនៅមានអ្នកកាន់ចុងឈើប្រត់ រមែងដើរទៅបាន កាលមិនមាន ក៏អង្គុយនៅទីនោះឯង យ៉ាងណា ពួកតិរ្ថិយក៏ដូច្នោះដែរ រមែងរឭកបានតាមលំដាប់ខន្ធ វៀរលំដាប់ចេញហើយ រមែងមិនអាចរឭកបាន ។ សូម្បីព្រះសាវកទាំងឡាយ ក៏រឭកតាមលំដាប់ខន្ធបាន លុះដល់កាលជាអ្នកមិនមានការដឹងជ្រាលជ្រៅ រមែងមិនឃើញការប្រព្រឹត្តទៅរបស់ខន្ធ ។ សូម្បីដូច្នេះ ឈ្មោះថា កាលដែលមិនមាននៃខន្ធទាំងឡាយរបស់សត្វ ដែលអន្ទោលទៅកាន់វដ្តៈទាំងនោះ រមែងមិនមាន តែក្នុងអសញ្ញភព រមែងប្រព្រឹត្តទៅ ៥០០ កប្ប ព្រោះដូច្នោះ សត្វទាំងឡាយឈានកន្លងកាលប្រមាណប៉ុណ្ណេះ តាំងនៅក្នុងពាក្យទូន្មានដែលព្រះពុទ្ធទាំងឡាយទ្រង់ប្រទានហើយ រមែងរឭកដល់ខាងមុខបាន ដូចកិក្ខុសោភិតៈ ដូច្នោះ ។ មួយវិញទៀត ព្រះអគ្គសាវកទាំងពីរ និងព្រះបច្ចេកពុទ្ធទាំងឡាយ ពិចារណាមើលចុតិ និងបដិសន្ធិហើយ រមែងរឭកដល់បាន ។ កិច្ច គឺ ចុតិ និងបដិសន្ធិរបស់ព្រះពុទ្ធទាំងឡាយ រមែងមិនមាន ។ ព្រះពុទ្ធទាំងឡាយ មានព្រះបំណងទ្រង់ឃើញឋានៈណា ៗ រមែងទ្រង់ឃើញឋានៈនោះ ៗ តែម្តង ។ មួយទៀត តិរ្ថិយទាំងឡាយ កាលរឭកដល់បុព្វេសន្និវាសរមែងរឭកដល់វត្ថុដែលខ្លួនឃើញហើយ ឮហើយ ស្តាប់ហើយប៉ុណ្ណោះ ។ ព្រះសាវកទាំងឡាយ និងព្រះបច្ចេកពុទ្ធទាំងឡាយ ក៏ដូច្នោះ ។ តែព្រះពុទ្ធទាំងឡាយ ទ្រង់រឭកដល់វត្ថុទាំងអស់តែម្តង ដែលព្រះអង្គ ឬអ្នកដទៃឃើញ

ហើយ ធ្វើហើយ ស្តាប់ហើយ ។ បុព្វេនិវាសញ្ញាណរបស់ពួកតិរ្ថិយ៍ ដូចពន្លឺអំពិលអំពែក , របស់ព្រះសាវកទាំងឡាយ ដូចពន្លឺប្រទីប , របស់ព្រះអគ្គសាវក ដូចពន្លឺផ្កាយព្រឹក្ស , របស់ព្រះបច្ចេកពុទ្ធទាំងឡាយ ដូចពន្លឺព្រះចន្ទ , របស់ព្រះពុទ្ធទាំងឡាយ ដូចពន្លឺសុរិយមណ្ឌលពាន់ដួង ។ ព្រះពុទ្ធនោះ មិនកំណត់ប្រមាណប៉ុណ្ណេះថា រយជាតិ ពាន់ជាតិ សែនជាតិ ឬរយកប្ប ពាន់កប្ប សែនកប្ប កាលព្រះអង្គទ្រង់រឭកដល់វត្ថុណាមួយ រមែងមិនខុស រមែងមិនទើសទាក់ដោយពិត ការនឹកគិតតជាប់គ្នា រមែងតជាប់គ្នាតាមសេចក្តីប្រាថ្នា ការពិចារណា និងចិត្តុប្បាទទុំះឯង បុព្វេនិវាសញ្ញាណ រមែងស្ទុះទៅមិនទើសទាក់ ដូចកូនសរដែលស្ទុះទៅយ៉ាងឆាប់រហ័ស ក្នុងគំនរស្លឹកឈើដែលពុកផុយ និងដូចផ្គរវជិរៈដែលគប់ទៅលើកំពូលភ្នំសិនេរុ ។

បទថា អហោ មហន្តំ ភគវតោ បុព្វេនិវាសញ្ញាណំ សេចក្តីថា ការសន្ទនាកើតឡើង គឺ ប្រព្រឹត្តទៅហើយ ប្រារព្ធព្រះមានព្រះភាគដោយប្រការដូច្នេះ ដើម្បីសម្តែងសេចក្តីទាំងអស់នោះដោយសង្ខេប លោកទើបពោលទុកក្នុងបាលីត្រឹមតែថា ឥតិបិ បុព្វេនិវាសោ ឥតិបិ បុព្វេនិវាសោ ។ ក្នុងបទទាំងនោះ បទថា ឥតិបិ ប្រែថា សូម្បីយ៉ាងនេះ ។

សេចក្តីណាដែលគួរពោលទុកក្នុងបាលីនេះថា អស្សោសិ ខោ ភគវា ។បេ។ អថ ភគវា អនុប្បត្តោ លោកពោលទុកហើយក្នុងអដ្ឋកថាព្រហ្ម-

ជាលសូត្រនោះឯង តទៅនេះ សេចក្តីនោះ ជាសេចក្តីផ្សេងគ្នា ។ ក្នុងសូត្រនោះ ព្រះមានព្រះភាគ ទ្រង់ស្តាប់ដោយព្រះសព្វញ្ញុតញ្ញាណ ។ ក្នុងសូត្រនេះ បានស្តាប់ដោយទិព្វសោត ។ មួយទៀត ក្នុងសូត្រនោះ សន្ទនាដល់គុណ និងទោស ។ ក្នុងសូត្រនេះ សន្ទនាដល់បុព្វេនិវាសញ្ញាណ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគទ្រង់ត្រិះរិះថា ភិក្ខុទាំងនេះ សរសើរគុណប្រារព្ធបុព្វេនិវាសញ្ញាណរបស់តថាគត តែមិនដឹងនូវការសម្រេចនៃបុព្វេ-និវាសញ្ញាណរបស់តថាគតឡើយ ណ្ហើយចុះ តថាគតនឹងសម្តែងដល់ការសម្រេចនៃបុព្វេនិវាសញ្ញាណនោះ ហើយសម្តែងដល់ពួកអ្នក ទើបស្តេចមកប្រថាប់ក្នុងពុទ្ធាសនៈដ៏ប្រសើរ ដែលតាមប្រក្រតីតាំងទុកដើម្បីព្រះពុទ្ធប្រថាប់សម្តែងធម៌ ដែលខណៈនោះ ភិក្ខុទាំងឡាយក្រាលថ្វាយទុក មានព្រះពុទ្ធបំណងទ្រង់សម្តែងធម្មីកថា ជាប់ទាក់ទងនឹងបុព្វេនិវាសញ្ញាណដល់ភិក្ខុទាំងនោះ ក្នុងទីបំផុតនៃពាក្យសួរថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញអ្នកទាំងឡាយអង្គុយប្រជុំគ្នា និយាយអំពីរឿងអ្វី និងពាក្យឆ្លើយតាំងពីដើមថា បពិត្រព្រះអង្គដ៏ចម្រើន កាលដែលខ្ញុំព្រះអង្គទាំងឡាយត្រឡប់មកពីបិណ្ឌបាត ក្នុងវេលាក្រោយភត្ត អង្គុយប្រជុំគ្នាក្នុងរោងករេរិមណ្ឌលនេះ ក៏កើតការសន្ទនាធម៌ឡើងទាក់ទងនឹងបុព្វេនិវាសញ្ញាណថា បុព្វេនិវាស បុព្វេនិវាស ដូច្នេះព្រះអង្គ ទើបត្រាស់ពាក្យជាដើមថា ពួកអ្នកប្រាថ្នានឹងស្តាប់ឬ ។

ក្នុងបទទាំងនោះ បទថា ឥច្ឆេយ្យាថ នោ ប្រែថា ពួកអ្នកប្រាថ្នានឹងស្តាប់ឬទេ ។

លំដាប់នោះ ភិក្ខុទាំងឡាយមានចិត្តរីករាយ កាលនឹងទូលអង្វរចំពោះព្រះមានព្រះភាគ ទើបក្រាបទូលថា បពិត្រព្រះមានព្រះភាគដល់វេលាហើយដែលព្រះអង្គនឹងទ្រង់ធ្វើធម្មីកថានេះ ។ ក្នុងបទទាំងនោះ បទថា ឯតស្ស គឺ ការធ្វើធម្មីកថានេះ ។

លំដាប់នោះ ព្រះមានព្រះភាគទទួលពាក្យទូលអង្វររបស់ភិក្ខុទាំងនោះ ទ្រង់មានព្រះបំណងនឹងសម្តែង ទើបទ្រង់បបួលភិក្ខុទាំងនោះឲ្យផ្ទៀងត្រចៀកស្តាប់ និងតាំងចិត្តស្តាប់ដោយល្អ ដោយព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយចូរស្តាប់ ហើយទ្រង់មានព្រះបំណងនឹងប្រកាសការរឭកដល់ផ្លូវដែលកាត់ផ្តាច់ មិនទូទៅទៅដល់ជនពួកដទៃ ទើបត្រាស់ពាក្យជាដើមថា ម្នាលភិក្ខុទាំងឡាយ រាប់អំពីនេះ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា យំ វិបស្សី គឺ ព្រះមានព្រះភាគព្រះនាមថា វិបស្សីក្នុងកប្បណា ។ ពិតមែន យំ សព្ទនេះ ប្រើក្នុងបឋមាវិភត្តិ ក្នុងបទទាំងឡាយជាដើមថា **បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីណាដែលខ្ញុំស្តាប់មកហើយ ទទួលមកហើយអំពីពួកទេវតាជាន់តាវតឹង្ស ខ្ញុំព្រះអង្គនឹងក្រាបទូលសេចក្តីនោះដល់ព្រះមានព្រះភាគ** ។ ប្រើក្នុងទុតិយាវិភត្តិ ក្នុងបទទាំងឡាយជាដើមថា **បពិត្រអកិត្តយិ ពួកខ្ញុំបានសួរសេចក្តីណាហើយ**

**ពួកខ្ញុំនឹងសូមសួរសេចក្តីដទៃ សូមលោកដ៏ចម្រើន ចូរប្រាប់សេចក្តីនោះដល់ខ្ញុំទាំងឡាយចុះ** ដូច្នេះ ។

ប្រើក្នុងតតិយាវិភត្តិ ក្នុងបទទាំងឡាយជាដើមថា **ប្រការដែលមិនមានចន្លោះ ដោយលោកធាតុមួយ មិនមែនជាឋានៈឡើយ** ។ តែក្នុងបទនេះ គប្បីជ្រាបថា ប្រើក្នុងសត្តមីវិភត្តិ ។ ព្រោះដូច្នោះ លោកទើបពោលថា យស្មិំ កប្បេ ប្រែថា ក្នុងកប្បណា ។

បទថា ឧឧចាធិ សេចក្តីថា ញុាំងម៉ឺនលោកធាតុឲ្យបន្លឺកើតឡើងហើយ ។

បទថា ភទ្ទកប្បេ សេចក្តីថា ក្នុងសុន្ទរកប្ប គឺ ក្នុងសារកប្ប ព្រោះមានព្រះពុទ្ធទ្រង់ឧប្បត្តិឡើង ៥ ព្រះអង្គ ដូច្នោះ ព្រះមានព្រះភាគកាលនឹងទ្រង់សរសើរកប្បនេះ ទើបត្រាស់យ៉ាងនេះ ។

ដូចបានជ្រាបមកថា តាំងពីព្រះមានព្រះភាគរបស់យើងទាំងឡាយទ្រង់បំពេញអភិនិហារ រមែងមិនមានសុញ្ញកប្បក្នុងកប្បមួយ ក្នុងចន្លោះនោះដែលព្រះពុទ្ធ ៥ ព្រះអង្គ ទ្រង់ឧប្បត្តិហើយ ។ ក៏ប៉ុន្តែ មុនអភិនិហាររបស់ព្រះមានព្រះភាគរបស់យើងទាំងឡាយ ព្រះពុទ្ធ ៤ ព្រះអង្គ គឺ ព្រះតណ្ហង្ករ ព្រះមេធង្ករ ព្រះសរណង្ករ ព្រះទីបង្ករ ទ្រង់ឧប្បត្តិហើយក្នុងកប្បតែមួយ ។ ក្នុងចំណែកដែលផុតអំពីព្រះពុទ្ធទាំងនោះហើយ បានសូន្យទទេចាកព្រះពុទ្ធ ដល់ទៅមួយអសង្ខេយ្យតែម្តង ។ ក្នុងទីបំផុតនៃ

មួយអសង្ខេយ្យកប្ប ព្រះពុទ្ធព្រះនាមថា កោណ្ឌញ្ញៈ តែមួយព្រះអង្គប៉ុណ្ណោះ ទ្រង់ឧប្បត្តិឡើងក្នុងកប្បមួយ ។ តអំពីនោះ ក៏សូន្យចាកព្រះពុទ្ធអស់មួយអសង្ខេយ្យកប្បទៀត ។ ក្នុងទីបំផុតនៃមួយអសង្ខេយ្យកប្ប ព្រះពុទ្ធ ៤ ព្រះអង្គ គឺ ព្រះសុមង្គលៈ ព្រះសុមនៈ ព្រះរេវតៈ ព្រះសោភិតៈ ទ្រង់ឧប្បត្តិឡើងក្នុងកប្បមួយ ។ បន្ទាប់ពីនោះ ក៏សូន្យចាកព្រះពុទ្ធអស់មួយអសង្ខេយ្យកប្បទៀត ។ ក្នុងទីបំផុតនៃមួយអសង្ខេយ្យកប្ប តអំពីនោះទៀត អសង្ខេយ្យក្រៃលែងដោយសែនកប្ប ព្រះពុទ្ធ ៣ ព្រះអង្គ គឺ ព្រះអនោមទស្សី ព្រះបទុមៈ ព្រះនារទៈ ទ្រង់ឧប្បត្តិឡើងក្នុងកប្បមួយ ។ សូម្បីអំពីនោះ ក៏សូន្យចាកព្រះពុទ្ធអស់មួយអសង្ខេយ្យ ។ ក្នុងទីបំផុតអសង្ខេយ្យកប្ប និងថែមសែនកប្ប ព្រះដ៏មានព្រះភាគព្រះនាមថា ព្រះ-បទុមុត្តរៈ តែមួយព្រះអង្គប៉ុណ្ណោះ ទ្រង់ឧប្បត្តិឡើងក្នុងកប្បមួយ ។ តអំពីនេះទៀត បីម៉ឺនកប្ប ព្រះពុទ្ធពីរព្រះអង្គ គឺ ព្រះសុមេធៈ ព្រះសុជាតៈ ទ្រង់ឧប្បត្តិឡើងក្នុងកប្បមួយ ។ ក្នុងចំណែកដ៏សេសអំពីនោះ តទៅទៀត ១៨.០០០ កប្ប ព្រះពុទ្ធ ៣ ព្រះអង្គ គឺ ព្រះបិយទស្សី ព្រះអត្ថទស្សី ព្រះធម្មទស្សី ទ្រង់ឧប្បត្តិឡើងក្នុងកប្បមួយ ។ តពីនោះទៅ ៩៤ កប្ប ព្រះពុទ្ធ ព្រះនាមថា សិទ្ធត្ថៈ ទ្រង់ឧប្បត្តិឡើងក្នុងកប្បមួយ តពីនោះ ៩២ កប្ប ព្រះពុទ្ធ ២ ព្រះអង្គ គឺ ព្រះតិស្សៈ ព្រះបុស្សៈ ទ្រង់ឧប្បត្តិឡើង ក្នុងកប្បមួយ ។ តពីនោះទៅ ៩១ កប្ប ព្រះមានព្រះភាគព្រះនាមថា វិបស្សី

ទ្រង់ឧប្បត្តិឡើង ។ តអំពីនោះ ៣១ កប្ប ព្រះពុទ្ធ ២ ព្រះអង្គ គឺ ព្រះសិខី ព្រះវេស្សភូ ទ្រង់ឧប្បត្តិឡើង ។ ក្នុងកប្បនេះ ព្រះពុទ្ធ ៤ ព្រះអង្គ គឺ ព្រះកកុសន្ធៈ ព្រះកោនាគមនៈ ព្រះកស្សបៈ ព្រះសម្មាសម្ពុទ្ធ របស់យើងទាំងឡាយទ្រង់ឧប្បត្តិឡើង ឯព្រះមេត្តេយ្យៈ ទ្រង់នឹងឧប្បត្តិឡើងជាខាងក្រោយ ។ កប្បនេះ ជាសុន្ទរកប្ប ជាសារកប្ប ព្រោះមានព្រះពុទ្ធទ្រង់ឧប្បត្តិឡើង ៥ ព្រះអង្គ ដោយប្រការយ៉ាងនេះ ដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់សរសើរកប្បនេះ ទើបត្រាស់យ៉ាងនេះ ។

សួរថា ប្រការដែលថា ព្រះពុទ្ធប្រមាណប៉ុណ្ណោះ ទ្រង់ឧប្បត្តិឡើងហើយក្តី នឹងទ្រង់ឧប្បត្តិឡើងក្តីក្នុងកប្បនេះ រមែងជាការប្រាកដដល់ព្រះពុទ្ធទាំងឡាយប៉ុណ្ណោះឬ ឬថា រមែងប្រាកដសូម្បីដល់អ្នកដទៃផង ។ ឆ្លើយថា រមែងប្រាកដសូម្បីដល់អ្នកដទៃផង ។ សួរថា ដល់នរណា ។ ឆ្លើយថា ដល់ព្រហ្មជាន់សុទ្ធាវាសផង ។

ពិតណាស់ ក្នុងកាលតាំងនៅនៃកប្ប កាលលោកសន្និវាសតាំងនៅរហូតមួយអសង្ខេយ្យ ភ្លៀងចាប់ផ្តើមធ្លាក់ដើម្បីឲ្យលោកតាំងនៅ ។ រមែងដូចជាទឹកសន្សើម ធ្លាក់ក្នុងទីបំផុតដែនពីដើមតែម្តង ។ តពីនោះ ក៏មានជាតំណក់ទឹក ប្រមាណប៉ុនគ្រាប់កន្ទក់ ប៉ុនគ្រាប់ល្ង ប៉ុនគ្រាប់អង្ករ ប៉ុនគ្រាប់សណ្តែកបាយ ប៉ុនគ្រាប់សណ្តែករាជមាស ប៉ុនផ្លែពុទ្រា ប៉ុនផ្លែកន្ទួតព្រៃ ប៉ុនផ្លែល្ពៅ ប៉ុនផ្លែត្រឡាច ប៉ុនផ្លែឃ្លោក ជាខ្សែទឹកចម្រើន

ឡើងដោយលំដាប់ មួយឧសភៈ ពីរឧសភៈ កន្ទះគាវុត មួយគាវុត កន្ទះយោជន៍ មួយយោជន៍ ពីរយោជន៍ បីយោជន៍ ១០ យោជន៍ ។ល។ សែនយោជន៍ជាប្រមាណ តាំងនៅបរិបូរណ៍ ក្នុងចន្លោះសែនកោដិចក្រវាឡ ជរាបដល់អកនិដ្ឋព្រហ្មលោក ។ លំដាប់នោះ ទឹកនោះស្រកចុះដោយលំដាប់ កាលទឹកស្រកចុះ ទេវលោកទាំងឡាយ រមែងតាំងនៅក្នុងទីរបស់ទេវលោកជាប្រក្រតី ។ វិធីសាងទេវលោកទាំងនោះ លោកពោលទុកហើយក្នុងបុព្វេនិវាសកថាក្នុងវិសុទ្ធិមគ្គ ។

ក៏ឋានៈរបស់មនុស្សលោក ដូចកាលទឹកចូលទៅ ហើយបិទមាត់ធម្មក្រកជិត ទឹកនោះ ក៏នៅបានដោយអំណាចខ្យល់ ។ ផែនដីរមែងតាំងនៅបានដូចស្លឹកឈូកនៅលើផ្ទៃទឹក ។ ទីមហាពោធិបល្ល័ង្ក កាលលោកវិនាស ក៏វិនាសក្រោយ កាលលោកតាំងឡើង ក៏ប្រាកដឡើងមុន ។ ក្នុងទីពោធិបល្ល័ង្កនោះ ឈូកមួយគុម្ព រមែងកើតឡើង ជាបុព្វនិមិត្ត ប្រសិនបើក្នុងកប្បនោះ ទីពោធិបល្ល័ង្កនោះ ព្រះពុទ្ធនឹងទ្រង់ឧប្បត្តិ ផ្កាឈូករមែងកើតឡើង បើទ្រង់មិនឧប្បត្តិ ផ្កាឈូកនឹងមិនកើត ។ មួយទៀត កាលផ្កាឈូកកើត បើព្រះពុទ្ធមួយអង្គនឹងឧប្បត្តិ ក៏កើតផ្កាតែមួយ ។ បើព្រះពុទ្ធនឹងឧប្បត្តិ ២ អង្គ ៣ អង្គ ៤ អង្គ ៥ អង្គ ផ្កាឈូកក៏កើត ៥ ផ្កា ។ មួយទៀត ផ្កាឈូកទាំងនោះ ជាផ្កាមានចង្កោមជាប់គ្នាក្នុងទងតែមួយទុ៎ះឯង ស្តេចសុទ្ធាវាសព្រហ្មទាំងឡាយ បបួលគ្នាថា លោកអ្នកនិរទុក្ខទាំងឡាយ

ពួកយើងចូរមក នឹងឃើញបុព្វនិមិត្ត ហើយនាំគ្នាមកកាន់មហាពោធិបល្ល័ង្ក-ស្ថាន ។ ក្នុងកប្បដែលព្រះពុទ្ធទាំងឡាយទ្រង់មិនឧប្បត្តិ ផ្កាឈូកក៏មិនមាន ។ ពួកទេពទាំងឡាយ ឃើញគុម្ពឈូកមិនមានផ្កា ក៏មានសេចក្តីសង្វេគថា ម្នាលគ្នាយើង លោកនឹងងងឹតឈឹងហ្ន៎ សត្វទាំងឡាយត្រូវកាពងងឹតគ្របសង្កត់ នឹងពេញក្នុងអបាយ ទេវលោក ៦ ព្រហ្មលោក ៩ នឹងទំនេរ គ្រាឃើញផ្កាឈូកក្នុងវេលារីក នាំគ្នាសប្បាយចិត្តថា កាលព្រះសព្វញ្ញូពោធិសត្វទ្រង់ឈានចុះកាន់គភ៌ព្រះមាតា ប្រសូត ត្រាស់ដឹង ញ៉ាំងធម្មចក្រឲ្យប្រព្រឹត្តទៅ ទ្រង់ធ្វើយមកបាដិហារ្យ ចុះអំពីទេវលោក ទ្រង់ដាក់អាយុសង្ខារ ស្តេចរំលត់ខន្ធបរិនិព្វាន ពួកយើងនឹងឃើញបាដិហារ្យដែលធ្វើឲ្យម៉ឺនចក្រវាឡញាប់ញ័រ និងអបាយទាំង ៤ នឹងវិនាសសាបសូន្យ ទេវលោក ៦ ព្រហ្មលោក ៩ នឹងបរិបូរណ៌ , ក៏នាំគ្នាថ្លែងឧទានទៅកាន់ព្រហ្មលោករបស់ខ្លួន រៀង ៗ ខ្លួន ។

ម្យ៉ាងទៀត ផ្កាឈូក ៥ ផ្កា កើតឡើងហើយក្នុងកប្បនេះ ។ សូម្បីស្តេចសុទ្ធាវាសព្រហ្មទាំងឡាយ គ្រាឃើញផ្កាឈូកទាំងនោះ ក៏ដឹងសេចក្តីនេះថា ព្រះពុទ្ធ ៤ ព្រះអង្គ ទ្រង់ឧប្បត្តិហើយ អង្គទី ៥ នឹងឧប្បត្តិតទៅ ដូច្នេះ ដោយអានុភាពនៃនិមិត្តទាំងនោះ ព្រោះហេតុនោះលោកទើបពោលថា សេចក្តីនោះជាការប្រាកដ សូម្បីដល់អ្នកដទៃដូច្នេះ ។

សូម្បីព្រោះហេតុនេះ ព្រះមានព្រះភាគ ទ្រង់សម្តែងបុព្វេនិវាស

ដោយអំណាចកំណត់កប្ប ដោយន័យជាដើមថា ម្នាលភិក្ខុទាំងឡាយ រាប់អំពីនេះទៅ ដូច្នេះ ។ ឥឡូវនេះ ដើម្បីនឹងទ្រង់សម្ដែងដោយអំណាចការកំណត់ជាតិជាដើម របស់ព្រះពុទ្ធទាំងនោះ ទើបត្រាស់ពាក្យជាដើមថា ម្នាលភិក្ខុទាំងឡាយ ព្រះមានព្រះភាគព្រះនាមថា ព្រះវិបស្សី ដូច្នេះ ។

## ពណ៌នាការកំណត់អាយុ

[២-៤] ក្នុងបទទាំងនោះ គប្បីជ្រាបវិនិច្ឆ័យក្នុងការកំណត់អាយុ ។ បទទាំងពីរនេះថា បរិត្តំ លហុកំ ជាវេវចនៈរបស់អាយុតិចនុ៎ះឯង ។ ព្រោះថា អាយុណាតិច អាយុនោះ រមែងជារបស់បន្តិចបន្តួច និងស្តួចស្តើង ។ បទថា អប្បំ វា ភិយ្យោ គឺ អាយុច្រើនជាង ១០០ ឆ្នាំ មានតិច ។ គ្រានៅមិនដល់ ១០០ ឆ្នាំ រមែងរស់នៅ ២០ ឆ្នាំ ៣០ ឆ្នាំ ៤០ ឆ្នាំ ៥០ ឆ្នាំ ឬ ៦០ ឆ្នាំ ។ តែអ្នកអាយុវែងយ៉ាងនេះ លំបាករកបានណាស់ បានឮថា អ្នកឯណោះនៅយូរយ៉ាងនេះ គួរនាំគ្នាទៅមើលក្នុងទីនោះ ៗ ។ បណ្តាអ្នកមានអាយុវែងនោះ ឧបាសិកាវិសាខា នៅបាន ១២០ ឆ្នាំ ព្រាហ្មណ៍បោក្ខរសាតិ ព្រាហ្មណ៍ព្រហ្មាយុ ព្រាហ្មណ៍សេលៈ ព្រាហ្មណ៍ពាវរិយៈ ព្រះអានន្ទត្ថេរ ព្រះមហាកស្សបត្ថេរ ក៏ដូចគ្នា តែព្រះអនុរុទ្ធត្ថេរនៅដល់ ១៥០ ឆ្នាំ ព្រះពាកុលត្ថេរនៅដល់ ១៦០ ឆ្នាំ ភិក្ខុរូបនេះ មានអាយុវែងជាងគេទាំងអស់ ។ សូម្បីលោកក៏នៅមិនដល់ ២០០ ឆ្នាំ ។

ក៏ព្រះពោធិសត្វទាំងឡាយ មានព្រះវិបស្សីជាដើម ចុះកាន់បដិសន្ធិក្នុងគភ៌ព្រះមាតា ដោយអសង្ខារិកចិត្ត សហគតដោយសោមនស្ស និងសម្បយុត្តដោយញាណ ដែលជាចំណែកខាងដើមនៃមេត្តា កាលចុះកាន់បដិសន្ធិដោយចិត្តនោះ នឹងមានអាយុមួយអសង្ខេយ្យ ។ ដោយហេតុនេះ

ព្រះពុទ្ធទាំងពួង ទើបមានព្រះជន្មាយុមួយអសង្ខេយ្យ ។ សួរថា ព្រោះហេតុអ្វី ព្រះអង្គទាំងនោះ ទើបមិនតាំងនៅដល់អសង្ខេយ្យ ។ ឆ្លើយថា ព្រោះសេចក្តីវិបត្តិនៃរដូវ និងភោជន ។ ពិតណាស់ អាយុរមែងសាបសូន្យខ្លះ រមែងចម្រើនខ្លះ ដោយអំណាចនៃរដូវ និងភោជន ។

ក្នុងសេចក្តីនោះ កាលណាព្រះរាជាទាំងឡាយ មិនប្រកបដោយធម៌ កាលនោះ ឧបរាជ សេនាបតី សេដ្ឋី សកលនគរ សកលរដ្ឋ ក៏រមែងមិនប្រកបដោយធម៌ដូចគ្នា ។ កាលនោះ អារក្ខទេវតានៃជនទាំងនោះ កុម្ភទេវតាជាមិត្តរបស់ទេវតាទាំងនោះ អាកាសដ្ឋកទេវតាជាមិត្តរបស់កុម្ភទេវតា ឧណ្ហវលាហកទេវតាជាមិត្តរបស់អាកាសដ្ឋកទេវតា អព្ភវលាហកទេវតាជាមិត្តរបស់ឧណ្ហវលាហកទេវតាទាំងនោះ សីតវលាហកទេវតាជាមិត្តរបស់អព្ភវលាហកទេវតាទាំងនោះ វស្សវលាហកទេវតាជាមិត្តរបស់សីតវលាហកទេវតាទាំងនោះ ចាតុម្មហារាជិកាទេវតាជាមិត្តរបស់វស្សវលាហកទេវតាទាំងនោះ តាវត្តិង្សទេវតាជាមិត្តរបស់ចាតុម្មហារាជិកាទេវតាទាំងនោះ យាមាទេវតាជាមិត្តរបស់តាវត្តិង្សទេវតាទាំងនោះជាដើម ដរាបដល់ភវគ្គព្រហ្ម វៀរព្រះអរិយសាវកទេវតាទាំងអស់ សូម្បីព្រហ្មបរិស័ទ ក៏ជាអ្នកមិនប្រកបដោយធម៌ ។ ព្រះចន្ទ ព្រះអាទិត្យ រមែងដំណើរទៅទាបខ្លះ ៗ ព្រោះទេវតាទាំងនោះមិនប្រកបដោយធម៌ ។ ខ្យល់រមែងមិនបក់ទៅតាមផ្លូវខ្យល់ ។ កាលខ្យល់មិនបក់ទៅតាមផ្លូវខ្យល់ រមែងធ្វើឲ្យវិមានដែលតាំងនៅលើអាកាស

ញវ៉េរញ្ជួយ ។ កាលវិមានញ័វរញ្ជួយ ពួកទេវតាក៏មិនមានចិត្តនឹងទៅលេង កីឡា កាលទេវតាមិនមានចិត្តនឹងទៅលេងកីឡា រដូវត្រជាក់ រដូវក្តៅ រមែង មិនប្រព្រឹត្តទៅតាមរដូវកាល ។ កាលរដូវ មិនប្រព្រឹត្តទៅតាមរដូវកាល ភ្លៀងរមែងមិនធ្លាក់ដោយល្អ គ្រាខ្លះធ្លាក់ គ្រាខ្លះមិនធ្លាក់ ក្នុងទីកន្លែងខ្លះ ធ្លាក់ ក្នុងទីកន្លែងខ្លះមិនធ្លាក់ ក៏កាលធ្លាក់ រមែងធ្លាក់ខណៈសាបព្រោះ ខណៈបែកពន្លក ខណៈបែកដើម ខណៈចេញកួរ ខណៈដាក់ទឹកដោះជាដើម រមែងធ្លាក់មិនជាឧបការៈដល់ស្រូវឡើយ និងរាំងស្ងួតអស់កាលយូរ ដោយ ហេតុនោះ ស្រូវទើបទុំមិនព្រមគ្នា ប្រាសចាកសម្បត្តិ មានក្លិន ពណ៌ និងរសជាដើម ។ សូម្បីក្នុងបាយដែលដាក់ក្នុងភាជនៈតែមួយជាមួយគ្នា បាយមួយចំណែកឆៅ មួយចំណែកជ្រាយ មួយចំណែកខ្លោច ។ បរិភោគ បាយនោះចូលទៅ រមែងដល់អាការ ៣ យ៉ាងក្នុងផ្ទៃ ។ សត្វទាំងឡាយ ជាអ្នកមានរោគច្រើន និងមានអាយុតិច ដោយហេតុនោះ ។ អាយុរមែង សាបសូន្យដោយអំណាចនៃរដូវ និងភោជនដោយប្រការដូច្នេះ ដោយពិត ។

សូម្បីទេវតាទាំងពួង រហូតដល់ព្រហ្មលោក រមែងជាអ្នកប្រកបដោយ ធម៌ ដោយន័យដែលមានក្នុងខាងដើមថា ក៏កាលណាព្រះរាជាជាអ្នកប្រកប ដោយធម៌ កាលនោះ សូម្បីសេនាបតី និងឧបរាជ ក៏ជាអ្នកប្រកបដោយ ធម៌ ដូច្នេះ ។ ព្រោះពួកទេវតាទាំងនោះ តាំងនៅក្នុងធម៌ ព្រះចន្ទ និង ព្រះអាទិត្យ រមែងធ្វើដំណើរទៅដោយស្មើ ។ ខ្យល់ រមែងបក់ទៅតាមផ្លូវ

របស់ខ្យល់ រមែងមិនធ្វើឲ្យវិមានដែលតាំងនៅលើអាកាសញ័ររញ្ជួយ ។ កាលវិមានមិនញ័ររញ្ជួយ ពួកទេវតាក៏មានចិត្តលេងកីឡា ។ រដូវរមែងប្រព្រឹត្តទៅតាមកាលយ៉ាងនេះ ។ ភ្លៀងរមែងធ្លាក់ដោយប្រពៃ ជំនួយដល់ស្រូវតាំងពីខណៈសាបព្រោះ ធ្លាក់តាមវេលា ។ ដោយហេតុនោះ ស្រូវទុំព្រមគ្នា មានក្លិនក្រអូប មានពណ៌ល្អ មានរសឆ្ងាញ់ មានឱជៈ ។ ភោជនដែលផ្សំដោយស្រូវនោះ សូម្បីបរិភោគហើយ ក៏ដល់ការរលួយឆាយ សត្វទាំងឡាយជាអ្នកមិនមានរោគ មានអាយុវែង ដោយហេតុនោះ ។ អាយុរមែងចម្រើនដោយអំណាចរដូវ និងភោជន ដោយប្រការដូច្នេះ ។

ក្នុងបណ្ដាព្រះមានព្រះភាគទាំងនោះ ព្រះមានព្រះភាគ ព្រះនាមថាវិបស្សី ទ្រង់ឧប្បត្តិក្នុងខណៈដែលសត្វមានអាយុ ៨០.០០០ ឆ្នាំ ព្រះសិខីទ្រង់ឧប្បត្តិក្នុងខណៈដែលសត្វមានអាយុ ៧០.០០០ ឆ្នាំ ដូច្នោះ លោកកំណត់អាយុនេះទុក ហាក់ដូចជាសាបសូន្យទៅដោយលំដាប់ តែមិនមែនសាបសូន្យយ៉ាងនោះ ។ គប្បីជ្រាបថា អាយុចម្រើន ចម្រើនហើយវិនាស ។ សួរថា យ៉ាងណា ។ ឆ្លើយថា ក្នុងភទ្រកប្បនេះមុន ព្រះមានព្រះភាគព្រះនាមថា កកុសន្ធ ទ្រង់ឧប្បត្តិក្នុងខណៈដែលសត្វមានអាយុ ៤០.០០០ ឆ្នាំ កំណត់អាយុទុក ៥ ចំណែក តាំងនៅ ៤ ចំណែក កាលដល់ចំណែកទី ៥ ក៏បរិនិព្វាន ។ អាយុនោះ វិនាសដល់កាលកិរិយានៃអាយុ ១០ ឆ្នាំ ហើយចម្រើនឡើងទៀតជាមួយអសង្ខេយ្យ តពីនោះក៏វិនាស តាំងនៅក្នុង

ខណៈដែលសត្វមានអាយុ ៣០.០០០ ឆ្នាំ ។ កាលនោះ ព្រះមានព្រះភាគ ព្រះនាមថា កោនាគមន ទ្រង់ឧប្បត្តិ ។ សូម្បីកាលព្រះកោនាគមនៈនិព្វាន ហើយ ក៏យ៉ាងនោះ អាយុនោះវិនាសដល់កាលកិរិយានៃអាយុ ១០ ឆ្នាំ ហើយចម្រើនឡើងទៀតជាអសង្ខេយ្យ វិនាសទៀត តាំងនៅក្នុងខណៈដែល សត្វមានអាយុ ២០.០០០ ឆ្នាំ ។ កាលនោះ ព្រះមានព្រះភាគព្រះនាមថា កស្សប ទ្រង់ឧប្បត្តិ ។ សូម្បីកាលព្រះកស្សបៈនោះ បរិនិព្វានយ៉ាងនោះ ហើយ អាយុនោះក៏វិនាស ដល់កាលកិរិយាកាលមានអាយុ ១០ ឆ្នាំ ហើយចម្រើនឡើងទៀតជាអសង្ខេយ្យ វិនាសទៀតដល់កាលកិរិយា កាល មានអាយុ ១០០ ឆ្នាំ ។ ពេលនោះ ព្រះសម្មាសម្ពុទ្ធរបស់ពួកយើង ទ្រង់ ឧប្បត្តិ ។ អាយុមិនបានវិនាសចុះដោយលំដាប់យ៉ាងនោះ គប្បីជ្រាបថា ចម្រើន ចម្រើនហើយ ទើបវិនាស ។ ក្នុងសេចក្តីនោះ គប្បីជ្រាបថា ប្រការដែលកាលបើមនុស្សទាំងឡាយមានអាយុចម្រើន ព្រះពុទ្ធរមែងទ្រង់ ឧប្បត្តិនោះឯង ជាកំណត់អាយុរបស់ព្រះពុទ្ធទាំងនោះ ។ ការកំណត់អាយុ ចប់ គប្បីជ្រាបវិនិច្ឆ័យក្នុងការកំណត់ស្ថានទីត្រាស់ដឹង ។

# ពណ៌នាការកំណត់ដើមពោធិព្រឹក្ស

[៥] បទថា ចាដលិយា មូលេ គឺ ខាងក្រោមដើមជ្រៃទៀង ។ ដើមជ្រៃទៀងនោះ មានកំពស់ ១០០ ហត្ថ គឺ ថ្ងៃនោះ ដើមលូតឡើងទៅ ៥០ ហត្ថ មែក ៥០ ហត្ថ ។ មួយទៀត ដើមជ្រៃទៀងនោះ ក្នុងថ្ងៃនោះ មានផ្កាភ្ជាប់ជាចង្កោម គ្របដណ្ដប់ពាសពេញតាំងពីគល់ដល់ចុង ។ ក្លិនទិព្វបក់ផាត់ទៅ ។ មិនមែនមានផ្កាតែដើមជ្រៃទៀងនេះមួយប៉ុណ្ណោះទេដែលរីក ។ ដើមជ្រៃទៀងទាំងអស់ក្នុងម៉ឺនចក្រវាឡក៏រីក ។ មិនមែនជ្រៃទៀងតែម្យ៉ាងរីកនោះទេ ។ បណ្ដាដើមឈើទាំងអស់ក្នុងម៉ឺនចក្រវាឡក៏រីក ដូចគុម្ពបទុមរីកត្រង់គុម្ព ទងបទុមរីកត្រង់ទង ចុងបទុមរីកត្រង់ចុង អាកាសបទុមរីកលើអាកាស ឈូកធំទម្លាយផែនដីផុសឡើង ។ សូម្បីមហាសមុទ្រ ក៏ជេរ-ដាស់ទៅដោយបទុម ៥ ប្រភេទ និងដោយឈូកស ឈូកក្រហម ។ ទាំងម៉ឺនចក្រវាឡ បានមានពពួកផ្កាឈើដូចជាទង់ ជេរដាស់ទៅដោយកម្រងផ្កាឈើ ជាប់គ្នានឹងគំនរផ្កាឈើដែលជ្រុះក្នុងទីនោះ ៗ ព្រោងព្រាតទៅដោយផ្កាឈើពណ៌ផ្សេង ៗ ហាក់ដូចជាសួននន្ទវ័ន ចិត្តលតាវ័ន មិស្សកវ័ន និងបារុសកវ័ន ។ ដូចជាលើកទង់ឡើងក្នុងកណ្ដាប់ចក្រវាឡនៃទិសខាងកើតទៅទល់នឹងកណ្ដាប់ចក្រវាឡនៃទិសខាងលិច ។ និងដូចលើកទង់ឡើងក្នុងកណ្ដាប់ចក្រវាឡនៃទិសខាងលិច ទិសខាងត្បូង ទិសខាងជើង ទៅទល់នឹង

មាត់កណ្ដាប់ចក្រវាឡនៃទិសខាងត្បូង ។ ប្រាកដជាចក្រវាឡដែលសម្បូរណ៍ដោយសិរីដល់គ្នានឹងគ្នា យ៉ាងនេះ ។ បទថា អភិសម្ពុទ្ធោ សេចក្ដីថា ចាក់ធ្លុះគុណ សេចក្ដីចម្រើន សិរីដែលជាពុទ្ធៈ គឺ ត្រាស់ដឹងក្រៃលែងនូវអរិយសច្ចៈ ៤ ។ សូម្បីក្នុងបទទាំងឡាយជាដើមថា ម្នាលភិក្ខុទាំងឡាយ ព្រះមានព្រះភាគព្រះនាមថា សិខី ជាព្រះអរហន្តសម្មាសម្ពុទ្ធ ត្រាស់ហើយនៅក្រោមដើមបុណ្ឌរិក (ស្វាយស) គប្បីជ្រាបការពណ៌នាដោយន័យនេះឯង ។

ក៏បទថា បុណ្ឌរីកោ ក្នុងទីនេះ គឺ ដើមស្វាយសមានរសផ្អែម ។ សូម្បីដើមស្វាយសនោះ ក៏មានប្រមាណនោះដូចគ្នា ។ មួយទៀត ក្នុងថ្ងៃនោះ ដើមស្វាយនោះ ក៏គ្របដណ្ដប់ទៅដោយផ្កាដែលជាទិព្វ និងមានក្លិនក្រអូប ។ មិនមែនផ្កាតែម្យ៉ាង ក៏មានផ្លែផង ។ ស្វាយនោះ ម្ខាងផ្លែខ្ចី ម្ខាងផ្លែកណ្ដាល ម្ខាងផ្លែមិនទាន់ចាស់ ម្ខាងផ្លែទុំមានរសឆ្ងាញ់ មានឱជៈដូចដាក់ទិព្វឱជៈចូលទៅ សំយុងចុះរយោង ។ ដើមស្វាយនោះយ៉ាងណាក្នុងម៉ឺនចក្រវាឡក៏យ៉ាងនោះ ដើមឈើដែលចេញផ្កាក៏បានប្រដាប់ដោយផ្កា ដើមឈើដែលចេញផ្លែក៏បានប្រដាប់ដោយផ្លែ ។

បទថា សាលោ គឺ ដើមសាលៈ ។ សូម្បីដើមសាលៈនោះ ក៏មានប្រមាណប៉ុណ្ណោះដូចគ្នា ។ គប្បីជ្រាបផ្កាសិរីចម្រើនយ៉ាងនោះដូចគ្នា ។ សូម្បីក្នុងដើមប្រេស ក៏ន័យនេះដូចគ្នា ។ ក្នុងដើមល្វាមិនមានផ្កា ការដុះ

លូតលាស់នៃផ្លែល្វានេះ មានន័យដូចពោលហើយក្នុងដើមស្វាយនោះឯង ។ ក្នុងដើមជ្រៃ ក្នុងដើមពោធិបាយ ក៏ដូចគ្នាដែរ ។

បល្ល័ង្ករបស់ព្រះពុទ្ធគ្រប់ព្រះអង្គក៏ដូចគ្នា ។ តែដើមឈើដទៃអំពីគ្នា ។ ក្នុងបណ្តាដើមឈើទាំងនោះ ព្រះពុទ្ធទាំងឡាយរមែងទ្រង់ដឹងច្បាស់ដល់ការត្រាស់ដឹង ពោលគឺ មគ្គញ្ញាណ ៤ ក្រោមដើមឈើណាៗ ដើមឈើនោះៗ លោកហៅថា ពោធិ ។ នេះឈ្មោះថា កំណត់ស្ថានទីត្រាស់ដឹង ។

## ពណ៌នាការកំណត់គូសាវក

[៦] គប្បីជ្រាបវិនិច្ឆ័យក្នុងការកំណត់សាវក ។ បទថា ខណ្ឌតិស្សំ គឺ សាវកឈ្មោះថា **ខណ្ឌៈ** និង **តិស្សៈ** ។ លោកទាំងពីរនោះ ព្រះខណ្ឌៈ រួមបិតាតែមួយ ជាប្អូន ព្រះតិស្សៈជាបុរោហិត ។ ព្រះខ័ណ្ឌៈ សម្រេចដល់ទីបំផុតនៃបញ្ញាបារមី ព្រះតិស្សៈសម្រេចទីបំផុតនៃសមាធិបារមី ។ បទថា អគ្គំ អធិប្បាយថា ជាអ្នកខ្ពស់បំផុត ព្រោះជាអ្នកមានគុណមិនដូចគ្នានឹងអ្នកដ៏សេស វៀរលែងតែព្រះមានព្រះភាគព្រះនាមថា វិបស្សី ។ បទថា ភទ្ទយុគំ អធិប្បាយថា ឈ្មោះថា គូដ៏ចម្រើន ព្រោះជាអ្នកកំពូលដ៏លើស ។

បទថា អភិភូសម្ភវំ គឺ សាវកឈ្មោះថា **អភិភូ** និង **សម្ភវៈ** លោកទាំងពីរនោះ ព្រះអភិភូសម្រេចទីបំផុតនៃបញ្ញាបារមីទៅកាន់ព្រហ្មលោក ចាកអរុណវតីជាមួយនឹងព្រះមានព្រះភាគព្រះនាមថា សិខី ហើយសម្តែងបាដិហារ្យច្រើនយ៉ាងដល់ព្រហ្មបរិស័ទ សម្តែងធម៌ផ្សាយទៅទូទាំងម៉ឺនលោកធាតុធ្វើឲ្យងងឹតឈឹង ហើយក៏ធ្វើឲ្យមានពន្លឺ ដល់អ្នកដែលកើតសង្ស័យថា នេះអ្វី ហើយអធិដ្ឋានថា សូមឲ្យជនទាំងពួងចូរឃើញរូបរបស់យើង និងចូរបានឮសំឡេងរបស់យើងដូច្នេះ បានពោលពីរគាថាថា អ្នកទាំងឡាយ ចូរចាប់ផ្តើមបានដូច្នេះជាដើម ឲ្យបានឮសំឡេង ។ ព្រះសម្ភវៈបានសម្រេចទីបំផុតនៃសមាធិបារមី ។

បទថា សោណុត្តរំ គឺ ព្រះសាវកឈ្មោះថា **ព្រះសោណៈ** និង **ព្រះឧត្តរៈ** ។ ក្នុងលោកទាំងពីរនោះ ព្រះសោណៈសម្រេចបញ្ញាបារមី ព្រះឧត្តរៈសម្រេចសមាធិបារមី ។

បទថា វិធុរសញ្ជីវំ គឺ ព្រះសាវកឈ្មោះថា **វិធុរៈ** និង **សញ្ជីវៈ** ក្នុងលោកទាំងពីរនោះ ព្រះវិធុរៈសម្រេចបញ្ញាបារមី ។ ព្រះសញ្ជីវៈសម្រេចសមាធិបារមី ជាអ្នកប្រាថ្នាចូលសមាបត្តិ ព្យាយាមដោយកម្លាំងសមាបត្តិ ក្នុងទីសម្រាកពេលយប់ សម្រាកពេលថ្ងៃ កុដិ ល្អាង និងមណ្ឌបជាដើម ចូលនិរោធក្នុងព្រៃរហូតដល់អស់ថ្ងៃមួយ ។ អ្នកធ្វើការងារក្នុងព្រៃជាដើម យល់ថា លោកមរណភាព ទើបនាំគ្នាដុតលោក ។ ព្រះសញ្ជីវៈនោះ គ្រាចេញចាកសមាបត្តិតាមកំណត់ ឃ្លុំដណ្ដប់ចីវរចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត្រ ។ អាស្រ័យហេតុនោះឯង ជនទាំងឡាយ ទើបស្គាល់លោកថា ព្រះសញ្ជីវៈ ដូច្នេះ ។

បទថា ភិយ្យោសុត្តរំ គឺ ព្រះសាវកឈ្មោះថា **ភិយ្យោសៈ** និង **ឧត្តរៈ** ។ ក្នុងលោកទាំងពីរនោះ ព្រះភិយ្យោសៈជាអ្នកកំពូលលើសដោយបញ្ញា ព្រះឧត្តរៈជាអ្នកកំពូលលើសដោយសមាធិ ។

បទថា តិស្សភារទ្វាជំ គឺ ព្រះសាវកឈ្មោះថា **តិស្សៈ** និង **ភារទ្វាជៈ** ។ ក្នុងលោកទាំងពីរនោះ ព្រះតិស្សៈបានសម្រេចបញ្ញាបារមី ព្រះភារទ្វាជៈបានសម្រេចសមាធិបារមី ។

*បទថា សារីបុត្តមោគ្គល្លានំ គឺ ព្រះសាវកឈ្មោះថា* ***សារីបុត្រ*** *និង* ***មោគ្គល្លាន*** *។ ក្នុងលោកទាំងពីរនោះ ព្រះសារីបុត្របានជាអ្នកកំពូលលើសក្នុងផ្លូវបញ្ញា ព្រះមោគ្គល្លានបានជាអ្នកកំពូលលើសក្នុងផ្លូវសមាធិ ។ នេះឈ្មោះថា កំណត់គូអគ្គសាវក ។*

# កំណាត់ការប្រជុំសាវក

គប្បីជ្រាបវិនិច្ឆ័យក្នុងការកំណត់ការប្រជុំសាវក ។ ការប្រជុំគ្រាដំបូងរបស់ព្រះមានព្រះភាគព្រះនាមថា វិបស្សី បានប្រកបដោយអង្គ ៤ គឺ ភិក្ខុទាំងអស់ជាឯហិភិក្ខុ ភិក្ខុទាំងអស់មានបាត្រ និងចីវរកើតឡើងដោយឫទ្ធិ ។ ភិក្ខុទាំងអស់មិនបានណាត់គ្នាទេ ។ មយ៉ាងទៀត ភិក្ខុទាំងនោះមកប្រជុំគ្នាក្នុងថ្ងៃឧបោសថ ១៥ កើត ។

[៧] លំដាប់នោះ ព្រះសាស្តាប្រថាប់ចាប់ផ្តិត ញ៉ាំងភិក្ខុឲ្យធ្វើឧបោសថ ។ គ្រាទី ២ គ្រាទី ៣ ក៏ន័យនេះឯង ។ ក្នុងការប្រជុំទាំងអស់របស់ព្រះពុទ្ធទាំងឡាយដ៏សេស ក៏ដូច្នោះ ។ ក៏ប៉ុន្តែថា ព្រះមានព្រះភាគរបស់យើងទាំងឡាយ បានធ្វើការប្រជុំក្នុងបឋមពោធិកាលប៉ុណ្ណោះ ព្រោះហេតុអ្វី , ព្រះសូត្រនេះ លោកពោលទុកហើយក្នុងភាគដទៃ ព្រោះដូច្នោះលោកទើបពោលថា **ម្នាលភិក្ខុទាំងឡាយ ការប្រជុំសាវករបស់តថាគតក្នុងឥឡូវនេះ មានតែមួយដង** ដូច្នោះ ការប្រជុំទើបចប់ ។

ក្នុងបទថា អឌ្ឍតេរសានិ ភិក្ខុសតានិ សេចក្តីថា ភិក្ខុ ១.២៥០ រូប គឺ បុរាណជដិល ១.០០០ រូប បរិវារព្រះអគ្គសាវក ២៥០ រូប ។ ក្នុងបណ្តាភិក្ខុទាំងនោះ គួរពោលដល់រឿងតាំងពីអភិនិហាររបស់ព្រះអគ្គ-សាវកទាំងពីរ ហើយសម្តែងដល់ការបព្វជ្ជា ។ មួយទៀត បណ្តាបព្វជិត

ទាំងនោះ ព្រះមហាមោគ្គល្លានសម្រេចព្រះអរហត្តក្នុងថ្ងៃទី ៧ ។ ព្រះ-ធម្មសេនាបតី កាលព្រះមានព្រះភាគ ទ្រង់សម្តែងវេទនាបរិគ្គហសូត្រ ជាធម្មយាគៈ ដែលត្រៀមទុកដល់ទីឃនខបរិព្វាជកជាក្មួយ ក្នុងល្អាងសូករខាតា នាក្នុំគិជ្ឈកូដ ក្នុងថ្ងៃទី ១៥ បញ្ជូនញាណទៅដើម្បីដឹងតាម ដោយវេក ទៅតាមទេសនា បានសម្រេចសាវកបារមីញាណ ។

ព្រះមានព្រះភាគ ជ្រាបដល់ការសម្រេចព្រះអរហត្តរបស់ព្រះថេរៈហើយ ស្តេចយាងតាមអាកាស ទៅប្រាកដក្នុងព្រះវិហារវេឡុវ័ន ។ ព្រះថេរៈរំពឹងថា ព្រះមានព្រះភាគស្តេចយាងទៅណាហ្ន៎ គ្រាជ្រាបសេចក្តីដែលព្រះអង្គប្រតិស្ថាននៅក្នុងព្រះវិហារវេឡុវ័ន សូម្បីលោកខ្លួនឯង ក៏ហោះតាមអាកាស ទៅប្រាកដក្នុងព្រះវិហារវេឡុវ័នដូចគ្នា ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ប្រកាសបាតិមោក្ខ ( ឱវាទបាតិមោក្ខ ) ព្រះមានព្រះភាគ ទ្រង់សំដៅដល់ការប្រជុំនោះ ទើបត្រាស់ថា ភិក្ខុ ១.២៥០ រូប ជាដើម ។ នេះគឺកំណត់ការប្រជុំរបស់ព្រះសាវក ។

## ពណ៌នាកំណត់ឧបដ្ឋាក

[៨] គប្បីជ្រាបវិនិច្ឆ័យ ក្នុងការកំណត់ឧបដ្ឋាកដូចតទៅ ។ ពាក្យថា **ព្រះអានន្ទ** លោកពោលសំដៅដល់ព្រះអានន្ទត្ថេរ ជាឧបដ្ឋាកជាប្រចាំ ។ ព្រោះថា ក្នុងបឋមពោធិកាល ព្រះមានព្រះភាគទ្រង់មានឧបដ្ឋាកមិនប្រចាំ ។ គ្រាខ្លះព្រះនាគសមាលៈកាន់បាត្រ និងចីវរតាមស្ដេច ។ គ្រាខ្លះព្រះនាគិតៈ ។ គ្រាខ្លះព្រះឧបវាណៈ ។ គ្រាខ្លះព្រះសុនក្ខត្តៈ ។ គ្រាខ្លះចុន្ទសមណុទ្ទេសៈ ។ គ្រាខ្លះព្រះសាគតៈ ។ គ្រាខ្លះព្រះមេឃិយៈ ។

ក្នុងបណ្ដាលោកទាំងនោះ គ្រាខ្លះព្រះមានព្រះភាគស្ដេចចារិកផ្លូវឆ្ងាយជាមួយនឹងព្រះនាគសមាលត្ថេរ ស្ដេចដល់ផ្លូវបែកជាពីរ ។ ព្រះថេរៈចៀសចេញចាកផ្លូវ ក្រាបទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គនឹងទៅតាមផ្លូវនេះ ។ ទីនោះ ព្រះមានព្រះភាគត្រាស់នឹងព្រះថេរៈនោះថា មកនេះភិក្ខុ យើងនឹងទៅផ្លូវនេះ ។ ព្រះថេរៈនោះក្រាបទូលថា បពិត្រព្រះមានព្រះភាគ សូមព្រះអង្គទទួលបាត្រ និងចីវររបស់ព្រះអង្គចុះ ខ្ញុំព្រះអង្គនឹងទៅតាមផ្លូវនេះ ហើយក៏ត្រៀមនឹងដាក់បាត្រ និងចីវរចុះលើផែនដី ។ លំដាប់នោះ ព្រះមានព្រះភាគត្រាស់ចំពោះព្រះថេរៈនោះថា នាំមកឲ្យតថាគតចុះភិក្ខុ ទ្រង់ក៏ទទួលបាត្រ និងចីវរ ហើយស្ដេចទៅ ។ កាលភិក្ខុនោះទៅផ្លូវមួយទៀត ពួកចោរប្លន់យកបាត្រ និងចីវរ និងវាយ

សីរសះ ។ ភិក្ខុនោះគិតថា ឥឡូវនេះ ព្រះមានព្រះភាគជាទីពឹងរបស់យើងមិនមានអ្នកដទៃ ហើយបានមកគាល់ព្រះមានព្រះភាគទាំងដែលឈាមហូរ ។ កាលព្រះមានព្រះភាគត្រាស់ថា មានរឿងអ្វីភិក្ខុ ទើបក្រាបទូលរឿងដែលកើតឡើងនោះ ។ លំដាប់នោះ ព្រះមានព្រះភាគត្រាស់នឹងភិក្ខុនោះថា កុំគិតអ្វីឡើយភិក្ខុ យើងហាមអ្នកដល់ហេតុនោះ ហើយទ្រង់លួងលោមភិក្ខុនោះ ។

ក៏ពេលខ្លះ ព្រះមានព្រះភាគស្តេចទៅកាន់ជន្តុគ្រាម ក្នុងវង្សមិគទាយវ័ន នាទិសខាងកើតជាមួយនឹងព្រះមេឃិយត្ថេរ ។ សូម្បីក្នុងទីនោះ ព្រះមេឃិយៈទៅបិណ្ឌបាតក្នុងជន្តុគ្រាម ឃើញព្រៃស្វាយគួររីករាយនៅត្រើយទន្លេ ក្រាបទូលថា បពិត្រព្រះមានព្រះភាគ សូមព្រះអង្គទ្រង់ទទួលបាត្រ និងចីវររបស់ព្រះអង្គចុះ ខ្ញុំព្រះអង្គនឹងបំពេញសមណធម៌នៅឯព្រៃស្វាយនោះ សូម្បីត្រូវព្រះមានព្រះភាគទ្រង់ហាមដល់ ៣ ដង ក៏នៅតែទៅទាល់តែបាន កាលត្រូវអកុសលវិតក្កៈគ្របសង្កត់ ទើបត្រឡប់មកក្រាបទូលហេតុដែលកើតឡើងនោះឲ្យទ្រង់ជ្រាប ។ ព្រះមានព្រះភាគ ត្រាស់ចំពោះព្រះមេឃិយៈថា តថាគតកំណត់ដឹងហេតុនេះដល់អ្នកហើយ បានជាហាមអ្នក ហើយស្តេចយាងទៅកាន់នគរសាវត្ថី ដោយលំដាប់ ។

ក្នុងព្រះនគរសាវត្ថីនោះ ព្រះមានព្រះភាគ ហែហមដោយពួកភិក្ខុប្រថាប់លើពុទ្ធាសនៈដ៏ប្រសើរដែលក្រាលទុកក្នុងបរិវេណគន្ធកុដិ ត្រាស់

ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះតថាគតចាស់ហើយ ភិក្ខុរូបខ្លះកាលតថាគតប្រាប់ថា តថាគតទៅតាមផ្លូវនេះចុះ បានចេញទៅផ្លូវដទៃ រូបខ្លះដាក់បាត្រ និងចីវររបស់តថាគតទុកលើផែនដី ពួកអ្នកចូរជ្រើសរើសភិក្ខុមួយរូប ជាឧបដ្ឋាកឲ្យនៅប្រចាំរបស់តថាគត ។ ភិក្ខុទាំងឡាយ កើតធម្មសង្វេគ លំដាប់នោះ ព្រះសារីបុត្រក្រោកអំពីអាសនៈថ្វាយបង្គំព្រះមានព្រះភាគហើយ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គតាំងសេចក្ដីប្រាថ្នាទុកចំពោះព្រះអង្គ បំពេញបារមីរហូតអស់អសង្ខេយ្យក្រៃលែងដោយសែនកប្ប ធម្មតាឧបដ្ឋាកមានបញ្ញាច្រើន ដូចខ្ញុំព្រះអង្គសមគួរមិនមែនឬ ខ្ញុំព្រះអង្គនឹងឧបដ្ឋាកព្រះអង្គ ដូច្នេះ ។ ព្រះមានព្រះភាគទ្រង់ហាមព្រះសារីបុត្រថា កុំឡើយសារីបុត្រ អ្នកនៅក្នុងទិសណា ទិសនោះមិនទទេទេ ឱវាទរបស់អ្នក ដូចគ្នានឹងឱវាទរបស់ព្រះពុទ្ធទាំងឡាយ អ្នកមិនត្រូវធ្វើនាទីឧបដ្ឋាកតថាគតឡើយ ។ ព្រះមហាសាវក ៨០ រូប ចាប់តាំងពីព្រះមហាមោគ្គល្លានជាដើម បានក្រោកឡើង ដោយទំនងដូចគ្នា ។ ព្រះមានព្រះភាគ ទ្រង់ហាមព្រះសាវកទាំងអស់នោះ ។ តែព្រះអានន្ទត្ថេរអង្គុយនៅស្ងៀម ។

លំដាប់នោះ ភិក្ខុទាំងឡាយពោលនឹងព្រះអានន្ទត្ថេរនោះយ៉ាងនេះថា លោកម្ចាស់អានន្ទ ពួកភិក្ខុក្រាបទូលសូមតំណែងឧបដ្ឋាក សូម្បីលោកក៏ចូរក្រាបទូលសូមខ្លះ ដូច្នេះ ។ ព្រះអានន្ទត្ថេរនោះពោលថា លោកដ៏មាន

អាយុទាំងឡាយ ឈ្មោះថា កិច្ចឧបដ្ឋាក ដែលក្រាបទូលសូមហើយ នឹងបានមកដូចម្តេច ព្រះសាស្តាទ្រង់មិនឃើញឃើងទេឬ បើព្រះអង្គនឹងពេញព្រះទ័យ ទ្រង់នឹងប្រាប់ថា អានន្ទ ចូរឧបដ្ឋាកតថាគត ដូច្នេះ ។ ពេលនោះព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អានន្ទមិនគួរឲ្យអ្នកដទៃបង្ខិតបង្ខំទេ នឹងដឹងដោយខ្លួនឯង ហើយឧបដ្ឋាកតថាគត ។ តអំពីនោះភិក្ខុច្រើនរូបពោលថា ព្រះអានន្ទក្រោកឡើងចុះ ចូរក្រាបទូលសូមតំណែងឧបដ្ឋាកចំពោះព្រះទសពល ។ ព្រះថេរៈ ក្រោកឡើងក្រាបទូលសូមពរ ៨ ប្រការ គឺ ការហាម ៤ ប្រការ ការអនុញ្ញាត ៤ ប្រការ ។

គប្បីជ្រាបការហាម ៤ ប្រការ ។ ព្រះអានន្ទត្ថេរ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ មិនគប្បីប្រទានចីវរដែលប្រណីតដែលព្រះអង្គបាន មកដល់ខ្ញុំព្រះអង្គ , និងមិនប្រទានបិណ្ឌបាត , និងមិនឲ្យនៅក្នុងព្រះគន្ធកុដិជាមួយព្រះអង្គ , ទទួលនិមន្តហើយនឹងមិនទៅរួមជាមួយព្រះអង្គ ដោយប្រការដូច្នេះ ខ្ញុំព្រះអង្គនឹងឧបដ្ឋាកព្រះមានព្រះភាគដូច្នេះ ។ កាលព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ អ្នកឃើញទោសអ្វីក្នុងសេចក្តីនេះ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន បើខ្ញុំព្រះអង្គនឹងបានវត្ថុទាំងនេះ នឹងមានអ្នកពោលដល់ខ្ញុំព្រះអង្គថា ព្រះអានន្ទប្រើចីវរដែលប្រណីតដែលព្រះទសពលបានហើយ ឆាន់បិណ្ឌបាតនៅក្នុងព្រះគន្ធកុដិជាមួយព្រះអង្គ ទៅកាន់ទីនិមន្តរួមជាមួយព្រះអង្គ កាលបានលាភនេះ ទើបឧបដ្ឋាក

ព្រះតថាគត កាលឧបដ្ឋាកយ៉ាងនេះនឹងជូនជូរលំបាកអ្វី ។ ព្រះអានន្ទត្ថេរ ក្រាបទូលសូមការហាម ៤ ប្រការ ទាំងនេះ ។

គប្បីជ្រាបការសូមអនុញ្ញាត ៤ ប្រការ ។ ព្រះអានន្ទត្ថេរ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន បើព្រះមានព្រះភាគស្តេចនឹងទៅកាន់ទីនិមន្ត ខ្ញុំព្រះអង្គទទួលទុក , បើខ្ញុំព្រះអង្គនឹងបានគាល់ព្រះមានព្រះភាគក្នុងខណៈ ដែលបរិស័ទមកពីខាងក្រៅដែន ខាងក្រៅជនបទ ដើម្បីគាល់ព្រះមានព្រះភាគ មកដល់ហើយ , ខណៈណាសេចក្តីសង្ស័យកើតឡើងដល់ខ្ញុំព្រះអង្គ ខណៈ នោះ ខ្ញុំព្រះអង្គនឹងបានចូលគាល់ព្រះមានព្រះភាគ , ព្រះមានព្រះភាគទ្រង់ សម្តែងធម៌ណាកំបាំងពីខ្ញុំព្រះអង្គ គ្រាស្តេចត្រឡប់មកហើយ នឹងទ្រង់ សម្តែងធម៌នោះដល់ខ្ញុំព្រះអង្គ , ដោយប្រការដូច្នេះ ខ្ញុំព្រះអង្គនឹងឧបដ្ឋាក ព្រះមានព្រះភាគ ដូច្នេះ ។ កាលព្រះមានព្រះភាគ ត្រាស់ថា អានន្ទ អ្នក ឃើញអានិសង្សអ្វីក្នុងសេចក្តីនេះ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន កុលបុត្រទាំងឡាយអ្នកមានសទ្ធា ក្នុងព្រះសាសនានេះ កាលមិនបានឱកាស អំពីព្រះមានព្រះភាគ រមែងពោលនឹងខ្ញុំព្រះអង្គយ៉ាងនេះថា បពិត្រព្រះអានន្ទ ថ្ងៃស្អែកនេះមេត្តាទទួលភិក្ខាក្នុងផ្ទះរបស់ពួកខ្ញុំ ព្រមដោយព្រះមានព្រះភាគ ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើនបើថា ព្រះមានព្រះភាគស្តេចនឹងមិនទៅក្នុង ទីនោះ ខ្ញុំព្រះករុណានឹងមិនបានឱកាស ដើម្បីចង់លបង្ហាញចំពោះបរិស័ទ ក្នុងខណៈ ដែលគេប្រាថ្នាដើម្បីបន្ទោបង់សេចក្តីសង្ស័យ នឹងមានអ្នកពោលថា

យ៉ាងដូចម្តេច ព្រះអានន្ទឧបដ្ឋាកព្រះទសពល សូម្បីយ៉ាងនោះ ព្រះមានព្រះភាគក៏ទ្រង់មិនធ្វើការអនុគ្រោះដល់ព្រះអានន្ទ ដូច្នេះ មួយវិញទៀត ជនទាំងឡាយនឹងសួរខ្ញុំព្រះអង្គ កំបាំងពីព្រះមានព្រះភាគថា បពិត្រព្រះអានន្ទ ព្រះមានព្រះភាគទ្រង់សម្តែង គាថានេះ សូត្រនេះ ជាតកនេះ ក្នុងទីណា ដូច្នេះបើខ្ញុំព្រះអង្គនឹងចង្អុលបង្ហាញសេចក្តីនោះមិនបាន នឹងមានអ្នកពោលថា សូម្បីយ៉ាងនេះ លោកក៏មិនទាន់ដឹង លោកមិនលះព្រះមានព្រះភាគដូចស្រមោលត្រាច់ទៅរហូតអស់កាលយូរ ព្រោះហេតុអ្វីដូច្នេះ ដោយហេតុនោះ ខ្ញុំព្រះអង្គប្រាថ្នា នឹងពោលធម៌ សូម្បីដែលព្រះអង្គទ្រង់សម្តែងក្នុងទីកំបាំងម្តងទៀត ។ ព្រះអានន្ទក្រាបទូលសូមការអនុញ្ញាត ៤ ប្រការនេះ ។

សូម្បីព្រះមានព្រះភាគ ក៏ទ្រង់ប្រទានដល់ព្រះអានន្ទនោះ ។ ព្រះអានន្ទ គ្រាទទួលពរ ៨ ប្រការទាំងនេះហើយ ក៏បានជាឧបដ្ឋាកជាប្រចាំដោយប្រការដូច្នេះ ។ ព្រះអានន្ទ សម្រេចផលនៃបារមីដែលបំពេញមករហូតដល់អស់សែនកប្បដើម្បីតំណែងនោះ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ ភិក្ខុអានន្ទជាឧបដ្ឋាករបស់តថាគត បានជាឧបដ្ឋាកដ៏កំពូលលើស ដូច្នេះ ។ សំដៅដល់សកាពដែលព្រះអានន្ទនេះជាឧបដ្ឋាកប្រចាំនោះ ។ នេះជាការកំណត់ឧបដ្ឋាក ។

[៩] ការកំណត់បិតាមានសេចក្តីងាយហើយ ។

បទថា វិហារំ បាវិសិ សេចក្តីថា ព្រះមានព្រះភាគស្តេចចូលទៅ

កាន់វិហារ ព្រោះហេតុអ្វី ន័យថា ព្រះមានព្រះភាគត្រាស់ដូច្នោះហើយ ទ្រង់ត្រិះរិះថា តថាគតសម្រេចដល់ទីបំផុត ដែលរកចន្លោះមិនបានហើយ មិនទាន់បានពោលដល់វង្សរបស់ព្រះពុទ្ធទាំងឡាយ ៧ ព្រះអង្គឡើយ ក៏កាល តថាគតចូលទៅកាន់វិហារ ភិក្ខុទាំងនេះបានប្រារព្ធដល់បុព្វេនិវាសញ្ញាណ ដោយប្រមាណដ៏ក្រៃលែង ហើយនឹងពោលដល់គុណ បើដូច្នោះ តថាគត នឹងពោលដល់ពុទ្ធវង្សដែលរកចន្លោះមិនបាន ឲ្យភិក្ខុទាំងឡាយសម្រេចដល់ ទីបំផុតហើយ នឹងសម្តែងដូច្នេះ ទ្រង់ឲ្យឱកាសភិក្ខុទាំងឡាយសន្ទនាគ្នា ទើបស្តេចក្រោកចាកអាសនៈចូលកាន់ព្រះវិហារ ។ ព្រះមានព្រះភាគត្រាស់ កំណត់យ៉ាងណាទុក ៩ វារៈទាំងនេះ មកហើយក្នុងការកំណត់នោះ គឺ កំណត់កប្ប កំណត់ជាតិ កំណត់គោត្រ កំណត់អាយុ កំណត់ការត្រាស់ដឹង កំណត់គូសាវក កំណត់ការប្រជុំសាវក កំណត់ឧបដ្ឋាក កំណត់បិតា ។ វារៈច្រើនយ៉ាង មិនទាន់មកដល់ តែនឹងនាំមកសម្តែង ។

ពិតហើយ កាលបុត្រសមគួរដល់ត្រកូល និងវង្សមួយរបស់ព្រះ-ពោធិសត្វទាំងឡាយកើតហើយ គួរចេញបួស នេះឯងជាវង្ស នេះជាប្រពៃណី ។ សួរថា ព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះថា តាំងពីការយាង ចុះកាន់គភ៌នៃមាតារបស់ព្រះពោធិសត្វ ដែលជាព្រះសព្វញ្ញូទាំងឡាយ មាន បាដិហារ្យច្រើនយ៉ាង ដូចបានពោលហើយក្នុងខាងដើម ប្រសិនបើថា ក្រុង កើតបិតាមាតា ភរិយាបុត្ររបស់ព្រះពោធិសត្វទាំងនោះ មិនគប្បីប្រាកដ

ក្រុងកើតបិតាបុត្ររបស់បុគ្គលនេះ ក៏មិនប្រាកដ ។

អ្នកនេះប្រាកដជាទេវតា ស្តេចសក្កៈ មារ ឬព្រហ្ម និងសម្គាល់ថា បាដិហារ្យដូច្នេះ របស់ទេវតាទាំងឡាយមិនគួរអស្ចារ្យ គប្បីសម្គាល់ដល់បាដិហារ្យដែលមិនគួរស្តាប់ មិនគួរជឿ ។ តអំពីនោះ ការត្រាស់ដឹងមិនគប្បីមាន កាលមិនមានការត្រាស់ដឹង ការឧប្បត្តិរបស់ព្រះពុទ្ធក៏មិនមានប្រយោជន៍ ពាក្យទូន្មានក៏មិននាំឲ្យរួចផុតចាកទុក្ខ ព្រោះដូច្នោះ កាលបុត្រសមគួរដល់ត្រកូល និងវង្សរបស់ព្រះពោធិសត្វទាំងឡាយកើត គួរចេញបួស នេះឯងជាវង្ស នេះជាប្រពៃណី ។ ព្រោះដូច្នោះ គួរនាំវារៈច្រើនយ៉ាងមកសម្តែងដោយអំណាចនៃបុត្រជាដើម ។

ក្នុងសម្ពហុលវារៈ គប្បីជ្រាប បុត្រទាំង ៧ តាមលំដាប់របស់ព្រះពុទ្ធ ៧ ព្រះអង្គ ទាំងនេះមុន គឺ សមវត្តក្ខន្ធៈ អតុលៈ សុប្បពុទ្ធៈ ឧត្តរៈ សត្ថវាហៈ វិជិតសេនៈ រាហុល ជាទី ៧ , ក្នុងបណ្តាបុត្រទាំងនោះ កាលរាហុលប្រសូត ពួករាជបុរសនាំសំបុត្រប្រាប់ដំណឹង មកដាក់លើព្រះហស្តរបស់ព្រះមហាបុរស ។ លំដាប់នោះ សេចក្តីស្នេហាក្នុងព្រះឱរសធ្វើឲ្យព្រះវរកាយគ្រប់ចំណែករបស់ព្រះមហាបុរសជ្រួតជ្រាប ។ ព្រះមហាបុរសត្រិះរិះថា កាលបុត្រកើតត្រឹមតែមួយនាក់ សេចក្តីស្នេហាក្នុងបុត្រកើតមានប្រាកដដល់ត្រឹមនេះ បើយើងនឹងមានបុត្រជាង ១.០០០ នាក់ ក្នុងបុត្រទាំងនោះ សូម្បីម្នាក់ កើតនូវចំណងដោយស្នេហាបន្ថែមច្រើនឡើង

យ៉ាងនេះ បេះដូងពិតជាបែកធ្លាយមិនខាន ព្រោះហេតុនោះ ព្រះអង្គទើបត្រាស់ថា កន្ទួល់កើតហើយ ចំណងកើតហើយ ។ ក្នុងថ្ងៃនោះឯង ព្រះ-មហាបុរសទ្រង់លះបង់រាជសម្បត្តិ ទ្រង់ចេញព្រះផ្នួស ។ ក្នុងការកើតបុត្ររបស់ព្រះពោធិសត្វគ្រប់អង្គ មានន័យនេះឯង នេះការកំណត់បុត្រ ។

បុត្រសូម្បីទាំង ៧ នោះ មានមាតាទាំងនេះ គឺ ព្រះនាងសុត្តនា ព្រះនាងសព្វកាមា ព្រះនាងសុចិត្តា ព្រះនាងរោចនី ព្រះនាងរុច្ចគិនី ព្រះនាងសុនន្ទា និងព្រះនាងពិម្ពាជាអង្គទី ៧ ។ ក៏ព្រះនាងពិម្ពាទេវី កាលរាហុលកុមារប្រសូត បានប្រាកដឈ្មោះថា រាហុលមាតា ។ នេះការកំណត់ករិយា ។

ក៏ព្រះពោធិសត្វ ២ អង្គនេះ គឺ ព្រះវិបស្សី ព្រះកកុសន្ធៈ ស្ដេចឡើងរថ ទឹមដោយសេះអាជានេយ្យ ស្ដេចចេញមហាភិនេស្រ្កមណ៍ ។ ព្រះពោធិសត្វ ២ អង្គ គឺ ព្រះសិខី ព្រះកោនាគមនៈ ប្រថាប់លើកដំរីដ៏ប្រសើរ ទ្រង់ចេញព្រះផ្នួស ។ ព្រះវេស្សភូពោធិសត្វប្រថាប់លើអង្រឹងមាសទ្រង់ចេញព្រះផ្នួស ។ ព្រះកស្សបៈ ប្រថាប់លើផ្ទៃមហាប្រាសាទ ញុំាំងអានាបានចតុត្ថឈានឲ្យកើត ចេញចាកឈានហើយ ធ្វើឈាននោះឲ្យជាបាទ ទ្រង់អធិដ្ឋានថា ប្រាសាទចូរទៅធ្លាក់ចុះក្នុងពោធិមណ្ឌល ប្រាសាទក៏ទៅផ្លូវអាកាស ហើយធ្លាក់ចុះក្នុងពោធិមណ្ឌល ។ សូម្បីព្រះមហាបុរសចុះអំពីប្រាសាទនោះ ប្រថាប់លើផែនដីទ្រង់អធិដ្ឋានថា ប្រាសាទចូរទៅ

តាំងនៅក្នុងទីដើម ។ ប្រាសាទនោះ ក៏ទៅតាំងនៅក្នុងទីដើម ។ សូម្បីព្រះមហាបុរស ក៏ទ្រង់ប្រកបសេចក្ដីព្យាយាមរហូតដល់អស់ ៧ ថ្ងៃ ប្រថាប់ក្នុងពោធិបល្ល័ង្ក បានត្រាស់ដឹងព្រះសព្វញ្ញុតញ្ញាណ ។ ក៏ព្រះពោធិសត្វរបស់យើងទាំងឡាយ ស្ដេចប្រថាប់នឹងសេះកណ្ឋកៈ ទ្រង់ចេញព្រះផ្នួស ។ នេះជាការកំណត់យាន ។

វិហាររបស់ព្រះមានព្រះភាគព្រះនាមថា វិបស្សី តាំងនៅក្នុងស្ថានទីប្រមាណមួយយោជន៍ ។ របស់ព្រះសិខី ៣ គាវុត ។ របស់ព្រះវេស្សភូកន្លះយោជន៍ របស់ព្រះកកុសន្ធៈមួយគាវុត របស់ព្រះកោនាគមនៈ កន្លះគាវុត របស់ព្រះកស្សបៈ ២០ ឧសភៈ ។ វិហាររបស់ព្រះមានព្រះភាគរបស់យើងតាំងនៅក្នុងស្ថានទី ១៦ ករីសៈ ដោយវត្តតាមប្រក្រតី ៨ ករីសៈដោយវត្តរបស់ហ្លួង ។ នេះជាការកំណត់ព្រះវិហារ ។

សេដ្ឋីទាំងឡាយឲ្យជាងធ្វើឥដ្ឋមាស បណ្ដោយ ១ ហត្ថ ទទឹង ១ ចំអាម ខ្ពស់ ៨ ធ្នាប់ ក្រាលដោយចំណែកទទឹង ហើយទិញស្ថានទីនៅថ្វាយចំពោះព្រះមានព្រះភាគព្រះនាមថា វិបស្សី ។ ក្រាលដោយផាលឈើ សសរមាស ទិញថ្វាយដល់ព្រះមានព្រះភាគព្រះនាមថា សិខី ។ ឲ្យជាងធ្វើជើងដំរីមាសក្រាលដោយទទឹង ទិញថ្វាយព្រះមានព្រះភាគព្រះនាមថា វេស្សភូ ។ ក្រាលដោយឥដ្ឋមាស តាមន័យដែលពោលហើយ ទិញថ្វាយព្រះមានព្រះភាគព្រះនាមថា កកុសន្ធៈ ។ ក្រាលដោយអណ្ដើកមាស

តាមន័យដែលពោលហើយ ទិញថ្វាយចំពោះព្រះមានព្រះភាគ ព្រះនាមថា កោនាគមនៈ ។ ក្រាលដោយមាសដុំ ទិញថ្វាយចំពោះព្រះមានព្រះភាគ ព្រះនាមថា កស្សបៈ ។ និងក្រាលដោយទទឹងនៃកហាបណៈ ដែលជាគ្រឿងសំគាល់ ទិញថ្វាយចំពោះព្រះមានព្រះភាគរបស់យើងទាំងឡាយ ។ នេះជាកំណត់ក្នុងការកាន់យកផ្ទៃដីសាងវិហារ ។

ឧបដ្ឋាកដែលទិញដីសាងវិហារថ្វាយចំពោះព្រះមានព្រះភាគ ព្រះ-នាមថា វិបស្សី ឈ្មោះ បុនព្វសុមត្តៈ ។ ថ្វាយព្រះមានព្រះភាគព្រះនាមថា សិខី ឈ្មោះ សិរីវឌ្ឍ ។ ថ្វាយព្រះវេស្សភូ ឈ្មោះ សោត្ថិយៈ ។ ថ្វាយព្រះកកុសន្ធៈ ឈ្មោះ អច្ចុតៈ ។ ថ្វាយព្រះកោនាគមនៈ ឈ្មោះ ឧគ្គៈ ។ ថ្វាយព្រះកស្សបៈ ឈ្មោះ សុមនៈ ។ ថ្វាយព្រះមានព្រះភាគរបស់យើងទាំងឡាយ ឈ្មោះ សុទត្តៈ ។ ក៏ឧបដ្ឋាកទាំងអស់នោះ បានជាសេដ្ឋីគហបតីមហាសាល ។ នេះកំណត់ឧបដ្ឋាក ។

នៅមានស្ថានទីដទៃទៀត ៤ កន្លែង ។ ដែលជាស្ថានទីដែលនឹងវៀរចេញមិនបាន គឺ ពោធិបល្ល័ង្ករបស់ព្រះពុទ្ធទាំងឡាយ វៀរមិនបានរមែងមានក្នុងទីតែមួយប៉ុណ្ណោះ ។ ការសម្តែងព្រះធម្មចក្រក្នុងព្រៃឥសិ-បតនមិគទាយវ័ន វៀរមិនបានឡើយ ។ ការប្រតិស្ថានព្រះបាទគ្រាដំបូងត្រង់ទ្វារនគរសង្កស្សៈ ពេលស្តេចចុះចាកទេវលោក វៀរមិនបានឡើយ ។ ទីតាំងជើងគ្រែ ៤ ក្នុងព្រះគន្ធកុដិ ក្នុងជេតវ័នមហាវិហារវៀរមិនបាន ។

ក៏ប៉ុន្តែថា វិហារមានតូចខ្លះធំខ្លះ ។ សូម្បីវិហារ ក៏វៀរមិនបាន ។ តែនគរ វៀរបាន ។ កាលណានគរនៅផ្នែកខាងកើត កាលនោះវិហារនៅផ្នែកខាងលិច ។ កាលណានគរនៅផ្នែកខាងត្បូង កាលនោះវិហារនៅផ្នែកខាងជើង ។ កាលណានគរនៅផ្នែកខាងលិច កាលនោះ វិហារនៅផ្នែកខាងកើត ។ កាលណានគរនៅផ្នែកខាងជើង កាលនោះ វិហារនៅផ្នែកខាងត្បូង ។ ក៏ឥឡូវនេះ នគរនៅផ្នែកខាងជើង វិហារនៅផ្នែកខាងត្បូង ។

ម្យ៉ាងទៀត ព្រះពុទ្ធគ្រប់ព្រះអង្គមានសេចក្តីផ្សេងគ្នា ៥ យ៉ាង គឺ ផ្សេងគ្នាដោយអាយុ ផ្សេងគ្នាដោយកម្ពស់ ផ្សេងគ្នាដោយត្រកូល ផ្សេងគ្នាដោយសេចក្តីព្យាយាម ផ្សេងគ្នាដោយរស្មី ។

ព្រះពុទ្ធខ្លះព្រះអង្គមានព្រះជន្មាយុវែង ព្រះអង្គខ្លះមានព្រះជន្មាយុខ្លី ឈ្មោះថា ផ្សេងគ្នាដោយអាយុ ។ ពិតយ៉ាងនោះ ព្រះពុទ្ធព្រះនាមថា ទីបង្ករ មានព្រះជន្មាយុប្រមាណមួយសែនឆ្នាំ ។ ព្រះមានព្រះភាគរបស់ពួកយើង មានព្រះជន្មាយុប្រមាណ ១០០ ឆ្នាំ ។ ព្រះពុទ្ធខ្លះមានព្រះកាយខ្ពស់ ខ្លះមានព្រះកាយទាប ឈ្មោះថា ផ្សេងគ្នាដោយប្រមាណ ។ ការពិតនោះ ព្រះទីបង្ករកម្ពស់ ៨០ ហត្ថ , ព្រះសុមនៈកម្ពស់ ៩០ ហត្ថ , តែព្រះមានព្រះភាគរបស់យើងទាំងឡាយ កម្ពស់ ១៨ ហត្ថ ។ ព្រះអង្គខ្លះទ្រង់ឧប្បត្តិក្នុងត្រកូលក្សត្រិយ៍ ព្រះអង្គខ្លះ ទ្រង់ឧប្បត្តិក្នុងត្រកូលព្រាហ្មណ៍ ឈ្មោះថា ផ្សេងគ្នាដោយត្រកូល ។ សេចក្តីព្យាយាមរបស់ព្រះអង្គខ្លះ មាន

វេលាខ្លី ដូចព្រះមានព្រះភាគព្រះនាមថា កស្សបៈ , ព្រះអង្គខ្លះ ព្យាយាមយូរ ដូចព្រះមានព្រះភាគរបស់យើងទាំងឡាយ ឈ្មោះថា ផ្សេងគ្នាដោយសេចក្ដីព្យាយាម ។ ព្រះរស្មីចេញអំពីព្រះវរកាយរបស់ព្រះមានព្រះភាគព្រះនាមថា សុមង្គលៈ ប្រមាណមួយម៉ឺនលោកធាតុ ។ របស់ព្រះមានព្រះភាគរបស់យើងប្រមាណមួយព្យាមដោយជុំវិញ ឈ្មោះថា ផ្សេងគ្នាដោយរស្មី ។

ក្នុងសេចក្ដីផ្សេងគ្នានោះ ផ្សេងគ្នាដោយរស្មី ជាប់ទាក់ទងនឹងព្រះពុទ្ធបំណង ។ ព្រះពុទ្ធអង្គណា ទ្រង់មានព្រះបំណងប៉ុនណា រស្មីចាកព្រះវរកាយរបស់ព្រះពុទ្ធអង្គនោះ រមែងផ្សាយទៅប៉ុណ្ណោះ ។ រស្មីចាកព្រះវរកាយរបស់ព្រះមានព្រះភាគព្រះនាមថា សុមង្គលៈ រមែងផ្សាយទៅម៉ឺនលោកធាតុជានិច្ច ដូច្នេះ បានដោយព្រះពុទ្ធបំណង ។ តែឈ្មោះថា សេចក្ដីផ្សេងគ្នាក្នុងគុណ គឺ ការត្រាស់ដឹង មិនមាន ។ បុរាណបណ្ឌិតសម្ដែងរឿងដទៃទៀតដូចជាកំណត់សហជាតិ និងកំណត់នក្ខត្តរបស់ព្រះមានព្រះភាគនៃយើងទាំងឡាយ ។

## ការកំណត់បុគ្គល និងវត្ថុ

បុគ្គល និងវត្ថុដែលកើតព្រមនឹងព្រះសព្វញ្ញូពោធិសត្វទាំង ៧ នេះ គឺ រាហុលមាតា ព្រះអានន្ទត្ថេរ ព្រះឆន្ន: សេះកណ្ឋក: ឆ្នាំងកំណប់ទ្រព្យ ដើមមហាពោធិ ព្រះកាឡុទាយី ។ ម្យ៉ាងទៀត ព្រះមហាបុរសទ្រង់បដិសន្ធិក្នុងព្រះគភ៌របស់ព្រះមាតា ស្តេចចេញមហាភិនេស្រ្កមណ៍ ទ្រង់សម្តែងព្រះធម្មចក្រ ទ្រង់សម្តែងយមកប្បាដិហារ្យក្នុងឫក្សឧត្តរាសាឡ្ហ:[១] ប្រសូតត្រាស់ដឹង និងបរិនិព្វាន ដោយឫក្សវិសាខ: ។

ប្រជុំព្រះសាវក និងទ្រង់ដាក់អាយុសង្ខារ ដោយឫក្សមាឃ: ។

ស្តេចចុះចាកទេវលោក ដោយឫក្សអសយុជ: គប្បីនាំមកសម្តែងត្រឹមតែប៉ុណ្ណេះ ។ នេះការកំណត់ច្រើនវារ: ។

[១០] ឥឡូវនេះ គប្បីជ្រាបសេចក្តីក្នុងបទថា អថខោ តេសំ ភិក្ខូនំ ជាដើម ភិក្ខុទាំងនោះ កើតសេចក្តីចម្លែកចិត្តក្រៃលែងណាស់ថា លោកដ៏មានអាយុ ព្រះមានព្រះភាគទ្រង់ពោលដល់ការចូលកាន់បដិសន្ធិ តាំងពីចុតិការបញ្ជូនញាណបញ្ច្រាស់ថយក្រោយ តាំងពីបដិសន្ធិទៅដល់ចុតិ ដែលជាផ្លូវនៃបុព្វេនិវាសសេចក្តីនេះអស្ចារ្យណាស់ ដូចទ្រង់ចង្អុលស្នាមជើងក្នុងអាកាស ហើយទើបពោលថា ម្នាលអ្នកមានអាយុទាំងឡាយ គួរអស្ចារ្យ

---

១-ឈ្មោះនក្សត្រទី ២១ , ទុតិយាសាឍ

ណាស់ កាលនឹងសម្តែងហេតុសូម្បីដទៃទៀត ទើបពោលថា យត្រ ហិ នាម តថាគតោ ដូច្នេះ ។

បទថា យត្រ ហិ នាម ជានិបាតប្រើក្នុងសេចក្តីថា គួរអស្ចារ្យ ។ អធិប្បាយថា ព្រះតថាគត ព្រះអង្គណាហ្ន៎ ។ ក្នុងបទថា ឆិន្នបបញ្ចេ នេះ សេចក្តីថា កិលេសទាំង ៣ យ៉ាងនេះ គឺ តណ្ហា មានះ ទិដ្ឋិ ឈ្មោះថា ធម៌ធ្វើឲ្យយឺតយូរ ។ បទថា ឆិន្នវដុមេ នេះ លោកពោលវដ្ដៈ គឺ កុសល-កម្ម និងអកុសលកម្មថា វដុម ។ បទថា បរិយាទិន្នវដ្ដេ ជាវេវចនៈ របស់បទថា ឆិន្នវដុមេ នោះឯង ។ អធិប្បាយថា គ្របសង្កត់វដ្ដៈ គឺ កម្ម ទាំងអស់បានហើយ ។ បទថា សព្វទុក្ខវីតិវត្តេ បានដល់ កន្លងទុក្ខ ពោលគឺ វិបាកវដ្ដៈទាំងអស់ ។

បទថា អនុស្សរិស្សតិ នេះ ជាពាក្យពោលដល់អនាគត ដោយអំណាចនៃនិបាតថា យត្រហិ ដូច្នេះ ។ ក៏ក្នុងបទនេះ គប្បីជ្រាបការអធិ-ប្បាយដោយអំណាចនៃអតីត ។ ពិតណាស់ ព្រះដ៏មានព្រះភាគទ្រង់រឭកដល់ព្រះពុទ្ធទាំងឡាយនោះហើយ មិនមែននឹងរឭកដល់ក្នុងកាលឥឡូវនេះ ។

បទថា ឯវំសីលា សេចក្តីថា មានសីលយ៉ាងនេះ ដោយមគ្គសីល ផលសីល លោកិយសីល លោកុត្តរសីល ។ បទថា ឯវំធម្មា សេចក្តីថា ធម៌ជាចំណែកសមាធិនុ៎ះឯង លោកប្រាថ្នាក្នុងបទនេះ ។ អធិប្បាយថា មានសមាធិយ៉ាងនេះ ដោយមគ្គសមាធិ ផលសមាធិ លោកិយសមាធិ

លោកុត្តរសមាធិ ។ បទថា ឯវំបញ្ញា សេចក្តីថា មានបញ្ញាយ៉ាងនេះ ដោយអំណាចនៃមគ្គប្បញ្ញាជាដើម ។

បទថា ឯវំវិហារី អធិប្បាយថា បើមានបញ្ហាថា ក៏ក្នុងបទនេះ ព្រោះធម៌ចំណែកសមាធិ លោកកាន់យកក្នុងខាងក្រោយ ជាការកាន់យក វិហារធម៌ផង ព្រោះហេតុអ្វី ទើបកាន់យកធម៌ដែលកាន់យកហើយ ទៀត ហ្ន៎ ។ ឆ្លើយថា នេះមិនមែនជាការកាន់យក ។ ព្រោះបទនេះ ទ្រង់ត្រាស់ ដើម្បីសម្តែងដល់និរោធសមាបត្តិ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគទាំង ឡាយ មានធម៌ជាគ្រឿងនៅ គឺ និរោធសមាបត្តិ គប្បីជ្រាបសេចក្តីក្នុងបទ នេះ យ៉ាងនេះ ។

បទថា ឯវំ វិមុត្តា សេចក្តីថា ការរួចផុតក្នុងបទនេះមាន ៥ យ៉ាង គឺ រួចផុតដោយគ្របសង្កត់ ( វិក្ខម្ភនវិមុត្តិ ) រួចផុតដោយខណៈ (តទង្គ- វិមុត្តិ ) រួចផុតដោយដាច់ខាត ( សមុច្ឆេទវិមុត្តិ ) រួចផុតដោយការស្ងប់ ( បដិបស្សទ្ធិវិមុត្តិ ) រួចផុតដោយការរលាស់ចេញ ( និស្សរណវិមុត្តិ ) ។

ក្នុងវិមុត្តិទាំងនោះ សមាបត្តិ ៨ ចាត់ជាវិក្ខម្ភនវិមុត្តិ ព្រោះរួចផុត ចាកនីវរណៈជាដើម ដែលគ្របសង្កត់បាន ។ អនុបស្សនា ៧ មានអនិ- ច្ចានុបស្សនាជាដើម ចាត់ជាតទង្គវិមុត្តិ ព្រោះកំណត់ដោយអំណាចជាសត្រូវ របស់ធម៌នោះៗ ឯង ព្រោះរួចផុតចាកនិច្ចសញ្ញាជាដើមទាំងនោះ ។ អរិយ- មគ្គ ៤ ចាត់ជាសមុច្ឆេទវិមុត្តិ ព្រោះរួចផុតចាកកិលេសដោយកាត់ដាច់

ហើយ ។ សាមញ្ញផល ៤ ចាត់ជាបដិបស្សទ្ធិវិមុត្តិ ព្រោះកើតឡើងក្នុងទីបំផុតនៃការស្ងប់កិលេសដោយអានុភាពមគ្គ ។ និព្វាន ចាត់ជានិស្សរណ-វិមុត្តិ ព្រោះរួចផុត គឺ ព្រោះប្រាសចាក គឺ ព្រោះតាំងនៅឆ្ងាយចាកកិលេសទាំងពួង ព្រោះហេតុនោះ គប្បីជ្រាបសេចក្តីក្នុងបទនេះថា រួចផុតហើយយ៉ាងនេះ ដោយអំណាចនៃវិមុត្តិ ៥ ទាំងនេះ ។

[១១] បទថា បដិសល្លានា វុដ្ឋិតោ សេចក្តីថា ព្រះមានព្រះភាគស្តេចចេញអំពីភាពជាអ្នកប្រថាប់នៅតែមួយព្រះអង្គ ។ សួរថា បន្តជាប់គ្នាយ៉ាងណា អំពីបទថា ឥតោ សោ ភិក្ខវេ ដូច្នេះ ។ ឆ្លើយថា ក៏ព្រះសូត្រនេះ ព្រះមានព្រះភាគទ្រង់ផ្តើមដោយពីរបទទាំងនេះថា ៖

**ម្នាលភិក្ខុទាំងឡាយ តថាគតបានត្រាស់ដឹងធម្មធាតុនេះ និងថា សូម្បីពួកទេព ក៏នាំគ្នាក្រាបទូលសេចក្តីនេះដល់តថាគត ដូច្នេះ ។**

ក្នុងបទទាំងពីរនោះ ព្រះមានព្រះភាគ ទ្រង់សម្តែងបទក្រាបទូលរបស់ទេវតានឹងពិចារណាដល់កោលាហលរបស់ទេវចារិក ក្នុងពេលចប់ព្រះសូត្រ ។ ព្រះមានព្រះភាគទ្រង់ប្រារព្ធទេសនានេះ ដោយអំណាចការបន្តជាប់គ្នាអំពីបទធម្មធាតុ ។

ក្នុងបទទាំងនោះ គប្បីជ្រាបបទ ១១ បទ ជាដើមថា ខត្តិយោ ជាតិយា ដោយន័យដែលពោលទុកហើយក្នុងនិទានកណ្ឌ ។

[១២] បទថា វិបស្សី ក្នុងបទជាដើមថា ម្នាលភិក្ខុទាំងឡាយ ព្រះពោធិសត្វព្រះនាមថា វិបស្សី ជាឈ្មោះរបស់ព្រះពោធិសត្វអង្គនោះ ។ ម្យ៉ាងទៀត លោកបានឈ្មោះនោះ ព្រោះជាអ្នកឆ្លាតក្នុងការឃើញសេចក្តីច្រើនយ៉ាង ។

បទថា ពោធិសត្តោ គឺ សត្វអ្នកឆ្លាត សត្វអ្នកត្រាស់ដឹង , ម្យ៉ាងទៀត សត្វអ្នកបួលចិត្ត គឺ មានការជាក់ចិត្តនៅក្នុងមគ្គ ៤ ពោលគឺ ពោធិ ឈ្មោះថា ពោធិសត្វ ។ ក្នុងបទថា សតោ សម្បជានោ នេះ បទថា សតោ គឺ ស្មារតីនុ៎ះឯង ។ បទថា សម្បជានោ គឺ ញាណ អធិប្បាយថា ព្រះពោធិសត្វទ្រង់ធ្វើសតិឲ្យតាំងមាំ កំណត់ដោយញាណ ស្តេចចុះកាន់ព្រះគភ៌របស់ព្រះមាតា ។

[១៣] បទថា ឱក្កមិ លោកសម្តែងសេចក្តីដែលព្រះពោធិសត្វស្តេចចុះ ដោយបទនេះ ក្នុងបាលីមិនបានសម្តែងដល់លំដាប់នៃការឈានចុះ ក៏ព្រោះលំដាប់នៃការឈានចុះនោះ លោកលើកឡើងកាន់អដ្ឋកថាដូច្នោះគប្បីជ្រាបយ៉ាងនេះ ។

ពិតណាស់ ព្រះពោធិសត្វគ្រប់ព្រះអង្គ ទ្រង់បំពេញបារមី ៣០ ទស ទ្រង់បរិច្ចាគ មហាបរិច្ចាគ ៥ ទ្រង់សម្រេចនូវទីបំផុតនៃញាតត្ថចរិយា លោកត្ថចរិយា ពុទ្ធចរិយា ទ្រង់តាំងនៅក្នុងអត្តភាពទី ៣ ដូចព្រះវេស្សន្តរ ទ្រង់ឲ្យមហាទាន ៧ លើក ទ្រង់ញាំងផែនដីឲ្យញាប់ញ័រ ៧ លើក ទ្រង់

ធ្វើកាលៈហើយ ទ្រង់ឧប្បត្តិក្នុងតុសិតភព ក្នុងវារៈនៃចិត្តទី ២ ។ សូម្បីព្រះពោធិសត្វព្រះនាមថា វិបស្សី ក៏ទ្រង់ធ្វើកាលៈដូចយ៉ាងនោះ ទ្រង់ឧប្បត្តិក្នុងសួគ៌ជាន់តុសិត ទ្រង់ប្រតិស្ឋាននៅក្នុងសួគ៌ជាន់តុសិតនោះ រហូត ៥៧ កោដិឆ្នាំ ក្រៃលែងដោយ ៦ លានឆ្នាំ ។ ក៏ក្នុងកាលដទៃ ព្រះពោធិ-សត្វទាំងឡាយ ទ្រង់ឧប្បត្តិក្នុងទេវលោក ដែលសត្វមានអាយុវែង រមែងមិនតាំងនៅដរាបគ្រប់អាយុនោះ ។ ព្រោះហេតុអ្វី ។ ព្រោះធ្វើបារមីឲ្យពេញបានលំបាកក្នុងទីនោះ ។ ព្រះពោធិសត្វទាំងនោះ ធ្វើអធិមុត្តកាល-កិរិយា ទើបកើតក្នុងភូមិរបស់មនុស្សនោះឯង ។ ក៏បារមីទាំងឡាយរបស់ព្រះវិបស្សីពោធិសត្វនោះ អាចនឹងញ៉ាំងព្រះសព្វញ្ញុតញ្ញាណ ឲ្យកើតដោយអត្តភាពតែមួយក្នុងឥឡូវនេះបាន យ៉ាងណា ក្នុងគ្រានោះ ព្រះវិបស្សី-ពោធិសត្វ បានតាំងនៅក្នុងសួគ៌ជាន់តុសិតនោះ ដរាបគ្រប់អាយុ ព្រោះបារមីពេញហើយដោយប្រការទាំងពួង ដូច្នោះ ។ ក៏ពួកទេវតា នឹងចុតិក្នុង ៧ ថ្ងៃ ដោយការគណនារបស់ពួកមនុស្ស ដូច្នោះ ។ បុព្វនិមិត្ត ៥ រមែងកើតឡើង គឺ ផ្កាឈើស្វិត សំពត់សៅហ្មង ញើសហូរអំពីក្លៀកទាំងពីរ សម្បុរពណ៌សៅហ្មង ទេវតាមិនតាំងនៅក្នុងទេវាសនៈ ។

ក្នុងបទទាំងនោះ បទថា មាលា បានដល់ ផ្កាឈើដែលប្រដាប់ក្នុងថ្ងៃចុះកាន់បដិសន្ធិ ។ ន័យថា ផ្កាឈើទាំងនោះ មិនស្វិតរហូតដល់អស់ ៥៧ កោដិឆ្នាំ ក្រៃលែងដោយ ៦ លានឆ្នាំ តែក្នុងពេលនោះស្វិត ។

សម្បីក្នុងសំពត់ទាំងឡាយ ក៏មានន័យនេះឯង ។ ក៏រហូតដល់អស់កាល ប្រមាណប៉ុណ្ណោះ ពួកទេវតាមិនដឹងត្រជាក់ មិនដឹងក្តៅ ។ ក្នុងកាលនោះ ញើសហូរអំពីសរីរៈជាតំណក់ ៗ ។ រហូតដល់អស់កាលប្រមាណប៉ុណ្ណោះ ក្នុងសរីរៈរបស់ទេវតាទាំងនោះ រមែងមិនប្រាកដវណ្ណៈ ផ្សេងគ្នាដោយអំណាចធ្មេញបាក់ និងសក់ស្កូវជាដើម ។ទេពធីតាប្រាកដដូចមានអាយុ ១៦ ទេវបុត្រប្រាកដដូចមានអាយុ ២០ ។ តែក្នុងវេលាជិតស្លាប់ អត្តភាពរបស់ទេវបុត្រទាំងនោះទ្រុឌទ្រោម ។ ម្យ៉ាងទៀត រហូតដល់អស់កាលប្រមាណប៉ុណ្ណោះ ទេវបុត្រទាំងនោះ មិនមានសេចក្តីអផ្សុកក្នុងទេវលោក ។ តែក្នុងវេលាជិតស្លាប់ ដកដង្ហើមមិនចេញ សោយសោក មិនត្រេកអរក្នុងអាសនៈរបស់ខ្លួន ។

ក៏បុព្វនិមិត្ត ៥ ទាំងនេះ រមែងប្រាកដដល់ទេវតាអ្នកមានសក្តិធំប៉ុណ្ណោះ មិនប្រាកដដល់ទេវតាទាំងពួង ដូចនិមិត្ត មានឧក្កាបាត ផែនដីញ័រ និងចន្ទគ្រាសជាដើម រមែងប្រាកដដល់ព្រះរាជា និងអាមាត្យរបស់ព្រះរាជាជាដើម អ្នកមានបុណ្យច្រើនប៉ុណ្ណោះ មិនប្រាកដដល់មនុស្សទាំងពួងដូច្នោះ ។ ដូចជាមានអ្នកហោរាសាស្ត្រ រមែងដឹងបុព្វនិមិត្តក្នុងមនុស្សទាំងឡាយ បុគ្គលទាំងពួងមិនដឹង យ៉ាងណា ពួកទេវតាទាំងពួង រមែងមិនដឹង សូម្បីនិមិត្តទាំងនោះ តែបណ្ឌិតប៉ុណ្ណោះដឹងបាន ដូច្នោះ ។ ទេវបុត្រពួកណាកើតក្នុងទេវលោកនោះដោយកុសលកម្មតិច កាលបើទេវបុត្រទាំង

នោះកើត គេខ្វាចថា ឥឡូវនេះ នរណានឹងដឹងពួកយើងកើតទីណា ទេវបុត្រ ដែលមានបុណ្យច្រើន រមែងមិនខ្វាចថា ពួកយើងអាស្រ័យទានដែលយើង ឲ្យ សីលដែលយើងរក្សា ភាវនាដែលយើងចម្រើន នឹងសោយសម្បត្តិក្នុង ទេវលោកខាងលើ ។

សូម្បីព្រះពោធិសត្វព្រះនាមថា វិបស្សី ទ្រង់ឃើញបុព្វនិមិត្តទាំង នោះ ហើយទ្រង់មិនខ្វាចថា ឥឡូវនេះ យើងនឹងជាព្រះពុទ្ធក្នុងអត្តភាព បន្ទាប់ទៅ ។ កាលបើដូច្នោះ កាលនិមិត្តទាំងនោះប្រាកដដល់ព្រះអង្គ ពួកទេពក្នុងម៉ឺនចក្រវាឡ នាំគ្នាមកប្រជុំទូលអង្វរថា បពិត្រលោកអ្នក និរទុក្ខ ព្រះអង្គទ្រង់បំពេញបារមី ១០ ទ្រង់មិនបានប្រាថ្នាសក្កសម្បត្តិ មារសម្បត្តិ ព្រហ្មសម្បត្តិ សម្បត្តិស្តេចចក្រពត្តិ តែព្រះអង្គទ្រង់ប្រាថ្នា ភាពជាពុទ្ធៈ ទ្រង់បំពេញបារមីដើម្បីនាំសត្វចេញចាកលោក ឥឡូវនេះ កាល នោះមកដល់ព្រះអង្គហើយ ជាសម័យដើម្បីភាពជាពុទ្ធៈហើយ ។

លំដាប់នោះ ព្រះមហាសត្វទ្រង់មិនបានទទួលពាក្យប្តេជ្ញារបស់ទេវតា ទាំងនោះ ទ្រង់ពិចារណាមើលមហាវិលោកនៈ ៥ ប្រការ ដោយទ្រង់ កំណត់កាល ទ្វីប ប្រទេស ត្រកូល និងអាយុរបស់ព្រះមាតា ។ ក្នុង មហាវិលោកនៈ ៥ នោះ ព្រះមហាសត្វទ្រង់ពិចារណាមើល **កាល** មុនថា ដល់វេលាឬនៅ ។ កាលអាយុរបស់សត្វចម្រើន ច្រើនជាងសែនឆ្នាំ ក៏ មិនមែនជាកាល ។ សួរថា ព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះក្នុងកាលនោះ

ជាតិ ជរា និងមរណៈ នឹងមិនប្រាកដដល់សត្វទាំងឡាយ ។ ឈ្មោះថា ព្រះធម្មទេសនារបស់ព្រះពុទ្ធទាំងឡាយ ដែលនឹងធ្វើឲ្យផុតចាកព្រះត្រៃ-លក្ខណ៍ ក៏នឹងមិនមាន ។ កាលព្រះពុទ្ធទាំងឡាយត្រាស់ថា **ទុក្ខំ អនិច្ចំ អនត្តា** ដូច្នេះ សត្វទាំងឡាយក៏នឹងនិយាយថា ព្រះពុទ្ធត្រាស់អ្វី ហើយមិនសម្គាល់ថា គួរស្តាប់ គួរជឿ ។ តពីនោះ ក៏នឹងមិនមានការត្រាស់ដឹង កាលមិនមានការត្រាស់ដឹង ។ ពាក្យទូន្មាន ក៏នឹងមិននាំសត្វឲ្យចេញចាកទុក្ខ ព្រោះដូច្នោះ ទើបមិនមែនជាកាល ។ សូម្បីកាលកាលសត្វមានអាយុថយចុះតិចជាង ១០០ ឆ្នាំ ក៏មិនមែនកាល ។ សួរថា ព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះក្នុងកាលនោះ សត្វទាំងឡាយមានកិលេសក្រាស់ ។ ឱវាទដែលឲ្យដល់សត្វ ដែលមានកិលេសក្រាស់ រមែងមិនតាំងនៅក្នុងឋានៈជាឱវាទ ដូចឈើប្រត់គូសទៅក្នុងទឹក ស្នាមទឹករមែងបាត់ទៅភ្លាម ព្រោះដូច្នោះ ទើបមិនមែនជាកាល ។ វេលាកាលអាយុសត្វតាំងនៅសែនឆ្នាំចុះមកដល់ ១០០ ឆ្នាំ ឈ្មោះថា **កាល** ។ ក៏ក្នុងកាលនោះ មនុស្សទាំងឡាយមានអាយុ ៨០.០០០ ឆ្នាំ ។ គ្រានោះ ព្រះមហាសត្វទ្រង់ឃើញថា ដល់កាលដែលគួរនឹងកើតហើយ ។ អំពីនោះ ព្រះមហាសត្វទ្រង់ពិចារណាមើល **ទ្វីប** ទ្រង់ឃើញទ្វីប ៤ ព្រមដោយបរិវារ ទ្រង់ឃើញថា ក្នុងទ្វីប ៣ ព្រះពុទ្ធទាំងឡាយមិនកើត កើតតែក្នុងជម្ពូទ្វីប ។ ជម្ពូទ្វីបមានទំហំប្រមាណ ១០.០០០ យោជន៍ ។ ទ្រង់ពិចារណាមើល **ប្រទេស**

តទៅថា ព្រះពុទ្ធទាំងឡាយ រមែងកើតក្នុងប្រទេសណាហ្ន៎ ទ្រង់ឃើញមជ្ឈិម-ប្រទេស ។ លោកពោលដល់មជ្ឈិមប្រទេសទុកក្នុងវិន័យ ដោយន័យជាដើមថា ក្នុងទិសខាងកើតមាននិគម ឈ្មោះជង្គលៈ ប្រទេសនោះដោយផ្នែកបណ្តោយប្រមាណ ៣០០ យោជន៍ ដោយផ្នែកទទឹងប្រមាណ ១៥០ ដោយជុំវិញប្រមាណ ៩០០ យោជន៍ ។ ពិតហើយ ក្នុងប្រទេសនោះ ព្រះពុទ្ធទាំងឡាយ ព្រះបច្ចេកពុទ្ធទាំងឡាយ ព្រះអគ្គសាវក ព្រះមហាសាវក ស្តេចចក្រពត្តិ និងក្សត្រិយ៍ ព្រាហ្មណ៍ គហបតី សេដ្ឋី អ្នកមានសក្តិធំពួកដទៃ រមែងកើត ។ មយ៉ាងទៀត ក្នុងប្រទេសនេះ មាននគរឈ្មោះពន្ធុមតី ព្រះមហាសត្វទ្រង់សម្រេចព្រះទ័យថា យើងគួរទៅកើតក្នុងនគរនោះ ។ តអំពីនោះ ទ្រង់ពិចារណាមើល **ត្រកូល** ទ្រង់ឃើញត្រកូលហើយថា ធម្មតាព្រះពុទ្ធទាំងឡាយ រមែងកើតក្នុងត្រកូលដែលមនុស្សលោកលើកតម្កើង ក៏ឥឡូវនេះ ត្រកូលក្សត្រិយ៍ដែលមនុស្សលោកលើកតម្កើងហើយ យើងនឹងកើតក្នុងត្រកូលនោះ ព្រះរាជាព្រះនាមថា **ពន្ធុ** នឹងជាព្រះបិតារបស់យើង ដូច្នេះ ។ តពីនោះ ទ្រង់ពិចារណាមើលមាតា ទ្រង់ឃើញថា ធម្មតាព្រះពុទ្ធមាតាមិនមែនជាស្រីឡេះឡោះទេ មិនមែនជាអ្នកលេងសុរា បំពេញបារមីមកហើយអស់សែនកប្ប តាំងពីកើតមកមានសីល ៥ មិនដាច់ ក៏ស្រ្តីដូចព្រះនាងពន្ធុមតីទេវីនេះ នឹងជាមាតារបស់យើង ដូច្នេះ ។ ទ្រង់រំពឹងថា ព្រះនាងពន្ធុមតីទេវី នឹងមានព្រះជន្មាយុប៉ុនណា ទ្រង់ឃើញ

ថា នឹងមានព្រះជន្មាយុ ៧ ថ្ងៃ តពី ១០ ខែ ។

ព្រះពោធិសត្វទ្រង់ពិចារណាមើលមហាវិលោកនះ ៥ នេះ ត្រាស់ថា ម្នាលអ្នកនិរទុក្ខទាំងឡាយ ជាកាលដែលសមគួររបស់យើងដើម្បីភាពជាព្រះពុទ្ធហើយ កាលទ្រង់នឹងធ្វើការសង្គ្រោះដល់ពួកទេព ប្រទានបដិញ្ញាថា ពួកលោកចូរនាំគ្នាត្រឡប់ទៅចុះ ទ្រង់បញ្ជូនទេវតាទាំងនោះ ហើយហែហមដោយទេវតាជាន់តុសិត ស្តេចចូលទៅកាន់សួននន្ទវ័នក្នុងតុសិត-ទេវលោក ។ សូម្បីក្នុងទេវលោកទាំងអស់ ក៏មានសួននន្ទវ័នដូចគ្នា ។ ពួកទេវតានាំគ្នាទូលដាស់តឿនថា សូមព្រះអង្គចូរចុតិអំពីទេវលោកនេះ ទៅកាន់មនុស្សសុគតិចុះ ហើយទូលឲ្យរឭកដល់ឱកាសដែលទ្រង់បំពេញកុសល-កម្មមកក្នុងកាលមុន ។ ព្រះពោធិសត្វនោះ ហែហមទៅដោយពួកទេវតាអ្នកឲ្យរឭកដល់កុសលយ៉ាងនេះ ស្តេចទៅនៅក្នុង សួននន្ទវ័ននោះ ទ្រង់ចុតិហើយ ។ ក៏គ្រាចុតិយ៉ាងនេះហើយ រមែងដឹងថា យើងចុតិ មិនដឹងចុតិចិត្ត សូម្បីកាន់បដិសន្ធិហើយទើបដឹង តែមិនដឹងបដិសន្ធិចិត្តទៀតនោះឯង តែដឹងយ៉ាងនេះថា យើងបដិសន្ធិក្នុងទីនេះ នុ៎ះឯង ។ តែព្រះថេរៈពួកខ្លះពោលថា គួរមានការនឹកគិតដោយបរិយាយ ព្រះពោធិសត្វនឹងដឹងវារៈចិត្តទីពីរ ទីបី ។

តែព្រះមហាសិវត្ថេរអ្នកទ្រទ្រង់ព្រះត្រៃបិដក ពោលថា បដិសន្ធិរបស់ព្រះពោធិសត្វ មិនដូចបដិសន្ធិរបស់សត្វដទៃ សេចក្តីថា សតិសម្បជញ្ញៈ

របស់ព្រះពោធិសត្វទាំងនោះដល់ទីបំផុតហើយ តែព្រោះមិនអាចធ្វើចិត្តដួងនោះដោយចិត្តដួងនោះបាន ដូច្នោះ ទើបមិនដឹងចុតិចិត្ត តែក្នុងខណៈចុតិនុ៎ះឯង , រមែងដឹងថា យើងចុតិ មិនដឹងបដិសន្ធិចិត្ត ដឹងត្រឹមតែថា យើងបានចាប់បដិសន្ធិក្នុងទីឯណោះ ដូច្នេះ ។ ក្នុងកាលនោះ មុឺនលោកធាតុ រមែងញាប់ញ័រ ។ ព្រះពោធិសត្វមានសតិសម្បជញ្ញៈយ៉ាងនេះ ស្ដេចចុះកាន់គភ៌មាតា ទ្រង់បដិសន្ធិដោយមហាវិបាកចិត្ត ដូចនឹងកុសលចិត្ត ដែលជាអសង្ខារិកៈសហគតដោយសោមនស្ស សម្បយុត្តដោយញាណដែលជាចំណែកខាងដើមនៃមេត្តាក្នុងបដិសន្ធិចិត្ត ១៩ ដួង ។ មួយវិញទៀត ព្រះមហាសិវត្ថេរពោលថា ចិត្តសហគតដោយឧបេក្ខា ។ ព្រះពោធិសត្វព្រះអង្គនោះ ក៏បានចុះចាប់បដិសន្ធិ ក្នុងខែឧត្តរាសាឡ្ហៈ ក្នុងថ្ងៃពេញបូណ៌មីខែ ៨ ដូចព្រះមានព្រះភាគរបស់យើងទាំងឡាយ ដូច្នោះ ។

បានឮថា ក្នុងគ្រានោះ ចាប់ផ្ដើមពីថ្ងៃទី ៧ នៃអាសាឡ្ហបុណ្ណមី ព្រះមាតារបស់ព្រះពោធិសត្វ ទ្រង់លេងនក្ខត្តកីឡា ទ្រង់ប្រដាប់ដោយផ្កាឈើ និងគ្រឿងក្រអូបជាដើម មិនមានការផឹកសុរា ស្ដេចក្រោកពីព្រឹកក្នុងថ្ងៃទី ៧ ទ្រង់ស្រោចស្រប់ដោយទឹកក្រអូប ទ្រង់តាក់តែងដោយគ្រឿងប្រដាប់គ្រប់ប្រភេទ សោយព្រះក្រយាហារដ៏ប្រសើរ ទ្រង់អធិដ្ឋានអដ្ឋឧបោសថ ស្ដេចចូលកាន់បន្ទប់សិរីផ្ទំលើព្រះសិរីសេយ្យាសនៈ ទ្រង់ចូលកាន់និទ្រាបានទតឃើញព្រះសុបិន្តនេះ ។

ក្នុងព្រះសុបិន្តនោះថា ស្តេចមហារាជទាំង ៤ បានលើកព្រះពុទ្ធ-មាតាព្រមដោយព្រះទីនាំង ទៅកាន់ស្រះអនោតត្តៈ ឲ្យស្រោចស្រប់ ឲ្យទ្រង់ស្លៀកដណ្តប់ដោយសំពត់ទិព្វ ឲ្យទ្រង់លាបស្រឡាបដោយរបស់ក្រអូបជាទិព្វ ប្រដាប់ផ្កាឈើទិព្វ មិនឆ្ងាយអំពីនោះ មានភ្នំប្រាក់ ខាងក្នុងភ្នំប្រាក់នោះមានវិមានមាស ឲ្យព្រះពុទ្ធមាតាបែរព្រះសិរសាទៅទិសខាងកើតផ្ទំក្នុងវិមានមាសនោះ ។

គ្រានោះ ព្រះពោធិសត្វជាដំរីសផូរផង់ មិនឆ្ងាយអំពីនោះ មានភ្នំមាសមួយ ព្រះពោធិសត្វស្តេចទៅត្រង់ភ្នំមាសនោះហើយ ស្តេចចុះអំពីភ្នំមាស ស្តេចឡើងភ្នំប្រាក់ហើយ ស្តេចចូលទៅកាន់វិមានមាស ធ្វើប្រទក្សិណព្រះមាតាហើយ ហាក់ដូចជាហែកព្រះឧទចំហៀងខាងស្តាំ ស្តេចចូលទៅកាន់ព្រះគភ៌ ។ ភ្លាមនោះ ព្រះទេវីទ្រង់ភ្ញាក់ឡើង ក្រាបទូលព្រះសុបិន្តនោះចំពោះព្រះរាជា ។

លុះភ្លឺហើយ ព្រះរាជាត្រាស់បង្គាប់ឲ្យហៅប្រធានព្រាហ្មណ៍ប្រមាណ ៦៤ នាក់ ឲ្យក្រាលអាសនៈដែលមានតម្លៃច្រើនលើផែ្ទ លាបដោយរបស់ខៀវ ធ្វើមង្គលសក្ការៈដោយបាយរីងជាដើម កាលព្រាហ្មណ៍ទាំងឡាយអង្គុយក្នុងទីនោះហើយ ទ្រង់នាំថាសមាស ថាសប្រាក់ដែលពេញទៅដោយបាយបាយាសយ៉ាងល្អ ផ្សំដោយទឹកដោះថ្លា ទឹកឃ្មុំ និងដុំស្ករគ្រាត គ្របដោយថាសមាស ថាសប្រាក់ទៀត ទើបថ្វាយ ។ ទ្រង់ឲ្យព្រាហ្មណ៍ទាំង

នោះផ្អែតស្កប់ស្កល់ ដោយវត្ថុយ៉ាងដទៃ មានសំពត់ថ្មី មេគោក្រហម និងទានជាដើម ។ ព្រះរាជាត្រាស់ប្រាប់ព្រះសុបិន្តនោះ ដល់ព្រាហ្មណ៍ទាំងនោះផ្អែតស្កប់ស្កល់ដោយសេចក្ដីប្រាថ្នាទាំងពួង ហើយត្រាស់សួរថា ព្រះសុបិន្តនោះ តើដូចម្ដេច ។ ពួកព្រាហ្មណ៍ក្រាបទូលថា សូមតេជៈបពិត្រមហារាជ ព្រះអង្គកុំទ្រង់ព្រះវិតក្កៈឡើយ ព្រះទេវីទ្រង់ព្រះគភ៌ហើយ ព្រះអង្គម្យ៉ាងទៀត ព្រះគភ៌នោះជាបុរស មិនមែនស្ត្រី ព្រះអង្គនឹងមានព្រះឱរស ព្រះឱរសនោះ បើគ្រប់គ្រងផ្ទះនឹងជាស្ដេចចក្រពត្តិ ប្រកបដោយធម៌ ជាធម្មរាជា បើចេញបួសនឹងជាព្រះពុទ្ធអ្នកបើកលោក ។ គប្បីជ្រាបលំដាប់ការពណ៌នាសេចក្ដីក្នុងបទនេះថា ព្រះពោធិសត្វ ស្ដេចចុះកាន់ព្រះគភ៌ព្រះមាតាដូច្នេះ ។ បទថា អយមេត្ថធម្មតា សេចក្ដីថា ប្រការនេះជាធម្មតាក្នុងការស្ដេចចុះកាន់ព្រះគភ៌ព្រះមាតានេះ ។ លោកអធិប្បាយថា នេះជាសេចក្ដីពិត នេះជាសេចក្ដីពិតប្រាកដ ដូច្នេះ ។

ឈ្មោះថា និយាមនេះ មាន ៥ យ៉ាង គឺ កម្មនិយាម ឧតុនិយាម ពីជនិយាម ចិត្តនិយាម ធម្មនិយាម ។ ក្នុងនិយាមទាំង ៥ នោះ ការឲ្យផលនៃកុសលដែលគួរប្រាថ្នា ការឲ្យផលនៃអកុសលដែលមិនគួរប្រាថ្នា នេះឈ្មោះ កម្មនិយាម ។ ដើម្បីសម្ដែងកម្មនិយាមនោះ គួរពោលដល់រឿងក្នុងគាថាដូច្នេះថា ន អន្តលិក្ខេ ន ដូច្នេះជាដើម ។

មានរឿងដំណាលថា ស្រីម្នាក់ឈ្មោះនឹងប្ដី ប្រាថ្នានឹងចងកសម្លាប់

ខ្លួន ទើបសិកកចូលទៅក្នុងអន្ទាក់ខ្សែ ។ បុរសម្នាក់កំពុងសំលៀងកាំបិត ឃើញស្រីនោះ ប្រាថ្នានឹងកាត់ខ្សែ ទើបរត់ទៅលួងលោមស្រីនោះថា អូន កុំខ្លាច អូនកុំខ្លាច ។ ខ្សែដូចជាអាសិរពិសកំពុងរឹតកស្ត្រីនោះ ។ បុរសនោះខ្លាចប្រញាប់គេចចេញទៅ ។ ស្រីនោះ ស្លាប់ក្នុងទីនោះឯង ។ គួរសម្តែងដល់រឿងទាំងឡាយជាដើម យ៉ាងនេះក្នុងទីនេះ ។

ក្នុងជនបទនោះៗ ក្នុងកាលនោះៗ ការរក្សាផ្កាឈើ និងផ្លែឈើជាដើម ដោយកាត់តែម្តងប៉ុណ្ណោះ ខ្យល់បក់ ខ្យល់មិនបក់ កំដៅថ្ងៃខ្លាំងក្លា កំដៅថ្ងៃតិច ភ្លៀងធ្លាក់ ភ្លៀងមិនធ្លាក់ ផ្កាឈូកពេលថ្ងៃរីក ពេលយប់ក្តោប យ៉ាងនេះជាដើម ជាឧតុនិយាម ។

ផ្លែស្រូវសាលី រមែងជាផលអំពីពូជស្រូវសាលីតែម្យ៉ាង រសផ្អែមរមែងជាផលអំពីពូជផ្អែម រសល្វីង រមែងជាផលអំពីពូជល្វីង នេះជាពីជ-និយាម ។

ធម៌ គឺ ចិត្ត និងចេតសិកដួងមុនៗ ជាបច្ច័យ ដោយឧបនិស្ស័យ-បច្ច័យនៃធម៌ គឺ ចិត្ត និងចេតសិកដួងក្រោយៗ ព្រោះដូច្នោះ ការកើតឡើងនៃសម្បដិច្ឆន្នៈជាដើម ក្នុងលំដាប់នៃចក្ខុវិញ្ញាណជាដើម នេះជាចិត្ត-និយាម ។

ការប្រព្រឹត្តទៅនៃសេចក្តីញាប់ញ័រក្នុងមុឺនលោកធាតុ ក្នុងការស្តេចចុះកាន់ព្រះគភ៌ព្រះមាតានៃព្រះពោធិសត្វទាំងឡាយ នេះឈ្មោះ ធម្មនិយាម ។

ក្នុងទីនេះលោកប្រាថ្នាធម្មនិយាម ។ ព្រោះដូច្នោះ ព្រះមានព្រះភាគ កាល នឹងទ្រង់សម្ដែងសេចក្ដីនោះ ទើបត្រាស់ពាក្យជាដើមថា ម្នាលភិក្ខុទាំងឡាយ រឿងនេះ ជារឿងធម្មតា ដូច្នេះ ។

[១៣] ក្នុងបទទាំងនោះ បទថា កុច្ឆឹ ឱក្កមតិ នេះ មានសេចក្ដីថា ព្រះពោធិសត្វស្ដេចចុះកាន់ព្រះគភ៌ ។ ក៏កាលព្រះពោធិសត្វនោះ ស្ដេចចុះហើយ យ៉ាងនេះ មិនមែនកំពុងស្ដេចចុះទេ ។ បទថា អប្បមាណោ សេចក្ដីថា មានប្រមាណច្រើន គឺ បរិបូណ៌ ។ បទថា ឧឡារោ ជាវេវចនៈ របស់បទនោះ ។ លោកពោលថា មានរសឆ្ងាញ់យ៉ាងក្រៃលែង ក្នុងបទជាដើមថា **ជនទាំងឡាយរមែងបំណងស៊ីរបស់គួរទំពារស៊ី ដែលមានរសឆ្ងាញ់ដ៏ក្រៃលែង** លោកពោលថា ប្រសើរយ៉ាងក្រៃលែង ។ ក្នុងបទមានជាអាទិថា បានឮមកថា ក្នុងកាលមុនវច្ឆៈដ៏ចម្រើន រមែងសរសើរព្រះ-សមណគោតម ដោយការសរសើរយ៉ាងក្រៃលែង ដូច្នេះ ។ តែក្នុងបទនេះ លោកបំណងយកភាពធំទូលាយ ។ ក្នុងបទថា ទេវានំ ទេវានុភាវំ នេះ មានសេចក្ដីថា អានុភាពរបស់ទេវតា ក៏គឺ សំពត់ស្លៀកមានរស្មីផ្សាយទៅ ១២ យោជន៍ រាងកាយក៏ដូច្នោះ គ្រឿងប្រដាប់ក៏ដូច្នោះ វិមានក៏ដូច្នោះ ព្រះពោធិសត្វកន្លងហួសទេវានុភាពនោះ ដូច្នេះ ។

បទថា លោកន្តរិកា សេចក្ដីថា ចន្លោះទទេមួយៗ ក្នុងចន្លោះចក្រវាឡទាំង ៣ រមែងមានក្នុងទីបំផុតលោក ដូចចន្លោះទទេត្រង់កណ្ដាល

កង់រទេះ ៣ កង់ ឬថាស ៣ ដែលដាក់ទល់គ្នាដូច្នោះ ។ ក៏លោកន្តរនរក នោះ ដោយចំណែកខាងទទឹង ៨.០០០ យោជន៍ ។ បទថា អឃា គឺ បើកជានិច្ច ។ បទថា អសំវុតា សេចក្តីថា សូម្បីខាងក្រោមក៏មិនមាន តាំងទុក ។ បទថា អន្ធការា គឺ ងងឹតឈឹង ។ បទថា អន្ធការតិមិសា សេចក្តីថា ប្រកបដោយអ័ព្ទដែលធ្វើសេចក្តីងងឹតផុតពីចក្ខុវិញ្ញាណ ។ ន័យ ថា ចក្ខុវិញ្ញាណ រមែងមិនកើតក្នុងទីនោះ ។ បទថា ឯវំ មហិទ្ធិកា សេចក្តីថា ព្រះចន្ទនិងព្រះអាទិត្យ រមែងប្រាកដក្នុង ៣ ទ្វីប ដោយបំភ្លឺ មួយជងប៉ុណ្ណោះ យ៉ាងនេះឈ្មោះថា ព្រះចន្ទ និងព្រះអាទិត្យមានឫទ្ធិច្រើន ។ ព្រះចន្ទ និងព្រះអាទិត្យកម្ចាត់កាពងងឹតរហូតមួយលាន ៨ សែនយោជន៍ ក្នុងទិសមួយៗ ហើយភ្លឺស្វាង យ៉ាងនេះឈ្មោះថា ព្រះចន្ទ និងព្រះអាទិត្យ មានអានុភាពច្រើន ។ បទថា អាភាយ ណានុភោន្តិ សេចក្តីថា ពន្លឺរបស់ ខ្លួនមិនអាច ។ សេចក្តីថា ព្រះចន្ទ និងព្រះអាទិត្យទាំងនោះ ត្រាច់ទៅ កណ្តាលចក្រវាឡបព៌ត ។ ក៏លោកន្តរនរកហួសចក្រវាឡបព៌តទៅ ព្រោះ ដូច្នោះ ព្រះចន្ទ និងព្រះអាទិត្យទាំងនោះ ទើបមិនមានពន្លឺក្នុងទីនោះ ។

បទថា យេបិ តត្ថ សត្តា សេចក្តីថា សូម្បីសត្វពួកណាកើត ហើយក្នុងលោកន្តរមហានរកនោះ ។ សួរថា ក៏សត្វទាំងនោះធ្វើកម្មអ្វីទុក ទើបកើតក្នុងលោកន្តរមហានរកនោះ ។ ឆ្លើយថា ធ្វើកម្មធ្ងន់ គឺ គ្រោតគ្រាត ។ សត្វទាំងនោះ ធ្វើខុសចំពោះមាតាបិតា និងសមណព្រាហ្មណ៍អ្នកតាំងនៅ

ក្នុងធម៌ និងកម្មដ៏សាហាវ មានសម្លាប់សត្វជាដើមរាល់ៗ ថ្ងៃ រមែងកើតក្នុងលោកន្តរនរកនោះ ដូចអកយចោរ និងនាគចោរជាដើម ក្នុងតម្ពបណ្ណិទ្វីប រាងកាយរបស់សត្វទាំងនោះខ្ពស់ ៣ គាវុត មានក្រចកវែងដូចក្រចកសត្វជ្រឹង សត្វទាំងនោះ តោងនៅលើក្នុំចក្រវាឡដោយក្រចក ដូចជ្រឹងតោងនៅលើដើមឈើដូច្នោះ កាលណាសត្វទាំងនោះវារទៅប៉ះត្រូវដៃរបស់គ្នានិងគ្នា កាលនោះក៏សម្គាល់ថា យើងជួបអាហារហើយ ទើបរត់ដេញទៅជុំវិញៗ ហើយក៏ធ្លាក់ទៅលើទឹកទ្រលោក កាលខ្យល់បក់ត្រូវក៏ដាច់ធ្លាក់ចុះទៅក្នុងទឹក ដូចផ្លែស្រគំ ពេលធ្លាក់ចុះទៅហើយ ក៏រលាយដូចដុំម្សៅធ្លាក់ចុះទៅក្នុងទឹកដែលប្រៃខាស់ ។ បទថា អញ្ញេបិ កិរ ភោ សន្តិ សត្តា សេចក្តីថា សត្វទាំងឡាយ រមែងឃើញគ្នា ក្នុងថ្ងៃនោះថា ឱហ្ន៎ សូម្បីសត្វពួកដទៃក៏កើតក្នុងទីនេះ សោយទុក្ខដូចពួកយើង សោយទុក្ខដ៏ធំក្រៃលែងដូច្នោះ ។ ក៏ពន្លឺនេះ មិនតាំងនៅយូរ តាំងនៅត្រឹមតែហុតបបរយាគូម្តង ផ្សាយចេញទៅដូចពន្លឺផ្លេកបន្ទោរ ត្រឹមតែមួយផ្ទាត់ម្រាមដៃប៉ុណ្ណោះ កាលសត្វទាំងឡាយនិយាយថា នេះអ្វី ក៏បាត់ទៅ ។ បទថា សំកម្បតិ គឺ ញាប់ញ័រទៅដោយជុំវិញ ។ ពីរបទតទៅ ជាវេវចនៈរបស់បទមុនទុ៎ះឯង ។ បទថា បុន អប្បមាណោ ច ជាដើមលោកពោលសេចក្តីសរុបតទៅ ។

[១៤] បទថា ចត្តារោ ក្នុងបទនេះថា ទេវបុត្រ ៤ អង្គ ចូល

ទៅរក្សាទិសទាំង ៤ លោកពោលសំដៅដល់ស្ដេចមហារាជ ៤ អង្គ ។ ក៏ក្នុងម៉ឺនចក្រវាឡចែកចេញក្នុង ១ ជា ៤ ក៏ជាបួនម៉ឺនចក្រវាឡ ។ ក្នុងបួនម៉ឺនចក្រវាឡនោះ ក្នុងចក្រវាឡនេះ ស្ដេចមហារាជកាន់ព្រះខ័នចូលទៅរក្សាព្រះពោធិសត្វ ចូលទៅកាន់បន្ទប់សិរី ញុំាំងពួកយក្ខជាដើមថាពួកបីសាចលេងធូលី ដែលរារាំងទប់ស្កាត់តាំងពីទ្វារបន្ទប់ឲ្យចៀសចេញទៅ ហើយកាន់ការរក្សារហូតដល់ចក្រវាឡ ។

ក៏ការរក្សានេះដើម្បីប្រយោជន៍អ្វី សូម្បីថា ចាប់ផ្ដើមតាំងពីកាលនៃកលលៈក្នុងខណៈបដិសន្ធិ ពួកមារសែនកោដិ លើកភ្នំសិនេរុសូម្បីសែនកោដិ គប្បីមកដើម្បីធ្វើអន្តរាយព្រះពោធិសត្វ ឬព្រះមាតាព្រះពោធិសត្វ អន្តរាយទាំងអស់គប្បីបាត់ទៅមិនមែនឬ ។ សូម្បីរឿងនេះ ព្រះមានព្រះភាគក៏ត្រាស់ទុកហើយ ក្នុងការធ្វើព្រះលោហិតឲ្យពុរពងថា ម្នាលទាំងឡាយ កាលដែលពួកមារនឹងគប្បីផ្ដាច់ព្រះជន្មតថាគត ដោយសេចក្ដីព្យាយាមរបស់អ្នកដទៃ មិនមែនជាឋានៈ មិនមែនជាឱកាស ម្នាលភិក្ខុទាំងឡាយ ព្រោះព្រះតថាគតទាំងឡាយ មិនបរិនិព្វានដោយសេចក្ដីព្យាយាមរបស់បុគ្គលដទៃទេ ។ ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរទៅតាមទីកន្លែងចុះ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតទាំងឡាយមិនគួរនឹងរក្សា ព្រោះដូច្នោះ អន្តរាយដល់ជីវិតនៃព្រះតថាគតទាំងនោះ រមែងមិនមានដោយសេចក្ដីព្យាយាមរបស់អ្នកដទៃយ៉ាងនេះឯង ។ ពួកទេវបុត្របានរក្សា ដើម្បីការពារភ័យក្ដី

សេចក្ដីតក់ស្លុតក្ដី ដែលគប្បីកើតដល់ព្រះមាតារបស់ព្រះពោធិសត្វ ព្រោះឃើញរូប ឬឮសំឡេងរបស់អមនុស្សដែលមានរូបពិការគួរស្អប់ គួរខ្លាច ជាម្រឹគ ជាបក្សី ។ មួយវិញទៀត ពួកទេវបុត្រកើតសេចក្ដីគោរពដោយតេជៈនៃបុណ្យរបស់ព្រះពោធិសត្វ សូម្បីបានប្រកាសសេចក្ដីគោរពរបស់ខ្លួនៗ ក៏បានធ្វើយ៉ាងនេះ ។

ក៏ស្ដេចមហារាជទាំង ៤ នេះ ចូលទៅឈរខាងក្នុងបន្ទប់ សម្ដែងខ្លួន ឬមិនសម្ដែងខ្លួនដល់ព្រះមាតារបស់ព្រះពោធិសត្វ ។ មិនសម្ដែងក្នុងវេលាទ្រង់ងូតទឹក ទ្រង់តាក់តែងព្រះវរកាយ ទ្រង់បរិភោគព្រះក្រយាហារជាដើម និងវេលាបន្ទោបង់ នឹងសម្ដែងតែក្នុងវេលាព្រះមាតាស្ដេចចូលបន្ទប់សិរីហើយផ្ទំលើព្រះសិរីសេយ្យាសនៈ ។ ក្នុងទីនោះឈ្មោះថា ការឃើញអមនុស្ស រមែងជាភ័យចំពោះមុខរបស់មនុស្សក៏ពិត ។ សូម្បីដូច្នោះ ព្រះមាតារបស់ព្រះពោធិសត្វឃើញអមនុស្សទាំងនោះ ដោយបុញ្ញានុភាពរបស់ខ្លួន និងរបស់ព្រះឱរស ទើបទ្រង់មិនខ្លាច ។ ព្រះទ័យរបស់ព្រះមាតានោះ រមែងកើតក្នុងអមនុស្សទាំងនោះ ដូចអ្នកថែរក្សាខាងក្នុងព្រះនគរតាមប្រក្រតី ។

[១៥] បទថា បកតិយា សីលវតី សេចក្ដីថា ជាអ្នកដល់ព្រមដោយសីលដោយសភាវៈនោះឯង ។ បានឮថា កាលព្រះពុទ្ធមិនទាន់ឧប្បត្តិ ពួកមនុស្សទាំងឡាយ តែងថ្វាយបង្គំក្នុងសម្នាក់របស់ពួកតាបស និងបរិ-

ព្វាជក ហើយអង្គុយប្រហោងសមាទានសីល ។ សូម្បីព្រះមាតារបស់ព្រះ-ពោធិសត្វរបស់យើងទាំងឡាយ ក៏ទ្រង់ទទួលសីលក្នុងសម្នាក់របស់ឥសីកាលទេវិល ។ តែកាលព្រះពោធិសត្វស្តេចកាន់ព្រះគភ៌ នរណាៗ ដទៃមិនអាចនឹងអង្គុយ ក្នុងបាទមូលបាន ។ សូម្បីអង្គុយទទួលសីលលើអាសនៈស្មើគ្នា ក៏ជាអាការមើលងាយ ព្រោះដូច្នោះ លោកទើបពោលថា ព្រះមាតាព្រះពោធិសត្វទ្រង់ទទួលសីលដោយព្រះអង្គឯង ។

[១៦] បទថា បុរិសេសុ សេចក្តីថា ចិត្តប្រាថ្នាក្នុងបុរស ក្នុងមនុស្សណាៗ សូម្បីព្រះបិតាព្រះពោធិសត្វជាដើម រមែងមិនកើតដល់ព្រះមាតាព្រះពោធិសត្វ ។ អ្នកមានសិល្បៈសូម្បីឆ្លាត ក៏មិនអាចនឹងគូររូបព្រះមាតាព្រះពោធិសត្វចុះក្នុងស្លឹកវិតជាដើមបាន ។ ដែលអ្នកណាៗ មិនអាចនឹងពោលបានថា ព្រោះឃើញរូបនោះ រាគៈរមែងមិនកើតដល់បុរស ។ ប្រសិនបើបុរសមានចិត្តតម្រេក ប្រាថ្នានឹងចូលទៅរកព្រះមាតាព្រះពោធិ-សត្វនោះ ជើងក៏មិននាំទៅ រមែងចងជាប់ដូចប្រវាក់ទិព្វ ព្រោះដូច្នោះ លោកទើបពោលពាក្យជាដើមថា ព្រះមាតាដែលនរណាៗ ប្រព្រឹត្តកន្លងមិនបានឡើយ ។

[១៧] បទថា បញ្ចន្នំ កាមគុណានំ សេចក្តីថា ក្នុងបទមុន លោកពោលដល់ការហាមវត្ថុ ដោយអំណាចសេចក្តីប្រាថ្នាក្នុងបុរស ក្នុងបទនេះថា កាមគុណូបសញ្ហិតំ ក្នុងបទនេះលោក សម្តែងដល់ការបាន

អារម្មណ៍ ។ បានឮថា ក្នុងកាលនោះព្រះរាជាទាំងឡាយដោយជុំវិញស្ដាប់ថា ព្រះឱរសបែបនេះ ទ្រង់ឧប្បត្តិក្នុងព្រះគភ៌របស់ព្រះទេវី ទ្រង់បញ្ជូនបណ្ណាការ ដែលជាទីតាំងនៃសេចក្ដីត្រេកអរក្នុងទ្វារ ៥ ដោយអំណាចអាភរណៈមានតម្លៃច្រើន និងតន្ត្រីជាដើម ។ ឈ្មោះថា ការកំណត់ប្រមាណនៃលាភនិងសក្ការៈ មិនមានដល់ព្រះពោធិសត្វ និងដល់មាតារបស់ព្រះពោធិសត្វ ព្រោះសន្សំកម្មដែលធ្វើទុក ។

[១៨] បទថា អកិលន្តកាយា សេចក្ដីថា ព្រះមាតាព្រះពោធិសត្វនោះ មិនមានសេចក្ដីលំបាកណាៗ ដូចស្ត្រីទាំងឡាយដទៃ លំបាកដោយធ្ងន់គភ៌ ដៃ និងជើង រមែងដល់ការហើមជាដើម ។

បទថា តិរោកុច្ឆិគតំ គឺ ស្ថិតនៅខាងក្នុងព្រះគភ៌ ។ បទថា បស្សតិ សេចក្ដីថា ព្រះមាតាព្រះពោធិសត្វ កាលកន្លង មានកលលៈជាដើម ទ្រង់ឃើញព្រះពោធិសត្វចូលដល់ភាពជាអ្នកមានអវយវៈតូចធំ និងព្រះឥន្ទ្រិយបរិបូរណ៍កើតហើយ ។ សួរថា ទ្រង់ឃើញដើម្បីអ្វី ។ ឆ្លើយថា ដើម្បីនៅសប្បាយ ។ ដូចមាតាអង្គុយ ឬដេក ជាមួយបុត្រ លើកដៃ ឬជើងរបស់បុត្រនោះសំយុងចុះ គិតថា យើងនឹងឲ្យបុត្រវឹងមាំ សម្លឹងមើលបុត្រដើម្បីនៅសប្បាយយ៉ាងណា សូម្បីព្រះមាតារបស់ព្រះពោធិសត្វក៏ដូច្នោះ គិតថា ទុក្ខណាកើតដល់គភ៌ក្នុងខណៈដែលមាតាឈរ ដើរទៅមក និងអង្គុយជាដើម និងក្នុងការលេបអាហារក្ដៅ ត្រជាក់ ប្រៃ ល្វីង

ហិរជាដើម របស់មាតា ទុក្ខនោះនឹងមានដល់បុត្រ របស់យើងឬទេហ្ន៎ ដូច្នេះ ហើយសម្លឹងមើលព្រះពោធិសត្វដើម្បីនៅយ៉ាងសប្បាយ ទ្រង់ឃើញព្រះពោធិសត្វប្រថាប់ចម្រើនសមាធិ ។ ដូចសត្វពួកដទៃនៅខាងក្នុង មានខ្នងបែរមកពោះ និងមានពោះបែរទៅខ្នង អាស្រ័យឆ្អឹងខ្នង ដាក់ចង្កាឱនទុកលើបាតដៃទាំងពីរ អង្គុយដូចស្វាក្នុងទីប្រហោងឈើកាលភ្លៀងធ្លាក់ យ៉ាងណា ព្រះពោធិសត្វមិនដូច្នោះឡើយ ។ ព្រះពោធិសត្វធ្វើឆ្អឹងខ្នងទុកខាងក្រោយ អង្គុយចម្រើនសមាធិ ក៏បែរព្រះភក្ត្រទៅទិសខាងកើត ដូចព្រះធម្មកថិកអង្គុយលើធម្មាសនៈ ។ ក៏កម្មដែលព្រះអង្គទ្រង់ធ្វើមកក្នុងកាលមុន ទើបធ្វើឲ្យវត្ថុរបស់ព្រះពោធិសត្វបរិសុទ្ធិ ។ កាលវត្ថុបរិសុទ្ធិ ព្រះលក្ខណៈ គឺ ព្រះឆវីល្អិតរមែងកើតឡើង ព្រះតចោក្នុងព្រះឧទរមិនអាចនឹងបិទបាំងព្រះឆវីនោះបាន ។ កាលព្រះមាតាទ្រង់ក្រឡេកមើល រមែងប្រាកដដូចតាំងនៅខាងក្រៅ ។ ព្រះដ៏មានព្រះភាគនោះឯង កាលទ្រង់នឹងធ្វើសេចក្តីនោះឲ្យជាក់ច្បាស់ដោយឧបមា ទើបត្រាស់ពាក្យជាអាទិថា សេយ្យថាបិ ដូច្នេះ ។ ក៏ព្រះពោធិសត្វប្រថាប់នៅខាងក្នុងព្រះគភ៌ ទ្រង់មិនឃើញព្រះមាតាទេ ។ ព្រោះចក្ខុវិញ្ញាណ រមែងមិនកើតឡើងខាងក្នុងផ្ទៃ ។

**[១៩]** បទថា កាលំ ករោតិ សេចក្តីថា មិនមែនដោយអស់អាយុ ព្រោះការប្រសូតជាបច្ច័យ សេចក្តីថា កន្លែងដែលព្រះពោធិសត្វប្រថាប់នៅដូចគ្នានឹងចេតិយ និងកុដិ មិនគួរដល់អ្នកដទៃនឹងរួមប្រើប្រាស់ ។ ម្យ៉ាង

ទៀត នរណាៗ មិនអាចនឹងនាំព្រះមាតាព្រះពោធិសត្វទៅតាំងនៅក្នុងឋានៈជាអគ្គមហេសីអ្នកដទៃបាន ដូច្នោះ ព្រះជន្មាយុរបស់ព្រះមាតាព្រះពោធិសត្វទើបមានប្រមាណប៉ុណ្ណោះ ព្រោះដូច្នោះ ព្រះនាងទើបស្តេចទិវង្គតក្នុងកាលនោះ ។

សួរថា ក៏ព្រះមាតាព្រះពោធិសត្វ ស្តេចទិវង្គតក្នុងវ័យណា ។ ឆ្លើយថា ក្នុងមជ្ឈិមវ័យ ។ ព្រោះថា ក្នុងអត្តភាពរបស់សត្វទាំងឡាយក្នុងបឋមវ័យ ឆន្ទរាគៈរមែងមានកម្លាំង ។ ព្រោះហេតុនោះ ស្ត្រីដែលតាំងគភ៌ក្នុងពេលនោះ ទើបមិនអាចនឹងរក្សាគភ៌ទុកបាន ។ គភ៌រមែងឈឺចាប់ច្រើន ។ តែគ្រាកន្លងហួសពីរចំណែកនៃមជ្ឈិមវ័យ ក្នុងចំណែកទីបី វត្ថុរមែងជារបស់បរិសុទ្ធិ ។ ទារកដែលកើតក្នុងវត្ថុបរិសុទ្ធិ រមែងមិនមានរោគ ។ ព្រោះដូច្នោះ ព្រះមាតារបស់ព្រះពោធិសត្វសោយសម្បត្តិក្នុងបឋមវ័យ ប្រសូតក្នុងចំណែកទីបីរបស់មជ្ឈិមវ័យ ហើយស្តេចទិវង្គតដូច្នោះ ប្រការនេះជាធម្មតាក្នុងរឿងនេះ ។

**[២០-២១]** វា សទ្ទ ក្នុងបទនេះថា ឆវ វា ឥស វា គប្បីជ្រាបដោយអំណាចជាគ្រឿងកំណត់ គប្បីជ្រាបការសង្គ្រោះសូម្បីពាក្យជាដើមយ៉ាងនេះថា ៧ ខែ ៨ ខែ ១១ ខែ ឬ ១២ ខែ ។ ក្នុងបទទាំងនោះទារកកើត ក្នុង ៨ ខែ នៅមានជីវិតរស់ តែទ្រាំត្រជាក់ និងក្តៅមិនបានកើតក្នុង ៧ ខែ រមែងមិនមានជីវិត ដ៏សេសនៅមានជីវិតរស់បាន ។

[២២] បទថា ទេវា បឋមំ បដិគ្គណ្ហន្តិ សេចក្តីថា ព្រហ្មជាព្រះខីណាស្រពក្នុងជាន់សុទ្ធាវាស រមែងទទួល ។ សួរថា យ៉ាងណា ។ ឆ្លើយថា អាចារ្យពួកខ្លះពោលថា ទទួលគ្រឿងតែងខ្លួនក្នុងពេលប្រសូត ។ តែសេចក្តីនោះត្រូវជំទាស់ហើយ ទើបពោលសេចក្តីនេះថា ក្នុងកាលនោះព្រះមាតាព្រះពោធិសត្វ ទ្រង់ស្លៀកសំពត់ប្រដាប់ដោយមាស ដូចក្អែកត្រីមានពីរជាន់គ្របរហូតដល់ព្រះបាទ បានប្រថាប់ឈរ ខណៈនោះ ព្រះមាតាព្រះពោធិសត្វបានប្រសូតព្រះឱរស ដូចទឹកហូរចេញចាកធម្មក្រក លំដាប់នោះ ពួកទេវតាមានភេទជាព្រហ្មតាមប្រក្រតី ចូលទៅទទួលដោយសំណាញ់មាសមុន ស្តេចមហារាជទាំង ៤ បានយកកម្រាលធ្វើដោយស្បែកខ្លាដំបងទទួលអំពីព្រះហស្ថរបស់ព្រហ្មទាំងនោះ បន្ទាប់ពីនោះពួកមនុស្សទើបទទួលដោយសំពត់ពីរជាន់ ព្រោះដូច្នោះ លោកទើបពោលថា ទេវតាទាំងឡាយទទួលមុន ពួកមនុស្សទទួលជាខាងក្រោយ ដូច្នេះ ។

[២៣] បទថា ចត្តារោ ធំ ទេវបុត្តា សេចក្តីថា មហារាជ ៤ អង្គ ។ បទថា បដិគ្គហេត្វា សេចក្តីថា ទទួលដោយកម្រាលធ្វើដោយស្បែកខ្លាដំបង ។ បទថា មហេសក្ខោ សេចក្តីថា មានតេជៈច្រើន មានយសច្រើន ដល់ព្រមដោយលក្ខណៈ ។

[២៤] បទថា វិសទោវ និក្ខមតិ សេចក្តីថា ស្តេចមិនប្រសូតដូចសត្វពួកដទៃដែលចងជាប់នៅត្រង់ប្រហោងប្រសូត គៀបហើយគៀបទៀត

ទើបប្រសូត ។ អធិប្បាយថា ស្ដេចប្រសូតដោយមិនទើសទាក់ ។ បទថា ឧទ្ធេន ប្រែថា ដោយទឹក ។ បទថា កេនចិ អសុចិនា សេចក្ដីថា ព្រះពោធិសត្វមិនដូចជាសត្វពួកដទៃ ត្រូវខ្យល់បក់បង្វិលមានជើងឡើងលើ មានក្បាលចុះក្រោមត្រង់ប្រហោងប្រសូត ដូចធ្លាក់ចុះទៅកាន់ជ្រោះជ្រៅ ១០០ ជំហរបុរស ដូចដំរីត្រូវទាញចេញពីប្រហោងរនុក សោយទុក្ខធំ ប្រឡាក់ដោយអសុចិផ្សេងៗ ហើយប្រសូត ដូច្នោះ ។ ពិតហើយ ខ្យល់កម្មជវាត មិនអាចធ្វើព្រះពោធិសត្វឲ្យមានជើងឡើងលើ មានក្បាលចុះក្រោមបាន ព្រះពោធិសត្វនោះ ដូចព្រះធម្មកថិកចុះអំពីធម្មាសនៈ និង ដូចបុរសចុះអំពីជណ្ដើរ ទ្រង់សណ្ដូកព្រះហស្ថទាំងពីរ និងព្រះបាទទាំងពីរ ប្រថាប់ឈរ មិនប្រឡាក់ដោយអសុចិណាមួយ ដែលមាននៅក្នុងព្រះគភ៌របស់ព្រះមាតាឡើយ ។

[២៥] បទថា ឧទកស្ស ធារា គឺ ធ្នារទឹក ។ ក្នុងធ្នារទឹកនោះ ទឹកត្រជាក់ហូរអំពីធ្នាំងមាស ទឹកក្ដៅហូរអំពីធ្នាំងប្រាក់ ។ មួយទៀត លោកពោលបទនេះដើម្បីសម្ដែងទឹកផឹក និងទឹកបរិភោគ និងធ្នារទឹកជាទីលេង មិនទូទៅដោយទឹកពួកដទៃនៃធ្នារទឹកទាំងនោះ ដែលមិនប្រឡាក់ដោយអសុចិយ៉ាងណាមួយលើផែនដី ។ មិនមានការកំណត់ទឹក ដែលនាំមកដោយធ្នាំងមាស និងធ្នាំងប្រាក់ដទៃ និងទឹកដែលហូរទៅកាន់ស្រះបោក្ខរណីមានហង្សវដក: ជាដើម ។

**[២៦-២៧]** បទថា សម្បតិជាតោ គឺ ប្រសូតបានមួយរំពេច ។ តែក្នុងបាលី លោកសម្ដែងមើលដូចឈ្មស្ដេចចេញចាកព្រះគភ៌របស់ព្រះមាតា តែក៏មិនគួរឃើញយ៉ាងនោះ ។ ព្រោះព្រហ្មទាំងឡាយ ទទួលព្រះពោធិសត្វនោះ ពេលស្ដេចប្រសូត ដោយសំណាញ់មាសជាមុន ។ ស្ដេចមហារាជទាំង ៤ ទទួលដោយកម្រាលធ្វើដោយស្បែកខ្លាដំបង អំពីដៃរបស់ព្រហ្មពួកនោះ ។ មនុស្សទាំងឡាយទទួលដោយសំពត់ពីរជាន់ ពីដៃរបស់ស្ដេចមហារាជទាំង ៤ ។ ព្រះពោធិសត្វផុតពីដៃមនុស្សទាំងឡាយហើយ ប្រតិស្ឋានលើផែនដី ។ បទថា សេតម្ហិ ឆត្តេ អនុធារិយមានេ សេចក្ដីថា កាលទេវតាបាំងស្វេតឆត្រទិព្វតាមស្ដេច ។ ក្នុងបទនេះ សូម្បីគ្រឿងរាជកកុធភ័ណ្ឌ ៥ មានព្រះខ័ន ជាដើម ដែលជាបរិវារនៃឆត្រនោះ ក៏ប្រាកដឡើងក្លាម ។ តែក្នុងបាលីលោកពោលដល់ឆត្រ ដូចព្រះរាជាក្នុងខណៈស្ដេចព្រះរាជដំណើរ ។ ក្នុងបញ្ចរាជកុក្កុដកណ្ឌនោះ ឆត្រប៉ុណ្ណោះប្រាកដ អ្នកកាន់ឆត្រមិនប្រាកដ ។ ដូចគ្នា ព្រះខ័ន ផ្ចិតស្លឹកត្នោត ផ្ចិតរោមកន្ទុយក្ងោក ផ្ចិតវាលវិជនី និងបាំងព្រះកក្រែ រមែងប្រាកដ អ្នកកាន់មិនប្រាកដ ។ ន័យថា ទេវតាទាំងឡាយ មិនប្រាកដរូបកាន់វត្ថុទាំងអស់នោះ ។ សូម្បីសេចក្ដីនេះ លោកក៏ពោលទុកថា ៖

**ពួកទេវតាបាំងឆត្រមានធ្មឹងច្រើន មានមណ្ឌលមួយពាន់**
**ឰដ៏អាកាសមានដងមាស ផ្ចិតចាមរមាសគ្រវីទៅមក តែ**

មិនឃើញអ្នកកាន់ផ្ចិតចាមរ និងឆត្រ ដូច្នេះ ។

បទថា សព្វា ច ទិសា នេះ លោកពោលដល់ព្រះពោធិសត្វប្រថាប់ឈរក្រោយអំពីស្តេចឈានព្រះបាទ ៧ ជំហានហើយ ទ្រង់ក្រឡេកមើលទិសទាំងអស់ មិនគួរឃើញយ៉ាងនោះឡើយ ។ សេចក្តីពិត ព្រះពោធិសត្វទ្រង់ផុតពីដៃរបស់ពួកមនុស្សហើយ ប្រតិស្ឋានលើផែនដី ទ្រង់ក្រឡេកមើលទិសខាងកើត ។ ច្រើនពាន់ចក្រវាឡបានជាទីទួលតែមួយដូចគ្នា ។ ក្នុងទីនោះ ពួកទេវតា និងមនុស្សបូជាដោយរបស់ក្រអូប និងផ្កាឈើផ្សេងៗ ជាដើម នាំគ្នាពោលថា បពិត្រព្រះមហាបុរស ក្នុងលោកនេះសូម្បីមនុស្សដូចព្រះអង្គក៏មិនមាន នឹងរកមនុស្សក្រៃលែងជាងព្រះអង្គបានអំពីណា ។ ព្រះពោធិសត្វទ្រង់ក្រឡេកមើលទិសធំ ៤ ទិសតូច ៤ ទិសខាងក្រោម ខាងលើ ទ្រង់មិនឃើញសូម្បីបុគ្គលដូចព្រះអង្គ ទ្រង់ត្រិះរិះថា នេះទិសខាងជើង ហើយទ្រង់បែរព្រះភ័ក្ត្រទៅទិសខាងជើង ទើបស្តេចយាងដោយព្រះបាទ ៧ ជំហាន ។ គប្បីជ្រាបសេចក្តីក្នុងបទនេះ យ៉ាងនេះ ។ បទថា អាសភិំ គឺ ខ្ពស់បំផុត ។ បទថា អគ្គោ គឺ ជាទីមួយរបស់ជនទាំងអស់ ដោយគុណធម៌ទាំងឡាយ ។ ២ បទទៀត ជាវេវចនៈរបស់បទនេះ ។ ព្រះពោធិសត្វទ្រង់ព្យាករណ៍ព្រះអរហត្ត ដែលព្រះអង្គត្រូវបានសម្រេចក្នុងអត្តភាពនេះ ដោយបទទាំងពីរថា នេះជាកំណើតចុងបំផុតរបស់អញ ឥឡូវនេះ ភពថ្មីពីនេះទៅទៀតមិនមានឡើយ ដូច្នេះ ។

ក៏ក្នុងបទនេះ គប្បីជ្រាបថា ការប្រតិស្ឋានលើផែនដីដោយព្រះបាទជាន់ស៊ប់ ជាបុព្វនិមិត្តនៃការបានឥទ្ធិបាទ ៤ , ការបែរព្រះភក្ត្រទៅកាន់ទិសឧត្តរ ជាបុព្វនិមិត្តនៃស្តេចគ្របសង្កត់មហាជន , ស្តេចឈានព្រះបាទ ៧ ជំហាន ជាបុព្វនិមិត្តនៃការបានរតនៈ គឺ ពោជ្ឈង្គៈ ៧ , ការបាំងស្វេត្រឆត្រទិព្វ ជាបុព្វនិមិត្តនៃការបានឆត្រដ៏ប្រសើរ គឺ វិមុត្តិ , ការបានរាជកុកុដភ័ណ្ឌ ៥ ជាបុព្វនិមិត្ត នៃការរួចផុតដោយវិមុត្តិ ៥ ការរមិលមើលនូវទិសទាំងពួង ជាបុព្វនិមិត្តនៃការបានអនាវរណញ្ញាណ , ការបន្លឺនូវអាសភិវាចា ជាបុព្វនិមិត្តនៃការប្រព្រឹត្តទៅនៃធម្មចក្រ ដែលមិនទាន់ប្រព្រឹត្តទៅ , ការបន្លឺសីហនាទថា នេះជាកំណើតចុងបំផុតរបស់អញ ជាបុព្វនិមិត្តនៃការបរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ ដូច្នេះ ។ វារៈទាំងនេះមកហើយក្នុងបាលី ។ តែច្រើនវារៈមិនទាន់មក គួរនាំមកសម្តែង ។

ពិតហើយ ក្នុងថ្ងៃព្រះមហាបុរសប្រសូត មុឺនលោកធាតុញាប់ញ័រទេវតាក្នុងមុឺនលោកធាតុ នាំគ្នាមកប្រជុំក្នុងចក្រវាឡតែមួយ ។ ទេវតាទទួលមុន ។ ពួកមនុស្សទទួលខាងក្រោយ ។ ពិណដែលមានខ្សែតឹងល្អស្គរដែលពាសស្បែក មិនមានអ្នកណាប្រគុំ ក៏ប្រគុំឡើងឯង ។ ប៉ម និងទីឃុំឃាំងជាដើម របស់ពួកមនុស្ស បាក់បែកជាដុំតូចៗ ។ រោគទាំងពួងស្ងប់អស់ទៅ ដូចស្នឹមមាសដែលលាងដោយរបស់ជូរ ។ អ្នកខ្វាក់ភ្នែកអំពីកំណើតក៏ឃើញរូប ។ អ្នកថ្លង់អំពីកំណើតបានឮសំឡេង ។ អ្នកពិការ

ក៏មានកម្លាំងបរិបូរណ៍ សតិរបស់មនុស្សស្លូម្បីអាក្រក់ដោយជាតិ មនុស្ស ឆ្កួតដោយទឹកប្រម៉ាត់ ក៏តាំងមាំបាន ។ ទូកដែលត្រាច់ទៅប្រទេសផ្សេងៗ ក៏ដល់កំពង់ដោយសប្បាយ ។ រតនៈដែលតាំងនៅលើអាកាស និងតាំង នៅលើផែនដី បានបញ្ចេញពន្លឺក្នុងកាលជាធំក្រៃលែងដោយខ្លួនឯង ។ អ្នក មានពៀរ ក៏មានមេត្តាចិត្តចំពោះគ្នា ។ ភ្លើងក្នុងអវិចីរលត់ ។ ពន្លឺក្នុង លោកន្តរនរកក៏កើតឡើង ទឹកក្នុងទន្លេមិនហូរ ។ ទឹកក្នុងមហាសមុទ្រ ក៏មានរសផ្អែម ។ ខ្យល់មិនបក់ ។ សត្វដែលហើរនៅលើអាកាស ដែល នៅលើភ្នំ និងដើមឈើ បានធ្លាក់ចុះទៅលើផែនដី ។ ព្រះចន្ទភ្លឺក្រៃលែង ណាស់ ។ ព្រះអាទិត្យមិនក្តៅមិនត្រជាក់ ប្រាសចាកមន្ទិល បានសម្បូរណ៍ តាមរដូវ ។ ពួកទេវតាប្រតិស្ឋាននៅក្នុងទ្វារវិមានរៀងៗ ខ្លួន លេងកីឡា យ៉ាងសប្បាយរីករាយ ដោយការទះដៃ ហួច បក់សំពត់ជាដើម ។ សូម្បី ភ្លៀងក៏បានធ្លាក់ចុះមកអំពីទិសទាំង ៤ ។ សេចក្តីស្រេកឃ្លានមិនបាន បៀតបៀនមហាជន ។ ទ្វារ និងបង្អួចទាំងឡាយបើកឯង ។ ឈើផ្កា ឈើផ្លែ ក៏ចេញផ្កាចេញផ្លែ ម៉ឺនលោកធាតុបានមានទង់ផ្កាឈើពាសពេញ ទាំងអស់ ។

សូម្បីក្នុងសេចក្តីនេះ គប្បីជ្រាបដូច្នេះ ម៉ឺនលោកធាតុញាប់ញ័រ ជាបុព្វនិមិត្តនៃការបានសព្វញ្ញុតញ្ញាណរបស់ព្រះមហាបុរសនោះ , ការប្រជុំ ក្នុងចក្រវាឡតែមួយរបស់ទេវតាទាំងឡាយ ជាបុព្វនិមិត្តនៃការប្រជុំដោយ

សភាពដូចគ្នានេះឯង ក្នុងកាលញ៉ាំងធម្មចក្រឲ្យប្រព្រឹត្តទៅ ហើយទទួលព្រះធម៌ , ការទទួលរបស់ពួកទេវតាគ្រាដំបូង ជាបុព្វនិមិត្តនៃការបានរូបាវចរឈាន ៤ , ការទទួលរបស់ពួកមនុស្សជាខាងក្រោយ ជាបុព្វនិមិត្តនៃការបានអរូបាវចរឈាន ៤ , ពិណដែលរឹតខ្សែល្អដេញដោយខ្លួនឯងជាបុព្វនិមិត្តនៃការបានអនុបុព្វវិហារធម៌ , ស្គរដែលពាសស្បែកគ្រាំពងដោយខ្លួនឯង ជាបុព្វនិមិត្តនៃការបានឮធម្មភេរីដ៏ធំសម្បើម , ប៉ម និងទីឃុំឃាំងជាដើមបាក់បែកដោយខ្លួនឯង ជាបុព្វនិមិត្តនៃការកាត់ផ្តាច់នូវអស្មិ-មានះ , មហាជនជាសះស្បើយពីរោគ ជាបុព្វនិមិត្តនៃការបានអរិយសច្ច ៤ , មនុស្សខ្វាក់ភ្នែកពីកំណើតឃើញរូបបាន ជាបុព្វនិមិត្តនៃការបានទិព្វចក្ខុ , មនុស្សត្រចៀកថ្លង់បានឮសំឡេង ជាបុព្វនិមិត្តនៃការបានទិព្វ-សោត , មនុស្សពិការមានកម្លាំង ជាបុព្វនិមិត្តនៃការបានឥទ្ធិបាទ ៤ , មនុស្សគ្លួតពីកំណើតមានសតិនិយាយបាន ជាបុព្វនិមិត្តនៃការបានសតិ-ប្បដ្ឋាន ៤ , ទូកត្រាច់ទៅប្រទេសផ្សេងៗ ដល់កំពង់ដោយសប្បាយ ជាបុព្វនិមិត្តនៃការបានបដិសម្ភិទា ៤ , ការដែលរតនៈបញ្ចេញពន្លឺដោយភាពជាធំក្រៃលែងរបស់ខ្លួន ជាបុព្វនិមិត្តនៃពន្លឺព្រះធម៌ ដែលព្រះពោធិសត្វនឹងប្រកាសដល់សត្វលោក , អ្នកមានពៀរគ្នាមានមេត្តាចិត្តចំពោះគ្នា ជាបុព្វនិមិត្តនៃការបានព្រហ្មវិហារ ៤ , ភ្លើងក្នុងអវិចីរលត់ ជាបុព្វនិមិត្តនៃការរលត់ភ្លើង ១១ កង , លោកន្តរនរកភ្លឺ ជាបុព្វនិមិត្តនៃការកម្ចាត់ភាព

ងងឹត គឺ អវិជ្ជា ហើយឃើញនូវពន្លឺនៃញាណ , ទឹកក្នុងទន្លេមិនហូរ ជាបុព្វនិមិត្តនៃការបានវេសារជ្ជធម៌ ៤ , ទឹកមហាសមុទ្រមានរសផ្អែម ជាបុព្វនិមិត្តនៃការមានរសតែមួយ ដោយរស គឺ ព្រះនិព្វាន , ការដែលខ្យល់មិនបក់ ជាបុព្វនិមិត្តនៃការទម្លាយទិដ្ឋិ ៦២ , សត្វទាំងឡាយមកកាន់ដី ជាបុព្វនិមិត្តនៃមហាជនអ្នកស្តាប់ឱវាទ ហើយដល់សរណៈដោយជីវិត , ការដែលព្រះចន្ទស្វាងស្វៃក្រៃលែង ជាបុព្វនិមិត្តនៃសេចក្តីល្អរបស់មនុស្សសត្វជាច្រើន , ការដែលព្រះអាទិត្យវៀរសេចក្តីក្តៅ និងត្រជាក់ ជាបុព្វនិមិត្តនៃការកើតសេចក្តីសុខផ្លូវកាយ និងផ្លូវចិត្ត ព្រោះរដូវសប្បាយ , ការដែលពួកទេវតាប្រតិស្ឋាននៅក្នុងទ្វារវិមាន រីករាយដោយការទះដៃជាដើម ជាបុព្វនិមិត្តនៃការដល់ភាពជាព្រះពុទ្ធហើយ ទ្រង់បន្លឺឧទាន , ការដែលភ្លៀងធ្លាក់ក្នុងទិសទាំង ៤ ជាបុព្វនិមិត្តនៃការធ្លាក់របស់ភ្លៀង គឺព្រះធម៌ដ៏ធំសម្បើម , ការមិនមានសេចក្តីស្រេកបៀតបៀន ជាបុព្វនិមិត្តនៃការបានទឹកអម្រឹត គឺ កាយគតាសតិ , ការមិនមានសេចក្តីឃ្លានបៀតបៀន ជាបុព្វនិមិត្តនៃភាពជាអ្នកដល់សេចក្តីសុខដោយវិមុត្តិសុខ , ការដែលទ្វារ និងបង្អួចបើកឯង ជាបុព្វនិមិត្តនៃការបើកទ្វារ គឺ មគ្គមានអង្គ ៨ , ការដែលដើមឈើចេញផ្កា និងផ្លែ ជាបុព្វនិមិត្តនៃផ្កាឈើ គឺ វិមុត្តិរីក និងភាពជាអ្នកពេញដោយភារៈ គឺ សាមញ្ញផល , ការដែលម៉ឺនលោកធាតុមានទង់ផ្កាឈើពាសពេញ ជាបុព្វនិមិត្តនៃភាពជាអ្នកមានទង់ផ្កាឈើ គឺ

អរិយៈ ។ នេះឈ្មោះ សម្ពហុលវារៈ ។

ក្នុងរឿងនេះជនទាំងឡាយសួរបញ្ហាថា ៖

ពេលដែលព្រះមហាបុរសប្រថាប់ឈរលើផែនដីហើយ ទ្រង់បែរព្រះភក្ត្រទៅទិសឧត្តរ ស្តេចទៅ ទ្រង់បានបន្លឺអាសភិវាចា ស្តេចយាងលើផែនដីឬ ឬថា ស្តេចទៅតាមអាកាស ស្តេចទ្រង់ទៅប្រាកដ ឬមិនប្រាកដ ស្តេចអាក្រាតព្រះកាយទៅ ឬតាក់តែងព្រះកាយ ស្តេចទៅដោយភាពជាក្មេង ឬជាមនុស្សចាស់ សូម្បីខាងក្រោយក៏បានជាដូច្នោះឬ ឬថា ជាទារកខ្ចីដដែលទៀត ។ ក៏បញ្ហានេះតាំងឡើងខាងក្រោមលោហប្រាសាទ ព្រះចូឡាភយត្ថេរអ្នកទ្រទ្រង់ព្រះត្រៃបិដក បានដោះស្រាយទុកហើយ ។

មានរឿងដំណាលមកថា ក្នុងរឿងនេះ ព្រះថេរៈពោលដល់សេចក្តីនោះទុកច្រើន ដោយអំណាចការពោលដល់ជោគល្អ ជោគអាក្រក់ កម្មចាស់និងការមិនប្រកាន់ខ្លួន ព្រោះភាពជាធំហើយក្នុងទីបំផុត បានព្យាករណ៍យ៉ាងនេះថា ព្រះមហាបុរសស្តេចទៅលើផែនដី តែបានប្រាកដដល់មហាជនហាក់ដូចជាស្តេចទៅតាមអាកាស ព្រះអង្គស្តេចទៅ តែដូចមិនប្រាកដដល់មហាជន , ស្តេចទៅដោយអាក្រាតព្រះកាយ តែប្រាកដដល់មហាជនដូចតាក់តែងព្រះកាយ , ស្តេចទៅដោយភាពជាអ្នកក្មេង តែប្រាកដដល់មហាជនដូចមានព្រះជន្ម ១៦ ព្រះវស្សា តែខាងក្រោយបានជាទារកខ្ចីដូចដើមមិនជាកម្លោះនោះទេ ដូច្នេះ ។ មួយទៀត បរិស័ទរបស់ព្រះថេរៈនោះ បាន

នាំគ្នាពេញចិត្តថា ព្រះថេរៈដោះស្រាយបញ្ហាល្អដូចព្រះពុទ្ធ ។ លោកន្ទ-វិកវារៈ មានន័យដូចដែលបានពោលទុកហើយ ។ ក៏ធម្មតា លោកពោលទុកហើយតាំងពីដើម ។ គប្បីជ្រាបថា ធម្មតាទាំងអស់នេះ រមែងមានចំពោះព្រះពោធិសត្វគ្រប់ព្រះអង្គ ។

## ពោលអំពីមហាលក្ខណៈ ៣២ ប្រការ

[២៨] *បទថា អទ្ទសា ខោ សេចក្ដីថា ព្រះរាជាពន្ធុមៈ បានទតឃើញព្រះកុមារដែលនាងស្នំឲ្យផ្ទំលើគ្រឿងទ្រទ្រង់ដាន់នាំមកគាល់ ។ បទថា មហាបុរិសស្ស សេចក្ដីថា នៃបុរសអ្នកធំក្រៃលែងដោយអំណាច ជាតិ គោត្រ ត្រកូល ប្រទេសជាដើម ។ បទថា ទ្វេ គតិយោ គឺ សេចក្ដីសម្រេចពីរយ៉ាង ។ ក៏ស័ព្ទថា គតិនេះ រមែងប្រព្រឹត្តទៅក្នុងគតិដែលសត្វទាំងឡាយគប្បីទៅ ដោយប្រភេទមាននរកជាដើម ក្នុងបាលីនេះថា ម្នាលសារីបុត្ត គតិ ៥ ទាំងនេះឯង ដូច្នេះ ។*

*រមែងប្រព្រឹត្តទៅក្នុងអជ្ឈាស្រ័យ ក្នុងបាលីនេះថា យើងមិនបានដឹងដំណើរមក និងដំណើរទៅ និងអជ្ឈាស្រ័យរបស់ពួកភិក្ខុ ដែលមានសីល មានកល្យាណធម៌ទាំងនេះបានឡើយ ។*

*រមែងប្រព្រឹត្តទៅក្នុងទីអាស្រ័យ ក្នុងបាលីនេះ ព្រះនិព្វានជាទីពឹងអាស្រ័យរបស់ព្រះអរហត្ត ។ម្យ៉ាងវិញទៀត រមែងប្រព្រឹត្តទៅក្នុងសេចក្ដីសម្រេចក្នុងបាលីនេះថា ម្នាលព្រហ្ម តថាគតរមែងដឹងការសម្រេចចុតិ និងឧប្បត្តិរបស់លោក ពួកព្រហ្មមានឫទ្ធិច្រើនយ៉ាងនេះ ។ គប្បីជ្រាបគតិស័ព្ទនោះ សូម្បីក្នុងបទនេះថា រមែងប្រព្រឹត្តទៅក្នុងសេចក្ដីសម្រេច ។ បទថា អនញ្ញា សេចក្ដីថា ឈ្មោះថា សេចក្ដីសម្រេចក្នុងគតិដទៃ រមែងមិន*

មាន ។ បទថា ធម្មិកោ សេចក្តីថា ប្រកបដោយកុសលធម៌ ១០ វៀរការ ដល់អគតិ ធម្មរាជា នេះ ជាវេវចនៈរបស់បទមុននោះឯង ។ ម្យ៉ាងទៀត ឈ្មោះថា ជាធម្មរាជា ព្រោះបានរាជសម្បត្តិដោយធម៌ ។

បទថា ចាតុរន្តោ សេចក្តីថា ភាពជាអ្នកមានឥស្សរៈក្នុងផែនដី មានមហាសមុទ្រ ៤ ជាព្រំដែន ដោយអំណាចសមុទ្រ ៤ មានសមុទ្រ ផ្នែកទិស ខាងកើតជាដើម ។ បទថា វិជិតាវី គឺ មានការឈ្នះសង្គ្រាម ។ អធិប្បាយថា សូម្បីជនបទ ដល់ភាពជាជនបទដែលឋិតថេរមាំមួន ព្រោះ ដូច្នោះ ព្រះកុមារទើបដល់ភាពជាអ្នកមានព្រះរាជអាណាចក្ររឹងមាំ ។ ពិត ហើយ កាលព្រះរាជាកាច បៀតបៀនលោកដោយដកពន្ធ និងដាក់អាជ្ញា ជាដើម ពួកមនុស្សនាំគ្នាលះបង់ចោលមជ្ឈិមជនបទ ទៅអាស្រ័យនៅតាម ភ្នំ និងត្រើយសមុទ្រជាដើម ចិញ្ចឹមជីវិតរស់នៅឯជាយដែន ។ ពួកមនុស្ស ត្រូវចោរចិត្តកាចបៀតបៀនដោយការប្លន់ប្រជាជន ទើបនាំគ្នាលះបង់ជាយ ដែន ទៅរកចិញ្ចឹមជីវិតក្នុងជនបទរបស់មនុស្សដែលខ្សត់ខ្សោយ ។ ជនបទ ក្នុងការឃុំគ្រងបែបនេះ រមែងមិនដល់ការរឹងមាំ ។ ក៏កាលព្រះកុមារនេះ សោយរាជសម្បត្តិ ជនបទរបស់ព្រះអង្គនឹងរឹងមាំ ដូចដាក់ផ្ទាំងថ្មទុកលើផែនដី ហើយលោមព័ទ្ធដោយផ្ទាំងដែក ព្រាហ្មណ៍អ្នកទស្សទាយទាំងឡាយ កាល បង្ហាញដូច្នេះ ទើបពោលថា ព្រះកុមារទើបដល់ភាពជាអ្នកមានព្រះរាជា- ណាចក្ររឹងមាំដូច្នេះ ។ រតនៈក្នុងបទថា ប្រកបដោយរតនៈ ៧ នេះ ដោយ

អត្ថ គឺ ញ៉ាំងសេចក្ដីត្រេកអរឲ្យកើត ។ មយ៉ាងវិញទៀត

**រតនៈធ្វើសេចក្ដីរីករាយ មានតម្លៃច្រើនរកអ្វីប្រៀបមិន**

**បាន ឃើញបានដោយលំបាក ជាវត្ថុប្រើប្រាស់របស់សត្វ**

**ដ៏វិសេស ព្រោះដូច្នោះទើបហៅថា រតនៈ ។**

មយ៉ាងទៀត ចាប់ផ្ដើមតាំងពីកាលដែលចក្ររតនៈកើត មិនមានទេវ-ស្ថានដទៃ ជនទាំងពួង រមែងធ្វើការបូជាចក្ររតន៍នោះឯងដោយរបស់ក្រអូប និងផ្កាឈើជាដើម និងការធ្វើការក្រាបថ្វាយបង្គំជាដើម ព្រោះដូច្នោះ រតនៈទើបប្រព្រឹត្តទៅដោយអត្ថថា គួរគោរពក្រែង ។

ការកាត់ថ្លៃថា ឈ្មោះថា ទ្រព្យមានប្រមាណប៉ុណ្ណេះ រមែងជាតម្លៃរបស់ចក្ររតនៈនោះឯងដូច្នេះ មិនមាន ព្រោះដូច្នោះ រតនៈទើបប្រព្រឹត្តទៅសូម្បីដោយអត្ថថា មានតម្លៃច្រើន ។

មយ៉ាងទៀត ចក្រកែវ មិនដូចរតនៈដទៃដែលមាននៅក្នុងលោក ព្រោះដូច្នោះ រតនៈ ទើបប្រព្រឹត្តទៅសូម្បីដោយអត្ថថា រកប្រៀបមិនបាន ។

ស្ដេចចក្រពត្តិ ឧប្បត្តិក្នុងកប្បដែលព្រះពុទ្ធទាំងឡាយឧប្បត្តិ ។ ក៏ប៉ុន្តែថា ព្រះពុទ្ធទាំងឡាយឧប្បត្តិក្នុងគ្រាខ្លះ ពេលខ្លះ ដូច្នោះ រតនៈទើបប្រព្រឹត្តទៅសូម្បីដោយអត្ថថា ឃើញបានដោយលំបាក ។

រតនៈនោះ រមែងកើតដល់សត្វដ៏វិសេស ក្រៃលែងដោយជាតិ រូប ត្រកូល និងភាពជាធំជាដើម មិនកើតដល់អ្នកដទៃ ព្រោះដូច្នោះ រតនៈ

ទើបប្រព្រឹត្តទៅស្ដួម្បីដោយអត្ថ គឺ ជារបស់ប្រើរបស់សត្វដ៏វិសេស ។

ម្យ៉ាងទៀត សូម្បីរតនៈដ៏សេស ក៏ដូចចក្រកែវនុ៎ះឯង ព្រះមហាបុរស ទ្រង់ប្រកបដោយរតនៈទាំង ៧ នេះ ដោយភាពជាបរិវារ និងដោយភាពជាឧបករណ៍នៃភោគៈទាំងពួង ព្រោះដូច្នោះ ព្រះមហាបុរស ទើបឈ្មោះថា ទ្រង់សម្បូរណ៍ដោយរតនៈ ៧ ។

ឥឡូវនេះ ដើម្បីសម្ដែងរតនៈទាំងនោះដោយសរុប ទើបត្រាស់ថា តស្សិមានិ ជាដើម ។

ក្នុងរតនៈទាំងនោះ នេះជាការអធិប្បាយដោយសង្ខេប ក្នុងបទថា ចក្រកែវជាដើម ចក្រកែវរមែងប្រាកដ អាចដណ្ដើមយកសិរីសម្បត្តិរបស់ទ្វីបធំទាំង ៤ មាន ទ្វីប ២.០០០ ជាបរិវារបាន ។ ដំរីកែវហោះទៅកាន់វេហាស៍ អាចចុះមកកាន់ផែនដី មានសាគរជាទីបំផុតមុនអាហារតែម្ដង ។ សេះកែវ ក៏ដូច្នោះដែរ ។ កាលមានសេចក្ដីងងឹតប្រកបដោយអង្គ ៤ កែវមណីអាចកម្ចាត់សេចក្ដីងងឹតប្រមាណមួយយោជន៍ ឲ្យភ្លឺស្វាងបាន ។ ស្ត្រីកែវ ជាអ្នកមានការប្រព្រឹត្តជាទីពេញចិត្ត វៀរទោស ៦ យ៉ាង ។ គហបតីកែវ អាចឃើញរណ្ដៅទ្រព្យដែលនៅខាងក្នុងផែនដីប្រមាណមួយយោជន៍បាន ។ បរិនាយកកែវ ពោលគឺ បុត្រដ៏ប្រសើរបំផុត អាចកើតក្នុងព្រះគភ៌របស់ព្រះអគ្គមហេសី ហើយគ្រងរាជសម្បត្តិបានទាំងអស់ រមែងប្រាកដ ។

បទថា បរោសហស្សំ គឺ ច្រើនជាងពាន់ ។ បទថា សូរា គឺ ក្លាហាន ។ បទថា វីរង្គរូបា គឺ មានរូបឆោមទ្រង់ទ្រាយសមជាវីរបុរស ។ បទនេះ ជាឈ្មោះរបស់សេចក្តីព្យាយាម ។ ឈ្មោះថា វីរង្គរូបា ព្រោះមានរូបរាងសមរម្យជាវីរបុរស ។ មានទ្រង់ទ្រាយសមជាវីរបុរស គឺ មានសេចក្តីព្យាយាមជាទីកើត មានសេចក្តីព្យាយាមជាសភាវៈ សម្រេចដោយសេចក្តីព្យាយាម ជាអ្នកមិនខ្ជិលច្រអូស ។ លោកអធិប្បាយថា សូម្បីច្បាំងរហូតដល់អស់មួយថ្ងៃ ក៏មិនហត់នឿយ ។

បទថា សាគរបរិយន្តំ សេចក្តីថា មានមហាសមុទ្រជាទីបំផុត ធ្វើភ្នំចក្រវាឡឲ្យជាព្រំប្រទល់ ។ បទថា អទណ្ឌេន សេចក្តីថា អ្នកណាពិន័យអ្នកមិនបានធ្វើខុស ១០០ ខ្ទះ ១.០០០ ខ្ទះ អ្នកនោះឈ្មោះថា ប្រើអំណាចដោយអាជ្ញា គឺ ទ្រព្យ ។ អ្នកណាចេញពាក្យបង្គាប់ឲ្យប្រហារនិងវុកកាន អ្នកនោះឈ្មោះថា ប្រើអំណាចដោយអាជ្ញា គឺ សស្ត្រា តែព្រះរាជាអង្គនេះ ទ្រង់លះអាជ្ញាសូម្បីទាំងពីរនោះ ទ្រង់គ្រប់គ្រងមិនចាំបាច់ប្រើអាជ្ញា ។ បទថា អសត្ថេន សេចក្តីថា អ្នកណាប្រើសស្ត្រាមានមុខតែម្ខាងជាដើម បៀតបៀនអ្នកដទៃ អ្នកនោះឈ្មោះថា ប្រើអំណាចដោយសស្ត្រា ។ តែព្រះរាជាអង្គនេះ ទ្រង់មិនធ្វើលោហិតរបស់នរណាៗ ត្រឹមតែសត្វរុយតូចផឹកបាន ឲ្យកើតឡើងដោយសស្ត្រា ទ្រង់បានទទួល ការទទួលអំពីព្រះរាជាដែលជាសត្រូវយ៉ាងនេះថា បពិត្រមហារាជ សូមព្រះអង្គស្តេចយាងមកដោយ

ធម៌ចុះ ដូច្នេះ ។ អធិប្បាយថា ទ្រង់ជណ្តើមផែនដីដូចពោលហើយ ទ្រង់គ្រប់គ្រង ទ្រង់ហាមប្រាម រហូតបានជាម្ចាស់គ្រប់គ្រង ។ គ្រាប្រាប់ដល់សេចក្តីសម្រេចទីមួយយ៉ាងនេះហើយ ដើម្បីនឹងប្រាប់សេចក្តីសម្រេចទីពីរ ទើបពោលពាក្យជាអាទិថា សចេ ខោ បន ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា **ព្រះកុមារនេះមានដំបូល គឺ កិលេសបើកហើយ** ព្រោះមានគ្រឿងបិទបាំងរាំង ពោលគឺ រាគៈ ទោសៈ មោហៈ មានះ ទិដ្ឋិ កិលេសតណ្ហាបើកហើយ គឺ កម្ចាត់បានហើយ ។ បាលីថា វិវដ្ដច្ឆទា ដូច្នេះខ្លះ ។ អធិប្បាយយ៉ាងនេះដូចគ្នា ។

[២៩-៣០] គ្រាប្រាប់សេចក្តីសម្រេចទីពីរយ៉ាងនេះហើយ ដើម្បីសម្តែងលក្ខណៈដែលជានិមិត្តនៃគតិទាំងនោះ ទើបពោលពាក្យជាអាទិថា អយំ ហិ ទេវ កុមារោ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា សុបតិដ្ឋិតបាទោ សេចក្តីថា ព្រះកុមារមិនដូចជាអ្នកដទៃ កាលអ្នកដទៃដាក់ជើងចុះលើផែនដី ចុងជើង ឬកែងជើង រមែងចុះមុន ក៏ប៉ុន្តែថា នៅប្រាកដប្រហោងកណ្តាល សូម្បីកាលលើកឡើងចំណែកមួយក្នុងចុងជើងជាដើមនោះឯង ក៏លើកឡើងមុន ។ បាតព្រះបាទទាំងអស់របស់ព្រះកុមារនោះ រមែងជាន់ផែនដីដោយទ្រង់ដាក់ព្រះបាទតែមួយដង ដូចផ្ទៃស្បែកជើងមាសដូច្នោះ ទ្រង់លើកព្រះបាទឡើងអំពីផែនដីក៏ដោយទំនងតែមួយគ្នាទុំះឯង ព្រោះដូច្នោះ ព្រះកុមារនេះ ទើប

ជាអ្នកមានព្រះបាទរាបស្មើគ្នា ។

បទថា ចក្កានិ លោកពោលទុកក្នុងបាលីថា ក្នុងផែនដី ព្រះបាទទាំង ២ មានចក្រ ២ កើតឡើង ចក្រទាំងនោះមានកាំ មានកង់ និងដុំ ។ ក៏គប្បីជ្រាបសេចក្ដីវិសេសនេះ ដោយបទនេះថា បរិបូរណ៍ដោយអាការទាំងពួង ។ បានឮថា ដុំរបស់ចក្រទាំងនោះប្រាកដត្រង់កណ្ដាលផ្ទៃព្រះបាត ។ ក្បាច់វង់មូលកំណត់ដោយដុំរមែងប្រាកដ វង់មូលលោមព័ទ្ធមុខដុំប្រាកដ ទ-ទឹកប្រាកដ កាំប្រាកដ ក្បាច់វង់មូលក្នុងកាំទាំងឡាយប្រាកដ កង់ប្រាកដ កង់កែវមណីប្រាកដ ។ នេះមកក្នុងបាលីមុនហើយ ។ តែសម្ពហុលវារៈនូវមិនទាន់មក ។ សម្ពហុលវារៈនោះ គប្បីជ្រាបយ៉ាងនេះ ។ រូបលំពែង រូបវង្វង់បំភ្លឺព្រះឆាយ រូបផ្កាត្រួត រូបខ្សែ ខ្សែរូបសង្វារ រូបថាសមាស រូបមច្ឆាគូ រូបតាំង រូបស្នូម រូបប្រាសាទ រូបសសរខឿន រូបស្វេតឆត្រ រូបព្រះខ័ឌ្គ រូបផ្លិតស្លឹកត្នោត រូបផ្លិតកន្ទុយសត្វក្ងោក រូបផ្លិតវាលវិជនី រូបមកុដ រូបកែវមណី រូបបាត្រ រូបកម្រងផ្កាម្លិះ រូបផ្កាឈូកស រូបផ្កាឈូកក្រហម រូបផ្កាឈូកខៀវ រូបផ្កាបទុម រូបផ្កាបុណ្ឌរិក រូបថ្នាំងពេញដោយទឹក រូបថាសពេញដោយទឹក រូបមហាសមុទ្រ រូបភ្នំចក្រវាឡ រូបព្រៃហិមពាន្ត រូបភ្នំសិនេរុ រូបព្រះចន្ទព្រះអាទិត្យ រូបផ្កាយនក្ខត្តឫក្ស រូបទ្វីបធំទាំង ៤ រូបទ្វីបតូច ២,០០០ ទាំងអស់ ដោយទីបំផុតសំដៅដល់បរិវាររបស់ស្ដេចចក្រពត្តិ ជាបរិវាររបស់ចក្រលក្ខណៈនុ៎ះឯង ។

បទថា អាយតបណ្ហិ សេចក្តីថា មានកែងព្រះបាទវែង គឺ មានកែងព្រះបាទបរិបូរណ៍ ។ អធិប្បាយថា កែងព្រះបាទរបស់ព្រះមហាបុរស មិនដូចជាចុងជើងរបស់អ្នកដទៃដែលវែង ស្នងជើងតាំងនៅបំផុតកែងជើង ដូចជាកាត់កែងជើងតាំងនៅដូច្នោះ ។ តែរបស់ព្រះមហាបុរស ព្រះបាទមាន ៤ ចំណែក ចុងព្រះបាទមាន ២ ចំណែក ដើមព្រះជង្ឃតាំងនៅក្នុងចំណែកទី ៣ កែងព្រះបាទក្នុងចំណែកទី ៤ ដូចគ្នានឹងកូនឃ្លីស្បែកធ្វើដោយសំពត់កម្ពលពណ៌ក្រហម ដូចស្រេះដោយចុងម្ជុលហើយតាំងទុក ។

បទថា ទីឃង្គុលិ សេចក្តីថា ម្រាមព្រះហស្តរបស់ព្រះមហាបុរស មិនដូចម្រាមរបស់អ្នកដទៃ ដែលម្រាមខ្លះវែង ម្រាមខ្លះខ្លី ។ តែរបស់ព្រះមហាបុរស ម្រាមព្រះហស្ត និងព្រះបាទវែងដូចរបស់ពានរ ខាងគល់ធំហើយស្រៀវទៅដោយលំដាប់ដល់ចុងម្រាម ដូចជាផង់មនោសិលាដែលគេលាយប្រេងហើយ ដូច្នេះ ។ ព្រោះដូច្នោះ លោកទើបពោលថា មានម្រាមព្រះហស្តវែងដូច្នេះ ។

បទថា មុទុតលុនហត្ថបាទោ សេចក្តីថា មានព្រះហស្ត និងព្រះបាទទន់ដូចសំឡីកប្បាសដែលវេ្តចបាន ១០០ ដង យកមកតាំងទុកក្នុងទឹកដោះថ្លា ។ សូម្បីក្នុងវេលាព្រះជន្មចម្រើន ព្រះហស្ត និងព្រះបាទ ក៏ទន់ល្អដូចកាលប្រសូត ។ ព្រះហស្ត និងព្រះបាទរបស់ព្រះពោធិសត្វនោះទន់ល្អ ព្រោះដូច្នោះ ព្រះពោធិសត្វទើបមានព្រះហស្ត និងព្រះបាទទន់ល្អ ។

បទថា ជាលហត្ថបាទោ សេចក្តីថា ចន្លោះព្រះអង្គុលី ស្បែកមិនជាប់គ្នា ។ ព្រោះអ្នកមានដៃជាប់គ្នាជាជួរដូច្នេះ ត្រូវកម្ចាត់ដោយបុរសមានទោស សូម្បីបួសក៏មិនបាន ។ ព្រះមហាបុរសមានម្រាមព្រះហស្ត ៤ ធ្នាប់ព្រះបាទ ៥ ជិតស្និទ្ធដូចតែមួយ ។ ក៏ព្រោះព្រះអង្គុលីទាំងឡាយជិតស្និទ្ធដូចជាតែមួយ ព្រះអង្គុលីទាំងឡាយ ទើបជាប់គ្នានិងគ្នា មានលក្ខណៈជាបាយជំណើបតាំងនៅ ។ ព្រះហស្ត និងព្រះបាទរបស់ព្រះពោធិសត្វនោះដូចគ្នានឹងបន្ទះក្រឡាសំណាញ់ ដែលជាងអ្នកឆ្លាតធ្វើហើយ ។ ព្រោះដូច្នោះលោកទើបពោលថា មានបាតព្រះហស្ត និងបាតព្រះបាទ មានធ្នូតដូចក្រឡាសំណាញ់ ។

ព្រោះក-ព្រះបាទតាំងនៅខាងលើ ព្រះបាទរបស់ព្រះពោធិសត្វនោះទើបដូចស័ង្ខផ្កាប់ ព្រោះដូច្នោះ ព្រះពោធិសត្វទើបមានព្រះបាទដូចស័ង្ខផ្កាប់ ។ ពិតហើយ កជើងរបស់អ្នកដទៃនៅត្រង់ខ្នងជើង ព្រោះដូច្នោះជើងរបស់អ្នកទាំងនោះ ទើបជាប់គ្នាដូចជាប់ដោយគន្លឹះ ត្រឡប់ទៅមកមិនបានតាមសប្បាយ កាលដើរទៅបាតជើងមិនប្រាកដ ។ តែកព្រះបាទរបស់ព្រះមហាបុរសឡើងទៅតាំងនៅខាងលើ ។ ព្រោះដូច្នោះ ព្រះវរកាយផ្នែកខាងលើរបស់ព្រះមហាបុរស តាំងពីព្រះនាភិឡើងទៅ ទើបមិនបានញាប់ញ័រឡើយ ដូចព្រះសុវណ្ណបដិមាប្រតិស្ឋាននៅក្នុងទូក ។ ព្រះវរកាយផ្នែកខាងក្រោម រមែងញាប់ញ័រ ។ ព្រះបាទត្រឡប់ទៅមកបានសប្បាយ ។

កាលជនទាំងឡាយឈរខាងមុខខ្លះ ខាងក្រោយខ្លះ សូម្បីក្នុងខាងទាំងពីរ ក៏ឃើញ បាតព្រះបាទរមែងប្រាកដ ។ តែមិនប្រាកដដូចឈរខាងក្រោយដំរី ។

បទថា ឯណិជង្ឃោ គឺ មានព្រះជង្ឃរៀវដូចសត្វទ្រាយ ។ អធិប្បាយថា មានព្រះជង្ឃបរិបូរណ៍ដោយដណ្តប់ព្រះមំសៈពេញ មិនមែនសាច់ត្រគាកជាប់ដោយភាពតែមួយ ប្រកបដោយព្រះជង្ឃ ដូចទឹងជង្ហឹមស្រូវសាលី ជង្ហឹមស្រូវជំណើប ឬស្រូវខ្សាយ ដែលមំសៈតាំងនៅស្មើគ្នាដោយជុំវិញហើយ មូលក្បំល្អ ។

បទថា អនោនមន្តោ គឺ មិនឱនចុះ ។ លោកសម្តែងដល់ព្រះ-មហាបុរសនោះមិនគម មិនតឿ ដោយបទនេះ ។ ក៏មនុស្សដ៏សេសជាមនុស្សគម ឬជាមនុស្សតឿ ។ មនុស្សគម កាយចំណែកខាងលើមិនបរិបូរ មនុស្សតឿ កាយចំណែកខាងក្រោមមិនបរិបូរ អ្នកទាំងនោះព្រោះកាយមិនបរិបូរកាលមិនឱនចុះ ទើបមិនអាចស្ទាបអង្រ្គលជង្គង់បាន ។ តែព្រះមហាបុរសព្រោះព្រះវរកាយទាំងចំណែកខាងលើ ចំណែកខាងក្រោមបរិបូរ ទើបអាចស្ទាបអង្រ្គលបាន ។

បទថា កោសោហិតវត្ថគុយ្ហោ សេចក្តីថា ព្រះមហាបុរសមានព្រះគុយ្ហៈលាក់នៅក្នុងស្រោម ដូចស្រោមឈូកមាស ដូចគុយ្ហៈនៃគោនិងដំរីជាដើម ព្រោះហេតុនោះ ព្រះមហាបុរស ទើបមានព្រះគុយ្ហៈលាក់នៅក្នុងស្រោម ។ បទថា វត្ថគុយ្ហំ លោកពោលអង្គជាតិគួរបិទបាំងដោយ

សំពត់ ។

បទថា សុវណ្ណវណ្ណោ សេចក្តីថា ព្រះមហាបុរសដូចទីងរូបជុំមាស ដែលលាយឡាំដោយពណ៌ក្រហម ហើយខាត់ដោយចង្កូមខ្លា ហើយលាយដោយជីក្រហមតាំងទុក ។ ដោយបទនេះ ដើម្បីសម្តែងដល់ព្រះវរកាយរបស់ព្រះមហាបុរសនោះ ស្និទ្ធល្អិតផូរផង់ហើយ ទើបសម្តែងព្រះឆវីវណ្ណ លោកទើបពោលថា ព្រះមហាបុរសមានព្រះឆវីវណ្ណដូចមាស ដូច្នេះ ។ម្យ៉ាងទៀត បទនេះជាវេវចនៈរបស់បទមុន ។

បទថា រជោជល្លំ គឺ ធូលី ឬមន្ទិល ។ បទថា ន ឧបលិម្បតិ សេចក្តីថា មិនជាប់ គឺ រមៀលដូចតំណក់ទឹករមៀលអំពីស្លឹកឈូក ។ ក៏ព្រះពុទ្ធទាំងពួងទ្រង់ធ្វើការជម្រះព្រះហស្តជាដើម ដើម្បីកំណត់រដូវ និងដើម្បីផលបុណ្យរបស់ពួកទាយក ។ ម្យ៉ាងទៀត ទ្រង់ធ្វើសូម្បីដោយគោលបដិបត្តិនោះឯង ។ ប្រការនេះ លោកពោលទុកថា ក៏ភិក្ខុទីងចូលទៅកាន់សេនាសនៈ គួរជម្រះជើងហើយ ទើបចូលទៅ ។

បទថា ឧទ្ធគ្គលោមោ សេចក្តីថា ព្រះមហាបុរស មានព្រះលោមជាតិមានចុងងឡើងខាងលើ ចុងវិលជាទក្ខិណាវដ្ត តាំងនៅសម្លឹងមើលព្រះភក្ត្រល្អ ព្រោះដូច្នោះ ព្រះមហាបុរសមានព្រះលោមជាតិមានចុងងឡើងខាងលើ ។

បទថា ព្រហ្មុជុគត្តោ សេចក្តីថា ព្រះមហាបុរស មានព្រះវរកាយ

ត្រង់ដូចកាយព្រហ្ម គឺ មានព្រះវរកាយខ្ពស់ត្រង់ឡើងទៅតែម្តង ។ សេចក្តីពិតដោយច្រើនសត្វទាំងឡាយ រមែងបន្ទោនទៅក្នុងទីទាំងបី គឺ ត្រង់ក ចង្កេះ និងជង្គង់ទាំងពីរ ។ សត្វទាំងនោះកាលឱនទៅ ចង្កេះ រមែងទៅខាងក្រោយ ។ ក្នុងទីទាំងពីរនោះ រមែងឱនទៅខាងមុខ ។ ក៏សត្វពួកខ្លះមានរាងកាយខ្ពស់ មានខាងវៀច ពួកខ្លះងើយមុខត្រាច់ទៅ ដូចជារាប់ដួងផ្កាយ ។ ពួកខ្លះមានសាច់ និងឈាមតិច ដូចជាអ្នកមានរោគចុកពោះ ។ ពួកខ្លះដើរទៅឈ្ងោកខាងមុខ ជង្គង់ទញ័រ ។ អាចារ្យទាំងឡាយពោលថា ក៏ព្រះមហាបុរសនេះ ទ្រង់ដំណើរព្រះវរកាយត្រង់តែម្យ៉ាង មានប្រមាណខ្ពស់ នឹងដូចជាសសរមាស ដែលលើកឡើងក្នុងទេវនគរ ។ ម្យ៉ាងទៀត គប្បីជ្រាបថា សេចក្តីនេះលោកពោលសំដៅដល់មហាបុរិសលក្ខណៈរបស់ព្រះមហាបុរស កាលដែលប្រសូតនូវមិនទាន់មានបរិបូណ៌ ដោយប្រការទាំងពួង នឹងចម្រើនក្នុងឱកាសតទៅ ។

បទថា សត្តុស្សទោ សេចក្តីថា ព្រះមហាបុរសមានព្រះមំសៈពេញបរិបូណ៌ដោយល្អក្នុងទី ៧ ស្ថាន គឺ ខ្នងព្រះហស្តទាំងពីរ ខ្នងព្រះបាទទាំងពីរ នឹងចង្កួយស្មាទាំងពីរ និងព្រះសុរង ព្រោះដូច្នោះ ព្រះមហាបុរសទើបឈ្មោះថា មានព្រះមំសៈពេញក្នុងទី ៧ ស្ថាន ។ តែរបស់មនុស្សពួកដទៃត្រង់ខ្នងដៃ និងខ្នងជើងជាដើម ប្រាកដសរសៃឈាមជាក្រឡាសំណាញ់ចង្កួយស្មា និងកប្រាកដចុងឆ្អឹង ។ មនុស្សទាំងនោះ រមែងប្រាកដដូចប្រេត ។

ព្រះមហាបុរសមិនប្រាកដយ៉ាងនោះ ។ ក៏ព្រះមហាបុរស មានព្រះសុរង្គ ដូចទីងស្គរមាសដែលគេក្រឡឹង ដោយខ្នងព្រះហស្តជាដើម មានសរសៃឈាមជាក្រឡាសំណាញ់លាក់ទុក ព្រោះមានព្រះមំសៈពេញបរិបូណ៌ក្នុងទី ៧ ស្ថាន រមែងប្រាកដដូចរូបសិលា និងរូបសូន ។

បទថា សីហបុព្វឌ្ឍកាយោ សេចក្តីថា ព្រះមហាបុរសមានពាក់កណ្តាលកាយខាងលើ ដូចពាក់កណ្តាលកាយខាងមុខរបស់រាជសីហ៍ ព្រោះដូច្នោះ ព្រះមហាបុរសទើបឈ្មោះថា មានចំណែកព្រះវរកាយខាងមុខ ដូចពាក់កណ្តាលកាយខាងមុខនៃរាជសីហ៍ ព្រោះថា កាយខាងមុខរបស់រាជសីហ៍បរិបូណ៌ កាយខាងក្រោយមិនបរិបូណ៌ ។ ព្រះវរកាយទាំងអស់របស់ព្រះ-មហាបុរសបរិបូណ៌ដូចកាយខាងមុខរបស់រាជសីហ៍ ។ សូម្បីព្រះវរកាយរបស់មហាបុរសក៏ដូចកាយរបស់រាជសីហ៍ មិនតាំងនៅខ្ពស់ៗ ទាបៗ ដោយអំណាចនៃការប៉ោងឡើង និងផតចុះជាដើម តែវែងក្នុងទីគួរវែង ខ្លីក្នុងទីគួរខ្លី មាំមួន រៀវ ទូលាយ មូលជាដើម ។ ដូចដែលព្រះអង្គត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ព្រះមហាបុរសទ្រង់ស្រស់ស្រាយព្រះទ័យពេកណាស់ កាលផលកម្មប្រាកដ ទ្រង់ស្រស់ល្អ ព្រោះអវយវៈចំណែកណាវែង អវយវៈចំណែកនោះរមែងតាំងនៅវែង ទ្រង់ស្រស់ល្អ ព្រោះអវយវៈចំណែកណាខ្លី អវយវៈចំណែកនោះរមែងតាំងនៅខ្លី ទ្រង់ស្រស់ល្អ ព្រោះអវយវៈចំណែកណាមាំមួន អវយវៈចំណែកនោះរមែងតាំងនៅមាំមួន ទ្រង់ស្រស់ល្អ ព្រោះអវយវៈ

ចំណែកណាវៀវ អវយវៈចំណែកនោះរមែងតាំងនៅវៀវ ទ្រង់ស្រស់ល្អ ព្រោះអវយវៈចំណែកណាទូលាយ អវយវៈចំណែកនោះរមែងតាំងនៅទូលាយ ទ្រង់ស្រស់ល្អ ព្រោះអវយវៈចំណែកណាមូល អវយវៈចំណែកនោះរមែងតាំងនៅមូល ដូច្នេះ ។ អត្តភាពរបស់ព្រះមហាបុរសសន្សំទុកដោយទានចិត្ត បុញ្ញចិត្ត រៀបចំទុកដោយបារមី ១០ ដោយប្រការដូច្នេះ ។ សិល្បៈទាំងពួង ឬអ្នកមានឫទ្ធិទាំងពួងក្នុងលោក មិនអាចសាងរូបប្រៀបបាន ។

បទថា ចិតន្តរំសោ សេចក្តីថា ក្នុងចន្លោះចំណែកទាំងពីរ លោកពោលថា អន្តរំសោ ។ ព្រះមហាបុរសមានព្រះអង្សាពេញ គឺ បរិបូណ៌ ព្រោះដូច្នោះ ព្រះមហាបុរសទើបមានចន្លោះព្រះអង្សាពេញ ។ កន្លែងពិតឋានៈនោះរបស់មនុស្សពួកដទៃ ខ្នងផត និងពោះទាំងពីរប្រាកដចំពោះខ្លួន ។ តែរបស់ព្រះមហាបុរសផ្ទៃព្រះមំសា តាំងពីពាក់កណ្តាលព្រះអង្គ ដរាបដល់ព្រះសុរងឡើងទៅបិទព្រះបិដ្ឋិ តាំងនៅដូចផែនក្តារមាស ដែលលើកឡើងតាំងទុក ។

បទថា និគ្រោធបរិមណ្ឌលោ គឺ ព្រះមហាបុរសមានបរិមណ្ឌលដូចដើមនិគ្រោធ ។ អធិប្បាយថា ព្រះមហាបុរសសូម្បីព្រះវរកាយ សូម្បីដោយព្យាម ប្រមាណប៉ុនគ្នាដូចដើមនិគ្រោធ មានដើម និងមែកស្មើគ្នា ព្រោះថាទីងជា ៥០ ហត្ថក៏ដោយ ១០០ ហត្ថក៏ដោយ រមែងមានប្រមាណប៉ុនគ្នាទាំងផ្នែកបណ្តោយទាំងផ្នែកទទឹង ។ កាយរបស់មនុស្សដទៃវែងមិនស្មើគ្នា

ព្រោះដូច្នោះឯង លោកទើបពោលថា យាវតក្វស្ស កាយោ ជាដើម ។ យាវតក្វស្ស កាត់បទជា យាវតកោ អស្ស សេចក្តីថា ព្រះវរកាយរបស់ព្រះមហាបុរសស្មើនឹងព្យាមរបស់ព្រះមហាបុរស ព្យាមរបស់ព្រះមហាបុរសស្មើនឹងកាយរបស់ព្រះមហាបុរស ។

បទថា សមវដ្ដក្ខន្ធោ គឺ ព្រះមហាបុរស មានបំពង់ព្រះសុរង់ស្មើគ្នា ។ អ្នកខ្លះមានដើមកវែង ខ្លី ក្រាស់ ដូចសត្វមៀម កុក ជ្រូក វេលានិយាយសរសៃជាក្រឡាសំណាញ់រមែងប្រាកដ សំឡេងចេញមកស្អកៗ យ៉ាងណារបស់ព្រះមហាបុរសមិនដូច្នោះ ។ ក៏បំពង់ព្រះសុរង់របស់ព្រះមហាបុរសដូចគ្នានឹងស្គរមាសដែលគេក្រឡឹងល្អហើយ ។ វេលាត្រាស់ សរសៃជាក្រឡាសំណាញ់មិនប្រាកដ ព្រះសូរសៀងខ្លាំងរំពងដូចសំឡេងផ្គរលាន់ ។

ក្នុងបទថា រសគ្គសគ្គី នេះ មានវិគ្រោះថា សរសៃប្រសាទនាំរសទៅ ឈ្មោះថា រសគ្គសា ។ បទនេះ ជាឈ្មោះរបស់សរសៃប្រសាទដែលនាំរសអាហារទៅ ។ សរសៃប្រសាទនាំរសអាហាររបស់ព្រះមហា-បុរសនោះដ៏យ៉ាងប្រសើរ ព្រោះហេតុនោះ ព្រះមហាបុរសទើបជាអ្នកមានចុងសរសៃប្រសាទសម្រាប់នាំរសអាហារដ៏ប្រសើរ ។ បានឮថា ព្រះមហាបុរសមានសរសៃប្រសាទសម្រាប់នាំរសអាហារប្រមាណ ៧.០០០ សរសៃមានចុងឡើងខាងលើ ហើយរួមចូលត្រង់បំពង់ព្រះសុរង់នុ៎ះឯង ។ ព្រះក្រយាហារ សូម្បីប៉ុនគ្រាប់ល្ងតាំងនៅក្នុងចុងព្រះជិវ្ហា រមែងផ្សាយទូទៅ

ព្រះវរកាយគ្រប់ចំណែក ។ ដោយហេតុនោះឯង កាលព្រះមហាបុរសទ្រង់ផ្តើមតាំងសេចក្តីព្យាយាមដ៏ធំក្រៃលែង បានញុំាងព្រះវរកាយឲ្យប្រព្រឹត្តទៅបាន ដោយបាយមួយគ្រាប់ជាដើមខ្លះ ដោយត្រឹមតែបន្ទៃជ្រក់មួយទុកដៃខ្លះ ។ តែចំពោះមនុស្សដទៃមិនមានយ៉ាងនោះ រសឱជាទើបមិនផ្សាយទូទៅទាំងកាយ ។ ព្រោះហេតុនោះ ជនទាំងនោះទើបមានរោគច្រើន ។

បទថា សីហហនុ មានវិគ្រោះថា ព្រះហនុរបស់ព្រះមហាបុរសដូចចង្ការបស់រាជសីហ៍ ព្រោះហេតុនោះ ព្រះមហាបុរសទើបមានព្រះហនុដូចចង្ការាជសីហ៍ ។ ក្នុងបទនោះអធិប្បាយថា រាជសីហ៍មានចង្កាកំណាត់ក្រោមបរិបូរណ៍ កំណាត់លើមិនបរិបូណ៌ ។ តែព្រះមហាបុរសបរិបូណ៌សូម្បីទាំងពីរដូចចង្កាខាងក្រោមរបស់រាជសីហ៍ ដូចជាព្រះចន្ទក្នុងថ្ងៃ ១២ កើត ។ លំដាប់នោះ ព្រាហ្មណ៍អ្នកព្យាករណ៍ទាំងឡាយ សម្លឹងមើលចុងព្រះហនុសង្កេតក្លាមថា ដែលព្រះហនុទាំងនេះ ព្រះទន្ត ៤០ គឺ ខាងក្រោម ២០ ខាងលើ ២០ នឹងតាំងនៅស្មើគ្នាយ៉ាងស្និទ្ធ ទើបក្រាបទូលថា បពិត្រព្រះសម្មតិទេព ព្រះកុមារនេះមានព្រះទន្ត ៤០ គត់ ក្រាបទូលដូច្នេះជាដើម ។ ក្នុងបទនោះមានអធិប្បាយដូចតទៅនេះ មនុស្សពួកដទៃ សូម្បីមានធ្មេញគ្រប់បរិបូណ៌ ក៏មានត្រឹម ៣២ គ្រាប់ ។ តែព្រះកុមារនេះនឹងមាន ៤០ គ្រាប់ , មយ៉ាងទៀត របស់មនុស្សពួកដទៃ ធ្មេញខ្លះខ្ពស់ខ្លះទាប ខ្លះមិនស្មើគ្នា ។ តែរបស់ព្រះកុមារនេះ នឹងស្មើគ្នាដូចគម្របស័ង្ខ

ដែលជាងដែកកាត់ ដូច្នោះ ។ ធ្មេញរបស់មនុស្សពួកដទៃ ឃ្លាតឆ្ងាយ ដូចធ្មេញក្រពើ កាលទំពារត្រី និងសាច់ រមែងសៀតនឹងចន្លោះធ្មេញ ។ តែព្រះទន្តរបស់ព្រះកុមារនេះ ជិតស្និទ្ធដូចជួរកែវវជិរៈ ដែលគេតាំងទុកលើផែនក្តារមាស នឹងដូចពេលដែលគេសម្តែងដោយជីពណ៌ស , មយ៉ាងទៀតធ្មេញរបស់មនុស្សពួកដទៃ មានធ្មេញចំពើស ព្រោះហេតុនោះ ក៏ខៀវខ្លះខ្មៅខ្លះ មិនមានពណ៌ខ្លះ ។ តែព្រះកុមារនេះ មានព្រះទាឋៈសស្អាត នឹងព្រះទាឋៈប្រកបដោយរស្មីរុងរឿងក្រៃលែងជាងសូម្បីផ្កាយព្រឹក្ស ។

បទថា បហុតជិវ្ហោ គឺ ព្រះកុមារមានព្រះជិវ្ហាធំ ។ អធិប្បាយថា អណ្តាតរបស់មនុស្សពួកដទៃ ក្រាស់ខ្លះ តូចខ្លះ ខ្លីខ្លះ រឹងខ្លះ មិនស្មើខ្លះ ។ តែព្រះជិវ្ហារបស់ព្រះមហាបុរស ទន់ វែង ធំ សម្បូរណ៍ដោយពណ៌ ។ ព្រះកុមារនោះ កាលកម្ចាត់សេចក្តីសង្ស័យរបស់អ្នកដែលមកដើម្បីស្វែងរកលក្ខណៈនោះ ព្រោះព្រះជិវ្ហាទន់ ទើបទ្រង់លៀនព្រះជិវ្ហានោះ ដូចរបស់រឹងដែលស្អាតហើយលូកចូលប្រហោងព្រះនាសិកទាំងពីរបាន ព្រោះព្រះជិវ្ហាវែងទើប ទ្រង់ស្ទាបប្រហោងព្រះកណ្ណៈទាំងពីរបាន ព្រោះព្រះជិវ្ហាធំ ទើបទ្រង់បិទព្រះនលាដសូម្បីទាំងអស់ដល់ទីបំផុតចុងព្រះកេសា ទ្រង់ប្រកាសដល់ព្រះជិវ្ហានោះទន់ វែង និងធំយ៉ាងនេះ ទើបទ្រង់កម្ចាត់សេចក្តីសង្ស័យរបស់ព្រាហ្មណ៍អ្នកព្យាករណ៍ទាំងនោះបាន ។ បទថា បហុតជិវ្ហោ លោកពោលសំដៅដល់ព្រះជិវ្ហា ដែលដល់ព្រមដោយលក្ខណៈទាំង ៣ យ៉ាងនេះ ។

បទថា ព្រហ្មស្សរោ សេចក្តីថា សូម្បីមនុស្សពួកដទៃ រមែងមានសំឡេងស្អកខ្លះ បែកខ្លះ ។ សំឡេងដូចក្អែកខ្លះ ។ តែព្រះកុមារនេះទ្រង់ប្រកបដោយសំឡេងដូចសំឡេងរបស់ស្តេចមហាព្រហ្ម ។ សេចក្តីថា ស្តេច មហាព្រហ្មមានសំឡេងច្បាស់ ព្រោះមិនលាយដោយទឹកប្រម៉ាត់ និងស្លេស្ម ។ កម្មសូម្បីដែលព្រះមហាបុរសទ្រង់ធ្វើហើយ រមែងជម្រះវត្ថុនៃសំឡេងនោះ ។ ព្រោះវត្ថុបរិសុទ្ធិ សំឡេងប្រាកដឡើងតាំងពីព្រះនាភីជាសំឡេងបរិសុទ្ធិ ប្រកបដោយអង្គ ៨ រមែងប្រាកដច្បាស់ ។ ព្រះកុមារត្រាស់ដូចសំឡេងសត្វករវិក ព្រោះហេតុនោះ ព្រះកុមារទើបត្រាស់មានសំនៀងដូចសំឡេងសត្វការវិក ។ អធិប្បាយថា ព្រះកុមារមានព្រះសូរ-សៀងក្រអៅពីរោះដូចសំឡេងសត្វករវិក ដែលគួរសរសើរ ។

បទថា អភិនីលនេត្តោ សេចក្តីថា ព្រះកុមារមានព្រះនេត្រ មិនខ្មៅទាំងអស់ ។ ព្រះនេត្ររបស់ព្រះកុមារនោះ ប្រកបដោយពណ៌ខៀវបរិសុទ្ធិក្រៃលែងណាស់ ដូចនឹងផ្កាត្រកៀត ។ ក្នុងទីដែលគួរលឿង ក៏មានពណ៌លឿង ដូចនឹងផ្កាកណ្ណិកា ។ ក្នុងទីដែលគួរក្រហម ក៏មានពណ៌ក្រហមដូចនឹងផ្កាច្បារ ។ ក្នុងទីដែលគួរស ក៏មានពណ៌ដូចផ្កាយព្រឹក្ស ក្នុងទីគួរខ្មៅ ក៏មានពណ៌ខ្មៅដូចនឹងផ្លែផ្គាំ ព្រះនេត្ររមែងប្រាកដដូចនឹងសីហបញ្ជរកែវដែលផ្សាយចេញហើយក្នុងវិមានមាស ។

បទថា បខុមំ ក្នុងបទថា គោបខុមោ នេះ លោកបំណងយក

ដូងនេត្រទាំងអស់ ។ គ្រាប់ភ្នែកនោះ របស់កូនគោខ្មៅ ជាធាតុក្រាស់ របស់កូនគោក្រហមថ្លាផូរផង់ អធិប្បាយថា ព្រះកុមារមានគ្រាប់ព្រះនេត្រ ដូចនឹងកូនគោក្រហម ដែលទើបនឹងកើតបានមួយភ្លែត ។ ពិតហើយ គ្រាប់ភ្នែករបស់មនុស្សពួកដទៃមិនបរិសុទ្ធិ ប្រកបដោយភ្នែកលៀនចេញ មកខ្លះ លឹបចូលទៅខ្លះ ដូចនឹងភ្នែកសត្វ មានដំរី និងកណ្តុរជាដើម ។ តែព្រះនេត្ររបស់ព្រះមហាបុរស សន្សំទុកដោយសេចក្តីស្រទន់ស្និទ្ធ ខ្មៅ ល្អិត ដូចកែវមណីមូល ដែលគេខាត់ហើយតាំងទុក ។

បទថា ឧណ្ណា គឺ ព្រះឧណ្ណាលោម ។ បទថា ភមុកន្តរេ សេចក្តីថា ព្រះឧណ្ណាលោម កើតក្នុងទីបំផុតព្រះនាសិក កណ្តាលចិញ្ចើមទាំងពីរ និង ឡើងទៅកើតត្រង់កណ្តាលព្រះនលាដ ។ បទថា ឱទាតា សេចក្តីថា បរិសុទ្ធិ គឺ មានពណ៌ស្មើដោយផ្កាយព្រឹក្ស ។ បទថា មុទុ សេចក្តីថា ព្រះឧណ្ណាលោម ដូចនឹងសរសៃកប្បាសដែលថ្លុចបាន ១០០ ដង ដែលគេ ដាក់ចុះទៅក្នុងទឹកដោះថ្លា តាំងទុក ។ បទថា តូលសន្និភា គឺ ស្មើដោយ សំឡីរកា និងសំឡីគ ។ នេះជាសេចក្តីប្រៀប ព្រោះភាពសរបស់សំឡី ។ ក៏កាលចាប់ចុងសរសៃព្រះលោមា ហើយទាញចេញ នឹងបានប្រមាណកន្លះ ព្រះពាហា កាលលែងទៅ សរសៃព្រះលោមាក៏នឹងមូរជាទក្ខិណាវដ្ត មាន ចុងខាងលើតាំងនៅ , ព្រះឧណ្ណាលោមនោះ រមែងរុងរឿងទៅដោយសិរី ជាទីចាប់ចិត្តក្រៃលែងណាស់ ដូចពងទឹកប្រាក់ តាំងនៅត្រង់កណ្តាលផែន

ក្តារមាស ដូចខ្សែទឹកដោះហូរចេញពីផ្ទាំងមាស និងដូចផ្កាយព្រឹក្សលើផ្ទៃមេឃ ជះសាចដោយពន្លឺអរុណ ។

បទថា ឧណ្ហីសសីសោ នេះ លោកពោលអាស្រ័យអំណាចប្រយោជន៍ ២ យ៉ាង គឺ ព្រះនលាដបរិបូណ៌ និងព្រះសិរសាបរិបូណ៌ ។ អធិប្បាយថា ព្រោះថា ផ្ទៃព្រះមំសៈរបស់ព្រះមហាបុរសនោះ ដុះឡើងតាំងពីគុម្ពព្រះកណ្ណៈខាងស្តាំ ប្រក់ព្រះនលាដទាំងអស់ ពេញបរិបូណ៌ទៅដល់គុម្ពព្រះកណ្ណៈខាងឆ្វេង ស្រស់ល្អដូចផែនឧណ្ហីស គ្រឿងប្រដាប់របស់ព្រះរាជា ។ បានឮថា ជនទាំងឡាយឃើញលក្ខណៈនេះរបស់ព្រះមហាបុរស បានធ្វើផ្ទាំងព្រះឧណ្ហីសៈសម្រាប់ព្រះរាជាទាំងឡាយ ។ នេះជាន័យប្រការមួយមុន ។ ក៏ជនពួកដទៃមានសិរសៈមិនបរិបូណ៌ ។ អ្នកខ្លះមានសិរសៈដូចស្វា អ្នកខ្លះមានសិរសៈដូចផ្លែឈើ អ្នកខ្លះមានសិរសៈដូចដំរី អ្នកខ្លះមានសិរសៈដូចផ្ទាំង អ្នកខ្លះមានសិរសៈដូចញកភ្នំ ។ តែព្រះមហាបុរសមានព្រះសិរសាដូចនឹងពងទឹក បរិបូណ៌ល្អ ដូចមូរដោយចុងម្ជុលតាំងទុក ។ ក្នុងពីរន័យនោះ ក្នុងន័យដំបូង ព្រះកុមារមានព្រះសិរសា ដូចព្រះសិរសា ប្រដាប់ដោយក្របព្រះភ័ក្ត្រ ។ ព្រោះហេតុនោះ ព្រះកុមារទើបឈ្មោះថា មានព្រះសិរសាដូចប្រដាប់ដោយក្របព្រះភ័ក្ត្រ ។ ក្នុងន័យទីពីរ ព្រះកុមារមានព្រះសិរសាជាបរិមណ្ឌលក្នុងទីទាំងពួង ដូចឧណ្ហីសៈ ព្រោះហេតុនោះ ទើបឈ្មោះថា មានព្រះសិរសាជាបរិមណ្ឌល ដូចឧណ្ហីសៈ ។

## ពោលអំពីប្រវត្តិព្រះវិបស្សីកុមារ

[៣១] បទថា សត្ថកាមេហិ នេះ លោកពោលថា ព្រះរាជាពន្ធុមៈ ឲ្យពួកព្រាហ្មណ៍មើលលក្ខណៈហើយ ដុបលៀងខាងក្រោយ ។ តែមិនគួរ ឃើញយ៉ាងនោះ ។ គប្បីជ្រាបថា ព្រះរាជាពន្ធុមៈ ទំនុកបម្រុងដុបលៀង ពួកព្រាហ្មណ៍ហោរា ដរាបផ្អែតគ្រប់គ្រាន់ជាមុនហើយ ទើបឲ្យពិនិត្យមើល លក្ខណៈជាខាងក្រោយ ។ សេចក្តីពិស្តាររបស់រឿងនោះ លោកពោល ទុកហើយក្នុងការឈានចុះកាន់ព្រះគភ៌ ។ បទថា ធាយេន្តិ គឺ ឲ្យផឹកទឹក ដោះ ។ បានឮថា ព្រះរាជាពន្ធុមៈបញ្ជាឲ្យនាងមេដោះ ៦០ នាក់ ផ្សំទឹក ដោះមានរសផ្អែមប្រាសចាកទោសបម្រុងព្រះពោធិសត្វ ។ សូម្បីនាងមេដោះ ដែលនៅសល់សុទ្ធជាអ្នកឆ្លាតក្នុងការងារនោះៗ ក៏មួយផ្ទែក ៦០ ដូចគ្នា ។ បញ្ជាឲ្យប្រុសៗ ៦០ នាក់ ធ្វើនាទីបម្រើនាងមេដោះទាំងនោះ ។ បញ្ជាឲ្យ តាំងអាមាត្យ ៦០ នាក់ ចាំមើលការធ្វើ និងមិនធ្វើរបស់ប្រុសៗ នោះ ។ ដោយប្រការដូច្នេះ បានមានឧបដ្ឋាក ៣៦០ នាក់ គឺ ពួកស្ត្រី ២៤០ នាក់ ពួកប្រុសៗ ១២០ នាក់ ។ បទថា សេតច្ឆត្តំ គឺ ទិព្វសេ្វតឆត្រ ។ ក៏ ទិព្វសេ្វតឆត្រ ជារបស់ដែលត្រកូលឲ្យតាំងនៅក្នុងបន្ទប់សិរីនោះឯង ។ គប្បីជ្រាបសេចក្តីថា កុំគ្របសង្កត់ឡើយ ក្នុងបទជាដើមថា មា នំ សីតំ វា ដូច្នេះ ។

បទថា ស្វាស្សុសុទំ កាត់បទជា សោ អស្សុ សុទំ ។ បទថា អង្កេនេវអង្កំ សេចក្តីថា ព្រះកុមារនោះ ដែលបុគ្គលផ្លាស់ប្តូរគ្នាព ផ្លាស់ប្តូរគ្នាបីត្រកង ។ បទថា បរិហរិយតិ សេចក្តីថា នាំទៅ គឺ ពទៅ ។

បទថា មញ្ជុស្សរោ គឺ ព្រះកុមារមានព្រះសូរសៀងមិនគ្រលរ ។ បទថា វគ្គុស្សរោ គឺ ព្រះកុមារមានព្រះសូរសៀងពេញទៅដោយសេចក្តីឆ្ងាត ។ បទថា មធុរស្សរោ គឺ ព្រះកុមារមានព្រះសូរសៀងគួរពេញចិត្ត ។ បទថា បេមនីយស្សរោ គឺ ព្រះកុមារមានព្រះសូរសៀងធ្វើឲ្យកើតសេចក្តីស្រឡាញ់ ។ សេចក្តីនេះ ជាអធិប្បាយក្នុងបទនោះ ព្រោះសត្វករវិកមានសំឡេងពីរោះ បានឮមកថា កាលសត្វករវិកចឹកស្វាយទុំ មានរសឆ្ងាញ់ដោយចំពុះ ហើយផឹករសដែលហូរចេញមក ទទះស្លាបស្រែក បណ្តាសត្វជើង ៤ ផ្តើមឈានទៅមុខទ្រេតទ្រោតដូចស្រវឹង ។ បណ្តាសត្វជើង ៤ សូម្បីកំពុងស៊ីអាហារ ក៏ចោលស្មៅដែលចូលទៅក្នុងមាត់ ដើម្បីស្តាប់សំឡេងនោះ ។ បណ្តាម្រឹគកាចដែលកំពុងដេញតាមពួកម្រឹគតូចៗ ក៏ដាក់ជើងដែលលើកឡើងឈរស្ងៀម ។ និងបណ្តាម្រឹគដែលត្រូវដេញតាម ក៏លះសេចក្តីខ្លាចស្លាប់ឈរស្ងៀម ។ សូម្បីបណ្តាសត្វកំពុងហើរនៅលើអាកាសក៏ត្រដាងស្លាបឈប់ស្តាប់សំឡេង ។ សូម្បីបណ្តាត្រីក្នុងទឹក ក៏កម្រើកស្លឹកត្រចៀកឈប់ស្តាប់សំឡេងនោះ ។ សត្វករវិកមានសំឡេងពីរោះយ៉ាងនេះ ។

សុមេធាព្រះនាងអសន្ធិមិត្តា ព្រះទេវីរបស់ព្រះបាទធម្មាសោករាជ ក៏បានត្រាស់សួរព្រះសង្ឃថា លោកម្ចាស់សំឡេងរបស់អ្នកណាៗ ដូចនឹងសំឡេងរបស់ព្រះពុទ្ធ មាននៅឬទេ ។ ព្រះសង្ឃថ្វាយព្រះពរថា ថ្វាយព្រះពរ មានសំឡេងរបស់សត្វករវិក ។ លោកម្ចាស់ សត្វទាំងនោះនៅទីណា , ថ្វាយព្រះពរថា នៅក្នុងព្រៃហិមពាន្ត ព្រះទេវីទូលព្រះរាជាថា បពិត្រព្រះទេវៈ ខ្ញុំម្ចាស់ប្រាថ្នានឹងឃើញសត្វករវិកព្រះពរ ។ ព្រះរាជាទ្រង់អធិដ្ឋានថា សត្វករវិកចូរមកទុំក្នុងទ្រុងនេះ ហើយលែងទ្រុងមាសទៅ ។ ទ្រុងមាសបានទៅតាំងនៅខាងមុខសត្វករវិកមួយក្បាល ។ សត្វករវិកនោះគិតថា ទ្រុងមាសមកតាមការត្រាស់បង្គាប់របស់ព្រះរាជា មិនអាចជំទាស់បាន ហើយក៏ទុំនៅក្នុងទ្រុងនោះ ។ ទ្រុងមាសបានមកតាំងនៅខាងមុខព្រះភ័ក្ត្ររបស់ព្រះរាជា អាមាត្យទាំងឡាយមិនអាចឲ្យសត្វករវិកបពោ្ចញសំឡេងបាន ។ លំដាប់នោះព្រះរាជាត្រាស់ថា ម្នាលនាយទាំងឡាយ សត្វករវិកទាំងនេះ បពោ្ចញសំឡេងយ៉ាងណា ។ ពួកអាមាត្យ ក្រាបទូលថា បពិត្រសម្មតិទេព សត្វករវិកទាំងនេះ ឃើញពួកញាតិទើបបពោ្ចញសំឡេង ។ លំដាប់នោះ ព្រះរាជាត្រាស់បញ្ជាឲ្យយកកញ្ចក់លោមព័ទ្ធ សត្វករវិកនោះ ។ សត្វករវិកនោះ គ្រាឃើញស្រមោលរបស់ខ្លួន សម្គាល់ថា ញាតិរបស់ខ្លួនមកហើយ ទើបទទះស្លាបស្រែក ដូចផ្លុំកែវមណី ដោយសំឡេងដ៏ទន់ក្រលួច ។ ពួកមនុស្សក្នុងសកលនគរទ្រេតទ្រោត ដូចអ្នកស្រវឹង ព្រះនាងអសន្ធិមិត្តា

ត្រិះរិះថា សំឡេងរបស់សត្វតិរច្ឆាននេះ អាចពីរោះយ៉ាងនេះ ព្រះសូរសៀង របស់ព្រះមានព្រះភាគទ្រង់សម្រេចសិរី គឺ ព្រះសព្វញ្ញុតញ្ញាណ នឹងដូច ម្តេចហ្ន៎ ញុំាងព្រះបីតិឲ្យកើត ទ្រង់មិនលះបីតិនោះ ទ្រង់បានតាំងនៅក្នុង សោតាបត្តិផលព្រមដោយបរិវារ ៧០០ គប្បីជ្រាបថា សំឡេងសត្វករវិក សូម្បីពីរោះយ៉ាងនេះ ។ តែព្រះសូរសៀងរបស់ព្រះវិបស្សីរាជកុមារ ពីរោះ ជាងនោះ រាប់រយពាន់ដង ។

បទថា កម្មវិបាកជំ គឺ មិនសម្រេចដោយភាវនា ។ ក៏មំសចក្ខុ ដូចគ្នានឹងចក្ខុរបស់ទេវតាទាំងឡាយ ដោយអំណាចផលរបស់កម្ម សូម្បីថា ល្ងមួយគ្រាប់ដែលធ្វើគ្រឿងសម្គាល់ទុកហើយ ដាក់ចុះទៅក្នុងផ្ទាំងល្ង ក៏ អាចលើកឡើងឲ្យបាន ដូច្នេះ ។

ក្នុងបទថា វិបស្សី នេះ ជាអត្ថរបស់ពាក្យនិយាយ ។ ឈ្មោះថា វិបស្សី ព្រោះឃើញច្បាស់ដោយវៀរចាកការបិទភ្នែក ក្លី និងងងឹត នឹងឃើញ ដោយភ្នែកដែលបើក ។ ក្នុងវារៈទីពីរ ។ ឈ្មោះវិបស្សី ព្រោះជ្រើសរើស មើល ។ អធិប្បាយថា សង្កេតមើល ។

បទថា អត្ថេ បនាយតិ សេចក្តីថា ដឹង ឃើញ ណែនាំ ឬ ពិចារណាអត្ថក្តី ។ បានឮថា ថ្ងៃមួយ កាលព្រះរាជាប្រថាប់លើសាលា សម្រាប់វិនិច្ឆ័យ ទ្រង់ពិចារណាក្តី មេដោះនាំព្រះមហាបុរសដែលប្រដាប់ តាក់តែងព្រះអង្គហើយ មកដាក់លើព្រះហស្ត កាលព្រះរាជានោះទ្រង់ទទួល

ព្រះកុមារដាក់លើព្រះភ្លៅ ហើយទ្រង់ក្រសោបថើប ពួកអ្នកពិចារណាបាន កាត់ក្តីអ្នកដែលជាម្ចាស់របស់ មិនឲ្យជាម្ចាស់របស់ ព្រះពោធិសត្វទ្រង់ថ្ងូងព្រះសូរសៀងសម្តែងការមិនពេញព្រះទ័យ ។ ព្រះរាជាត្រាស់ថា ពួកអ្នកពិចារណាក្តីនេះយ៉ាងណា ។ ពួកអាមាត្រសម្លឹងមើលមិនឃើញមនុស្សដទៃ ព្រោះខ្លួនវិនិច្ឆ័យក្តីខុស គិតថា យើងនឹងកាត់ក្តីយ៉ាងនេះ ។ ពួកអ្នកពិភាក្សាកាត់ក្តី អ្នកជាម្ចាស់របស់ដោយពិត ឲ្យជាម្ចាស់របស់ថ្មី ហើយពិចារណាមើលថា ព្រះកុមារទ្រង់ជ្រាបឬទេហ្ន៎ ទើបទ្រង់ធ្វើយ៉ាងនេះ បានកាត់ក្តីអ្នកជាម្ចាស់របស់មិនឲ្យជាម្ចាស់របស់ទៀត ។ ព្រះពោធិសត្វ ទ្រង់បញ្ចេញព្រះសូរសៀងយ៉ាងនោះទៀត ។ ពេលនោះព្រះរាជាទ្រង់ត្រិះរិះថា ព្រះកុមារជាមហាបុរសរមែងដឹង តាំងពីនោះមក ទ្រង់មិនបានប្រមាទឡើយ ។ លោកពោលថា ព្រះកុមារទ្រង់ពិចារណាក្តី សំដៅដល់សេចក្តីនេះ ។

ក្នុងបទថា វស្សិកំ ជាដើម សេចក្តីថា ស្ថានទីនៅយ៉ាងមានសេចក្តីសុខក្នុងរដូវភ្លៀង ឈ្មោះថា វស្សិក ។ ប្រាសាទសម្រាប់ប្រថាប់ក្នុងរដូវភ្លៀង ក្រៅពីនេះក៏មានន័យនេះដូចគ្នា ។ សេចក្តីនេះ ក្នុងបទនេះមានអត្ថជាពាក្យនិយាយ ។ ការនៅក្នុងរដូវភ្លៀងឈ្មោះ វស្សៈ អ្នកសមគួរដល់រដូវភ្លៀងនោះឈ្មោះ វស្សិកៈ ។ សូម្បីក្នុងបទក្រៅនេះ ក៏មានន័យនេះឯង ។ ក្នុងប្រាសាទ ៣ ខ្នងនោះ ប្រាសាទដែលប្រថាប់ក្នុងរដូវភ្លៀង មិន

ខ្ពស់ពេក មិនទាបពេក ។ សូម្បីទ្វារ និងបង្អួចរបស់ប្រាសាទនោះ ក៏មិនច្រើនពេក មិនតិចពេក ។ មួយទៀត កម្រាលផែនដី កម្រាលរបស់ទំពារ និងរបស់បរិភោគក្នុងប្រាសាទនេះរួមគ្នា ។ ក្នុងប្រាសាទសម្រាប់ប្រថាប់ក្នុងរដូវត្រជាក់ សូម្បីសសរ សូម្បីជញ្ជាំងក៏ទាប ។ សូម្បីទ្វារ និងបង្អួចតិចក៏មានប្រហោងជាសប្បាយ ។ ដើម្បីចូលទៅរកការអប់កំដៅ គួរនាំជញ្ជាំង និងផ្ទៃរបេញ ក៏ក្នុងប្រាសាទខ្នងនេះកម្រាលផែនដី សំពត់ស្បៀក សំពត់ដណ្តប់ គួរជាសំពត់កម្ពលជាដើម ជួយឲ្យកើតការអប់កំដៅ ។ របស់ទំពារ និងរបស់បរិភោគឆ្ងាញ់ និងលាយរសហឹរ ។ ក្នុងប្រាសាទសម្រាប់ប្រថាប់ក្នុងរដូវក្តៅ សូម្បីសសរ សូម្បីជញ្ជាំងក៏ខ្ពស់ ។ ក៏ក្នុងប្រាសាទខ្នងនេះទ្វារ និងបង្អួច មានក្រឡាសំណាញ់ច្រើន ។ កម្រាលផែនដីជាដើម គួរសម្រេចដោយសំពត់ពីរជាន់ ។ របស់ទំពារ និងរបស់បរិភោគ គួរជារបស់ត្រជាក់មានរសឆ្ងាញ់ ។ មួយទៀត ក្នុងប្រាសាទខ្នងនេះ ជនទាំងឡាយតាំងពាងថ្មីទុកក្នុងទីជិតបង្អួច ដាក់ទឹកដរាបពេញ ហើយដាំឈូកខៀវជាដើម ។ ខ្សែទឹកហូរដូចភ្លៀងធ្លាក់ តាមផ្លូវទីដែលជនទាំងឡាយធ្វើទឹកទុក ។ បទថា និប្បុរិសេហិ គឺ មិនមានប្រុស ។ អធិប្បាយថា ប្រាសាទនេះមិនមានតន្ត្រីតែម្យ៉ាងប៉ុណ្ណោះ សូម្បីមនុស្សប្រុសក៏មិនមាន ។ សូម្បីស្ថានទីទាំងអស់ ក៏មិនមានមនុស្សប្រុសដូចគ្នា ។ សូម្បីអ្នកយាមទ្វារ ក៏ជាស្រី ។ សូម្បីអ្នកធ្វើបរិការ មានងូតទឹកជាដើម ក៏ជាស្រីទាំងអស់ ។ បានឮថា

ព្រះរាជាទ្រង់ត្រិះរិះថា សេចក្ដីរន្ធៀសនឹងបុរស ព្រោះឃើញបុរស រមែងកើតឡើងដល់អ្នកសោយឥស្សរិយសម្បត្តិ និងសុខសម្បត្តិបែបនោះ សេចក្ដីរន្ធៀសនឹងបុរសនោះ កុំគប្បីមានដល់បុត្ររបស់យើងឡើយ ដូច្នេះ ទើបទ្រង់តាំងមនុស្សស្រីប៉ុណ្ណោះក្នុងកិច្ចការទាំងអស់ ។

ចប់ អដ្ឋកថា ភាណវារៈទីមួយ

# ពណ៌នា ការទតឃើញបុរសចាស់

[៣២-៣៣] គប្បីជ្រាបក្នុងការណវារៈទីពីរ ។ បទថា គោបានសិវង្គំ គឺ មានឆ្អឹងជំនីកោងដូចបង្កង់ ។ បទថា ភគ្គំ សេចក្តីថា មានខ្នងកោងក្នុងទីទាំង ៣ គឺ ត្រង់ដើមក ចង្កេះ និងជង្គង់ទាំង ២ ។ បទថា ទណ្ឌបរាយណំ គឺ ទៅដោយឈើច្រត់ មានឈើច្រត់ជាទីពឹង ។ បទថា អាតុរំ គឺ រសាប់រសល់ ព្រោះជរា ។ បទថា គតយោព្វនំ គឺ កន្លងវ័យកម្លោះ តាំងនៅក្នុងបច្ឆិមវ័យ ។ បទថា ទិស្វា សេចក្តីថា ព្រះកុមារហែហមដោយពួកពលប្រមាណកន្លះយោជន៍ បានចាត់រក្សាយ៉ាងល្អ ស្តេចទៅទតឃើញបុរសនោះ ដែលព្រហ្មជាន់សុទ្ធាវាស និងព្រហ្មជាខីណាស្រពសម្តែង ប្រាកដខាងមុខរថ ដោយអានុភាពរបស់ព្រះអង្គ ក្នុងឱកាសដែលរថនៅខាងមុខពួកពលនៅខាងក្រោយ ។ ន័យថា មហាព្រហ្មជាន់សុទ្ធាវាសត្រិះរិះថា ព្រះមហាបុរសទ្រង់ជាប់ក្នុងកាមគុណទាំង ៥ ដូចដំរីជាប់ភក់ យើងនឹងញុំាងសតិឲ្យកើតដល់ព្រះមហាបុរសនោះ ដូច្នេះ ទើបបានសម្តែងបុរសនោះ ។ ម្យ៉ាងទៀត ទាំងព្រះពោធិសត្វ និងសារថី ក៏ទតឃើញនិងឃើញបុរស ដែលស្តេចមហាព្រហ្មសម្តែងទុកហើយយ៉ាងនេះ ។ ពិតហើយ សូម្បីព្រហ្មទាំងឡាយបានសម្តែងបុរសនោះ ក៏ដើម្បីការមិនប្រមាទរបស់ព្រះពោធិសត្វ និងដើម្បីការសន្ទនារបស់សារថី ។ ព្រះកុមារត្រាស់

សួរថា ក៏បុគ្គលនេះ ជាអ្វី ។ សារថីទូលថា បុគ្គលនេះជាមនុស្សចាស់ ព្រះអង្គ លោកពោលទុកយ៉ាងណា ។ ព្រះកុមារត្រាស់សួរថា នេះនែ៎ យើងមិនធ្លាប់ឃើញបុគ្គលបែបនេះ មកអំពីមុនឡើយ ។ បទថា តេនហិ សេចក្តីថា បើដូច្នោះ សូម្បីយើងក៏នឹងគប្បីមានសក់បែបនេះ មានកាយបែបនេះ ។ ច្រើនបទថា **បើដូច្នោះសារថីសម្លាញ់ ថ្ងៃនេះល្មមហើយសម្រាប់ការក្រសាលសួន** សេចក្តីថា ព្រះកុមារត្រាស់ថា ថ្ងៃនេះ យើងល្មមហើយសម្រាប់ការក្រសាលសួន យើងត្រឡប់ទៅវិញចុះ ដូច្នេះ ទ្រង់ស្តុតព្រះទ័យត្រាស់អនុរូបដល់សេចក្តីសង្វេគ ។

[៣៤] បទថា អន្តេបុរំ គតោ សេចក្តីថា ព្រះកុមារទ្រង់លះបង់ស្ត្រី ប្រថាប់តែមួយព្រះអង្គឯងក្នុងបន្ទប់សិរី ។ បទថា យត្រ ហិ នាម សេចក្តីថា កាលមានជាតិ ជរារមែងប្រាកដ ចូរតិះដៀលស្អប់ខ្ពើមជាតិជាតិ ឈ្មោះថា ជាវត្ថុគួរខ្ពើម ព្រោះហេតុនោះ ព្រះកុមារប្រថាប់ជីកឫសរបស់ជាតិ ដូចត្រូវកូនសរដំបូងចាក់ព្រះទ័យ ដូច្នោះ ។

[៣៥] បទថា សារថឹ អាមន្តាបេត្វា សេចក្តីថា ន័យថា ព្រះរាជាតាំងពីពួកព្រាហ្មណ៍អ្នកព្យាករណ៍ ក្រាបទូល ទ្រង់ផ្ទៀងព្រះសោតស្តាប់រហូតដល់ចប់ ។ ព្រះរាជាទ្រង់ស្តាប់ថា ព្រះកុមារនោះ ស្តេចប្រពាតព្រះឧទ្យាន ស្តេចត្រឡប់ក្នុងចន្លោះផ្លូវ ទើបទ្រង់បង្គាប់ឲ្យហៅសារថីមក ។

ក្នុងបទថា មា ហេវ ខោ ជាដើម សេចក្ដីថា ព្រះរាជាទ្រង់ត្រិះរិះយ៉ាង នេះថា ឱរសរបស់យើង ចូរគ្រងរាជសម្បត្តិ ចូរកុំបួស ពាក្យរបស់ពួកព្រាហ្មណ៍សូមកុំឲ្យពិត ដូច្នេះ ។

## ពណ៌នាការឧតឃើញបុរសឈឺ

បទថា អទ្ទសា ខោ សេចក្ដីថា ព្រះកុមារបានទតឃើញបុរសដែលស្ដេចសុទ្ធាវាសមហាព្រហ្មសម្ដែង ដោយន័យដែលពោលហើយក្នុងខាងដើមនោះឯង ។ បទថា អាពាធិកំ សេចក្ដីថា មានការឈឺចាប់ដោយអាពាធផ្សេងៗ ដែលទម្លាយឥរិយាបថ ។ បទថា ទុក្ខិតំ គឺ ដល់ទុក្ខដោយទុក្ខ គឺ រោគ ។ បទថា ពាឡ្ហគិលានំ គឺ ឈឺធ្ងន់ ។ បទថា បលិបន្នំ គឺ លិច ។ សូម្បីក្នុងបទនេះថា ជរានឹងប្រាកដ ព្យាធិនឹងប្រាកដ សេចក្ដីថា កាលមានជាតិ ជរា ព្យាធិទាំងពីរនេះ រមែងប្រាកដ ជាតិគួរខ្ពើម មិនមានជាតិ នឹងត្រចះត្រចង់ ព្រោះហេតុនោះ ព្រះកុមារប្រថាប់អង្គុយជីកឫសរបស់ជាតិ ដូចត្រូវកូនសរទីពីរមុត ។

## ពណ៌នាការឧតឃើញបុរសស្លាប់

[៣៦-៣៧] បទថា វិលាតំ គឺ គ្រៀងស្នែង ។ បទថា បេតំ គឺ លះបង់ទៅអំពីលោកនេះ ។ បទថា កាលកតំ គឺ ស្លាប់ ។ អធិប្បាយថា ដែលមនុស្ស

យើងធ្វើវត្ថុទាំងពួង រហូតអស់កាលដែលរស់នៅ គ្រាសម្រេចហើយ ក៏ស្លាប់ ។ ព្រហ្មទាំងឡាយសម្តែងសូម្បីរឿងនេះ ដល់ព្រះកុមារ ដោយន័យមុនទុំះឯង ។ សូម្បីក្នុងបទថា យត្រ ហិ នាម នេះ ក៏មានអធិប្បាយថា កាលបើមានជាតិ ជរា ព្យាធិ មរណៈ ទាំង ៣ នេះ ប្រាកដជាតិជារបស់គួរខ្ពើម កាលមិនមានជាតិ ក៏រួចផុត ព្រោះហេតុនោះ ព្រះកុមារប្រែថាប់អន្តរាយដ៏កម្ទេចរបស់ជាតិ ដូចត្រូវកូនសរទី ៣ មុត ។

# ពណ៌នាការទតឃើញបព្វជិត

[៣៨] បទថា ភណ្តុំ គឺ ត្រងោល ។ ព្រហ្មទាំងឡាយសម្តែងសូម្បីរឿងនេះ ដល់ព្រះកុមារ ដោយន័យមុននោះឯង ។

ក្នុងបទថា សាធុ ធម្មចរិយា ជាដើម សេចក្តីថា សារថីទូលព្រះកុមារថា បពិត្រទេវៈ ភាពជាអ្នកប្រព្រឹត្តធម៌នេះ ជាសេចក្តីល្អ ដូច្នេះ គប្បីជ្រាបការប្រកបបទមួយៗ យ៉ាងនេះថា បព្វជិតោ ដូច្នេះ ។ម្យ៉ាងទៀត បទទាំងអស់នេះជាវេវចនៈរបស់កុសលកម្មបថ ១០ នោះឯង ។ ក៏ក្នុងទីបំផុត បទថា អវិហឹសា ជាចំណែកខាងដើមរបស់ករុណា ។ បទថា អនុកម្បា ជាចំណែកខាងដើមរបស់មេត្តា ។ បទថា តេនហិ ជានិបាតក្នុងសេចក្តីថា បន្ទិតបន្ទំ ។ ព្រោះព្រះកុមារទតឃើញបព្វជិតហើយ មាន

ព្រះទ័យបង្អោនទៅក្នុងបព្វជ្ជា ។ លំដាប់នោះ ព្រះកុមារមានព្រះបំណង ដើម្បីត្រាស់នឹងសារថីនោះ កាលនឹងទ្រង់បញ្ជូនសារថីឲ្យត្រឡប់ ទើប ត្រាស់ពាក្យជាអាទិថា តេនហិ ដូច្នេះ ។

## ពណ៌នាព្រះពោធិសត្វបព្វជ្ជា

បទថា អទ្ទសា ភិក្ខវេ សេចក្ដីថា ព្រះកុមារទ្រង់ស្ដាប់ពាក្យ ជាដើមថា ការប្រព្រឹត្តធម៌ជាសេចក្ដីល្អរបស់បព្វជិត និងពាក្យដទៃច្រើន ទៀត ដែលជាធម្មកថាប្រកបដោយទោសរបស់អ្នកនៅគ្រប់គ្រងផ្ទះ ដែល ចង្អៀតចង្អល់ដោយបុត្រ និងភរិយា ដែលពួកមហាជនរក្សាហើយ និងប្រកប ដោយអានិសង្សនៃវិវេក របស់បព្វជិតអ្នកនៅក្នុងព្រៃតាមសប្បាយ មាន ចិត្តដូចជាម្រឹគហើយ មានព្រះបំណងនឹងបព្វជ្ជា ម្នាលភិក្ខុទាំងឡាយ គ្រា នោះឯង វិបស្សីកុមារ ទើបបានហៅសារថីមក ។ ឈ្មោះថា ការឃើញ ទេវទូតទាំង ៤ នេះ ហើយបួស ជាវង្ស ជាបែបផែន ជាប្រពៃណីរបស់ ព្រះពោធិសត្វគ្រប់ព្រះអង្គ ។ ម្យ៉ាងទៀត ព្រះពោធិសត្វសូម្បីពួកដទៃ ក៏រមែងឃើញអស់កាលយូរ ដូចព្រះវិបស្សីកុមារព្រះអង្គនេះ ទ្រង់ឃើញ ហើយរហូតដល់អស់កាលយូរ ។ តែព្រះពោធិសត្វរបស់យើងទាំងឡាយ ទ្រង់ឃើញទេវទូតទាំង ៤ ក្នុងថ្ងៃតែមួយប៉ុណ្ណោះ ក៏ស្ដេចចេញមហា-

កិនទ្រូម៍ ទ្រង់បព្វជ្ជាត្រង់ប្រាំងស្ទឹងអនោមា តពីនោះ ស្ដេចយាងដល់ក្រុងរាជគ្រឹះ ក្នុងទីនោះព្រះរាជាពិម្ពិសារទូលសួរថា លោកបណ្ឌិត លោកបួសដើម្បីអ្វី ទ្រង់ត្រាស់ថា ៖

**មហាបពិត្រ អាត្មាឃើញមនុស្សចាស់ មនុស្សឈឺ បានទទួលទុក្ខ និងមនុស្សស្លាប់ដល់អាយុក្ខ័យ និងបានឃើញបព្វជិតស្លៀកដណ្តប់សំពត់កាសាយៈ ព្រោះដូច្នោះទើបបួស ថ្វាយព្រះពរ ។**

បទថា សុត្វាន គេសំ សេចក្ដីថា មហាជន ៨៤.០០០ នាក់នោះបានស្តាប់ហើយមានការត្រិះរិះដូច្នេះ ។ បទថា ឱរកោ គឺ ខ្វះខាត លាមក ។ បទថា អនុបព្វជិំសុ គឺ បួសតាម ។ ក៏ព្រោះហេតុអ្វីក្នុងទីនេះលោកទើបមិនពោល ដូចដែលលោកពោលទុកខាងដើមថា ព្រះកុមារស្ដេចចេញចាករាជធានីពន្ធុមតី ព្រមដោយវ័ណ្ណៈ និងតិស្សៈចេញបួសតាម ។ ព្រោះចេញទៅហើយ ទើបបានស្ដាប់ ។ បានឮថា មហាជនសូម្បីទាំងអស់នេះជាបុរសឧបដ្ឋាករបស់ព្រះវិបស្សីកុមារ ។ មហាជនទាំងនោះមកឧបដ្ឋាកតាំងពីព្រឹកព្រលឹម កាលមិនឃើញព្រះកុមារ ទើបនាំគ្នាស៊ីអាហារព្រឹក លុះស៊ីអាហារព្រឹកស្រេចហើយ ទើបមកសួរថា ព្រះកុមារទៅណា លុះស្ដាប់ថា ព្រះកុមារស្ដេចទៅព្រះឧទ្យាន ទើបនាំគ្នាចេញទៅដោយគិតថា

ពួកយើងនឹងគាល់ព្រះកុមារក្នុងព្រះឧទ្យាននោះ លុះឃើញសារថីត្រឡប់ បានស្តាប់ពាក្យរបស់សារថីនោះថា ព្រះកុមារទ្រង់បព្វជ្ជាហើយ ទើបដោះអាភរណៈគ្រប់យ៉ាងទុកក្នុងទីដែលបានស្តាប់ហើយនុ៎ះឯង ឲ្យអ្នកនាំសំពត់កាសាយៈពណ៌លឿងអំពីផ្សារមក កោរសក់ និងពុកមាត់ ហើយបួស ។ ដោយហេតុដូច្នេះ ក្នុងទីនេះទើបមិនពោលថា ចេញចាករាជធានីពន្ធុមតី ព្រោះចេញចាកនគរហើយ ទើបបានស្តាប់ក្រៅនគរ ។

បទថា ចារិកំ ចរតិ សេចក្តីថា ព្រះវិបស្សីពោធិសត្វសាងមណ្ឌបជំក្នុងទីដែលទៅហើយ ត្រៀមទានមកទទួលនិមន្តក្នុងថ្ងៃស្អែក ទទួលភិក្ខាដែលមហាជនទូលប្រាប់ទុក ត្រាច់ចារិកទៅរហូតអស់ ៤ ខែ ។ បទថា អាកិណ្ណោ គឺ ត្រូវហែហមដោយគណៈនេះ ។ ក៏សេចក្តីវិតក្កៈនេះ កើតឡើងដល់ព្រះពោធិសត្វក្នុងកាលណា ។ ក្នុងថ្ងៃ ១៤ កើត ព្រោះថ្ងៃស្អែកនេះ ជាថ្ងៃពេញបូណ៌មីខែ ៦ ។ បានឮថា គ្រានោះព្រះពោធិសត្វទ្រង់ត្រិះរិះថា អ្នកទាំងនេះ កាលមុនហែហមយើង បុគ្គលជាគ្រហស្ថត្រាច់ទៅយ៉ាងណា សូម្បីតែម្នាក់នេះ ក៏យ៉ាងនោះទៀត ប្រយោជន៍អ្វីដោយគណៈនេះ ទ្រង់រង្កៀសដោយការប្រឡូកប្រឡល់នៅលាយឡំនឹងគណៈ ទ្រង់ត្រិះរិះថា យើងនឹងទៅក្នុងថ្ងៃនេះឯង ហើយទ្រង់ត្រិះរិះទៀតថា ថ្ងៃនេះមិនទាន់ដល់វេលា បើយើងនឹងទៅតែម្នាក់ឯងយ៉ាងនេះ អ្នកទាំងអស់នេះក៏នឹងដឹង

ឃើងនឹងទៅថ្ងៃស្អែកនេះ ។ មយ៉ាងទៀត ក្នុងថ្ងៃនោះ អ្នកស្រុកក្នុងស្រុក ដូចជាអ្នកស្រុកឧរុវេលា បាននិមន្តព្រះពោធិសត្វដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ អ្នកស្រុកទាំងនោះ ត្រៀមបាយបាយាសសម្រាប់បព្វជិត ៨៤.០០០ រូប និងសម្រាប់ព្រះមហាបុរស ។ ខណៈនោះ ព្រះមហាបុរសបានឆាន់អាហារ ជាមួយបព្វជិតទាំងនោះក្នុងស្រុកនោះ ក្នុងថ្ងៃស្អែកឡើងបានទៅទីកន្លែង នោះ ទីនោះពួកបព្វជិត បានប្រណិបត្តិព្រះមហាបុរសសម្រេចហើយ ក៏ ចូលទៅកាន់ទីសម្រាកពេលយប់ និងពេលថ្ងៃរៀងៗ ខ្លួន ។ សូម្បីព្រះ ពោធិសត្វ ស្ដេចក៏ចូលទៅប្រថាប់ក្នុងបណ្ណសាលា ទ្រង់រំពឹងថា ៖

**កាលបើដល់វេលាថ្ងៃត្រង់ បក្សីទាំងឡាយនឹងមកប្រជុំគ្នា**
**ព្រៃធំនឹងមានសំឡេងគឹកកង ភ័យនោះ នឹងប្រាកដដល់**
**យើង ។**

ក្នុងកាលមានភ័យដល់អ្នកត្រេកអរក្នុងសេចក្ដីស្ងាត់ ក្នុងកាលមាន សេចក្ដីក្រវល់ក្រវាយដល់សត្វទាំងពួងបែបនេះ ព្រះពោធិសត្វទ្រង់ត្រិះរិះ ថា នេះដល់វេលាហើយ ទើបស្ដេចបិទទ្វារបណ្ណសាលាចេញ បែរព្រះភ័ក្ត្រ កាន់ពោធិមណ្ឌៈ ។ សូម្បីក្នុងកាលដទៃ ព្រះពោធិសត្វត្រាច់ទៅក្នុងទី នោះ ទ្រង់ឃើញពោធិមណ្ឌៈ ។ តែព្រះទ័យព្រះពោធិសត្វនោះ មិនធ្លាប់ បង្អោនទៅដើម្បីប្រថាប់អង្គុយឡើយ ។ តែថ្ងៃនោះ ព្រះញាណរបស់ព្រះ

ពោធិសត្វចាស់ក្លា ព្រោះដូច្នោះ កើតចិត្តដើម្បីទតព្រះនេត្រពោធិមណ្ឌល ដែលតាក់តែងហើយស្តេចឡើងទៅ ។ ព្រះពោធិសត្វនោះ ស្តេចចូលទៅ ដោយចំណែកទិសខាងត្បូង ទ្រង់ប្រទក្ខិណ ក្រាលបល្ល័ង្កទំហំ ១៤ ហត្ថ ក្នុងទិសខាងកើត ទ្រង់អធិដ្ឋានសេចក្តីព្យាយាមប្រកបដោយអង្គ ៤ ប្រថាប់អង្គុយ ទ្រង់តាំងបដិញ្ញាថា យើងនឹងមិនក្រោកអំពីទីនេះ រហូតដល់វេលា ដែលយើងមិនទាន់បានជាព្រះពុទ្ធ ។ លោកពោលបទនេះថា ព្រះពោធិសត្វ តែមួយព្រះអង្គ ចៀសចេញចាកគណៈ សំដៅដល់ការចៀសចេញចាកនៃ ព្រះពោធិសត្វព្រះអង្គនេះ ។

បទថា អញ្ញេនេវ គានិ សេចក្តីថា ន័យថា បព្វជិតពួកនោះ មកឧបដ្ឋាកព្រះពោធិសត្វពេលល្ងាច ហើយអង្គុយលោមព័ទ្ធបណ្ណសាលា ពោលថា ហួសវេលាទៅច្រើនហើយ ពួកលោកចូរចូលទៅសង្កេតការណ៍ គ្រាបើកបណ្ណសាលា សូម្បីកាលមិនឃើញព្រះពោធិសត្វនោះ ក៏មិនបាន តាមរកឲ្យដឹងថា ព្រះពោធិសត្វស្តេចទៅណា ។ ពួកបព្វជិតគិតថា ព្រះមហាបុរស ទ្រង់នឿយណាយក្នុងការនៅរួមជាមួយគណៈ ប្រាកដជាមាន ព្រះបំណងនឹងប្រថាប់នៅតែមួយព្រះអង្គឯង ពួកយើងនឹងឃើញព្រះពោធិសត្វ ពេលបានជាព្រះពុទ្ធហើយនោះឯង ហើយនាំគ្នាត្រឡប់ទៅខាងក្នុង ជម្ពូទ្វីប ចៀសចេញចារិកទៅ ។

## ពណ៌នា អភិសម្ពោធិ

*បទថា វាសូបគតស្ស សេចក្តីថា ចូលទៅនៅមួយរាត្រីក្នុងពោធិ-មណ្ឌៈ ។ បទថា រហោគតស្ស គឺ ទៅក្នុងទីកំបាំង ។ បទថា បដិសល្លីនស្ស គឺ ពួនសម្ងំនៅ ដោយអំណាចនៃភាពជាបុគ្គលម្នាក់ឯង ។ បទថា កិច្ឆំ គឺ លំបាក ។ ក៏ទាំងពីរបទនេះ គឺ ចវតិ ច ឧប្បជ្ជតិ ច លោកពោលសំដៅដល់ចុតិ និងបដិសន្ធិតៗ ទៅ ។ ក្នុងបទថា ជរាមរណស្ស នេះ សេចក្តីថា ព្រោះព្រះពោធិសត្វ កាលទ្រង់ព្រះផ្នួស ទតឃើញមនុស្សចាស់ មនុស្សឈឺ និងមនុស្សស្លាប់នុ៎ះឯង ទើបទ្រង់ព្រះផ្នួស ដូច្នោះ ជរា និងមរណៈនុ៎ះឯង រមែងប្រាកដដល់ព្រះពោធិសត្វនោះ ។ ដោយហេតុនោះ ព្រះមានព្រះភាគត្រាស់ហើយថា ជរាមរណស្ស ដូច្នេះ ។*

[៣៩] *ដោយប្រការដូច្នេះ ម្នាលភិក្ខុទាំងឡាយ គ្រានោះ ព្រះវិបស្សីពោធិសត្វ មានសេចក្តីត្រិះរិះដូច្នេះ ទ្រង់ធ្វើជរា និងមរណៈ ឲ្យជាមូល តាំងមាំចំពោះហើយ ដូចធ្លាក់ចុះអំពីភវគ្គព្រហ្ម ។ បទថា យោ-និសោមនសិការា សេចក្តីថា ធ្វើទុកក្នុងចិត្តដោយឧបាយ គឺ ធ្វើទុកក្នុងចិត្ត ។ អធិប្បាយថា ពិតហើយ កាលធ្វើទុកក្នុងចិត្តនូវលក្ខណៈ មានការមិនទៀងជាដើម ដោយលក្ខណៈ មានការមិនទៀងជាដើម ឈ្មោះថា អ្នកធ្វើទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃ ។ មួយទៀត យោនិសោមនសិការ*

នេះ យ៉ាងណាមួយរបស់បណ្ដាអភិសម័យទាំងនោះ ព្រោះការប្រព្រឹត្តទៅដោយអំណាចនៃប្រាជ្ញាពិចារណាឃើញ ទាំងការកើត ទាំងការរលត់ថា កាលអ្វីមានហ្ន៎ ជាតិជាដើមរមែងមាន កាលអ្វីមិនមាន ជាតិជាដើមរមែងមិនមាន ដូច្នេះ ព្រោះដូច្នោះ ការត្រាស់ដឹងដោយបញ្ញា បានប្រាកដដល់ព្រះពោធិសត្វនោះ ព្រះអង្គធ្វើទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃអំពីនេះ ។ គឺ ដោយការធ្វើទុកក្នុងចិត្តដោយឧបាយនេះ ដូច្នោះ កាលវត្ថុណាមាន ជរា មរណៈ រមែងមាន ការរួមគ្នាចូលជាមួយនឹងហេតុ គឺ ជរា និងមរណៈនោះ បានប្រាកដដល់ព្រះបញ្ញារបស់ព្រះពោធិសត្វ ។ ក៏ជរា និងមរណៈនោះ មានព្រោះអ្វី ។ ព្រោះជាតិ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ថា **កាលជាតិមាន ជរាមរណៈទើបមាន** ការរួមគ្នាចូលនឹងបញ្ញាកំណត់ហេតុនៃជរា និងមរណៈ បានប្រាកដដល់ព្រះពោធិសត្វ នេះជាអធិប្បាយក្នុងសេចក្ដីនេះ ។ គប្បីជ្រាបបទទាំងអស់ ដោយទំនងនេះ ។

ក៏ក្នុងបទថា **កាលនាមរូបកើតមាន វិញ្ញាណទើបកើតមាន** នេះ សេចក្ដីថា គួរនឹងពោលថា កាលសង្ខារមាន វិញ្ញាណទើបមាន និងកាលអវិជ្ជាមាន សង្ខារទើបមាន សូម្បីទាំងពីរនោះ កាន់យកមិនបាន ។ ព្រោះអ្វី ។ ព្រោះអវិជ្ជា និងសង្ខារជាអតីតភព ។ វិបស្សនានេះ មិនចំពោះតែអវិជ្ជា និងសង្ខារទាំងនោះ ។ ពិតហើយ ព្រះមហាបុរស ទ្រង់តាំងមាំហើយដោយអំណាចនៃបច្ចុប្បន្ន ។ ដែលអ្នកមិនឃើញអវិជ្ជា និងសង្ខារ

មិនអាចជាព្រះពុទ្ធបាន មិនមែនឬ ។ ពិតជាមិនអាចបាន ។ តែធម៌ទាំងនោះ ដែលព្រះមហាបុរសនេះឃើញហើយ ដោយអំណាចនៃកត ឧបាទាន និង តណ្ហា ។ ក៏ក្នុងទីនេះ គួរពោលដល់បដិច្ចសមុប្បាទដោយពិស្តារ ។ បដិ-ច្ចសមុប្បាទនោះ លោកពោលទុកហើយក្នុងវិសុទ្ធិមគ្គ ។

បទថា បច្ចុធាវត្តតិ គឺ ត្រឡប់ទៅត្រឡប់មក ។ ក៏ក្នុងបទនេះ វិញ្ញាណត្រឡប់ទៅត្រឡប់មក ដូចម្តេច ? ។ វិញ្ញាណនោះ បានដល់ បដិសន្ធិ-វិញ្ញាណខ្លះ វិបស្សនាវិញ្ញាណខ្លះ ក្នុងវិញ្ញាណទាំងពីរនោះ **បដិសន្ធិវិញ្ញាណ** ត្រឡប់ត្រឡប់មក ព្រោះបច្ច័យ ។ **វិបស្សនាវិញ្ញាណ** ត្រឡប់ត្រឡប់មក ពោះអារម្មណ៍ ។ សូម្បីទាំងពីរ ក៏មិនផុតពីនាមរូប ដទៃចាកនាមរូប រមែងទៅមិនបាន ។ ក្នុងបទទាំងឡាយមានអាទិថា ឯត្តាវតា ជាយេថ វា សេចក្តីថា លោកសម្តែងបទទាំង ៥ ព្រមដោយចុតិ និងបដិសន្ធិដទៃៗ សេចក្តីថា កាលវិញ្ញាណជាបច្ច័យដល់នាមរូប និងកាលនាមរូបជាបច្ច័យដល់ វិញ្ញាណ សូម្បីទាំងពីរ ក៏ជាបច្ច័យដល់គ្នានិងគ្នា ដោយហេតុត្រឹមតែប៉ុណ្ណេះ សត្វលោក គប្បីកើតខ្លះ គប្បីចាស់ខ្លះ គប្បីស្លាប់ខ្លះ គប្បីចុតិខ្លះ គប្បី ឧប្បត្តិខ្លះ ក៏ក្រៅអំពីនេះ យ៉ាងដទៃនៅមានទៀតឬ សត្វគប្បីកើតខ្លះ ។ល។ គប្បីឧប្បត្តិខ្លះ នេះប៉ុណ្ណោះមិនមែនឬ សត្វរមែងកើត ។ល។ និងរមែង ឧប្បត្តិ កាលនឹងពង្រីកសេចក្តីដែលលោកពោលពាក្យនោះទៀតថា ឯត្តាវតា ទើបពោលថា ព្រោះនាមរូបជាបច្ច័យ ទើបមានវិញ្ញាណ ព្រោះវិញ្ញាណជា

បច្ច័យ ទើបមាននាមរូប តពីនោះដើម្បីនឹងសម្ដែងជាតិ ជរា និងមរណៈ សូម្បីតទៅ ដែលមាននាមរូបជាឫសគល់ ព្រោះវិញ្ញាណជាបច្ច័យ ដោយអំណាចបច្ចយាការដោយអនុលោម ទើបពោលពាក្យជាអាទិថា ព្រោះនាមរូបជាបច្ច័យ ទើបមានសឡាយតនៈ ។ ក្នុងបទទាំងឡាយនោះ បទថា កេវលស្ស ទុក្ខក្ខន្ធស្ស សមុទយោ ហោតិ សេចក្ដីថា ការកើតឡើងនៃកងទុក្ខទាំងមូល មានប្រភេទជាដើមថា ជាតិ ជរា មរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្ស និងឧបាយាស រមែងមានបាន ។ ព្រះមហាបុរសបានឃើញការកើតនៃវដ្ដទុក្ខទាំងមូល ដោយប្រការដូច្នេះ ។

បទថា សមុទយោ សមុទយោតិ ខោ សេចក្ដីថា កើតឡើង កើតឡើង ដូច្នេះឯង ។ បទថា អននុស្សុតេសុ សេចក្ដីថា មិនបានស្ដាប់មកហើយ គឺ មិនធ្លាប់ស្ដាប់មកហើយ ។

ក្នុងពាក្យទាំងឡាយថា **ចក្ខុកើតឡើងហើយ** ជាដើម សេចក្ដីថា ក៏បញ្ញាឃើញការកើតនេះ លោកពោលថា ជាចក្ខុ ដោយអត្ថថា ឃើញ , ជាញាណ ដោយអត្ថថា ធ្វើឲ្យដឹង , ជាបញ្ញា ដោយអត្ថថា ដឹងទូទៅ , ជាវិជ្ជា ដោយអត្ថថា ដឹងច្បាស់ចាក់ធ្លុះកើតឡើងហើយ , ជាអាលោកដោយអត្ថថា ភ្លឺស្វាង ដូច្នេះ ។ ដូចលោកពោលហើយថា ចក្ខុកើតឡើងហើយ ដោយអត្ថថា ឃើញ , ញាណកើតឡើងហើយ ដោយអត្ថថា ធ្វើឲ្យដឹង , បញ្ញាកើតឡើងហើយ ដោយអត្ថថា ដឹងទូទៅ , វិជ្ជាកើតឡើង

ហើយ ដោយអត្ថថាចាក់ធ្លុះ , ពន្លឺកើតឡើងហើយ ដោយអត្ថថាភ្លឺស្វាង ។ ចក្ខុជាហេតុ អត្ថថាឃើញជាផល , ញាណជាហេតុ អត្ថថាដឹងជាផល , បញ្ញាជាហេតុ អត្ថថាដឹងទូទៅជាផល , វិជ្ជាជាហេតុ អត្ថថាចាក់ធ្លុះជាផល , ពន្លឺជាហេតុ អត្ថថាពន្លឺភ្លឺស្វាងជាផល ដូច្នេះ ។ លោកពោលដោយបទត្រឹមតែប៉ុណ្ណេះឬ ។ លោកពោលត្រឹមតែឲ្យកំណត់ដឹងបច្ច័យថា កាលវត្ថុនេះមាន វត្ថុនេះរមែងមាន ដូច្នេះ ។ មួយវិញទៀត លោកសម្តែងដល់តរុណវិបស្សនា ដែលជាផ្លូវបដិបត្តិ ។

[៦០] បទថា អធិគតោ ខោ មយាយំ សេចក្តីថា មគ្គនេះ ដែលតថាគតចាក់ធ្លុះហើយ ។ បទថា **មគ្គ** គឺ វិបស្សនាមគ្គ ។ បទថា ពោធាយ សេចក្តីថា ដើម្បីដឹងអរិយសច្ច ៤ ឬដើម្បីដឹងនិព្វាន ។ មួយវិញទៀត ឈ្មោះ **ពោធិ** ព្រោះដឹង ។ នេះជាឈ្មោះរបស់អរិយមគ្គ ។ ដែលលោកពោលថា ដើម្បីប្រយោជន៍ដល់អរិយមគ្គនោះខ្លះ ។ ព្រោះអរិយមគ្គ មានវិបស្សនាមគ្គជាមូល ។ ឥឡូវនេះ កាលនឹងពង្រីកសេចក្តីនៃមគ្គនោះ ទើបពោលពាក្យជាអាទិថា យទិទំ នាមរូបនិរោធា ដូច្នេះ ។ មួយទៀត ក្នុងបទនេះ លោកពោលដល់និព្វានប៉ុណ្ណោះ ដោយបទបឋមាវិភត្តិថា វិញ្ញាណនិរោធោ ជាដើម ដោយប្រការដូច្នេះ ព្រះមហាបុរសទ្រង់បានឃើញការរលត់ គឺ ការមិនកើតឡើងនៃវដ្តទុក្ខទាំងមូល ។

បទថា និរោធោ និរោធោតិ ខោ សេចក្តីថា មិនកើត មិនកើត

នោះឯង ។ ពាក្យថា **ចក្ខុំ** ជាដើម មានសេចក្ដីដូចលោកពោលទុកហើយនុ៎ះឯង ។ តែក្នុងទីនេះ ដោយបទទាំងអស់នេះ លោកពោលត្រឹមតែឲ្យដឹងដល់ការរលត់ប៉ុណ្ណោះថា កាលវត្ថុនេះមិនមាន វត្ថុនេះរមែងមិនមាន ដូច្នេះ ។ម្យ៉ាងទៀត លោកពោលដល់វិបស្សនាចាស់ក្លា ដែលនឹងឲ្យដល់ការរួចផុត ។

[៤១] បទថា អបរេន សមយេន សេចក្ដីថា ព្រះពោធិសត្វទ្រង់ដឹងបច្ច័យ និងការរលត់នៃបច្ច័យយ៉ាងនេះ ក្នុងសម័យដទៃអំពីនោះ ។ បទថា ឧបាទានក្ខន្ធេសុ គឺ ក្នុងខន្ធដែលជាបច្ច័យនៃឧបាទាន ។ បទថា ឧទយព្វយានុបស្សី សេចក្ដីថា ពិចារណាឃើញការកើត និងការសាបសូន្យដែលឃើញហើយគ្រាដំបូងនុ៎ះឯង ។ បទថា វិហាសិ សេចក្ដីថា ព្រះពោ-ធិសត្វទ្រង់ចម្រើនវិបស្សនា ដែលជាហេតុឲ្យដល់ការរួចផុតដល់កំពូល ។ លោកពោលសេចក្ដីនេះទុកព្រោះហេតុអ្វី ។ ព្រោះព្រះពោធិសត្វទាំងឡាយទាំងពួង ទ្រង់បំពេញបារមីក្នុងបច្ឆិមភព ស្ដេចចេញមហាភិនេស្រ្កម៍ក្នុងថ្ងៃព្រះឱរសប្រសូតិ ទ្រង់ព្រះផ្នួស ទ្រង់ប្រកបដោយសេចក្ដីព្យាយាម ស្ដេចឡើងកាន់ពោធិបល្ល័ង្ក ទ្រង់កម្ចាត់មារ និងសេនាមារ ក្នុងបឋមយាម ទ្រង់រឭកដល់ខន្ធដែលធ្លាប់នៅអាស្រ័យក្នុងភពមុន ក្នុងមជ្ឈិមយាម ទ្រង់ជម្រះទិព្វចក្ខុ ក្នុងបច្ឆិមយាម ទ្រង់ពិចារណាបច្ចយាការ ទ្រង់ចេញពីចតុត្ថជ្ឈានកំណត់ខ្យល់ដកដង្ហើមចេញចូល ទ្រង់សម្លឹងពិនិត្យក្នុងខន្ធ ៥ ទ្រង់ឃើញលក្ខណៈ ៥០ គត់ ដោយអំណាចការកើត និងការវិនាស ទ្រង់ចម្រើន

វិបស្សនាដរាបដល់គោត្រភូញាណ ហើយទ្រង់ចាក់ធ្លុះនូវពុទ្ធគុណទាំងអស់ ដោយអរិយមគ្គ ។ មួយ៉ាងទៀត ព្រះមហាបុរសព្រះអង្គនេះ ក៏បានបំពេញបារមីហើយ ។ ព្រះអង្គទ្រង់ធ្វើតាមលំដាប់ទាំងអស់ ដូចដែលពោលហើយ ក្នុងបច្ឆិមយាម ទ្រង់ចេញចាកចតុត្ថជ្ឈាន កំណត់ខ្យល់ដកដង្ហើមចេញចូល ទ្រង់ពិចារណាក្នុងខន្ធ ៥ ទ្រង់ប្រារព្ធការឃើញច្បាស់ការកើត និងការវិនាស មានសេចក្តីដូចដែលពោលហើយ ។ លោកពោលដល់ការឃើញច្បាស់ ដែលនឹងឲ្យដល់ការរួចផុតនេះ ដើម្បីសម្តែងដល់ការឃើញច្បាស់នូវការកើត និងការរលត់នោះ ។

ក្នុងបទទាំងនោះ បទថា ឥតិ រូបំ សេចក្តីថា រូបនេះ រូបមានប្រមាណប៉ុណ្ណោះ រូបដ៏សេសអំពីនេះរមែងមិនមាន ព្រោះហេតុនោះ លោកទើបពោលដល់ការកំណត់រូប ដែលមិនមានចំណែកសល់ ដោយអំណាចនៃលក្ខណៈ រស បច្ចុប្បដ្ឋាន និងបទដ្ឋាន ធ្វើសភាវៈនៃការបែកធ្លាយទៅ និងប្រភេទនៃការអាស្រ័យកើតជាអាទិ ។ លោកពោលការឃើញហេតុកើតនៃរូប ដែលកំណត់ទុកយ៉ាងនេះ ដោយបទនេះថា ឥតិ រូបស្ស សមុទយោ ដូច្នេះ ។ ក្នុងបទទាំងនោះ បទថា ឥតិ សេចក្តីថា យ៉ាងនេះជាហេតុកើត ។ គប្បីជ្រាបសេចក្តីពិស្តាររបស់បទ សមុទយោ នោះ យ៉ាងនេះថា ព្រោះអវិជ្ជាកើត រូបទើបកើត ព្រោះតណ្ហាកើត រូបទើបកើត ព្រោះកម្មកើត រូបទើបកើត ព្រោះអាហារកើត រូបទើបកើត ព្រោះហេតុនោះ

សូម្បីឃើញលក្ខណៈនៃការកើតហើយ ក៏រមែងឃើញហេតុកើតរបស់រូប-ក្ខន្ធ ។ សូម្បីក្នុងការរលត់ ក៏គប្បីជ្រាបសេចក្តីពិស្តារយ៉ាងនេះថា ព្រោះអវិជ្ជារលត់ រូបទើបរលត់ ។ល។ សូម្បីឃើញលក្ខណៈនៃការប្រែប្រួលហើយ ក៏រមែងឃើញការរលត់ នៃរូបក្ខន្ធ ។ សូម្បីក្នុងបទទាំងឡាយថា ឥតិ វេទនា ជាដើម ក៏មានសេចក្តីថា វេទនានេះ វេទនាមានប្រមាណប៉ុណ្ណេះ វេទនាដ៏សេសអំពីនេះ រមែងមិនមាន សញ្ញានេះ សង្ខារទាំងនេះ វិញ្ញាណនេះ វិញ្ញាណមានប្រមាណប៉ុណ្ណេះ វិញ្ញាណដ៏សេសអំពីនេះរមែងមិនមានដូច្នេះ លោកពោលកំណត់ វេទនា សញ្ញា សង្ខារ និងវិញ្ញាណមិនមានសល់ ដោយអំណាចនៃលក្ខណៈ រស បច្ចុប្បដ្ឋាន និងបទដ្ឋាន ធ្វើសភាពនៃការសោយអារម្មណ៍ ការរឭកដឹង ការតាក់តែង និងការយល់ និងប្រភេទនៃសុខជាដើម រូបសញ្ញាជាដើម ផស្សៈជាដើម ចក្ខុវិញ្ញាណជាដើម ឲ្យជាអាទិ ។ ក៏ប៉ុន្តែថា លោកពោលដល់ការឃើញហេតុកើតនៃ វេទនា សញ្ញា សង្ខារ និងវិញ្ញាណទាំងឡាយ ដែលកំណត់ទុកយ៉ាងនេះ ដោយបទថា ឥតិ វេទនាយ សមុទយោ ជាដើម ។ បទថា ឥតិ សូម្បីក្នុងបទនោះ ក៏មានសេចក្តីថា យ៉ាងនេះជាហេតុកើតដូច្នេះ ។ សេចក្តីពិស្តាររបស់បទទាំងនោះថា ព្រោះអវិជ្ជាកើត វេទនាទើបកើត គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងរូបនោះឯង ។ តែមានសេចក្តីប្លែកចេញទៅដូច្នេះ ។ ក្នុងខន្ធ ៣ មិនគួរពោលថា ព្រោះអាហារកើត គួរពោលថា

ព្រោះផស្សៈកើត ។ ក្នុងវិញ្ញាណខន្ធ គួរពោលថា ព្រោះនាមរូបកើត ។ សូម្បីបទថា ការរលត់ គប្បីប្រកបដោយអំណាចនៃបទទាំងនោះឯង ។ នេះជាសេចក្តីសង្ខេបក្នុងបទនេះ ។ សេចក្តីវិនិច្ឆ័យការកើត និងការរលត់យ៉ាងពិស្តារបរិបូណ៌ដោយប្រការទាំងពួង លោកពោលទុកហើយក្នុងវិសុទ្ធិ-មគ្គ ។ ពាក្យថា កាលព្រះពោធិសត្វ ទ្រង់ពិចារណាឃើញនូវកិរិយាកើតនិងរលត់ទៅក្នុងឧបាទានក្ខន្ធ ៥ សេចក្តីថា កាលព្រះវិបស្សីពោធិសត្វនោះពិចារណាឃើញការកើត និងការរលត់ ដោយអំណាចលក្ខណៈ ៥០ គត់ក្នុងឧបាទានក្ខន្ធ ៥ មានរូបជាដើមទាំងនេះ កាលវិបស្សនាញាណចម្រើនហើយតាមលំដាប់ ចិត្តមិនប្រកាន់មាំ ព្រោះមិនកើត រមែងរួចផុតចាកកិលេសទាំងឡាយ ពោលគឺ អាសវៈរលត់ស្និទ្ធដោយអនុប្បាទនិរោធ ។ ចិត្តនោះឈ្មោះថា រមែងរួចផុតក្នុងខណៈមគ្គ ឈ្មោះថា រួចផុតហើយក្នុងខណៈផល ឬថា រួចផុតហើយ និងនឹងរួចផុតក្នុងខណៈមគ្គ ជាការរួចផុតហើយក្នុងខណៈផលនុ៎ះឯង ។ ដោយហេតុត្រឹមតែប៉ុណ្ណេះឯង ព្រះមហាបុរសទ្រង់រួចផុតហើយអំពីគ្រឿងចងទាំងពួង មានព្រះសន្តានរីកកាយ ដូចបទុមត្រូវពន្លឺព្រះអាទិត្យដូច្នោះ មានព្រះតម្រិះបរិបូណ៌ ប្រថាប់ក្នុងពោធិបល្ល័ង្ក ទ្រង់ធ្វើមគ្គញ្ញាណ ៤ ផលញាណ ៤ បដិសម្ភិទា ៤ ញាណកំណត់កំណើត ៤ ញាណកំណត់គតិ ៥ អសាធារណញ្ញាណ ៦ និងព្រះពុទ្ធគុណទាំងមូលឲ្យនៅក្នុងកណ្តាប់ព្រះហស្ត ។ ទ្រង់ធ្វើទុកក្នុងព្រះទ័យយ៉ាងនេះថា ៖

យើងស្ទុះទៅអស់សង្សារច្រើនជាតិ ស្វែងរកជាងធ្វើផ្ទះ
មិនជួប ការកើតញយៗ ជាទុក្ខ ម្នាលជាងធ្វើផ្ទះ យើង
ជួបអ្នកហើយ អ្នកមិនអាចធ្វើផ្ទះទៀតឡើយ យើងកាច់
បំបាក់ឆ្អឹងជំនីរបស់អ្នកអស់ហើយ យើងរើដំបូលចេញ
ហើយ ចិត្តរបស់យើងមិនបានតាក់តែង យើងបានសម្រេច
ការអស់តណ្ហាហើយ មិនមានគតិ ដើម្បីប្រកាសដល់អ្នក
ដែលរួចផុតដោយប្រពៃ អ្នកឆ្លងឱឃៈ ដែលជាគ្រឿងចង
ដោយកាម អ្នកសម្រេចសេចក្តីសុខ ដែលមិនញាប់ញ័រ
ដូចនរណាៗ មិនដឹងគតិរបស់អ្នកទម្លាយចម្រឹងដែកដ៏រុង
រឿងដោយព្រះវេទ ជាអ្នកស្ងប់ដោយលំដាប់ ដូច្នោះ ។

ទ្រង់រុងរឿងដូចព្រះអាទិត្យក្នុងសារទកាល និងដូចព្រះចន្ទក្នុងថ្ងៃពេញបូណ៌មី ។

ចប់ ភាណវារកថា ទី ២

[៤២] **គប្បីជ្រាបក្នុងភាណវារទី ៣ ។** បទថា យន្នូនាហំ ធម្មំ ទេសេយ្យំ សេចក្ដីថា ធ្វើដូចម្ដេចហ្ន៎ តថាគតនឹងសម្ដែងធម៌ ។ ក៏វិតក្កៈនេះកើតឡើងហើយ កាលណា ។ កើតឡើងក្នុងសប្ដាហ៍ទី ៨ របស់ព្រះពុទ្ធ ។

បានឮថា ព្រះមានព្រះភាគព្រះនាមថា វិបស្សីនោះ បានជាព្រះពុទ្ធហើយ ប្រថាប់អង្គុយក្នុងពោធិបល្ល័ង្កអស់ ១ សប្ដាហ៍ ប្រថាប់ឈរសម្លឹងមើលពោធិបល្ល័ង្កអស់ ១ សប្ដាហ៍ ស្ដេចចង្ក្រមក្នុងផ្ទះកែវអស់ ១ សប្ដាហ៍ ប្រថាប់អង្គុយក្នុងអជបាលនិគ្រោធ ប្រថាប់អង្គុយពិចារណាព្រះធម៌ក្នុងផ្ទះកែវអស់ ១ សប្ដាហ៍ ប្រថាប់អង្គុយត្រង់អជបាលនិគ្រោធ ១ សប្ដាហ៍ ប្រថាប់អង្គុយត្រង់គល់មុចលិន្ទ ១ សប្ដាហ៍ ប្រថាប់អង្គុយនៅរាជាយតនៈ ១ សប្ដាហ៍ ស្ដេចក្រោកចាករាជាយតនៈនោះ លុះព្រះអង្គស្ដេចមកក្នុងសប្ដាហ៍ទី ៨ ប្រថាប់អង្គុយក្នុងអជបាលនិគ្រោធទៀត វិតក្កៈនេះ និងវិតក្កៈក្រៅអំពីនេះ ដែលព្រះពុទ្ធប្រព្រឹត្ត និងប្រព្រឹត្តមកយ៉ាងស្មើ កើតឡើងហើយដល់ព្រះពុទ្ធទាំងពួង ។

ក្នុងបទទាំងឡាយទាំងនោះ បទថា អធិគតោ គឺ ចាក់ធ្លុះហើយ ។ បទថា ធម្មោ បានដល់ ធម៌ គឺ អរិយសច្ច ៤ បទថា គម្ភីរោ នេះ ជាឈ្មោះនៃការបដិសេធសេចក្ដីថា ជារបស់រាក់ ។ បទថា ទុទ្ទសោ សេចក្ដីថា ជាធម៌ដែលឃើញបានលំបាក ជាធម៌ដែលបុគ្គលឃើញ ដោយលំបាក

គឺ មិនអាចឃើញដោយងាយ ព្រោះជាធម៌ជ្រាលជ្រៅ ។ ព្រោះជាធម៌ដែលឃើញបានលំបាក ទើបជាធម៌ដែលត្រាស់ដឹងដោយលំបាក ដែលបុគ្គលគប្បីត្រាស់ដឹងដោយលំបាក គឺ មិនអាចត្រាស់ដឹងបានដោយងាយ ។ បទថា សន្តោ គឺ រលត់ស្និទ្ធហើយ ។ បទថា បណីតោ គឺ មិនក្តៅក្រហាយ ទាំងពីរបទនេះ លោកពោលសំដៅដល់លោកុត្តរៈនុ៎ះឯង ។ បទថា អតក្កាវចរោ សេចក្តីថា មិនគួរប៉ាន់ស្មាន គឺ មិនគួរឈានចុះដោយការត្រិះរិះ គួរប៉ាន់ស្មានដោយញាណប៉ុណ្ណោះ ។ បទថា និបុណោ គឺ ល្អិតល្អន់ ។ បទថា បណ្ឌិតវេទនីយោ សេចក្តីថា ដែលបណ្ឌិតអ្នកបដិបត្តិបដិបទាដ៏ប្រពៃគប្បីដឹងបាន ។ បទថា អាលយរាមា សេចក្តីថា សត្វទាំងឡាយ រមែងជាប់ក្នុងកាមគុណ ៥ ព្រោះដូច្នោះ សត្វទាំងនោះលោកពោលថា អាលយា ។ សត្វទាំងឡាយ រមែងនៅជាមួយនឹងការជាប់ព័ន្ធវិបរិតរបស់តណ្ហា ១០៨ ព្រោះដូច្នោះ លោកទើបពោលថា អាលយា ។ សត្វទាំងឡាយ រមែងត្រេកអរដោយអាល័យទាំងនោះ ព្រោះដូច្នោះ ទើបឈ្មោះថា អាលយារាមា គឺ មានអាល័យជាទីត្រេកអរ ។ សត្វទាំងឡាយត្រេកអរហើយក្នុងអាល័យ ព្រោះដូច្នោះ ទើបឈ្មោះថា អាលយរតា គឺត្រេកអរហើយក្នុងអាល័យ ។ សត្វទាំងឡាយរីករាយ ហើយដោយល្អក្នុងអាល័យទាំងឡាយ ព្រោះដូច្នោះ ទើបឈ្មោះថា អាលយសម្មុទិតា គឺរីករាយហើយក្នុងអាល័យ ។ សត្វទាំងឡាយរមែងត្រេកអរ ដោយអាល័យ

ក្នុងកាម និងអាល័យក្នុងតណ្ហាសូម្បីទាំងនេះ ជាអ្នករីករាយត្រេកអរក្នុងសង្សារវដ្ដ ដូចព្រះរាជាស្ដេចប្រពាតព្រះរាជឧទ្យាន ដែលសម្បូរណ៍ដោយរុក្ខជាតិដែលពេញទៅដោយផ្កា និងផ្លែជាដើម ដែលតាក់តែងទុកជាយ៉ាងល្អ ទ្រង់រីករាយមនោរម្យ រីករាយ ត្រេកត្រេនដោយសម្បត្តិនោះៗ ទ្រង់មិននឿយណាយ ទ្រង់មិនប្រាថ្នានឹងត្រឡប់សូម្បីល្ងាច ដូច្នោះ ។ ដោយហេតុនោះ ព្រះមានព្រះភាគកាលនឹងទ្រង់សម្ដែងសេចក្ដីអាល័យសូម្បី ២ យ៉ាង ដូចទីឧទ្យានដល់សត្វទាំងនោះ ទើបត្រាស់ថា អាលយរាមា គឺ មានសេចក្ដីអាល័យជាទីត្រេកអរ ដូច្នេះជាដើម ។ បទថា យទិទំ ជានិបាត ។ គប្បីជ្រាបសេចក្ដីយ៉ាងនេះថា បទថា យំ ឥទំ សំដៅដល់ឋានៈរបស់បទនោះ ។ បទថា យោ អយំ សំដៅដល់បដិច្ចសមុប្បាទ ។ បច្ច័យរបស់បទទាំងពីរនេះថា ឥទប្បច្ចយតា បដិច្ចសមុប្បាទោ ឈ្មោះថា ឥទប្បច្ចយា គឺ វត្ថុនេះជាបច្ច័យរបស់វត្ថុនេះ ។ ឈ្មោះថា ឥទប្បច្ចយតា និង បដិច្ច-សមុប្បាទោ ព្រោះសេចក្ដីដែលវត្ថុនេះជាបច្ច័យរបស់វត្ថុនេះ និងបច្ច័យដែលជាទីអាស្រ័យគ្នាកើតឡើង ។ បទនេះ ជាឈ្មោះរបស់អវិជ្ជាជាដើម ដែលជាបច្ច័យនៃសង្ខារជាដើម ។ បទទាំងអស់ថា សព្វសង្ខារសមថោ ជាដើម ជានិព្វានតែម្យ៉ាង ។ ព្រោះសេចក្ដីក្ដៅក្រហាយនៃសង្ខារទាំងពួង អាស្រ័យនិព្វាននោះ រមែងស្ងប់ រមែងរម្ងាប់ ដូច្នោះ លោកទើបពោលថា សព្វ-សង្ខារសមថោ គឺ ជាទីរម្ងាប់នៃសង្ខារទាំងពួង ដូច្នេះ ។ ម្យ៉ាងទៀត

ព្រោះកិលេសទាំងពួងជាការលះបង់ទៅបាន តណ្ហាទាំងពួងអស់ទៅ កិលេសរាគៈទាំងពួងប្រាសទៅ ទុក្ខទាំងពួងរលត់ទៅ ព្រោះអាស្រ័យនិព្វាននោះ ដូច្នោះ លោកទើបពោលថា សព្វូបធិបដិនិស្សគ្គោ ជាទីលះបង់កិលេសទាំងពួង តណ្ហក្ខយោ ជាទីអស់ទៅនៃតណ្ហា វិរាគោ ប្រាសចាកតម្រេក និរោធោ រំលត់ទុក្ខ ដូច្នេះ ។ ក៏តណ្ហានោះ រមែងនាំទៅ គឺ រួបរឹតភព ដោយភព ឬកម្ម និងផលកម្ម ព្រោះដូច្នោះ លោកទើបពោលថា តណ្ហាធ្វើការរួបរឹត ។ ឈ្មោះនិព្វាន ព្រោះចេញចាកគ្រឿងរួបរឹតនោះ ។ បទថា សោ មមស្ស កិលមថោ សេចក្តីថា ការសម្តែងធម៌ដល់អ្នកមិនដឹង គប្បីជាសេចក្តីលំបាករបស់តថាគត ។ ដែលលោកពោលថា គប្បីជាសេចក្តីលំបាកផ្លូវកាយ និងគប្បីជាការបៀតបៀនផ្លូវកាយ ។ ក៏ប៉ុន្តែថា ទាំងពីរនេះ មិនបានមានក្នុងព្រះទ័យរបស់ព្រះពុទ្ធទាំងឡាយ ។

បទថា អបិស្សុ ជានិបាតក្នុងអត្ថថា កពូន ។ និបាតនោះ សម្តែងថា មិនមែនមានសេចក្តីវិតក្កនេះតែម្យ៉ាង សូម្បីគាថាទាំងនេះ ក៏ជាក់ច្បាស់ហើយ ។ ក្នុងបទទាំងឡាយថា វិបស្សិំ ជាអាទិ សេចក្តីថា ព្រះវិបស្សីព្រះមានព្រះភាគ ជាព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់ ។

បទថា អនច្ឆរិយា គឺ អស្ចារ្យតិច ។ បទថា បដិភំសុ សេចក្តីថា ធម៌ជាគោចរទាំងឡាយបានកើតដល់ញាណ ពោលគឺ បដិភាណ ដល់ភាពជាធម៌គប្បីបរិវិតក្កៈ ។

បទថា កិច្ឆេន សេចក្ដីថា ដោយលំបាក គឺ មិនមែនដើម្បីបដិបត្តិលំបាក ។ ព្រោះសុប្បីមគ្គ ៤ ក៏រមែងជាការបដិបត្តិងាយរបស់ព្រះពុទ្ធទាំងឡាយ ។ បទនេះ លោកពោលសំដៅដល់ការបដិបត្តិដើម្បីបានគុណវិសេសរបស់អ្នកដែលនៅមានរាគៈ មានទោសៈ និងមានមោហៈ ក្នុងវេលាបំពេញបារមីនោះឯង ឲ្យវត្ថុជាដើមយ៉ាងនេះ គឺ កាត់សិរសៈដែលប្រដាប់តាក់តែងហើយ យកឈាមចេញចាកក ខ្វេះគ្រាប់ភ្នែកទាំងពីរខាងដែលបន្តក់ថ្នាំទុកយ៉ាងល្អ លះបង់បុត្រជាអ្នកនឹងបន្តវង្សត្រកូល លះបង់ករិយាដែលមានការប្រព្រឹត្តជាទីពេញចិត្ត ឲ្យដល់ស្មូមទាំងឡាយ ដែលនាំគ្នាមក និងសូប្បីយ៉ាងដទៃ មានការកាត់ និងទម្លាយក្នុងអត្តភាព ដូចជាខន្តិវាទីតាបសជាដើម ។ ហ អក្សរ ក្នុងបទថា ហលំ នេះ ត្រឹមតែជានិបាត ប្រែថា គួរ ។ បទថា បកាសិតុំ គឺ ដើម្បីសម្ដែង គឺ កាលអ្នកសម្រេចធម៌បានលំបាកយ៉ាងនេះ ក៏មិនគួរសម្ដែង គឺ គួរសម្ដែងនឹងអ្នកឆ្លាត លោកអធិប្បាយថា ប្រយោជន៍អ្វីដោយការសម្ដែង ។ បទថា រាគទោសបរេតេហិ គឺ ត្រូវរាគៈ ទោសៈគ្របសង្កត់ ឬរាគៈ ទោសៈជាប់តាមទៅ ។ បទថា បដិសោតគាមិ សេចក្ដីថា សច្ចធម៌ ៤ ដែលដល់ហើយយ៉ាងនេះថា ជាធម៌បញ្ច្រាសក្រសែនៃសេចក្ដីទៀងជាដើម គឺ ការមិនទៀង ជាទុក្ខ មិនមានតួខ្លួន និងមិនស្អាត ។ បទថា រាគរត្តា សេចក្ដីថា ត្រូវកាមរាគៈ ភវរាគៈ និងទិដ្ឋិរាគៈពន្ទិចទុក ។ បទថា ន ទក្ខន្តិ

សេចក្ដីថា សត្វទាំងឡាយនឹងមិនឃើញតាមសេចក្ដីពិតថា ជារបស់មិនទៀង ជាទុក្ខ មិនមានតួខ្លួន មិនស្អាត ដូច្នេះ អ្នកណាហ្ន៎ នឹងអាចឲ្យអ្នកដែលមិនឃើញទាំងនោះ កាន់យកយ៉ាងនេះបាន ។ បទថា តមោក្ខន្ធេន អាវុតា សេចក្ដីថា ត្រូវកងអវិជ្ជាចាក់ស្រេះទុក ។

[៤៣] បទថា អប្បោស្សុក្កតាយ សេចក្ដីថា ព្រោះទ្រង់មិនប្រាថ្នានឹងសម្ដែង ដោយភាពជាអ្នកមិនមានសេចក្ដីខ្វល់ខ្វាយ ។ ក៏ព្រោះហេតុអ្វី ព្រះទ័យរបស់ព្រះអង្គទើបបង្អោនទៅយ៉ាងនេះហ្ន៎ ព្រះអង្គទ្រង់ធ្វើសេចក្ដីប្រាថ្នាទុកថា តថាគតរួចផុតហើយនឹងដោះលែងសត្វ តថាគតឆ្លងបានហើយនឹងឲ្យសត្វឆ្លងខ្លះ

**នឹងបានប្រយោជន៍អ្វី ដោយតថាគតអ្នកដឹងច្បាស់ធម៌ក្នុងលោកនេះហើយ នឹងមិនឲ្យអ្នកដទៃដឹងខ្លះ តថាគតសម្រេចសព្វញ្ញុតញ្ញាណហើយ នឹងញុំាងសត្វ ព្រមទាំងទេវតាឲ្យឆ្លងរួចផុតទៅ ដូច្នេះ មិនមែនឬ**

ហើយទ្រង់បំពេញបារមី ដរាបបានសម្រេចព្រះសព្វញ្ញុតញ្ញាណ ។ ប្រការនោះ ជាសេចក្ដីពិត តែចិត្តរបស់ព្រះអង្គទ្រង់បង្អោនទៅយ៉ាងនោះ ដោយអានុភាពនៃការពិចារណា ។ ពិតហើយ កាលព្រះអង្គសម្រេចសព្វញ្ញុតញ្ញាណហើយ សូម្បីទ្រង់ពិចារណាដល់សត្វទាំងឡាយនៅជាប់ស្អិតដោយកិលេស និងសភាពនៃព្រះធម៌ជាធម៌ជ្រាលជ្រៅ សភាពនៃសត្វទាំងឡាយ

នៅជាប់ស្អិតដោយកិលេស និងសភាពនៃព្រះធម៌ជាធម៌ជ្រាលជ្រៅ ប្រាកដដោយអាការទាំងពួង ។ ព្រោះដូច្នោះ កាលព្រះអង្គទ្រង់ត្រិះរិះថា សត្វទាំងនេះឯង ពេញទៅដោយកិលេស សៅហ្មងក្រៃលែងពេកណាស់ ត្រូវរាគៈពន្ធ័ច ត្រូវទោសៈគ្របសង្កត់ ឈ្ងក់វង្វេងទៅដោយមោហៈ ដូចទឹកកុណ្ឌីពេញទៅដោយទឹកដោះជូរ ដូចថាសពេញទៅដោយប្រេង ដូចផ្ទាំងសំពត់ប្រឡាក់ទៅដោយខ្លាញ់រាវ និងខ្លាញ់ ដូចដៃប្រឡាក់ទៅដោយថ្នាំបន្តក់ភ្នែក បុគ្គលទាំងនោះនឹងដឹងច្បាស់ចាក់ធ្លុះបានយ៉ាងណា ដូច្នេះ ចិត្តទើបបង្អោនទៅយ៉ាងនោះ ដោយអានុភាពនៃការប្រកាន់របស់កិលេស និងការពិចារណា ។ មួយវិញទៀត ព្រះធម៌នេះជ្រាលជ្រៅ ដូចទឹកទ្រផែនដីទុកបានឃើញដោយលំបាក ដូចគ្រាប់ស្ពៃដែលត្រូវភ្នំបាំងទុក នឹងដឹងតាមបានលំបាក ដូចការចែកចុងដោយចុងនៃរោមសត្វ ដែលពុះចេញជា ១០០ ចំរៀក ។ ពិតហើយ តថាគតព្យាយាមដើម្បីដឹងច្បាស់នូវធម៌នេះ មិនមែនមិនបានឲ្យទាន មិនមែនមិនបានរក្សាសីល មិនមែនមិនបានបំពេញបារមីនោះទេ សូម្បីកាលតថាគតកម្ចាត់មារ និងសេនាមារ ដូចមិនមានសេចក្តីឧស្សាហ៍ ផែនដីក៏មិនញាប់ញ័រ សូម្បីកាលតថាគតរឭកដល់ខន្ធដែលធ្លាប់នៅអាស្រ័យក្នុងជាតិមុនក្នុងបឋមយាម ក៏មិនញាប់ញ័រ សូម្បីកាលតថាគតជម្រះទិព្វចក្ខុក្នុងមជ្ឈិមយាម ក៏មិនញាប់ញ័រ តែកាលតថាគតដឹងច្បាស់ចាក់ធ្លុះនូវបដិច្ចសមុប្បាទក្នុងបច្ឆិមយាម ផែនដីមុឺនលោកធាតុ បានញាប់ញ័រហើយ

ដោយប្រការដូច្នេះ សូម្បីជនដូចតថាគតបានដឹងច្បាស់ចាក់ធ្លុះនូវធម៌នេះ ដោយញាណដ៏ខ្លាំងក្លាដោយលំបាកដល់ម្ល៉េះហើយ មហាជននឹងដឹងច្បាស់ចាក់ធ្លុះនូវធម៌នោះ បានយ៉ាងណា ព្រោះហេតុនោះ គប្បីជ្រាបថា ព្រះទ័យរបស់ព្រះអង្គបង្អោនទៅហើយយ៉ាងនោះ សូម្បីដោយអានុភាពនៃព្រះធម៌ជាធម៌ជ្រាលជ្រៅ និងដោយការពិចារណា ដូច្នេះ ។ មួយវិញទៀត កាលព្រហ្មទូលអង្វរ ព្រះទ័យរបស់ព្រះអង្គក៏បង្អោនទៅយ៉ាងនេះ ព្រោះមានព្រះបំណងនឹងសម្តែង ។ ពិតហើយ ព្រះមានព្រះភាគរមែងទ្រង់ជ្រាបថា កាលចិត្តរបស់តថាគតបង្អោនទៅ ព្រោះតថាគតជាអ្នកមានសេចក្តីប្រាថ្នាតិច មហាព្រហ្មអង្វរតថាគត ដើម្បីសូមឲ្យសម្តែងធម៌ ក៏សត្វទាំងនេះជាអ្នកគោរពព្រហ្ម កាលដឹងថា មានដំណឹងថា ព្រះសាស្តាមិនមានព្រះបំណងនឹងសម្តែងធម៌ដល់ពួកយើង ពេលនោះ មហាព្រហ្មទូលអង្វរព្រះអង្គឲ្យសម្តែងហើយ អ្នកដ៏ចម្រើនទាំងឡាយ ព្រះធម៌ស្ងប់ហ្ន៎ ប្រណីតហ្ន៎ នឹងតាំងចិត្តស្តាប់ ដូច្នេះ ។ គប្បីជ្រាបថា អាស្រ័យហេតុនេះ ព្រះទ័យរបស់ព្រះអង្គ ទើបបង្អោនទៅ ដើម្បីជាអ្នកមានសេចក្តីខ្វល់ខ្វាយតិច មិនបង្អោនទៅ ដើម្បីនឹងទ្រង់សម្តែងធម៌ ។

[៤៤] ក្នុងបទថា អញ្ញតរស្ស នេះ លោកពោលថា អញ្ញតរោ ក៏ពិត សូម្បីដូច្នោះគប្បីជ្រាបថា នោះគឺ មហាព្រហ្មជាធំក្នុងចក្រវាឡនេះ ។ បទថា ឧស្សន្តិ វត ភោ លោកោ សេចក្តីថា ន័យថា មហាព្រហ្មនោះ

បន្ទីសម្រេចនេះ ដោយពួកព្រហ្មក្នុងម៉ឺនលោកធាតុស្តាប់ហើយ ទាំងអស់ប្រជុំគ្នា ។ បទថា យត្រ ហិ ឆាម គឺ ក្នុងលោកឈ្មោះណា ។ បទថា បុរតោ ធាតិរហោសិ សេចក្តីថា មហាព្រហ្មបានប្រាកដព្រមទាំងព្រហ្មមួយម៉ឺនទាំងនោះ ។ បទថា អប្បរជក្ខជាតិកា សេចក្តីថា ធូលី គឺ រាគៈ ទោសៈ និងមោហៈស្រាលស្តើង គឺ បន្តិចបន្តួច ក្នុងភ្នែកដែលសម្រេចដោយបញ្ញា សភាពយ៉ាងនេះរបស់សត្វទាំងឡាយនោះ នៅមាន ព្រោះហេតុនោះ សត្វទាំងឡាយឈ្មោះថា អប្បរជក្ខជាតិកា គឺ មានធូលី គឺ កិលេសក្នុងចក្ខុស្រាលស្តើង ។ បទថា អស្សវនតា គឺ ព្រោះមិនបានស្តាប់ ។ បទថា ភវិស្សន្តិ សេចក្តីថា លោកពោលថា សត្វទាំងឡាយសន្សំបុណ្យទុកហើយដល់កាលចាស់ក្លាក្នុងព្រះពុទ្ធអង្គមុនៗ ដោយអំណាចបុញ្ញកិរិយាវត្ថុ ១០ ប្រាថ្នាព្រះធម៌ទេសនាតែម្យ៉ាង ដូចបទុមជាតិប្រាថ្នាពន្លឺព្រះអាទិត្យ ជាអ្នកគួរឈានចុះកាន់អរិយភូមិ ក្នុងកាលចប់គាថា ៤ បទ មិនមែនតែម្នាក់ មិនមែនពីរនាក់ មានច្រើនសែននាក់នឹងជាអ្នកដឹងធម៌ដូច្នេះ ។

បទថា អជ្ឈេសនំ គឺ អង្វរយ៉ាងនេះ ៣ ដង ។ បទថា ពុទ្ធចក្ខុនា សេចក្តីថា ដោយប្រាជ្ញាកំណត់ដឹងភាពទន់ខ្លី និងចាស់ក្លានៃឥន្ទ្រិយរបស់សត្វទាំងឡាយ និងដោយអាសយានុសយញ្ញាណ ។ បទថា ពុទ្ធចក្ខុ ជាឈ្មោះនៃញាណទាំងពីរនេះ ។ ពាក្យថា **សមន្តចក្ខុ** ជាឈ្មោះនៃព្រះ

សព្វញ្ញុតញ្ញាណ ។ ពាក្យថា **ធម្មចក្ខុ** ជាឈ្មោះនៃមគ្គញ្ញាណ ៣ ។ ក្នុងបទថា អប្បរជក្ខេ ជាដើម សេចក្តីថា សត្វដែលមានធូលី មានរាគៈជាដើម ក្នុងបញ្ញាចក្ខុតិច ដោយន័យដែលពោលនោះឯង ។ ឈ្មោះថា អប្បរជក្ខា គឺ មានកិលេសប្រាកដដូចធូលីក្នុងចក្ខុតិច ។ សត្វដែលមានធូលី មានរាគៈជាដើមនោះ ក្នុងបញ្ញាចក្ខុច្រើនឈ្មោះថា មហារជក្ខា គឺ មានកិលេស ប្រាកដដូចធូលីក្នុងចក្ខុច្រើន ។ សត្វដែលមានឥន្ទ្រិយ មានសទ្ធាជាដើម ចាស់ក្លា ឈ្មោះថា តិក្ខិន្ទ្រិយា គឺ មានឥន្ទ្រិយចាស់ក្លា ។ សត្វដែលមានឥន្ទ្រិយទាំងនោះទន់ខ្សោយ ឈ្មោះថា មុទុន្ទ្រិយា គឺ មានឥន្ទ្រិយទន់ខ្សោយ ។ សត្វដែលមានអាការ មានសទ្ធាជាដើមទាំងនោះ ល្អ ឈ្មោះស្វាការា គឺ មានអាការល្អ ។ សត្វដែលកំណត់ហេតុដែលពោល អាចឲ្យដឹងបានងាយ ឈ្មោះថា សុវិញ្ញាបយា គឺ ឲ្យដឹងច្បាស់បានងាយ ។ សត្វដែលឃើញបរលោក និងទោស ដោយភាពជាភ័យ ឈ្មោះថា បរលោក-វជ្ជភយទស្សាវិនោ គឺ ច្រើនឃើញបរលោក និងទោស ដោយភាពជាភ័យ ។

ក៏ក្នុងរឿងដែលមានបាលីដូច្នេះ ៖

**បុគ្គលដែលមានសទ្ធា មានកិលេសត្រឹមតែដូចធូលី ក្នុងចក្ខុតិច បុគ្គលដែលមិនមានសទ្ធា មានកិលេសប្រាកដដូចធូលីក្នុងចក្ខុច្រើន បុគ្គលដែលប្រារព្ធសេចក្តីព្យាយាម មានកិលេសប្រាកដដូចធូលីក្នុងចក្ខុតិច បុគ្គលដែលខ្ជិល**

ប្រអូស មានកិលេសប្រាកដដូចធូលីក្នុងចក្ខុច្រើន បុគ្គលដែលមានសតិតាំងមាំ មានកិលេសប្រាកដដូចធូលី ក្នុងចក្ខុតិច បុគ្គលដែលភ្លេចស្មារតី មានកិលេសប្រាកដដូចធូលីក្នុងចក្ខុច្រើន បុគ្គលដែលមានចិត្តតាំងមាំ មានកិលេសប្រាកដដូចធូលី ក្នុងចក្ខុតិច បុគ្គលដែលមានចិត្តមិនតាំងមាំ មានកិលេសប្រាកដដូចធូលី ក្នុងចក្ខុច្រើន បុគ្គលដែលមានបញ្ញា មានកិលេសប្រាកដដូចក្នុងចក្ខុតិច បុគ្គលដែលមានបញ្ញាទន់ខ្សោយ មានកិលេសប្រាកដដូចធូលី ក្នុងចក្ខុច្រើន ដូចគ្នានឹងបុគ្គលដែលមានសទ្ធា មានឥន្ទ្រិយចាស់ក្លា ។ល។ បុគ្គលដែលមានបញ្ញាច្រើន ឃើញលោកដទៃ និងទោសដោយភាពជាភ័យ បុគ្គលដែលមានបញ្ញាទន់ខ្សោយមិនឃើញលោកដទៃ និងទោស ដោយភាពជាភ័យ ។

ពាក្យថា **លោកោ** បានដល់ ខន្ធលោក ធាតុលោក អាយតនលោក សម្បត្តិភវលោក វិបត្តិភវលោក សម្បត្តិ និងវិបត្តិភវលោក វិបត្តិ-សម្បត្តិភវលោក , លោកមួយ គឺ សត្វទាំងឡាយទាំងពួងរស់នៅបានដោយអាហារ , លោក ២ គឺ នាម និងរូប , លោក៣ គឺ វេទនា ៣ , លោក ៤ គឺ អាហារ ៤ , លោក ៥ គឺ ឧបាទានក្ខន្ធ ៥ , លោក ៦ គឺ អាយ-

តនៈខាងក្នុង ៦ , លោក ៧ គឺ ភូមិជាទីតាំងនៃវិញ្ញាណ ៧ , លោក ៨ គឺ លោកធម៌ ៨ , លោក ៩ គឺ ភពជាទីនៅរបស់សត្វ ៩ , លោក ១០ គឺ អាយតនៈ ១០ , លោក ១២ គឺ អាយតនៈ ១២ , លោក ១៨ គឺ ធាតុ ១៨ ។

បទថា វជ្ជំ បានដល់ កិលេសគ្រប់ប្រភេទជាទោស ទុច្ចរិតគ្រប់ប្រភេទជាទោស អភិសង្ខារគ្រប់ប្រភេទជាទោស កម្ម គឺ ការទៅកាន់ភពគ្រប់ប្រភេទជាទោស ដោយប្រការដូច្នេះ ទាំងក្នុងលោកនេះ ទាំងទោសនេះ ជាការប្រាកដអត្ថន័យដោយសភាពជាភ័យយ៉ាងខ្លាំងក្លា ដូចពេជ្ឈ-ឃាតងាជាវ , ព្រះមានព្រះភាគព្រះនាមថា វិបស្សី ទ្រង់ដឹង ទ្រង់ឃើញ ទ្រង់ដឹងក្រៃលែង ទ្រង់ចាក់ធ្លុះនូវឥន្ទ្រិយ ៥ ទាំងនេះ ដោយអាការទាំង ៥០ នេះ នេះជាព្រះប្រាជ្ញាកំណត់ដឹងភាពទន់ខ្ចី និងភាពចាស់ក្លានៃឥន្ទ្រិយទាំងឡាយរបស់ព្រះតថាគត ។

បទថា ឧប្បលិនិយំ គឺ ក្នុងគុម្ពព្រលិត ។ សូម្បីក្នុងបទក្រៅនេះក៏មានន័យនេះដូចគ្នា ។ បទថា អន្តោនិមុគ្គបោសីនិ គឺ ផ្កាឈូកសូម្បីដទៃពួកណាលិចនៅក្នុងទឹកដែលទឹកចិញ្ចឹមទុក ។ បទថា ឧទកំ អច្ចុគ្គម្ម តិដ្ឋន្តិ គឺ ឈូកពួកខ្លះតាំងឡើងផុតពីទឹក ។ ក្នុងបទនោះ អធិប្បាយថា ឈូកពួកខ្លះតាំងឡើងផុតទឹក រង់ចាំតែសម្ផស្សពន្លឺព្រះអាទិត្យ ហើយរីកក្នុងថ្ងៃនេះ ។ ពួកខ្លះតាំងនៅស្មើទឹកនឹងរីកក្នុងថ្ងៃស្អែកនេះ ។ ពួកខ្លះ

លិចនៅខាងក្នុងទឹក ដែលទឹកចិញ្ចឹមទុកនឹងរីកក្នុងថ្ងៃទី ៣ ។ ប៉ុន្តែថា នៅមានផ្កាឈូកជាដើមដែលមានរោគ សូម្បីពួកដទៃមិនទាន់ឡើងផុតពីទឹក ហើយផ្កាឈូកពួកណានឹងមិនរីក នឹងជាអាហារនៃត្រី និងអណ្តើកតែម្យ៉ាង ផ្កាឈូកទាំងនោះ លោកមិនគប្បីនាំឡើងកាន់បាលី បានសម្តែងទុកច្បាស់ហើយ ។

បុគ្គល ៤ ជំពូក គឺ ឧគ្ឃដិតញ្ញូ វិបចិត្តញ្ញូ នេយ្យៈ បទបរមៈ ក៏ប្រៀបដូចផ្កាឈូក ៤ ទាំងនេះឯង ។

ក្នុងបុគ្គល ៤ ជំពូកនោះ បុគ្គលដែលត្រាស់ដឹងធម៌ ព្រមនឹងវេលាដែលលោកលើកឡើងសម្តែង ឈ្មោះ **ឧគ្ឃដិតញ្ញូ** ។ បុគ្គលដែលត្រាស់ដឹងធម៌ កាលលោកចែកសេចក្តីនៃពាក្យសង្ខេបដោយពិស្តារ ឈ្មោះថា **វិបចិត្តញ្ញូ** ។ បុគ្គលដែលត្រាស់ដឹងធម៌ដោយលំដាប់ ដោយការប្រារព្ធព្យាយាមទន្ទេញចាំ ដោយការសាកសួរ ដោយធ្វើទុកក្នុងចិត្តដោយឧបាយដ៏ប្រពៃ ដោយគប់រក សមាគមនឹងកល្យាណមិត្ត ឈ្មោះថា **នេយ្យៈ** ។ បុគ្គលដែលមិនត្រាស់ដឹងធម៌បានក្នុងជាតិនោះ សូម្បីរៀនច្រើន ចាំទុកច្រើន គេទូន្មានច្រើន ឈ្មោះថា **បទបរមៈ** ។

ក្នុងបទនោះ ព្រះមានព្រះភាគទ្រង់ពិចារណាមើលមុនលោកធាតុដូចជាផ្កាឈូកជាដើម ទ្រង់បានឃើញហើយថា បុគ្គលពួកឧគ្ឃដិតញ្ញូដូចផ្កាឈូកនឹងរីកក្នុងថ្ងៃនេះ បុគ្គលពួកវិបចិត្តញ្ញូ ដូចផ្កាឈូកនឹងរីកក្នុង

ថ្ងៃស្អែកនេះ បុគ្គលពួកនេយ្យៈ ដូចផ្កាឈូកនឹងរីកក្នុងថ្ងៃទី ៣ បុគ្គលពួកបទបរមៈ ដូចផ្កាឈូកដែលជាអាហារនៃត្រី និងអណ្តើក ។ មួយទៀត ព្រះមានព្រះភាគ កាលទ្រង់ពិចារណាមើល ទ្រង់បានឃើញដោយអាការទាំងពួងយ៉ាងនេះថា សត្វមានកិលេសដូចធូលីក្នុងចក្ខុតិច មានប្រមាណប៉ុណ្ណេះ , សត្វមានកិលេសដូចធូលីក្នុងចក្ខុច្រើន មានប្រមាណប៉ុណ្ណេះ សូម្បីក្នុងសត្វទាំងនោះ ពួកដែលជាឧគ្ឃដិតញ្ញូ មានប្រមាណប៉ុណ្ណេះ ដូច្នេះ ។ ក្នុងសត្វ ៤ ពួកនោះ ការសម្តែងធម៌របស់ព្រះមានព្រះភាគ រមែងសម្រេចប្រយោជន៍ដល់បុគ្គល ៣ ពួក ក្នុងអត្តភាពនេះឯង ។ ពួកបទបរមៈ នឹងមានវាសនាដើម្បីប្រយោជន៍ក្នុងអនាគត ។

លំដាប់នោះ ព្រះមានព្រះភាគទ្រង់ប្រកាសព្រះធម៌ទេសនា ដែលនាំមកនូវប្រយោជន៍ដល់បុគ្គល ៤ ពួក ទាំងនេះហើយ ញុំាងភាពជាអ្នកមានព្រះបំណងនឹងទ្រង់សម្តែងឲ្យកើតឡើង ទ្រង់បានចែកសត្វសូម្បីទាំងពួងក្នុងភព ៣ ឲ្យជាពីរចំណែក ដោយអំណាចនៃភ័ព្វសត្វ និងអភ័ព្វសត្វ សត្វដែលលោកពោលសំដៅដល់នោះ គឺ សត្វពួកណាប្រកបដោយ **កម្មាវរណៈ វិបាកាវរណៈ កិលេសាវរណៈ** មិនមានសទ្ធា មិនមានសេចក្តីព្យាយាម មានបញ្ញាថោកទាប ជាអ្នកមិនគួរឈានចុះកាន់សភាពត្រឹមត្រូវក្នុងធម៌ទាំងឡាយដែលជាកុសលយ៉ាងពិតប្រាកដ សត្វទាំងឡាយនោះ ជាអភ័ព្វសត្វ , ភ័ព្វសត្វដូចម្តេច ? សត្វពួកណាមិនប្រកបដោយកម្មាវរណៈ

។ល។ សត្វទាំងឡាយនេះ ជាភព្វសត្វ ដូច្នេះ ។

ក្នុងបទនោះ ព្រះមានព្រះភាគទ្រង់លះអភព្វបុគ្គលសូម្បីទាំងអស់ ទ្រង់កំណត់ភព្វបុគ្គលតែម្យ៉ាងដោយព្រះញាណ ទ្រង់ចែកឲ្យជា ៦ ចំណែក គឺ សត្វពួករាគចរិតប្រមាណប៉ុណ្ណេះ សត្វពួកទោសចរិត មោហចរិត វិតក្កចរិត សទ្ធាចរិត ពុទ្ធិចរិត មានប្រមាណប៉ុណ្ណេះ ។ គ្រាទ្រង់ចាត់យ៉ាងនេះហើយ ទើបទ្រង់ត្រិះរិះថា តថាគតនឹងសម្តែងធម៌ ដូច្នេះ ។

ព្រហ្ម លុះជ្រាបដូច្នោះហើយ កើតសោមនស្ស បានក្រាបទូលព្រះមានព្រះភាគដោយគាថា ជាច្រើនគាថា ។

ព្រះមានព្រះភាគត្រាស់ថា អជ្ឈោ សោ ភិក្ខវេ មហាព្រហ្មា ជាដើម ទ្រង់សំដៅដល់សេចក្តីនេះ ។ ក្នុងបទទាំងនោះ បទថា អជ្ឈភាសិ កាត់បទជា អធិ អភាសិ អធិប្បាយថា បានក្រាបទូលប្រារព្ធឲ្យក្រៃលែងឡើងទៅ ។

[៤៥] បទថា សេលេ យថា បព្វតមុទ្ធនិដ្ឋិតោ គឺ ដូចបុគ្គលឈរលើភ្នំថ្មសុទ្ធ ។ ពិតហើយ កាលបុគ្គលឈរលើកំពូលភ្នំនោះ ក៏មិនមានកិច្ចជាដើមថា ចំទើត និងអើតក សូម្បីដើម្បីនឹងមើល ។ បទថា តថូបមំ សេចក្តីថា ប្រៀបផ្ទឹមដោយវត្ថុនោះ គឺ ប្រៀបផ្ទឹមដោយភ្នំថ្មសុទ្ធ ។ ក៏សេចក្តីសង្ខេបក្នុងរឿងនេះ មានដូច្នេះ ។ បុរសអ្នកមានចក្ខុ ឈរលើកំពូលភ្នំថ្មសុទ្ធ គប្បីឃើញពួកជនដោយជុំវិញយ៉ាងណា បពិត្រព្រះមាន-

ព្រះភាគ ព្រះអង្គជាអ្នកមានបញ្ញាល្អ មានចក្ខុដោយជុំវិញដោយព្រះសព្វ-ញ្ញុតញ្ញាណក៏ដូច្នោះ ស្តេចឡើងកាន់ប្រាសាទ សម្រេចដោយធម៌ សម្រេចដោយបញ្ញា ជាអ្នកប្រាសចាកសេចក្តីសោកដោយព្រះអង្គឯង ទ្រង់ពិចារណាទ្រង់ត្រួតត្រាពួកជនអ្នកសញ្ជប់សញ្ជឹងទៅដោយសេចក្តីសោក ត្រូវជាតិជរាគ្របសង្កត់ហើយ ។

ក្នុងបទនេះមានអធិប្បាយដូច្នេះ ដូចជាមនុស្សទាំងឡាយ ធ្វើទីដីដ៏ធំជុំវិញជើងភ្នំ ហើយសាងខ្ទមក្នុងជួរផ្ទៃដីសមគួរដល់ការសាងក្នុងទីដីនោះ អុជភ្លើងក្នុងវេលាយប់ ម្យ៉ាងទៀត ទីដីនោះ គប្បីមានសភាពងងឹតប្រកបដោយអង្គ ៤ ខណៈនោះ កាលបុរសអ្នកមានចក្ខុ ឈរលើកំពូលភ្នំនោះ សម្លឹងមើលផ្ទៃដី ផ្ទៃដីមិនប្រាកដ ទីដីសាងខ្ទមមិនប្រាកដខ្ទមមិនប្រាកដ ពួកមនុស្សដែលដេកក្នុងខ្ទមនោះមិនប្រាកដ ប្រាកដត្រឹមតែពន្លឺភ្លើងក្នុងខ្ទមទាំងឡាយប៉ុណ្ណោះ យ៉ាងណា កាលព្រះតថាគតស្តេចឡើងកាន់ធម្មប្រាសាទ ទ្រង់ត្រួតមើលពួកសត្វ សត្វទាំងឡាយដែលមិនបានធ្វើសេចក្តីល្អ សូម្បីអង្គុយនៅក្បែរព្រះជានុខាងស្តាំ ក្នុងទីកន្លែងជាមួយគ្នា ក៏ដូច្នោះ ក៏មិនមកដល់គន្លងនៃពុទ្ធចក្ខុ ដូចកូនសរដែលបាញ់ទៅក្នុងវេលាយប់ តែសត្វទាំងឡាយដែលធ្វើសេចក្តីល្អ ជាវេនេយ្យបុគ្គលសូម្បីនេះ នៅឆ្ងាយពីព្រះតថាគតនោះ រមែងមកកាន់គន្លងបាន ។ សត្វទាំងនោះ រមែងដូចជាពន្លឺភ្លើង និងដូចភ្នំហិមពាន្ត ។ ដូចដែលទ្រង់ត្រាស់

ទុកថា ៖

ទូរេ សន្តោ បកាសេន្តិ  ហិមវន្តោវ  បព្វតោ
អសន្តេត្ថ ន ទិស្សន្តិ  រត្តឹ ខិត្តា យថា សរា ។

**ពួកសប្បុរសទាំងឡាយ រមែងប្រាកដក្នុងទីជិត ដូចភ្នំ ហិមពាន្ត ដូច្នោះ ពួកអសប្បុរសទាំងឡាយ រមែងមិន ប្រាកដក្នុងទីនេះ ដូចជាកូនសរ ដែលគេបាញ់ទៅក្នុង វេលាយប់** ដូច្នោះ ។

បទថា ឧដ្ឋេហិ សេចក្ដីថា ព្រហ្មក្រាបទូលអង្វរដល់ការស្ដេចចារិក ដើម្បីប្រោសសម្ដែងធម៌របស់ព្រះមានព្រះភាគ ។ គប្បីជ្រាបក្នុងបទថា **វីរ** ជាដើមថា ព្រះមានព្រះភាគ ព្រះនាមថា វីរៈ ព្រោះព្រះអង្គមានសេចក្ដី ព្យាយាម , ឈ្មោះថា ជាអ្នកឈ្នះសង្គ្រាម ព្រោះព្រះអង្គទ្រង់ឈ្នះ ទេវបុត្តមារ មច្ចុមារ និងកិលេសមារ , ឈ្មោះថា ជាអ្នកនាំពពួកជន ព្រោះព្រះអង្គទ្រង់ឆ្លងជាតិកន្តារជាដើមបាន គឺ ព្រោះព្រះអង្គអាចណែនាំ ហើយនាំពពួកជនទៅបាន , ឈ្មោះថា ជាអ្នកមិនមានបំណុល ព្រោះមិន មានបំណុល គឺ កាមច្ឆន្ទៈ ដូច្នេះ ។

[៤៦-៤៧] បទថា អបារុតា គឺ បើក ។ ពាក្យថា **ទ្វារអមតៈ** បាន ដល់ អរិយមគ្គ ។ ព្រះមានព្រះភាគទ្រង់សម្ដែងទុកថា ព្រោះតថាគតបានបើក ទ្វារនិព្វាន ពោលគឺ អមតៈ តាំងទុកហើយ ។ បទថា បមុញ្ចន្តុ សទ្ធំ

សេចក្តីថា អ្នកមានសោតទាំងពួង ចូរបញ្ចេញ គឺ បញ្ចេញសទ្ធារបស់ខ្លួនចុះ ។ ក្នុងពីរបទក្រោយ មានសេចក្តីថា តថាគតជាអ្នកស្គាល់ការដឹងលំបាកដោយកាយ និងវាចា ទើបមិនបានពោលធម៌ដ៏ប្រណីត គឺ ខ្ពស់បំផុតនេះ ដែលតថាគតធ្វើឲ្យស្ទាត់ជំនាញ គឺ ប្រព្រឹត្តទៅដោយល្អហើយ ក៏ឥឡូវនេះជនទាំងពួង ចូរបង្អោនភាជនៈ គឺ សទ្ធាចូលទៅចុះ តថាគតនឹងញុំាងសេចក្តីត្រិះរិះរបស់ជនទាំងនោះឲ្យបរិបូណ៌ ដូច្នេះ ។

## ពណ្ណនាពុទ្ធកិច្ច

[៤៨] បទថា ពោធិរុក្ខមូលេ សេចក្តីថា ព្រះមានព្រះភាគព្រះនាមថាវិបស្សី បានបាត់ព្រះអង្គត្រង់ដើមអជបាលនិគ្រោធមិនឆ្ងាយពោធិព្រឹក្ស ។ បទថា ខេមេ មិគទាយេ សេចក្តីថា ឥសិបតនមិគទាយវ័ន ដោយសម័យនោះជាសួន ឈ្មោះថា **ខេមៈ** ក៏សួននោះលោកឲ្យឈ្មោះថា មិគទាយវ័ន ព្រោះជាទីដែលលោកឲ្យអភ័យ ដើម្បីការរស់នៅដល់ម្រឹគទាំងឡាយ ។ លោកពោលថា ខេមេ មិគទាយេ សំដៅដល់សួននោះ ។

សូម្បីព្រះពុទ្ធព្រះអង្គដទៃៗ ក៏ដូចព្រះមានព្រះភាគព្រះនាមវិបស្សី ស្តេចទៅដើម្បីសម្តែងធម៌ជាគ្រាដំបូង ស្តេចបានទៅតាមអាកាស ហើយស្តេចចុះក្នុងទីនោះដូចគ្នា ។ តែព្រះមានព្រះភាគរបស់យើងទាំងឡាយ ទតឃើញឧបនិស្ស័យរបស់ឧបកាជីវក ទ្រង់ជ្រាបថា ឧបកៈដើរមកផ្លូវនេះ

ឃើញតថាគត និងសន្ទនាជាមួយតថាគតហើយទៅ តែកាលឧបកៈនឿយណាយ នឹងមករកតថាគតទៀត ហើយនឹងធ្វើឲ្យច្បាស់នូវព្រះអរហត្ត ដូច្នេះទើបស្តេចយាងដោយព្រះបាទទទេអស់ផ្លូវ ១៨ យោជន៍ ។

បទថា **ព្រះមានព្រះភាគ ត្រាស់ហៅអ្នករក្សាសួន** សេចក្តីថា ព្រះមានព្រះភាគ ទតព្រះនេត្រមើលអ្នកថែរក្សាសួនមិគទាយវ័ន ច្រើនជងរូបហើយត្រាស់ហៅឲ្យចូលទៅរក ត្រាស់បង្គាប់ឲ្យទៅប្រាប់ខណ្ឌរាជបុត្រ និងតិស្សបុត្របុរោហិតថា លោកដ៏ចម្រើន ព្រះតថាគតរបស់យើងទាំងឡាយ ស្តេចមកហើយ ។

បទថា អនុបុព្វកថំ សេចក្តីថា ព្រះមានព្រះភាគ ត្រាស់កថាតាមលំដាប់យ៉ាងនេះ គឺ ទានកថា សីលក្នុងលំដាប់ទាន សួគ៌ក្នុងលំដាប់សីល មគ្គក្នុងលំដាប់សួគ៌ ។ កថាបដិសំយុត្តដោយគុណរបស់ទាន មានជាអាទិយ៉ាងនេះថា ក្នុងបទទាំងនោះ បទថា ទានកថំ សេចក្តីថា ឈ្មោះថា ទាននេះ ជាហេតុនៃសេចក្តីសុខទាំងឡាយ ជាអណ្តូងកើតនៃសម្បត្តិទាំងឡាយ ជាទីតាំងនៃភោគៈទាំងឡាយ ជាចម្បាំង ជាទីអាស្រ័យ ជាគតិជាគ្រឿងគាំទ្ររបស់អ្នកដែលដល់សេចក្តីស្ងប់វិសេស ជាទីពឹង ជាទីតាំងជាអារម្មណ៍ ចម្បាំង ទីអាស្រ័យ គតិ ការគាំទ្រ ដូចនឹងទាន រមែងមិនមានក្នុងលោកនេះ និងក្នុងលោកខាងមុខ ។ ពិតហើយ ទាននេះ ឈ្មោះថាដូចសីហាសនៈសម្រេចដោយកែវ ព្រោះអត្ថថា ជាទីពឹង ឈ្មោះថា ដូចផែន

ដីធំ ព្រោះអត្ថថា ជាទីតាំង ឈ្មោះថា ដូចខ្សែរឹត ព្រោះអត្ថថា ជាគ្រឿងតោងស្អិត ឈ្មោះថា ដូចទូក ព្រោះអត្ថថា ឆ្លងទៅចាកទុក្ខ ឈ្មោះថា ដូចកាពខ្លាំងក្លាក្នុងសង្គ្រាម ព្រោះអត្ថថា ជាគ្រឿងលួងលោមចិត្ត ឈ្មោះថា ដូចនគរដែលតាក់តែងល្អហើយ ព្រោះអត្ថថា ការពារភ័យ ឈ្មោះថា ដូចបទុម ព្រោះអត្ថថា មិនជាប់ដោយមន្ទិល គឺ សេចក្ដីកំណាញ់ជាដើម ឈ្មោះថា ដូចភ្លើង ព្រោះអត្ថថា ដុតកិលេសទាំងនោះ ឈ្មោះថា ដូចអាសិរពិស ព្រោះអត្ថថា ចូលទៅជិតបានលំបាក ឈ្មោះថា ដូចសីហៈ ព្រោះអត្ថថា មិនតក់ស្លុត ឈ្មោះថា ដូចដំរី ព្រោះអត្ថថា មានកម្លាំង ឈ្មោះថា ដូចគោឈ្មោលពណ៌ស ព្រោះអត្ថថា ការឃើញ ជាមង្គលក្រៃលែង ឈ្មោះថា ដូចស្ដេចសេះវលាហកៈ ព្រោះអត្ថថា ឲ្យដល់ទីភូមិភាគដែលរួចផុតភ័យ ។ ពិតហើយ ទាន រមែងឲ្យសក្កសម្បត្តិក្នុងលោក រមែងឲ្យមារសម្បត្តិ ព្រហ្មសម្បត្តិ ចក្រពត្តិសម្បត្តិ សាវកបារមីញាណ បច្ចេក-ពោធិញ្ញាណ អភិសម្ពោធិញ្ញាណ ។ ក៏ព្រោះការឲ្យទាន ទើបអាចសមាទានសីលបាន ដូច្នោះ ព្រះអង្គទើបត្រាស់ សីលកថា ក្នុងលំដាប់ទាននោះ ។

បទថា **សីលកថំ** សេចក្ដីថា កថាបដិសំយុត្ត ដោយគុណរបស់សីល មានជាអាទិយ៉ាងនេះថា ឈ្មោះថា សីលនេះ ជាទីពឹង ជាទីតាំង ជាអារម្មណ៍ ជាគ្រឿងការពារ ជាទីអាស្រ័យ ជាគតិ ជាគ្រឿងគាំទ្រ ពិតហើយ ទីពឹង ទីតាំង អារម្មណ៍ គ្រឿងការពារ ជាទីអាស្រ័យ គតិ

គ្រឿងតាំទ្រ ដូចនឹងសីល រមែងមិនមានដល់សម្បត្តិក្នុងលោកនេះ និង លោកមុខ គ្រឿងប្រដាប់ដូចសីល រមែងមិនមាន , ផ្កាឈើ ដូចនឹងផ្កាឈើ គឺ សីល រមែងមិនមាន , ក្លិន ដូចនឹងក្លិនសីល រមែងមិនមាន ពិតហើយ លោក ព្រមទាំងទេវលោក សម្លឹងមើលការប្រដាប់ដោយគ្រឿងប្រដាប់ គឺ សីល ការតាក់តែងដោយផ្កាឈើ គឺ សីល ការលាបស្រឡាបដោយក្លិន គឺ សីល រមែងមិនដល់សេចក្តីឆ្អែត ។ ដើម្បីសម្តែងថា អ្នកបានសួគ៌ ព្រោះ អាស្រ័យសីលនេះ ។ ព្រះអង្គ ទើបត្រាស់សគ្គកថា ក្នុងលំដាប់សីល ។

បទថា សគ្គកថំ សេចក្តីថា កថាបដិសំយុត្ត ដោយសួគ៌ មានជា អាទិយ៉ាងនេះថា ឈ្មោះថា សួគ៌នេះ គួរប្រាថ្នា គួររីករាយ គួរពេញចិត្ត កីឡាដែលជាទិព្វសម្បត្តិ រមែងបានក្នុងសួគ៌នេះជានិច្ច ពួកទេវតាជាន់ ចាតុម្មហារាជិកា រមែងបានទិព្វសុខ និងទិព្វសម្បត្តិ រហូតដល់អស់ ៩ លានឆ្នាំ , ពួកទេវតាជាន់តាវត្តិង្ស រមែងបានទិព្វសុខ និងទិព្វសម្បត្តិ រហូតដល់អស់ ៣ កោដិឆ្នាំ និង ៦ លានឆ្នាំ ។ ពិតហើយ កាលព្រះពុទ្ធ ទាំងឡាយត្រាស់ដល់សម្បត្តិសួគ៌មិនទាន់សមល្មម ។ ដូចព្រះអង្គត្រាស់ ទុកថា ម្នាលភិក្ខុទាំងឡាយ តថាគតគប្បីពោលនូវសគ្គកថា ដោយបរិយាយ មិនតិច ដូច្នេះជាដើម ។ ព្រះមានព្រះភាគទ្រង់លួងលោម ដោយត្រាស់ដល់ សួគ៌យ៉ាងនេះហើយ ដើម្បីទ្រង់សម្តែងថា សូម្បីសួគ៌នេះក៏មិនទៀង មិន ឋិតថេរ មិនគួរធ្វើសេចក្តីប្រាថ្នាដោយសេចក្តីពេញចិត្តក្នុងសួគ៌នេះ ដូច

ប្រដាប់ដំរីហើយ កាត់ប្រមោយដំរីនោះ ទើបត្រាស់ដល់ទោស សេចក្តីអាក្រក់ សេចក្តីសៅហ្មងរបស់កាមទាំងឡាយ ដោយន័យជាដើមថា ៖

**កាមទាំងឡាយ មានសេចក្តីរីករាយតិច មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះ មានច្រើនពេកណាស់** ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា អាទីនវោ គឺ ទោស ។ បទថា ឱការោ គឺ ភាពអាក្រក់ លាមក ។ បទថា សង្កិលេសោ សេចក្តីថា ភាពសៅហ្មងក្នុងសង្សាររបស់សត្វទាំងឡាយ កើតមានព្រោះកាមទាំងឡាយនោះ ។ ដែលលោកពោលថា **អ្នកដ៏ចម្រើនទាំងឡាយ សត្វទាំងឡាយនឹងសៅហ្មង** ដូច្នេះ ។ ព្រះមានព្រះភាគ ទ្រង់បង្ហាញទោសរបស់កាមយ៉ាងនេះហើយ ទ្រង់ប្រកាសអានិសង្សក្នុងនេក្ខម្មៈ អធិប្បាយថា ទ្រង់ប្រកាសគុណរបស់បព្វជ្ជា ។ បទដ៏សេស មានន័យដូចពោលហើយ ក្នុងអដ្ឋកថាអម្ពដ្ឋសូត្រ និងមានសេចក្តីងាយ ។

បទថា អលត្តំ គឺ បានហើយយ៉ាងណា ។ បានហើយដោយភាពជាឯហិភិក្ខុ ។ បានឮថា ព្រះមានព្រះភាគទ្រង់ពិចារណាមើលការសន្សំបាត្រ និងចីវរសម្រេចដោយឫទ្ធិ ទ្រង់ឃើញការថ្វាយចីវរជាដើម ក្នុងជាតិមិនតិចរបស់ពួកជនទាំងនោះ ទើបត្រាស់ពាក្យមានជាអាទិថា ម្នាលភិក្ខុទាំងឡាយ ចូរមកចុះ ដូច្នេះ ។ ពួកជនទាំងនោះមានសិរសៈត្រងោល

ស្បៀកដណ្តប់សំពត់កាសាយៈ មានភិក្ខុបរិក្ខារ ៨ ពាក់ក្នុងរាងកាយ អង្គុយថ្វាយបង្គំនមស្ការព្រះមានព្រះភាគ ដូចព្រះថេរៈមានវស្សា ២០ ។

ក្នុងបទថា សន្ទស្សេសិ ជាដើម សេចក្តីថា ព្រះមានព្រះភាគទ្រង់សម្តែងដល់ប្រយោជន៍ក្នុងលោកនេះ និងប្រយោជន៍ក្នុងលោកខាងមុខ ។ កាលទ្រង់សម្តែងដល់ប្រយោជន៍ក្នុងលោកនេះ ទ្រង់សម្តែងថា អនិច្ចំ ទុក្ខំ អនត្តា ដូច្នេះ ទ្រង់សម្តែងខន្ធទាំងឡាយ ធាតុទាំងឡាយ អាយតនៈទាំងឡាយ បដិច្ចសមុប្បាទ កាលទ្រង់សម្តែងការកើតឡើងនៃរូបក្ខន្ធ ទ្រង់សម្តែងដល់លក្ខណៈ ៥ កាលទ្រង់សម្តែងសេចក្តីសាបសូន្យនៃវេទនាខន្ធជាដើម ក៏យ៉ាងនោះ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបទ្រង់សម្តែងលក្ខណៈ ៥០ ដោយអំណាចការកើតឡើង និងការសាបសូន្យ ។ កាលទ្រង់សម្តែងដល់ប្រយោជន៍លោកខាងមុខ ទ្រង់សម្តែងដល់កំណើតនរក តិរច្ឆានប្រេតវិស័យ អសុរកាយ ទ្រង់សម្តែងវិបាកនៃកុសល ៣ យ៉ាង សម្បត្តិនៃទេវលោក ៦ ជាន់ ព្រហ្មលោក ៩ ជាន់ ។

បទថា សមាទបេសិ សេចក្តីថា ឲ្យកាន់យកកល្យាណធម៌ មានបារិសុទ្ធិសីល ៤ ធុតង្គ កថាវត្ថុ ១០ ជាដើម ។

បទថា សមុត្តេជេសិ គឺ ឲ្យអាចហានដោយល្អ ឲ្យឧស្សាហ៍ក្រៃលែងឡើងៗ ។ ព្រះមានព្រះភាគទ្រង់ញ៉ាំងសេចក្តីក្លៀវក្លាឲ្យក្លៀវក្លាប្រយោជន៍ក្នុងលោកនេះ និងប្រយោជន៍ក្នុងលោកខាងមុខ ត្រាស់ធ្វើដូច

សម្រេចហើយ ។ ក៏កាលព្រះពុទ្ធមានព្រះភាគទ្រង់ធ្វើឲ្យសត្វភ័យតក់ស្លុត ភ័យខ្លាចហើយ ត្រាស់ដល់ប្រយោជន៍ក្នុងលោកនេះ ដែលមានប្រភេទ ដូចកម្មការណ៍ ៣២ និងមហាភ័យ ២៥ រមែងធ្វើឲ្យកើតសេចក្តីភ័យតក់ស្លុត ដូចត្រូវចងដៃក្រពាត់ទៅក្រោយយ៉ាងណែន ហើយវាយ ១០០ ដង បណ្តើរតាមផ្លូវបែកជា ៤ នាំចេញទៅតាមទ្វារខាងត្បូង ដូចដាក់សីសៈត្រង់កំណាល់សម្រាប់ប្រហារ ដូចជាន់លើលំពែង និងដូចត្រូវដំរីចុះប្រេងជាន់ ។ និងកាលទ្រង់ពោលដល់ប្រយោជន៍ក្នុងលោកខាងមុខ រមែងដូចជាកើតក្នុងនរកជាដើម និងដូចសោយសម្បត្តិក្នុងទេវលោក ។

បទថា សម្បហំសេតិ គឺ ឲ្យរីករាយដោយគុណដែលខ្លួនបានហើយ ។ អធិប្បាយថា ទ្រង់ពោលធ្វើឲ្យមានអានិសង្សច្រើន ។

បទថា សង្ខារានំ អាទីនវំ សេចក្តីថា ត្រាស់ដល់ទោសរបស់កាមទាំងឡាយ ដើម្បីសម្រេចបឋមមគ្គ ។ តែក្នុងបទនេះ ដើម្បីសម្រេចមគ្គថ្នាក់ខ្ពស់ ព្រះអង្គទើបទ្រង់ប្រកាសទោសរបស់សង្ខារទាំងឡាយ និងសភាពនៃសង្ខារទាំងឡាយលាមក និងសេចក្តីលំបាក ដែលមានសង្ខារជាបច្ច័យ ដោយន័យជាដើមថា ៖

ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយមិនទៀង មិនយឺនយូរ មិនត្រចះត្រចង់ ម្នាលភិក្ខុទាំងឡាយ ក៏យ៉ាងនេះ ត្រឹមតែល្មម ដើម្បីសេចក្តីនឿយណាយក្នុងសង្ខារ

ទាំងឡាយ ត្រឹមតែល្មមដើម្បីប្រាសចាកតម្រេក ត្រឹមតែល្មមដើម្បីការរួចផុត ដូច្នេះ ។

ទ្រង់ប្រកាសអានិសង្សក្នុងនិព្វានដោយន័យជាដើមថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថា និព្វាននេះ មាននៅក្នុងនេក្ខម្មៈដូចគ្នា ជាវត្ថុប្រណីត ជាគ្រឿងការពារ ជាទីអាស្រ័យ ដូច្នេះ ។

## ពណ៌នា បព្វជ្ជា ឧបសម្បទារបស់ពួកមហាជន

[៤៩-៥០] បទថា មហាជនកាយោ សេចក្ដីថា ពួកមហាជនអ្នកជាឧបដ្ឋាករបស់កុមារទាំងពីរនោះឯង ។ បទថា ខ្ញុំទាំងឡាយសូមដល់ព្រះមានព្រះភាគ និងព្រះធម៌ជាទីពឹងដូច្នេះ សេចក្ដីថា ពួកជនទាំងនោះបានពោលវាចាពីរដង (គឺពោលដល់ព្រះពុទ្ធមួយដង ព្រះធម៌មួយដង) ជាសរណៈ ព្រោះមិនទាន់គ្រប់ព្រះសង្ឃ ។ បទថា អលត្ថុំ គឺ បានហើយដោយភាពជាឯហិភិក្ខុ ដោយន័យដែលពោលហើយក្នុងពេលមុន ។ សូម្បីក្នុងគ្រាដែលបួសហើយ ក្នុងលំដាប់អំពីនេះក៏មានន័យនេះឯង ។

## ពុទ្ធានុញ្ញាត ការចារិករបស់ភិក្ខុ

[៥១-៥២] បទថា បរិវិតក្កោ ឧទបាទិ សេចក្ដីថា សេចក្ដីបរិវិតក្កៈកើតឡើងកាលណា ។ កើតឡើងកាលកន្លង ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ អំពីការ

ត្រាស់ដឹង ។

បានឮថា ព្រះមានព្រះភាគ ទ្រង់ធ្វើការសង្គ្រោះព្រះជនកហើយ ។ សូម្បីព្រះរាជាក៏ទ្រង់ត្រិះរិះថា ឱរសច្បងរបស់យើងចេញបួសជាព្រះពុទ្ធហើយ ឱរសទីពីររបស់យើងចេញបួសជាអគ្គសាវកទីមួយ បុត្របុរោហិតជាសាវកទីពីរ មួយទៀត ភិក្ខុទាំងឡាយដ៏សេសទាំងនេះ សូម្បីក្នុងវេលាជាគ្រហស្ថ ក៏បានហែហមឱរសរបស់យើងត្រាច់ទៅ ភិក្ខុទាំងនេះ កាលមុនជាភារៈរបស់យើង សូម្បីឥឡូវនេះក៏នៅជាភារៈរបស់យើងនុ៎ះឯង យើងនឹងទំនុកបម្រុងភិក្ខុទាំងនោះដោយបច្ច័យ ៤ យើងនឹងមិនឲ្យឱកាសដល់អ្នកដទៃដូច្នេះ ។ ព្រះរាជាបង្គាប់ឲ្យសាងកំពែងធ្វើដោយឈើដើមគគីទាំងពីរខាង តាំងពីស៊ុមទ្វារព្រះវិហារដរាបដល់ទ្វារក្រុងរាជគ្រឹះ គ្របដោយកន្ទេលផែង ប្រក់ដោយសំពត់ និងបិទបាំងក្នុងខាងលើ ទ្រង់ឲ្យធ្វើពិតានមានកម្រងផ្កាឈើច្រើនប្រភេទ ប្រមាណប៉ុនដើមត្នោតសំយុងចុះមក វិចិត្រដោយដួងមាស ខាងក្រោមទីផ្ទៃក្រាលដោយកម្រាលដែលស្អាតល្អ បង្គាប់ឲ្យចាត់ផ្កាឈើក្នុងលំដាប់ក្លិន និងក្លិនក្នុងលំដាប់ផ្កាដរាបពេញធ្នាំងទឹកក្នុងសួនផ្កាឈើ ក្នុងខាងទាំងពីរ ខាងក្នុង ដើម្បីឲ្យនៅក្នុងផ្លូវតែមួយទាំងអស់ ហើយបង្គាប់ឲ្យក្រាបទូលវេលាចំពោះព្រះមានព្រះភាគ ។ ព្រះមាន-ព្រះភាគហែហមដោយពួកភិក្ខុស្តេចទៅក្រុងរាជគ្រឹះ ខាងក្នុងវាំងនោះឯងសោយព្រះអាហារសម្រេចហើយ ស្តេចត្រឡប់ទៅព្រះវិហារ ។ អ្នកណាៗ

ដទៃ រមែងមិនបានសូម្បីត្រឹមតែឃើញ ក៏ការថ្វាយភិក្ខាក្តី ការធ្វើការបូជាក្តី ការស្តាប់ធម៌ក្តី នឹងមានអំពីណាហ្ន៎ ។ អ្នកនគរគិតគ្នាថា ថ្ងៃនេះកាលព្រះសាស្តាទ្រង់ឧប្បត្តិឡើងក្នុងលោកហើយ សូម្បីពួកយើងមិនបានដើម្បីឃើញរហូតដល់អស់ ៧ ឆ្នាំ ៧ ខែ នឹងពោលទៅថ្វីដល់ការថ្វាយភិក្ខា ការធ្វើការបូជា ឬការស្តាប់ធម៌ ព្រះរាជាទ្រង់ស្រឡាញ់ហួងហែងថា ព្រះពុទ្ធរបស់យើងតែម្នាក់ ព្រះធម៌របស់យើងតែម្នាក់ ព្រះសង្ឃរបស់យើងតែម្នាក់ ហើយទ្រង់ទំនុកបម្រុងត្រឹមតែមួយអង្គឯង ក៏ព្រះសាស្តាកាលទ្រង់ឧប្បត្តិបានឧប្បត្តិដើម្បីប្រយោជន៍ ដើម្បីអនុគ្រោះដល់លោកព្រមទាំងទេវលោកពិតហើយ នរករបស់ព្រះរាជាមិនគប្បីក្តៅ របស់ពួកអ្នកដទៃនឹងប្រាកដដូចគុម្ពឈូកស ព្រោះដូច្នោះ ពួកយើងនឹងក្រាបទូលព្រះរាជា ប្រសិនបើព្រះរាជាទ្រង់មិនឲ្យព្រះសាស្តាដល់ពួកយើង ប្រសិនបើទ្រង់មិនឲ្យពួកយើងសូម្បីត្រូវច្បាំងជាមួយព្រះរាជា ក៏នឹងនាំសង្ឃទៅ ហើយធ្វើបុណ្យមានទានជាដើម តែអ្នកនគរជាអ្នកបរិសុទ្ធិគង់មិនអាចធ្វើយ៉ាងនោះ ពួកយើងនឹងកាន់យកបុរសដ៏ចម្រើនម្នាក់ដូច្នេះ អ្នកនគរទាំងនោះ គេទៅរកសេនាបតីប្រាប់សេចក្តីនោះដល់សេនាបតី ហើយពោលថា លោកជាបក្ខពួករបស់យើងមិនមែនឬ ឬជាបក្ខពួករបស់ព្រះរាជា ។ សេនាបតីនោះពោលថា យើងជាបក្ខពួករបស់ពួកលោក ក៏ប៉ុន្តែថា ថ្ងៃដំបូងគួរឲ្យយើងមុន ថ្ងៃជាខាងក្រោយ ទើបដល់វារៈរបស់ពួកលោក ។ ពួកអ្នកនគរទាំងនោះទទួល

ពាក្យនោះ ។ សេនាបតីនោះ ចូលទៅគាល់ព្រះរាជាទូលថា បពិត្រព្រះអង្គ អ្នកនគរគេនាំគ្នាក្រោធនឹងព្រះអង្គ ក្រាបទូល ។ ព្រះរាជាត្រាស់សួរថា ក្រោធរឿងអ្វីហ្ន៎ ។ ក្រាបទូលថា រឿងថា ព្រះអង្គប៉ុណ្ណោះទ្រង់ទំនុកបម្រុង ព្រះសាស្តា ពួកទូលបង្គំមិនបានឡើយ បើថា អ្នកនគរបានក្នុងឥឡូវនេះខ្លះ ពួកគេក៏នឹងមិនក្រោធ កាលមិនបាន ពួកគេនឹងច្បាំងជាមួយព្រះអង្គក្រាបទូល ។ ត្រាស់ថា នេះនែបា ! យើងនឹងច្បាំង យើងនឹងមិនឲ្យពួកសង្ឃ ។ ទូលថា បពិត្រព្រះអង្គ អ្នកនគរជាទាសៈរបស់ទូលបង្គំ ពួកទូលបង្គំនឹងច្បាំងជាមួយព្រះអង្គ ។ ត្រាស់ថា ពួកបាឯងនឹងចាប់អ្នកណាច្បាំង ។ បាឯងជាសេនាបតីមិនមែនឬ ។ ក្រាបទូលថា បពិត្រព្រះអង្គ ទូលបង្គំវៀរអ្នកនគរចេញហើយ មិនអាចនឹងច្បាំងបាន ក្រាបទូល ។ តអំពីនោះ ព្រះរាជាទ្រង់ជ្រាបថា អ្នកនគរមានកម្លាំងច្រើន សូម្បីសេនាបតីក៏ជាបក្ខពួកអ្នកនគរដែរ ហើយត្រាស់ថា ពួកអ្នកនគរចូរឲ្យពួកភិក្ខុដល់យើង រហូតដល់អស់ ៧ ឆ្នាំ ៧ ខែតទៅ ពួកអ្នកនគរមិនព្រមទទួល ព្រះរាជាទ្រង់បន្ថយមក ៦ ឆ្នាំ ៥ ឆ្នាំ ៣ ឆ្នាំ ២ ឆ្នាំ ១ ឆ្នាំ ។ សូម្បីឲ្យថយយ៉ាងនេះ អ្នកនគរក៏មិនព្រមទទួល ។ ព្រះរាជាទ្រង់សូម ៧ ថ្ងៃ ។ ពួកអ្នកនគរគិតគ្នាថា ឥឡូវនេះ ពួកយើងមិនគួរធ្វើសេចក្តីខ្លាំងក្លានឹងព្រះរាជា ទើបអនុញ្ញាត ។ ព្រះរាជាទ្រង់ត្រៀមអាហារទាន ដែលព្រះអង្គត្រៀមទុកហើយដល់ ៧ ឆ្នាំ ៧ ខែ នៅសល់ត្រឹមតែ ៧ ថ្ងៃប៉ុណ្ណោះ , ទ្រង់ឲ្យទានរហូត

អស់ ៦ ថ្ងៃ តែមនុស្សពួកខ្លះមិនទាន់ឃើញទាននោះ ក្នុងថ្ងៃទី ៧ ត្រាស់ហៅអ្នកនគរមក ត្រាស់ថា ពួកលោកនឹងអាចឲ្យទានបែបនេះបានឬ ។ សូម្បីពួកអ្នកនគរក៏នាំគ្នាក្រាបទូលថា ទាននោះអាស្រ័យពួកខ្ញុំព្រះអង្គទាំងឯងទើបកើតឡើងចំពោះព្រះអង្គមិនមែនឬ , ក្រាបទូលថា ពួកខ្ញុំព្រះអង្គនឹងអាច ព្រះអង្គ ។ ព្រះរាជាទ្រង់ជូតព្រះអស្សុជលដោយខ្នងព្រះហស្ត ថ្វាយបង្គំព្រះមានព្រះភាគ ហើយទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គគិតហើយថា ខ្ញុំព្រះអង្គនឹងមិនធ្វើភិក្ខុ ៦ លាន ៨ សែនរូប ឲ្យជាការៈរបស់អ្នកដទៃ នឹងទំនុកបម្រុងដោយបច្ច័យ ៤ រហូតដល់អស់ជីវិត ឥឡូវនេះ ខ្ញុំព្រះអង្គ អនុញ្ញាតដល់អ្នកនគរហើយ ព្រោះអ្នកនគរនាំគ្នាក្រោធថា ពួកយើងមិនបានដើម្បីថ្វាយទាន តាំងពីថ្ងៃស្អែកនេះ លោកម្ចាស់ទាំងឡាយចូរធ្វើអនុគ្រោះដល់អ្នកនគរទាំងនោះចុះ ។ លុះដល់ថ្ងៃទីពីរ សេនាបតីត្រៀមមហាទានហើយពោលថា ថ្ងៃនេះពួកលោកចូររក្សា មិនឲ្យអ្នកដទៃណាថ្វាយសូម្បីតែភិក្ខាបានឡើយ បានតាំងបុរសទុកដោយជុំវិញ ។ ក្នុងថ្ងៃនោះ ភរិយាសេដ្ឋីស្រែកយំនិយាយចំពោះកូនក្រមុំថា កូនអើយ បើបិតារបស់កូននៅមានជីវិត ថ្ងៃនេះ ម៉ែគង់នឹងញាំងព្រះទសពលឲ្យសោយមុន ។ កូនក្រមុំនិយាយចំពោះម៉ែថា អ្នកម៉ែ កុំគិតអ្វីឡើយ កូននឹងធ្វើឲ្យពួកភិក្ខុមានព្រះពុទ្ធជាប្រធាន សោយភិក្ខារបស់ពួកយើងមុន ។ តពីនោះ ក្នុងថាសមាសមានតម្លៃប្រមាណមួយសែន ពេញទៅដោយបាយបាយាសមិន

មានទឹក នាងបានផ្សំទឹកដោះថ្លា ទឹកឃ្មុំ ជុំស្ករត្នោតជាដើម យកថាសស្ពឹកដទៃគ្របថាសមាស រុំព័ទ្ធថាសនោះដោយខ្សែក្លួនផ្កាម្ទិះ ធ្វើស្រដៀងខ្សែក្រងផ្កាឈើ ក្នុងវេលាព្រះមានព្រះភាគស្តេចចូលកាន់ស្រុក នាងលើកឡើងឯង ហែហមដោយពួកបរិវារចេញចាកផ្ទះ ។ ក្នុងចន្លោះផ្លូវ ពួកអ្នកបម្រើរបស់សេនាបតីពោលថា ម្នាលនាង នាងចូរកុំមកផ្លូវនេះ ។ ធម្មតាស្ត្រីអ្នកមានបុណ្យច្រើន រមែងមានពាក្យនិយាយគួរពេញចិត្ត ។ កាលអ្នកបម្រើរបស់សេនាបតីទាំងនោះ និយាយរឿយៗ ក៏មិនអាចហាមពាក្យសំដីរបស់នាងបាន ។ នាងពោលថា លោកពូ លោកអ៊ំ លោកមា ចុះព្រោះហេតុអ្វី ពួកលោកទើបមិនឲ្យខ្ញុំទៅហ្ន៎ ។ អ្នកបម្រើទាំងនោះពោលថា សេនាបតីតាំងយើងទុកថា ពួកអ្នកចូរកុំឲ្យអ្នកណាៗ ដទៃថ្វាយរបស់ទំពារ របស់បរិភោគបាន ។ នាងពោលថា ក៏ពួកលោកឃើញរបស់ទំពារ របស់បរិភោគក្នុងដៃរបស់ខ្ញុំឬ ។ អ្នកបម្រើឆ្លើយថា ពួកយើងឃើញកម្រងផ្កាឈើ ។ នាងសួរថា សេនាបតីរបស់ពួកលោកមិនឲ្យធ្វើសូម្បីការបូជាដោយកម្រងផ្កាឈើឬ ។ អ្នកបម្រើឆ្លើយថា ឲ្យថ្វាយបាននាង ។ នាងពោលថា បើដូច្នោះពួកលោកចូរចៀសទៅចុះ ហើយចូលទៅគាល់ព្រះមានព្រះភាគក្រាបទូលថា បពិត្រព្រះមានព្រះភាគ សូមព្រះអង្គទ្រង់ទទួលកម្រងផ្កាឈើនេះចុះ ព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ក្រឡេកមើលអ្នកបម្រើរបស់សេនាបតីម្នាក់ ឲ្យទទួលកម្រងផ្កាឈើ ។ នាងថ្វាយបង្គំព្រះ-

មានព្រះភាគហើយ តាំងសេចក្តីប្រាថ្នាថា កាលខ្ញុំម្ចាស់ត្រូវកើតក្នុងភពតូចភពធំ សូមកុំមានជីវិតក័យតក់ស្លុតឡើយ សូមឲ្យខ្ញុំចូរជាទីស្រឡាញ់ជាទីពេញចិត្ត និងសូមឲ្យឈ្មោះថា សុមនាក្នុងទីដែលកើត ដូចកម្រងផ្កាម្លិះចុះ ហើយព្រះសាស្តាត្រាស់ថា សូមនាងចូរមានសេចក្តីសុខចុះ ហើយនាងថ្វាយបង្គំធ្វើប្រទក្សិណចៀសចេញទៅ ។ ព្រះមានព្រះភាគស្តេចទៅផ្ទះសេនាបតី ប្រថាប់ក្នុងអាសនៈដែលគេក្រាលទុក សេនាបតីកាន់បាយយាគូចូលទៅថ្វាយ ។ ព្រះសាស្តាទ្រង់បិទបាត្រ ។ សេនាបតីក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកភិក្ខុអង្គុយហើយព្រះអង្គ ។ ព្រះសាស្តាត្រាស់ថា ពួកតថាគតមានបិណ្ឌបាតមួយ ដែលបានក្នុងចន្លោះផ្លូវ ។ សេនាបតីនាំកម្រងផ្កាឈើចេញ បានឃើញបិណ្ឌបាតហើយ ពោលថា មាតុគ្រាមពោលនឹងខ្ញុំថា "នាយ ផ្កាឈើ" បានបញ្ឆោតបន្ទំហើយ ។ បាយបាយាស ល្មមគ្រប់គ្រាន់ដល់ភិក្ខុទាំងអស់ តាំងពីព្រះមានព្រះភាគជាដើម ។ សូម្បីសេនាបតីក៏បានថ្វាយទេយ្យធម៌របស់ខ្លួន ។ ព្រះសាស្តាសោយភត្តាហារស្រេចហើយ ត្រាស់មង្គលស្តេចត្រឡប់ ។ សេនាបតីសួរថា ស្ត្រីថ្វាយបិណ្ឌបាតនោះឈ្មោះអ្វី ។ ជាកូនក្រមុំសេដ្ឋី លោក ។ សេនាបតីគិតថា ស្ត្រីនោះមានបញ្ញា កាលស្ត្រីបែបនេះនៅក្នុងផ្ទះឈ្មោះថា សម្បត្តិ គឺ សួគ៌របស់បុរសនឹងរកបានមិនលំបាក ទើបនាំស្រីនោះមកតាំងទុកក្នុងតំណែងជាបងស្រី ។

ថ្ងៃស្អែក អ្នកនគរនាំគ្នាថ្វាយទាន បានប្រារព្ធដើម្បីថ្វាយដោយធ្លាស់គ្នាយ៉ាងនេះថា សូម្បីព្រះរាជាក៏នឹងទ្រង់ថ្វាយក្នុងថ្ងៃស្អែក ។ ព្រះរាជាទ្រង់តាំងចារបុរសទុកហើយ ទ្រង់ថ្វាយឲ្យក្រៃលែងជាងទានដែលអ្នកនគរថ្វាយ ។ សូម្បីអ្នកនគរក៏ធ្វើយ៉ាងនោះដូចគ្នា ថ្វាយក្រៃលែងជាងទានដែលព្រះរាជាទ្រង់ថ្វាយ ។

ស្រីរបាំទាំងឡាយក្នុងក្រុងរាជគ្រឹះ ពោលនឹងសាមណេរកម្លោះថា លោកម្ចាស់សាមណេរទាំងឡាយ និមន្តទទួលទានដែលមិនបានធ្វើដោយដៃ ដែលជូតដោយសំពត់ជូតខ្លួនគហបតីទាំងឡាយ ហើយលាងជម្រះទឹកមាត់ និងសម្បោរជាដើមរបស់កុមារតូចៗ ធ្វើឲ្យជាទានស្អាតប្រណីត ។ ថ្ងៃស្អែក សូម្បីងអ្នកនគរទាំងឡាយ ក៏ពោលនឹងសាមណេរកម្លោះទាំងឡាយថា លោកម្ចាស់សាមណេរទាំងឡាយ និមន្តទទួលទាន ដែលមិនធ្វើដោយបាយ ទឹកដោះស្រស់ ទឹកដោះជូរ និងទឹកដោះថ្លា ដែលបានមកពីក្នុងក្រុង ក្នុងស្រុក និងនិគមជាដើម មិនបានធ្វើដោយការទម្លាយសិរសៈ និងខ្នងរបស់អ្នកដទៃ ហើយនាំមកថ្វាយ ធ្វើដោយទឹកដោះថ្លា និងទឹកដោះស្រស់សុទ្ធជាដើមតែម្តង ។ គ្រាកាលកន្លងទៅ ៧ ឆ្នាំ ៧ ខែ និង ៧ ថ្ងៃ យ៉ាងនេះហើយ ពេលនោះសេចក្តីវិតក្កៈនេះបាន កើតឡើងដល់ព្រះមានព្រះភាគ ។ ដែលលោកពោលទុកថា កន្លងទៅ ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ អំពីថ្ងៃត្រាស់ដឹង វិតក្កៈបានកើតឡើងហើយ ដូច្នេះ ។

បទថា អញ្ញតរោ មហាព្រហ្មា សេចក្តីថា ព្រហ្មទូលអង្វរឲ្យទ្រង់សម្តែងធម៌ ។

[៥៣] បទថា ចតុរាសីតិអាវាសសហស្សានិ គឺ វិហារ ៨៤.០០០ ខ្នង ។ វិហារទាំងអស់នោះ ជាវិហារធំទទួលភិក្ខុ បានដល់ មួយលានពីរសែនរូប បានដូចគ្នានឹងមហាវិហារអភ័យគីរី ចេតិយបព្វត និងចិត្តលបព្វត ។

[៥៤] បទថា ខន្តិ បរមំ តបោ សេចក្តីថា ខន្តី គឺ សេចក្តីអត់ធន់ជាតបៈយ៉ាងក្រៃលែង ។ បទថា តីតិក្ខា ជាវេវចនៈរបស់ខន្តីនោះឯង ។ អធិប្បាយថា អធិវាសនក្ខន្តិ ពោលគឺ សេចក្តីអត់ធន់ជាតបៈ យ៉ាងក្រៃលែង ។ បទថា និព្វានំ បរមំ សេចក្តីថា ព្រះពុទ្ធទាំងឡាយត្រាស់ថា និព្វានជាធម៌យ៉ាងក្រៃលែងដោយអាការទាំងពួង ។ បទថា ន ហិ បព្វជិតោ បរូបឃាតី សេចក្តីថា អ្នកណាចូលទៅប្រទូសរ៉ាយ រុកកួន និងបៀតបៀនអ្នកដទៃ ព្រោះវៀរចាកអធិវាសខន្តី អ្នកនោះមិនឈ្មោះថា ជាបព្វជិត ។ ក៏បាទទី ៤ ជាវេវចនៈរបស់បទនោះឯង ។ បទថា ន សមណោ ហោតិ ជាវេវចនៈរបស់បទនេះថា ន ហិ បព្វជិតោ ។ បទថា បរំ វិហេឋយន្តោ ជាវេវចនៈរបស់បទនេះថា បរូបឃាតី ។ មយ៉ាងទៀត បទថា បរូបឃាតី គឺ ទម្លាយសីល ។ ព្រោះសីល ទ្រង់ត្រាស់ថា បរំ ដោយអត្ថថា ខ្ពស់បំផុត អធិប្បាយថា ក៏អ្នកណាជាសមណៈ បៀតបៀន សត្វដទៃណាមួយ ឈ្មោះថា

ចូលទៅប្រទូសរ៉ាយអ្នកដទៃ គឺ ធ្វើសីលរបស់ខ្លួនឲ្យវិនាស អ្នកនោះមិនឈ្មោះថា ជាបព្វជិត ។ មួយវ៉ាងទៀត អ្នកណាចូលទៅប្រទូសរ៉ាយអ្នកដទៃ ព្រោះមិនមានអធិវាសខន្តិ សម្លាប់សត្វដទៃ ដោយទីបំផុតសូម្បីរបោម និងមូស អ្នកនោះមិនឈ្មោះថា ជាបព្វជិត ។ ព្រោះហេតុអ្វី ។ ព្រោះនៅវៀរមន្ទិលមិនបាន ។ ដូចដែលលោកពោលថា ព្រោះវៀរចាកមន្ទិលរបស់ខ្លួនបាន ព្រោះដូច្នោះ លោកទើបពោលថា បព្វជិតដូច្នេះ នេះគឺ លក្ខណៈរបស់បព្វជិត ។

សូម្បីអ្នកណាមិនប្រទូសរ៉ាយ មិនសម្លាប់ តែបៀតបៀនដោយអាជ្ញាជាដើម អ្នកនោះនៅបៀតបៀនអ្នកដទៃ មិនឈ្មោះថា ជាសមណៈ ។ ព្រោះហេតុអ្វី ។ ព្រោះមិនស្ងប់អំពីការបៀតបៀន ។ ដូចដែលទ្រង់ថា អ្នកដែលហៅថា សមណៈ ព្រោះស្ងប់បាប ដូច្នេះ នេះគឺ លក្ខណៈរបស់សមណៈ ។

គប្បីជ្រាបក្នុងគាថាទីពីរ ។ បទថា សព្វបាបស្ស បានដល់ អកុសលគ្រប់ប្រភេទ ។ បទថា អករណំ គឺ មិនឲ្យកើតឡើង ។ បទថា កុសល បានដល់ កុសលដែលមានក្នុងភូមិ ៤ ។ បទថា ឧបសម្បទា គឺ បានចំពោះ ។ បទថា សចិត្តបរិយោទបនំ គឺ ញ៉ាំងចិត្តរបស់ខ្លួនឲ្យភ្លឺ ។ ក៏បទនោះ រមែងបានប្រាកដដោយភាពជាព្រះអរហន្ត ដោយប្រការដូច្នេះ ។ បព្វជិតគួរលះបង់បាបទាំងពួងដោយសីលសំវរៈ ញ៉ាំងកុសលឲ្យដល់ព្រម

ដោយសមថៈ និងវិបស្សនាទាំងឡាយ ញុំាងចិត្តឲ្យផូរផង់ដោយអរហត្តផល នេះជាពាក្យទូន្មាន គឺ ជាឱវាទ គឺ ជាពាក្យជាស់តឿនរបស់ព្រះពុទ្ធទាំងឡាយ ។

គប្បីជ្រាបក្នុងគាថាទីបី បទថា អនុបវាទោ គឺ មិនចូលទៅពោលប្រទូស្តដល់អ្នកណាៗ ដោយវាចា ។ បទថា អនុបឃាតោ គឺ មិនប្រទូសរ៉ាយដោយកាយ ។ បទថា ចាតិមោក្ខេ ចែកស័ព្ទជា ប អតិ មោក្ខ ប្រែថា ការរួចផុតទូទៅក្រៃលែង គឺ សីលខ្ពស់បំផុត រមែងរក្សាដោយសេចក្តីវិសេស គឺ សុគតិ និងរមែងឲ្យផុតពីភ័យ គឺ ទុគ្គតិ ឬរមែងរក្សាសុគតិ រមែងឲ្យផុតទុគ្គតិ ព្រោះដូច្នោះ សីលនោះទ្រង់ត្រាស់ថា ចាតិមោក្ខំ អ្នកសង្រួមក្នុងបាតិមោក្ខនោះ ។

បទថា មត្តញ្ញុតា គឺ ដឹងប្រមាណដោយអំណាចការទទួល និងការបរិភោគ ។ បទថា បន្តញ្ច សយនាសនំ សេចក្តីថា វៀរការប្រៀតប្រៀតទីដេក និងទីអង្គុយ ។ ក្នុងបទនោះគប្បីជ្រាបថា គឺ លោកពោលដល់សេចក្តីសន្តោសក្នុងបច្ច័យ ៤ ដោយបច្ច័យ ២ ប៉ុណ្ណោះ ។ បទថា ឯតំ ពុទ្ធាន សាសនំ សេចក្តីថា ការមិនពោលតិះដៀល មិនចូលទៅបៀតបៀនអ្នកដទៃ ការសង្រួមក្នុងបាតិមោក្ខ ភាពជាអ្នកស្គាល់ប្រមាណក្នុងការទទួល និងការបរិភោគ ការសេពសេនាសនៈដ៏ស្ងាត់ ព្រោះជាអ្នកជំនាញក្នុងសមាបត្តិ ៨ នេះជាពាក្យទូន្មាន ជាឱវាទ ជាពាក្យជាស់តឿន

របស់ព្រះពុទ្ធទាំងឡាយ ។ ក៏គប្បីជ្រាបគាថាទាំងនេះ ជាគាថាសម្តែងបាតិមោក្ខុទ្ទេសរបស់ព្រះពុទ្ធទាំងឡាយ ។

[៥៥] ក៏ដោយហេតុមានប្រមាណប៉ុណ្ណេះ ដើម្បីទ្រង់ប្រកាសដល់កាលដែលព្រះអង្គទ្រង់ដឹងច្បាស់ចាក់ធ្លុះនូវធម្មធាតុ ដែលព្រះអង្គត្រាស់ទុកយ៉ាងនេះថា **ម្នាលភិក្ខុទាំងឡាយ តថាគតចាក់ធ្លុះធម្មធាតុនេះហើយ** ដូច្នេះ ទើបទ្រង់ប្រកាសការទូលអង្វររបស់ទេវតា ដែលលោកពោលទុកថា **ឥឡូវនេះ សូម្បីពួកទេវតាទាំងឡាយ ក៏បានប្រាប់សេចក្តីនុ៎ះដល់ព្រះតថាគត** ដូច្នេះ ទើបត្រាស់ពាក្យជាអាទិថា ឯកមិទាហំ ដូច្នេះ ដោយពោលពិស្តារតាមការប្រព្រឹត្តទៅនៃរឿងរ៉ាវ របស់ព្រះមានព្រះភាគព្រះនាមថា **វិបស្សី** នេះ ។

ក្នុងបទទាំងនោះបទថា សុភវនេ ក្នុងព្រៃឈ្មោះយ៉ាងនោះ ។ បទថា សាលរាជមូលេ បានដល់ គល់ឈើធំ ជាឈើជាម្ចាស់ព្រៃ ។ ពាក្យថា **ប្រាសចាកសេចក្តីពេញចិត្តក្នុងកាម** សេចក្តីថា កម្ចាត់ដោយអំណាចដកឫសចេញដោយអនាគាមិមគ្គ ក៏ពួកទេវតា អ្នកប្រព្រឹត្តធម៌ដ៏ប្រសើរនៅក្នុងព្រះសាសនា បាននាំគ្នាក្រាបទូលសូម្បីដល់ព្រះពុទ្ធដ៏សេសដូចក្រាបទូលចំពោះព្រះវិបស្សី ។ តែបាលីមកដោយអំណាចនៃព្រះវិបស្សី និងព្រះមានព្រះភាគរបស់យើងទាំងឡាយ ។

ក្នុងទេវតាទាំងនោះ ទេវតាឈ្មោះថា អាវិហា ព្រោះមិនលះ គឺ

មិនសាបសូន្យអំពីសម្បត្តិរបស់ខ្លួន ។ ទេវតាឈ្មោះ អតប្បា ព្រោះមិនដុតសត្វណាៗ ។ ឈ្មោះ សុទស្សា ព្រោះមើលល្អស្អាតគួរជ្រះថ្លា ។ ឈ្មោះ សុទស្សី ព្រោះគួរមើលរបស់អ្នកបានឃើញ ។ ឈ្មោះ អកនិដ្ឋា ព្រោះជាធំដោយគុណទាំងពួង និងដោយសម្បត្តិក្នុងភព មិនមែនតិចក្នុងភពនេះ ។ គួរប្រជុំកាណវារៈទាំងឡាយទុកក្នុងទីនេះ ។ ក៏ក្នុងសូត្រនេះ លោកពោល ៣ កាណវារៈ ដោយអំណាចរឿងរ៉ាវរបស់ព្រះមានព្រះភាគព្រះនាមថា **វិបស្សី** លោកពោលដោយរឿងរ៉ាវ សូម្បីរបស់ **ព្រះសិខី** ជាដើម , ក៏ដូចព្រះវិបស្សី ។ តែបាលីសង្ខេបពេក ។ ព្រះមានព្រះភាគរបស់យើងទាំងឡាយត្រាស់ ២១ កាណវារៈ ដោយអំណាចព្រះពុទ្ធ ៧ ព្រះអង្គ ដោយប្រការដូច្នេះ ទេវតាជាន់អវិហា អតប្បា សុទស្សា សុទស្សី អកនិដ្ឋា ក៏ពោលយ៉ាងនោះ ។ សូម្បីទាំងអស់ក៏មាន ២.៦០០ កាណវារៈ ។ ព្រះសូត្រដទៃក្នុងពុទ្ធវចនៈ ព្រះត្រៃបិដក មិនមានចំនួន ២.៦០០ កាណវារៈ ។ គប្បីជ្រាបថា ព្រះសូត្រនេះឈ្មោះថា សុតន្តរាជ-សូត្រ ។

**[៥៦]** ព្រះមានព្រះភាគកាលទ្រង់កំណត់អនុសន្ធិទាំងពីរ តពីនេះទើបត្រាស់ថា ឥតិ ខោ ភិក្ខវេ ដូច្នេះជាអាទិ ។ បទទាំងអស់នោះ មានសេចក្តីងាយនោះឯង ។

" ចប់អដ្ឋកថា មហាបទានសូត្រ ទី ១ "

# មហានិទានសូត្រ សូត្រទី ២

## សុត្តនិទាន

[៥៧] មហានិទានសូត្រមានបទចាប់ផ្តើមថា ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយព្រះមានព្រះភាគជាម្ចាស់ ទ្រង់ប្រថាប់នៅ ក្នុងកុរុជនបទ ដូច្នេះ ។

តទៅនេះ ជាការពណ៌នាបទដែលលំបាកក្នុងព្រះសូត្រនោះ បទថា កុរូសុ វិហរតិ សេចក្តីថា ព្រះរាជកុមារអ្នកជនបទ ឈ្មោះថា កុរុ ទីប្រថាប់របស់ព្រះរាជកុមារនោះជាជនបទមួយ លោកពោលថា កុរូសុ ដោយស័ព្ទដែលផ្តើមឡើងមក ក្នុងជនបទឈ្មោះកុរូសុនោះ ក៏ព្រះអដ្ឋកថាចារ្យទាំងឡាយពោលទុកថា ក្នុងរជ្ជកាលព្រះបាទមន្ធាតុ ពួកមនុស្សក្នុង ៣ ទ្វីប បានឮមកថា ជម្ពូទ្វីបជាទីកើតរបស់បុរសអ្នកខ្ពស់បំផុត រាប់ពីព្រះពុទ្ធ ព្រះបច្ចេកពុទ្ធ ព្រះមហាសាវក និងស្តេចចក្រពត្តិ ជាទ្វីបឧត្តមគួររីករាយក្រៃលែងណាស់ ទើបនាំគ្នាមកជាមួយស្តេចចក្រពត្តិមន្ធាតុរាជអ្នកបង្វិលចក្រកែវ ហើយប្រាថ្នាយាងទៅកាន់ទ្វីបទាំង ៤ លំដាប់នោះព្រះរាជាត្រាស់សួរបរិនាយកកែវថា នៅមានទីរីករាយជាងមនុស្សលោកឬទេហ្ន៎ បរិនាយកកែវក្រាបទូលថា បពិត្រព្រះអង្គ ព្រោះហេតុអ្វី ព្រះអង្គទើបត្រាស់យ៉ាងនោះ ព្រះអង្គទ្រង់ មិនឃើញអានុភាពរបស់ព្រះច័ន្ទ និង

ព្រះអាទិត្យ ឬឋានៈរបស់ព្រះចន្ទ និងព្រះអាទិត្យទាំងនោះ គួរកែកាយជាង នេះមិនមែនឬ ព្រះអង្គ ព្រះរាជាបានទ្រង់បង្វិលចក្រកែវទៅក្នុងទីនោះ ។

ស្ដេចមហារាជទាំង ៤ បានស្ដាប់ថា ព្រះបាទមន្ធាតុរាជស្ដេចមក ហើយ គិតថា ព្រះរាជាទ្រង់ឫទ្ធិច្រើន យើងមិនអាចនឹងហាមការច្បាំង បាន ទើបប្រគល់រាជសម្បត្តិរបស់ខ្លួនឲ្យព្រះបាទមន្ធាតុរាជ ទ្រង់ទទួល រាជសម្បត្តិនោះហើយ ត្រាស់សួរគេទៅថា នៅមានទីគួរកែកាយក្រៃលែង ជាងនេះទៀតទេ លំដាប់នោះ ស្ដេចមហារាជទាំងនោះ ក្រាបទូលនូវភព តាវត្តិង្សដល់ព្រះអង្គថា បពិត្រព្រះអង្គ ភពតាវត្តិង្សគួរកែកាយជាងនេះ មហារាជទាំង ៤ នេះ ជាអ្នកនៅបម្រើរបស់ស្ដេចសក្កទេវរាជក្នុងពិភព នោះ ឈរក្នុងផែនដីរបស់អ្នករក្សាទ្វារ ស្ដេចសក្កទេវរាជមានឫទ្ធិច្រើន មានអានុភាពច្រើន ស្ដេចសក្កទេវរាជនោះ មានស្ថានទីសម្រាប់បម្រើទាំង នោះ គឺ វេជយន្តប្រាសាទកម្ពស់ ១,០០០ យោជន៍ ទេវសភាឈ្មោះ សុធម្មាកម្ពស់ ៥០០ យោជន៍ វេជយន្តរថកម្ពស់ ១៥០ យោជន៍ ដំរី ឯរាវ័ណក៏ដូចគ្នា សួននន្ទវ័ន ចិត្តលតាវ័ន បារុសកវ័ន មិស្សកវ័ន ប្រដាប់ដោយដើមឈើទិព្វ ១,០០០ ដើម ដើមរលួសមាសជាបារិច្ឆត្តកព្រឹក្ស កម្ពស់ ១,០០០ យោជន៍ ខាងក្រោមដើមនោះ មានទីប្រថាប់បណ្ឌុ-កម្ពលសិលាសនៈ បណ្ដោយ ៦០ យោជន៍ ទទឹង ៥០ យោជន៍ កម្ពស់ ១៥ យោជន៍ មានពណ៌ដូចផ្កាជ័យព្រឹក្ស ព្រោះភាពទន់របស់បណ្ឌុកម្ពល-

សិលាសនៈនោះ កាលស្តេចសក្កៈប្រថាប់ ព្រះវរកាយពាក់កណ្តាលទ្រុឌ ចុះទៅ ព្រះរាជាទ្រង់ស្តាប់ដូច្នោះហើយ មានព្រះបំណងនឹងស្តេចទៅក្នុង សក្កទេវលោកនោះ ចក្រកែវបានហោះឡើងទៅហើយ ចក្រកែវនោះតាំង នៅលើអាកាសព្រមទាំងសេនាប្រកបដោយអង្គ ៤ តអំពីនោះ ចក្រកែវ ក៏បានចុះកណ្តាលទេវលោកទាំងពីរ ប្រតិស្ឋាននៅលើផែនដី ព្រមនឹងសេនា ប្រកបដោយអង្គ ៤ មានបរិនាយកកែវជាប្រធាន ព្រះរាជាតែមួយព្រះអង្គ ប៉ុណ្ណោះ ស្តេចទៅកាន់តាវត្តិង្សពិភព ។

ស្តេចសក្កទេវរាជដឹងថា ព្រះបាទមន្ធាតុរាជ ស្តេចមកហើយ ក៏ ធ្វើការទទួលព្រះបាទមន្ធាតុរាជនោះ ត្រាស់ថា បពិត្រមហារាជ ព្រះអង្គ ស្តេចមកល្អហើយបពិត្រមហារាជ សម្បត្តិនេះជារបស់ព្រះអង្គ បពិត្រ មហារាជ សូមព្រះអង្គបូរទ្រង់គ្រប់គ្រងចុះ ហើយទ្រង់បែងចែករាជសម្បត្តិ ព្រមដោយនាងរបាំឲ្យជាពីរចំណែក បានប្រទានឲ្យមួយចំណែក កាលព្រះ រាជាមន្ធាតុរាជស្តេចប្រថាប់នៅលើភពតាវត្តិង្សប៉ុណ្ណោះ ភាពជាមនុស្ស ក៏បានបាត់ទៅ ភាពជាទេវតាបានប្រាកដក្លាម បានឮថា កាលព្រះរាជា ប្រថាប់ក្នុងបណ្ឌុកម្ពលសិលាសនៈនឹងស្តេចសក្កៈ ពួកទេវតាមិនបានសង្កេត ព្រះរាជានោះថា សេចក្តីផ្សេងគ្នា រមែងប្រាកដដោយត្រឹមតែប៉ប្រិចភ្នែក រមែងកាន់ប្រឡំក្នុងសេចក្តីផ្សេងគ្នារបស់ស្តេចសក្កៈ និងរបស់ព្រះរាជា នោះ ព្រះរាជាមន្ធាតុរាជ ទ្រង់សោយទិព្វសម្បត្តិក្នុងភពតាវត្តិង្សនោះ

ទ្រង់គ្រងរាជសម្បត្តិ ដ៏រាបស្តេចសក្កៈទ្រង់ឧប្បត្តិ និងចុតិដល់ ៣៦ អង្គ ទ្រង់មិនឆ្អែតដោយកាម គ្រាអស់បុណ្យអំពីកពតាវត្តិង្សហើយ ក៏ធ្លាក់ចុះក្នុងព្រះឧទ្យានរបស់ព្រះអង្គ ព្រះវរកាយត្រូវសម្ពស្សខ្យល់ និងកំដៅថ្ងៃ ស្តេចក៏បានសុគតទៅ ។

ក៏កាលចក្រកែវតាំងនៅលើផែនដី បរិនាយកកែវឲ្យគូរស្នាមព្រះបាទរបស់ព្រះបាទមន្ធាតុរាជដោយផែនមាស ហើយប្រកាសរាជសម្បត្តិថា នេះគឺ រាជសម្បត្តិរបស់ព្រះបាទមន្ធាតុរាជ សូម្បីពួកមនុស្សដែលមកអំពីទ្វីបទាំង ៣ នោះ ក៏មិនអាចនឹងត្រឡប់ទៅវិញបាន ទើបចូលទៅរកបរិនាយកកែវអង្វរថា បពិត្រលោកម្ចាស់ ពួកខ្ញុំមកដោយអានុភាពរបស់ព្រះរាជា ឥឡូវនេះមិនអាចត្រឡប់ទៅវិញបាន សូមលោកបានមេត្តាឲ្យទីលំនៅដល់ពួកខ្ញុំចុះ បរិនាយកកែវបានឲ្យជនបទមួយៗ ដល់មនុស្សទាំងនោះក្នុងប្រទេសនោះ ប្រទេសដែលពួកមនុស្សមកពីបុព្វវិទេហទ្វីបអាស្រ័យនៅ បានឈ្មោះថា **វិទេហរដ្ឋ** តាមអត្ថន័យពីដើមនោះឯង ប្រទេសដែលពួកមនុស្សមកពីអមរគោយានទ្វីបអាស្រ័យនៅ បានឈ្មោះថា **អបរន្តជនបទ** ប្រទេសដែលពួកមនុស្សមកពីឧត្តរកុរុទ្វីប បានឈ្មោះថា **កុរុរដ្ឋ** លោកពោលជាពហុវចនៈប្រាថ្នាយកស្រុក និងនិគមជាដើមច្រើន ព្រោះហេតុនោះ លោកទើបពោល កុរូសុ វិហរតិ ។

ក្នុងបទថា កម្មាសធម្មំ នេះ អាចារ្យពួកខ្លះ ពណ៌នាសេចក្តីដោយ

ផ្ទាស់ ធ ជា ទ ។ ឈ្មោះថា កម្មាសធម្ម ព្រោះកម្មាសៈ ត្រូវទូន្មានក្នុងហេតុនេះ ។ បទថា កម្មាសោ លោកពោលថា កម្មាសទាធ មនុស្សស៊ីមនុស្ស ។ បានឮមកថា ដំបៅកើតឡើងត្រង់ជើងរបស់កម្មាសបាទនោះ ក្នុងទីដែលប៉ះដង្គត់ទាបៗ បានពងឡើង ដូចគ្នានឹងដើមចេតមូលភ្លើង ព្រោះដូច្នោះ កម្មាសៈ បានប្រាកដឈ្មោះថា កម្មាសទាធ ។ ក៏កម្មាសបាទ ត្រូវទូន្មានក្នុងឱកាសនោះ ទើបបានឈប់ពីការស៊ីមនុស្ស ។ អ្នកណាទូន្មាន ។ ព្រះមហាសត្វ ។ ពោលទុកក្នុងជាតកណា ។ អាចារ្យពួកខ្លះពោលថា ក្នុងមហាសុត្តសោមជាតក ។ តែព្រះថេរៈទាំងនេះពោលថា ក្នុងជយ-ទិសជាតក ។ ក៏គ្រានោះ កម្មាសបាទត្រូវបានព្រះមហាសត្វទូន្មាន ដូចដែលព្រះពោធិសត្វពោលទុកថា ៖

**យើងជាឱរសរបស់ព្រះបាទជយទិសៈ អ្នកជាធំក្នុងដែន**
**បញ្ចាល យើងបានលះបង់ជីវិតឲ្យកម្មាសបាទលែងព្រះជនក**
**និងយើងបានឲ្យស្ទូម្បីកម្មាសបាទជ្រះថ្លាហើយ ដូច្នេះ ។**

តែអាចារ្យពួកខ្លះពណ៌នាដោយ ធ អក្សរប៉ុណ្ណោះ បានឮថា កុរុធម៌របស់អ្នកដែនកុរុ កើតភាពសៅហ្មងឡើងហើយក្នុងដែននោះ ព្រោះដូច្នោះ ទីនោះជាទីមានធម៌ពុះពពាលកើតឡើងហើយ លោកទើបហៅថា **កម្មាសធម្ម** កម្មាសធម្មៈនេះ ជាឈ្មោះរបស់និគមដែលអ្នកកុរុនៅអាស្រ័យក្នុងទីនោះ ព្រោះហេតុអ្វី លោកទើបមិនពោលដោយសត្តមីវិភត្តិ

ព្រោះមិនមែនឱកាសជាទីនៅ ន័យថា ឱកាសជាទីនៅក្នុងនិគមនោះរបស់ព្រះមានព្រះភាគ មិនមែនជាព្រះវិហារទេ តែឃ្លាតពីនិគមដែលមានព្រៃធំក្នុងភូមិភាគដែលគួររីករាយសម្បូរណ៍ដោយទឹកឯណាមួយ ព្រះមានព្រះភាគទ្រង់ប្រថាប់នៅទីនោះ ទ្រង់ធ្វើនិគមនោះឲ្យជាគោចរគ្រាម ព្រោះដូច្នោះគប្បីជ្រាបសេចក្ដីក្នុងបទនេះថា ព្រះមានព្រះភាគប្រថាប់នៅក្នុងកុរុជនបទមាននិគមរបស់អ្នកកុរុ ឈ្មោះថា កម្មាសធម្មៈ ទ្រង់ធ្វើនិគមនោះឲ្យជាគោចរគ្រាម ។

បទថា អាយស្មា នេះ ជាពាក្យពោលដោយសេចក្ដីស្រឡាញ់ ជាពាក្យពោលដោយសេចក្ដីគោរព ។ បទថា អានន្ទោ ជាឈ្មោះរបស់ព្រះថេរៈអង្គនោះ ។ បទថា ឯកមន្តំ សម្ដែងដល់ភេទជានបុំសកលិង្គ ដូចក្នុងបទមានជាដើមថា ព្រះច័ន្ទ និងព្រះអាទិត្យចរទៅមិនស្មើគ្នា ដូច្នេះ ព្រោះដូច្នោះ គប្បីជ្រាបសេចក្ដីក្នុងបទនេះ យ៉ាងនេះថា ព្រះអានន្ទអង្គុយហើយ ដោយអាការដែលព្រះអានន្ទអង្គុយ រមែងអង្គុយហើយក្នុងទីសមគួរមួយ ឬថា បទនេះជាទុតិយាវិភត្តិ ចុះក្នុងអត្ថនៃសត្តមីវិភត្តិ ។

បទថា និសីទិ គឺ ចូលទៅនៅហើយ ពិតហើយ បណ្ឌិតទាំងឡាយចូលទៅរកអ្នកដែលនៅក្នុងទីឋានដែលជាទីគោរព រមែងអង្គុយក្នុងទីមួយដ៏សមគួរ ព្រោះជាអ្នកឆ្លាតក្នុងការអង្គុយ ក៏ព្រោះព្រះអានន្ទនេះជាបណ្ឌិតមួយរូបក្នុងបណ្ដាបណ្ឌិតទាំងនោះ ព្រោះដូច្នោះ ទើបអង្គុយហើយក្នុងទី

មួយដ៏សមគួរ តើអង្គុយយ៉ាងណា ទើបឈ្មោះថា អង្គុយហើយក្នុងទីមួយដ៏សមគួរ ? អង្គុយវៀរទោសនៃការអង្គុយ ៦ យ៉ាង គឺ អង្គុយឆ្ងាយពេក ១ អង្គុយជិតពេក ១ អង្គុយលើខ្យល់ ១ អង្គុយទីខ្ពស់ ១ អង្គុយត្រង់មុខពេក ១ អង្គុយខាងក្រោយពេក ១ ។ ព្រោះអង្គុយឆ្ងាយពេក បើចង់សួរក៏ត្រូវនិយាយដោយសំឡេងខ្លាំង , អង្គុយជិតពេក នឹងត្រូវធ្វើសេចក្តីប្រៀតបៀតគ្នា , អង្គុយក្នុងទីលើខ្យល់ រមែងរុកកួន (អ្នកដទៃ) ដោយក្លិនរបស់ខ្លួន , អង្គុយក្នុងទីខ្ពស់ រមែងសម្តែងការមិនគោរព , អង្គុយក្នុងទីត្រង់មុខពេក បើប្រាថ្នានឹងមើល នឹងត្រូវសម្លឹងមើលទល់ភ្នែកគ្នានឹងគ្នា , អង្គុយខាងក្រោយពេក បើប្រាថ្នានឹងមើល នឹងត្រូវអើតកចេញទៅមើល ព្រោះដូច្នោះ សូម្បីព្រះអានន្ទនេះ ក៏ធ្វើប្រទក្សិណព្រះដ៏មានព្រះភាគ ៣ ជុំ ហើយថ្វាយបង្គំគោរព វៀរទោសនៃការអង្គុយ ៦ យ៉ាង ចូលទៅខាងក្នុងនៃព្រះពុទ្ធរស្មី មាន ៦ យ៉ាង ក្នុងទីចំពោះមុខនៃមណ្ឌលព្រះជានុខាងស្តាំ ព្រះអានន្ទ ដែលជាភណ្ឌាគារិកនៃព្រះធម៌ បានអង្គុយហើយ ដូចចុះកាន់រសជ័រដែលថ្វាស្អាត ដូចដណ្តប់ផ្ទាំងមាស ដូចចូលទៅកាន់កណ្តាលពិតាននៃផ្កាឧប្បលពណ៌ក្រហម ព្រោះដូច្នោះ លោកទើបពោលថា ព្រះអានន្ទអង្គុយហើយក្នុងទីមួយដ៏សមគួរ ក៏ព្រះអានន្ទនេះ ចូលទៅគាល់ព្រះដ៏មានព្រះភាគក្នុងពេលណា ព្រោះហេតុអ្វី ? ក្នុងពេលល្ងាច ព្រោះហេតុ គឺ ការសួរបញ្ហារឿងបច្ចយាការដូច

ក្នុងថ្ងៃនោះ ព្រះអានន្ទត្រាច់ទៅកាន់ស្រុកកម្មាសធម្មៈដើម្បីបិណ្ឌបាត ដូច ចូលទៅកាន់ស្រុក ដែលមានគណ្ឌៈ ១.០០០ ក្នុងទ្វារផ្ទះ ដើម្បីសង្គ្រោះ ត្រកូល ត្រឡប់អំពីបិណ្ឌបាតហើយ មើលថែប្រណិបត្តិព្រះសាស្ដា កាល ព្រះសាស្ដាស្ដេចទៅកាន់ព្រះគន្ធកុដិ ថ្វាយបង្គំព្រះសាស្ដាហើយ ទៅកាន់ ទីសម្រាកពេលថ្ងៃរបស់ខ្លួន កាលកូនសិស្សទាំងឡាយមើលថែប្រណិបត្តិ ហើយត្រឡប់ទៅវិញ បានបោសសំអាតទីសម្រាកពេលថ្ងៃ ក្រាលកម្រាល ស្បែក ដួសទឹកអំពីពាង លាងដៃ និងជើងឲ្យត្រជាក់ អង្គុយចម្រើន សមាធិ ចូលសមាបត្តិថ្នាក់សោតាបត្តិផល កាលចេញពីសមាបត្តិតាម ដែលកំណត់ហើយ ក៏ចុះកាន់ញាណក្នុងបច្ចយាការ ។

ព្រះអានន្ទនោះ ដល់បទទីបំផុតតាំងពីបទដើមថា ព្រោះអវិជ្ជាជា បច្ច័យ ទើបមានសង្ខារដូច្នេះ តាំងពីបទដើមរហូតដល់បទចុងបំផុត ផ្ដើម ពីបទកណ្ដាល រហូតដល់បទចុងបំផុតទាំងពីរ ផ្ដើមពីបទចុងបំផុតទាំងពីរ ដល់បទកណ្ដាល ការពិចារណាបច្ចយាការ ១២ បទ ៣ ដង កាលពិចារណា យ៉ាងនេះ បច្ចយាការ ក៏ជាក់ច្បាស់ក្រៃលែងណាស់ ប្រាកដដូចជាងាយសែន ងាយ តពីនោះព្រះអានន្ទ ត្រិះរិះថា បច្ចយាការនេះ ព្រះពុទ្ធទាំងឡាយ ទ្រង់ត្រាស់ថា ជ្រាលជ្រៅ និងប្រាកដជារបស់ជ្រាលជ្រៅ ក៏យើងជាសាវក តាំងនៅហើយក្នុងសេចក្ដីដឹង រឿងដែលងាយ និងប្រាកដជាក់ច្បាស់ជាសេចក្ដី ងាយនោះ ជាការងាយប្រាកដដល់យើងប៉ុណ្ណោះឬ ឬសូម្បីដល់អ្នកដទៃផង

លំដាប់នោះ ព្រះថេរៈមានសេចក្តីត្រិះរិះថា បើយ៉ាងណា យើងនឹងនាំបញ្ហានេះ ទៅទូលសួរព្រះមានព្រះភាគ ព្រះមានព្រះភាគនឹងធ្វើរឿងនេះជាហេតុកើតឡើងហើយ នឹងត្រាស់ព្រះសុត្តន្តពួកមួយ នឹងទ្រង់សម្តែងដល់យើងពិតប្រាកដ ដូចទ្រង់លើកភ្នំសាលិនូសិនេរុឡើងដូច្នោះ ពិតហើយព្រះញាណដែលព្រះពុទ្ធ ទាំងឡាយទ្រង់ដល់ឋានៈ ៤ យ៉ាងទាំងនេះ គឺការបញ្ញត្តិព្រះវិន័យ លំដាប់ឫសគល់បច្ចយាការ លំដាប់សម័យជាញាណដែលគឹកកង កោលាហលធំក្រៃលែង ព្រះមានព្រះភាគទ្រង់ចូលដល់ព្រះញាណ រមែងប្រាកដភាពជាពុទ្ធញ្ញាណដែលធំក្រៃលែង ទេសនាជាសេចក្តីជ្រាលជ្រៅ កម្ចាត់ដោយព្រះត្រៃលក្ខណ៍ បដិសំយុត្តដោយភាពជារបស់សូន្យ ដូច្នេះ ព្រះអានន្ទនោះ តាមប្រក្រតី ក្នុងមួយថ្ងៃចូលទៅគាល់ព្រះមានព្រះភាគ ១០០ ដង ខ្លះ ១,០០០ ដងខ្លះ ក៏ពិត រមែងមិនចូលទៅគាល់ដោយមិនមានហេតុការណ៍ តែថ្ងៃនោះ ព្រះអានន្ទនាំបញ្ហានេះទៅ ហើយគិតថា យើងនឹងអង្គុយជិតព្រះពុទ្ធ ដូចគន្ធហត្ថី ហើយស្តាប់ព្រះសូរ-សៀងគឹកកងដោយព្រះញាណ នឹងអង្គុយជិតព្រះពុទ្ធ ដូចសីហៈ ស្តាប់ការបន្លឺព្រះសូរសៀងដូចសីហៈដោយព្រះញាណ នឹងអង្គុយជិតព្រះពុទ្ធ ដូចសិន្ធព ហើយនឹងឃើញការឈានទៅកាន់ផ្លូវនៃព្រះញាណ ដូច្នេះ ហើយក្រោកចាកទីសម្រាកពេលថ្ងៃបត់កម្រាលស្បែក កាន់ទៅគាល់ព្រះមានព្រះភាគក្នុងវេលាល្ងាច ព្រោះហេតុនោះ លោកទើបពោលថា ព្រះអានន្ទចូល

ទៅគាល់ដោយហេតុ គឺ ការសួរបញ្ហា ជាប់ទាក់ទងនឹងបច្ចយាការ ក្នុងវេលាល្ងាច ដូច្នេះ ។

យាវ ស័ព្ទក្នុងបទថា យាវគម្ភីរោ នេះ ប្រព្រឹត្តទៅក្នុងសេចក្តីថា លើសប្រមាណ អធិប្បាយថា កន្លងប្រមាណ ជ្រាលជ្រៅក្រៃលែង ។ បទថា គម្ភីរាវភាសោ សេចក្តីថា ប្រាកដ គឺ ឃើញជារបស់ជ្រៅ ព្រោះថា ធម៌មួយងាយដោយពិត តែជារបស់ជ្រាលជ្រៅ ដូចទឹកល្អក់ មានពណ៌ខ្មៅដោយអំណាចរសរបស់ស្លឹកឈើស្អុយ ក៏ទឹកនោះសូម្បីត្រឹមជង្គង់ ក៏ប្រាកដដូចជាមានជម្រៅ ១០០ ជួរបុរស បទមួយជ្រាលជ្រៅ ប្រាកដជារបស់ងាយដូចទឹកថ្លាក្នុងមណិគង្គា ដោយថា ទឹកនោះសូម្បី ១០០ ជួរបុរស ក៏ប្រាកដដូចនៅត្រឹមជង្គង់ បទមួយងាយប្រាកដជារបស់ងាយ ដូចទឹកក្នុងភាជនៈ មានពាងជាដើម បទមួយងាយប្រាកដជារបស់ជ្រាលជ្រៅ រមែងឃើញដូចទឹកក្នុងមហាសមុទ្រទាជើងភ្នំសិនេរុ ទឹកទុំះឯង រមែងបានឈ្មោះ ៤ យ៉ាង យ៉ាងនេះ តែសេចក្តីនេះ មិនមានក្នុងបដិច្ចសមុប្បាទ ព្រោះបដិច្ចសមុប្បាទនេះ រមែងបានឈ្មោះតែម្យ៉ាងប៉ុណ្ណោះថា ជ្រាលជ្រៅ និងប្រាកដជារបស់ជ្រាលជ្រៅ ដូច្នេះ បដិច្ចសមុប្បាទសូម្បីមានសភាពបែបនេះ ក៏ប៉ុន្តែថា ប្រាកដដល់យើងដូចងាយសែនងាយ ព្រះអានន្ទកាលនឹងប្រកាសសេចក្តីចម្លែកចិត្តរបស់ខ្លួនយ៉ាងនេះថា បពិត្រព្រះអង្គចម្រើន គួរអស្ចារ្យណាស់ បពិត្រព្រះអង្គដ៏ចម្រើន មិនធ្លាប់មានទេ ដូច្នេះ ទើបទូល

សួរបញ្ហា ហើយអន្ទុយស្មៀម ។

ព្រះមានព្រះភាគ ទ្រង់ស្តាប់ពាក្យរបស់ព្រះអានន្ទនោះហើយ ទ្រង់ត្រិះរិះថា អានន្ទពោលបញ្ហាដែលជាពុទ្ធវិស័យថា ជារបស់ងាយសម្រាប់ខ្លួន ដូចលូកដៃដើម្បីចាប់កវគ្គព្រហ្ម ដូចព្យាយាមដើម្បីទម្លាយភ្នំសិនេរុ ហើយនាំរំអិលចេញ ដូចប្រាថ្នានឹងឆ្លងមហាសមុទ្រដោយមិនមានទូក និងដូចព្យាយាមត្រឡប់ផែនដី កាន់យកឱជៈរបស់ផែនដីដូច្នេះ ហើយត្រាស់ថា មា ហេវំ ជាអាទិ ហ អក្សរ ក្នុងបទថា មា ហេវំ នោះ ត្រឹមតែជានិបាត អធិប្បាយថា អ្នកកុំពោលយ៉ាងនោះ មួយទៀត ព្រះមានព្រះភាគកាលនឹងញុំាងព្រះអានន្ទឲ្យលះបង់ខ្វះ ឲ្យអស់សេចក្តីត្រេកអរខ្វះ ទើបត្រាស់ថា មា ហេវំ ដូច្នេះ ក្នុងបទនោះ ព្រះមានព្រះភាគសូម្បីកាលនឹងញុំាងព្រះអានន្ទឲ្យលះបង់ ទើបត្រាស់ថា ម្នាលអានន្ទ អ្នកជាអ្នកមានបញ្ញាច្រើន មានសេចក្តីឆ្លាត ព្រោះហេតុនោះ បដិច្ចសមុប្បាទជ្រាលជ្រៅ និងប្រាកដជារបស់ជ្រាលជ្រៅ អ្នកមិនគួរយល់ថា បដិច្ចសមុប្បាទសូម្បីជ្រាលជ្រៅក៏ប្រាកដជារបស់ងាយដល់អ្នក ទាំងជារបស់ងាយដល់អ្នកដទៃផង ដូច្នេះ ។

ក្នុងរឿងនោះអាចារ្យទាំងឡាយ រមែងពោលដល់ឧបមា ៤ ប្រការ ជនទាំងឡាយ សម្លឹងមើលថ្មរបស់អ្នកប្រដាល់ ក្នុងចន្លោះអ្នកប្រដាល់ធំ អ្នកជំខ្ពស់ អ្នកសម្លូស្សនឹងរសអាហារដែលល្អរហូតដល់ ៦ ខែ ធ្វើការបញ្ចេញកម្លាំងលើកថ្មរបស់អ្នកប្រដាល់ ដែលសម្តែងក្នុងពេលមានមហោ-

ស្រព អ្នកទៅកាន់យុទ្ធភូមិ ត្រូវអ្នកប្រដាល់ពោលថា នេះអ្វី ថ្មរបស់អ្នកប្រដាល់ ពួកលោកចូរនាំថ្មនោះមក កាលជនទាំងឡាយនិយាយថា ពួកយើងលើកមិនរួចទេ គេក៏ទៅដោយខ្លួនឯង ពោលថា ទម្ងន់របស់ថ្មនេះមានត្រង់ណា ហើយលើកថ្ម ២ ដុំឡើង ដោយដៃទាំង ២ ហើយគ្រវែងទៅដូចលេងកូនប៉ូល ហើយក៏ទៅ ក្នុងរឿងនោះគួរនិយាយបានថា ថ្មរបស់អ្នកប្រដាល់ ជារបស់ស្រាលដល់អ្នកប្រដាល់ មិនស្រាលដល់ពួកអ្នកដទៃពិតហើយ ព្រះអានន្ទដល់ព្រមហើយដោយអភិនិហារ រហូតដល់អស់សែនកប្ប ដូចអ្នកប្រដាល់ដែលសម្លស្សន៍ទឹងរសអាហារដ៏ល្អរហូតដល់អស់ ៦ ខែ ថ្មរបស់អ្នកប្រដាល់ជារបស់ស្រាល ព្រោះអ្នកប្រដាល់ជាអ្នកមានកម្លាំងច្រើន យ៉ាងណា បដិច្ចសមុប្បាទជារបស់ងាយ ព្រោះព្រះថេរៈជាអ្នកមានបញ្ញាច្រើន ដូច្នោះ មិនគួរពោលថា បដិច្ចសមុប្បាទ ងាយដល់ពួកអ្នកដទៃផងទេ ។

មួយទៀត ក្នុងមហាសមុទ្រ ត្រីឈ្មោះតិមិ ទំហំ ២០០ យោជន៍ ឈ្មោះតិមិង្គលៈ ទំហំ ៣០០ យោជន៍ ឈ្មោះតិមិតិមិង្គលៈ ទំហំ ៤០០ យោជន៍ ឈ្មោះតិមិរមិង្គលៈ ទំហំ ៥០០ យោជន៍ ។ ត្រី ៤ ប្រភេទនេះគឺ ត្រីអានន្ទៈ ត្រីតិមិន្ទៈ ត្រីអជ្ឈរោហៈ ត្រីមហាតិមិ ទំហំ ១,០០០ យោជន៍ ក្នុងបទនោះ អាចារ្យទាំងឡាយសម្តែងដល់ត្រីឈ្មោះ តិមិរមិង្គលៈ តែម្យ៉ាង ដំណាលមកថា កាលត្រីតិមិរមិង្គលៈនោះ កម្រើកព្រុយស្តាំ

ទឹករលករញ្ជួយទៅដល់ ៥០០ យោជន៍ កម្រើកព្រុយឆ្វេង កន្ទុយ ក្បាល ក៏ដូចគ្នា តែបើត្រីឈ្មោះតិមិរមិង្គលៈនោះ កម្រើកត្រចៀកទាំងពីរ ខាង យកកន្ទុយបក់ទឹក គ្រវីក្បាលទៅមក ប្រាថ្នាដើម្បីនឹងលេងទឹកក្នុងទី ៧-៨ រយយោជន៍ រមែងក្តៅ ពុះ ដូចទឹកដែលដាក់ក្នុងភាជនៈ ដែលលើក ឡើងពីចង្ក្រាន ដូច្នោះ ទឹកក្នុងទីប្រមាណ ៣០០ យោជន៍ មិនអាចនឹង លិចផុតខ្នងបាន គេគប្បីពោលយ៉ាងនេះថា ជនទាំងឡាយនាំគ្នានិយាយថា មហាសមុទ្រនេះ ជ្រៅ មានជ្រៅឯណា ពួកយើងមិនបានទឹក សូម្បីត្រឹម តែលិចខ្នងផងហ្នឹង ព្រោះមហាសមុទ្រនោះជ្រៅណាស់ ក្នុងសេចក្តីនោះ គួរពោលថា សម្រាប់ត្រីឈ្មោះតិមិរមិង្គលៈលិចទៅទាំងខ្លួន មហាសមុទ្រ រាក់ , សម្រាប់ពួកត្រីតូចៗដទៃ មហាសមុទ្រមិនរាក់ , គួរពោលថា សម្រាប់ព្រះថេរៈអ្នកចូលដល់ញាណបដិច្ចសមុប្បាទជារបស់រាក់ សម្រាប់ ពួកអ្នកដទៃមិនរាក់ យ៉ាងនោះដូចគ្នា ។

មួយទៀត ស្តេចគ្រុឌ ធំប្រមាណ ១៥០ យោជន៍ ស្លាបស្តាំរបស់ ស្តេចគ្រុឌប្រមាណ ៥០ យោជន៍ ស្លាបឆ្វេងក៏ដូចគ្នា ផ្ទៃកកន្ទុយប្រមាណ ៦០ យោជន៍ កប្រមាណ ៣០ យោជន៍ មាត់ ៩ យោជន៍ ជើងទាំងពីរ ប្រមាណ ១២ យោជន៍ កាលស្តេចគ្រុឌនោះសម្តែងខ្យល់របស់ស្តេចគ្រុឌ ទី ៧-៨ រយយោជន៍ មិនល្មមគ្រប់គ្រាន់ គេគប្បីពោលយ៉ាងនេះថា គេ ទាំងឡាយនិយាយគ្នាថា អាកាសនេះមិនមានទីបំផុត អាកាសនេះមិនមាន

ទីបំផុតមកពីណា ពួកយើងមិនបាន សូម្បីឱកាសដែលនឹងទទះស្នាប ព្រោះអាកាសនោះមិនមានទីបំផុត ក្នុងសេចក្តីនោះគប្បីពោលថា អាកាសរបស់ស្តេចគ្រុឌគួរប្រៀបទៅដល់ទាំងខ្លួនតូចបង្អៀត , របស់ពួកសត្វតូចៗ ដទៃមិនតូចបង្អៀត , គប្បីពោលថា បដិច្ចសមុប្បាទរបស់ព្រះថេរៈអ្នកចូលដល់ញាណទុំះឯងរាក់ សូម្បីរបស់អ្នកដទៃមិនរាក់យ៉ាងនោះដូចគ្នា ។

មួយទៀត អសុរិន្ទរាហូ តាំងពីចុងសក់ដល់បាទជើង មានកម្ពស់ ៤,៨០០ យោជន៍ ចន្លោះដៃទាំងពីរខាងរបស់អសុរិន្ទរាហូ ប្រវែង ១,២០០ យោជន៍ ទំហំខ្លួន ៦០០ យោជន៍ ផ្ទៃបាតដៃបាតជើង ២០០ យោជន៍ ប្រមុះ ៣០០ យោជន៍ មាត់ក៏ដូចគ្នា ថ្នាំងម្រាមដៃមួយថ្នាំងៗ ៥០ យោជន៍ ចន្លោះចញ្ចើមក៏ដូចគ្នា ថ្ងាស់ ៣០០ យោជន៍ សិរសៈ ៩០០ យោជន៍ កាលអសុរិន្ទរាហូនោះ ដាក់ជើងចុះទៅក្នុងមហាសមុទ្រ ទឹកមានប្រមាណត្រឹមក្បាលជង្គង់ គេគប្បីពោលយ៉ាងនេះថា ជនទាំងឡាយនាំគ្នាពោលថា មហាសមុទ្រនេះជ្រៅ មានជ្រៅឯណា ពួកយើងមិនបានទឹក សូម្បីត្រឹមតែលិចជង្គង់ ព្រោះមហាសមុទ្រនោះជ្រៅ សម្រាប់រាហូដែលចុះ ទៅទាំងខ្លួន , ក្នុងមហាសមុទ្រនោះរាក់ សម្រាប់ពួកអ្នកដទៃមិនរាក់ , គប្បីពោលថា បដិច្ចសមុប្បាទរបស់ព្រះថេរៈដែលចូលដល់ញាណ ជារបស់រាក់ ឯអ្នកដទៃមិនរាក់ ដូច្នេះ ព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ អ្នកកុំពោលដូច្នោះ ម្នាលអានន្ទ អ្នកកុំពោលយ៉ាងនោះ ដូច្នេះ ទ្រង់សំដៅដល់សេចក្តី

នោះ ។

ពិតហើយ បដិច្ចសមុប្បាទ សូម្បីជ្រៅ ដែលប្រាកដជា ជារបស់ងាយដល់ព្រះថេរៈដោយហេតុ ៤ ប្រការ ហេតុ ៤ ប្រការដូចម្តេច ? ដោយការដល់ព្រមដោយឧបនិស្ស័យក្នុងជាតិមុន , ដោយការនៅក្នុងសម្នាក់គ្រូ , ដោយភាពជាព្រះសោតាបន្ន , ដោយភាពជាពហុស្សូត ។ បានឮថា រាប់ត្រឡប់ពីកប្បនេះទៅ ១ សែនកប្ប ព្រះសាស្តាព្រះនាមថា បទុមុត្តរៈ ទ្រង់ឧប្បត្តិឡើងក្នុងលោក មាននគររបស់ព្រះអង្គឈ្មោះ ហង្សវតី ព្រះរាជបិតាព្រះនាមថា អានន្ទៈ ព្រះរាជមាតាព្រះនាមថា សុមេធាទេវី ព្រះពោធិសត្វមានព្រះនាមថា ឧត្តរកុមារ ព្រះពោធិសត្វនោះ ក្នុងថ្ងៃដែលព្រះឱរសប្រសូតិ ស្តេចចេញមហាភិនេស្រ្កម៍ ទ្រង់ព្រះផ្នួស ទ្រង់ប្រកបសេចក្តីព្យាយាម សម្រេចព្រះសព្វញ្ញុតញ្ញាណដោយលំដាប់ ទ្រង់បន្លឺឧទានថា អនេកជាតិសំសារំ ដូច្នេះជាដើម ញុំាងសប្តាហ៍មួយឲ្យកន្លងទៅក្នុងពោធិបល្ល័ង្ក ហើយទ្រង់ត្រិះរិះថា យើងនឹងជាន់លើផែនដី ដូច្នេះ ហើយទ្រង់ដាក់ព្រះបាទចុះ ភ្លាមនោះបទុមធំ ទម្លាយផែនដីផុសឡើងហើយ ត្របករបស់បទុមនោះ ៩០ ហត្ថ កេសរ ៣០ ហត្ថ ផ្លែឈូក ១២ ហត្ថ លំអងប្រមាណ ៩ ធ្នាំងទឹក ក៏ព្រះសាស្តាមានកម្ពស់ ៥៨ ហត្ថ ចន្លោះព្រះពាហាទាំងពីររបស់ព្រះអង្គ ១៨ ហត្ថ ព្រះនលាដ ៥ ហត្ថ ព្រះហស្ថនិងព្រះបាទ ទាំងពីរ ១១ ហត្ថ កាលព្រះសាស្តាទ្រង់ជាន់ដល់ ផ្លែឈូក

១២ ហត្ថ ដោយព្រះបាទ ១១ ហត្ថ លំអងផ្សាយចេញ ប្រមាណ ៩ ឆ្នាំងទឹក ហុយខ្វាយឡើងកាន់ទីនៅប្រមាណ ៥៨ ហត្ថ ផ្សាយឡើងដូចជាផងរបស់មនោសិលាដែលហុយសោត់ឡើង អាស្រ័យហេតុនោះ ព្រះមានព្រះភាគ ទើបទ្រង់ប្រាកដព្រះនាមថា **ព្រះបទុមុត្តរ** ។

ព្រះអង្គមានអគ្គសាវក ២ រូប គឺ **ព្រះទេវិលៈ** និង **ព្រះសុជាតៈ** អគ្គសាវិកា ២ រូប គឺ **នាងអមិតា** និង **នាងអសមា** ឧបដ្ឋាកឈ្មោះ **ព្រះសុមន** ។ ព្រះមានព្រះភាគព្រះនាមថា បទុមុត្តរៈ មានភិក្ខុមួយសែនអង្គជាបរិវារ ទ្រង់ធ្វើការសង្គ្រោះព្រះជនក ប្រថាប់នៅក្នុងរាជធានីហង្សវតី ។

ចំណែកព្រះកនិដ្ឋារបស់ព្រះបទុមុត្តរៈ ព្រះនាមថា សុមនកុមារ ព្រះរាជាបានព្រះរាជទានស្រុកសួយ ដល់ព្រះរាជកុមារ ក្នុងផ្ទៃដីប្រមាណ ២,០០០ យោជន៍ ឆ្ងាយពីហង្សវតីនគរ ព្រះសុមនកុមារនោះ ពេលខ្លះស្ដេចមកគាល់ព្រះជនក និងព្រះសាស្ដា តមកថ្ងៃមួយ ជាយដែនកម្រើក សុមនកុមារទ្រង់បញ្ជូនដំណឹងឲ្យព្រះរាជបិតាទ្រង់ជ្រាបថា ជាយដែនកម្រើក ព្រះរាជបិតាទ្រង់បញ្ជូនត្រឡប់ទៅថា យើងតាំងលោកទុកក្នុងទីនោះព្រោះអ្វី ព្រះរាជកុមារនោះស្ដេចចេញបង្ក្រាបចោរដេកបស្ងប់ ហើយទើបទ្រង់បញ្ជូនដំណឹងឲ្យព្រះរាជបិតាទ្រង់ជ្រាបថា ចោរស្ងប់ហើយព្រះអង្គ ព្រះរាជបិតាទ្រង់ពេញព្រះទ័យ ត្រាស់ថា ឱរសរបស់យើងចូរមកដោយរហ័សចុះ ព្រះឱរសនោះ មានអាមាត្យប្រមាណ ១,០០០ ក្នុងចន្លោះផ្លូវ ព្រះអង្គទ្រង់

បានប្រឹក្សានឹងអាមាត្រទាំងនោះថា ព្រះជនករបស់យើងទ្រង់ពេញព្រះទ័យ បើព្រះជនកនឹងព្រះរាជទានពរដល់យើង យើងនឹងយកអ្វីទើបល្អ លំដាប់នោះ អាមាត្រពួកខ្លះទូលថា សូមព្រះអង្គទូលសូម ដំរី សេះ ជនបទ កែវទាំង ៧ ចុះ មួយពួកទៀតទូលថា ព្រះអង្គជាឱរសរបស់ស្តេចផែនដី ទ្រព្យ របស់ព្រះអង្គបានមិនលំបាក មួយទៀត សូម្បីព្រះអង្គបានទ្រព្យហើយ ក៏គួរលះបង់ទ្រព្យទាំងអស់នោះទៅ ព្រះអង្គគួរទ្រង់កាន់យកបុណ្យប៉ុណ្ណោះ ព្រោះដូច្នោះ កាលព្រះរាជាព្រះរាជប្រទានពរ សូមព្រះអង្គចូរទូលសូម ពរដើម្បីទំនុកបម្រុងព្រះមានព្រះភាគ ព្រះនាមថា បទុមុត្តរៈ រហូតដល់ អស់ ៣ ខែ ចុះព្រះអង្គ ព្រះរាជកុមារនោះ ត្រាស់ថា ពួកលោកជា កល្យាណមិត្តរបស់យើង យើងមិនមានសេចក្តីគិតដូច្នេះឡើយ ពួកលោក ធ្វើឲ្យយើងកើតសេចក្តីគិត យើងនឹងធ្វើយ៉ាងនោះ ហើយស្តេចទៅក្រាប បង្គំព្រះជនក ព្រះជនកទ្រង់ក្រសោប ហើយថើបជញ្ចក់ត្រង់ព្រះសិរសា ត្រាស់ថា កូនសម្លាញ់ ឪពុកនឹងឲ្យពរដល់កូន ដូច្នេះ ទូលថា បពិត្រ ព្រះបិតា ក្រាបទូល បុត្រសូមនូវការទំនុកបម្រុងព្រះមានព្រះភាគដោយ បច្ច័យ ៤ រហូតអស់ ៣ ខែ ប្រាថ្នាធ្វើជីវិតមិនឲ្យជាដាច់សូន្យ សូម ព្រះបិតាព្រះរាជទានពរនេះ ដល់បុត្រចុះ ក្រាបទូល ព្រះរាជបិតាត្រាស់ ថា កូនសម្លាញ់ បិតាមិនអាចឲ្យពរនោះបានទេ បិតានឹងឲ្យពរដទៃ ព្រះ សុមនរាជកុមារទូលថា បពិត្រព្រះបិតា ធម្មតាក្សត្រិយ៍ទាំងឡាយ មិន

មានព្រះតម្រាស់ជាពីរ , សូមព្រះបិតាព្រះរាជទានពរនោះ ដល់បុត្រចុះ ក្រាបទូល បុត្រមិនត្រូវការពរដទៃទេ ព្រះរាជបិតាត្រាស់ថា កូនសម្លាញ់ ធម្មតាព្រះពុទ្ធទាំងឡាយមានព្រះទ័យដឹងបានលំបាក បើព្រះមានព្រះភាគ ទ្រង់នឹងមិនប្រាថ្នា សូម្បីយើងឲ្យពរ បានយ៉ាងណា ព្រះសុមនរាជកុមារ នោះទូលថា បពិត្រព្រះបិតា បុត្រនឹងជ្រាបព្រះទ័យរបស់ព្រះមានព្រះភាគ ដូច្នេះ ហើយស្តេចទៅកាន់ព្រះវិហារ ។

ក៏ដោយសម័យនោះ ព្រះមានព្រះភាគ កាលសោយព្រះក្រយាហារ ហើយ ស្តេចបានចូលគន្ធកុដិ ព្រះសុមនរាជកុមារនោះ បានទៅកាន់ សម្នាក់របស់ភិក្ខុទាំងឡាយ ដែលអង្គុយនៅក្នុងបារាំ ភិក្ខុទាំងនោះពោល នឹងព្រះសុមនរាជកុមារថា ព្រះរាជបុត្រព្រះអង្គស្តេចមកដើម្បីអ្វី ព្រះ សុមនរាជកុមារត្រាស់ថា ដើម្បីគាល់ព្រះមានព្រះភាគ សូមលោកម្ចាស់ ទាំងឡាយ ចូរបង្ហាញព្រះមានព្រះភាគដល់ខ្ញុំចុះ ភិក្ខុទាំងឡាយពោលថា ព្រះរាជបុត្រ ពួកអាត្មាមិនបានឃើញព្រះសាស្តា ក្នុងខណៈដែលប្រាថ្នា ហើយប្រាថ្នាទៀត ព្រះសុមនរាជកុមារត្រាស់ថា លោកម្ចាស់ ក៏អ្នក ណាហ្ន៎ បានឃើញ ភិក្ខុទាំងឡាយពោលថា ព្រះរាជបុត្រ ព្រះសុមនត្ថេរ បានឃើញ ព្រះសុមនរាជកុមារត្រាស់សួរថា លោកម្ចាស់ ព្រះថេរៈ នៅទីណា ហើយត្រាស់សួរដល់ទីដែលព្រះថេរៈគង់ ស្តេចទើបទៅថ្វាយ បង្គំ ហើយត្រាស់ថា លោកម្ចាស់ ខ្ញុំព្រះករុណា ប្រាថ្នានឹងគាល់ព្រះ

មានព្រះភាគ សូមលោកម្ចាស់មេត្តាបង្ហាញដល់ខ្ញុំព្រះករុណាចុះ ព្រះថេរៈពោលថា មកចុះព្រះរាជបុត្រ ហើយនាំព្រះសុមនរាជកុមារ ទៅកាន់ទីបរិវេណព្រះគន្ធកុដិ ព្រះថេរៈឡើងទៅកាន់ព្រះគន្ធកុដិ លំដាប់នោះ ព្រះមានព្រះភាគត្រាស់សួរថា សុមនៈ អ្នកមកព្រោះអ្វី ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន រាជឱរសមកគាល់ព្រះអង្គ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ បើដូច្នោះ អ្នកចូរក្រាលអាសនៈចុះ ព្រះថេរៈបានក្រាលអាសនៈហើយ ព្រះមានព្រះភាគប្រថាប់លើអាសនៈដែលក្រាលហើយ ព្រះរាជឱរសថ្វាយបង្គំព្រះមានព្រះភាគហើយ ទ្រង់បានធ្វើបដិសណ្ឋារៈ ព្រះមានព្រះភាគត្រាស់សួរថា អ្នកមកតាំងពីពេលណា រាជបុត្រក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាលព្រះអង្គស្តេចចូលគន្ធកុដិ តែភិក្ខុទាំងឡាយពោលថា ពួកអាត្មាក៏មិនបានឃើញព្រះមានព្រះភាគ ក្នុងខណៈដែលប្រាថ្នាហើយប្រាថ្នាទៀតឡើយ បញ្ជូនខ្ញុំព្រះករុណាឲ្យមករកព្រះថេរៈ តែព្រះថេរៈបានបង្ហាញត្រឹមតែពាក្យតែមួយប៉ុណ្ណោះ បពិត្រព្រះអង្គដ៏ចម្រើន ព្រះថេរៈប្រហែលជាអ្នកប្រោសប្រាណ ក្នុងសាសនារបស់ព្រះអង្គទេដឹង ព្រះអង្គត្រាស់ថា ត្រូវហើយកុមារ ភិក្ខុនោះ ជាអ្នកប្រោសប្រាណក្នុងសាសនារបស់តថាគត ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុទាំងឡាយធ្វើអ្វីទើបជាអ្នកប្រោសប្រាណក្នុងសាសនារបស់ព្រះពុទ្ធទាំងឡាយ ទ្រង់ត្រាស់ថា រាជកុមារ បុគ្គលឲ្យទាន សមាទានសីល រក្សាឧបោសថ នឹងបានជាអ្នក

ប្រោសប្រាណក្នុងសាសនារបស់ព្រះពុទ្ធទាំងឡាយ ក្រាបទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គនឹងប្រាថ្នាជាអ្នកប្រោសប្រាណក្នុងព្រះពុទ្ធសាសនាដូចព្រះថេរៈ សូមព្រះអង្គចូរទ្រង់ទទួលនិមន្តនៅចាំវស្សាបរហូតដល់អស់ ៣ ខែ ដល់ខ្ញុំព្រះករុណាចុះ ព្រះអង្គ ព្រះមានព្រះភាគទ្រង់ពិចារណាមើលថា ការទៅក្នុងទីនោះ នឹងមានប្រយោជន៍ឬហ្ន៎ ទ្រង់ឃើញថា មានទើបត្រាស់ថា រាជកុមារ ព្រះតថាគតទាំងឡាយ រមែងត្រេកអរក្នុងសុញ្ញាគារ ព្រះកុមារក្រាបទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គជ្រាបហើយបពិត្រព្រះសុគត ខ្ញុំព្រះអង្គជ្រាបហើយ” ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងត្រឡប់ទៅមុន ហើយសាងទីប្រថាប់កាលខ្ញុំព្រះអង្គបញ្ជូនដំណឹងមកហើយ សូមព្រះអង្គចូរស្តេចយាងទៅព្រមដោយភិក្ខុសែនរូប គ្រាទទួលបដិញ្ញាហើយ ទើបស្តេចទៅគាល់ព្រះជនកក្រាបទូលថា បពិត្រព្រះបិតា ព្រះមានព្រះភាគទ្រង់ឲ្យបដិញ្ញាដល់ខ្ញុំព្រះអង្គហើយ កាលខ្ញុំព្រះអង្គបញ្ជូនដំណឹងមក សូមព្រះបិតាយាងព្រះមានព្រះភាគទៅផង ដូច្នេះ ហើយថ្វាយបង្គំព្រះជនក ស្តេចចេញទៅសាងព្រះវិហារក្នុងទីមួយយោជន៍ ស្តេចទៅផ្លូវឆ្ងាយដល់ ២,០០០ យោជន៍ទ្រង់ជ្រើសរើសស្ថានទីសាងវិហារក្នុងព្រះនគររបស់ព្រះអង្គ ទតឃើញសួនរបស់កុដុម្ពីឈ្មោះសោភៈ ទ្រង់ទិញមួយសែន ទ្រង់លះបង់មួយសែនសាងព្រះវិហារ ក្នុងព្រះវិហារ ព្រះសុមនរាជកុមារទ្រង់សាងគន្ធកុដិថ្វាយ

ព្រះមានព្រះភាគ និងកុដិសម្រាប់ពួនសម្ងំ និងមណ្ឌបដើម្បីជាទីសម្រាក ពេលយប់ និងពេលថ្ងៃរបស់ភិក្ខុដ៏សេស ធ្វើកំពែងលោមព័ទ្ធ និងសាង ទ្វារសម្រេចហើយ ទើបបញ្ជូនដំណឹងឲ្យព្រះជនកទ្រង់ជ្រាបថា កិច្ចរបស់ បុត្រសម្រេចហើយ សូមព្រះបិតាទ្រង់យាងព្រះសាស្ដាមកចុះ ។

ព្រះរាជាទ្រង់អង្គាសព្រះមានព្រះភាគហើយ ក្រាបទូលថា បពិត្រ ព្រះមានព្រះភាគ កិច្ចរបស់សុមនៈសម្រេចហើយ លោកប្រាថ្នាឲ្យព្រះអង្គ ស្ដេចយាង ដូច្នេះ ព្រះមានព្រះភាគមានភិក្ខុមួយសែនជាបរិវារ ប្រថាប់នៅ ក្នុងព្រះវិហារទាំងឡាយក្នុងទីមួយយោជន៍ៗ ស្ដេចទៅហើយ ព្រះកុមារ ទ្រង់ស្ដាប់ថា ព្រះសាស្ដាស្ដេចយាងមក ទើបស្ដេចទៅទទួលអស់ផ្លូវមួយ យោជន៍ ទ្រង់បូជាដោយរបស់ក្រអូប និងផ្កាឈើជាដើម ទូលអារាធនា ព្រះមានព្រះភាគឲ្យស្ដេចយាងចូលទៅកាន់ព្រះវិហារ ហើយទូលថា

**បពិត្រព្រះមហាមុនី សូមព្រះអង្គទ្រង់ទទួលសួនឈ្មោះ សោភនៈ ដែលខ្ញុំព្រះអង្គទិញមកដោយទ្រព្យមួយសែន សាងដោយទ្រព្យមួយសែនទៀត ព្រះអង្គ ហើយប្រគល់ ព្រះវិហារថ្វាយ ។**

សុមនរាជកុមារនោះ ក្នុងថ្ងៃចូលវស្សាថ្វាយទាន ហើយត្រាស់ ហៅឱរស និងជាយារបស់ព្រះអង្គ និងអាមាត្រទាំងឡាយមក ត្រាស់ថា " ព្រះសាស្ដា ព្រះអង្គនេះ មកកាន់សម្នាក់របស់យើងអំពីទីឆ្ងាយណាស់

មួយទៀត ធម្មតាព្រះពុទ្ធទាំងឡាយជាអ្នកជូនក្នុងធម៌ មិនសម្លឹងចំពោះអាមិស ព្រោះដូច្នោះ យើងនឹងស្លៀកដណ្តប់សំពត់សាដក ២ ផ្ទាំង សមាទានសីលនៅក្នុងទីនេះឯង រហូតដល់អស់ ៣ ខែនេះ ពួកអ្នកទាំងឡាយចូរថ្វាយទានដល់ព្រះខីណាស្រពមួយសែនរូប ដោយទំនងនេះឯងរហូតអស់ ៣ ខែ ។

សុមនរាជកុមារនោះ ប្រថាប់នៅក្នុងកន្លែងដែលមានចំណែកស្មើគ្នានឹងទីនៅរបស់ព្រះសុមនត្ថេរ ទ្រង់ឃើញវត្តបដិបត្តិដែលព្រះថេរៈធ្វើចំពោះព្រះមានព្រះភាគទាំងអស់ ទើបទ្រង់ត្រិះរិះថា ព្រះថេរៈនេះជាអ្នកប្រោសប្រាណដោយចំណែកតែមួយក្នុងទីនេះ យើងគួរប្រាថ្នាឋានន្តរៈរបស់ព្រះថេរៈនេះចុះ កាលជិតដល់ថ្ងៃបវារណា ស្តេចចូលទៅកាន់ស្រុក ទ្រង់បរិច្ចាគទានធំរហូតដល់អស់ ៧ ថ្ងៃ ក្នុងថ្ងៃទី ៧ ទ្រង់តាំងត្រៃចីវរទុកក្នុងទីជិតជើងរបស់ភិក្ខុមួយសែនរូប ថ្វាយបង្គំព្រះមានព្រះភាគ ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន បុណ្យឯណាដែលខ្ញុំព្រះករុណាធ្វើហើយ ចាប់ផ្តើមតាំងពីការសាងព្រះវិហារ ដែលមានក្នុងចន្លោះមួយយោជន៍ ៗ តាមផ្លូវ បុណ្យនោះ ខ្ញុំព្រះករុណាមិនបានប្រាថ្នាសក្កៈសម្បត្តិ មារសម្បត្តិ និងព្រហ្មសម្បត្តិទេ ប្រាថ្នាតែតំណែងឧបដ្ឋាករបស់ព្រះពុទ្ធ ទើបបានធ្វើ ព្រោះដូច្នោះ ទើបក្រាបទូលថា បពិត្រព្រះមានព្រះភាគ សូម្បីខ្ញុំព្រះករុណាក៏នឹងគប្បីបានជាឧបដ្ឋាករបស់ព្រះពុទ្ធ ក្នុងអនាគតដូចព្រះសុមនត្ថេរ ហើយ

ក្រាបថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ព្រះមានព្រះភាគ ទ្រង់ពិចារណាមើលថា ចិត្តដ៏ក្រៃលែងរបស់កុលបុត្រនឹងសម្រេចឬទេហ្ន៎ ទ្រង់ជ្រាបថា ក្នុងអនាគត ក្នុងកប្បទី ១ សែន បន្ទាប់ពីកប្បនេះទៅ ព្រះពុទ្ធព្រះនាមថាគោតមទ្រង់នឹងឧប្បត្តិ សុមនៈនេះ នឹងជាឧបដ្ឋាករបស់ព្រះពុទ្ធព្រះអង្គនោះ ទើបទ្រង់ប្រទានពរថា ៖

**សូមសេចក្តីប្រាថ្នា ដែលតាំងទុកទាំងអស់នោះឯង ចូរសម្រេចដល់អ្នក សូមសេចក្តីត្រិះរិះ ទាំងឡាយទាំងពួងចូរពេញ ដូចព្រះចន្ទក្នុងថ្ងៃពេញបូណ៌មី ដូច្នេះ ។**

ព្រះកុមារទ្រង់ស្តាប់ដូច្នោះ ទើបត្រិះរិះថា ធម្មតាព្រះពុទ្ធទាំងឡាយរមែងមានព្រះតម្រាស់មិនមានពីរដូច្នេះ ក្នុងថ្ងៃទីពីរនុ៎ះឯង ទ្រង់ទទួលបាត្រនិងចីវររបស់ព្រះមានព្រះភាគព្រះអង្គនោះហើយ បានធ្វើដូចជាទ្រង់ដំណើរទៅតាមក្រោយ ព្រះកុមារនោះថ្វាយទានក្នុងពុទ្ធប្បាទនោះ រហូតដល់អស់មួយសែនឆ្នាំ ទ្រង់ទៅកើតក្នុងសួគ៌ សូម្បីក្នុងកាលសាសនារបស់ព្រះពុទ្ធកស្សបៈ ក៏បានថ្វាយសំពត់សាដកសាច់ល្អ កាលទទួលបាត្ររបស់ព្រះថេរៈដែលត្រាច់ទៅបិណ្ឌបាត ទ្រង់បានធ្វើការបូជា បានទៅកើតក្នុងសួគ៌ទៀត ចុតិអំពីនោះហើយ បានជាស្តេចនគរពារាណសី ទ្រង់សាងបណ្ណសាលាថ្វាយព្រះបច្ចេកពុទ្ធ ៨ អង្គ តាំងធ្នាំងទឹកថ្លាដូចកែវមណីទុក ទ្រង់បានធ្វើការទំនុកបម្រុងដោយបច្ច័យ ៤ រហូតអស់ ១ ម៉ឺនឆ្នាំ ហេតុទាំងនេះ ប្រាកដ

ច្បាស់ហើយ ។

ក៏ព្រះសុមនរាជកុមារនោះ ទ្រង់បរិច្ចាគទានតែម្យ៉ាង រហូតដល់អស់មួយសែនកប្ប ទ្រង់កើតក្នុងកពតុសិតព្រមនឹងព្រះពោធិសត្វរបស់យើង លុះចុតិអំពីកពតុសិតនោះ បានបដិសន្ធិក្នុងព្រះតំណាក់របស់ព្រះបាទសក្យៈ ព្រះនាមថា **អមិតោទន** កាលព្រះមានព្រះភាគ ស្តេចទ្រង់ចេញព្រះផ្នួសដោយលំដាប់ បានសម្រេចសម្មាសម្ពោធិញ្ញាណហើយ ស្តេចទៅកាន់ក្រុងកបិលកស្តុដោយស្តេចទៅជាគ្រាដំបូង ហើយស្តេចចេញចាកក្រុងកបិលកស្តុ កាលព្រះរាជកុមារទាំងឡាយនាំគ្នាទ្រង់ព្រះផ្នួស ដើម្បីជាបរិវាររបស់ព្រះមានព្រះភាគ ស្តេចចេញព្រមនឹងស្តេចសក្យៈទាំងឡាយមានព្រះភទ្ទិយៈជាដើម ទ្រង់ព្រះផ្នួសក្នុងសំណាក់របស់ព្រះមានព្រះភាគមិនយូរប៉ុន្មាន បានស្តាប់ធម្មកថា ក្នុងសម្នាក់របស់ព្រះបុណ្ណមន្តានីបុត្តហើយតាំងនៅក្នុងសោតាបត្តិផល ព្រះថេរៈនេះ ជាអ្នកដល់ព្រមដោយឧបនិស្ស័យក្នុងជាតិមុនដោយប្រការដូច្នេះ ។ បដិច្ចសមុប្បាទសូម្បីជ្រាលជ្រៅ ក៏ប្រាកដដូចជារបស់ងាយ ព្រោះសេចក្តីដល់ព្រមដោយឧបនិស្ស័យក្នុងជាតិមុនរបស់ព្រះថេរៈនោះ ។

គេចិអាចារ្យពោលដល់ការរៀន ការស្តាប់ ការសាកសួរ និងការចាំទុក ក្នុងសម្នាក់គ្រូទាំងឡាយរឿយៗ ដោយបទថា តិត្ថវាសោ គឺការនៅក្នុងសម្នាក់គ្រូ ការនៅក្នុងសម្នាក់គ្រូនោះរបស់ព្រះថេរៈ បរិសុទ្ធិ

យ៉ាងក្រៃលែង សូម្បីដោយហេតុនោះ បដិច្ចសមុប្បាទនេះ សូម្បីជ្រាលជ្រៅ ក៏ប្រាកដដល់ព្រះថេរៈ ដូចជារបស់ងាយ មួយទៀត បច្ចយាការប្រាកដជារបស់ងាយរបស់ព្រះសោតាបន្ន ក៏ព្រះថេរៈនេះបានជាព្រះសោតា-បន្នហើយ ។

ការកំណត់នាមរូប រមែងប្រាកដដល់លោកដែលជាពហុស្សូត ដូចគ្រៃ និងតាំង រមែងប្រាកដ កាលដួងប្រទីបបំភ្លឺឲ្យភ្លឺក្នុងបន្ទប់ដេកប្រមាណ ៤ ហត្ថ ក៏ព្រះថេរៈនេះ ជាកំពូលលើសរបស់អ្នកជាពហុស្សូតទាំងឡាយ បច្ច័យការសូម្បីជ្រាលជ្រៅ ក៏ប្រាកដដល់ព្រះថេរៈនោះ ដូចជារបស់ងាយដោយអានុភាពនៃភាពជាពហុស្សូត ដោយប្រការដូច្នេះ ។

ក្នុងសេចក្តីងាយ និងសេចក្តីជ្រាលជ្រៅរបស់បដិច្ចសមុប្បាទនោះ បដិច្ចសមុប្បាទឈ្មោះថា ជារបស់ជ្រាលជ្រៅដោយអាការ ៤ យ៉ាង គឺ ជ្រាលជ្រៅដោយអត្ថ ជ្រាលជ្រៅដោយធម៌ ជ្រាលជ្រៅដោយទេសនា ជ្រៅដោយបដិវេធ , ក្នុងការជ្រាលជ្រៅ ៤ យ៉ាងនោះ បដិច្ចសមុប្បាទជារបស់ជ្រាលជ្រៅ មានអត្ថថា មាន និងកើតឡើង ព្រោះជាតិជាបច្ច័យនៃជរា និងមរណៈជារបស់ជ្រាលជ្រៅ មានអត្ថថា មាន និងកើតឡើង ព្រោះអវិជ្ជាជាបច្ច័យនៃសង្ខារទាំងឡាយ ព្រោះហេតុនោះ នេះគឺ អត្ថនៃបដិច្ចសមុប្បាទមានសេចក្តីជ្រាលជ្រៅ ដោយអត្ថបដិច្ចសមុប្បាទជារបស់ជ្រាលជ្រៅ មានអត្ថ គឺ អវិជ្ជាជាបច្ច័យនៃសង្ខារទាំងឡាយ ជារបស់

ជ្រាលជ្រៅ មានអត្ថ គឺ ជាតិជាបច្ច័យនៃជរា និងមរណៈ ព្រោះហេតុនោះ នេះឈ្មោះថា សេចក្ដីដែលបដិច្ចសមុប្បាទ មានភាពជ្រាលជ្រៅដោយធម៌ ក្នុងសូត្រខ្លះ ទ្រង់សម្ដែងបដិច្ចសមុប្បាទដោយអនុលោម ក្នុងសូត្រខ្លះ ដោយបដិលោម ក្នុងសូត្រខ្លះទាំងអនុលោម និងបដិលោម ក្នុងសូត្រខ្លះ ដោយអនុលោម ឬដោយបដិលោមតាំងពីផ្នែកកណ្ដាល ក្នុងសូត្រខ្លះដោយ អនុលោម ឬដោយបដិលោមតាំងពីផ្នែកចុង ក្នុងសូត្រខ្លះ មានសន្ធិ ៣ សង្ខេប ៤ , ក្នុងសូត្រខ្លះ មានសន្ធិ ២ សង្ខេប ៣ , ក្នុងសូត្រខ្លះមាន សន្ធិ ១ សង្ខេប ២ ព្រោះហេតុនោះ នេះឈ្មោះថា អត្ថនៃបដិច្ចសមុប្បាទ មានសេចក្ដីជ្រាលជ្រៅដោយទេសនា ។

ម្យ៉ាងទៀត បដិច្ចសមុប្បាទជារបស់ជ្រាលជ្រៅ មានអត្ថថា មិនដឹង មិនឃើញ មិនចាក់ធ្លុះសច្ចធម៌នៃអវិជ្ជា ជារបស់ជ្រាលជ្រៅ មានអត្ថថា តាក់តែង រួបរួមសង្ខារទាំងឡាយ មានតម្រេក និងកម្ចាត់តម្រេក មាន អត្ថថា ជារបស់សូន្យ ការមិនខ្វល់ខ្វាយ ការមិនឃ្លាតចាកទី និងការ ប្រាកដនៃបដិសន្ធិវិញ្ញាណ មានអត្ថថា កើតតែម្ដង ការបែកគ្នា ការមិន បែកគ្នា ការបង្អោនទៅ ការទម្លាយរបស់នាមរូប មានអត្ថថា ជាធំ ជាទ្វារ និងខេត្តរបស់លោក និងជាធម៌មានអារម្មណ៍របស់អាយតនៈ ៦ មានអត្ថ ថា ប៉ះខ្ទប់ រួមទីងប្រជុំរបស់ផស្សៈ មានអត្ថថា ការសោយអារម្មណ៍ និងរស និងការសោយវត្ថុគ្មានជីវិត គឺ ភាពជាសុខ ជាទុក្ខ និងកណ្ដាលៗ

របស់វេទនា មានអត្ថថា គ្រេកអរក្រៃលែង កន្លល់ក្រៃលែង ខ្សែទឹកស្អិត គឺ តណ្ហា ពេញបានលំបាករបស់តណ្ហា មានអត្ថថា កាន់ ទទួល គោង ពាល់ត្រូវ កន្ទង់ទៅបានលំបាករបស់ឧបាទាន មានអត្ថថា ប្រមូលតាក់តែង និងការបោះទៅក្នុងយោនិ គតិ ឋិតិ និងនិវាសស្ថានទាំងឡាយរបស់កព មានអត្ថថា ការប្រាកដនៃជាតិ សញ្ជាតិ ការឈានចុះ ការកើតឡើងរបស់ជាតិ មានអត្ថថា អស់ទៅ សាបសូន្យទៅ បែកធ្លាយទៅ និងប្រែប្រួលនៃជរា និងមរណៈដោយប្រការយ៉ាងនេះ សភាវៈនៃអវិជ្ជាជាដើមណា ធម៌ទាំងឡាយមានអវិជ្ជាជាដើម ជាការដឹងច្បាស់នូវលក្ខណៈ ដែលមានរសដោយបដិវេធណា សភាវៈ និងបដិវេធនោះ ជារបស់ជ្រាលជ្រៅ ព្រោះហេតុនោះ គប្បីជ្រាបថា នេះគឺ បដិច្ចសមុប្បាទ មានសភាពជ្រាលជ្រៅដោយបដិវេធ ។

បដិច្ចសមុប្បាទសូម្បីទាំងអស់នោះ ប្រាកដដល់ព្រះថេរៈដូចជារបស់ងាយដោយហេតុនោះ ព្រះមានព្រះភាគ កាលនឹងញុំាងព្រះអានន្ទឲ្យបំបាត់ការគិត ទើបត្រាស់ថា មា ហេវំ ដូច្នេះជាដើម ក៏ក្នុងសេចក្ដីនេះ មានអធិប្បាយថា ម្នាលអានន្ទ អ្នកជាអ្នកមានបញ្ញាច្រើន មានបញ្ញាធ្លាតឈ្លាស ដោយហេតុនោះ បដិច្ចសមុប្បាទ សូម្បីជារបស់ជ្រាលជ្រៅរមែងប្រាកដដល់អ្នក ដូចជារបស់ងាយ ព្រោះដូច្នោះ អ្នកកុំគប្បីពោលយ៉ាងនេះថា បដិច្ចសមុប្បាទនេះ ប្រាកដជារបស់ងាយដល់យើងប៉ុណ្ណោះឬ

ឬថា សូម្បីដល់អ្នកដទៃដោយក្នុងបទដែលលោកពោលថា អបសាទេន្តោ នោះ មានអធិប្បាយថា ម្នាលអានន្ទ អ្នកកុំពោលយ៉ាងនេះថា ក៏កាលបើដូច្នោះ បដិច្ចសមុប្បាទនេះ រមែងប្រាកដដល់យើងដូចជារបស់ងាយៗ ប្រសិនបើថា បដិច្ចសមុប្បាទនេះ រមែងប្រាកដដល់អ្នក ដូចជារបស់ងាយៗ មែននោះ ព្រោះហេតុអ្វី អ្នកទើបមិនបានជាសោតាបន្នតាមធម្មតារបស់ខ្លួន អ្នកតាំងនៅក្នុងន័យដែលតថាគតឲ្យហើយ ទើបសម្រេចសោតាបត្តិមគ្គ ម្នាលអានន្ទ និព្វាននេះប៉ុណ្ណោះ ជារបស់ជ្រាលជ្រៅ តែបច្ចយាការជារបស់ងាយរបស់អ្នក បើដូច្នោះ ព្រោះហេតុអ្វី អ្នកដកកិលេស ៤ ទាំងនេះ គឺ កាមរាគសញ្ញោជនៈ (ការចងចិត្តដោយកាមរាគៈ) បដិឃសញ្ញោ-ជនៈ (ការចងចិត្តដោយសេចក្តីថ្នាំងថ្នាក់) យ៉ាងគ្រោតគ្រាត កាមរាគា-នុស័យ (កិលេសដែលដេកត្រាំនៅក្នុងសន្តាន គឺ កាមរាគៈ) បដិឃានុ-ស័យយ៉ាងគ្រោតគ្រាត (កិលេសដែលដេកត្រាំនៅក្នុងសន្តាន គឺ សេចក្តីថ្នាំងថ្នាក់) បានហើយ ទើបមិនធ្វើឲ្យច្បាស់នូវសកទាគាមិផល អ្នកដកកិលេស ៤ ដែលជាប់ទាក់ទងជាមួយហេតុនោះបានហើយ មិនធ្វើឲ្យច្បាស់នូវអនាគាមិផល អ្នកដកកិលេស ៨ ទាំងនេះ គឺ សញ្ញោជនៈ ៥ មានរូបរាគៈ (តម្រេកក្នុងរូប) ជាដើម ភវរាគានុស័យ (កិលេសដែលដេកត្រាំក្នុងសន្តាន គឺ តម្រេកក្នុងភព) មានានុស័យ (កិលេសដែលដេកត្រាំក្នុងសន្តាន គឺ មានះ) អវិជ្ជានុស័យ (កិលេសដែលដេកត្រាំក្នុងសន្តាន គឺ

អវិជ្ជា) បានហើយ មិនធ្វើឲ្យច្បាស់នូវព្រះអរហត្ត មួយទៀត ព្រោះហេតុអ្វី អ្នកទើបមិនសម្រេចសាវកបារមីញាណ ដូចព្រះសារីបុត្រ និងព្រះមោគ្គល្លាន អ្នកបំពេញបារមីរហូតដល់អស់អសង្ខេយ្យក្រៃលែងដោយសែនកប្ប និងអ្នកមិនសម្រេចបច្ចេកពោធិញ្ញាណ ដូចព្រះបច្ចេកពុទ្ធទាំងឡាយ អ្នកបំពេញបារមីរហូតដល់អស់ ២ អសង្ខេយ្យក្រៃលែងដោយសែនកប្ប ឬប្រសិនបើថា បដិច្ចសមុប្បាទនោះប្រាកដជារបស់ងាយ ដោយប្រការទាំងពួងដល់អ្នក បើដូច្នោះ ព្រោះហេតុអ្វី អ្នកទើបមិនធ្វើឲ្យច្បាស់នូវព្រះសព្វញ្ញុតញ្ញាណ ដូចព្រះពុទ្ធទាំងឡាយ ដែលបំពេញបារមីមកហើយរហូតដល់អស់ ៤ អសង្ខេយ្យ ៨ អសង្ខេយ្យ ឬ ១៦ អសង្ខេយ្យក្រៃលែងដោយសែនកប្ប អ្នកជាអ្នកមិនមានប្រយោជន៍អ្វីដោយការសម្រេចគុណវិសេសទាំងនេះ អ្នកចូរសម្លឹងមើលសេចក្តីខុសក្នាត់របស់អ្នកដោយសព្វគ្រប់ចុះថា សាវកដូចអ្នកតាំងនៅក្នុងសេចក្តីដឹងមួយជ្រុងៗ រមែងនិយាយដល់បច្ចយាការដែលជ្រាលជ្រៅក្រៃលែងណាស់ថា ប្រាកដជារបស់ងាយដល់យើងដូច្នេះ ពាក្យនិយាយនេះ របស់អ្នកនោះ ជាពាក្យនិយាយផ្ទុយគ្នានឹងព្រះតម្រាស់របស់ព្រះពុទ្ធទាំងឡាយ ពាក្យដែលភិក្ខុដូចអ្នកនឹងគប្បីពោលផ្ទុយគ្នានឹងព្រះតម្រាស់របស់ព្រះពុទ្ធទាំងឡាយមិនសមគួរដូច្នេះ ម្នាលអានន្ទ កាលតថាគតព្យាយាមដើម្បីសម្រេចបច្ចយាការនេះកន្លងទៅអស់ ៤ អសង្ខេយ្យក្រៃលែងដោយសែនកប្ប ក៏និងឈ្មោះថា អ្នកដែលយើងមិនទូន្មានហើយ

ដើម្បីសម្រេចបច្ចយាការមិនមាន ឈ្មោះថា បារមីដែលតថាគតមិនបំពេញ ហើយមិនមាន និងកាលយើងកម្ចាត់មារ និងសេនាមារ ដូចមិនដកដង្ហើម ដោយគិតថា ថ្ងៃនេះតថាគតនឹងសម្រេចបច្ចយាការ ផែនដីដ៏ធំនេះមិនញាប់-ញ័រ សូម្បីគ្រាន់តែ ២ ធ្លាប់ កាលតថាគតសម្រេចបុព្វេនិវាស (ខន្ធបញ្ចកៈដែលអាស្រ័យនៅក្នុងជាតិមុន) ក្នុងបឋមយាម , សម្រេចទិព្វចក្ខុ ក្នុងមជ្ឈិម-យាមក៏ដូចគ្នា , តែក្នុងបច្ឆិមយាម ពេលជិតភ្លឺ ពេលតថាគតឃើញថា អវិជ្ជាជាបច្ច័យនៃសង្ខារទាំងឡាយ ដោយអាការ ៩ យ៉ាង ដូច្នេះប៉ុណ្ណោះ ម៉ឺនលោកធាតុបញ្ចេញសម្លេងស្រែកកងរំពងជាពាន់ៗ សម្លេង ដូចរគាំងគង ត្រូវគោះដោយអន្ទង់ដែក ញាប់ញ័រដូចតំណក់ទឹកលើស្លឹកឈូក កាលត្រូវខ្យល់ដូច្នោះ ម្នាលអានន្ទ ក៏បដិច្ចសមុប្បាទនេះ ជារបស់ជ្រាលជ្រៅយ៉ាងនេះ នឹងប្រាកដថា ជារបស់ជ្រាលជ្រៅ ម្នាលអានន្ទ ការមិនដឹងតាមមិនសម្រេចធម៌នេះ រមែងមិនកន្លងផុតសង្សារទៅបាន ដូច្នេះ ។

បទថា ឯតស្ស ធម្មស្ស គឺ នៃបច្ច័យធម៌នោះ ។ បទថា អននុពោធា គឺ មិនដឹងតាម ដោយអំណាចញាតបរិញ្ញា (ការកំណត់ដឹងថាដឹងហើយ) ។ បទថា អបដិវេធា គឺ មិនចាក់ធ្លុះដោយអំណាចនៃការពិចារណា ការលះ និងការកំណត់ដឹង ។ បទថា តន្តាកុលកជាតា គឺ កើតជាអ្នកជំពាក់វាក់វិនដូចអំបោះ អធិប្បាយថា សត្វទាំងឡាយខុសក្លាត់ក្នុងបច្ចយាការនេះ រមែងជាអ្នកក្រវល់ក្រវាយ ជំពាក់វាក់វិន ចាក់ក្រជាញ់

មិនអាចធ្វើបច្ចយាការឲ្យត្រង់បាន ដូចអំបោះរបស់ជាងតម្បាញរក្សាទុក មិនល្អត្រូវកណ្ដុរខាំ រមែងជំពាក់វាក់វិនចាក់ក្រជាញ់ក្នុងទីនោះៗ ទើបជាការលំបាកដែលនឹងធ្វើចុងឲ្យស្មើចុង ធ្វើដើមឲ្យស្មើដើមបាន ព្រោះមិនដឹងថា នេះចុង នេះដើម ដូច្នោះ ក្នុងការជំពាក់វាក់វិនចាក់ក្រជាញ់របស់ផ្នែកខាងនោះ បុគ្គលដាក់អំបោះទុកក្នុងការងាររបស់បុរសចំពោះខ្លួន ក៏គប្បីធ្វើឲ្យត្រង់បាន ក៏សត្វទាំងឡាយដទៃ វៀរព្រះពោធិសត្វទាំងពីរចេញ ឈ្មោះថា អាចនឹងធ្វើបច្ចយាការឲ្យត្រង់បានតាមធម្មតារបស់ខ្លួន រមែងមិនមាន សត្វទាំងឡាយនេះ ខុសក្លាត់ក្នុងបច្ច័យទាំងឡាយ មិនអាចធ្វើបច្ច័យឲ្យត្រង់បាន រមែងជំពាក់វាក់វិន ចាក់ក្រជាញ់ ជាគំនួចដោយអំណាចទិដ្ឋិ ៦២ ដូចអំបោះ ជំពាក់ ចាក់ក្រជាញ់ផ្សំដោយទឹកបាយ បុគ្គលជំដោយផ្ដៅជ្រលក់មក្លឿ ចងជាគំនួចក្នុងទីនោះៗ ដូច្នោះ ក៏សត្វពួកណាមួយអាស្រ័យទិដ្ឋិទាំងឡាយ មិនអាចធ្វើបច្ចយាការឲ្យត្រង់បាន ។ បទថា គុណ-គណ្ឋិកាជាតា គឺ អំបោះផ្សំទឹកបាយរបស់ជាងតម្បាញ លោកពោលថា ជាគំនួចដូចដុំអំបោះ អាចារ្យពួកមួយពោលថា សំបុករបស់សកុណីនោះឈ្មោះ **គុណះ** (គ្រៀងចង) ដូច្នេះខ្លះ របស់ជំពាក់វាក់វិន ចាក់ក្រជាញ់សូម្បីទាំងពីរយ៉ាងនោះ គប្បីប្រកបដោយន័យមុននោះឯងថា ជាការលំបាកដែលនឹងធ្វើចុងឲ្យស្មើចុង ធ្វើដើមឲ្យស្មើដើមបាន ដូច្នេះ ។ បទថា មុញ្ជបព្វជភូតា គឺ ដូចជាស្មៅជំណេកទន្សាយ និងដូចស្មៅយ៉ាប្លង់ ពួក

សត្វនេះ មិនអាចធ្វើបច្ចយាការឲ្យត្រង់បាន ជាអ្នកមានគំនួចដោយអំណាចរបស់ទិដ្ឋិ រមែងមិនផុតពីអបាយ ទុគតិ វិនិបាត សង្សារ ដូចកាន់ខ្សែដែលគេជំស្នៀទាំងនោះហើយធ្វើជាខ្សែ កាលខ្សែចាស់ ក៏នឹងធ្លាក់ចុះក្នុងទីណាៗ ទើបជាការលំបាកដែលនឹងធ្វើឲ្យចុងស្មើចុង ធ្វើគល់ឲ្យស្មើគល់បាន ព្រោះមិនដឹងថា នេះចុង នេះគល់នៃខ្សែទាំងនោះ ដូច្នោះ បុគ្គលដាក់ខ្សែនោះទុកក្នុងការងាររបស់បុរសចំពោះខ្លួន គប្បីធ្វើឲ្យត្រង់បាន ក៏សត្វពួកដទៃវៀរព្រះពោធិសត្វទាំងពីរអង្គចេញ ឈ្មោះថា អាចនឹងធ្វើបច្ចយាការឲ្យត្រង់តាមធម្មតារបស់ខ្លួន រមែងមិនមាន ។

ក្នុងបទទាំងនោះ បទថា អបាយោ បានដល់ នរក កំណើតតិរច្ឆាន ប្រេតវិស័យ និងអសុរកាយទាំងឡាយ ពិតហើយ សូម្បីទាំងអស់នោះ លោកពោលថា **អបាយ** ព្រោះមិនមានសេចក្ដីចម្រើន ពោលគឺ **វុឌ្ឍិ** មួយទៀត ឈ្មោះថា **ទុគ្គតិ** ព្រោះជាផ្លូវទៅកាន់ទុក្ខ , ឈ្មោះថា **វិនិបាត** ព្រោះធ្លាក់អំពីការតាំងឡើងនៃសេចក្ដីសុខ ។ ចំណែកលោកក្រៅពីនេះពោលថា លំដាប់នៃខន្ធ ធាតុ និងអាយតនៈ នៅប្រព្រឹត្តទៅមិនដាច់ខ្សែ លោកពោលថា **សង្សារ** ។

ពួកសត្វ រមែងមិនផុត គឺ មិនឈានកន្លង សូម្បីសភាពទាំងអស់នោះ លំដាប់នោះឯង ពួកសត្វកាន់យកចុតិ និងបដិសន្ធិរឿយៗ យ៉ាងនេះ គឺ តពីចុតិ ដល់បដិសន្ធិ តពីបដិសន្ធិដល់ចុតិ រមែងវិលវល់ផ្លាស់ប្ដូរ

ក្នុងភព ៣ ក្នុងកំណើត ៤ ក្នុងគតិ ៥ ក្នុងវិញ្ញាណដ្ឋិតិ ៧ ក្នុងសត្តាវាស ៩ ដូចទូកត្រូវខ្យល់បោះទៅក្នុងមហាសមុទ្រ និងដូចគោដែលត្រូវទឹមក្នុងគ្រឿងយន្ត ដោយប្រការដូច្នេះ គប្បីជ្រាបសេចក្ដីទាំងអស់នេះថា ព្រះមានព្រះភាគ កាលនឹងញ៉ាំងព្រះអានន្ទឲ្យបំបាត់សេចក្ដីគិត ទើបត្រាស់ហើយ ។

[៥៨] ឥឡូវនេះ ព្រោះសូត្រនេះ ព្រះមានព្រះភាគទ្រង់ផ្ដើមដោយបទទាំងពីរនេះឯងថា ម្នាលអានន្ទ បដិច្ចសមុប្បាទនេះជ្រៅផង និងសត្វទាំងឡាយ កើតទៅជាស្មុគ្រស្មាញដូចអំបោះរបស់ជាងតម្បាញ ដូច្នេះកាលទ្រង់ប្រារព្ធទេសនា ដើម្បីឃើញសេចក្ដីជ្រាលជ្រៅរបស់បច្ចយាការដោយបន្តជាប់អំពីមុនថា ម្នាលអានន្ទ បដិច្ចសមុប្បាទនេះ ជ្រាលជ្រៅទើបត្រាស់ពាក្យជាអាទិថា ជរា និងមរណៈកើតមាន ព្រោះជាតិជាបច្ច័យដូច្នេះ ។

បច្ច័យនៃជរា និងមរណៈនេះ ឈ្មោះ ឥទប្បច្ច័យ (មានវត្ថុនេះជាបច្ច័យ) ព្រោះដូច្នោះ ជរា និងមរណៈ ទើបមានវត្ថុនេះជាបច្ច័យ ម្នាលអានន្ទ មានបុគ្គលដែលជាបណ្ឌិតសួរហើយយ៉ាងនេះថា បច្ច័យរបស់ជរានិងមរណៈមានឬ ជរា និងមរណៈគប្បីមានវត្ថុណាជាបច្ច័យ មិនគួរបដិបត្តិដោយអាការដែលគប្បីជាអ្នកស្ងៀមចំពោះបញ្ហា ព្រោះកាលមានអ្នកពោលថា នោះជីវៈ នោះសរីរៈ ហើយគួរកំណត់ទុក ឬគួរនឹងពោលថា សេចក្ដី

នេះ ព្រះតថាគតទ្រង់មិនព្យាករណ៍ ដូច្នេះ គួរពោលដល់គេថា មានដោយចំណែកតែមួយប៉ុណ្ណោះ ដូចជាកាលមានអ្នកពោលថា ចក្ខុទៀង ឬមិនទៀង គួរពោលដោយចំណែកតែមួយប៉ុណ្ណោះថា មិនទៀង កាលមានអ្នកពោលទៀតថា ជរា និងមរណៈមានអ្វីជាបច្ច័យ ជរា និងមរណៈ រមែងមានព្រោះបច្ច័យអ្វី ដូច្នេះ គួរពោលដល់គេដូច្នេះថា ជរា និងមរណៈ មានជាតិជាបច្ច័យ អធិប្បាយថា គួរពោលយ៉ាងនេះ ក្នុងបទទាំងអស់មានន័យយ៉ាងនេះ ។ ក៏បទនេះថា ផស្សៈ មាននាមរូបជាបច្ច័យ ព្រោះកាលពោលថា មានសឡាយតនៈជាបច្ច័យ ជាការទទួលសម្ផស្សដែលជាផល ៦ មានចក្ខុសម្ផស្ស ជាដើម តែក្នុងទីនេះ ព្រះមានព្រះភាគទ្រង់បំណងសម្ដែងសេចក្ដីវិសេសរបស់បច្ច័យដែលកើតឡើងទទួលខ្លះ មិនទទួលខ្លះ ដោយបទនេះថា មានសឡាយតនៈជាបច្ច័យ ដូច្នេះ និងបច្ច័យដែលវិសេស សូម្បីយ៉ាងដទៃរបស់ផស្សៈ ក្រៅពីជាងសឡាយតនៈ ដូច្នោះ គប្បីជ្រាបថា ព្រះអង្គត្រាស់ទុកហើយ សួរថា ក៏ដោយការៈនេះ ព្រះមានព្រះភាគត្រាស់អ្វីទុក ឆ្លើយថា ត្រាស់ហេតុនៃបច្ច័យទាំងឡាយទុក ពិតហើយ ព្រះសូត្រនេះ លោកពោលថា **មហានិទាន** ព្រោះធ្វើបច្ច័យទាំងឡាយ ឲ្យមិនមានបច្ច័យ មិនឲ្យមានការពាក់ព័ន្ធ មិនឲ្យមានការកឡើង ទើបពោលទុក ឥឡូវនេះ ដើម្បីនឹងទ្រង់សម្ដែងបច្ច័យទាំងនោះ ជាបច្ច័យពិត មិនជាយ៉ាងដទៃ ទើបត្រាស់ពាក្យជាអាទិថា ជរា និងមរណៈ មានជាតិជាបច្ច័យ តថាគត

ពោលអធិប្បាយពាក្យនេះ ទុកដោយប្រការដូច្នេះ ។

ក្នុងបទទាំងនោះ បទថា បរិយាយេន គឺ ដោយហេតុ ។ បទថា សព្វេន សព្វំ សព្វថា សព្វំ ទាំងពីរបទនេះជានិបាត អធិប្បាយបទនោះថា ប្រសិនបើថា ឈ្មោះថា ជាតិទាំងអស់ មិនគប្បីមានដោយអាការទាំងអស់ មិនគប្បីមានដោយសភាវៈទាំងអស់ ដូច្នេះ សូម្បីក្នុងភពជាដើម គប្បីជ្រាបដោយន័យនេះឯង ។ បទថា កស្សចិ នេះ ជាពាក្យមិនពិតប្រាកដ គឺ ដល់នរណាៗ ក្នុងទេវលោកជាដើម សូម្បីបទនេះថា កិម្ហិចិ ក៏ជាពាក្យមិនពិតប្រាកដដូចគ្នា គឺ ក្នុងទីណាៗ ក្នុងភពទាំង ៩ មានកាមភពជាដើម ។ បទថា សេយ្យថីទំ ជានិបាត ក្នុងអត្ថថា កំណត់ក្នុងសេចក្តីមិនពិតប្រាកដ និងពង្រីកសេចក្តីសង្ខេបចេញទៅ , បទនោះ ប្រែថា **គឺថា** មានអធិប្បាយថា យើងនឹងពង្រីកសេចក្តីនៃបទដែលយើងពោលទុកដល់នរណាៗ ក្នុងទីណាៗ កាលព្រះមានព្រះភាគទ្រង់ពង្រីកសេចក្តីនោះ ទើបត្រាស់ពាក្យមានជាអាទិថា **ដល់ពួកទេវតា ដើម្បីភាវៈជាទេវតា** ។

ក្នុងបទទាំងនោះ ពាក្យថា **ដល់ពួកទេវតា ដើម្បីភាវៈជាទេវតា** ពួកទេវតា លោកពោលថា **ទេវា** ដោយកំណត់នៃខន្ធ ដើម្បីភាពជាទេវតានៃទេវតាទាំងឡាយ គប្បីជ្រាបសេចក្តីក្នុងបទទាំងពួងដោយន័យនេះឯងថា ប្រសិនបើថា ជាតិមិនមានគ្រប់ទីទាំងពួង ដូច្នេះ ក៏ក្នុងបទទាំងនេះបទថា ទេវា គឺ ឧប្បត្តិទេវតា (កើតឡើង) ។ បទថា គន្ធព្វា គឺ

ទេវតាដែលស្ថិតនៅតាមគល់ឈើ និងដើមឈើ ជាដើម ។ បទថា យក្ខា គឺ ពួកអមនុស្ស ។ បទថា ភូតា គឺ សត្វពួកណាមួយដែលកើតហើយ ។ បទថា បក្ខិនោ គឺ សត្វពួកណាមួយ មានធ្មេញជាស្លាបក្ដី មានស្បែកជាស្លាបក្ដី មានរោមជាស្លាបក្ដី ។ បទថា សិរឹសបា គឺ សត្វពួកណាមួយលូនវារទៅលើផែនដី ។ បទថា តេសំ តេសំ គឺ បណ្ដាទេវតា និងគន្ធព្វជាដើមទាំងនោះៗ ។ បទថា តជត្តាយ គឺ ដើម្បីភាពជាទេវតា និងគន្ធព្វជាដើម ។ បទថា ជាតិនិរោធា សេចក្ដីថា ព្រោះប្រាសចាកជាតិ ព្រោះមិនមានជាតិ ។

សូម្បីបទទាំងអស់មានជាអាទិថា ហេតុដូច្នេះ ជាវេវចនៈរបស់ហេតុនោះឯង ពិតហើយ ព្រោះហេតុ រមែងប្រាថ្នា រមែងប្រព្រឹត្តទៅដើម្បីត្រូវការផលរបស់ខ្លួន ដូច្នោះ លោកទើបពោលថា ហេតុដូច្នេះ ព្រោះប្រគល់ផលនោះឲ្យ ដូចប្រគល់ឲ្យ ដោយពាក្យថា អ្នកទាំងឡាយចូរទទួលផលនេះចុះដូច្នេះ ដូច្នោះ លោកទើបពោលនិទាន ព្រោះផលរមែងតាំងឡើង គឺ រមែងកើតឡើងអំពីហេតុនោះ និងអាស្រ័យហេតុនោះ រមែងដល់ គឺ រមែងប្រព្រឹត្តទៅ ដូច្នោះ លោកទើបពោលថា សមុទ័យ និងបច្ច័យ ដូច្នេះ ក្នុងបទទាំងអស់មានន័យនេះ ។ មួយវិញទៀត បទថា យទិទំ ក្នុងបទនេះថា យទិទំ ជាតិ ដូច្នេះ ជានិបាត គប្បីជ្រាបសេចក្ដីនៃនិបាតនោះ ដោយអនុរូបដល់លិង្គក្នុងបទទាំងអស់ ក៏ក្នុងទីនេះមានអធិប្បាយបទនេះ យ៉ាងនេះថា

យា ឯសា ដូច្នេះ ។ ពិតហើយ ការកើតនៃជរា និងមរណៈ រមែងជា បច្ច័យនៃទីបំផុតរបស់ឧបនិស្ស័យ ។

លោកធ្វើការកំណត់ឱកាសក្នុងបទនៃភព ដោយបទនេះថា គត្ថិចិ ក្នុងបទនោះគប្បីជ្រាបថា កាមភព ក្នុងខាងក្នុង និងធ្វើទីបំផុតអវេចីខាងក្រោម ធ្វើទេវលោកជាន់បរនិម្មិតវសវត្តិក្នុងខាងលើ ក្នុងឧប្បត្តិភពក៏មានន័យនេះ តែក្នុងបទនេះគួរជាកម្មភព ព្រោះកម្មភពនោះ ជាបច្ច័យនៃទីបំផុតរបស់ឧបនិស្ស័យនៃជាតិ ស្សប្បីក្នុងបទនៃឧបាទានជាដើម គប្បីជ្រាបថា លោកធ្វើការកំណត់ឱកាសដោយបទនេះថា គត្ថិចិ ដូច្នេះ ។

ក្នុងបទថា **ព្រោះឧបាទានជាបច្ច័យ ទើបមានភពនេះ** សេចក្តីថា កាមុបាទានជាបច្ច័យនៃកម្មភព ៣ និងឧប្បត្តិភព ៣ ស្សប្បីបទដ៏សេសក៏យ៉ាងនោះ គប្បីជ្រាបភព ២៤ មានឧបាទានជាបច្ច័យ កម្មភព ១២ រមែងបានក្នុងបទនេះដោយត្រង់ ឧបាទាននៃកម្មភពទាំងនោះ ជាបច្ច័យនៃទីបំផុតរបស់សហជាតខ្លះ នៃទីបំផុតរបស់ឧបនិស្ស័យខ្លះ ។

ពាក្យថា **រូបតណ្ហា** គឺ បំណងក្នុងរូបារម្មណ៍ ក្នុងសទ្ទតណ្ហាជាដើម ក៏មានន័យនេះ ក៏តណ្ហានេះ រមែងជាបច្ច័យ នៃទីបំផុតរបស់សហជាតខ្លះ នៃទីបំផុតរបស់ឧបនិស្ស័យខ្លះ របស់ឧបាទាន ។

ក្នុងបទថា **បច្ច័យនៃតណ្ហា ក៏គឺ វេទនា** សេចក្តីថា វិបាកវេទនា រមែងជាបច្ច័យនៃទីបំផុតនៃឧបនិស្ស័យរបស់តណ្ហា វេទនាយ៉ាងដទៃ ក៏ជា

បច្ច័យសម្បីដោយប្រការដទៃ ។

ក៏ដោយហេតុត្រឹមតែប៉ុណ្ណោះ ព្រះមានព្រះភាគទ្រង់សម្ដែងតណ្ហាខាងដើម ដែលមានវដ្ដៈជាមូល ឥឡូវនេះកាលនឹងទ្រង់សម្ដែងដល់តណ្ហាដែលជាការផ្សាយឡើងពាសពេញ ដោយបទទាំងឡាយ ៩ ដូចបុគ្គលដំត្រង់ខ្នង ឬចាប់ត្រង់សក់ ហើយប្រានអ្នកដែលកំពុងស្រែកសូមជីវិតចេញពីផ្លូវ ទើបត្រាស់ពាក្យមានជាអាទិថា **ម្នាលអានន្ទ ព្រោះហេតុដូច្នោះឯង** ពាក្យនេះ គឺ ព្រោះអាស្រ័យវេទនា ទើបកើតតណ្ហា ដូច្នេះ ។

## ហេតុ និងបច្ច័យនៃអកុសលធម៌ទាំងឡាយ

[៥៩] ក្នុងពាក្យទាំងនោះ ពាក្យថា **តណ្ហា** សេចក្ដីថា តណ្ហាមាន ២ យ៉ាង គឺ **ឯសនាតណ្ហា** និង **ឯសិតតណ្ហា** បុគ្គលដើរទៅកាន់ផ្លូវពពែនិងផ្លូវបន្ទាជាដើម ហើយស្វែងរកភោគៈទាំងឡាយដោយតណ្ហាណា តណ្ហានេះឈ្មោះ **ឯសនាតណ្ហា** , តណ្ហាណា សូម្បីកាលបុគ្គលស្វែងរកបានហើយ តណ្ហានេះ ក៏ឈ្មោះថា **ឯសិតតណ្ហា** សូម្បីទាំងពីរពាក្យនោះក៏ជាឈ្មោះរបស់តណ្ហា ដែលមានការផ្សាយឡើងនោះឯង ព្រោះដូច្នោះ តណ្ហា ២ យ៉ាងនេះ អាស្រ័យវេទនា ទើបឈ្មោះថា កើតតណ្ហា ។ បទថា បរិយេសនា គឺ ការស្វែងរកអារម្មណ៍ មានរូបជាដើម ព្រោះថា ការស្វែងរកនោះ រមែងជាការរលឹកដល់តណ្ហា ។ បទថា លាភោ គឺ ការ

បានអារម្មណ៍មានរូបជាដើម ព្រោះថា ការបាននោះ រមែងជាការរលឹក ដោយការស្វែងរក ។

វិនិច្ឆ័យមាន ៤ យ៉ាង គឺ ញាណ តណ្ហា ទិដ្ឋិ និងវិតក្ក ។ ក្នុងវិនិច្ឆ័យទាំងនោះ គប្បីដឹងវិនិច្ឆ័យ ដែលជាសេចក្តីសុខ លុះដឹងវិនិច្ឆ័យដែលជាសុខហើយ គប្បីព្យាយាមរកសេចក្តីសុខក្នុងខាងក្នុង នេះគឺ ញាណ-វិនិច្ឆ័យ ។ សេចក្តីវិបរិតនៃតណ្ហា ១០៨ មកហើយយ៉ាងនេះថា បទថា វិនិច្ឆ័យ បានដល់ វិនិច្ឆ័យ ២ យ៉ាង គឺ តណ្ហាវិនិច្ឆ័យ និងទិដ្ឋិវិនិច្ឆ័យ ឈ្មោះថា តណ្ហាវិនិច្ឆ័យ ។ ទិដ្ឋិ ៦២ ឈ្មោះថា ទិដ្ឋិវិនិច្ឆ័យ ។ វិតក្កៈដែលលោកពោលថា វិនិច្ឆ័យ ក្នុងទីនេះមកហើយក្នុងសក្កបញ្ហសូត្រនេះថា បពិត្រទេវានមិន្ទ ឆន្ទៈ មានវិតក្កៈជាដើមហេតុ ដូច្នេះ ក៏មនុស្សទាំងឡាយបានលាភហើយ រមែងកាត់ក្តីថា គួរពេញចិត្ត និងមិនគួរពេញចិត្ត ល្អ និងមិនល្អ ដោយវិតក្កៈតែម្យ៉ាង បុគ្គលត្រិះរិះថា យើងនឹងមានលាភប៉ុណ្ណោះ ដើម្បីត្រូវការរូបារម្មណ៍ យើងនឹងមានលាភប៉ុណ្ណោះដើម្បីអារម្មណ៍មានសទ្ទារម្មណ៍ជាដើម នឹងមានដល់យើងប៉ុណ្ណោះ នឹងមានដល់អ្នកដទៃប៉ុណ្ណោះ យើងនឹងប្រើប្រាស់ប៉ុណ្ណោះ យើងនឹងរក្សាប៉ុណ្ណោះ ដូច្នេះ ដោយហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា អាស្រ័យលាភទើបកាត់ក្តី ។

បទថា ឆន្ទរាគោ សេចក្តីថា រាគៈដែលខ្សោយ និងរាគៈដែលមាន

កម្លាំង រមែងកើតឡើងក្នុងវត្ថុដែលត្រិះរិះហើយ ដោយអកុសលវិតក្កៈ ក៏បទនេះ ជាតណ្ហាក្នុងទីនេះ ។ បទថា ឆន្ទោ ជាឈ្មោះរបស់រាគៈដែលខ្សោយ ។ បទថា អជ្ឈោសានំ គឺ ចុះកាន់ក្នុងការឃើញយ៉ាងខ្លាំងថា យើង របស់យើង ដូច្នេះ ។ បទថា បរិគ្គហោ គឺ ធ្វើការប្រកាន់ដោយអំណាចតណ្ហា និងទិដ្ឋិ ។ បទថា មច្ឆរិយំ សេចក្តីថា ព្រោះទ្រាំមិនបានចំពោះរបស់ដែលទូទៅដល់អ្នកដទៃ ដោយហេតុនោះឯង បុរាណាចារ្យទាំងពីរ ទើបពោលអត្ថនៃពាក្យរបស់បទនោះ យ៉ាងនេះថា ទ្រង់ត្រាស់ថា មច្ឆរិយំ ព្រោះការតាំងចិត្តថា វត្ថុអស្ចារ្យនេះ ចូរជារបស់យើងតែម្នាក់ ចូរកុំជារបស់អ្នកដទៃឡើយ ដូច្នេះ ។ បទថា អារក្ខោ គឺ ការការពារយ៉ាងល្អដោយអំណាចការបិទទ្វារ និងដាក់ទុកក្នុងហិបជាដើម ។

ឈ្មោះថា អធិករណា ព្រោះអត្ថថា ធ្វើឲ្យក្រៃលែង បទនេះជាឈ្មោះរបស់ហេតុ ។ បទថា អារក្ខាធិករណំ ជាភាវនបុំសកៈ (មិនមានភេទ) អធិប្បាយថា ហេតុនៃការការពារក្នុងការកាន់ឈើជាដើម ការកាន់កំណាត់ឈើ ដើម្បីហាមអ្នកដទៃ ឈ្មោះ ទណ្ឌាទានំ , ការកាន់កាំបិតមានមុតតែម្ខាងជាដើម ឈ្មោះ សត្ថាទានំ , បទថា កលហោ គឺ ឈ្មោះផ្លូវកាយខ្លះ ឈ្មោះផ្លូវវាចាខ្លះ , សេចក្តីពិរោធមានមកមុនៗ ឈ្មោះថា វិគ្គហ មានមកពេលក្រោយៗ ឈ្មោះ **វិវាទ** (ការពោលប្រឆាំងគ្នា) ។ បទថា តុវំ តុវំ ជាពាក្យមិនគោរព គឺ និយាយថា អាម៉ឹង ឯងហ្ន ។

## ហេតុ និងបច្ច័យនៃធម៌ទាំងឡាយមានឆន្ទរាគៈជាដើម...

*ឥឡូវនេះ ព្រះមានព្រះភាគកាលទ្រង់សម្ដែងតណ្ហា ដែលផ្សាយទៅពាសពេញនោះ សូម្បីដោយន័យបដិលោម ទើបទ្រង់ប្រារព្ធបទថា អារក្ខាធិករណំ (ហេតុនៃការរក្សា) គឺ ទ្រង់សម្ដែងបញ្ញាស់ ។ ក្នុងបទទាំងនោះ បទថា កាមតណ្ហា បានដល់ ការប្រាថ្នាក្នុងរូបជាដើម ដែលកើតឡើងហើយ ដោយអំណាចរាគៈដែលប្រកបដោយកាមគុណ ៥ ។ បទថា* ***ភវតណ្ហា*** *គឺ រាគៈសហគតដោយសស្សតទិដ្ឋិ (ការឃើញថាទៀង) ។ បទថា* ***វិភវតណ្ហា*** *គឺ រាគៈសហគតដោយឧច្ឆេទទិដ្ឋិ (ការឃើញថាសូន្យ) ។*

## ពោលអំពីហេតុបច្ច័យនៃវេទនា និងធម៌ទាំងឡាយ មានផស្សៈជាដើម.....

[៦០] *បទថា* ឥមេ ទ្វេ ធម្មា *គឺ ធម៌ ២ យ៉ាងទាំងនេះ គឺ តណ្ហាមានវដ្ដៈជាឫសគល់ និងតណ្ហាដែលផ្សាយទៅ ។ បទថា* ទ្វយេន *សេចក្ដីថា ធម៌ទាំង ២ យ៉ាងនេះ សូម្បីដល់ភាពតែមួយ ក៏ដោយលក្ខណៈរបស់តណ្ហា រមែងជាការរួមក្នុងទីតែមួយជាមួយគ្នានឹងវេទនា ដោយចំណែក ២ ដោយអំណាចតណ្ហាមានវដ្ដៈជាឫសគល់ និងតណ្ហាដែលផ្សាយទៅ អធិប្បាយថា ធម៌ទាំងឡាយនោះ មានបច្ច័យរួមគ្នា ដោយមានវេទនាជាបច្ច័យ ។ ពិតហើយ ការរួមគ្នាមាន ៣ យ៉ាង គឺ ការប្រជុំរួមគ្នា ការរួមសហជាត*

ការរួមបច្ច័យ ក្នុងបទទាំងនោះ បទនេះថា គ្រានោះឯង ការរួមអ្នកស្រុកទាំងអស់នោះ រមែងមានឡើង ដូច្នេះ ឈ្មោះថា **ការប្រជុំរួមគ្នា** , ពាក្យនេះថា ម្នាលអាវុសោទាំងឡាយ ធម៌ទាំងអស់ មានឆន្ទៈជាមូល មានផស្សៈជាទីកើត មានវេទនាជាទីប្រជុំចុះ ឈ្មោះ **រួមសហជាតិ** , ក៏គប្បីជ្រាបបទនេះថា ការរួមជាមួយគ្នានឹងវេទនាដោយ ២ ចំណែក ឈ្មោះថា **រួមបច្ច័យ** ។

ផស្សៈទាំងអស់ មានចក្ខុសម្ផស្សជាដើម ជាផស្សៈដែលជាផលតែម្យ៉ាង ក្នុងផស្សៈទាំងនោះ វៀរផស្សៈដែលជាផលនៃលោកុត្តរៈ ៤ ដ៏សេស រមែងមានផស្សៈ ៣២ ។ ក៏ក្នុងបទនេះថា យទិទំ ឯស្សោ ដោយច្រើន ផស្សៈ រមែងជាបច្ច័យនៃវេទនា ។

ទ្រង់ត្រាស់អាការទាំងឡាយ ក្នុងបទថា យេហិ អានន្ទ អាការេហិ ជាដើម មានសភាពមិនដូចគ្នានិងគ្នានៃវេទនាជាដើម ទ្រង់សម្តែងអាការទាំងនោះទុកដោយល្អ ឈ្មោះថា **លិង្គ** (ភេទ) ព្រោះដល់ការសោបសូន្យ ទ្រង់ឱ-ទ្រោម ឈ្មោះថា **និមិត្ត** ព្រោះហេតុ គឺ ដឹងរឿងនោះៗ ឈ្មោះ **ឧទ្ទេស** ព្រោះគួរសម្តែងយ៉ាងនោះៗ ព្រោះដូច្នោះ ក្នុងបទនេះ មានអធិប្បាយដូចតទៅនេះ ៖

ម្នាលអានន្ទ ការបញ្ញត្តិនាមកាយ ដែលជាទីប្រជុំរបស់
នាម រមែងមានបានដោយ អាការ លិង្គ និមិត្ត ឧទ្ទេស

កាលមានឧទ្ទេសនៃវេទនាថា វេទនាក្នុងអាការដឹង ក្នុងដឹងភេទ ក្នុងការដឹងនិមិត្ត កាលមានឧទ្ទេសនៃសញ្ញាថា សញ្ញាក្នុងអាការដឹងព្រម ក្នុងការដឹងភេទព្រម ក្នុងការនិមិត្តព្រម កាលមានឧទ្ទេសនៃសង្ខារទាំងឡាយថា ចេតនានៃសង្ខារទាំងឡាយ ក្នុងអាការនៃចេតនា ក្នុងភេទនៃចេតនា ក្នុងនិមិត្តនៃចេតនា កាលមានឧទ្ទេសនៃវិញ្ញាណថា វិញ្ញាណក្នុងអាការដឹងច្បាស់ ក្នុងការដឹងភេទច្បាស់ ក្នុងការដឹងនិមិត្តច្បាស់ ដូច្នេះ រមែងបញ្ញត្តិនាមកាយថា នេះជានាមកាយ កាលមិនមានអាការជាដើម ក្នុងវេទនាជាដើម ដែលជាហេតុឲ្យបញ្ញត្តិនាមកាយ ការសម្ផ័ស្សត្រឹមតែឈ្មោះក្នុងរូបកាយ ទើបគប្បីប្រាកដបានខ្លះទេ មនោសម្ផ័ស្សយ៉ាងណា ដែលជាវេវចនៈរបស់ការសម្ផ័ស្សត្រឹមតែឈ្មោះក្នុងមនោទ្វារ ធ្វើខន្ធ ៤ ឲ្យជាវត្ថុហើយ ទើបកើតឡើង មនោសម្ផស្សនោះ នឹងគប្បីប្រាកដក្នុងរូបកាយ គប្បីធ្វើបសាទទាំង ៥ ឲ្យជាវត្ថុហើយ គប្បីកើតឡើងបានខ្លះទេ ដូច្នេះ ។

លំដាប់នោះ ព្រះអានន្ទ កាលមិនព្រមទទួលការកើតឡើងនៃសម្ផ័ស្សនោះអំពីរូបកាយ ដូចកាលមិនមានដើមស្វាយ ក៏មិនទទួលការកើតឡើង

របស់ផ្លែស្វាយទុំអំពីដើមជម្ពូ ដូច្នោះ ទើបក្រាបទូលថា នោ ហេតំ ភន្តេ ដូច្នេះ ។

ក្នុងបញ្ហាទី ២ គប្បីជ្រាបសេចក្ដីនៃអាការជាដើម ដោយអំណាចអាការនៃការលាយ ភេទនៃការលាយ និមិត្តនៃការលាយ និងដោយអំណាចនៃកាយលើកឡើងថា រូប ដូច្នេះ ។ បទថា បដិឃសម្ផស្សោ គឺ ការសម្ផ័ស្ស ធ្វើរូបក្ខន្ធដែលប្រព្រឹត្តទៅ និងដោយការប៉ះខ្ទប់ឲ្យជាវត្ថុ ហើយកើតឡើង សួប្បីក្នុងបទនេះ ព្រះថេរៈកាលមិនទទួលការកើតឡើងនៃសម្ផ័ស្ស នោះអំពីនាមកាយ ដូចកាលមិនមានដើមជម្ពូ ក៏មិនទទួលការកើតឡើងនៃផ្លែជម្ពូទុំអំពីដើមស្វាយ ដូច្នោះ ទើបក្រាបទូលថា នោ ហេតំ ភន្តេ ដូច្នេះ ។

ក្នុងបញ្ហាទី ៣ ទ្រង់ត្រាស់ទុកដូចបញ្ហាទាំងពីរនុ៎ះឯង ក្នុងបញ្ហាទី ៣ នោះ ព្រះថេរៈកាលនឹងមិនទទួលការកើតឡើងនៃផស្សៈ សួប្បីទាំងពីរក្នុងការមិនមាននៃនាមរូប ដូចមិនទទួលការកើតឡើងនៃផ្លែស្វាយទុំ និងផ្លែជម្ពូទុំលើអាកាសដូច្នោះ ទើបក្រាបទូលថា នោ ហេតំ ភន្តេ ដូច្នេះ ព្រះមានព្រះភាគ ទ្រង់សម្ដែងបច្ច័យតែមួយយ៉ាងៗ នៃផស្សៈទាំងពីរយ៉ាងនេះ ឥឡូវនេះ ដើម្បីទ្រង់សម្ដែងផស្សៈសួប្បីទាំងពីរនោះ ជាបច្ច័យនៃនាមរូបដោយមិនផ្សេងគ្នា ទើបទ្រង់ប្រារព្ធបញ្ហាទី ៤ ថា យេហិ អានន្ទ អាការេហិ (ម្នាលអានន្ទ ដោយអាការឯណា) ដូច្នេះ ។

បទថា យទិទំ នាមរូបំ គឺ នាមរូបឯណា អធិប្បាយថា នាមរូបក្នុងទ្វារសូម្បីទាំង ៦ នេះណា នេះឯងជាហេតុ នេះឯងជាបច្ច័យ ដូច្នេះ ។ ពិតហើយ ចក្ខុជាដើម និងរូបារម្មណ៍ជាដើម ក្នុងចក្ខុទ្វារជាដើម ជារូបធម៌ដែលប្រកបជាមួយគ្នាជានាម ផស្សៈនោះសូម្បី ៥ យ៉ាង យ៉ាងនេះដោយប្រការដូច្នេះ ព្រោះនាមរូបជាបច្ច័យ ទើបមានផស្សៈ សូម្បីក្នុងមនោទ្វារ ហទយវត្ថុ និងរូប រមែងជាអារម្មណ៍ ជារូប , សម្បយុត្តធម៌ និងវត្ថុមិនមានរូប រមែងជាអារម្មណ៍ ជានាម ដោយប្រការដូច្នេះ យ៉ាងនេះ សូម្បីមនោសម្ផ័ស្ស ក៏គប្បីជ្រាបថា ព្រោះមាននាមរូបជាបច្ច័យ ទើបកើតផស្សៈ ក៏ប៉ុន្តែថា នាមរូបដោយច្រើន រមែងជាបច្ច័យនៃផស្សៈនោះ ។

បទថា ន ឱក្កមិស្សថ សេចក្តីថា វិញ្ញាណនឹងមិនប្រព្រឹត្តទៅដោយអំណាចនៃបដិសន្ធិ ដូចចូលទៅហើយប្រព្រឹត្តទៅ ។ បទថា សមុច្ចិស្សថ សេចក្តីថា កាលបដិសន្ធិវិញ្ញាណមិនមាន នាមរូបចំណែកដ៏សេសបរិសុទ្ធិជានាមរូបកាត់ផ្តាច់ការប្រកបជាមួយគ្នា ប្រព្រឹត្តទៅដោយភាពជាកលលៈជាដើម ខាងក្នុងផ្ទៃរបស់មាតាបានខ្វះទេ ។ បទថា ឱក្កមិត្វា ឱក្កមិស្សថ សេចក្តីថា វិញ្ញាណនឹងធ្លាក់ចុះដោយអំណាចបដិសន្ធិហើយ កន្លងទៅ គឺរលត់ទៅដោយអំណាចចុតិ ។ ក៏ការរលត់នៃវិញ្ញាណនោះ រមែងមិនមានដោយការរលត់នៃចិត្តនុ៎ះឯង អំពីនោះវិញ្ញាណ រមែងមិនមានដោយការរលត់នៃចិត្តដួងទី ២ និងទី ៣ ។ ពិតហើយ កម្មជរូប គ្រប់ ៣០ ដែល

តាំងឡើងព្រមនឹងបដិសន្ធិចិត្ត រមែងកើត កាលកម្មជរូបទាំងនោះ តាំងនៅនុ៎ះឯង ភវង្គចិត្ត ១៦ កើតឡើង ហើយរមែងរលត់ទៅ ។ មិនមានអន្តរាយដល់ទារកអ្នកកាន់យកបដិសន្ធិក្នុងចន្លោះនោះ ឬដល់មាតារបស់ទារកនោះ ព្រោះអន្តរាយនេះ ឈ្មោះថា មិនទាន់មានឱកាស ។ ប្រសិនបើថា រូបដែលប្រាកដឡើងព្រមនឹងបដិសន្ធិចិត្ត អាចដើម្បីជាបច្ច័យដល់ភវង្គចិត្តដួងទី ១៧ បាន ការប្រព្រឹត្តទៅ រមែងប្រព្រឹត្តទៅជាប្រវេណីតទៅ ។ ប្រសិនបើថា មិនអាច ការប្រព្រឹត្តទៅ រមែងមិនប្រព្រឹត្តទៅជាប្រវេណី ឈ្មោះថា កន្លងទៅ ។ ទ្រង់សំដៅដល់ការកន្លងទៅនោះ ទើបត្រាស់ថា ឱក្កមិត្វា ឱក្កមិស្សថ (ធ្លាក់ចុះហើយកន្លងទៅ) ដូច្នេះ ។ បទថា ឥត្ថត្តាយ គឺ ដើម្បីភាពជាយ៉ាងនេះ អធិប្បាយថា កាលខន្ធ ៥ បរិបូណ៌ហើយយ៉ាងនេះ ។

បទថា ទហរស្សេវ សតោ គឺ នៅទនខ្ចីនុ៎ះឯង ។ បទថា វោច្ឆិជ្ជិស្សតិ គឺ ដាច់ការបន្ត ។ បទថា វុឌ្ឍឹ វិរុឡ្ហឹ វេបុល្លំ សេចក្តីថា កាលវិញ្ញាណដាច់ការបន្ត នាមរូបបរិសុទ្ធិនឹងតាំងឡើងហើយ ដល់ការចម្រើនក្នុងបឋមវ័យ ការដុះដាលល្អក្នុងមជ្ឈិមវ័យ ការធំធាត់ក្នុងបច្ឆិមវ័យ ខ្លះបានទេ អធិប្បាយថា នាមរូបនឹងដល់ការចម្រើន ការដុះដាលល្អ ការធំធាត់ ដោយមានអាយុដល់ ១០ ឆ្នាំ ២០ ឆ្នាំ ។ល។ ១,០០០ ឆ្នាំ បានខ្លះទេ ។

បទថា តស្មាតិហានន្ទ សេចក្ដីថា ព្រោះវិញ្ញាណនុ៎ះឯងជាបច្ច័យនៃនាមរូបនោះ ក្នុងការបដិសន្ធិក្នុងផ្ទៃមាតាខ្លះ ក្នុងខណៈនៅក្នុងផ្ទៃខ្លះ ក្នុងខណៈចេញចាកផ្ទៃខ្លះ ក្នុងវេលាមានអាយុ ១០ ឆ្នាំ ប្រព្រឹត្តទៅខ្លះ ដូច្នោះ នេះជាហេតុ នេះជាបច្ច័យនៃនាមរូប គឺ វិញ្ញាណ វិញ្ញាណរមែងជាបច្ច័យនៃនាមរូប ដូចបុគ្គលពោលដល់នាមរូបយ៉ាងនេះ ដោយសេចក្ដីថា លោក ឈ្មោះនាម លោក ឈ្មោះរូប លោកឈ្មោះនាមរូប ដូច្នេះ អ្នកណាធ្វើនាមរូបនោះ យើងធ្វើមែនឬ បើថា កាលយើងជាបុរេចារិកមិនកាន់យកបដិសន្ធិក្នុងផ្ទៃរបស់មាតា លោកគប្បីជានាម គប្បីជារូប ឬគប្បីជានាមរូប ពួកយើងគប្បីដឹងកម្លាំងរបស់លោក ដូចជាថា ព្រះរាជាកាលនឹងទ្រង់គម្រាមប្រជារាស្ដ្ររបស់ព្រះអង្គ គប្បីត្រាស់ថា អ្នកឯងជាឧបរាជ អ្នកឯងជាសេនាបតីដូច្នេះ អ្នកណាតែងតាំងអ្នកឯង យើងតែងតាំងអ្នកឯងមិនមែនឬ ប្រសិនបើកាលយើងមិនតែងតាំងអ្នកឯង អ្នកឯងនឹងគប្បីជាឧបរាជ ឬគប្បីជាសេនាបតីតាមធម្មតារបស់ខ្លួន យើងគប្បីដឹងកម្លាំងរបស់អ្នកឯង ដូច្នោះ ក៏វិញ្ញាណនេះ ដោយច្រើនរមែងជាបច្ច័យនៃនាមរូប ។

បទថា ទុក្ខសមុទយសម្ភវោ គឺ ការកើតឡើងនៃគំនរទុក្ខ ។ បទថា យទិទំ នាមរូបំ សេចក្ដីថា នាមរូបនេះណា នេះជាហេតុ នេះជាបច្ច័យ សូម្បី នាមរូប ក៏ដូចបុគ្គលពោលដល់វិញ្ញាណយ៉ាងនេះ ដោយសេចក្ដីថា

លោកជាបដិសន្ធិវិញ្ញាណ ។ អ្នកណាធ្វើបដិសន្ធិវិញ្ញាណ យើងធ្វើមែនឬ ក៏បើលោកមិនអាស្រ័យខន្ធ ៣ និងហទយវត្ថុ នឹងគប្បីឈ្មោះថា បដិសន្ធិ-វិញ្ញាណ យើងគប្បីឃើញលោកជាបដិសន្ធិវិញ្ញាណ ដូច្នេះ ដូចសេចក្ដីថា រាជបុរសទាំងឡាយ គប្បីទូលចំពោះព្រះរាជាដែលទ្រង់គម្រាមថា ព្រះអង្គជាព្រះរាជា អ្នកណាតាំងព្រះអង្គ ពួកទូលបង្គំតាំងព្រះអង្គមិនមែនឬ ប្រសិនបើថា កាលទូលបង្គំមិនតាំងនៅក្នុងតំណែងឧបរាជ ក្នុងតំណែងសេនាបតី ព្រះអង្គគប្បីជាព្រះរាជាតែមួយព្រះអង្គឯងប៉ុណ្ណោះ ពួកខ្ញុំព្រះអង្គ គប្បីឃើញភាពជាព្រះរាជារបស់ព្រះអង្គ ដូច្នេះ ក៏នាមរូបនេះ ដោយច្រើនរមែងជាបច្ច័យនៃវិញ្ញាណ ។ បទថា ឯត្តាវតា ខោ សេចក្ដីថា កាលវិញ្ញាណជាបច្ច័យនៃនាមរូប កាលនាមរូបជាបច្ច័យនៃវិញ្ញាណ បើធម៌ទាំងពីរប្រព្រឹត្តទៅដោយអំណាចនៃបច្ច័យដល់គ្នានិងគ្នា ដោយហេតុត្រឹមតែប៉ុណ្ណេះ វិញ្ញាណនិងនាមរូប ទើបនៅតែ កើត ចាស់ ស្លាប់ ចុតិ ឬឧប្បត្តិ ជាតិជាដើម ឬចុតិ បដិសន្ធិដទៃៗ គប្បីប្រាកដ ។

បទថា អធិវចនបថោ សេចក្ដីថា ផ្លូវនៃវោហារ ដែលមិនឃើញសភាពរបស់ពាក្យជាដើមថា សិរិវឌ្ឍក: ធនវឌ្ឍក: តាំងឡើងទុកត្រឹមតែហៅឈ្មោះប៉ុណ្ណោះ ។ បទថា និរុត្តិបថោ សេចក្ដីថា ជាគន្លងនៃវោហារដែលប្រព្រឹត្តទៅ ដោយអំណាចការអាងហេតុ នៃពាក្យជាដើមថា អ្នកមានសតិ ព្រោះរលឹកបាន អ្នកមានសម្បជញ្ញ: ព្រោះដឹងខ្លួន ។ បទថា

បញ្ញត្តិបថោ សេចក្តីថា ផ្លូវនៃវោហារ ដែលប្រព្រឹត្តទៅដោយអំណាចនៃការឲ្យដឹងដោយប្រការផ្សេងៗ របស់ពាក្យមានជាអាទិថា អ្នកដឹង អ្នកឆ្លាត អ្នកមានបញ្ញា អ្នកជំនាញ អ្នកជំទាស់ សូម្បីខន្ធទាំងឡាយដែលជាវត្ថុនៃឈ្មោះជាដើម លោកក៏ពោលអំពីបទទាំង ៣ ដោយប្រការដូច្នេះ ។ បទថា បញ្ញាវចរំ សេចក្តីថា គប្បីកំណត់ គឺ គប្បីដឹងដោយបញ្ញា ។ បទថា វដ្ដំ វដ្តតិ គឺ សង្សារវដ្តរមែងប្រព្រឹត្តទៅ ។ បទថា ឥត្ថត្តំ គឺ ភាពជាយ៉ាងនេះ ពាក្យនេះ ជាឈ្មោះរបស់ខន្ធបញ្ចក: (ពួក ៥ នៃខន្ធ) ។ បទថា បញ្ញាបនាយ គឺ ដើម្បីបញ្ញត្តិឈ្មោះ អធិប្បាយថា សូម្បីខន្ធបញ្ចក: ក៏រមែងប្រាកដដោយហេតុត្រឹមតែប៉ុណ្ណេះ ដើម្បីត្រូវការបញ្ញត្តិនាម ដោយបទថា វេទនា សញ្ញាជាដើម ។ បទថា យទិទំ នាមរូបំ សហវិញ្ញាណេន សេចក្តីថា នេះគឺ នាមរូប និងវិញ្ញាណ រមែងប្រព្រឹត្តទៅ ព្រោះជាបច្ច័យដល់គ្នានិងគ្នា លោកអធិប្បាយពោលអំពីហេតុត្រឹមតែប៉ុណ្ណេះ ដូច្នេះ នេះជាពាក្យដែលត្រូវនាំចេញទៅក្នុងបទនេះ ។

## ពោលអំពីការបញ្ញត្តិខ្លួន

[៦១] ដោយប្រការដូច្នេះ ព្រះមានព្រះភាគ លុះទ្រង់សម្តែងអនុសន្ធិនៃបទថា ម្នាលអានន្ទ ក៏បដិច្ចសមុប្បាទនេះ ជារបស់ជ្រាលជ្រៅ និងប្រាកដជារបស់ជ្រាលជ្រៅ ដូច្នេះហើយ ឥឡូវនេះកាលនឹងទ្រង់សម្តែង

អនុសន្ធិនៃបទថា តន្តាកុលកជាតា (ស្មុគ្រស្មាញដូចអំបោះនៃជាងតម្បាញ) ដូច្នេះ ទ្រង់ប្រារព្ធទេសនាមានជាអាទិថា កិត្តាវតា ច (ដោយហេតុមានប្រមាណប៉ុនណា) ដូច្នេះ ។ ក្នុងបទទាំងនោះ ក្នុងបទថា រូបឹ វា ហិ អានន្ទ បរិត្តំ អត្តានំ ដូច្នេះ សេចក្តីថា អ្នកដែលបញ្ញត្តិអត្តាមានរូបបន្តិចបន្តួច រមែងប្រកាន់ថា កសិណនិមិត្តដែលនៅមិនចម្រើន ជាអត្តា ដូច្នេះ មួយទៀត អ្នកដែលបញ្ញត្តិអត្តានោះថា ពេលខ្លះខៀវ ពេលខ្លះលឿង ដូច្នេះ រមែងជាអ្នកមានប្រក្រតីបានកសិណផ្សេងៗ អ្នកដែលបញ្ញត្តិអត្តា មានរូបមិនមានទីបំផុត រមែងប្រកាន់ថា កសិណនិមិត្ត ដែលចម្រើនហើយ ជាអត្តា ដូច្នេះ ឬអ្នកដែលបញ្ញត្តិអត្តាមិនមានរូបបន្តិចបន្តួច បើកកសិណនិមិត្តដែលមិនទាន់ចម្រើនហើយ កាន់យកឱកាសដែលនិមិត្តពាល់ត្រូវហើយ ឬខន្ធ ៤ ដែលប្រព្រឹត្តទៅក្នុងនិមិត្តនោះ ឬត្រឹមតែវិញ្ញាណក្នុងខន្ធ ៤ ទាំងនោះ ប៉ុណ្ណោះថា ជាអត្តាដូច្នេះ អ្នកដែលបញ្ញត្តិអត្តាមិនមានរូប មិនមានទីបំផុត បើកកសិណនិមិត្តដែលចម្រើនហើយ រមែងកាន់យកឱកាស ដែលនិមិត្តពាល់ត្រូវហើយ ឬខន្ធដែលប្រព្រឹត្តទៅក្នុងនិមិត្តនោះ ឬត្រឹមតែវិញ្ញាណក្នុងខន្ធទាំង ៤ នោះ ប៉ុណ្ណោះថា ជាអត្តា ដូច្នេះ ។

បទថា តត្រ ក្នុងបទថា តត្រានន្ទ នេះ គឺ ក្នុងពួកទិដ្ឋិ ៤ យ៉ាងនោះ ។ បទថា ឯតរហិ វា គឺ ក្នុងកាលឥឡូវនេះ មិនមែនដទៃអំពីនេះ

ទ្រង់ត្រាស់ពាក្យនេះដោយអំណាចឧច្ឆេទទិដ្ឋិ ។ បទថា តថាភាវិ វា គឺសភាពរស់នៅក្នុងបរលោក ដែលនៅយ៉ាងនោះ ទ្រង់ត្រាស់ពាក្យនេះ ដោយអំណាចសស្សតទិដ្ឋិ ។ បទថា អតថំ វា បន សន្តំ គឺ ឬសភាវៈដែលមិនពិត មានហើយ មានហើយ ។ បទថា តថត្តាយ គឺ ដើម្បីសេចក្តីពិតវិញ ។ បទថា ឧបកប្បេស្សាមិ គឺ យើងនឹងឲ្យដល់ព្រម ព្រះមានព្រះភាគ ទ្រង់សម្តែងការជំទាស់សូម្បីដោយបទនេះ ព្រោះអ្នកមានវាទៈថាសូន្យ គិតហើយថា យើងនឹងញុំាងអត្តាដែលមិនទៀងពិត គឺ សូម្បីសេចក្តីពិត មិនសូន្យ របស់អ្នកមានវាទៈថា ទៀង ឲ្យសម្រេច ដើម្បីសភាពដែលទៀងពិត គឺ មានសភាពសូន្យ ហើយយើងនឹងអ្នកមានវាទៈថា ទៀងដឹងហើយ នឹងឲ្យគេកាន់វាទៈថា សូន្យតែម្យ៉ាង សូម្បីអ្នកមានវាទៈថាទៀង ក៏គិតហើយថា យើងនឹងញុំាងអត្តាដែលមិនទៀងពិត សូម្បីសេចក្តីពិតមិនទៀង ឲ្យសម្រេច ដើម្បីមានសភាពទៀងពិត គឺ ដើម្បីសភាពដែលទៀង នឹងញុំាងអ្នកមានវាទៈថា សូន្យ ឲ្យដឹងហើយ ឲ្យគេកាន់វាទៈថា ទៀងតែម្យ៉ាង ដូច្នេះ ។ បទថា ឯវំ សន្តំ ខោ សេចក្តីថា ឲ្យបញ្ញត្តិអត្តាដែលមានរូបបន្តិចបន្តួច មានយ៉ាងនេះ ។ បទថា រូបិំ គឺ មានប្រក្រតីបានរូបជាកសិណ ។ បទថា បរិត្តត្តានុទិដ្ឋិ អនុសេតិ សេចក្តីថា ការឃើញនេះថា អត្តាបន្តិចបន្តួច រមែងដេកត្រាំក្នុងសន្តាន ក៏គប្បីជ្រាបសេចក្តីឃើញនោះថា ការយល់ឃើញនោះ រមែងមិនដេកជាប់ ដូចវល្លិ

និធលតា គឺ ឈ្មោះថា រមែងដេកត្រាំក្នុងសន្ដាន ដោយអត្ថថា លះមិនបាន ។ បទថា ឥច្ចាលំ វចនាយ សេចក្ដីថា គួរដើម្បីនឹងពោលថា ការឃើញបែបនេះ រមែងដេកត្រាំក្នុងបុគ្គលនោះ ក្នុងបទទាំងអស់មានន័យនេះ ក៏ក្នុងបទថា អរូបី នេះ គឺ មានប្រក្រតីបានអរូប ជាកសិណា គប្បីជ្រាបសេចក្ដីយ៉ាងនេះថា មានអរូបក្ខន្ធ ជាគោចរ ។

ដោយហេតុត្រឹមតែប៉ុណ្ណេះ គឺ ទ្រង់សម្ដែងដល់អ្នកប្រកាន់ដោយទិដ្ឋិ ១៦ ពួក ដោយសេចក្ដីថា ពួកអ្នកមានលាភ ៤ ពួកកូនសិស្សរបស់អ្នកមានលាភ ៤ ពួកអ្នកមានការឃើញខុស ៤ កូនសិស្សរបស់ពួកអ្នកមានការឃើញខុស ៤ ។

## ពោលអំពីការមិនបញ្ញត្តិខ្លួន

[៦២] លុះព្រះមានព្រះភាគ ទ្រង់សម្ដែងដល់អ្នកដែលបញ្ញត្តិអត្តាយ៉ាងនេះហើយ ឥឡូវនេះ ដើម្បីទ្រង់សម្ដែងដល់អ្នកដែលមិនបញ្ញត្តិអត្តាទើបត្រាស់ពាក្យជាអាទិថា កិត្តាវតា ច អានន្ទ ដូច្នេះ សួរថា ពួកណាមិនបញ្ញត្តិ ឆ្លើយថា សេចក្ដីពិត ព្រះអរិយបុគ្គលទាំងអស់ប៉ុណ្ណោះ មិនបញ្ញត្តិ មួយទៀត ព្រះអរិយបុគ្គលដែលជាពហុស្សូតទ្រទ្រង់ បិដក ៣ បិដក ២ បិដក ១ ដោយទីបំផុតវិនិច្ឆ័យ សូម្បីនិកាយតែមួយដោយល្អបុគ្គលដែលសម្ដែងធម៌តាមដែលបានរៀនខ្លះ អ្នកប្រារព្ធវិបស្សនាខ្លះ រមែង

មិនបញ្ញត្តិ ព្រោះលោកទាំងនោះ មានសញ្ញាចាំថា កសិណដែលមានចំណែកប្រៀបធៀបក្នុងកសិណ ដែលមានចំណែកប្រៀបធៀបដូច្នេះ អធិប្បាយថា អរូបក្ខន្ធ ក្នុងអរូបក្ខន្ធនោះឯង ។

## ពោលអំពីការពិចារណាខ្លួន

[៦៣] ព្រះមានព្រះភាគ ទ្រង់សម្ដែងដល់អ្នកដែលមិនបញ្ញត្តិយ៉ាងនេះហើយ ឥឡូវនេះ ព្រោះអ្នកដែលពិចារណាឃើញដោយអំណាចទិដ្ឋិរមែងបញ្ញត្តិ ក៏ការពិចារណាឃើញនេះ រមែងមានបាន ព្រោះមិនទាន់លះសក្កាយទិដ្ឋិមានវត្ថុ ២០ ដូច្នោះ ដើម្បីទ្រង់សម្ដែងដល់សក្កាយទិដ្ឋិមានវត្ថុ ២០ នោះ ទើបត្រាស់ទៀតថា កិត្តាវតា ច អានន្ទ ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ ទ្រង់ត្រាស់សក្កាយទិដ្ឋិដែលមានវេទនាខន្ធ ជាវត្ថុដោយបទនេះថា វេទនំ វា ហិ ដូច្នេះ ។

ទ្រង់ត្រាស់សក្កាយទិដ្ឋិ ដែលមានរូបក្ខន្ធជាវត្ថុ ដោយបទនេះថា អប្បដិសំវេទនោ មេ អត្តា អត្តារបស់តើងមិនសោយវេទនា ដូច្នេះ ។ ទ្រង់ត្រាស់សក្កាយទិដ្ឋិ ដែលមាន សញ្ញា សង្ខារ វិញ្ញាណជាវត្ថុ ដោយបទនេះថា អត្តារបស់យើងសោយវេទនា ព្រោះអត្តារបស់យើងមានវេទនាជាធម្មតា ដូច្នេះ ក៏ខន្ធទាំង ៣ នេះ នៅសោយវេទនា ព្រោះសម្បយុត្តដោយវេទនា , មួយទៀត អត្តាមានវេទនាជាធម្មតា គឺ មិនមានការប្រកប

ជាសភាវៈ រមែងមានដល់ខន្ធទាំង ៣ នោះ ឥឡូវនេះ ព្រះមានព្រះភាគ កាលនឹងទ្រង់សម្ដែងទោសក្នុងការឃើញទាំងនោះ ទើបត្រាស់ពាក្យមានជាអាទិថា តត្រានន្ទ ដូច្នេះ ។

ក្នុងបទទាំងនោះ បទថា តត្រ គឺ ក្នុងទិដ្ឋិទាំង ៣ នោះ ទ្រង់ត្រាស់បទជាដើមថា យស្មិំ អានន្ទ សមយេ ដូច្នេះ ដើម្បីចង្អុលទោសជាដើម យ៉ាងនេះថា គ្រាខ្លះមាន គ្រាខ្លះមិនមាន នៃអត្តារបស់អ្នកដែលពិចារណាឃើញថា វេទនាជាអត្តា ។

ក្នុងបទថា អនិច្ចា ជាដើម សេចក្ដីថា វេទនា ឈ្មោះថា ជារបស់មិនទៀង ព្រោះមានហើយមិនមាន ឈ្មោះថា **ដែលបច្ច័យតាក់តែង** ព្រោះតាក់តែងឡើងដោយហេតុនោះៗ ឈ្មោះថា **អាស្រ័យគ្នាកើតឡើង** ព្រោះអាស្រ័យបច្ច័យនោះៗ ហើយកើតឡើងដោយហេតុដ៏ប្រពៃ បទទាំងអស់មានជាអាទិថា ខយធម្មា ជាវេវចនៈរបស់ការបែកធ្លាយ ពិតហើយ វត្ថុណារមែងបែកធ្លាយ វត្ថុនោះរមែងអស់ទៅខ្លះ សាបសូន្យទៅខ្លះ បាត់ទៅខ្លះ រលត់ទៅខ្លះ ព្រោះដូច្នោះ ទ្រង់ទើបត្រាស់ពាក្យមានជាអាទិថា ខយធម្មា ដូច្នេះ ។ បទថា ព្យគា មេ អធិប្បាយថា អត្តារបស់យើងដល់សេចក្ដីសាបសូន្យ ទ្រុឌទ្រោម គឺ ប្រាសទៅ រលត់ទៅ ដូច្នេះ ។

ពុទ្ធវចនៈថា នោះខ្លួនរបស់យើង រមែងមានដល់បុគ្គលតែម្នាក់ប៉ុណ្ណោះ សូម្បីក្នុងកាលទាំង ៣ នឹងមិនមានដល់អ្នកដែលមានទិដ្ឋិឬ ព្រោះ

ធម្មតា វល្លិ៍ រមែងមិនមានដល់គល់ឈើ ដែលគេរក្សាទុកក្នុងគំនរអង្កាម ដូចស្វាព្រៃ រមែងកាន់យកវត្ថុដទៃ រមែងចោលវត្ថុដទៃ ។ បទថា អនិច្ចំ សុខំ ទុក្ខំ វោកិណ្ណំ សេចក្តីថា បុគ្គលកាលពិចារណា ឃើញវេទនានោះៗ ដោយពិសេសថា ជាអត្តា រមែងពិចារណាឃើញអត្តា មិនទៀង ជាសុខ និងជាទុក្ខ កាលពិចារណាឃើញវេទនាដោយមិនពិសេសថា ជាអត្តា រមែងពិចារណាឃើញអត្តាមានការប្រែប្រួល កើតឡើង និងសូន្យទៅជាធម្មតា ។ ពិតហើយ វេទនា មាន ៣ យ៉ាង និងមានការកើតឡើង មានការសូន្យទៅជាធម្មតា ក៏គេរមែងពិចារណាឃើញវេទនានោះថា ជាអត្តា ដោយប្រការដូច្នេះ អត្តារបស់គេ ទើបមិនទៀង និងការកើតឡើងនៃវេទនាទាំងឡាយច្រើន រមែងដល់ក្នុងខណៈតែមួយ តែគេរមែងដឹងតាមអត្តានោះឯងថា មិនទៀង មិនមានវេទនាជាច្រើនកើតឡើងក្នុងខណៈតែមួយ ព្រះមានព្រះភាគ ទ្រង់សំដៅដល់សេចក្តីនេះ ទើបត្រាស់ថា **ព្រោះហេតុនោះឯង** សេចក្តីនេះ ទើបមិនទាន់គួរពិចារណាឃើញថា វេទនាជាអត្តារបស់យើង ដោយពាក្យដូចពោលហើយ ដូច្នេះ ។

បទថា យត្ថ បនាវុសោ សេចក្តីថា ក្នុងរូបក្ខន្ធសុទ្ធ ក៏មិនមានការសោយអារម្មណ៍ ដោយប្រការទាំងពួង ។ បទថា អបិ នុ ខោ តត្ថ សេចក្តីថា ក្នុងរូបក្ខន្ធនោះ គឺ ក្នុងដើមត្នោត ឬក្នុងបង្គួចដែលវៀរវេទនាហើយ ហើយនឹងកើតអហង្ការថា ជាយើងយ៉ាងនេះទៀតឬ ។

បទថា តស្មាតិហានន្ទ សេចក្តីថា ព្រោះរូបក្ខន្ធសុទ្ធតាំងឡើងហើយ មិនទាន់ពោលថា ជាយើង ដូច្នោះ សេចក្តីនេះ ទើបមិនគួរដល់ការពិចារណាឃើញថា វេទនាជាអត្តារបស់យើង ដោយពាក្យដូចពោលហើយនេះ ក្នុងរូបក្ខន្ធនឹងនៅកើតអហង្ការថា នេះជាយើងបានឬ ព្រោះដូច្នោះ ក្នុងវេទនាទាំងនោះ ក្នុងខន្ធ ៣ សូម្បីខន្ធតែមួយ គួរនឹងពោលយ៉ាងនេះថា ឈ្មោះនេះ ជាយើង ដូច្នេះបានឬ ម្យ៉ាងទៀត អធិប្បាយថា កាលខន្ធទាំង ៣ នោះរលត់ព្រមនឹងវេទនា ព្រោះវេទនារលត់ នឹងគប្បីកើតអហង្ការថា នេះជាយើង ឬយើងជានេះ ដូច្នេះបានឬ លំដាប់នោះ ព្រះអានន្ទកាលមិនព្រមទទួលសេចក្តីនោះ ដូចបុគ្គលមិនព្រមទទួលនូវការមុតរបស់ស្នែងទន្សាយ ដូច្នោះ ទើបក្រាបទូលថា នោ ហេតំ ភន្តេ ដូច្នេះ ។

ដោយហេតុត្រឹមតែប៉ុណ្ណេះ ព្រះមានព្រះភាគត្រាស់ដល់អ្វី ត្រាស់ដល់វដ្ដៈ ពិតហើយ ព្រះមានព្រះភាគកាលនឹងត្រាស់ដល់រឿងវដ្ដៈ ក្នុងកន្លែងខ្លះត្រាស់មូលអវិជ្ជា កន្លែងខ្លះត្រាស់មូលតណ្ហា កន្លែងខ្លះត្រាស់មូលទិដ្ឋិ ក្នុងមូលទាំងនោះ ត្រាស់មូលអវិជ្ជាយ៉ាងនេះថា ៖

ម្នាលភិក្ខុទាំងឡាយ ទីបំផុតខាងដើមរបស់អវិជ្ជាមិនប្រាកដមកអំពីកាលមុន មុនអំពីនេះ អវិជ្ជាមិនមាន ប៉ុន្តែថា បានកើតមានហើយក្នុងកាលខាងក្រោយ ព្រោះហេតុនោះ ម្នាលភិក្ខុទាំងឡាយ តថាគតសម្តែងមូលអវិជ្ជានេះ យ៉ាងនេះ ខណៈអវិជ្ជារមែងប្រាកដ ព្រោះមានវត្ថុនេះជាបច្ច័យ

ទើបមានអវិជ្ជា ។

ត្រាស់មូលតណ្ហាយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ទីបំផុតខាងដើមរបស់ភវតណ្ហាមិនប្រាកដ មុនអំពីនេះ ភវតណ្ហាមិនមាន តែថា បានកើតមានហើយក្នុងកាលខាងក្រោយ ព្រោះហេតុនោះ ម្នាលភិក្ខុទាំងឡាយ ក៏ពាក្យថា ភវតណ្ហានេះ តថាគតសម្តែងដល់មូលនៃតណ្ហាទុកយ៉ាងនេះ ខណៈតណ្ហារមែងប្រាកដ ព្រោះមានវត្ថុនេះជាបច្ច័យ ។

ត្រាស់មូលទិដ្ឋិទុកយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ទីបំផុតខាងដើមរបស់ភវទិដ្ឋិមិនប្រាកដ មុនអំពីនេះ ភវទិដ្ឋិមិនមាន តែថា បានកើតឡើងក្នុងកាលខាងក្រោយ ព្រោះហេតុនោះ ម្នាលភិក្ខុទាំងឡាយ តថាគតសម្តែងដល់ភវទិដ្ឋិនេះ យ៉ាងនេះ ខណៈភវទិដ្ឋិរមែងប្រាកដ ព្រោះមានវត្ថុនេះជាបច្ច័យ ទើបមានភវទិដ្ឋិ ដូច្នេះ ។ សូម្បីក្នុងភវទិដ្ឋិនេះ ក៏ត្រាស់ដោយមូលទិដ្ឋិដូចគ្នា ពិតហើយ អ្នកមានទិដ្ឋិ ប្រកាន់វេទនា មានសុខ-វេទនាជាដើម ជាអត្តា លុះចុតិអំពីភពនោះៗ ក្នុងភព កំណើត គតិ វិញ្ញាណដ្ឋិតិ និងសត្តាវាសទាំងពួង ដោយអំណាចការប្រកាន់ថា យើងជារបស់យើង ហើយទៅកើតក្នុងភពនោះៗ រមែងស្ទុះទៅកាន់ភូមិរឿយៗ ដូចទូកត្រូវខ្យល់បោកបក់ក្នុងមហាសមុទ្រ មិនអាចងើកក្បាលឡើងអំពីវដ្តៈបានឡើយ ។

## ពោលអំពីការមិនពិចារណានូវវេទនាថាខ្លួន

[៦៤] ដោយប្រការដូច្នេះ ព្រះមានព្រះភាគត្រាស់ដល់វដ្ដៈ ដោយកថាមគ្គត្រឹមតែប៉ុណ្ណោះដល់អ្នកមានទិដ្ឋិវង្វេងក្នុងបច្ចយាការហើយ ឥឡូវនេះ កាលនឹងត្រាស់ដល់ព្រះនិព្វាន ទើបត្រាស់ពាក្យមានជាអាទិថា យតោ ខោ អានន្ទ ភិក្ខុ ដូច្នេះ ។

ក៏ព្រះមានព្រះភាគ ព្រោះព្រះអង្គទ្រង់ឆ្លាតក្នុងទេសនា ទ្រង់មិនឲ្យប៉ះពាល់ដល់វិវដ្ដកថា (រឿងនិព្វាន) ចំពោះបុគ្គលដែលរវើរវាយដោយអំណាចនវកម្មជាដើម អ្នកលះបង់ចោលកម្មដ្ឋាន ហើយកាលនឹងទ្រង់ប្រារព្ធដោយអំណាចបុគ្គល ដែលមានប្រក្រតីដោយសតិប្បដ្ឋាន ជាការកបុគ្គល ទើបត្រាស់ពាក្យជាអាទិថា ភិក្ខុរមែងមិនពិចារណាឃើញវេទនាថា ជាអត្តា ដូច្នេះ ។

ពិតហើយ ភិក្ខុបែបនេះ រមែងមិនពិចារណាឃើញវេទនាថា ជាអត្តា រមែងមិនពិចារណាឃើញធម៌ពួកដទៃ ព្រោះការប្រព្រឹត្តទៅក្នុងធម៌ទាំងពួងដោយអំណាចនៃសម្មសនញ្ញាណ ដែលព្រះមានព្រះភាគត្រាស់ទុកហើយ ដោយន័យមានជាអាទិថា រូបយ៉ាងណាមួយដែលជាអតីត អនាគត និងបច្ចុប្បន្ន ខាងក្នុង ឬខាងក្រៅ គ្រោតគ្រាត ឬល្អិត ថោកទាប ឬប្រណីត ឆ្ងាយ ឬជិត ភិក្ខុរមែងកំណត់រូបទាំងពួង ដោយភាពជារបស់មិនទៀង ពិចារណា ១ ដង រមែងកំណត់ដោយភាពជាទុក្ខ ពិចារណា ១ ដង រមែង

កំណត់ដោយភាពជាអនត្តា ពិចារណា ១ ផង ដូច្នេះ ភិក្ខុនោះ កាលមិនពិចារណារឿយៗ យ៉ាងនេះថា អ្វីៗ ក្នុងលោកមិនគួរប្រកាន់មាំ ដូច្នេះ អ្វីៗ សូម្បីធម៌មួយក្នុងធម៌ទាំងឡាយ មានរូបជាដើម ក្នុងលោក ដែលផ្សេងដោយខន្ធលោកជាដើម មិនគួរប្រកាន់មាំថា ជាអត្តា ឬកើតក្នុងអត្តា ដូច្នេះ ។ បទថា អនុបាទិយំ ន បរិតស្សតិ សេចក្តីថា ភិក្ខុកាលមិនប្រកាន់មាំ រមែងមិនតក់ស្លុត សូម្បីដោយសេចក្តីតក់ស្លុត គឺតណ្ហា ទិដ្ឋិ និងមានះ ។ បទថា អបរិតស្សំ គឺ កាលមិនតក់ស្លុត ។ បទថា បច្ចត្តញ្ញេវ បរិនិព្វាយតិ សេចក្តីថា រមែងបរិនិព្វានដោយការរលត់កិលេសដោយខ្លួនឯង ។ ព្រះមានព្រះភាគត្រាស់ថា ខីណា ជាតិ ដូច្នេះជាដើម ដើម្បីទ្រង់សម្តែងដល់ការប្រព្រឹត្តទៅនៃបច្ចវេក្ខណៈ របស់អ្នកបរិនិព្វានហើយយ៉ាងនេះ ។

បទថា ឥតិ សា ទិដ្ឋិ សេចក្តីថា ទិដ្ឋិរបស់ព្រះអរហន្តអ្នករួចផុតហើយ យ៉ាងនោះឈ្មោះថា ទិដ្ឋិយ៉ាងនេះ បាលីថា ឥតិស្ស ទិដ្ឋិ ដូច្នេះខ្លះ ។ អធិប្បាយថា អ្នកនោះជាអ្នកឆ្ងាយចាកកិលេស ជាអ្នករួចផុតហើយយ៉ាងនោះ គប្បីមានទិដ្ឋិយ៉ាងនេះ ។ បទថា តទកល្លំ គឺ សេចក្តីនោះមិនសមប្រកប ។ ព្រោះហេតុអ្វី ។ ព្រោះកាលយ៉ាងនោះ គួរពោលថា ព្រះអរហន្ត រមែងមិនដឹងអ្វីៗ គ្រាដឹងយ៉ាងនេះហើយ មិនគួរពោលនឹងព្រះអរហន្តដែលរួចផុតហើយថា មិនដឹងអ្វីៗ ។ ដោយហេតុនោះឯង ក្នុង

ទីបំផុតនៃន័យ សូម្បី ៤ យ៉ាង ព្រះមានព្រះភាគទើបត្រាស់ថា តំ កិស្ស ហេតុ ដូច្នេះ ។

បទថា យាវតានន្ទ អធិវចនំ សេចក្ដីថា មានវោហារ ពោលគឺ ឈ្មោះដរាបណា ។ បទថា យាវតា អធិវចនបថោ គឺ ជាផ្លូវនៃឈ្មោះប្រព្រឹត្តទៅដរាបណា ។ ខន្ធ អាយតនៈ ឬធាតុ នៅមាន ។ ក្នុងទីទាំងអស់មានន័យនេះ ។ បទថា បញ្ញាវចរំ គឺ ខន្ធបញ្ចកៈដែលកំណត់ដឹងដោយបញ្ញា ។ បទថា តទភិញ្ញា គឺ ព្រោះដឹងក្រៃលែងនូវវដ្ដៈនោះ ។ ដោយហេតុត្រឹមតែប៉ុណ្ណេះ ព្រះមានព្រះភាគទ្រង់សម្ដែងអ្វី ។ ទ្រង់សម្ដែងអនុសន្ធិរបស់បទ ពោលពីការស្មុគស្មាញ ដូចអំបោះរបស់ជាងតម្បាញ ។

## ពោលអំពីវិញ្ញាណដ្ឋិតិ ៧

**[៦៥]** ឥឡូវនេះ អ្នកដែលលោកពោលថា មិនបញ្ញត្តិ ព្រោះមិននៅ ឈ្មោះថា រួចផុតអំពីចំណែកទាំងពីរ មួយទៀត អ្នកដែលលោកពោលថា មិនពិចារណាឃើញ ព្រោះទៅហើយ ឈ្មោះថា ផុតដោយបញ្ញា ដូច្នោះ ដើម្បីទ្រង់សម្ដែងបទសរុប និងឈ្មោះរបស់ភិក្ខុទាំង ២ ពួក ដែលពោលហើយទាំងនោះ ទើបត្រាស់ពាក្យជាអាទិថា ម្នាលអានន្ទ វិញ្ញាណដ្ឋិតិនេះមាន ៧ ។

ក្នុងបទទាំងនោះ បទថា សត្តា លោកពោលដោយអំណាចបដិសន្ធិ ។

វិញ្ញាណដ្ឋិតិ ៤ លោកពោលទុកដោយអំណាចនៃអារម្មណ៍ នឹងមកក្នុងសង្គីតិសូត្រ ។ ឈ្មោះថា វិញ្ញាណដ្ឋិតិ ព្រោះមានវិញ្ញាណតាំងនៅ ។

បទថា វិញ្ញាណដ្ឋិតិ នេះ ជាឈ្មោះនៃទីកន្លែងដែលវិញ្ញាណតាំងនៅ ។ បទថា ទ្វេ អាយតនានិ គឺ ទីនៅអាស្រ័យ និងទីតាំង ២ ។ ក៏ពាក្យថា អាយតនៈ ក្នុងទីនេះ លោកប្រាថ្នាយកទីនៅអាស្រ័យ ។ ដោយហេតុនោះឯង លោកនឹងពោលដល់អាយតនៈ ២ គឺ អសញ្ញីសត្តាយតនៈ ទីនៅរបស់សត្វអ្នកមិនមានសញ្ញា នេវសញ្ញានាសញ្ញាយតនៈ ទីនៅរបស់សត្វមានសញ្ញាក៏មិនមែនមិនមានសញ្ញាក៏មិនមែន ។ សួរថា ក៏ព្រោះហេតុអ្វី លោកទើបកាន់យកអាយតនៈនេះទាំងអស់ ។ ឆ្លើយថា ដើម្បីរក្សាវដ្តៈ ។ ពិតហើយ វដ្តៈ រមែងមិនដល់ការរក្សាដោយអំណាចវិញ្ញាណដ្ឋិតិដែលបរិសុទ្ធិ ឬដោយអំណាចអាយតនៈបរិសុទ្ធិ តែរមែងដល់ការរក្សាដោយអំណាចកព កំណើត គតិ និងសត្តាវាស ព្រោះដូច្នោះ លោកទើបកាន់យកអាយតនៈនេះទាំងអស់ ។ ឥឡូវនេះ ព្រះសាស្តា កាលនឹងទ្រង់ចែកសេចក្តីនោះដោយលំដាប់ ទើបត្រាស់ពាក្យ ជាអាទិថា កតមា សត្តដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា សេយ្យថាបិ ជានិបាតក្នុងអត្ថថា ឧបមា , ប្រែថា **ដូច** ។ អធិប្បាយថា ដូចជាមនុស្ស ដូច្នេះ ។ ពិតហើយ ក្នុងចក្រវាឡដែលរកប្រមាណមិនបាន ដូចមួយមិនមានពីរ ដោយអំណាចនៃ

វណ្ណៈ និងសណ្ឋានជាដើម របស់មនុស្សដែលរកប្រមាណមិនបាន ។ សេចក្តីប្លែកគ្នាដោយអាការជាដើមថា ការសម្លឹងមើល ការក្រឡេកមើល ការនិយាយ ការសើច ការដើរ និងការឈរ រមែងមានត្រឹមនេះ បងប្អូនជាកូនភ្លោះក្នុងទីណាៗ រមែងដូចគ្នាដោយវណ្ណៈ ឬដោយទ្រង់ទ្រាយ ព្រោះដូច្នោះ លោកទើបពោលថា ឆានត្តកាយា **មានកាយផ្សេងគ្នា** ។ តែបដិសន្ធិវិញ្ញាណរបស់សត្វទាំងនោះមានហេតុ ២ ខ្លះ មានហេតុ ៣ ខ្លះ មិនមានហេតុខ្លះ ព្រោះដូច្នោះ លោកទើបពោលថា មានសញ្ញាផ្សេងគ្នា ។

បទថា ឯកច្ចេ ច ទេវា គឺ ទេវតាជាន់ឆកាមាវចរ ។ ក៏ក្នុងទេវតាទាំងនោះ ពួកខ្លះមានវណ្ណៈខៀវ ពួកខ្លះមានវណ្ណៈលឿងជាដើម ។ តែសញ្ញារបស់ទេវតាទាំងនោះ មានហេតុ ២ ខ្លះ មានហេតុ ៣ ខ្លះ មិនមានហេតុខ្លះ ។

បទថា ឯកច្ចេ ច វិនិបាតិកា សេចក្តីថា វេមានិកប្រេត មានជាអាទិយ៉ាងនេះថា យក្ខិណី ឈ្មោះ ឧត្តរមាតា បិយង្ករមាតា ផុស្សមិត្តា ធម្មគុត្តា អ្នកនៅក្នុងអបាយ ៤ ក៏កាយរបស់ប្រេតទាំងនោះផ្សេងៗ គ្នា ដោយអំណាចពណ៌ មានពណ៌លឿង ពណ៌ស ពណ៌ខ្មៅ ពណ៌មាស ពណ៌ស្រអាប់ជាដើម និងដោយអំណាចការស្គម ធាត់ ខ្ពស់ និងទាប ។ សូម្បីសញ្ញាក៏មាន ដោយអំណាចទ្វិហេតុកៈ តិហេតុកៈ និងអហេតុកៈ ដូចមនុស្សទាំងឡាយ ។ ក៏ប្រេតទាំងនោះ មិនមានសក្តិធំដូចទេវតា មាន

សត្តតូចដូចមនុស្សកំព្រា របស់ស៊ី សំពត់អាវ រកបានដោយលំបាក ត្រូវទុក្ខបៀតបៀន ។ ពួកខ្លះ បានទទួលទុក្ខក្នុងខាងរនោច បានទទួលសុខក្នុងខាងខ្នើត ព្រោះដូច្នោះ លោកទើបពោលថា វិនិបាតិកៈ ព្រោះជាអ្នកធ្លាក់ទៅអំពីការសន្សំសេចក្តីសុខ ។ ក៏ក្នុងប្រេតទាំងនេះ សូម្បីការត្រាស់ដឹងធម៌ ក៏រមែងមាន បានដល់ ប្រេតពួកតិហេតុកៈ ។ ក៏យក្ខិណីឈ្មោះបិយង្ករមាតា បានស្តាប់ព្រះអនុរុទ្ធត្ថេរ សម្តែងធម្មបទនៅក្នុងវេលាជិតភ្លឺ លួងលោមបុត្រតូចយ៉ាងនេះថា ៖

ម្នាលបិយង្ករៈ ភិក្ខុកំពុងពោលធម្មបទ ម្យ៉ាងទៀត យើងដឹងធម្មបទហើយ នឹងប្រតិបត្តិដើម្បីប្រយោជន៍របស់យើង សេចក្តីនោះគប្បីមាន យើងគប្បីសង្រួមក្នុងសត្វទាំងឡាយ មិនគប្បីពោលកុហកទាំងដឹងខ្លួន គប្បីសិក្សាក្នុងភាពជាអ្នកមានសីលរបស់ខ្លួន យើងក៏នឹងរួចផុតអំពីកំណើតបិសាចដូច្នេះ ។ ហើយបានសម្រេចសោតាបត្តិផលក្នុងថ្ងៃនោះឯង ។

បទថា ព្រហ្មកាយិកា បានដល់ ព្រហ្មបារិសជ្ជា ព្រហ្មបុរោហិតា មហាព្រហ្មា ។ បទថា បឋមាភិនិព្វត្តា បានដល់ ពួកទេវតាទាំងអស់នោះ កើតដោយបឋមឈាន ។ ក៏ក្នុងបណ្តាទេវតាទាំងនោះ ព្រហ្មបារិសជ្ជា កើតហើយ ដោយគុណបន្តិចបន្តួច ។ ព្រហ្មបារិសជ្ជាទាំងនោះ អាយុប្រមាណ ៣ ចំណែករបស់កប្ប ព្រហ្មបុរោហិត កើតហើយដោយគុណ

កណ្តាល អាយុប្រមាណកន្លះកប្ប និងកាយរបស់ព្រហ្មបុរោហិតនោះ ល្អ ស្អាតជាង ។ មហាព្រហ្មកើតដោយគុណដ៏ប្រណីត អាយុប្រមាណ ១ កប្ប ។ កាយរបស់ទេវតាទាំងនោះ ល្អស្អាតក្រៃលែងណាស់ ។ ដោយប្រការដូច្នេះ គប្បីជ្រាបថា ទេវតាទាំងនោះ មានកាយផ្សេងគ្នា មានសញ្ញាដូចគ្នា ព្រោះកាយផ្សេងគ្នា ព្រោះសញ្ញាដូចគ្នា ដោយអំណាចបឋមឈាន ។ សត្វទាំងឡាយក្នុងអបាយ ៤ ក៏ដូចទេវតាទាំងនោះ ។

ក៏ក្នុងនរក អត្តភាពរបស់សត្វពួកខ្លះមួយគាវុត ពួកខ្លះកន្លះយោជន៍ ពួកខ្លះមួយយោជន៍ ។ តែអត្តភាពរបស់ភិក្ខុទេវទត្ត ១០០ យោជន៍ ។ សូម្បីក្នុងតិរច្ឆានទាំងឡាយ ពួកខ្លះតូច ពួកខ្លះធំ ។ ក្នុងប្រេតវិស័យ ពួកខ្លះ ៦០ ហត្ថ , ពួកខ្លះ ៧០ ហត្ថ , ពួកខ្លះ ៨០ ហត្ថ ពួកខ្លះសម្បុរល្អ ពួកខ្លះសម្បុរមិនល្អ ។ កាលញ្ជិកាសុរ ក៏ដូច្នោះ ។ ម្យ៉ាងទៀត ក្នុងបណ្តាប្រេតទាំងនេះ ទីឃបិដ្ឋិកប្រេតខ្ពស់ដល់ទៅ ៦០ យោជន៍ ។ តែសញ្ញារបស់ប្រេតសូម្បីទាំងអស់ ជាអហេតុកៈ ផ្នែកខាងអកុសលវិបាក ។ ដោយប្រការដូច្នេះ សូម្បីសត្វក្នុងអបាយ រមែងរាប់បានថា មានកាយផ្សេងគ្នា មានសញ្ញាដូចគ្នា ដូច្នេះ ។

បទថា អាភស្សរា សេចក្តីថា រស្មីអំពីសរីរៈរបស់ទេវតាទាំងនោះ ដូចអណ្តាតគប់ភ្លើងជាដើម ផ្សាយចេញដាច់ៗ ហើយធ្លាក់ ព្រោះហេតុនោះ ទើបឈ្មោះថា **អាភស្សរា** ។ ក្នុងព្រហ្មទាំងនោះ ព្រហ្មដែលចម្រើន

គុណបន្តិចបន្តួច មាន ២ ឈាន គឺ ទុតិយឈាន និងតតិយឈាន ក្នុង ចតុកន័យ និងបញ្ចកន័យ កើតឡើងហើយ ឈ្មោះថា **បរិត្តាភា** ។ ប្រមាណអាយុរបស់ព្រហ្មបរិត្តាភាទាំងនោះ ២ កប្ប ។ អ្នកចម្រើនគុណកណ្តាលកើតឡើងហើយ ឈ្មោះថា **អប្បមាណាភា** ។ ប្រមាណអាយុរបស់ព្រហ្មអប្បមាណាភាទាំងនោះ ៤ កប្ប ។ អ្នកចម្រើនគុណប្រណីតពិត កើតឡើងហើយ ឈ្មោះ **អាភស្សរា** ។ ប្រមាណអាយុរបស់អាភស្សរាទាំងនោះ ៨ កប្ប ។ ក៏ក្នុងទីនេះ លោកកំណត់យកទេវតាទាំងអស់នោះ ដោយអំណាចការកំណត់យ៉ាងឧក្រិដ្ឋ ។ កាយរបស់ទេវតាទាំងនោះ សុម្បីទាំងអស់មានភាពល្អស្អាតដូចគ្នាពិត ។ តែសញ្ញាត្រឹមតែមិនមានវិតក្ក តែមានវិចារ ឬមិនមានទាំងវិតក្ក មិនមានទាំងវិចារ ព្រោះហេតុនោះ ទើបផ្សេងគ្នា ។

បទថា សុភកិណ្ហា គឺ ផ្សព្វផ្សាយពាសពេញទៅដោយសេចក្តីល្អ ។ អធិប្បាយថា មានសេចក្តីណែនក្រាស់ជាប់គ្នា ដោយពន្លឺនៃរស្មីក្នុងសរីរៈដែលល្អ ក៏ប៉ុន្តែថា រស្មីនៃទេវសុភកិណ្ហាទាំងនោះមិនដាច់ៗ ហើយបាញ់ទៅដូចរស្មីរបស់អាភស្សរាព្រហ្ម ។ តែក្នុង បញ្ចកន័យ ទេវកើតជាបរិត្តសុភា ។ ទេវអប្បមាណសុភា ។ ទេវសុភកិណ្ហា មានអាយុ ១៦ កប្ប , ៣២ កប្ប , ៦០ កប្ប ដោយអំណាចចតុត្ថឈានខ្សោយ កណ្តាល និងប្រណីត ។ ដោយប្រការដូច្នេះ ទេវតាទាំងនោះសុម្បីទាំងអស់ គប្បី

ប្រាបថា មានកាយដូចគ្នា និងមានសញ្ញាដូចគ្នា ដោយសញ្ញានៃចតុត្ថ-ឈាន ដូច្នេះ ។ មួយទៀត សុទ្ធាវាសព្រហ្ម ក៏រួមចូលនឹងវិញ្ញាណ-ដ្ឋិតិទី ៤ ដូចគ្នា ។ សត្វមិនមានសញ្ញា ព្រោះមិនមានវិញ្ញាណ មិនសង្គ្រោះចូលក្នុងវិញ្ញាណដ្ឋិតិនេះ តែសង្គ្រោះ ចូលក្នុងសត្តាវាស ។ សុទ្ធាវាសព្រហ្ម តាំងនៅក្នុងចំណែកវិវដ្ដៈ មិនកំណត់កាលទាំងពួង ក៏មិនកើតក្នុងលោកដែលសូន្យចាកព្រះពុទ្ធ ១ សែនកប្បខ្លះ មួយអសង្ខេយ្យខ្លះ កាលព្រះពុទ្ធទ្រង់ឧប្បត្តិក្នុងចន្លោះ ១៦,០០០ កប្បនោះឯង ទើបកើត រមែងដូចគ្នានឹងទីតាំងបន្ទាយរបស់ព្រះមានព្រះភាគ ដែលញ៉ាំងធម្មចក្រឲ្យប្រព្រឹត្តទៅហើយ ព្រោះដូច្នោះ សុទ្ធាវាសព្រហ្ម ទើបមិនរួមចូលនឹងវិញ្ញាណដ្ឋិតិ មិនរួមចូលនឹងសត្តាវាស ។ តែព្រះមហាសិវត្ថេរពោលថា សុទ្ធាវាសព្រហ្ម ក៏នៅតែរួមចូលនឹងវិញ្ញាណដ្ឋិតិទី ៤ សត្តាវាសទី ៤ នោះឯង ដោយព្រះសូត្រនេះថា ៖

> ម្នាលសារីបុត្រ សត្តាវាស ដែលតថាគតមិនធ្លាប់នៅហើយដោយកាលវែងនេះ វៀរលែងទេវសុទ្ធាវាស មិនជាទីកន្លែងដែលមិនកើត មិនមាន ដូច្នេះ ។

ឃើញដោយព្រះសូត្រនោះ ព្រោះព្រះសូត្រលោកមិនហាមទុក ។

សេចក្ដីនៃបទជាអាទិថា សព្វសោ រូបសញ្ញានំ លោកពោលទុកហើយក្នុងវិសុទ្ធិមគ្គ ។ ក៏នេវសញ្ញានាសញ្ញាយតនៈ មានវិញ្ញាណក៏មិន

មែន មិនមានវិញ្ញាណក៏មិនមែន ព្រោះសុខុមវិញ្ញាណល្អិត ដូចសភាពល្អិតតូចរបស់សញ្ញា ព្រោះដូច្នោះ លោកទើបមិនពោលក្នុងវិញ្ញាណដ្ឋិតិ ហើយពោលទុកក្នុងអាយតនៈ ។

បទថា តត្រ គឺ ក្នុងវិញ្ញាណដ្ឋិតិទាំងនោះ ។ បទថា តញ្ច បជានាតិ គឺ រមែងដឹងវិញ្ញាណដ្ឋិតិនោះ ។ បទថា តស្សា ច សមុទយំ សេចក្ដីថា រមែងដឹងការកើតឡើងនៃវិញ្ញាណដ្ឋិតិនោះ ដោយន័យជាអាទិថា ព្រោះអវិជ្ជាកើត រូបទើបកើត ដូច្នេះ ។ បទថា តស្សា ច អត្ថង្គមំ សេចក្ដីថា រមែងដឹងការរលត់នៃវិញ្ញាណដ្ឋិតិនោះ ដោយន័យជាអាទិថា ព្រោះអវិជ្ជារលត់ រូបទើបរលត់ ដូច្នេះ ។ បទថា អស្សាទំ សេចក្ដីថា រមែងដឹងសេចក្ដីពេញចិត្តរបស់វិញ្ញាណដ្ឋិតិនោះ យ៉ាងនេះថា សេចក្ដីសុខសោមនស្ស រមែងកើតឡើងព្រោះអាស្រ័យ រូប វេទនា សញ្ញា សង្ខារ វិញ្ញាណណា នេះគឺ សេចក្ដីពេញចិត្តនៃវិញ្ញាណ ។ បទថា អាទីនវំ សេចក្ដីថា រមែងដឹងទោសវិញ្ញាណដ្ឋិតិនោះ យ៉ាងនេះថា រូប វេទនា សញ្ញា សង្ខារ វិញ្ញាណណា មិនទៀង ជាទុក្ខ មានសេចក្ដីប្រែប្រួលទៅជាធម្មតា នេះគឺ ទោសនៃវិញ្ញាណ ។ បទថា និស្សរណំ សេចក្ដីថា ការនាំចេញនូវឆន្ទរាគៈ ការលះឆន្ទរាគៈ ក្នុងរូប វេទនា សញ្ញា សង្ខារ វិញ្ញាណណានេះ គឺ ឧបាយជាគ្រឿងនាំចេញទៅនៃវិញ្ញាណ ដូច្នោះ រមែងដឹងវិញ្ញាណដ្ឋិតិនោះយ៉ាងនេះ ។ បទថា កល្លំ នុ តេន សេចក្ដីថា ភិក្ខុ

នោះគួរដល់ការកើតកើន វិញ្ញាណដ្ឋិតិនោះ ថាយើង ថារបស់យើង ដោយអំណាចនៃតណ្ហា មានះ និងទិដ្ឋិ ទៀតឬ ។ គប្បីជ្រាបសេចក្តីក្នុងទីទាំងពួងដោយឧបាយនេះ ។ ក៏ប៉ុន្តែថា គប្បីប្រកបសមុទ័យជាដើម ដោយអំណាចនៃខន្ធទាំងឡាយ ៤ ក្នុងទីដែលមិនមានរូប ដោយអំណាចនៃខន្ធមួយ ក្នុងទីដែលមិនមានវិញ្ញាណ ។ ក្នុងទីនេះ មួយទៀតមិនគប្បីប្រកបបទនេះថា ព្រោះអាហារកើត ព្រោះអាហាររលត់ ដូច្នេះ ។

បទថា យតោ ខោ អានន្ទ ភិក្ខុ សេចក្តីថា ម្នាលអានន្ទ កាលណាភិក្ខុ ។ បទថា អនុបាទា វិមុត្តោ សេចក្តីថា ជាអ្នករួចផុតព្រោះមិនប្រកាន់មាំដោយឧបាទាន ៤ ។ បទថា បញ្ញាវិមុត្តោ សេចក្តីថា ជាអ្នករួចផុតដោយបញ្ញា ។ អធិប្បាយថា មិនបានធ្វើឲ្យច្បាស់នូវវិមោក្ខ ៨ តែធ្វើនាមកាយ និងរូបកាយ ឲ្យប្រព្រឹត្តទៅមិនបាន ដោយកម្លាំងបញ្ញានោះឯង ឈ្មោះថា ជាអ្នករួចផុតហើយ ។ ភិក្ខុដែលរួចផុតហើយនោះមាន ៥ យ៉ាង គឺ ជាសុក្ខវិបស្សក: និងតាំងនៅក្នុងបឋមឈានជាដើមយ៉ាងណាមួយ ហើយសម្រេចព្រះអរហត្ត ដូចដែលលោកពោលសេចក្តីនេះទុកថា ក៏បុគ្គលពួកណាជាបញ្ញាវិមុត្តិ បុគ្គលខ្វះក្នុងលោកនេះ មិនបានពាល់ត្រូវវិមោក្ខ ៨ ដោយកាយទេ តែអាសវៈទាំងឡាយរបស់គេអស់ទៅព្រោះឃើញដោយបញ្ញា បុគ្គលនេះ លោកពោលថា ជាបញ្ញាវិមុត្តិ ដូច្នេះ ។

## ពោលអំពីវិមោក្ខ ៨

[៦៦] ព្រះមានព្រះភាគទ្រង់សម្តែងបទសរុប និងនាមរបស់ភិក្ខុមួយរូបយ៉ាងនេះហើយ ដើម្បីទ្រង់សម្តែងដល់ភិក្ខុក្រៅនេះ ទើបត្រាស់ថា អដ្ឋ ខោ ឥមេ ដូច្នេះជាដើម ។

ក្នុងបទទាំងនោះ បទថា វិមោក្ខា សួរថា ឈ្មោះថា វិមោក្ខ ដោយអត្ថថា ដូចម្តេច ? ឆ្លើយថា ដោយអត្ថថា រួចផុត សួរថា វិមោក្ខនេះ មានអត្ថថា រួចផុត តើដូចម្តេច ? ឆ្លើយថា មានអត្ថថា រួចផុតដោយល្អអំពីធម៌ជាសត្រូវ និងរួចផុតដោយល្អ ដោយអំណាចសេចក្តីត្រេកអរក្នុងអារម្មណ៍ ។ លោកអធិប្បាយថា **វិមោក្ខ** រមែងប្រព្រឹត្តទៅក្នុងអារម្មណ៍ ព្រោះអស់សេចក្តីសង្ស័យ ដោយសេចក្តីមិនប្រកាន់ ដូចទារកអ្នកបញ្ចេញអវយវៈតូចធំដេកលើភ្លៅរបស់បិតា ។ ក៏សេចក្តីនេះមិនមានក្នុងវិមោក្ខពេលខាងក្រោយ តែមានក្នុងផ្នែកខាងដើមទាំងអស់ ។

ក្នុងបទថា រូបី រូបានិ បស្សតិ នេះ មានសេចក្តីថា រូប ជារូបឈានដែលធ្វើឲ្យកើតឡើង ដោយអំណាចនីលកសិណជាដើម ក្នុងសក់ជាដើមខាងក្នុង ឈ្មោះថា **រូបី** ។ ព្រោះមានរូបឈាន ដោយបទនេះ លោកសម្តែងរូបាវចរឈាន ៤ ដល់បុគ្គលដែលធ្វើឈានឲ្យកើតក្នុងកសិណទាំងឡាយ ដែលមានវត្ថុខាងក្នុង ។

បទថា អជ្ឈត្តំ អរូបសញ្ញី គឺ មិនមានសេចក្ដីសម្គាល់ក្នុងរូបខាងក្នុង សេចក្ដីថា មិនធ្វើរូបាវចរឈានឲ្យកើតក្នុងអាការ ៣២ មានសក់ជាដើមរបស់ខ្លួន ។ បទថា ពហិទ្ធា រូបានិ បស្សតិ សេចក្ដីថា រមែងមាន

ជារូប មាននីលកសិណជាដើម សូម្បីខាងក្រៅដោយញាណចក្ខុ ។ ដោយបទនេះ លោកធ្វើបរិកម្មខាងក្រៅហើយ សម្ដែងរូបាវចរឈាន ៤ នៃឈានដែលធ្វើឲ្យកើតហើយខាងក្រៅ ។

លោកសម្ដែងឈានក្នុងវណ្ណកសិណ មានពណ៌ខៀវជាដើម ដែលបរិសុទ្ធិល្អហើយ ដោយបទនេះថា សុភន្តេវ អធិមុត្តោ ហោតិ ដូច្នេះ ក្នុងបទនោះ មិនមានការធ្វើទុកក្នុងចិត្តថា ល្អក្នុងអប្បនាខាងក្នុង ក៏ពិតមែន ប៉ុន្តែអ្នកដែលធ្វើកសិណដែលល្អបរិសុទ្ធិហើយនោះ រមែងជាអ្នកគួរពោលបានថា អ្នកដែលបង្អោនចិត្តជឿថា កសិណជារបស់ល្អយ៉ាងនេះ ដូច្នោះ លោកទើបសម្ដែងយ៉ាងនេះ ។ តែក្នុងបដិសម្ភិទាមគ្គ លោកពោលថា វិមោក្ខ ក្នុងបទថា អ្នកដែលបង្អោនចិត្តជឿថា កសិណល្អដូចម្ដេច ភិក្ខុក្នុងធម្មវិន័យនេះ មានចិត្តសហគតៈដោយមេត្តា ផ្សាយទៅកាន់ទិសមួយ ។ល។ ព្រោះជាអ្នកចម្រើនមេត្តា សត្វទាំងឡាយ ទើបមិនជាអ្នកគួរស្អប់ មានចិត្តសហគតៈដោយករុណា មុទិតា ឧបេក្ខា ផ្សាយទៅកាន់ទិសមួយ ។ល។ ព្រោះជាអ្នកចម្រើនឧបេក្ខា សត្វទាំងឡាយ ទើបជាអ្នកមិនគួរស្អប់

វិមោក្ខក្នុងបទថា អ្នកដែលបង្អោនចិត្តជឿថា កសិណជារបស់ល្អយ៉ាងនេះ ដូច្នេះ ។

ក្នុងបទថា សត្តសោ រូបសញ្ញានំ ជាដើម បទទាំងអស់ដែលគួរពោល លោកពោលទុកហើយក្នុងវិសុទ្ធិមគ្គនោះឯង ។ បទថា អយំ អដ្ឋមោ វិមោក្ខោ សេចក្តីថា នេះឈ្មោះវិមោក្ខ ដែលខ្ពស់បំផុតប្រការទី ៨ ព្រោះខន្ធ ៤ បរិសុទ្ធិដោយប្រការទាំងពួង ព្រោះដែលរួចផុតហើយ ។ បទថា អនុលោមំ គឺ តាំងពីបទដើម ដរាបដល់បទចុងក្រោយ ។

បទថា បដិលោមំ គឺ តាំងពីបទចុង ដរាបដល់បទដើម ។ បទថា អនុលោមបដិលោមំ នេះ លោកពោលដោយអំណាចនៃសមាបត្តិមិនតាំងមាំ ព្រោះជំនាញពេកទៅ វិលទៅផ្លូវឯណោះវិលទៅផ្លូវនេះ ។ បទថា យត្ថិច្ឆកំ គឺ សម្តែងដល់ឱកាស សេចក្តីថា ប្រាថ្នាក្នុងឱកាសណាៗ ។ បទថា យទិច្ឆកំ គឺ សម្តែងដល់សមាបត្តិ បានដល់ ប្រាថ្នាសមាបត្តិណាៗ ។ បទថា យាវតិច្ឆកំ គឺ សម្តែងដល់ការកំណត់ផ្លូវឆ្ងាយ បានដល់ ប្រាថ្នាផ្លូវឆ្ងាយប្រមាណត្រឹមណា ។ បទថា សមាបជ្ជតិ គឺ ចូលកាន់សមាបត្តិនោះៗ ។ បទថា វុដ្ឋាតិ គឺ ចេញចាកសមាបត្តិនោះ ហើយតាំងនៅ ។

បទថា ឧភតោភាគវិមុត្តោ សេចក្តីថា រួចផុតដោយចំណែកទាំងពីរ គឺ រួចផុតពីរូបកាយដោយអរូបសមាបត្តិ ផុតពីនាមកាយដោយមគ្គ ។ ដូចដែលលោកពោលទុកដូច្នេះថា ៖

អច្ចិ យថា វាតវេគេន ខិត្តា (ឧបសីវាតិ ភគវា) អត្ថំ បលេតិ ន ឧបេតិ សង្ខំ ឯវំ មុនី នាមកាយា វិមុត្តោ អត្ថំ បលេតិ ន ឧបេតិ សង្ខំ ។

*ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ថា ម្នាលឧបសីវៈ មុនីរួចផុតហើយអំពីនាមកាយ រមែងដល់នូវការតាំងនៅមិនបាន រមែងមិនចូលដល់នូវការរាប់ ដូចអណ្តាតភ្លើងត្រូវកម្លាំងខ្យល់បក់ រមែងដល់នូវការតាំងនៅមិនបាន រមែងមិនដល់នូវការរាប់ដូច្នោះ ។*

ក៏ភិក្ខុនេះរួចផុតហើយ ដោយចំណែកទាំងពីរ ចេញចាកអាកាសានញ្ចាយតនៈជាដើមយ៉ាងណាមួយ ហើយសម្រេចព្រះអរហត្ត និងជាអនាគាមី ចេញចាកនិរោធហើយ សម្រេចព្រះអរហត្ត រួមជា ៥ យ៉ាង ។ តែអាចារ្យពួកខ្លះពោលថា ព្រោះសុម្បីរូបាវចរចតុត្ថឈាន ក៏សហគតៈដោយឧបេក្ខា មានអង្គពីរ សូម្បីអរូបាវចរឈានក៏ដូច្នោះដែរ ដូច្នោះភិក្ខុចេញចាករូបាវចរចតុត្ថឈាន សូម្បីសម្រេចព្រះអរហត្ត ក៏ឈ្មោះថាឧភតោភាគវិមុត្តិ ដូច្នេះ ។ ក៏បញ្ហាឧភតោភាគវិមុត្តិនេះ តាំងឡើងសូម្បីខាងក្រោមលោហប្រាសាទ អាស្រ័យការពណ៌នារបស់ព្រះចូឡសុមនត្ថេរអ្នកទ្រទ្រង់ព្រះត្រៃបិដកអស់កាលយូរ ទើបដល់ការសម្តែងយ៉ាងជាច់ខាត ។

មានរឿងថា ក្នុងគិរីវិហារ អន្តេវាសិករបស់ព្រះថេរៈស្តាប់បញ្ហា

នោះ អំពីមាត់របស់ភិក្ខុដែលកាន់បិណ្ឌបាតិកវត្តមួយរូប ហើយពោលថា ម្នាលអាវុសោ កាលអាចារ្យរបស់យើង អធិប្បាយធម៌ក្នុងខាងក្រោមលោហ-ប្រាសាទដែលនរណាៗ មិនធ្លាប់ស្តាប់ហើយ ពួកភិក្ខុទើបសួរថា លោកដ៏ចម្រើន ក៏ព្រះថេរៈបានពោលយ៉ាងណា អន្តេវាសិកឆ្លើយថា ម្នាលអាវុសោព្រះថេរៈបានពោលថា រូបាវចរចតុត្ថឈានសហគតៈដោយឧបេក្ខាមានអង្គពីរ រមែងគ្របសង្កត់កិលេសបានក៏ពិត តែទោះជាយ៉ាង នោះ រូបាវចរចតុត្ថឈាន រមែងកម្រើកក្នុងឋានៈនៃរូបារម្មណ៍ សូម្បីជាចំណែកជិតនៃកិលេសទាំងឡាយ ព្រោះធម្មតាកិលេសទាំងនេះ ចូលទៅអាស្រ័យអារម្មណ៍ ក្នុងនីលកសិណជាដើមយ៉ាងណាមួយ ក្នុងកពជាន់ក្រោមទាំង ៥ រមែងកម្រើក មួយទៀត រូបាវចរឈាន រមែងមិនឈានទៅកាន់អារម្មណ៍នោះ ព្រោះដូច្នោះ ភិក្ខុផ្លាស់រូបដោយប្រការទាំងពួង ហើយគ្របសង្កត់កិលេសដោយអំណាចអរូបឈានហើយ ទើបសម្រេចព្រះអរហត្ត ជាឧភតោ-ភាគវិមុត្តិ ដូច្នេះ ក៏ព្រះថេរៈគ្រាពោលពាក្យនេះហើយ ទើបនាំសូត្រនេះមកថា ក៏បុគ្គលពួកណាជាឧភតោភាគវិមុត្តិ បុគ្គលខ្លះក្នុងលោកនេះ សម្ផស្សវិមោក្ខ ៨ ដោយកាយហើយ និងអាសវៈរបស់បុគ្គលនោះអស់ទៅ ព្រោះឃើញដោយបញ្ញា បុគ្គលនេះ លោកពោលថា ជាឧភតោភាគវិមុត្តិ ដូច្នេះ ។ បទថា អានន្ទ ឥមាយ ច ឧភតោភាគវិមុត្តិយា សេចក្តីថា ម្នាលអានន្ទ ឧភតោភាគវិមុត្តិដទៃអំពីឧភតោភាគវិមុត្តិនេះ ។ បទដ៏សេសមានសេចក្តី

ឆាយក្នុងទីទាំងពួង ។

ចប់ អដ្ឋកថា មហានិទានសូត្រ ទី ២

# អដ្ឋកថា មហាបរិនិព្វានសូត្រ ទី ៣

## និទានកថា

[៦៧] មហាបរិនិព្វានសូត្រ ចាប់ផ្តើមថា ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ។

ពណ៌នាសេចក្តីតាមលំដាប់បទក្នុងមហាបរិនិព្វានសូត្រនោះ ដូចតទៅនេះ ៖

បទថា គិជ្ឈកូដេ សេចក្តីថា លើភ្នំឈ្មោះថា គិជ្ឈកូដ ព្រោះមានហ្វូងសត្វត្មាតនៅលើកំពូល ឬមានកំពូលស្រដៀងសត្វត្មាត ។ បទថា អភិយាតុកាមោ បានដល់ ស្តេចមានព្រះបំណងនឹងយាត្រាទ័ព ដណ្តើមដែនវជ្ជី ។ បទថា វជ្ជី បានដល់ ពួក ស្តេចវជ្ជី ។ បទថា ឯវំមហិទ្ធិកេ បានដល់ ប្រកបដោយរាជឫទ្ធិដ៏ធំយ៉ាងនេះ ។ ព្រះបាទអជាតសត្តុ ត្រាស់ដល់ភាវៈដែលស្តេចវជ្ជីទាំងនោះសាមគ្គីគ្នា ដោយព្រះតម្រាស់នេះ ។ បទថា ឯវំមហានុភាវេ បានដល់ ប្រកបដោយអានុភាពច្រើនយ៉ាងនេះ ។ ព្រះបាទអជាតសត្តុ ត្រាស់ដល់ភាវៈដែលស្តេចវជ្ជីទាំងនោះ ទ្រង់សិក្សាហត្ថិសិល្បៈជាដើម ដែលលោកសំដៅយក ពោលទុកថា ពួកលិច្ឆវីរាជកុមារនេះសិក្សាហ្វឹកហាត់ជំនាញល្អហើយហ្ន៎ បេះបាញ់សរតាមរន្ធរនុកទ្វារដ៏តូចអំពីចម្ងាយឲ្យចេញទៅតៗ គ្នា មិនឲ្យដាច់ឡើយ ។ បទថា ឧច្ឆេជ្ជាមិ គឺ នឹង

កាត់ផ្តាច់ ។ បទថា វិនាសេស្សាមិ គឺ នឹងធ្វើឲ្យដល់សេចក្តីមិនប្រាកដ ។ ក្នុងពាក្យថា អនយព្យសនំ នេះ មានវចនត្ថថា សេចក្តីចម្រើនមិនមាន ហេតុនោះ ទើបឈ្មោះថា **អនយ** ។ ពាក្យថា **អនយ** នេះ ជាឈ្មោះរបស់សេចក្តីមិនចម្រើន ។ សេចក្តីមិនចម្រើននោះ រមែងកម្ចាត់ចោលនូវប្រយោជន៍ និងសេចក្តីសុខ ហេតុនោះ ទើបឈ្មោះថា **ព្យសន** ។ ពាក្យថា **ព្យសន** នេះ ជាឈ្មោះនៃសេចក្តីវិនាស មានវិនាសញាតិជាដើម ។ បទថា អាចានេស្សាមិ ប្រែថា នឹងឲ្យដល់ ។

បានឮថា ព្រះបាទអជាតសត្តុនោះ ត្រាស់ចំពោះការប្រយុទ្ធយ៉ាងនេះ ក្នុងឥរិយាបថមានឈរ និងអង្គុយជាដើម ទើបបញ្ជាកងទ័ពយ៉ាងនេះថា ពួកស្តេចចូរត្រៀមយាត្រាទ័ព ។ ព្រោះហេតុអ្វី ។ បានឮថា ត្រង់បត្តនគ្រាមតំបន់មួយនៃទន្លេគង្គា ព្រះបាទអជាតសត្តុទ្រង់មានអំណាចកន្លះយោជន៍ ពួកស្តេចលិច្ឆវីមានអំណាចកន្លះយោជន៍ ។ អធិប្បាយថា ក៏ក្នុងតំបន់នេះជាទីកន្លែងដែលធ្លាក់នៅខាងក្រោមអំណាចឃុំគ្រង ។ម្យ៉ាងទៀត ក្នុងទីនោះវត្ថុដែលមានតម្លៃច្រើនធ្លាក់អំពីជើងភ្នំ ។ កាលព្រះបាទអជាតសត្តុទ្រង់ជ្រាបដូច្នោះហើយ ទ្រង់ព្រះត្រិះរិះថា ទៅថ្ងៃនេះ ទៅថ្ងៃស្អែកនេះ ទើបត្រៀមក្បាម ពួកស្តេចលិច្ឆវីទ្រង់មានសាមគ្គីគ្នា ទើបនាំគ្នាទៅមុន ដណ្តើមរបស់មានតម្លៃជាច្រើនយកទុកអស់ ។ ព្រះបាទអជាតសត្តុស្តេចទៅដល់ក្រោយ ទ្រង់ជ្រាបរឿងនោះហើយ ទ្រង់ទឹងក្រោធ

ស្តេចទៅ ។ ស្តេចលិច្ឆវីទាំងនោះ ក៏ធ្វើយ៉ាងនោះឯងសូម្បីក្នុងឆ្នាំតមក ។ ដូច្នោះ ព្រះបាទអជាតសត្តុ ទើបទ្រង់អាឃាតយ៉ាងខ្លាំងក្លា ទ្រង់បានធ្វើយ៉ាងនោះក្នុងគ្រានោះ ។ តពីនោះ ទ្រង់ត្រិះរិះថា ឈ្មោះថា ការប្រយុទ្ធនឹងគណៈស្តេចជារឿងធ្ងន់ ឈ្មោះថា ការវាយដណ្តើមដែលគ្មានប្រយោជន៍សូម្បីក្នុងគ្រាតែមួយក៏មានមិនបាន តែកាលប្រឹក្សានឹងបណ្ឌិតត្រឹមតែម្នាក់រមែងមិនខុសក្លាត់ ក៏បណ្ឌិតដូចព្រះសាស្តាមិនមាន ទាំងព្រះសាស្តា ក៏ប្រថាប់នៅក្នុងវិហារជិតៗ នេះឯង ។ ណ្ហើយចុះ យើងនឹងបញ្ជូនអ្នកទៅទូលសួរ បើយើងទៅហើយ នឹងមានប្រយោជន៍អ្វី ព្រះសាស្តាក៏នឹងទ្រង់តុណ្ហីភាព ក៏កាលមិនជាប្រយោជន៍ដូច្នេះ ព្រះសាស្តានឹងត្រាស់ថា ព្រះរាជា ស្តេចទៅក្នុងទីនោះ នឹងមានប្រយោជន៍អ្វី ។ ទើបស្តេចបញ្ជូនវស្សការព្រាហ្មណ៍ទៅ ។ ព្រាហ្មណ៍ទៅហើយ ក៏ក្រាបទូលសេចក្តីនោះចំពោះព្រះមានព្រះភាគ ។ ដោយហេតុនោះ លោកទើបពោលថា អថ ខោ រាជា ។បេ។ អាចាមេស្សាមិ វជ្ជី ដូច្នេះ ។

## អបរិហានិយធម៌ ៧ របស់ពួកវជ្ជីក្សត្រ

[៦៨] បទថា ភគវន្តំ វីជយមានោ សេចក្តីថា ព្រះថេរៈឈរបក់ផ្លិតថ្វាយព្រះមានព្រះភាគតាមទំនៀម តែព្រះមានព្រះភាគ ទ្រង់នឹងត្រជាក់ឬទ្រង់ក្តៅ ក៏មិនមែន ។ ព្រះមានព្រះភាគ ទ្រង់ស្តាប់ពាក្យរបស់ព្រាហ្មណ៍

ហើយ ទ្រង់មិនប្រឹក្សានឹងព្រាហ្មណ៍នោះ ត្រឡប់មានព្រះបំណងប្រឹក្សានឹងព្រះថេរៈ ទើបត្រាស់ពាក្យថា កិន្តិ តេ អានន្ទ សុតំ ដូច្នេះជាអាទិ ។

បទថា អភិណ្ហសន្និបាតា សេចក្ដីថា ប្រជុំគ្នាមួយថ្ងៃ ៣ ដងខ្លះ ប្រជុំគ្នាជាចន្លោះខ្លះ ឈ្មោះថា ប្រជុំគ្នារឿយៗ ។ បទថា សន្និបាតពហុលា សេចក្ដីថា កាលមិនឈប់សម្រាកថា កាលម្សិលមិញ ក៏ប្រជុំគ្នាហើយ ទាំងថ្ងៃមុនក៏ប្រជុំគ្នាហើយ ថ្ងៃនេះនឹងប្រជុំគ្នាដូចម្ដេចទៀត ឈ្មោះថា ច្រើនដោយការប្រជុំ ។ បទថា យាវកីវញ្ច ប្រែថា រហូតដល់អស់កាលត្រឹមណា ។ បទថា វុឌ្ឍិយេវ អានន្ទ វជ្ជីនំ បាដិកង្ខា នោ បរិហានិ សេចក្ដីថា ព្រោះកាលមិនប្រជុំគ្នារឿយៗ មិនស្ដាប់ដំណឹងដែលមកពីគ្រប់ទិស គ្រប់ផ្លូវ ក៏មិនដឹងរឿងក្រវល់ក្រវាយដែលកើតឡើង អំពីខេត្ត ស្រុក ឬនិគមឯណោះ ឬក្រុមចោរជួបជុំក្នុងទីឯណោះ ។ សូម្បីពួកចោរដឹងថា ពួកស្ដេចនាំគ្នាប្រមាទ ទើបប្លន់ស្រុក និងនិគមជាដើម ធ្វើជនបទឲ្យវិនាស ។ ពួកស្ដេច រមែងសាបសូន្យដោយប្រការដូច្នេះ ។ តែកាលប្រជុំគ្នារឿយៗ ដឹងដំណឹងនោះៗ បន្ទាប់ពីនោះ ក៏នឹងបញ្ជូនកម្លាំងទៅបង្ក្រាបចំណែកដែលមិនមែនមិត្ត សូម្បីចោរទាំងឡាយដឹងថា ពួកស្ដេចមិនប្រមាទ ពួកយើងក៏មិនអាចនឹងប្រមូលគ្នាជាពួក ត្រាច់ទៅបាន ហើយក៏បែកគ្នាទៅ ។ ស្ដេចទាំងឡាយ រមែងចម្រើនដោយប្រការដូច្នេះ ។ ដោយហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា អ្នកស្រុកវជ្ជី គប្បីប្រាថ្នាសេចក្ដីចម្រើន

លូតលាស់តែម្យ៉ាង មិនសាបសូន្យឡើយ ។ បណ្តាបទទាំងនោះ បទថា ចាដិកន្ទ្វា បានដល់ គប្បីប្រាថ្នា អធិប្បាយថា គប្បីឃើញយ៉ាងនេះថា សេចក្តីចម្រើននឹងមានពិតប្រាកដ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា សមគ្គា ជាដើម ដូច្នេះ ។

កាលស្គរហៅប្រជុំលាន់ឮឡើង ពួកស្តេចលិច្ឆវីធ្វើការបែរង៉ាកថា ថ្ងៃនេះយើងមានកិច្ច ថ្ងៃនេះមង្គល ដូច្នេះ ឈ្មោះថា មិនព្រមព្រៀងគ្នាប្រជុំ ។ តែពេលបានឮសំឡេងស្គរ កំពុងស៊ីក្តី កំពុងតែងខ្លួនក្តី កំពុងស្លៀកសំពត់ក្តី ស៊ីបានពាក់កណ្តាលខ្លះ តែងខ្លួនបានពាក់កណ្តាលខ្លះ កំពុងស្លៀកសំពត់ខ្លះ ក៏ចូលប្រជុំ ឈ្មោះថា ព្រមព្រៀងគ្នាប្រជុំ ។ ចំណែកចូលប្រជុំហើយ ក៏គិត ក៏ប្រឹក្សាគ្នា ធ្វើកិច្ចដែលគួរធ្វើ មិនលះបង់ការព្រមគ្នា ឈ្មោះថា មិនព្រមព្រៀងគ្នាលះបង់ការប្រជុំ ។ ក៏កាលមិនលះការប្រជុំគ្នាយ៉ាងនេះហើយ ពួកដែលទៅមុន មានសេចក្តីគិតយ៉ាងនេះថា ពួកយើងបានឮតែនិយាយគ្នាក្រៅរឿង ឥឡូវនេះ នឹងនិយាយតែរឿងដែលមានការត្រឹមត្រូវ ។ តែកាលមិនលះបង់ការព្រមគ្នា ក៏ឈ្មោះថា ព្រមព្រៀងគ្នា ។ មួយទៀតបានឮថា សេចក្តីក្រវល់ក្រវាយ ឬក្រុមចោរប្រជុំគ្នានៅខេត្ត ស្រុក ឬនិគម ក្នុងទីឯណោះ កាលសាកសួរគ្នាថា អ្នកណានឹងទៅធ្វើការបង្ក្រាបបក្ខពួកដែលមិនមែនជាមិត្តហ្ន៎ ម្នាក់ៗ ដណ្តើមគ្នាអាសានិយាយថា ខ្ញុំមុន ខ្ញុំមុន ហើយនាំគ្នាទៅក្តី ឈ្មោះថា ព្រមព្រៀងគ្នា ។

តែកាលការងាររបស់ស្តេចមួយអង្គ ត្រូវវៀរទៅ ពួកស្តេចដ៏សេស ក៏បញ្ជូនបុត្រ និងបងប្អូនទៅជួយការងាររបស់ស្តេចអង្គនោះ មិននិយាយចំពោះស្តេចដែលជាអាគន្តុកៈថា មេត្តាស្តេចទៅតំណាក់ របស់ស្តេចអង្គឯណោះចុះ បើសង្គ្រោះព្រមគ្នាទាំងអស់គ្នី និងកាលការងារមង្គល រោគ ឬសុខទុក្ខដូច្នោះ យ៉ាងដទៃកើតឡើងដល់ស្តេចអង្គនោះ ក៏នាំគ្នាទៅជួយក្នុងរឿងនោះទាំងអស់គ្នី ឈ្មោះថា ព្រមព្រៀងគ្នាធ្វើកិច្ច ដែលអ្នកវជ្ជីគប្បីធ្វើ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា អបញ្ញត្តំ ជាដើមដូច្នេះ ។ មិនតាំងកាស៊ីអាករ ឬពលី ឬអាជ្ញាដែលមិនធ្លាប់ធ្វើ ឈ្មោះថា មិនបញ្ញត្តិច្បាប់ដែលមិនបានបញ្ញត្តិ ។ ចំណែកប្រើច្បាប់ ដែលមានមកពីបុរាណប្រពៃណីឈ្មោះថា មិនដកច្បាប់ដែលលោកបញ្ញត្តិទុកហើយ ។ កាលបុគ្គលត្រូវគេចាប់មក សម្តែងថា ជាចោរ ។ មិនព្រមវិនិច្ឆ័យ បង្គាប់ដាក់ទោសដោយដាច់ខាតតែម្តង ឈ្មោះថា មិនប្រព្រឹត្តវជ្ជីធម៌បុរាណ ។

កាលស្តេចទាំងនោះបញ្ញត្តិច្បាប់ដែលមិនទាន់បញ្ញត្តិ ពួកអ្នកដែលត្រូវបៀតបៀនដោយកាស៊ីថ្មីៗ ជាដើម រឭកដឹងថា យើងត្រូវបៀតបៀនអ្នកណានឹងនៅក្នុងដែនរបស់ស្តេចទាំងនេះបាន ហើយក៏នាំគ្នាទៅកាន់ជាយដែន ជាចោរខ្លះ ជាបក្ខពួករបស់ចោរខ្លះ ប្លន់ជនបទ ។ កាលពួកស្តេចលើកច្បាប់បញ្ញត្តិទុក មិនរក្សាកាស៊ីជាដើម ដែលមានមកតាមប្រពៃណីឃ្លាំងក៏សាបសូន្យទៅ តពីនោះកងទ័ព ដំរី សេះ និងរេហ៍ពល កាលមិន

បានវត្តជាប់ជានិច្ច សូម្បីអ្នកធ្វើការងារដែលជិតស្និទជាដើម ក៏នឹងសាបសូន្យផ្លូវកម្លាំងចិត្តកម្លាំងកាយ ពួកគេក៏មិនគួរនឹងច្បាំង មិនគួរនឹងធ្វើឲ្យចម្រើនលូតលាស់បាន ។ កាលមិនប្រព្រឹត្តវជ្ជីធម៌បុរាណ មនុស្សក្នុងព្រំដែនក៏នឹងនាំគ្នាក្រោធថា ពួកស្តេចធ្វើ បុត្រ បិតា បងប្អូន របស់យើងដែលមិនមែនជាចោរថា ជាចោរ កាត់ទម្លាយគ្នា ហើយនាំគ្នាទៅជាយដែនជាចោរខ្លះ ជាបក្ខពួករបស់ចោរខ្លះ លោមព័ទ្ធវាយជនបទ ។ ពួកស្តេចរមែងសាបសូន្យ ដោយអាការយ៉ាងនេះ ។ តែកាលពួកស្តេចបញ្ញត្តិច្បាប់ដែលបញ្ញត្តិហើយ ពួកមនុស្សក៏នឹងនាំគ្នារីករាយត្រេកអរថា ពួកស្តេចធ្វើតែច្បាប់ដែលមកតាមប្រពៃណី ដូច្នេះហើយ ក៏នឹងនាំគ្នាធ្វើការងារផ្សេងៗមានកសិកម្ម និងពាណិជ្ជកម្មជាដើម ឲ្យកើតផលសម្បូរណ៍ ។ កាលមិនដកច្បាប់ដែលបញ្ញត្តិទុក ហើយរក្សាពន្ធដារជាដើម ដែលមានមកតាមប្រពៃណី ឃ្លាំងក៏ចម្រើន តអំពីនោះ ទ័ពដំរី សេះ និងពលទាហាន កាលបានវត្តជាប់ជានិច្ច អ្នកធ្វើការងារដែលជិតស្និទ សម្បូរណ៍ដោយកម្លាំងចិត្តកម្លាំងកាយ ហើយគួរច្បាំងបាន គួរនឹងញ៉ាំងសេចក្តីចម្រើនបាន ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា ចោរាណំ វជ្ជិធម្មំ នេះ ដូចតទៅនេះ ឮថា ពួកស្តេចវជ្ជីពីមុនមិនត្រាស់ថា កាលខ្លួនត្រូវគេនាំមក សម្តេងថា អ្នកនេះជាចោរ ពួកលោកចូរចាប់ចោរនោះ ហើយប្រគល់ឲ្យមហាមាត្រផ្នែកខាងវិនិច្ឆ័យ ។ ចំណែកអាមាត្រទាំងនោះ វិនិច្ឆ័យហើយ ប្រសិនបើថា

មិនមែនចោរ ក៏ដោះលែងទៅ បើជាចោរក៏មិននិយាយអ្វីៗ ដោយខ្លួនឯង ហើយប្រគល់ឲ្យមហាមាត្រ ផ្នែកខាងអ្នកពិភាក្សា ។ មហាអាមាត្រអ្នកពិភាក្សាវិនិច្ឆ័យហើយ បើមិនមែនចោរ ក៏ដោះលែងទៅ បើជាចោរ ក៏ប្រគល់ឲ្យដល់មហាមាត្រ ផ្នែកដែលឈ្មោះថា គណៈវិនិច្ឆ័យ ។ គណៈវិនិច្ឆ័យទាំងនោះ វិនិច្ឆ័យហើយ បើមិនមែនចោរក៏ដោះលែងទៅ បើជាចោរ ក៏ប្រគល់ឲ្យមហាមាត្រ ៨ ត្រកូល ។ មហាមាត្រ ៨ ត្រកូលនោះ ក៏ធ្វើយ៉ាងនោះដូចគ្នា ហើយប្រគល់ឲ្យសេនាបតី ។ សេនាបតីក៏ប្រគល់ឲ្យដល់ឧបរាជ ឧបរាជក៏ប្រគល់ថ្វាយចំពោះព្រះរាជា ។ ព្រះរាជាវិនិច្ឆ័យហើយ បើថា មិនមែនចោរ ក៏ដោះលែងទៅ បើថាជាចោរ ក៏នឹងបញ្ជាឲ្យប្រធានអានគម្ពីរច្បាប់ប្រពៃណី ។ ក្នុងគម្ពីរច្បាប់ប្រពៃណីនោះ សរសេរទុកថា អ្នកណាធ្វើខុសច្បាប់នេះ អ្នកនោះនឹងត្រូវមានទោសយ៉ាងនេះ ។ ព្រះរាជាទ្រង់នាំការធ្វើរបស់អ្នកនោះ មកធៀបនឹងបទច្បាប់នោះហើយ ទ្រង់ដាក់ទោសតាមសមគួរដល់កំហុសនោះ ។ ដូច្នោះកាលពួកស្តេច កាន់វជ្ជីធម៌បុរាណប្រព្រឹត្ត មនុស្សទាំងឡាយ រមែងមិនតិះដៀល ។ ពួកស្តេចទាំងឡាយ រមែងធ្វើការងារតាមប្រពៃណីបុរាណ ស្តេចទាំងនោះ រមែងមិនមានទោស រមែងមានទោសតែយើងប៉ុណ្ណោះ ព្រោះដូច្នោះ គេទើបមិនប្រមាទក្នុងការងារ ។ ស្តេចទាំងឡាយ រមែងចម្រើនដោយអាការយ៉ាងនេះ ។ ដោយហេតុនេះ ព្រះមានព្រះភាគទើបត្រាស់ថា អានន្ទ ពួក

ស្តេចវជ្ជី គប្បីសង្ឃឹមសេចក្តីចម្រើនលូតលាស់តែម្យ៉ាង មិនមានសេចក្តីសាបសូន្យឡើយ ។

បទថា សក្ករោន្តិ បានដល់ កាលធ្វើសក្ការៈដល់ស្តេចវជ្ជីទាំងនោះយ៉ាងណាមួយ រមែងធ្វើតែល្អៗ ប៉ុណ្ណោះ ។ បទថា គរុករោន្តិ បានដល់ធ្វើការលើកសរសើរភាពជាអ្នកគួរគោរព ។ បទថា មានេន្តិ បានដល់ស្រឡាញ់ដោយចិត្ត ។ បទថា បូជេន្តិ បានដល់ សម្តែងការគោរព ។ បទថា សោតព្វំ មញ្ញន្តិ បានដល់ ទៅប្រណិបត្តិមួយថ្ងៃ ២-៣ ដង រមែងសម្គាល់ពាក្យរបស់ស្តេចវជ្ជីទាំងនោះថា គួរស្តាប់ គួរជឿ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងសេចក្តីនោះ ដូច្នេះ ។ ជនពួកណាមិនធ្វើសក្ការៈដល់ស្តេចចាស់យ៉ាងនេះ និងមិនទៅប្រណិបត្តិ ស្តេចទាំងនោះ ដើម្បីស្តាប់ឱវាទជនទាំងនោះ ត្រូវស្តេចទាំងនោះបោះបង់ចោល មិនឲ្យឱវាទ ដាក់ចិត្តតែខាងលេងសប្បាយ ក៏រមែងសាបសូន្យចាកភាពជាព្រះរាជា ។ ចំណែកស្តេចពួកណា បដិបត្តិតាមយ៉ាងនោះ ស្តេចដែលចាស់ រមែងទូន្មានប្រពៃណីបុរាណដល់ស្តេចទាំងនោះថា វត្ថុនេះគួរធ្វើ វត្ថុនេះមិនគួរធ្វើ សូម្បីដល់សម័យធ្វើសង្គ្រាម ក៏រមែងសម្តែងឧបាយថា គួរចូលទៅយ៉ាងនេះ គួរចេញទៅយ៉ាងនេះ ។ ស្តេចទាំងនោះទទួលឱវាទ បដិបត្តិតាមឱវាទ រមែងអាចរក្សារាជប្រពៃណីទុកបាន ។ ដោយហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា អានន្ទ ពួកស្តេចវជ្ជី គប្បីសង្ឃឹមសេចក្តីចម្រើនលូតលាស់

តែម្យ៉ាង មិនសាបសូន្យឡើយ ។

បទថា កុលិត្ថិយោ បានដល់ ស្រីមេផ្ទះរបស់ត្រកូល ។ បទថា កុលកុមារិយោ បានដល់ ធីតារបស់ស្រីមេផ្ទះទាំងនោះ អ្នកមិនទាន់បានជាឥស្សរៈ ។ ក្នុងពាក្យថា ឱក្កស្ស បសយ្ហ នេះពាក្យថា ឱក្កស្ស ក្តី បសយ្ហ ក្តី នេះជាឈ្មោះ របស់អាការគ្របសង្កត់បង្ខិតបង្ខំ ។ សាសនិកជន សូត្រថា ឧក្កស្ស ដូច្នេះ ក៏មាន ។ ក្នុងបទទាំងនោះ បទថា ឱក្កស្ស គឺ អូសទាញ ។ បទថា បសយ្ហ គឺ គ្របសង្កត់ ។ ក៏កាលស្តេចទាំងនោះធ្វើយ៉ាងនេះ ពួកមនុស្សក្នុងព្រំដែន ក៏នាំគ្នាក្រោធថា ពួកស្តេចទាំងនេះចាប់បុត្រ និងមាតា ក្នុងផ្ទះរបស់យើងខ្លះ ចាប់ធីតាដែលយើងយកមាត់បឺតទឹកមាត់ ទឹកសម្បោរជាដើម ចិញ្ចឹមធំធាត់មក ដោយពលការឲ្យនៅក្នុងផ្ទះរបស់ខ្លួនខ្លះ ហើយចូលទៅក្នុងចុងដែនជាចោរខ្លះ ជាបក្ខពួកចោរខ្លះ លោមព័ទ្ធវាយជនបទ ។ តែកាលមិនធ្វើយ៉ាងនោះ ពួកមនុស្សក្នុងដែន ក៏ខ្វល់ខ្វាយតិច ធ្វើការងាររបស់ខ្លួន រមែងធ្វើឃ្លាំងហ្លួងឲ្យចម្រើន ។ គប្បីជ្រាបសេចក្តីចម្រើន និងសេចក្តីសាបសូន្យ ក្នុងសេចក្តីនេះ ដោយប្រការដូច្នេះ ។

បទថា វជ្ជីនំ វជ្ជិចេតិយានិ សេចក្តីថា ទីកន្លែងយក្ខ បាននាមថាចេតិយ ព្រោះអត្ថថា គេធ្វើទុកយ៉ាងស្អាតក្នុងដែន គឺ រដ្ឋរបស់ពួកស្តេចវជ្ជី ។ បទថា អព្ភន្តរានិ គឺ តាំងនៅខាងក្នុងព្រះនគរ ។ បទថា

ពាហិរានិ គឺ តាំងនៅខាងក្រៅព្រះនគរ ។ បទថា ទិន្នបុព្វំ គឺ ដែលគេធ្លាប់ថ្វាយ ។ បទថា កតបុព្វំ គឺ ដែលគេធ្លាប់ធ្វើ ។ បទថា នោ បរិហាបេស្សន្តិ សេចក្តីថា នឹងមិនឲ្យថយចុះ ធ្វើដូចពីដើមនុ៎ះឯង ។ ពិតហើយ កាលស្តេចវជ្ជីដកពលីកម្មដែលត្រឹមត្រូវតាមធម៌ ពួកទេវតារមែងមិនធ្វើការរក្សាដែលចាត់ចែងទុកយ៉ាងល្អ ទាំងមិនអាចនឹងញុំាងទុក្ខដែលមិនទាន់កើតឲ្យកើតឡើង ធ្វើរោគក្អក រោគក្នុងសិរសៈជាដើម ដែលកើតឡើងហើយឲ្យកម្រើក កាលមានសង្គ្រាមក៏មិនជួយ តែកាលពួកស្តេចវជ្ជីមិនដកពលីកម្ម ទេវតាទាំងឡាយ រមែងធ្វើការរក្សា ដែលចាត់ចែងទុកយ៉ាងល្អ សូម្បីមិនអាចធ្វើសេចក្តីសុខដែលនៅមិនកើត ឲ្យកើតឡើង តែក៏កម្ចាត់រោគក្អក រោគក្នុងសិរសៈជាដើម ដែលកើតឡើងហើយបាន ទាំងនឹងជួយក្នុងយាមសង្គ្រាមផង គប្បីជ្រាបសេចក្តីចម្រើន និងសេចក្តីសាបសូន្យក្នុងសេចក្តីនេះ ដូចពោលមកនេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា ធម្មិកា រក្ខាវរណគុត្តិ ដូចតទៅនេះ ៖

ឈ្មោះថា អាវរណា ព្រោះការពារដោយឧបាយដល់វត្ថុដែលមិនគួរប្រាថ្នា នៅមិនទាន់មកដល់ ។ ឈ្មោះថា គុត្តិ ព្រោះគ្រប់គ្រងដោយឧបាយដល់វត្ថុដែលគួរប្រាថ្នាមានប្រាកដហើយ មិនឲ្យវិនាសទៅ ឈ្មោះថា រក្ខាដូចគ្នា ។ ក្នុងពាក្យនោះ ការលោមព័ទ្ធរក្សាដោយគំនរក្លើង មិនឈ្មោះថា ធម្មិកា រក្ខាវរណគុត្តិ ដើម្បីបព្វជិត តែការធ្វើដោយមិនកាត់

ដើមឈើក្នុងព្រៃជិតវិហារ មិនចាប់ម្រឹគដោយអន្ទាក់ មិនចាប់ត្រីក្នុងស្រះបោក្ខរណី ឈ្មោះថា ធម្មិកា រក្ខាវរណគុត្តិ ។ ក៏ដោយពាក្យថា កតិអនាគតា ៥ នេះ លោកសួរសេចក្តីក្នុងចិត្តរបស់ស្តេចវជ្ជីទាំងនោះថា មានចិត្តសន្តានប្រាកដយ៉ាងនេះ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យនោះ ដូចតទៅនេះ ៖

ស្តេចវជ្ជីពួកណា មិនប្រាថ្នាការមក របស់ព្រះអរហន្តទាំងឡាយ ដែលនៅមិនទាន់មក ស្តេចវជ្ជីទាំងនោះ ឈ្មោះថា ជាអ្នកមិនមានសទ្ធា មិនជ្រះថ្លា កាលបព្វជិតមកដល់ហើយ ក៏មិនទៅទទួល មិនទៅសួរសុខទុក្ខ មិនធ្វើបដិសណ្ឋារ មិនសួរបញ្ហា មិនស្តាប់ធម៌ មិនឲ្យទាន មិនស្តាប់អនុមោទនា មិនចាត់ចែងទីនៅអាស្រ័យ ហេតុដូច្នោះ សំឡេងតិះដៀលស្តេចវជ្ជីទាំងនោះ ក៏នឹងឮសុះសាយទៅថា ស្តេចឈ្មោះឯណោះមិនជឿ មិនជ្រះថ្លា កាលបព្វជិតមកដល់ក៏មិនទទួល ។ល។ មិនចាត់ចែងទីនៅ-អាស្រ័យ ។ ពួកបព្វជិតស្តាប់រឿងនោះហើយ សូម្បីកន្លងផ្លូវទ្វារព្រះនគររបស់ស្តេចអង្គនោះ ក៏មិនចូលទៅកាន់ព្រះនគរ ។ ពួកព្រះអរហន្តដែលមិនទាន់មក ក៏រមែងមិនមក ដោយប្រការដូច្នេះ ។ កាលមិនមានទីនៅជាសប្បាយ សម្រាប់ព្រះអរហន្តដែលមកហើយ មិនមាន ។ សូម្បីពួកព្រះអរហន្ត ដែលមិនដឹង មកដល់ក៏គិតថា កាលមុនយើងគិតនឹងមកនៅតែអ្នកណាហ្ន៎ នឹងនៅបាន ដោយសេចក្តីមិនត្រេកអររបស់ស្តេចទាំងនេះ

ដូច្នេះហើយ ក៏នាំគ្នាចេញទៅ ។ ដោយប្រការដូចពោលមកនេះ កាលពួកព្រះអរហន្តដែលមិនទាន់មក ក៏មិនមក ដែលមកហើយក៏លំបាកនៅក្នុងអាវាសនោះ ដែលមិនជាទីនៅសម្រាប់បព្វជិត ។ តពីនោះការរក្សារបស់ទេវតា ក៏រមែងមិនមាន កាលបើដូច្នោះ ពួកអមនុស្សក៏បានឱកាស ។ ពួកអមនុស្សក៏ណែនក្រាស់ រមែងធ្វើជម្ងឺដែលមិនទាន់កើត ឲ្យកើតឡើង ។ បុណ្យដែលមានទីតាំង ដូចការឃើញ ការសួរបញ្ហា ពួកលោកអ្នកមានសីលជាដើម ក៏មិនមកដល់ ។ តែកាលពោលដោយបរិយាយផ្ទុយគ្នា បុណ្យដែលជាចំណែកស ដែលផ្ទុយគ្នានឹងបាបចំណែកខ្មៅ តាមដែលពោលហើយ រមែងកើតព្រម គប្បីជ្រាបសេចក្តីចម្រើន និងសេចក្តីសាបសូន្យក្នុងសេចក្តីនេះ ដូចពោលមកដូច្នេះ ។

[៦៩] ព្រះមានព្រះភាគ ត្រាស់ពាក្យនេះថា ឯកមិទាហំ ក៏ដើម្បីទ្រង់ប្រកាសភាវៈនៃវជ្ជីសូត្រនេះ ដែលទ្រង់សម្តែងទុកហើយ ដល់ពួកស្តេចវជ្ជីក្នុងកាលមុន ។

បណ្តាបទទាំងនោះ បទថា សារន្ទទេ ចេតិយេ គឺ វិហារដែលមានឈ្មោះយ៉ាងនេះ បានឮថា កាលព្រះពុទ្ធមិនទាន់ឧប្បត្តិ ស្ថានទីនៅរបស់សារន្ទទយក្ខ ក្នុងទីនោះ បានជាចេតិយ ។ គ្រានោះពួកស្តេចវជ្ជី ឲ្យសាងវិហារថ្វាយចំពោះព្រះមានព្រះភាគក្នុងទីនោះ ។ វិហារនោះ ក៏រាប់បានថា សារន្ទទចេតិយនុ៎ះឯង ព្រោះទ្រង់សាងទុកត្រង់ទីសារន្ទទចេតិយ ។

បទថា អករណីយា គឺ មិនគប្បីធ្វើ អធិប្បាយថា មិនគួរប្រកាន់ ។ ពាក្យថា យទិទំ នេះ ត្រឹមតែជានិបាត ។ បទថា យុទ្ធស្ស ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថតតិយាវិភត្តិ សេចក្តីថា នរណាៗ មិនអាចប្រឈមមុខដើម្បីតយុទ្ធបាន ។ បទថា អញ្ញត្រ ឧបលាបនាយ បានដល់ ឲ្យវៀរលែងពីការលួងលោម ។ អធិប្បាយថា ការបញ្ជូនគ្រឿង បណ្ណាការ មានដំរី សេះ រថ ប្រាក់ និងមាសជាដើមសង្គ្រោះគ្នា ដោយពោលថា ល្មមហើយ សម្រាប់ការទាស់ទែងគ្នា ពួកយើងសាមគ្គីគ្នាឥឡូវនេះចុះ ដូច្នេះ ឈ្មោះថា ការលួងលោមគ្នា ។ ការសង្គ្រោះគ្នាយ៉ាងនេះ ក៏អាចស្អិតរមួតគ្នាបានដោយសេចក្តីស្និទ្ធស្នាលតែម្យ៉ាង ។ បទថា អញ្ញត្រ មិថុភេទាយ បានដល់ វៀរលែងតែធ្វើឲ្យបែកគ្នាជាពីរចំណែក ដោយពាក្យនេះ លោកសម្តែងថា សូម្បីធ្វើការបំបែកនូវគ្នានិងគ្នា ក៏អាចចាប់ពួកស្តេចវជ្ជីទាំងនោះបាន ។ ព្រាហ្មណ៍យល់ន័យ នៃព្រះតម្រាស់របស់ព្រះមានព្រះភាគហើយ ទើបពោលពាក្យនេះ ។ សួរថា ក៏ព្រះមានព្រះភាគទ្រង់ជ្រាបថា ព្រាហ្មណ៍បានន័យនៃព្រះតម្រាស់នេះឬ ។ ឆ្លើយថា ទ្រង់ជ្រាបបាន ។ សួរថា កាលទ្រង់ជ្រាបហេតុអ្វី ទើបត្រាស់ ។ ឆ្លើយថា ព្រោះទ្រង់អនុគ្រោះ ។ បានឮថា ព្រះមានព្រះភាគនោះ ទ្រង់ព្រះត្រិះរិះថា សូម្បីកាលតថាគតមិនសម្តែង ២-៣ ថ្ងៃ ព្រាហ្មណ៍នឹងទៅចាប់ស្តេចវជ្ជីទាំងនោះ តែកាលតថាគតសម្តែង ព្រាហ្មណ៍កាលនឹងទម្លាយសាមគ្គី ក៏ត្រូវប្រើវេលាដល់ ៣ ឆ្នាំ នឹងមានជីវិតរស់នៅ

ត្រឹមតែប៉ុណ្ណោះក៏ប្រសើរហើយ ដោយថា ពួកស្តេចវជ្ជីរស់នៅបានត្រឹមនេះ ក៏នឹងធ្វើបុណ្យជាទីពឹងរបស់ខ្លួនបាន ។ បទថា អភិនន្ទិត្វា ប្រែថា ត្រេកអរហើយដោយចិត្ត ។ បទថា អនុមោទិត្វា បានដល់ ត្រេកអរដោយវាចាថា "បពិត្រព្រះគោតមដ៏ចម្រើន ពាក្យនេះជាពាក្យសុភាសិតពិត" ។ បទថា បក្កាមិ បានដល់ ទៅកាន់រាជសម្នាក់ ។

លំដាប់នោះ ព្រះរាជា (អជាតសត្តុ) ត្រាស់សួរព្រាហ្មណ៍នោះថា អាចារ្យព្រះមានព្រះភាគត្រាស់ថា យ៉ាងណា ។ ព្រាហ្មណ៍ទូលថា ព្រះតម្រាស់របស់ព្រះសមណគោតមសម្តែងថា អ្នកណាៗ មិនអាចចាប់ពួកស្តេចវជ្ជីបាន ប៉ុន្តែថា អាចចាប់បានដោយការលួងលោម ១ ដោយការធ្វើឲ្យបែកសាមគ្គី ១ ។ ព្រះរាជាត្រាស់សួរព្រាហ្មណ៍នោះថា ដំរី សេះជាដើមរបស់យើង នឹងវិនាសដោយការលួងលោម យើងនឹងចាប់ពួកស្តេចវជ្ជី ដោយការទម្លាយសាមគ្គីប៉ុណ្ណោះ យើងនឹងធ្វើយ៉ាងណា ។ ព្រាហ្មណ៍ទូលថា មហារាជ បើយ៉ាងនោះ សូមប្រារព្ធដែនវជ្ជី លើករឿងឡើងត្រាស់ក្នុងទីប្រជុំ តពីនោះ ខ្ញុំព្រះអង្គនឹងទូលថា មហារាជ ព្រះអង្គនឹងទ្រង់ប្រាថ្នាអ្វីដោយសម្បត្តិរបស់ស្តេចទាំងនោះ ស្តេចទាំងនោះចូរធ្វើកសិកម្ម និងពាណិជ្ជកម្មជាដើម ចិញ្ចឹមជីវិតចុះ ដែលធ្វើហើយ នឹងគេចចេញទៅ តពីនោះ ព្រះអង្គគប្បីត្រាស់ថា ហេតុណាហ្ន៎ ព្រាហ្មណ៍នេះ ទើបជំទាស់រឿងដែនវជ្ជីដែលប្រារព្ធ ។ នៅពេលថ្ងៃ ខ្ញុំព្រះអង្គនឹង

បញ្ជូនគ្រឿងបណ្ណាការទៅថ្វាយស្តេចវជ្ជីទាំងនោះ សូមព្រះអង្គក៏ចូរឲ្យចាប់ខ្ញុំព្រះអង្គនោះ លើកទោសរបស់ខ្ញុំព្រះអង្គ មិនធ្វើការឃុំឃាំង និងវាយជាដើម គ្រាន់តែកោរក្បាលតែម្យ៉ាង និរទេសចេញអំពីព្រះនគរទៅ កាលបើដូច្នោះ ខ្ញុំព្រះអង្គនឹងពោលថា ខ្ញុំព្រះអង្គឲ្យសាងកំផែង និងមើលក្នុងព្រះនគររបស់ព្រះអង្គ ខ្ញុំព្រះអង្គនឹងដឹងដល់ស្ថានទីរឹងមាំ និងទន់ខ្សោយ និងស្ថានទីរាក់ និងជ្រៅ ឥឡូវនេះ ខ្ញុំព្រះអង្គនឹងធ្វើព្រះនគរនោះ ឲ្យត្រង់មិនយូរឡើយ ព្រះអង្គស្តាប់ពាក្យនោះ គប្បីត្រាស់បង្គាប់ឲ្យទៅ ដូច្នេះ ។ ព្រះរាជាក៏បានធ្វើគ្រប់ប្រការ ។

ពួកស្តេចលិច្ឆវី ទ្រង់ស្តាប់ការនិរទេសព្រាហ្មណ៍នោះហើយត្រាស់ថា ព្រាហ្មណ៍អួតអាង លោកទាំងឡាយកុំឲ្យព្រាហ្មណ៍នោះឆ្លងទន្លេគង្គាទៅបាន ។ បណ្តាស្តេចលិច្ឆវីទាំងនោះ កាលស្តេចលិច្ឆវីពួកខ្លះពោលថា គេថា ព្រាហ្មណ៍នោះត្រូវគេធ្វើយ៉ាងនេះ ព្រោះគេនិយាយប្រាប់ពួកយើង ស្តេចវជ្ជីមួយពួកទៀតពោលថា នាយ លោកកុំបានឲ្យព្រាហ្មណ៍ចូលមក ។ ព្រាហ្មណ៍នោះទៅជួបពួកស្តេចលិច្ឆវី ត្រូវសួរថា លោកបានធ្វើខុសអ្វី ទើបមានរឿងនោះ ។ ពួកស្តេចលិច្ឆវី ពោលថា ព្រាហ្មណ៍ធ្វើខុសបន្តិចបន្តួច មិនគួរដាក់ទោសធ្ងន់យ៉ាងនេះ ហើយទើបសួរថា ក្នុងនគរនោះលោកមានតំណែងអ្វី ។ ព្រាហ្មណ៍ឆ្លើយថា ខ្ញុំព្រះអង្គជាអាមាត្យផ្នែកវិនិច្ឆ័យ ។ ស្តេចលិច្ឆវី ត្រាស់ថា លោកចូរតាំងនៅក្នុងតំណែងនោះចុះ ។ ព្រាហ្មណ៍

នោះ ក៏ធ្វើមុខនាទីវិនិច្ឆ័យយ៉ាងល្អ ។ រាជកុមារទាំងឡាយនាំគ្នាសិក្សាសិល្បៈក្នុងសម្នាក់របស់ព្រាហ្មណ៍នោះ ។ ព្រាហ្មណ៍នោះ ថ្ងៃមួយនាំស្តេចលិច្ឆវីមួយអង្គទៅទីកន្លែងមួយ សួរថា ក្មេងៗ ធ្វើស្រែឬ ។ ស្តេចលិច្ឆវីមួយអង្គ ឆ្លើយថា អើ ! ធ្វើស្រែ សួរថា ទឹមគោពីរឬ ។ ឆ្លើយថា អើ ! ទឹមគោពីរ ។ ព្រាហ្មណ៍ពោលយ៉ាងនេះហើយក៏ត្រឡប់ទៅ ។ តពីនោះស្តេចលិច្ឆវីអង្គដទៃ ទើបសួរស្តេចលិច្ឆវីអង្គនោះថា អាចារ្យនិយាយយ៉ាងណា មិនជឿពាក្យស្តេចលិច្ឆវីអង្គនោះប្រាប់ គិតថា ស្តេចលិច្ឆវីអង្គនោះមិនប្រាប់យើងតាមសេចក្តីពិត ក៏បែកគ្នានឹងស្តេចលិច្ឆវីអង្គនោះ ។ សូម្បីក្នុងថ្ងៃដទៃៗ ព្រាហ្មណ៍ក៏នាំស្តេចលិច្ឆវីមួយអង្គ ទៅទីកន្លែងមួយសួរថាលោកសោយជាមួយអ្វី ហើយក៏ត្រឡប់ ។ ស្តេចលិច្ឆវីអង្គដទៃមិនជឿក៏បែកគ្នាយ៉ាងនោះ ដូចគ្នា ។ សូម្បីក្នុងថ្ងៃតៗ មក ព្រាហ្មណ៍ក៏នាំស្តេចលិច្ឆវីមួយអង្គទៀត ទៅទីកន្លែងមួយហើយសួរថា គេថា លោកក្រីក្រណាស់ឬ ។ សាកសួរថា អ្នកណានិយាយយ៉ាងនេះ ។ ព្រាហ្មណ៍ឆ្លើយថា ស្តេចលិច្ឆវីឈ្មោះឯណោះ ។ ព្រាហ្មណ៍ក៏នាំស្តេចលិច្ឆវីអង្គដទៃៗ ទៅទីកន្លែងមួយ ហើយសួរថា គេថា លោកកំសាកណាស់ឬ ។ សាកសួរថា អ្នកណានិយាយយ៉ាងនោះ ។ ឆ្លើយថា ស្តេចលិច្ឆវីឈ្មោះឯណោះ ។ ព្រាហ្មណ៍ពោលពាក្យដែលស្តេចលិច្ឆវីមួយអង្គទៀតមិនបានពោល ចំពោះស្តេចលិច្ឆវីមួយអង្គទៀត ដោយអាការយ៉ាងនេះ ៣ ឆ្នាំ ទើបបំបែកស្តេចលិច្ឆវីទាំង

នោះចេញអំពីគ្នា ហើយធ្វើដោយប្រការដែលស្តេចលិច្ឆវីទាំង ២ ចំណែក មិនធ្វើដំណើររួមគ្នា ទើបឲ្យវាយស្គរហៅប្រជុំ ។ ពួកស្តេចលិច្ឆវីនិយាយគ្នាថា អ្នកជាធំចូរប្រជុំគ្នា អ្នកខ្លាចចូរប្រជុំគ្នាចុះ ហើយក៏មិនប្រជុំគ្នា ។ ព្រាហ្មណ៍ទើបបញ្ជូនដំណឹងថ្វាយព្រះរាជាថា ឥឡូវនេះ ដល់វេលាហើយ មេត្តាប្រញាប់ស្តេចមកចុះ ។

ព្រះរាជាស្តាប់ហើយ ក៏បញ្ជាឲ្យវាយស្គរហៅពលទាហាន ស្តេចលើកទ័ពចេញទៅ ។ អ្នកនគរវេសាលី ក៏វាយស្គរប្រកាសថា ពួកយើងនឹងមិនព្រមឲ្យព្រះរាជាស្តេចឆ្លងទន្លេគង្គា ។ អ្នកនគរវេសាលី ស្តាប់ប្រកាសនោះហើយ ក៏និយាយថា អ្នកជាធំចូរនាំគ្នាទៅចុះ ដូច្នេះជាដើម ហើយក៏មិនទៅប្រជុំគ្នា ។ អ្នកនគរវេសាលី ក៏វាយស្គរប្រកាសថា ពួកស្តេចនឹងមិនឲ្យព្រះរាជាស្តេចចូលព្រះនគរ នឹងបិទទ្វារឲ្យជិត មិនទៅប្រជុំសូម្បីតែម្នាក់ ។ ព្រះរាជាស្តេចចូលតាមផ្លូវទ្វារដែលបើកទុក ទ្រង់ធ្វើពួកស្តេចវជ្ជីទាំងអស់ឲ្យដល់សេចក្តីវិនាស ហើយស្តេចទៅ ។

## ទ្រង់ឲ្យប្រជុំភិក្ខុទាំងឡាយ

[៧០] គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា អថខោ ភគវា អចិរប្បក្កន្តេ ជាដើម ដូចតទៅនេះ ៖

បទថា សន្និបាតេត្វា សេចក្តីថា ព្រះអានន្ទហៅប្រជុំថា លោកអ្នក

មានអាយុទាំងឡាយ ចូរបញ្ជូនលោកអ្នកមានឫទ្ធិ ទៅកាន់វិហារឆ្ងាយៗ ចូរទៅប្រជុំគ្នាឯវិហារជិតៗ ព្រះមានព្រះភាគ មានព្រះបំណងនឹងប្រជុំពួកលោក ។ បទថា អបរិហានិយេ សេចក្តីថា មិនធ្វើហេតុនៃសេចក្តីចម្រើនឲ្យសាបសូន្យ ។ បទថា ធម្មេ ទេសេស្សាមិ សេចក្តីថា យើងនឹងពោលឲ្យជាក់ច្បាស់ ដូចជាលើកព្រះច័ន្ទ ១ ពាន់ដួង ព្រះអាទិត្យ ១ ពាន់ដួងឡើង ដូចជាអុជប្រទីបប្រេង ១ ពាន់ដួង ក្នុងផ្ទះទាំង ៤ ជ្រុង ។

បណ្តាបទទាំងនោះ បទថា អភិណ្ហសន្និបាតា នេះ ក៏ដូចគ្នាដែលពោលទុកហើយក្នុងការប្រជុំរបស់ស្តេចវជ្ជីទាំងឡាយ ។ មួយទៀត ព្រោះហេតុដែលមិនប្រជុំគ្នារឿយៗ ភិក្ខុទាំងឡាយក្នុងធម្មវិន័យនេះ មិនបានឮដំណឹងដែលមកក្នុងទិសផ្សេងៗ តពីនោះ សីមារបស់វត្តឯណោះ ក៏មានការជ្រួលច្របល់ ឧបោសថ និងបវារណាក៏វៀរ ភិក្ខុទាំងឡាយក្នុងទីឯណោះ ធ្វើអនេសនកម្ម មានវេជ្ជកម្ម និងទូតកម្មជាដើម ជាអ្នកច្រើនដោយវិញ្ញត្តិ មិនស្គាល់កិច្ចជាដើមថា ចិញ្ចឹមជីវិតដោយអនេសនកម្ម មានការឲ្យផ្កាឈើជាដើម ។ សូម្បីភិក្ខុអាក្រក់ទាំងឡាយដឹងថា សង្ឃធ្វេសប្រហែស ក៏រួមគ្នាជាក្រុម រមែងធ្វើសាសនាឲ្យសាបសូន្យអន់ថយ ។ តែព្រោះប្រជុំគ្នារឿយៗ ភិក្ខុទាំងឡាយរមែងបានឮរឿងនោះៗ ។ តពីនោះ ក៏បញ្ជូនភិក្ខុសង្ឃទៅធ្វើសីមាឲ្យត្រង់ ធ្វើឧបោសថ និងបវារណាជាដើម ឲ្យប្រព្រឹត្តទៅ ។ បញ្ជូនភិក្ខុដែលរាប់បញ្ចូលក្នុងអរិយវង្ស ទៅក្នុងទីដែលច្រើនទៅ

ដោយពួកភិក្ខុមិច្ឆាជីវៈ ឲ្យពោលអរិយវង្ស ឲ្យពួកព្រះវិន័យធរធ្វើនិគ្គហៈ ភិក្ខុអាក្រក់ទាំងឡាយ សូម្បីភិក្ខុអាក្រក់ទាំងឡាយដឹងថា សង្ឃមិនធ្វេសប្រហែស ពួកយើងមិនអាចរួមជាពួកក្រុមបានទេ ក៏ចៀសចេញទៅ ។ គប្បីជ្រាបសេចក្តីសាបសូន្យ និងសេចក្តីចម្រើន ក្នុងសេចក្តីនេះ ដោយប្រការដូច្នេះ ។

## អបរិហានិយធម៌ ៧ របស់ភិក្ខុ

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា សមគ្គា ជាដើម ដូចតទៅនេះ ៖

កាលគេវាយស្គរ ឬគោះរគាំងប្រកាសថា សង្ឃចូរប្រជុំគ្នា ព្រោះប្រាថ្នានឹងបង្ហាញកតិកាវត្ត ព្រោះប្រាថ្នានឹងឲ្យឱវាទ ដើម្បីបដិបត្តិព្រះចេតិយ បដិបត្តិទីលានពោធិព្រឹក្ស ឬដើម្បីប្រក់រោងឧបោសថ ដើម្បីចៀសវាងថា ខ្ញុំមានកិច្ចដោយចីវរ ខ្ញុំដុតបាត្រ ខ្ញុំមានការកសាង ឈ្មោះថា មិនព្រមព្រៀងគ្នាធ្វើ ។ ចំណែកភិក្ខុទាំងឡាយវៀរកិច្ចការនោះទាំងអស់ ប្រជុំគ្នាដោយការស្រែកប្រកាស់តែមួយដងប៉ុណ្ណោះ ដោយសេចក្តីធ្វើទុកក្នុងចិត្តថា ខ្ញុំមុន ខ្ញុំមុន ឈ្មោះថា ព្រមព្រៀងគ្នាប្រជុំ ។ មួយទៀត ប្រជុំគ្នាហើយ គិតប្រឹក្សាគ្នាធ្វើកិច្ចដែលគួរធ្វើមិនព្រមគ្នា មិនឈ្មោះថា ព្រមព្រៀងគ្នា ។ ក៏បណ្តាភិក្ខុទាំងឡាយកំណត់គ្នាហើយយ៉ាងនេះ ពួកភិក្ខុដែលទៅមុន គិតយ៉ាងនេះថា ពួកយើងស្តាប់តែរឿងក្រៅរឿង ឥឡូវនេះ

នឹងនិយាយគ្នាដល់ប្រការដែលពិត ។ តែកាលលើកដោយព្រមព្រៀងគ្នា ក៏ឈ្មោះថា ព្រមព្រៀងគ្នាលើក មួយទៀត ភិក្ខុទាំងឡាយស្តាប់ថា សីមារបស់វិហារក្នុងទីឈ្មោះឯណោះ ប្រឡូកប្រឡល់ ឧបោសថ និងបវារណាក៏រៀបចំភិក្ខុអាក្រក់ អ្នកធ្វើអនេសនកម្ម មានវេជ្ជកម្មជាដើម ក្នុងទីឈ្មោះឯណោះមានយ៉ាងច្រើន កាលភិក្ខុទាំងនោះពោលថា អ្នកណានឹងទៅធ្វើការនិគ្គហៈភិក្ខុទាំងនោះ ទើបនិយាយទទួលាថា ខ្ញុំមុន ខ្ញុំមុន ហើយក៏ទៅ ឈ្មោះថា ព្រមព្រៀងគ្នាលើក ។ ក៏ភិក្ខុទាំងឡាយ ជួបភិក្ខុអាគន្តុកៈមិននិយាយអ្វីថា ចូរទៅបរិវេណនេះ ចូរទៅបរិវេណនោះទាំងអស់ សូម្បីធ្វើវត្តហើយក្តី ជួបភិក្ខុដែលមានបាត្រ ចីវរចាស់ ស្វែងរកបាត្រ ចីវរដោយភិក្ខុចារវត្ត ដើម្បីភិក្ខុនោះក្តី ស្វែងរកគិលានភេសជ្ជៈ (ថ្នាំ) ដើម្បីភិក្ខុឈឺក្តី មិននិយាយចំពោះភិក្ខុឈឺអ្នកមិនមាន ទីពឹងថា ចូរទៅបរិវេណឯណោះចុះ ចូរទៅបរិវេណឯណោះចុះក្តី បដិបត្តិក្នុងបរិវេណរៀងៗ ខ្លួនក្តី មានគម្ពីរនៅសល់សូម្បីមួយ ក៏សង្គ្រោះភិក្ខុអ្នកមានបញ្ញា ឲ្យភិក្ខុនោះលើកគម្ពីរនោះឡើងក្តី ឈ្មោះថា ព្រមព្រៀងគ្នាធ្វើកិច្ចរបស់សង្ឃ ដែលគប្បីធ្វើ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា អប្បញ្ញត្តំ ដូច្នេះជាដើម ដូចតទៅនេះ ៖

ភិក្ខុទាំងឡាយតែងវត្តកតិកា ឬសិក្ខាបទ ដែលមិនត្រូវតាមធម៌ថ្មី

ឈ្មោះថា បញ្ញត្តិប្រការដែលព្រះពុទ្ធទ្រង់មិនបានបញ្ញត្តិ ដូចពួកភិក្ខុក្រុងសាវត្ថី ក្នុងរឿងលាយក្ខាប់សន្ថ័តចាស់ ។ ពួកភិក្ខុដែលពោលពាក្យប្រៀនប្រដៅក្រៅធម៌ ក្រៅវិន័យ ឈ្មោះថា ដកសិក្ខាបទដែលព្រះពុទ្ធទ្រង់បញ្ញត្តិហើយ ដូចពួកភិក្ខុវជ្ជីបុត្រក្នុងនគរវេសាលី កាលព្រះមានព្រះភាគបរិនិព្វានបាន ១០០ ឆ្នាំ ។ ចំណែកពួកភិក្ខុប្រព្រឹត្តកន្លងល្មើសអាបត្តិតូចៗ ឈ្មោះថា មិនសមាទានប្រព្រឹត្តក្នុងសិក្ខាបទទាំងឡាយ តាមដែលទ្រង់បញ្ញត្តិទុក ដូចជា ភិក្ខុអស្សជិបុនព្វសុកៈ ។ ចំណែកភិក្ខុទាំងឡាយ មិនតែងតាំងកតិកាវត្ត ឬសិក្ខាបទឡើងថ្មី ពោលពាក្យប្រៀនប្រដៅអំពីធម្មវិន័យ មិនដកនូវសិក្ខាបទតូចៗ ឈ្មោះថា មិនបញ្ញត្តិសិក្ខាបទដែលទ្រង់មិនបញ្ញត្តិ មិនដកនូវសិក្ខាបទដែលទ្រង់បញ្ញត្តិទុកហើយ សមាទានប្រព្រឹត្តក្នុងសិក្ខាបទតាមដែលទ្រង់បញ្ញត្តិទុក ដូចព្រះឧបសេនៈ ព្រះយសកាកណ្ឌកបុត្រ និងព្រះមហាកស្សបៈ អ្នកតម្កល់បែបផែននេះថា ម្នាលអាវុសោ សង្ឃចូរស្តាប់ខ្ញុំ សិក្ខាបទទាំងឡាយរបស់ពួកយើង ជាចំណែករបស់គ្រហស្ថមាន សូម្បីពួកគ្រហស្ថទាំងឡាយ ក៏ដឹងថា វត្ថុនេះគួរដល់លោកទាំងឡាយជាសមណៈសក្យបុត្រ វត្ថុនេះមិនគួរដល់លោក ។ បើយើងទាំងឡាយនឹងដកនូវសិក្ខាបទតូចៗ ដោយលំដាប់ចេញហើយ ក៏នឹងមានអ្នកពោលតិះដៀលថា សិក្ខាបទដែលព្រះសមណគោតមបញ្ញត្តិហើយដល់សាវកទាំងឡាយ បានត្រឹមតែប្រមាណមួយផ្សែងភ្លើង សាវកទាំងនេះ

សិក្សាក្នុងសិក្ខាបទទាំងឡាយ ដរាបដែលព្រះសាស្តារបស់សាវកទាំងនេះតាំងនៅ ព្រះសាស្តារបស់សាវកទាំងនេះ បរិនិព្វានហើយ ឥឡូវនេះ សាវកទាំងនេះក៏មិនព្រមសិក្សាក្នុងសិក្ខាបទទាំងឡាយ ដូច្នេះ ប្រសិនបើថា សេចក្តីព្រមព្រៀងរបស់សង្ឃដល់ហើយ សង្ឃមិនគប្បីបញ្ញត្តិសិក្ខាបទ ដែលទ្រង់បញ្ញត្តិទុកហើយ គប្បីសមាទានប្រព្រឹត្តក្នុងសិក្ខាបទទាំងឡាយ តាមដែលទ្រង់បញ្ញត្តិទុក ។ បទថា វុឌ្ឍិយេវ បានដល់ សេចក្តីចម្រើនដោយគុណមានសីលជាដើម មិនសាបសូន្យឡើយ ។

បទថា ថេរា បានដល់ អ្នកដល់ភាពជាអ្នករឹងមាំ គឺ ប្រកបដោយគុណដែលធ្វើភាពរឹងមាំ ។ ឈ្មោះថា រត្តញ្ញូ ព្រោះដឹង រាត្រីច្រើន ។ ឈ្មោះថា ចិរបព្វជិតា ព្រោះបួសមកយូរ ។ ឈ្មោះថា សង្ឃបិតរោ ព្រោះតាំងនៅក្នុងឋានៈជាបិតារបស់សង្ឃ ។ ឈ្មោះថា សង្ឃបរិណាយកា ព្រោះរក្សាសង្ឃ ហេតុតាំងនៅក្នុងឋានៈជាបិតា ជាប្រធានបដិបត្តិ ក្នុងបទគឺ សិក្ខា ៣ ។ ភិក្ខុពួកណា មិនធ្វើសក្ការៈជាដើម ដល់ព្រះថេរៈទាំងនោះមិនទៅប្រណិបត្តិមួយថ្ងៃ ២-៣ ដង ដើម្បីទទួលឱវាទព្រះថេរៈ សូម្បីថេរៈទាំងនោះ រមែងមិនឲ្យឱវាទ មិនពោលរឿងប្រពៃណី មិនឲ្យសិក្សាធម្មបរិយាយ ដែលជាសារៈដល់ភិក្ខុទាំងនោះ ។ ភិក្ខុទាំងនោះ ត្រូវព្រះថេរៈទាំងនោះលះបង់ចោលហើយ រមែងសាបសូន្យអំពីគុណទាំងឡាយ មានជាអាទិ៍យ៉ាងនេះ គឺ អំពីធម្មក្ខន្ធ មានសីលខន្ធជាដើម និងអំពីអរិយទ្រព្យ

៧ ។ ចំណែកភិក្ខុពួកណា ធ្វើសក្ការៈជាដើម ទៅប្រណិបត្តិព្រះថេរៈទាំងនោះ សូម្បីព្រះថេរៈទាំងនោះ រមែងឲ្យឱវាទដល់ភិក្ខុទាំងនោះថា លោកគប្បីឈានទៅយ៉ាងនេះ គប្បីថយត្រឡប់យ៉ាងនេះ គប្បីស្លៀមយ៉ាងនេះ គប្បីក្រឡេកយ៉ាងនេះ គប្បីបត់ចូលយ៉ាងនេះ គប្បីលាចេញយ៉ាងនេះ គប្បីទ្រទ្រង់បាត្រ និងចីវរយ៉ាងនេះ រមែងទូន្មានរឿងប្រពៃណី រមែងឲ្យសិក្សាធម្មបរិយាយដែលជាសារៈ ទូន្មានដោយធុតង្គ ១៣ កថាវត្ថុ ១០ ។ ភិក្ខុទាំងនោះនៅក្នុងឱវាទរបស់ព្រះថេរៈទាំងនោះ ចម្រើនដោយគុណមានសីលជាដើម រមែងសម្រេចសាមញ្ញផលដោយលំដាប់ ។ គប្បីជ្រាបសេចក្តីសាបសូន្យ និងសេចក្តីចម្រើនក្នុងសេចក្តីនេះ ដោយប្រការដូច្នេះ ។

ការឲ្យកើតទៀត ឈ្មោះថា ភពថ្មី ភពថ្មីនោះ ជាប្រក្រតីរបស់តណ្ហានោះ ហេតុនោះ តណ្ហានោះ ទើបឈ្មោះថា ពោនោព្ភវិកា ។ អធិប្បាយថា ឲ្យកើតទៀត ។ នៃតណ្ហាដែលឲ្យភពថ្មីនោះ ។ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា ន វសំ គច្ឆិស្សន្តិ ដូចតទៅនេះ ភិក្ខុពួកណាទទួលបិណ្ឌបាតរបស់ឧបដ្ឋាកហើយ អំពីស្រុកមួយទៅស្រុកមួយ ព្រោះហេតុនៃបច្ច័យ ៤ ភិក្ខុទាំងនោះ ឈ្មោះថា នៅក្នុងអំណាចរបស់តណ្ហានោះ ។ ចំណែកភិក្ខុដែលមិនបដិបត្តិយ៉ាងនោះ ឈ្មោះថា មិននៅក្នុងអំណាចនៃតណ្ហា ។ សេចក្តីសាបសូន្យ និងសេចក្តីចម្រើនក្នុងសេចក្តីនោះ ប្រាកដច្បាស់ហើយ ។

បទថា អារញ្ញកេសុ បានដល់ ព្រៃចម្ងាយ ៥០០ ជួរធ្នូជាទីបំផុត ។ បទថា សាបេក្ខា បានដល់ មានតណ្ហា មានអាល័យ ។ សួរថាភិក្ខុមិនទាន់សម្រេចឈានក្នុងសេនាសនៈជិតស្រុក លុះចេញចាកឈាននោះ បានឮសំឡេងស្រី ប្រុស និងក្មេងស្រីជាដើម ជាហេតុសាបសូន្យគុណវិសេសដែលភិក្ខុនោះសម្រេចហើយ តែលោកដេកក្នុងព្រៃ លុះភ្ញាក់ឡើង ក៏បានឮតែសំឡេងរាជសីហ៍ ខ្លា និងសត្វក្ងោកជាដើម កាលលោកបានបីតិក្នុងព្រៃហើយ ពិចារណាបីតិ នោះឯង តាំងនៅក្នុងផលដ៏ប្រសើរ ។ ដូច្នោះព្រះមានព្រះភាគ ទើបទ្រង់សរសើរភិក្ខុអ្នករស់នៅក្នុងព្រៃប៉ុណ្ណោះ ក្រៃលែងជាងភិក្ខុដែលមិនសម្រេចឈាននៅក្នុងសេនាសនៈជិតស្រុក ។ ព្រោះដូច្នោះព្រះមានព្រះភាគ ទ្រង់អាស្រ័យប្រយោជន៍នោះឯង ទើបត្រាស់ថា នឹងជាអ្នកអាល័យក្នុងសេនាសនៈព្រៃ ។

បទថា បច្ចត្តំយេវ សតិ ឧបដ្ឋបេស្សន្តិ បានដល់ នឹងតាំងសតិទុកក្នុងខាងក្នុងរបស់ខ្លួន ។ បទថា បេសលា គឺ អ្នកគួរស្រឡាញ់ ។ ពួកភិក្ខុម្ចាស់ទីកន្លែង មិនប្រាថ្នាឲ្យមិត្តសព្រហ្មចារីមកក្នុងទីនេះ ជាអ្នកមិនមានសទ្ធា មិនជ្រះថ្លា រមែងមិនធ្វើសាមីចិកម្ម មានការទៅទទួលបាត្រចីវរ ក្រាលអាសនៈ បក់ដោយផ្លិតស្លឹកត្នោតជាដើម ដល់ពួកភិក្ខុដែលមកដល់ហើយ ។ គ្រានោះ សំឡេងតិះដៀលភិក្ខុទាំងនោះ ក៏ខ្ចរខ្ចាយទៅថា ពួកភិក្ខុវត្តឯណោះ មិនមានសទ្ធា មិនជ្រះថ្លា មិនធ្វើវត្តបដិបត្តិ

ដល់ពួកភិក្ខុអ្នកចូលទៅវត្ត ។ បព្វជិតទាំងឡាយ ស្តាប់រឿងនោះហើយ ក៏កន្ទុងទ្វារវត្ត មិនព្រមចូលវត្ត ។ ពួកភិក្ខុដែលនៅមិនទាន់មក រមែងមិនមក ដោយប្រការដូច្នេះ ។ ចំណែកពួកភិក្ខុដែលមកហើយ កាលមិនមានវត្តនៅជាសុខ ពួកភិក្ខុដែលមិនដឹងមកហើយ ក៏គិតមុនថា នឹងនៅ តែក៏ត្រូវត្រឡប់ចេញទៅ ដោយឃើញថា ពួកយើងនាំគ្នាមកហើយ តែដោយការមិននាំរបស់ភិក្ខុម្ចាស់អាវាសទាំងនេះ ។ កាលបើដូច្នោះ វត្តនោះភិក្ខុដទៃៗ ក៏មកនៅមិនបាន ។ តពីនោះ ពួកភិក្ខុម្ចាស់អាវាស កាលមិនបានជួបពួកភិក្ខុអ្នកមានសីល ក៏បណ្តែតបណ្តោយ មិនបានភិក្ខុដែលជួយបន្ទោបង់សេចក្តីសង្ស័យ ឬអ្នកឲ្យសិក្សាធម្មបរិយាយ ឬស្តាប់ធម៌ដ៏ពីរោះ ភិក្ខុម្ចាស់អាវាសទាំងនោះ ក៏មិនបានទទួលធម៌ ដែលមិនទាន់បានទទួល មិនបានធ្វើការស្វាធ្យាយធម៌ដែលទទួលទុកហើយ ។ ដូច្នោះ ភិក្ខុម្ចាស់អាវាសទាំងនោះ ទើបមានតែសេចក្តីសាបសូន្យទៅតែម្យ៉ាង មិនមានសេចក្តីចម្រើនឡើយ ។ ចំណែកភិក្ខុពួកណា បំណងនឹងឲ្យមិត្តសព្រហ្មចារីមកភិក្ខុទាំងនោះ មានសទ្ធា មានសេចក្តីជ្រះថ្លា ធ្វើការទទួលជាដើម ដល់មិត្តសព្រហ្មចារីដែលមកហើយ ចាត់សេនាសនៈឲ្យ នាំចូលទៅភិក្ខាចារ បន្ទោបង់សេចក្តីសង្ស័យ បានស្តាប់ធម៌ដ៏ពីរោះ កាលដូច្នោះ កិត្តិស័ព្ទរបស់ភិក្ខុទាំងនោះ ក៏ខ្ចរខ្ចាយទៅថា ពួកភិក្ខុក្នុងវត្តឯណោះ មានសទ្ធាជ្រះថ្លា ដល់ព្រមដោយវត្ត សង្គ្រោះយ៉ាងនេះ ភិក្ខុទាំងឡាយ បានស្តាប់រឿងនោះហើយ

សូម្បីឆ្ងាយ ក៏នាំគ្នាទៅរកពួកភិក្ខុម្ចាស់អាវាស ធ្វើវត្តដល់ភិក្ខុអាគន្តុកៈទាំងនោះមកជិតៗ ហើយសំពះអាគន្តុកៈដែលចាស់ជាង ហើយអង្គុយកាន់អាសនៈអង្គុយជិតៗ អាគន្តុកៈអ្នកខ្ចីជាង ហើយសួរថា ពួកលោកនឹងនៅក្នុងវត្តនេះឬ នឹងទៅ កាលអាគន្តុកៈ ឆ្លើយថា នឹងទៅ ក៏ពោលថា សេនាសនៈសប្បាយ ភិក្ខាក៏រកបានងាយ មិនព្រមឲ្យទៅ ។ បើអាគន្តុកៈជាវិន័យធរ ក៏ស្វាធ្យាយវិន័យក្នុងសម្នាក់ របស់ព្រះវិន័យធរ បើអាគន្តុកៈទ្រទ្រង់ព្រះសូត្រជាដើម ក៏ស្វាធ្យាយធម៌នោះៗ ក្នុងសម្នាក់របស់ព្រះធម្មធរនោះ នៅក្នុងឱវាទរបស់ព្រះអាគន្តុកៈដែលជាព្រះថេរៈ រមែងសម្រេចព្រះអរហត្តព្រមដោយបដិសម្ភិទា ។ ពួកព្រះអាគន្តុកៈ គិតនឹងនៅត្រឹមតែ ២ ថ្ងៃ ទើបពោលថា ពួកយើងនាំគ្នាមក ហើយក៏នឹងនៅត្រឹមតែ ១០-១២ ថ្ងៃ ព្រោះភិក្ខុទាំងនេះ មានការនៅរួមយ៉ាងសប្បាយ ។ គប្បីជ្រាបសេចក្តីចម្រើន និងសេចក្តីសាបសូន្យ ដោយប្រការដូច្នេះ ។

[៧១] គប្បីជ្រាបវិនិច្ឆ័យក្នុងសត្តកៈទី ២ ដូចតទៅនេះ ៖

ភិក្ខុឈ្មោះថា **កម្មារាម** ព្រោះមានការងារជាទីត្រេកអរ ។ ឈ្មោះថា **កម្មរត** ព្រោះត្រេកអរក្នុងការងារ ។ បទថា កម្មារាមតំ អនុយុត្តា សេចក្តីថា ប្រកបហើយ ប្រកបទូទៅហើយ ប្រកបតាមហើយ ។ ក្នុងបទទាំងនោះ ការងារដែលនឹងគប្បីធ្វើ ហៅថា **កម្ម** ។ គឺអ្វីខ្លះ ។ គឺ ដូចកាត់ចីវរ ធ្វើចីវរ ជួយគ្នាធ្វើវត្ត មានបំពង់ម្ជុល ស្មោកបាត្រ ខ្សែយោគ

វត្តព្វទ្ធបង្អែះ ជើងទ្រេបាទ ទ្រនាប់ជើង និងអំបោសជាដើម ។ ពិតហើយ ភិក្ខុរូបខ្លះ កាលធ្វើកិច្ចទាំងនេះ រមែងនាំគ្នាធ្វើទាំងថ្ងៃតែម្តង ។ លោក សំដៅយកសេចក្តីនោះ ទើបហាមទុកដូច្នេះ ។ ចំណែកភិក្ខុណាធ្វើកិច្ច ទាំងនោះ ក្នុងវេលាធ្វើកិច្ចទាំងនោះប៉ុណ្ណោះ ក្នុងវេលាឧទ្ទេស ក៏រៀនឧទ្ទេស ក្នុងវេលាសាធ្យាយ ក៏សាធ្យាយ វេលាបោសលានព្រះចេតិយ ក៏ធ្វើវត្តលើ លានព្រះចេតិយ ក្នុងវេលាមនសិការ ក៏ធ្វើមនសិការ ភិក្ខុនោះមិនឈ្មោះ ថា មានការងារជាទីត្រេកអរ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា ន ភស្សារាមា នេះ ដូចតទៅនេះ ៖

ភិក្ខុណាកាលធ្វើការប្រាស្រ័យចរចា ដោយរឿងមនុស្សស្រី-ប្រុស ជាដើម ឲ្យវេលាកន្លងអស់ថ្ងៃ និងយប់ ជជែកគ្នាដូច្នេះមិនចប់ ភិក្ខុនេះ ឈ្មោះថា មានការជជែកគ្នាដែលជាទីនាំមកនូវសេចក្តីត្រេកអរ ។ ចំណែក ភិក្ខុណា និយាយធម៌ ដោះស្រាយបញ្ហា ឈ្មោះថា មិនជជែកគ្នាដែលនាំ មកនូវសេចក្តីត្រេកអរ ភិក្ខុនេះឈ្មោះថា ជជែកគ្នាតិច ជជែកគ្នាមានទី បញ្ចប់ ។ ព្រោះហេតុអ្វី ព្រោះព្រះមានព្រះភាគត្រាស់ទុកថា ភិក្ខុទាំង ឡាយ ពួកអ្នកប្រជុំគ្នាមានករណីយ៍ ២ យ៉ាង គឺ និយាយធម៌ ឬស្ងៀម ដូចជាអរិយៈ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា ន និទ្ទារាមា នេះ ដូចតទៅនេះ ៖

ភិក្ខុណាដើរក្តី អង្គុយក្តី ដេកក្តី ត្រូវថីនមិទ្ធៈគ្របសង្កត់ហើយ

ក៏លក់បានទាំងអស់ ភិក្ខុនេះឈ្មោះថា មានការដេកលក់ជាទីត្រេកអរ ចំណែកភិក្ខុណា មានចិត្តធ្លាក់ចុះកវង្គ ព្រោះការឈឺចាប់តាមផ្លូវករដ្ឋកាយ ព្រោះហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា "ម្នាលអគ្គិវេស្សនៈ តថាគតដឹងក្រៃលែងថា ខាងចុងរដូវក្តៅ ក្រោយត្រឡប់ពីបិណ្ឌបាតហើយ ក្រាលសង្ឃាដិ ៤ ជាន់ មានសតិសម្បជញ្ញៈ ឈានចុះកាន់ការសឹងលក់ ដោយផ្អៀងខាងស្តាំ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា ន សង្គណិការាមា នេះ ដូចតទៅនេះ ៖

ភិក្ខុណាមានសម្លាញ់ ១ រូប ២ រូប ៣ រូប ៤ រូប នៅប្រឡូកប្រឡល់យ៉ាងនេះ មិនបានទទួលសេចក្តីត្រេកអរតែម្នាក់ឯង ភិក្ខុនេះឈ្មោះថា មានការប្រឡូកប្រឡល់ជាទីត្រេកអរ ។ ចំណែកភិក្ខុណាមានសេចក្តីត្រេកអរក្នុងឥរិយាបថ ទាំង ៤ តែម្នាក់ឯង ភិក្ខុនេះគប្បីជ្រាបថា មិនមែនជាអ្នកមានសេចក្តីប្រឡូកប្រឡល់ជាទីត្រេកអរ ។

ពួកភិក្ខុ ដែលប្រកបដោយសេចក្តីប្រាថ្នា ការលើកតម្កើងគុណដែលមិនមាន ជាអ្នកទ្រុស្តសីល ឈ្មោះថា ជាអ្នកប្រាថ្នាលាមកក្នុងពាក្យថា ន បាបិច្ឆា នេះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបាបមិត្តជាដើម ដូចតទៅនេះ ឈ្មោះថា **បាបមិត្ត** ព្រោះមានមិត្តអាក្រក់ ។ ឈ្មោះថា **បាបសហាយ** ព្រោះមាន

សម្មាញ់អាក្រក់ ដោយហេតុទៅជាមួយគ្នាក្នុងឥរិយាបថទាំង ៤ ។ ឈ្មោះថា **បាបសម្បវង្កោ** ព្រោះជាសម្មាញ់ក្នុងពួកភិក្ខុអាក្រក់ ហេតុជាអ្នកទោទន់តាមភិក្ខុអាក្រក់នោះ ។

បទថា ឱរមត្តកេន បានដល់ មានប្រមាណទាប មានប្រមាណតិច ។ បទថា អន្តរា បានដល់ ក្នុងរវាងមិនទាន់សម្រេចព្រះអរហត្តនោះ ។ បទថា ឱសានំ បានដល់ វៀរសេចក្ដីព្យាយាម រួញរាថា ល្មមប៉ុណ្ណឹងហើយ ដោយហេតុត្រឹមប៉ុណ្ណេះ បានដល់ បញ្ឈប់កិច្ច ។ លោកអធិប្បាយទុកដូច្នេះថា ភិក្ខុទាំងឡាយមិនដល់ទីបំផុតដោយផល ត្រឹមតែមានសីលបរិសុទ្ធិ ត្រឹមតែវិបស្សនា ត្រឹមតែឈាន ត្រឹមតែជាព្រះសោតាបន្ន ត្រឹមតែជាព្រះសកទាគាមី ឬត្រឹមតែជាព្រះអនាគាមី ត្រឹមណា ភិក្ខុទាំងឡាយ គប្បីប្រាថ្នាតែសេចក្ដីចម្រើនតែម្យ៉ាង មិនសាបសូន្យឡើយ ។

**[៧២] គប្បីជ្រាបវិនិច្ឆ័យក្នុងសត្តកៈទី ៣ ដូចតទៅនេះ ៖**

បទថា សទ្ធា បានដល់ ដល់ព្រមដោយសទ្ធា ។ ក្នុងសេចក្ដីថា សទ្ធា នោះ សទ្ធាមាន ៤ គឺ អាគមនីយសទ្ធា អធិគមសទ្ធា បសាទសទ្ធា ឱកប្បនសទ្ធា ។ បណ្ដាសទ្ធាទាំង ៤ នោះ **អាគមនីយសទ្ធា** រមែងមានដល់ព្រះពោធិសត្វជាសព្វញ្ញូ ។ **អធិគមសទ្ធា** រមែងមានដល់ ព្រះអរិយបុគ្គលទាំងឡាយ កាលពោលថា ពុទ្ធោ ធម្មោ សង្ឃោ ក៏ជ្រះថ្លា ឈ្មោះថា **បសាទសទ្ធា** ។ ចំណែកការដាក់ចិត្តជឿ ឈ្មោះថា **ឱកប្បនសទ្ធា** ។

ការជឿទាំង ២ នោះ លោកប្រាថ្នាយកក្នុងទីនេះ ។ ពិតហើយ ភិក្ខុដែលប្រកបដោយសទ្ធានោះ ជាអ្នកបង្អោនទៅក្នុងសទ្ធា ក៏ដូចព្រះវក្កលិត្ថេរ ។ សេចក្តីពិត ព្រះវក្កលិត្ថេរ ជាការធ្វើចេតិយង្គណវត្ត ឬថា ពោធិយង្គណវត្ត បំពេញវត្តគ្រប់យ៉ាង មានឧបជ្ឈាយវត្ត និងអាចរិយវត្តជាដើម ។ បទថា ហិរិមនា បានដល់ អ្នកមានចិត្តប្រកបដោយហិរិ ដែលមានលក្ខណៈស្អប់ខ្ពើមបាប ។ បទថា ឱត្តប្បី បានដល់ អ្នកប្រកបដោយឱត្តប្បៈ ដែលមានលក្ខណៈខ្លាចបាប ។

ក៏ក្នុងបទថា ពហុស្សុតា នេះ ពហុស្សូតមាន ២ គឺ បរិយត្តិពហុស្សូត បដិវេធពហុស្សូត ។ បិដក ៣ ឈ្មោះថា បរិយត្តិ ។ ការចាក់ធ្លុះសច្ចៈ ឈ្មោះថា បដិវេធ ។ ក៏ក្នុងទីនេះ លោកបំណងយកបរិយត្តិ ។ ភិក្ខុដែលមានសុតៈច្រើន ឈ្មោះថា ពហុស្សូត ។ ក៏ភិក្ខុពហុស្សូតនេះមាន ៤ គឺ និស្ស័យមុត្តកៈ បរិស្សុបដ្ឋាបកៈ ភិក្ខុនោវាទកៈ សព្វត្ថពហុស្សូតៈ ។ ក្នុង ៤ ទាំងនោះ ។ ពហុស្សូតៈ ៣ ពួក គប្បីកាន់យកបានតាមន័យដែលលោកពោលទុកហើយក្នុងឱវាទវគ្គ ក្នុងអដ្ឋកថាវិន័យឈ្មោះសមន្តបាសាទិកា ។ ពួកសព្វត្ថពហុស្សូតៈ ក៏ដូចជាព្រះអានន្ទត្ថេរ ។ ពួកសព្វត្ថពហុស្សូតៈនោះ លោកបំណងយកក្នុងទីនេះ ។ ឈ្មោះថា អារទ្ធវីរិយា បានដល់ ពួកភិក្ខុ ដែលប្រារព្ធសេចក្តីព្យាយាមផ្លូវកាយ និងផ្លូវចិត្ត ។ ក្នុងភិក្ខុទាំងនោះ ភិក្ខុពួកណា បន្ទោបង់សេចក្តីប្របូកប្របល់

ដោយនៅតែម្នាក់ឯង ក្នុងឥរិយាបថទាំង ៤ ដោយអារម្មណ៍ ៨ ភិក្ខុទាំង នោះ ឈ្មោះថា ប្រារព្ធសេចក្ដីព្យាយាមផ្លូវកាយ ។ ភិក្ខុពួកណាបន្ទោបង់ សេចក្ដីប្រេបូកប្រេបល់ ផ្លូវចិត្តនៅតែម្នាក់ឯង ដោយសមាបត្តិ ៨ មិនព្រម ឈរក្នុងកាលកិលេសកើតក្នុងខណៈដើរ ក៏មិនព្រមដេកក្នុងកាលកិលេស កើតក្នុងខណៈអង្គុយ គ្រប់សង្កត់កិលេសដែលកើតឡើងហើយ កើតឡើង ទៀត ភិក្ខុទាំងនោះ ឈ្មោះថា ប្រារព្ធសេចក្ដីព្យាយាមផ្លូវចិត្ត ។

បទថា ឧបដ្ឋិតស្សតិ បានដល់ រឭកដល់ តាមរឭកដល់កិច្ចដែល ធ្វើទុកហើយសូម្បីយូរជាដើម ដូចព្រះមហាគតិម្ពអភ័យត្ថេរ ព្រះទីឃក-អភ័យត្ថេរ និងព្រះតិបិដកចូឡាភយត្ថេរ បានឮថា ព្រះមហាគតិម្ពអភ័យ-ត្ថេរ ឃើញសត្វក្អែកកំពុងឈរបែរចំពុះទៅរកបាយមធុបាយាស ដែលជា មង្គល ក្នុងថ្ងៃទី ៥ គិតពីថ្ងៃខួនកើត ក៏ស្រែកមានសំឡេង អូ អូ ។ តមក កាលព្រះថេរៈត្រូវពួកភិក្ខុសួរថា លោកម្ចាស់ លោករឭកបានអំពី កាលណា ទើបពោលថា អ្នកមានអាយុ តាំងពីស្រែកយំឡើងក្នុងថ្ងៃទី ៥ រាប់ពីខួនកើត ។ មាតារបស់ព្រះទីឃកអភ័យត្ថេរ បង្អោនខ្លួនចុះបំណាង នឹងថើប តាំងពីថ្ងៃទី ៩ រាប់ពីព្រះថេរៈកើត ។ ផ្នួងសក់របស់នាងក៏ រំសាយ ។ តពីនោះ ផ្កាម្លិះប្រមាណមួយនាឡិ ក៏ធ្លាក់ទៅលើទ្រូងរបស់ ទារកធ្វើឲ្យកើតទុក្ខ ។ កាលជាព្រះថេរៈ លោកត្រូវពួកភិក្ខុសួរថា លោក ម្ចាស់រឭកបានតាំងពីកាលណា ឆ្លើយថា តាំងពីថ្ងៃទី ៩ រាប់ពីខួនកើត ។

ព្រះតិបិដកចូឡាភ័យត្ថេរ ពោលថា បើទបិទទ្វារ ៣ ខាងក្នុងអនុរាធបុរី ឲ្យមនុស្សចេញទ្វារមួយ ហើយសួរថា លោកឈ្មោះអ្វី អ្នកឈ្មោះអ្វី ដល់ពេលល្ងាចក៏មិនសួរទៀតទេ អាចចាំឈ្មោះរបស់មនុស្សទាំងនោះបាន ។ ក៏លោកសំដៅយកភិក្ខុបែបនោះ ទើបពោលថា **ឧបដ្ឋិតស្សតិ** ។ បទថា បញ្ញវន្តោ បានដល់ ប្រកបដោយបញ្ញា កំណត់ការកើតរលត់របស់បញ្ចក្ខន្ធជាអារម្មណ៍ ។ម្យ៉ាងទៀត ដោយពីរបទនេះ លោកពោលដល់សម្មាសតិនិងវិបស្សនាបញ្ញា ដែលជាហេតុឧបត្ថម្ភដល់វិបស្សនា របស់ពួកភិក្ខុអ្នកចម្រើនវិបស្សនា ។

**[៧៣] គប្បីជ្រាបវិនិច្ឆ័យក្នុងសត្តកៈទី ៤ ដូចតទៅនេះ**

សម្ពោជ្ឈង្គៈ គឺ សតិ ឈ្មោះថា សតិសម្ពោជ្ឈង្គៈ ។ គ្រប់បទទាំងអស់ក៏ន័យនេះ ។ ក្នុងសម្ពោជ្ឈង្គៈ សតិសម្ពោជ្ឈង្គៈ មានសេចក្តីប្រាកដជាលក្ខណៈ ធម្មវិចយសម្ពោជ្ឈង្គៈ មានការជ្រើសរើសជាលក្ខណៈ វីរិយសម្ពោជ្ឈង្គៈ មានការផ្គងចិត្តជាលក្ខណៈ បីតិសម្ពោជ្ឈង្គៈ មានការជ្រួតជ្រាបទៅជាលក្ខណៈ បស្សទ្ធិសម្ពោជ្ឈង្គៈ មានសេចក្តីស្ងប់ជាលក្ខណៈ សមាធិសម្ពោជ្ឈង្គៈ មានសេចក្តីមិនរវើរវាយជាលក្ខណៈ ឧបេក្ខាសម្ពោជ្ឈង្គៈ មានការពិចារណាជាលក្ខណៈ ។ បទថា ភាវេស្សន្តិ សេចក្តីថា ភិក្ខុទាំងឡាយតាំងសតិសម្ពោជ្ឈង្គៈ ដោយហេតុ ៤ , តាំងធម្មវិច័យសម្ពោជ្ឈង្គៈ ដោយហេតុ ៦ , តាំងវីរិយសម្ពោជ្ឈង្គៈ ដោយហេតុ ៩ ,

តាំងបីតិសម្ពោជ្ឈង្គៈ ដោយហេតុ ១០ , តាំងបស្សទ្ធិសម្ពោជ្ឈង្គៈ ដោយហេតុ ៧ , តាំងសមាធិសម្ពោជ្ឈង្គៈ ដោយហេតុ ១០ , តាំងឧបេក្ខា-សម្ពោជ្ឈង្គៈ ដោយហេតុ ៥ នឹងធ្វើឲ្យចម្រើន ។ លោកពោលសម្ពោជ្ឈង្គៈលាយគ្នាទាំងលោកិយៈ និងលោកុត្តរៈ ប្រកបដោយវិបស្សនា និងមគ្គផលដោយបទនេះ ។

**[៧៤] គប្បីជ្រាបវិនិច្ឆ័យក្នុងសត្តកៈទី ៥ ដូចតទៅនេះ**

សញ្ញាដែលកើតឡើងព្រមនឹងអនិច្ចានុបស្សនា ឈ្មោះថា **អនិច្ច-សញ្ញា** ។ សូម្បីក្នុងអនត្តសញ្ញាជាដើម ក៏ន័យនេះដូចគ្នា ។ គប្បីជ្រាបថាសញ្ញា ៧ នេះ ជាលោកិយវិបស្សនាក៏មាន សញ្ញា ២ ក្នុងទីនេះ ជាលោ-កុត្តរវិបស្សនាក៏មាន ដោយបាលីដែលមកថា

**និព្វាននេះស្ងប់ ប្រណីត គឺ ធម៌ដែល**

**រម្ងាប់សង្ខារទាំងពួង ។ល។ និរោធ**

**[៧៥] គប្បីជ្រាបវិនិច្ឆ័យក្នុងឆក្កៈដូចតទៅនេះ ៖**

បទថា មេត្តំ កាយកម្មំ បានដល់ កាយកម្មដែលគប្បីធ្វើដោយមេត្តាចិត្ត ។ សូម្បីក្នុងវចីកម្ម និងមនោកម្ម ក៏ន័យនេះដូចគ្នា ។ ក៏កម្មទាំង ៣ នេះ មកជារបស់ពួកភិក្ខុ សូម្បីក្នុងពួកគ្រហស្ថក៏ប្រើបាន ពិតហើយសម្រាប់ពួកភិក្ខុ ការបំពេញធម៌ គឺ អភិសមាចារដោយមេត្តាចិត្ត ឈ្មោះថាមេត្តាកាយកម្ម ។ សម្រាប់គ្រហស្ថ កិច្ចមានជាដើមយ៉ាងនេះ គឺ ការទៅ

សំពះព្រះចេតិយ សំពះដើមពោធិ និមន្តសង្ឃ ការជួបពួកភិក្ខុចូលស្រុកទៅបិណ្ឌបាត ហើយទទួលបាត្រ ក្រាលអាសនៈ ដើរតាមលាបប្រេង ។ ឈ្មោះថា មេត្តាកាយកម្ម ។ សម្រាប់ពួកភិក្ខុ ការទូន្មានអាចារៈ បញ្ញត្តិសិក្ខាបទ និងកម្មដ្ឋាន ការសម្តែងធម៌ សូម្បីព្រះត្រៃបិដក ពុទ្ធវចនៈដោយមេត្តាចិត្ត ឈ្មោះថា មេត្តាវចីកម្ម ។ ចំពោះគ្រហស្ថ ក្នុងវេលាពោលជាដើមថា ពួកយើងទៅសំពះព្រះចេតិយ ទៅសំពះដើមពោធិព្រឹក្ស ធ្វើការស្តាប់ធម៌ ឲ្យធ្វើការបូជាដោយផ្កាឈើ ធូប ទៀន សមាទានប្រព្រឹត្តសុចរិត ៣ ថ្វាយសលាកភត្តជាដើម ថ្វាយសំពត់ងូតទឹកភ្លៀង ថ្ងៃនេះថ្វាយបច្ច័យ ៤ ដល់សង្ឃ និមន្តសង្ឃថ្វាយរបស់ទំពារជាដើម ក្រាលអាសនៈ តាំងទឹកធាន់ ទួលសង្ឃនាំមកឲ្យគង់លើអាសនៈដែលក្រាលទុកកើតឆន្ទៈ ឧស្សាហ៍ ធ្វើការខ្វល់ខ្វាយ ឈ្មោះថា មេត្តាវចីកម្ម ។ ចំពោះភិក្ខុក្រោកឡើងពីព្រឹកព្រលឹម បដិបត្តិសរីរៈ និងធ្វើវត្តនៅទីលានព្រះចេតិយជាដើម អង្គុយលើអាសនៈដែលស្ងាត់ គិតថា សូមភិក្ខុទាំងឡាយក្នុងវត្តនេះ ចូរបានសុខ កុំមានពៀរ កុំបៀតបៀនគ្នាជាដើម ឈ្មោះថា មេត្តាមនោកម្ម ។ សម្រាប់គ្រហស្ថ គិតថា សូមលោកម្ចាស់ចូរបានសុខ កុំមានពៀរ កុំបៀតបៀនគ្នា ឈ្មោះថា មេត្តាមនោកម្ម ។

បទថា អាវិ ចេវ រហោ ច បានដល់ ក្នុងទីចំពោះមុខ និងទីកំបាំងមុខ ។ ក្នុងបទនោះ ការរួមគ្នាក្នុងចីវរកម្មជាដើម សម្រាប់ភិក្ខុទាំងឡាយ

ឈ្មោះថា មេត្តាកាយកម្មចំពោះមុខ ។ តែសម្រាប់ព្រះថេរៈ សាមីចិកម្មទាំងអស់ សូម្បីផ្សេងដោយការលាងជើង និងបក់ផ្លិតជាដើម ក៏ឈ្មោះថា មេត្តាកាយកម្មចំពោះមុខ ។ មិនធ្វើការមើលងាយក្នុងភិក្ខុទាំងនោះ ហើយរក្សាទុកដាក់វត្ថុ មានគ្រឿងឈើជាដើម ដែលសូម្បីភិក្ខុ ២ ចំណែករក្សាទុកមិនល្អ ដូចដែលខ្លួនរក្សាទុកមិនល្អ ឈ្មោះថា មេត្តាកាយកម្មកំបាំងមុខ ។ ការពោលលើក តម្កើងយ៉ាងនេះថា ព្រះទេវត្ថេរ ព្រះតិស្សត្ថេរ ឈ្មោះថា មេត្តាវចីកម្មចំពោះមុខ ។ ការដែលភិក្ខុសាកសួរដល់អ្នកដែលមិនមាននៅក្នុងវត្ត ពោលពាក្យដែលគួរស្រឡាញ់ថា ព្រះថេរៈទៅណា ព្រះតិស្សត្ថេរទៅណា កាលណានឹងមក ដូច្នេះ ឈ្មោះថា មេត្តាវចីកម្មកំបាំងមុខ ការបើកភ្នែកដែលថ្លាផូរផង់ ដោយសេចក្តីប្រាថ្នាល្អ និងសេចក្តីព្រួយបារម្ភ សម្លឹងមើលដោយទឹកមុខថ្លាផូរផង់ ឈ្មោះថា មេត្តាមនោកម្មចំពោះមុខ ។ ការតាំងចិត្តថា សូមព្រះទេវត្ថេរ ព្រះតិស្សត្ថេរ ចូរជាអ្នកមិនមានរោគ មិនមានអាពាធ ឈ្មោះថា មេត្តាមនោកម្មកំបាំងមុខ ។

បទថា លាភា បានដល់ បច្ច័យដែលបានមក មានចីវរជាដើម ។ បទថា ធម្មិកា សេចក្តីថា វៀរមិច្ឆាជីវៈផ្សេងៗ ដោយការបោកបញ្ឆោតជាដើម កើតដោយភិក្ខាចារវត្ត ដោយធម៌ដែលស្មើ ។ បទថា អន្តមសោ បត្តបរិយាបន្នមត្តម្បិ សេចក្តីថា ដោយយ៉ាងទាបទីបំផុត សូម្បីត្រឹមតែភិក្ខា ២-៣ វែក ដែលជាប់ក្នុងបាត្រ គឺ ដែលនៅខាងក្នុងបាត្រ ។ ក្នុង

ពាក្យថា អប្បដិវិភត្តភោគី នេះ បដិវិភត្ត មាន ២ យ៉ាង គឺ អាមិសបដិវិភត្ត បុគ្គលបដិវិភត្ត ។ ក្នុង ២ យ៉ាងនោះ ការបែងចែកដោយចិត្តគិតយ៉ាងនេះថា យើងនឹងឲ្យប៉ុណ្ណេះ នឹងមិនឲ្យប៉ុណ្ណេះ ឈ្មោះថា **អាមិសបដិវិភត្ត** ។ ការបែងចែកដោយចិត្ត គិតយ៉ាងនេះថា យើងនឹងឲ្យអង្គឯណោះ មិនឲ្យដល់អង្គឯណោះ ដូច្នេះ ឈ្មោះថា **បុគ្គលបដិវិភត្ត** ។ ភិក្ខុមិនធ្វើសូម្បីទាំង ២ យ៉ាង បរិភោគបច្ច័យដែលនៅមិនបានបែងចែក ឈ្មោះថា **អប្បដិវិភត្តភោគី** ។ ក្នុងពាក្យថា សីលវន្តេហិ សព្រហ្មចារីហិ សាធារណភោគី នេះ ជាលក្ខណៈរបស់ភិក្ខុអ្នកបរិភោគទូទៅ ។ ភិក្ខុបានលាភណាៗ ដែលប្រណីត ឲ្យលាភនោះដល់ពួកគ្រហស្ថដោយមុខ គឺ ការតលាភដោយលាភក៏មិនមែន បរិភោគដោយខ្លួនឯងក៏មិនមែន ។ កាលទទួលក៏ចាត់ទុកថា ចូរទូទៅនឹងសង្ឃ យើញលាភដែលគេគោះរគាំងហើយ បរិភោគដូចរបស់សង្ឃ ។ សួរថា នរណាៗ បំពេញ នរណាមិនបំពេញសារាណីយធម៌នេះ ។ ឆ្លើយថា ភិក្ខុដែលទ្រុស្តសីលមិនបំពេញ ។ ព្រោះភិក្ខុដែលមានសីល មិនព្រមទទួលរបស់របរភិក្ខុនោះ ។ ចំណែកភិក្ខុអ្នកមានសីលបរិសុទ្ធិ បំពេញវត្តមិនដាច់ ។ វត្តក្នុងសេចក្តីនោះ មានឧទាហរណ៍ដូច្នេះ ។

## សារាណីយធម៌បែក

ក៏ភិក្ខុណា ឲ្យដោយចំពោះដល់មាតាបិតា ឬអាចារ្យ និងឧបជ្ឈាយ៍ ជាដើម ភិក្ខុនោះ រមែងឲ្យវត្ថុដែលគួរឲ្យ ភិក្ខុនោះមិនមានសារាណីយធម៌ ឈ្មោះថា បដិបត្តិដោយសេចក្តីកង្វល់ ។ ពិតមែន សារាណីយធម៌ រមែងគួរដល់បុគ្គលដែលផុតសេចក្តីកង្វល់ប៉ុណ្ណោះ ។ ក៏ភិក្ខុនោះ កាលឲ្យដោយចំពោះ គប្បីឲ្យដល់ភិក្ខុឈឺ ភិក្ខុអ្នករក្សាភិក្ខុមានជម្ងឺ ដល់ភិក្ខុអាគន្តុកៈ ភិក្ខុដែលត្រៀមនឹងទៅ និងភិក្ខុបួសថ្មី អ្នកមិនដឹងការទទួលសង្ឃាដិ និងបាត្រ ។ គួរឲ្យដល់ជនទាំងនោះ ចំណែកដ៏សេសមិនឲ្យតិចតួច តាំងពីថេរាសនៈ ហើយគប្បីឲ្យស្មើដែលភិក្ខុនឹងទទួលបាន ។ កាលចំណែកដែលនៅសល់មិនមាន ត្រាច់ទៅបិណ្ឌបាតទៀត ឲ្យវត្ថុដែលប្រណីតៗ តាំងពីថេរាសនៈ ហើយបរិភោគចំណែកដែលនៅសល់ ។ មិនគួរឲ្យដល់ភិក្ខុទ្រុស្តសីល ព្រោះព្រះបាលីថា សីលវន្តេហិ ដូច្នេះ ។ ក៏សារាណីយ-ធម៌នេះ បំពេញបានលំបាក សម្រាប់បរិស័ទដែលមិនទាន់បានសិក្សា បំពេញមិនលំបាកសម្រាប់បរិស័ទដែលបានសិក្សាហើយ ។ ភិក្ខុណាបានរបស់ដោយផ្លូវដទៃ ភិក្ខុនោះ រមែងមិនកាន់យក ។

សូម្បីកាលមិនបានដោយផ្លូវដទៃ ក៏ទទួល តែគួរដល់ប្រមាណប៉ុណ្ណោះ មិនទទួលឲ្យច្រើនពេក ។ ក៏សារាណីយធម៌នេះ ១២ ឆ្នាំ ទើបនឹងបរិបូរណ៍ សម្រាប់ភិក្ខុដែលត្រាច់បិណ្ឌបាតរឿយ ៗ ហើយឲ្យរបស់

ដែលបានមកៗ ដោយប្រការដូច្នេះ មិនតិចជាងនោះ ។ ក៏បើភិក្ខុបំពេញសារាណីយធម៌គ្រប់ឆ្នាំទី ១២ ដាក់បាត្រដែលពេញដោយអាហារ ទុកក្នុងរោងឆាន់ហើយ ទៅស្រង់ទឹក ព្រះសង្ឃត្រូវសួរថា នោះបាត្ររបស់អ្នកណា កាលភិក្ខុដទៃឆ្លើយថា របស់ភិក្ខុដែលបំពេញសារាណីយធម៌ ទើបពោលថា នាំបាត្រនោះមកចុះ ហើយចែកចាយអាហារក្នុងបាត្រទាំងអស់ហើយឆាន់ ដាក់តែបាត្រទទេទុកទីនោះ ភិក្ខុនោះឃើញបាត្រទទេ កើតការទាស់ចិត្តថា ភិក្ខុទាំងឡាយឆាន់មិនបន្សល់ទុកឲ្យយើងផងឡើយ សារាណីយធម៌ក៏បែក ។ ត្រូវបំពេញ ១២ ឆ្នាំ សាជាថ្មី ។ ក៏សារាណីយធម៌ក៏ដូចតិត្ថិយបរិវាស កាលដាច់មួយដង ក៏ត្រូវបំពេញជាថ្មី ។ ចំណែកភិក្ខុណាកើតសេចក្តីសប្បាយចិត្តថា នេះជាលាភរបស់យើងហ្ន៎ យើងបានល្អហើយហ្ន៎ ដែលយើងមិនត្រូវប្រាប់ដល់វត្ថុដែលមាននៅក្នុងបាត្រ មិត្តសព្រហ្មចារីក៏នាំគ្នាឆាន់ ក៏ឈ្មោះថា សារាណីយធម៌នោះពេញហើយ ។ ក៏ភិក្ខុដែលមានសារាណីយធម៌ពេញយ៉ាងនេះហើយ រមែងមិនមានសេចក្តីឫស្យា មិនមានសេចក្តីកំណាញ់ ។ ភិក្ខុនោះ រមែងជាទីស្រឡាញ់របស់មនុស្សទាំងឡាយ និងរមែងរកបច្ច័យបានងាយ ។ របស់ដែលនៅក្នុងបាត្រ ដែលគេថ្វាយដល់ភិក្ខុនោះ រមែងមិនអស់ទៅ ។ លោករមែងបានតែរបស់ដ៏ប្រសើរក្នុងទីដែលគេចែករបស់ ។ កាលប្រសព្វភ័យ ឬសេចក្តីស្រេកខ្លួន ពួកទេវតាក៏ជួយខ្វល់ខ្វាយ ។ ក្នុងសេចក្តីនោះ មានរឿងនេះ

ជាឧទាហរណ៍ ។

## សារាណីយធម៌ពេញ

គេជំណាលថា ព្រះតិស្សត្ថេរ នៅក្នុងលេណគិរិ អាស្រ័យមហាគិរីគ្រាម ។ ព្រះមហាថេរៈ ៥០ រូប ទៅកាន់នាគទ្វីប ប្រាថ្នានឹងសំពះព្រះចេតិយ ត្រាច់បិណ្ឌបាតក្នុងសិរីគ្រាម មិនបានអ្វីៗ ឡើយ ក៏នាំគ្នាចេញទៅ ។ ក៏ព្រះថេរៈ កាលចូលទៅជួបព្រះថេរៈទាំងនោះហើយ សួរថា លោកម្ចាស់បានអាហារហើយឬ ។ ឆ្លើយថា ពួកយើងនឹងនាំគ្នាទៅកាន់ទីចារិក អ្នកមានអាយុ ។ ព្រះថេរៈដឹងថា ព្រះថេរៈទាំងនោះមិនបានអាហារ ទើបពោលថា លោកម្ចាស់មេត្តារង់ចាំនៅត្រង់នេះសិន បន្តិចទៀតខ្ញុំនឹងមក ។ ឆ្លើយថា យើងមានដល់ទៅ ៥០ រូប មិនបានសូម្បីត្រឹមតែទឹកសើមបាត្រ ។ ព្រះថេរៈនិយាយថា លោកម្ចាស់ធម្មតាថា ភិក្ខុប្រចាំអាវាស រមែងជាអ្នកអាចសូម្បីកាលមិនបាន ក៏ស្គាល់ភិក្ខុដែលជាសម្ងាត់ផ្លូវភិក្ខាចារ ។ ព្រះថេរៈទាំងឡាយនាំគ្នាមកហើយ ។ ព្រះថេរៈក៏ចូលមកស្រុក ។ មហាឧបាសិកាក្នុងស្រុកជិតៗ ក៏ចាត់ទឹកដោះ និងអាហារចាំព្រះថេរៈ ពេលព្រះថេរៈមកដល់ទ្វារស្រុក ក៏ថ្វាយពេញបាត្រ ។ ព្រះតិស្សត្ថេរនោះ ក៏នាំបិណ្ឌបាតទៅកាន់សម្នាក់ព្រះថេរៈទាំងឡាយ ពោលនឹងព្រះសង្ឃត្ថេរថា សូមលោកម្ចាស់មេត្តាទទួលចុះ ។ ព្រះថេរៈសម្លឹង

មើលមុខព្រះថេរៈដទៃៗ ដោយគិតថា ពួកយើងដល់ប៉ុណ្ណោះមិនបានអ្វីឡើយ តែព្រះថេរៈរូបនេះទៅតែមួយរំពេចក៏ត្រឡប់មក យ៉ាងណាហ្ន៎ ។ ព្រះតិស្សត្ថេរ ដឹងដោយអាការដែលសម្លឹងមើលប៉ុណ្ណោះពោលថា លោកម្ចាស់ ពួកលោកកុំកង្វល់ចិត្តឡើយ មេត្តាទទួលបិណ្ឌបាតដែលបានមកដោយសប្បាយចុះ ហើយក៏ថ្វាយអាហារល្មមនឹងសេចក្តីត្រូវការ ដល់ព្រះថេរៈគ្រប់រូបតាំងពីដើម សូម្បីខ្លួនឯងក៏បានឆាន់គ្រប់គ្រាន់ ។ កាលឆាន់សម្រេចហើយ ព្រះថេរៈទាំងឡាយក៏សួរព្រះតិស្សត្ថេរនោះថា អ្នកមានអាយុ សម្រេចលោកុត្តរធម៌កាលណា ។ ព្រះតិស្សត្ថេរ ឆ្លើយថា លោកុត្តរធម៌របស់ខ្ញុំ មិនមានទេលោកម្ចាស់ ។ សួរថា អ្នកមានអាយុ លោកបានឈានឬ ។ ឆ្លើយថា សូម្បីយ៉ាងនេះក៏មិនមានដែរ លោកម្ចាស់ ។ សួរថា អ្នកមានអាយុគួរអស្ចារ្យណាស់ហ្ន៎ ។ ឆ្លើយថា លោកម្ចាស់ ខ្ញុំបំពេញសារាណីយធម៌ តាំងពីវេលាដែលសារាណីយធម៌របស់ខ្ញុំនោះសម្រេចហើយ សូម្បីបើមានភិក្ខុមួយសែនរូប វត្ថុដែលនៅក្នុងបាត្រ ក៏មិនអស់ទៅ ។ ព្រះថេរៈ ទាំងនោះ ស្តាប់ហើយក៏នាំគ្នាពោលថា សាធុ សាធុ លោកសប្បុរស ធម៌នេះរបស់លោក សមគួរហើយ ។ ក្នុងពាក្យថា បត្តគតំ ន ខីយតិ របស់ដែលនៅក្នុងបាត្រមិនអស់ទៅនេះ មានរឿងប៉ុណ្ណោះសិន ។

មួយទៀត ព្រះថេរៈអង្គនេះឯង ទៅកាន់ទីឲ្យទាននៅគិរិភណ្ឌមហា

បូជា ឯចេតិយបព៌ត ក៏សួរគេថា ក្នុងទាននេះអ្វីជាវត្ថុដ៏កំពូល ។ ឆ្លើយថា សំពត់សាដក ២ ផ្ទាំង លោកម្ចាស់ ។ ព្រះថេរៈនិយាយថា សំពត់សាដក ២ ផ្ទាំងទាំងនោះ នឹងត្រូវបានមកយើង ។ អាមាត្របានស្ដាប់ដូច្នោះហើយ ទើបក្រាបទូលដល់ព្រះរាជាថា ភិក្ខុកម្លោះមួយរូប និយាយយ៉ាងនេះ ។ ព្រះរាជាត្រាស់ថា ភិក្ខុកម្លោះមានចិត្តគិតយ៉ាងនេះ តែសំពត់សាដកសាច់ល្អិតគួរដល់ព្រះមហាថេរៈទាំងឡាយ ទើបតាំងទុក ដោយសំដៅនឹងថ្វាយព្រះថេរៈទាំងឡាយ ។ ព្រះរាជាកាលនឹងថ្វាយក្នុងកាលភិក្ខុសង្ឃឈរវៀងគ្នា សំពត់សាដក ២ ផ្ទាំងដែលដាក់ទុកជិតៗ ក៏មិនឡើងកាន់ព្រះហស្ដ ឡើងតែសំពត់ផ្ទាំងដទៃៗ តែក្នុងវេលាដែលថ្វាយភិក្ខុកម្លោះសំពត់សាដក ២ ផ្ទាំងនោះ ឡើងកាន់ព្រះហស្ដរបស់ព្រះរាជា ។ ស្ដេចដាក់ទុកក្នុងដៃរបស់ភិក្ខុកម្លោះនោះ មើលមុខរបស់អាមាត្រ ឲ្យភិក្ខុកម្លោះអង្គុយថ្វាយទាន ទ្រង់លះសង្ឃហើយ ប្រថាប់ជិតភិក្ខុកម្លោះ ត្រាស់ថា លោកម្ចាស់ លោកសម្រេចធម៌កាលណា ។ ភិក្ខុកម្លោះនោះមិនទូលដល់គុណដែលមិនមានសូម្បីផ្លូវអម ទូលថា ថ្វាយព្រះពរ លោកុត្តរធម៌របស់អាត្មាភាពមិនមានទេ ។ ត្រាស់ថា លោកម្ចាស់ ពីមុនលោកបាននិយាយទុកមិនមែនឬ ។ ទូលថា ថ្វាយព្រះពរ ពិតហើយ អាត្មាភាពបំពេញសាភាណីយធម៌ តាំងពីវេលាដែលធម៌នោះរបស់អាត្មាភាពសម្រេចហើយ វត្ថុដ៏ប្រសើរក៏មកដល់ក្នុងស្ថានទីចែក ។ ព្រះរាជាត្រាស់ថា សាធុ

សាធុ លោកម្ចាស់ គុណធម៌នេះរបស់លោកម្ចាស់ សមគួរពិត ហើយក៏ស្តេចត្រឡប់ ។ ក្នុងពាក្យថា ភាជនីយដ្ឋានេ អគ្គភណ្ឌំ ចាបុណាតិ វត្ថុដ៏ប្រសើរដល់ក្នុងស្ថានទីចែកចាយនេះ មានរឿងដូចពោលមកនេះ ។

ម្យ៉ាងទៀត មនុស្សនៅភាគក្រោម ក្នុងព្រាហ្មណតិស្សភ័យនគរ មិនពោលលាដល់ព្រះនាគថេរី នាំគ្នាចៀសចេញទៅ ។ វេលាជិតភ្លឺ ព្រះថេរីនិយាយចំពោះពួកភិក្ខុនីក្រមុំថា ភូមិស្រុកស្ងប់ស្ងៀមពេកណាស់ នាងនាំគ្នាទៅមើលមើល៍ ។ ភិក្ខុនីក្រមុំទាំងនោះទៅមើល ក៏ដឹងថា អ្នកស្រុក នាំគ្នាភៀសខ្លួនទៅអស់ហើយ ទើបមកប្រាប់ដល់ព្រះថេរី ។ ព្រះថេរីនោះ ស្តាប់ហើយក៏ពោលថា ពួកអ្នកកុំគិតថា អ្នកស្រុកទាំងនោះភៀសខ្លួនទៅឡើយ ចូរធ្វើសេចក្តីព្យាយាមក្នុងការរៀនសូត្របាលី អដ្ឋកថា និងយោនិសោមនសិការរបស់ខ្លួនប៉ុណ្ណោះ វេលាភិក្ខាចារក៏ដណ្តប់សំពត់ រួមគ្នា ១២ រូប រួមទាំងខ្លួនឯង សូម្បីឈរនៅត្រង់គល់ដើមជ្រៃជិតទ្វារស្រុក ទេវតាដែលស្ថិតនៅត្រង់ដើមឈើ ក៏ថ្វាយបិណ្ឌបាតដល់ភិក្ខុនី ១២ រូប ហើយពោលថា ព្រះម៉ែម្ចាស់ កុំទៅទីដទៃឡើយមេត្តានៅទីនេះជានិច្ចចុះ ។ តែព្រះថេរីមានប្អូនប្រុសឈ្មោះព្រះនាគត្ថេរ ព្រះថេរៈគិតថា មានភ័យធំ យើងមិនអាចនៅក្នុងទីនេះបាន នឹងទៅត្រើយឯណោះ មានភិក្ខុ ១២ រូប ទាំងខ្លួន ចេញចាកទីនៅរបស់ខ្លួន មកកាន់ភាគក្រោម ដោយបំណងថា នឹងជួបព្រះថេរីហើយ ទើបនឹងទៅ ។ ព្រះថេរីជ្រាបថា ពួកព្រះថេរៈនាំ

គ្នាមកហើយ ទើបទៅសម្នាក់របស់ព្រះថេរៈទាំងនោះ សួរថា មានអ្វីដែរ លោកម្ចាស់ ។ ព្រះថេរៈក៏ប្រាប់រឿងនោះ ។ ព្រះថេរីប្រាប់ថា ថ្ងៃនេះ ពួកលោកចូរនៅក្នុងវត្តនេះមួយថ្ងៃសិនហើយ ស្អែកសឹមទៅ ។ ព្រះថេរៈទាំងឡាយក៏នាំគ្នាទៅកាន់វត្ត ។ ស្អែកព្រះថេរីត្រាច់បិណ្ឌបាត ត្រង់ទីគល់ឈើ ចូលទៅរកព្រះថេរៈនិយាយថា លោកឆាន់បិណ្ឌបាតនេះចុះ ។ ព្រះថេរៈពោលថា នឹងគួរឬព្រះថេរី ហើយក៏ឈរស្ងៀម ។ ព្រះថេរីពោលថា លោកម្ចាស់ បិណ្ឌបាតនេះ បានមកដោយធម៌ កុំរង្កៀស មេត្តាឆាន់ចុះ ។ ព្រះថេរៈនិយាយថា គួរឬ ព្រះថេរី ។ ព្រះថេរីចាប់បាត្របាន ក៏បោះទៅក្នុងអាកាស ។ បាត្រក៏តាំងនៅក្នុងអាកាស ។ ព្រះថេរៈក៏ពោលថា ព្រះថេរី ភត្តសូម្បីតាំងនៅក្នុងទីកំពស់ ៧ ដើមត្នោត ក៏ជាភត្តសម្រាប់ភិក្ខុនីនុ៎ះឯង ហើយពោលទៀតថា ឈ្មោះថា ភ័យ មិនមែនមានគ្រប់កាល កាលភ័យស្ងប់ យើងក៏ពោលដល់អរិយវង្ស លោកត្រូវដាស់តឿនដោយចិត្តថា ម្នាលលោកអ្នកកាន់បិណ្ឌបាតិកធុតង្គ ពួកលោកមេត្តាឆាន់អាហាររបស់ភិក្ខុនីបែបនេះ រឿយៗ ចុះដូច្នេះ ខ្ញុំមិនអាចជួយបាន ភិក្ខុនីទាំងឡាយ ពួកលោកចូរជាអ្នកមិនប្រមាទចុះ ហើយចេញដំណើរទៅ ។ សូម្បីរុក្ខទេវតាក៏គិតថា បើព្រះថេរៈឆាន់បិណ្ឌបាតអំពីដៃព្រះថេរី យើងនឹងមិននាំព្រះថេរៈនោះត្រឡប់ បើព្រះថេរៈ មិនឆាន់ក៏នឹងនាំត្រឡប់ ឈរមើលព្រះថេរៈទៅ ចុះអំពីដើមឈើនិយាយថា មេត្តាឲ្យបាត្រមកលោកម្ចាស់

ហើយទទួលបាត្រនាំព្រះថេរៈមកត្រង់គល់ឈើនោះឯង ក្រាលអាសនៈថ្វាយបិណ្ឌបាត ឲ្យព្រះថេរៈអ្នកឆាន់ស្រេចហើយ បដិញ្ញាណទំនុកបម្រុងភិក្ខុនី ១២ រូប ភិក្ខុ ១២ រូប ៧ ឆ្នាំ ក្នុងសេចក្តីនេះថា ទេវតា ឧស្សុក្កំ អាបជ្ជន្តិ ទេវតា រមែងជួយជ្រោមជ្រែង មានរឿងដូចពោលមកនេះ ។ ពិតហើយ ក្នុងសេចក្តីនោះ ព្រះថេរីក៏បានជាអ្នកបំពេញសាភាណីយធម៌ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា អខណ្ឌានិ ជាដើម ដូចតទៅនេះ ៖

ភិក្ខុណាមានសិក្ខាបទដាច់ក្នុងខាងដើម ឬទីបំផុតក្នុងអាបត្តិទាំង ៧ កង សីលរបស់ភិក្ខុនោះ ឈ្មោះថា **ដាច់** ដូចសំពត់ដាច់ត្រង់ជាយ ។ មួយទៀត ភិក្ខុណាមានសិក្ខាបទដាច់ត្រង់កណ្តាល សីលរបស់ភិក្ខុនោះ ឈ្មោះថា **ធ្លុះ** ដូចសំពត់ធ្លុះកណ្តាលផ្ទាំង ។ ចំណែកភិក្ខុណាមានសិក្ខាបទ ២-៣ សិក្ខាបទ ដាច់តាមលំដាប់ សីលរបស់ភិក្ខុនោះ ឈ្មោះថា **ពព្រុស** ដូចមេគោមានពណ៌ខ្មៅលាយពណ៌ក្រហមជាដើម ដោយពណ៌ដែលផ្សេងគ្នានៅត្រង់ខ្នងខ្លះ ពោះខ្លះ ។ ភិក្ខុណាមានសិក្ខាបទដាច់ក្នុងចន្លោះៗ សីលរបស់ភិក្ខុនោះ ឈ្មោះថា **ពពាល** ដូចមេគោមានពណ៌អុជផ្សេងៗ ក្នុងចន្លោះៗ ។ ចំណែកភិក្ខុណា មានសិក្ខាបទមិនដាច់ សីលទាំងនោះ របស់ភិក្ខុនោះ ឈ្មោះថា មិនដាច់ មិនធ្លុះ មិនពព្រុស មិនពពាល ។ ក៏សីលនោះ ៗ ឈ្មោះថា ជាអ្នកគ្មានបំណុល ព្រោះធ្វើឲ្យផុតពីភាពជាទាសតណ្ហា ត្រឡប់ជាគ្មានបំណុល ឈ្មោះថា វិញ្ញូជនសរសើរហើយ ព្រោះវិញ្ញូជន មាន

ព្រះពុទ្ធជាដើម ទ្រង់សរសើរហើយ ឈ្មោះថា ដែលកិលេសមិនពាល់ត្រូវ ព្រោះតណ្ហា និងទិដ្ឋិមិនពាល់ត្រូវហើយ និងព្រោះដែលនរណាៗ មិនអាចប្រមាទមើលងាយថា លោកធ្លាប់ត្រូវអាបត្តិឈ្មោះនេះ ។ លោកហៅថា ប្រព្រឹត្តទៅដើម្បីសមាធិ ព្រោះញ៉ាំងឧបចារសមាធិ ឬអប្បនាសមាធិឲ្យប្រព្រឹត្តទៅ ។ បទថា សីលសាមញ្ញគតា វិហរិស្សន្តិ បានដល់ នឹងមានសីលស្មើនឹងភិក្ខុអ្នកនៅក្នុងទិសាភាគនោះៗ ឯង ។ ពិតហើយ សីលរបស់ព្រះសោតាបន្នជាដើម រមែងស្មើនឹងសីលរបស់ព្រះសោតាបន្នជាដើម ពួកដទៃអ្នកនៅក្នុងចន្លោះសមុទ្រក្តី ក្នុងទេវលោកក្តី ។ សេចក្តីផ្សេងគ្នាក្នុងសីលដែលប្រកបដោយមគ្គផលមិនមាន ។ លោកសំដៅយកប្រការនោះ ទើបពោលពាក្យនេះ ។

បទថា យាយំ ទិដ្ឋិ បានដល់ សម្មាទិដ្ឋិដែលសម្បយុត្តដោយមគ្គ ។ បទថា អរិយា បានដល់ មិនមានទោស ។ បទថា និយ្យាតិ បានដល់ នាំទុក្ខចេញទៅ ។ បទថា តក្ករស្ស បានដល់ អ្នកធ្វើយ៉ាងនោះ ។ បទថា សម្មាទុក្ខក្ខយាយ បានដល់ ដើម្បីការអស់ទុក្ខក្នុងវដ្ដៈទាំងពួង ។ បទថា ទិដ្ឋិសាមញ្ញគតា សេចក្តីថា នឹងជាអ្នកចូលដល់ភាពជាអ្នកមានទិដ្ឋិស្មើគ្នា ។ បទថា វុឌ្ឍិយេវ សេចក្តីថា ភិក្ខុអ្នកនៅយ៉ាងនេះ គប្បីប្រាថ្នាសេចក្តីចម្រើនលូតលាស់តែម្យ៉ាង មិនសាបសូន្យឡើយ ។

បទថា ឯតទេវ ពហុលំ សេចក្តីថា ព្រះមានព្រះភាគ កាលទ្រង់

ប្រទានឱវាទភិក្ខុទាំងឡាយ ទើបទ្រង់ធ្វើធម្មីកថាយ៉ាងនេះឯងរឿយៗ ព្រោះជិតបរិនិព្វាន ។ បទថា **ឥតិ សីលំ** គឺ សីលយ៉ាងនេះ សីលប៉ុណ្ណេះ ។ ក្នុងសេចក្តីនោះ គប្បីជ្រាបថា ចតុប្បារិសុទ្ធិសីល ឈ្មោះថា **សីល** ។ ចិត្តេកគ្គតា ឈ្មោះថា **សមាធិ** ។ វិបស្សនា ឈ្មោះថា **បញ្ញា** ។ គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា សីលបរិភាវិតោ ដូច្នេះ ភិក្ខុទាំងឡាយតាំងនៅក្នុងសីលណា រមែងកើតសមាធិដែលសម្បយុត្តដោយមគ្គ សមាធិដែលសម្បយុត្តដោយផលសមាធិនោះ ដែលសីលនោះអប់រំហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ។ ភិក្ខុទាំងឡាយតាំងនៅក្នុងសមាធិណា រមែងកើតបញ្ញា ដែលសម្បយុត្តដោយមគ្គប្បញ្ញា ដែលសម្បយុត្តដោយផលប្បញ្ញានោះ ដែលសមាធិនោះអប់រំហើយ រមែងមានផលច្រើន មានអានិសង្សច្រើន ។ ភិក្ខុទាំងឡាយ តាំងនៅក្នុងបញ្ញាណា រមែងកើតមគ្គចិត្ត ផលចិត្ត ចិត្តនោះ ដែលបញ្ញានោះអប់រំហើយ រមែងរួចផុតពីអាសវៈទាំងឡាយ ដោយប្រពៃតែម្យ៉ាង ។

## ព្រះមានព្រះភាគស្តេចយាងកាន់អម្ពលដ្ឋិកាឧទ្យាន

**[៧៦]** បទថា យថាភិរន្តំ សេចក្តីថា ឈ្មោះថា ការមិនត្រេកអរក្រៃលែង សេចក្តីភ័យតក់ស្លុតរបស់ព្រះពុទ្ធជាដើម មិនមាន ។ តែលោកអធិប្បាយថា តាមសេចក្តីពេញចិត្ត តាមអធ្យាស្រ័យ ។ បទថា អាយាម

ប្រែថា មកទៅជាមួយគ្នាចុះ បាឋៈថា **អយាម** ក៏មាន ។ អធិប្បាយថា ទៅជាមួយគ្នា ។ ព្រះមានព្រះភាគ ត្រាស់ហៅព្រះអានន្ទអ្នកជាប់តាមទៅជិតៗ ថា អានន្ទ ។ ចំណែកព្រះថេរៈប្រាប់ភិក្ខុទាំងឡាយថា អ្នកមានអាយុ ចូរត្រៀមកាន់បាត្រ ចីវរ ព្រះមានព្រះភាគ ទ្រង់ព្រះបំណងស្តេចនឹងទៅទីឯណោះ ។ រឿងការស្តេចមកអម្ពលដ្ឋិកាវ័ន ងាយទាំងអស់ ។

## ពោលអំពីការសាកសួរព្រះពុទ្ធគុណ

[៧៧] ពាក្យថា អថ ខោ អាយស្មា សារីបុត្តោ ដូច្នេះជាដើម លោកពោលទុកពិស្តារហើយ ក្នុងសម្បសាទនីយសូត្រ ។

## ពណ៌នាទោសនៃការទ្រុស្តសីល

[៧៨] បទថា អាវសថាគារំ បានដល់ ផ្ទះសំណាក់សម្រាប់អ្នកត្រាច់មក ។ គេថា ក្នុងបាដលិគ្រាម សម្លាញ់របស់ព្រះរាជាពីរព្រះអង្គនាំគ្នាមកជានិច្ច នាំក្រុមគ្រួសារចេញចាកស្រុក មកសម្រាក មួយខែខ្លះ កន្លះខែខ្លះ ។ មនុស្សទាំងនោះត្រូវរុកកួនជានិច្ច ក៏គិតគ្នាថា ក្នុងវេលាដែលអ្នកទាំងនោះនាំគ្នាមក ក៏មានទីនៅ ដូច្នេះហើយ ទើបសាងសាលាធំកណ្តាលព្រះនគរ សាងទីរក្សាវត្ថុទុកមួយចំណែក សាងទីនៅអាស្រ័យទុកមួយចំណែករបស់សាលានោះ ។ មនុស្សទាំងនោះបានជ្រាបថា ព្រះ-មានព្រះភាគស្តេចមកហើយ ក៏មើលឃើញប្រយោជន៍យ៉ាងនេះថា សូម្បី

ពួកយើងក៏គប្បីទៅយាងព្រះមានព្រះភាគមក ព្រះអង្គ ស្តេចមកដល់ទីនៅរបស់ពួកយើងដោយព្រះអង្គឯង ហើយថ្ងៃនេះ ពួកយើងនឹងអារាធនាព្រះមានព្រះភាគត្រាស់សម្តែងមង្គលក្នុងទីសម្រាក ព្រោះដូច្នោះ ទើបនាំគ្នាពោលយ៉ាងនេះ ។ បទថា យេនាវសថាគារំ សេចក្តីថា បានឮថា មនុស្សទាំងនោះមិនដឹងព្រះទ័យរបស់ព្រះមានព្រះភាគថា ធម្មតាព្រះពុទ្ធទាំងឡាយមានព្រះអធ្យាស្រ័យ ពេញចិត្តក្នុងព្រៃ ត្រេកអរក្នុងព្រៃ នឹងទ្រង់ប្រាថ្នាឬមិនប្រាថ្នាប្រថាប់នៅក្នុងស្រុក ទើបមិនចាត់ចែងផ្ទះសម្រាក នាំគ្នាគិតថា ឥឡូវនេះ ពួកយើងដឹងព្រះទ័យរបស់ព្រះមានព្រះភាគហើយ នឹងនាំគ្នាទៅចាត់ចែងជាមុន ដូច្នោះ ទើបនាំគ្នាទៅកាន់ផ្ទះសម្រាក ។ បទថា សព្វសន្ថរិតំ ប្រែថា ក្រាលទុកនូវកម្រាលគ្រប់យ៉ាង ។

[៧៩] បទថា ទុស្សីលោ បានដល់ អ្នកមិនមានសីល ។ បទថា សីលវិបន្នោ បានដល់ មានសីលវិបត្តិ មានសំវរៈបែកធ្លាយ ។ បទថា បមាទាធិករណំ បានដល់ ព្រោះសេចក្តីប្រមាទជាហេតុ ។ ក៏ព្រះសូត្រនេះ ប្រើសម្រាប់គ្រហស្ថ សូម្បីបព្វជិតក៏ប្រើបាន ។ ពិតហើយ គ្រហស្ថចិញ្ចឹមជីវិតដោយការប្រើប្រែងសិក្សាសិល្បៈ មិនថា ជាកសិកម្ម ពាណិជ្ជកម្មខុសភ្លាត់ទៅដោយការធ្វើបាណាតិបាតជាដើម ក៏មិនអាចនឹងធ្វើសិល្បៈនោះៗ ឲ្យសម្រេចតាមកាល កាលបើដូច្នោះ ឫសគល់របស់គេ ក៏វិនាស ។ តែក្នុងវេលាក្រលំបាក រមែងធ្វើបាណាតិបាត និងអទិន្នាទាន នឹងសាប-

សូន្យគោគៈយ៉ាងធំ ព្រោះអំណាចទោស ។ ចំណែកបព្វជិតទ្រុស្តសីល រមែងដល់សេចក្តីសាបសូន្យចាកសីល ចាកពុទ្ធវចនៈ ចាកឈាន និងចាក អរិយទ្រព្យ ៧ ព្រោះសេចក្តីប្រមាទជាហេតុ ។ សម្រាប់គ្រហស្ថនោះ កិត្តិស័ព្ទដែលអាក្រក់ រមែងខ្ចរខ្ចាយទៅកណ្តាលបរិស័ទថា អ្នកឯណោះ កើតក្នុងត្រកូលឯណោះ ទ្រុស្តសីល មានបាបធម៌ លះបង់ទាំងលោកនេះ និងលោកមុខ មិនថ្វាយទាន សូម្បីត្រឹមតែសលាកភត្ត ។ ឬសម្រាប់បព្វជិត កិត្តិស័ព្ទដែលអាក្រក់ក៏ផ្សាយទៅយ៉ាងនេះថា ភិក្ខុឈ្មោះឯណោះ មិនអាច រក្សាសីលបាន មិនអាចនឹងរៀនព្រះពុទ្ធវចនៈបាន ចិញ្ចឹមជីវិតដោយ អនេសនកម្ម មានវេជ្ជកម្មជាដើម ប្រកបដោយអគារវៈ ៦ ។ បទថា អវិសារទោ សេចក្តីថា គ្រហស្ថមានសេចក្តីខ្លាចថា កាលមុននេះ បុគ្គល ពួកខ្លះនឹងដឹងរឿងកម្មរបស់យើង ដូច្នោះ ក៏នឹងគ្របសង្កត់យើង ឬសម្តែង ខ្លួនចំពោះរាជត្រកូលក្នុងទីប្រជុំនៃមនុស្សច្រើនជាប្រាកដ ទើបចូលទៅមិន ក្លៀវក្លា សំយុងក ឱនមុខចុះ អង្គុយយកមេដៃគ្រូះដី ដល់ភាពជាអ្នកខ្លាច ក៏មិនអាចនិយាយចរចាបាន ។ ចំណែកបព្វជិត មានសេចក្តីខ្លាចថា ភិក្ខុ ជាច្រើនប្រជុំគ្នា អង្គខ្លះនឹងដឹងកម្មរបស់យើងពិត ដូច្នោះ នឹងវៀរឧបោសថ ខ្លះ បវារណាខ្លះដល់យើង នឹងទាញយើងឲ្យឃ្លាតចាកភេទសមណៈ ទើប ចូលទៅរក សូម្បីជាអ្នកខ្លាំងក្លាក៏មិនអាចនិយាយស្តីបាន ។ ចំណែកភិក្ខុ អង្គខ្លះ សូម្បីទ្រុស្តសីល ក៏ត្រាច់ទៅដូចជាអ្នកមិនទ្រុស្តសីល សូម្បីភិក្ខុ

នោះ ក៏រមែងជាអ្នកធ្លាក់ធ្លងដោយអធ្យាស្រ័យតែម្តង ។ បទថា សម្មូឡ្ហោ កាលំ ករោតិ សេចក្តីថា ក៏កាលភិក្ខុដែលទ្រុស្តសីលនោះ ដេកលើគ្រែសម្រាប់ស្លាប់ ទីដែលធ្លាប់ប្រព្រឹត្តក្នុងកម្ម គឺ ទ្រុស្តសីល រមែងមកប្រាកដ ។ ភិក្ខុទ្រុស្តសីលនោះ បើកភ្នែកក៏ឃើញលោកនេះ បិទភ្នែកក៏ឃើញបរលោក អបាយ ៤ ប្រាកដដល់ភិក្ខុទ្រុស្តសីលនោះ ។ ភិក្ខុទ្រុស្តសីលនោះ ក៏ដូចជាត្រូវដោយលំពែង ១០០ ដើម ចាក់លើក្បាល លោកនឹងស្រែកថា ឈប់ក្លាម ឈប់ក្លាម មរណៈទៅ ។ ដោយហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា សម្មូឡ្ហោ កាលំ ករោតិ វង្វេងធ្វើមរណៈ-កាល ដូច្នេះ បទទី ៥ ក៏ងាយដូចគ្នា ។ រឿងអានិសង្ស ក៏គប្បីជ្រាបដោយបរិយាយផ្ទុយគ្នាដែលពោលទុកហើយ ។

[៨១] បទថា ពហុទេវ រត្តឹ ធម្មិយា កថាយ សេចក្តីថា ព្រះ-មានព្រះភាគទ្រង់ឲ្យរីករាយហើយ ឲ្យឃើញច្បាស់ហើយ ឲ្យសមាទានហើយ ឲ្យអាចហ៊ានហើយ ឲ្យចូលដល់សេចក្តីអស់ និងសេចក្តីសាបសូន្យហើយ រហូតដល់អស់រាត្រីជាច្រើន ហើយទ្រង់បញ្ជូនទៅដោយធម្មកថាដែលផុតចាកបាលីយ៉ាងដទៃ និងដោយកថាអនុមោទនា ការថ្វាយផ្ទះសម្រាក ដូចជាទ្រង់នាំធ្លងអាកាស គង្គា ដូចជាទ្រង់រម្ងាស់ផ្តិតឃ្មុំធំ ទំហំមួយយោជន៍ ឲ្យមហាជនផឹកទឹកឃ្មុំ ដូច្នោះ ។ បទថា អភិក្កន្តា បានដល់ កន្លងទៅហើយ អស់ទៅហើយ ។ បទថា សុញ្ញាគារំ សេចក្តីថា ដែលឈ្មោះថា ផ្ទះស្ងាត់

ដែលចែកជាចំណែកមួយដទៃផ្សេង មិនមាន ។ តែក្នុងទីនោះឯង ពួកអ្នកស្រុកបាដលិគ្រាម លោមព័ទ្ធទុកដោយកំផែង គឺ រាំងនននុកម្ខាង ហើយចាត់ចែគ្រទុកដោយប្រាថ្នាថា ព្រះសាស្តានឹងទ្រង់សម្រាកក្នុងទីនេះ ។ ព្រះមានព្រះភាគ ទ្រង់សម្រេចសីហសេយ្យាលើគ្រែនោះ ដោយមានព្រះពុទ្ធបំណងថា ផ្ទះសម្រាកនេះ តថាគតប្រើប្រាស់ហើយ ដោយឥរិយាបថសូម្បីទាំង ៤ កុសលនោះ នឹងមានផលច្រើនដល់អ្នកស្រុកបាដលិគ្រាមទាំងនោះដូច្នេះ ។ លោកសំដៅយកផ្ទះសម្រាកនោះ ទើបពោលថា សុញ្ញាគារំ ចាវិសិ ដូច្នេះ ។

## ពោលអំពីការសាងក្រុងក្នុងចាដលិគ្រាម

[៨២] បទថា សុនីធវស្សការា បានដល់ ព្រាហ្មណ៍ ២ នាក់ គឺ សុនីធៈម្នាក់ វស្សការៈម្នាក់ ។ បទថា មហាមត្តា បានដល់ មហាមត្តៈ គឺ មហាមាត្ររបស់ស្តេចនគរមគធៈ មយ៉ាងទៀត ឈ្មោះថា មហាមាត្យដែនមគធៈ ក៏ព្រោះមហាមាត្រក្នុងដែនមគធៈ ប្រកបដោយឋានន្តរៈ គឺ ឥស្សរិយយសធំក្រៃលែង ។ បទថា ចាដលិគាមេ ឆគរំ បានដល់ កសាងបាដលិគ្រាមធ្វើឲ្យជានគរ ។ បទថា វជ្ជីនំ បដិពាហាយ បានដល់ ដើម្បីផ្តាច់ផ្លូវ ពន្រឹកខ្លួនជារាជវង្សដែនវជ្ជី ។

បទថា សហស្សេវ បានដល់ តែមួយពួក រាប់ជាពាន់ៗ ។ បទថា

វត្ថូនិ បានដល់ ទីសាងផ្ទះ ។ បទថា ចិត្តានិ នមន្តិ និវេសនានិ មាបេតុំ សេចក្តីថា ចិត្តរបស់មហាមាត្រអ្នកមានវិជ្ជាទាយមើលផ្ទៃដី បង្អោនទៅដើម្បីសាងគ្រឹះស្ថានសម្រាប់ព្រះរាជា និងមហាមាត្ររបស់ព្រះរាជា ។ បានឮមកថា មហាមាត្រទាំងនោះ ប្រើអានុភាពនៃសិល្បៈរបស់ខ្លួន មើលឃើញខាងក្រោមផែនដីប្រមាណ ៦០ ហត្ថ ថា ទីនេះនាគហួងហែងទុក ទីនេះយក្ខស្ថិតនៅ ទីនេះភូតស្ថិតនៅ មានថ្ម ឬកក់ ។ វេលានោះ អាមាត្រទាំងនោះ រាយសិល្បៈសាងឡើងបាន ដូចប្រឹក្សាជាមួយទេវតាទាំងឡាយ ។ មួ៉ាងទៀត ទេវតាស្ថិតនៅក្នុងរាងកាយរបស់អាមាត្យទាំងនោះ បង្អោនចិត្តទៅដើម្បីសាងគ្រឹះស្ថានក្នុងទីនោះៗ ពេលគេបោះបង្គោលចុះក្នុងជ្រុងទាំង ៤ ទេវតាទាំងនោះ ទើបស្ថិតត្រង់ផ្ទៃដី ។ ទេវតាអ្នកមានសទ្ធា ធ្វើយ៉ាងនោះដល់ត្រកូលអ្នកមានសទ្ធា ទេវតាអ្នកមិនមានសទ្ធាក៏ធ្វើយ៉ាងនោះដល់ត្រកូលអ្នកមិនមានសទ្ធា ។ ព្រោះហេតុអ្វី ។ ព្រោះអ្នកមានសទ្ធា មានការគិតយ៉ាងនេះថា មនុស្សទាំងឡាយក្នុងលោកនេះ លុះសាងផ្ទះហើយ ជាដំបូង និមន្តភិក្ខុសង្ឃឲ្យគង់ ឲ្យពោលតែមង្គល កាលដូច្នេះ ។ ពួកយើងក៏នឹងបានឃើញអ្នកមានសីល ស្តាប់ធម្មកថា ការដោះស្រាយបញ្ហា និងអនុមោទនា មនុស្សឲ្យទានហើយនឹងឲ្យចំណែកបុណ្យដល់យើង ។

បទថា តាវត្តិំសេហិ សេចក្តីថា សំឡេងផ្សាយទៅថា ពួកមនុស្ស

ក្នុងត្រកូលឯណោះ អាស្រ័យមនុស្សដែលជាបណ្ឌិតម្នាក់ ក្នុងត្រកូលមួយ រមែងជាបណ្ឌិត ឬភិក្ខុក្នុងវិហារឯណោះ អាស្រ័យភិក្ខុដែលជាពហុស្សូតមួយរូបក្នុងវិហារមួយ រមែងជាពហុស្សូតមួយ ក្នុងវិហារមួយ រមែងជាពហុស្សូត យ៉ាងណា ។ សំឡេងផ្សាយទៅថា ទេវតាជាន់តាវត្តិង្ស អាស្រ័យស្តេចសក្កទេវរាជ និងវិស្សុកម្មទេវបុត្រ រមែងជាបណ្ឌិត ដូច្នោះដែរ ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា តាវតឹសេហិ ។ អធិប្បាយថា រមែងសាង ដូចប្រឹក្សាជាមួយទេវតាជាន់តាវត្តិង្ស ។ បទថា យាវតា អរិយំ អាយតនំ សេចក្តីថា ឈ្មោះថា ដែលជាទីប្រជុំរបស់មនុស្ស ផៅពង្សអរិយកៈមានប្រមាណប៉ុនណា ។ បទថា យាវតា វណិប្បថោ សេចក្តីថា ឈ្មោះថា ស្ថានទីទិញលក់ដោយគំនរវត្ថុ ដែលពួកឈ្មួញនាំមក ឬស្ថានទីរស់នៅរបស់ពួកឈ្មួញទាំងឡាយ មានប្រមាណប៉ុនណា ។ បទថា ឥទំ អគ្គនគរំ សេចក្តីថា អគ្គនគរនេះ នឹងជាក្រុងចម្រើន ជាក្រុងធំ សម្រាប់ពួកអរិយកៈនិងពួកឈ្មួញនោះៗ ។ បទថា បុដភេទនំ បានដល់ ទីស្រាយបង្វេចទ្រព្យ ។ លោកអធិប្បាយថា ជាទីស្រាយបង្វេចទ្រព្យនៃម្ចាស់ទ្រព្យផ្សេងៗ ។ អធិប្បាយថា ក៏ជនទាំងឡាយសូម្បីមិនបានទ្រព្យក្នុងសកលជម្ពូទ្វីប ក៏នឹងបានក្នុងទីនេះឯង សូម្បីអ្នកមិនទៅធ្វើជំនួញក្នុងទីដទៃ ក៏នឹងទៅក្នុងទីនេះ ព្រោះដូច្នោះ ពួកគេនឹងស្រាយកញ្ចប់ទ្រព្យ ក្នុងទីនេះប៉ុណ្ណោះ ។ លោកសម្តែងថា ពិតហើយ

រាល់ៗ ថ្ងៃ មូលតម្លៃនឹងកើតឡើង ៥ សែន យ៉ាងនេះ គឺ តាមទ្វារព្រះនគរទាំងបួន បួនសែន ត្រង់កណ្តាលព្រះនគរ មួយសែន ។

វា សំព្តក្នុងបទថា អត្ថិគោ វា មានអត្ថស្មើគ្នានឹង ៥ សេចក្តីថា នឹងវិនាសដោយភ្លើង ដោយទឹក ឬដោយការបែកគ្នាជា ២ ចំណែក អធិប្បាយថា ចំណែកមួយវិនាសដោយភ្លើង មិនអាចនឹងរលត់បាន ចំណែកមួយទន្លេគង្គាកួចយកទៅ ចំណែកមួយនឹងវិនាសទៅដោយ ការបែកនៃគ្នានិងគ្នារបស់ពួកមនុស្ស អ្នកបែកគ្នាដោយអំណាចបិសុណាវាចា ដែលពោលថា អ្នកនេះមិននិយាយចំពោះអ្នកឯណោះ អ្នកឯណោះមិននិយាយចំពោះអ្នកនេះ ។

## រឿងសុនីធៈ និងវស្សការព្រាហ្មណ៍

[៨៣] កាលព្រះមានព្រះភាគត្រាស់ដូច្នេះហើយ វេលាជិតភ្លឺ ស្តេចទៅកាន់ច្រាំងទន្លេគង្គា ទ្រង់ជម្រះព្រះភក្ត្រហើយ ប្រថាប់គង់ចាំវេលាភិក្ខាចារ ។ ចំណែកមហាមាត្រមគធៈ ឈ្មោះសុនីធៈ និងវស្សការ គិតថា ព្រះរាជារបស់ពួកយើង ជាឧបដ្ឋាករបស់ព្រះសមណគោតម ព្រះអង្គនឹងត្រាស់សួរពួកយើងថា បានឮថា ព្រះសាស្តាស្តេចយាងទៅបាដលិគ្រាម ពួកលោកបានចូលគាល់ព្រះអង្គឬទេ កាលក្រាបទូលថា ខ្ញុំព្រះអង្គចូលគាល់ ទើបត្រាស់សួរទៀតថា ពួកលោកបាននិមន្តឬទេ កាលក្រាបទូលថា

មិនបាននិមន្ត នឹងលើកទោសពួកយើង មួយទៀតសោត ពួកយើងក៏នឹងសាងព្រះនគរក្នុងទីដែលមិនទាន់បានសាង ក៏ក្នុងទីដែលព្រះសមណគោតមស្តេចទៅហើយៗ ពួកសត្វកាឡកិណីនឹងគេចចេញទៅ ទើបគិតថា ពួកយើងនឹងឲ្យព្រះអង្គត្រាស់វត្ថុដែលជាមង្គលដល់ព្រះនគរ ដូច្នេះហើយទើបចូលទៅគាល់ព្រះសាស្តា ទូលអារាធនា ព្រោះដូច្នោះ លោកទើបពោលថា អថខោ សុនីធវស្សការា ជាដើម ។

បទថា បុព្វណ្ហសមយំ ប្រែថា ក្នុងវេលាព្រឹក ។ បទថា និវាសេត្វា ប្រែថា ទ្រង់ស្លៀកអន្តរវាសក ចងវត្ថពន្ធចង្កេះតាមធម្មទំនៀម ចូលស្រុក ។ បទថា បត្តចីវរមាទាយ ប្រែថា ទ្រង់កាន់បាត្រ និងចីវរ នៅជិតព្រះអង្គ ។

## អនុមោទនាកថា

[៨៤] បទថា សីលវន្តេត្ថ កាត់ជា សីលវន្តេ ឯត្ថ ។ បទថា សញ្ញតេ បានដល់ អ្នកសង្រួមដោយកាយវាចាចិត្ត ។ បទថា តាសំ ទក្ខិណមាទិសេ សេចក្តីថា គប្បីឧទ្ទិសបច្ច័យបួនដែលថ្វាយសង្ឃ គឺ គប្បីឲ្យចំណែកបុណ្យដល់ទេវតាប្រចាំផ្ទះទាំងនោះ ។ បទថា បូជិតា បូជយន្តិ សេចក្តីថា ទេវតារមែងរក្សាដោយល្អ ដោយបង្គាប់ថា មនុស្សទាំងនេះសូម្បីមិនមែនញាតិរបស់យើង ក៏គង់ឲ្យចំណែកបុណ្យដល់ពួកយើងយ៉ាងនេះ ព្រោះដូច្នោះ ពួកលោកចូរចាត់ការរក្សាដោយល្អ ។ បទថា មានិតា

មានយន្តិ សេចក្តីថា ទេវតាទាំងឡាយដែលពួកមនុស្សរាប់អាន ដោយការធ្វើពលីកម្មតាមកាលសមគួរ ទើបរាប់អាន គឺ កម្ចាត់អន្តរាយដែលកើតឡើង ដោយហេតុថា មនុស្សទាំងនេះ សូម្បីមិនមែនញាតិរបស់ពួកយើង ក៏គង់ធ្វើពលីកម្មដល់ពួកយើងក្នុងរវាង ៤ ខែ ៦ ខែ ។ បទថា តតោ នំ បានដល់ តពីនោះ ទេវតាក៏រមែងអនុគ្រោះបុគ្គលបណ្ឌិតនោះ ។ បទថា ឱរសំ បានដល់ ដាក់ទុកត្រង់ទ្រូងឲ្យបម្រើនធំធាត់ ។ អធិប្បាយថា រមែងអនុគ្រោះ ដូចមាតាអនុគ្រោះបុត្រដែលកើតពីទ្រូង ព្យាយាមកម្ចាត់អន្តរាយដែលកើតឡើង ដូច្នោះ ។ បទថា ភទ្រានិ បស្សតិ ប្រែថា ឃើញវត្ថុដែលល្អ ។

[៨៩] បទថា ឧឡុម្បំ បានដល់ ពាហនៈដែលគេភ្ជាប់ស្នៀត សាងទុកដើម្បីទៅត្រើយឯណោះ ( ផែ ) ។ បទថា កុល្លំ បានដល់ ពាហនៈដែលគេប្រើវល្លិ៍ជាដើមចងទុក ( ក្បូន ) ។

ពាក្យថា អណ្ណវំ ក្នុងគាថា ថា យេ តរន្តិ អណ្ណវំ នេះ ជាឈ្មោះនៃទីដែលមានទឹកជ្រៅ និងទូលំទូលាយ ដោយកំណត់យ៉ាងជិតបំផុតប្រមាណមួយយោជន៍ ។ ក្នុងបទថា សរំ នេះ លោកប្រាថ្នាយកទន្លេ ។ មានពាក្យអធិប្បាយថា អ្នកដែលឆ្លងស្រះ គឺ តណ្ហា ដែលទាំងជ្រៅទាំងទូលំទូលាយ សាងស្ពាន ពោលគឺ អរិយមគ្គ លះភក់ល្បាប់ គឺ ទីទំនាបពេញដោយទឹកប៉ះពាល់មិនបាន ឆ្លងទៅ ចំណែកមនុស្សនេះ សូម្បី

ត្រូវការនឹងឆ្លងទន្លេ សូម្បីបន្តិចបន្តួចនេះ ក៏ត្រូវចងក្បូន ចំណែកអ្នកមានបញ្ញា គឺ ព្រះពុទ្ធ និងសាវករបស់ព្រះពុទ្ធមិនត្រូវប្រើក្បូន ក៏ឆ្លងបាន ។

ចប់ កថាពណ៌នាបឋមភាណវារៈ

# ទ្រង់សម្តែងចតុរារិយសច្ចកថា

[៨៦] បទថា កោដិគាមោ បានដល់ ស្រុកដែលសាងទុកខាងចុង ប្រាសាទរបស់ព្រះបាទមហាបនាទៈ ។ បទថា អរិយសច្ចានំ បានដល់ សច្ចៈដែលធ្វើឲ្យជាព្រះអរិយៈ ។ បទថា អននុពោធា បានដល់ ព្រោះមិនត្រាស់ដឹង គឺ មិនដឹង ។ បទថា អប្បដិវេធា គឺ ព្រោះមិនចាក់ធ្លុះ ។ បទថា សន្ធាវិតំ បានដល់ អន្ទោលទៅ ដោយចេញពីភពទៅកាន់ភព ។ បទថា សំសរិតំ បានដល់ ត្រាច់ទៅ ដោយទៅមករឿយៗ ។ បទថា មមំ ចេវ តុម្ហាកញ្ច ប្រែថា ដែលតថាគត និងអ្នកទាំងឡាយ ។ ន័យមួយទៀត គប្បីជ្រាបសេចក្តីក្នុងសេចក្តីនេះ យ៉ាងនេះថា បទថា សន្ធាវិតំ សំសរិតំ សេចក្តីថា ការស្ទុះទៅ ត្រាច់ទៅ អន្ទោលទៅ បានមានហើយទាំងដល់តថាគត និងអ្នកទាំងឡាយ ។

[៨៧-៨៨] បទថា សំសរិតព្វំ ប្រែថា ត្រាច់ទៅ ។ បទថា ភវនេត្តិ សមូហតា បានដល់ ខ្សែ គឺ តណ្ហាដែលអាចនាំសត្វចាកភព ទៅកាន់ភពដែលតថាគត និងអ្នកទាំងឡាយកម្ចាត់ហើយ កាត់ហើយ ធ្វើមិនឲ្យប្រព្រឹត្តទៅហើយដោយល្អ ។

## ពោលអំពី ផ្លូវទៅកាន់នាទិកគ្រាម

[៨៩] បទថា នាទិកា បានដល់ ស្រុកពីររបស់បុត្រ នៃពូ និងអ៊ំទាំងពីរ អាស្រ័យស្រះតែមួយ ។ បទថា នាទិកេ បានដល់ ពួកញាតិក្នុងស្រុកមួយ ។ បទថា គិញ្ជកាវសថេ បានដល់ ផ្ទះសម្នាក់ធ្វើដោយឥដ្ឋ ។ បទថា ឱរម្ភាគិយានំ បានដល់ ចំណែកខាងក្រោម អធិប្បាយថា ធ្វើឲ្យបដិសន្ធិក្នុងកាមភពប៉ុណ្ណោះ ។ មយ៉ាងទៀត ឱរម្ភាគិយសញ្ញោជនៈ ដែលគប្បីលះដោយមគ្គទាំងបី ដែលបានឈ្មោះថា ឱរំ ។ ក្នុងសញ្ញោជនៈទាំងនោះ សញ្ញោជនៈពីរនេះ គឺ កាមឆន្ទៈ ព្យាបាទៈ ដែលគ្របសង្កត់មិនបានដោយសមាបត្តិ ឬលះបង់មិនបានដោយមគ្គ មិនឲ្យទៅកាន់រូបភពនិងអរូបភពខាងខ្ពស់ ។ សញ្ញោជនៈបី មានសក្កាយទិដ្ឋិជាដើម នាំសត្វសូម្បីដែលកើតក្នុងភពនោះ ឲ្យមកកើតក្នុងភពនេះទៀត ព្រោះដូច្នោះ សញ្ញោជនៈទាំងបី ទើបឈ្មោះថា ឱរម្ភាគិយសញ្ញោជនៈ ។ បទថា អនាវត្តិធម្មា បានដល់ មានការមិនត្រឡប់មកដោយបដិសន្ធិជាសភាវៈ ។ ក្នុងពាក្យថា រាគទោសមោហានំ តនុត្តា នេះ គប្បីជ្រាប សេចក្តីដែលរាគៈ ទោសៈ មោហៈ ស្រាលស្តើង ដោយអាការទាំងពីរយ៉ាង គឺ ដោយការកើតឡើងក្នុងគ្រាខ្លះ និងមានបរិយុដ្ឋានកិលេសតិច ។ កិលេសមានរាគៈជាដើម រមែងមិនកើតឡើងរឿយៗ ដល់ព្រះសកទាគាមី ដូចបុថុជ្ជន

កើតឡើងកើតក្នុងគ្រាខ្លះ តែកាលកើតឡើង មិនកើតឡើងច្រើន ៗ ដូចបុថុជ្ជន កើតឡើងខ្លះ ៗ ដូចភាជនៈដាក់ត្រី តែព្រះមហាសិវត្ថេរអ្នកវចនាគម្ពីរទីឃនិកាយពោលថា ព្រោះព្រះសកទាគាមីនៅមានបុត្រធីតា និងនៅមានអ្នកស្និទ្ធ ដូច្នោះទើបនៅមានកិលេសក្រាស់ តែពាក្យនេះ លោកពោលដល់កិលេសក្នុងភពស្រាលស្តើង ។ ពាក្យនោះ ក្នុងអដ្ឋកថាលោកជំទាស់ ព្រោះលោកពោលទុកថា ព្រះសោតាបន្ន វៀរភព ៧ ចេញ កិលេសដែលស្រាលស្តើងក្នុងភពទី ៨ មិនមាន ចំណែកព្រះសកទាគាមី វៀរភពពីរចេញ មិនមានកិលេសស្រាលស្តើងក្នុងភពទាំង ៥ ឯព្រះអនាគាមីវៀររូបភព អរូបភព មិនមានកិលេសស្រាលស្តើងក្នុងកាមភព ព្រះខីណាស្រពមិនមានកិលេសស្រាលស្តើងក្នុងភពណាៗ ឡើយ ។ ពាក្យនេះថា ឥមំ លោកំ នេះ ទ្រង់សំដៅយកកាមាវចរលោក ។ ក៏ក្នុងសេចក្តីនេះ មានអធិប្បាយដូចតទៅនេះ ៖

ក៏បើព្រះអរិយបុគ្គល ដែលសម្រេចសកទាគាមិផលក្នុងមនុស្សលោក ហើយកើតក្នុងទេវលោក រមែងធ្វើឲ្យច្បាស់នូវព្រះអរហត្ត ប្រការនេះល្អយ៉ាងនេះ តែកាលអាចត្រឡប់មកកាន់មនុស្សលោកហើយ រមែងធ្វើឲ្យច្បាស់នូវព្រះអរហត្ត ចំណែកអរិយបុគ្គលដែលសម្រេចសកទាគាមិផលក្នុងទេវលោក បើមកកើតក្នុងមនុស្សលោក រមែងធ្វើឲ្យជាក់ច្បាស់នូវព្រះអរហត្តបាន សេចក្តីនេះ ល្អយ៉ាងនេះ តែកាលអាចទៅកាន់ទេវលោក

រមែងធ្វើឲ្យជាក់ច្បាស់នូវព្រះអរហត្តដោយពិត ។ ការធ្លាក់ទៅដោយមិនមានសល់ ឈ្មោះថា **វិនិបាត** ក្នុងពាក្យថា អវិនិបាតធម្មោ នេះ អធិប្បាយថា ការធ្លាក់ទៅដោយមិនមានសល់របស់ព្រះសោតាបន្ននោះ ជាធម៌មិនអាចប្រព្រឹត្តទៅបាន ហេតុនោះ ព្រះសោតាបន្ននោះ ឈ្មោះថា មានការមិនធ្លាក់ចុះជាធម្មតា គឺ មានការមិនធ្លាក់ទៅ ដោយមិននៅសល់ក្នុងអបាយបួនជាសភាវៈ ។ បទថា និយតោ បានដល់ ពិតប្រាកដ ដោយការកំណត់នៃធម៌ ។ បទថា សម្ពោធិបរាយណោ សេចក្តីថា សម្ពោធិពោលគឺ មគ្គបីក្នុងខាងលើ ជាទីទៅ ជាដំណើរ ជាទីពឹងអាស្រ័យរបស់បុគ្គលនោះ គឺ ដែលបុគ្គលនោះ គប្បីសម្រេចពិតប្រាកដក្នុងពេលខាងមុខ ហេតុនោះ បុគ្គលនោះឈ្មោះថា **មានសម្ពោធិជាទីទៅខាងមុខ** ។

## ទ្រង់សម្តែងធម្មបរិយាយ ឈ្មោះធម្មាទាសៈ

ដោយបទថា វិហេសាវេសា ទ្រង់សម្តែងថា ម្នាលអានន្ទ នោះជាសេចក្តីលំបាកកាយរបស់តថាគត តថាគតពិចារណាមើលដោយញាណគតិ ញាណឧប្បត្តិ ញាណអភិសម្បរាយៈ របស់ពួកសត្វនោះៗ ។ តែសេចក្តីលំបាកចិត្ត មិនមានដល់ព្រះពុទ្ធទាំងឡាយ ។

បទថា ធម្មាទាសំ បានដល់ កញ្ចក់ គឺ ធម៌ ។ បទថា យេន បានដល់ អ្នកប្រកបដោយកញ្ចក់ធម៌ដទៃណា ។ បទថា ខីណាបាយ-

ទុគ្គតិវិនិបាតោ នេះ លោកពោលដោយវេវចនៈរបស់នរកជាដើមប៉ុណ្ណោះ ។ ពិតហើយ **នរក** ជាដើម ឈ្មោះថា **អបាយ** ព្រោះប្រាសចាកអយៈ គឺសេចក្តីចម្រើន ឈ្មោះថា **ទុគ្គតិ** ព្រោះជាទីដំណើរទៅ ជាទីពឹងអាស្រ័យនៃទុក្ខ ឈ្មោះថា **វិនិបាត** ព្រោះជាទីធ្លាក់ទៅដោយមិនមានសល់ របស់ពួកជនអ្នកធ្វើអាក្រក់ ។ បទថា អវេច្ចប្បសាទេន បានដល់ ដោយសេចក្តីជ្រះថ្លាដែលមិនញាប់ញ័រ ព្រោះដឹងដល់ព្រះពុទ្ធគុណតាមសេចក្តីពិត ទុំះឯង ។ សូម្បីក្នុងពីរបទខាងដើម ក៏ន័យនេះដូចគ្នា ។ ចំណែកសេចក្តីពិស្តាររបស់ពាក្យថា ឥតិបិ សោ ភគវា ជាដើម ពោលទុកហើយក្នុងគម្ពីរវិសុទ្ធិមគ្គ ។ បទថា អរិយកន្តេហិ បានដល់ ជាទីប្រាថ្នា ជាទីស្រឡាញ់ ជាទីពេញចិត្តរបស់ព្រះអរិយៈទាំងឡាយ ។ សីល ៥ ឈ្មោះថា ជាទីប្រាថ្នារបស់ព្រះអរិយៈទាំងឡាយ ព្រោះលោកមិនលះបង់សូម្បីក្នុងភពដទៃ ។ លោកសំដៅដល់សីល ៥ នោះ ទើបពោលពាក្យនេះទុក ។ តែក្នុងទីនេះ បានដល់ សំវរៈទាំងអស់ ។ ពាក្យថា សោតាបន្នោហមស្មិ នេះជាប្រធានទេសនាប៉ុណ្ណោះ ។ តែសូម្បីព្រះសកទាគាមីជាដើម រមែងព្យាករណ៍ដោយន័យមានអាទិថា សកទាគាមីហមស្មិ យើងជាសកទាគាមីដូច្នេះ ។ ការព្យាករណ៍នៃព្រះអរិយសាវកទាំងពួង ក្នុងឋានៈដែលគួរដោយមិនខុសសិក្ខាបទ (វិន័យ) ដែលព្រះមានព្រះភាគ ទ្រង់អនុញ្ញាតហើយ ។

## ទ្រង់សម្ដែងសតិប្បដ្ឋាន៤

[៩០] គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា វេសាលិយំ វិហរតិ នេះ ដូចតទៅនេះ គប្បីជ្រាប សេចក្ដីដែលក្រុងវេសាលីជានគរសម្បូរណ៍ ។ ដោយន័យដែលពោលហើយក្នុងខន្ធកវិន័យថា តេន ខោ បន សមយេន វេសាលី ឥទ្ធាចេវ ហោតិ ជីតា ច ដូច្នេះ ។ បទថា អម្ពបាលិវនេ បានដល់ ក្នុងព្រៃស្វាយ ដែលជាសួនរបស់នាងអម្ពបាលិគណិកា ។ បទថា សតោ ភិក្ខវេ សេចក្ដីថា ព្រះមានព្រះភាគ ទ្រង់ផ្ដើមសតិប្បដ្ឋានទេសនា ក្នុងទីនេះ ដោយពិសេសដើម្បីឲ្យសតិប្រាកដ ក្នុងកាលទ្រង់ទស្សនាអម្ពបាលិវ័ន ។ ក្នុងបទទាំងនោះ ឈ្មោះថា សតោ ព្រោះរឭកបាន ឈ្មោះថា សម្បជានោ ព្រោះដឹងខ្លួន អធិប្បាយថា គប្បីជាអ្នកប្រកបដោយសតិសម្បជញ្ញៈ ។ ខ្ញុំនឹងពោលពាក្យដែលគួរពោល ក្នុងពាក្យជាដើមថា កាយេ កាយានុបស្សី ទុកក្នុងមហាសតិប្បដ្ឋានសូត្រ ។

[៩២] ពាក្យថា នីលា ជាដើមនេះ ពោលរួមពណ៌ទាំងអស់ ។ ចំណែកពាក្យថា នីលវណ្ណា ជាដើម ជាការសម្ដែងចែកពណ៌នោះឯង ។ ក៏ក្នុងពាក្យនោះ លោកពោលពាក្យនេះទុក ព្រោះពណ៌ទាំងនោះ មិនមែនពណ៌ខៀវជាប្រក្រតី ព្រោះផ្សំដោយពណ៌ខៀវ ។ បទថា នីលវត្ថា សេចក្ដីថា សំពត់ធម្មតា សំពត់សំបកឈើ និងសំពត់ផ្ទៃជាដើម ។

ឈ្មោះថា ទៀតសម្រាប់សំពត់ទាំងនោះ ។ បទថា នីលាលង្ការា បានដល់ប្រដាប់ដោយមណីខៀវ ផ្កាឈើខៀវ ។ សូម្បីរថរបស់ស្តេចលិច្ឆវីទាំងនោះ ក៏វិចិត្រដោយមណីខៀវ ដេរប៉ាក់ដោយសំពត់ខៀវ មានទង់ខៀវប្រកបដោយទាហានពាក់ក្រោះខៀវ អាភរណៈខៀវ ទឹមដោយសេះខៀវ សូម្បីជងខ្សែតីក៏ខៀវដូចគ្នា ។ សេចក្តីក្នុងគ្រប់បទ ក៏គប្បីជ្រាបដោយន័យនេះ ។

បទថា បដិវដ្ដេសិ គឺ ប៉ះ ។ ពាក្យថា ជេ ក្នុងពាក្យថា កឹ ជេ អម្ពបលិ ជាពាក្យហៅ ។ លោកអធិប្បាយថា នាងអម្ពបាលី តើហេតុអ្វី ? បាលីថា កិញ្ចិ ក៏មាន ។ ក្នុងពាក្យនេះក៏មានសេចក្តីដូចគ្នា ។ បទថា សាហារំ បានដល់ ព្រមដោយជនបទ ។ បទថា អង្គុលី ធោធេសុំ បានដល់ រលាស់ម្រាមដៃ ។ បទថា អម្ពកាលិកាយ បានដល់ មាយាស្រី ។ ពាក្យថា យេសំ ជាឆដ្ឋីវិភត្តិ ចុះក្នុងអត្ថតតិយាវិភត្តិ ។ លោកអធិប្បាយថា ដែលភិក្ខុពួកណាមិនឃើញហើយ ។ បទថា ឱលោកេថ បានដល់ ចូរមើលចុះ ។ បទថា អវលោកេថ បានដល់ ចូរមើលរឿយៗ បទថា ឧបសំហរថ បានដល់ បង្អោនចូលមក ។ អធិប្បាយថា ពួកលោកចូរបង្អោននាំមកប្រៀបធៀបជាមួយបរិស័ទរបស់ស្តេចលិច្ឆវីនេះ ដូចជាទេវតាជាន់តាវត្តិង្ស ដោយចិត្តរបស់ពួកលោក ចូរមើល ប្រៀបធៀបនឹងពួកទេវតាជាន់តាវត្តិង្សថា សូម្បីស្តេចលិច្ឆវីទាំងនេះ ក៏ដូចពួកទេវតាជាន់

តាវត្តិង្សដែលល្អស្អាតគួរជ្រះថ្លា មានវណ្ណៈផ្សេងៗ គ្នា មានវណ្ណៈខៀវជាដើម ដូច្នោះ ។ សួរថា ក៏ហេតុអ្វី ព្រះមានព្រះភាគ ទើបទ្រង់ហាមអាយតនៈខាងក្នុងមានចក្ខុជាដើម កាន់យកនូវនិមិត្តក្នុងអាយតនៈខាងក្រៅមានរូបជាដើម ដោយសូត្រច្រើនរយសូត្រ តែក្នុងសូត្រនេះទ្រង់ត្រឡប់ប្រកបភិក្ខុទុកក្នុងការកាន់យកនូវនិមិត្តដោយឧស្សាហ៍យ៉ាងធំ ។ ឆ្លើយថា ព្រោះទ្រង់ប្រាថ្នាប្រយោជន៍ ។

ដូចបានឮមក ភិក្ខុពួកខ្លះក្នុងក្រុងវេសាលីនោះ មានសេចក្ដីព្យាយាមធូរថយ ។ ព្រះមានព្រះភាគ កាលនឹងទ្រង់ប្រើសម្បត្តិរបស់ទេវតាជាន់តាវត្តិង្សលួងលោម ទើបត្រាស់ដើម្បីឲ្យភិក្ខុទាំងនោះកើតឧស្សាហ៍ក្នុងសមណ-ធម៌ថា កាលភិក្ខុធ្វើសមណធម៌ដោយសេចក្ដីមិនប្រមាទ ក៏បានឥស្សរិយ-សម្បត្តិបែបនេះដោយងាយ ។ ព្រះមានព្រះភាគត្រាស់យ៉ាងនេះ ដើម្បីសេចក្ដីជាក់ច្បាស់នៃអនិច្ចលក្ខណៈក៏បាន ។ សេចក្ដីពិត មិនយូរប៉ុន្មានឡើយ ស្ដេចលិច្ឆវីសូម្បីទាំងអស់នេះ ក៏នឹងដល់សេចក្ដីវិនាស ដោយអំណាចរបស់ព្រះបាទអជាតសត្តុ ។ គ្រានោះ ព្រះមានព្រះភាគត្រាស់ដើម្បីសេចក្ដីជាក់ច្បាស់នៃអនិច្ចលក្ខណៈ ដោយព្រះពុទ្ធបំណងថា ពួកភិក្ខុដែលឈរមើលសិរីរាជសម្បត្តិរបស់ស្ដេចលិច្ឆវីទាំងនោះ នឹងបានចម្រើនអនិច្ចលក្ខណៈថា សេចក្ដីវិនាសនៃសិរីសម្បត្តិបែបនោះនឹងប្រាកដ ហើយក៏សម្រេចព្រះអរហត្តព្រមដោយបដិសម្ភិទា ។ ក្នុងបទថា អធិវាសេតុ

សួរថា ហេតុអ្វី ពួកស្តេចលិច្ឆវីទាំងដែលដឹងថា ព្រះមានព្រះភាគទទួលនិមន្តនាងអម្ពបាលីហើយ ទើបទទួលនិមន្តទៀត ។ ឆ្លើយថា ព្រោះទ្រង់មិនជឿ និងព្រោះជាធម្មទំនៀម ។ ក៏ពួកស្តេចលិច្ឆវីទាំងនោះគិតថា ស្រីអ្នកលេងនោះ មិននិមន្ត និយាយថា និមន្ត ។ ក៏ជឿថា ការទៅនិមន្តក្នុងវេលាទៅ ស្អាប់ធម៌ ជាទំនៀមរបស់មនុស្ស ទុំះឯង ។

## ព្រះមានព្រះភាគទ្រង់មានអាពាធខ្លាំងក្លា

[៩៣] បទថា វេឡុវគាមកោ បានដល់ ស្រុកវេឡុវៈ ជិតក្រុងវេសាលី ។ មិត្ត ក៏គឺមិត្ត ក្នុងពាក្យថា យថាមិត្តំ ជាដើម ។ បទថា សន្ទិដ្ឋា គឺ មិត្តដែលត្រឹមតែជួបឃើញគ្នាក្នុងទីនោះៗ ឈ្មោះថា មិត្តដែលធ្លាប់ឃើញគ្នា មិនមែនមិត្តជិតស្និទ ។ បទថា សម្ភត្តា បានដល់ មិត្តដែលសេពគប់គ្នាមកដោយល្អ ជាមិត្តជិតស្និទ ។ អធិប្បាយថា ពួកលោកចូរចូលទៅចាំវស្សាក្នុងទីដែលពួកភិក្ខុបែបនោះមាន ។ ព្រោះហេតុអ្វី ព្រះមានព្រះភាគ ទើបត្រាស់យ៉ាងនេះ ។ ព្រោះមានព្រះពុទ្ធបំណងឲ្យភិក្ខុទាំងនោះនៅជាសុខ ។ សេចក្តីពិត សេនាសនៈក្នុងវេឡុវគ្រាមមិនល្មមដល់ភិក្ខុទាំងនោះ ទាំងភិក្ខាមានតិច ចំណែកជុំវិញក្រុងវេសាលីសេនាសនៈក៏មានច្រើន ទាំងភិក្ខាក៏រកបានងាយ ព្រោះដូច្នោះ ព្រះអង្គទើបត្រាស់យ៉ាងនេះ ។ កាលបើដូច្នោះ ព្រោះហេតុអ្វី ទើបមិនត្រាស់

ធ្វើយថា ពួកលោកគង់នៅជាសប្បាយ ។ ដើម្បីទ្រង់អនុគ្រោះភិក្ខុទាំងនោះ ។ បានឮថា ព្រះអង្គទ្រង់ព្រះតម្រិះថា តថាគតនៅបានត្រឹមតែ ១០ ខែ ក៏នឹងបរិនិព្វាន ។ បើភិក្ខុទាំងនេះនឹងទៅឆ្ងាយ ក៏មិនអាចឃើញតថាគតក្នុងវេលាបរិនិព្វាន បើដូច្នោះ ភិក្ខុទាំងនោះក៏នឹងកើតសេចក្តីក្តៅក្រហាយថា ព្រះសាស្តាកាលបរិនិព្វាន ក៏មិនប្រទានសូម្បីត្រឹមតែសតិដល់យើង បើពួកយើងដឹង ក៏នឹងមិនគប្បីនៅឆ្ងាយយ៉ាងនេះ មិនត្រាស់ធ្វើយថា ភិក្ខុទាំងឡាយនៅជុំវិញក្រុងវេសាលី ក៏នឹងមកស្តាប់ធម៌បានមួយខែ ៨ ដង នឹងបានទទួលឱវាទរបស់ព្រះមានព្រះភាគ ។

បទថា ១ពោ គឺ គ្រោតគ្រាត ។ បទថា អាពាធោ បានដល់រោគដែលជាសត្រូវ ។ បទថា ពាឡ្ហា ប្រែថា ធ្ងន់ធ្ងរ ។ បទថា មរណន្តិកា បានដល់ អាចឲ្យដល់ការស្លាប់ គឺ ជិតនឹងបរិនិព្វាន ។ បទថា សតោ សម្បជានោ អធិវាសេសិ សេចក្តីថា បានដល់ តាំងសតិឲ្យមាំកំណត់ដោយខន្តិញ្ញាណ ។ បទថា អវិហញ្ញមានោ បានដល់ មិនធ្វើឲ្យអាការរសាប់រសល់ ដោយបណ្តោយតាមវេទនា មិនត្រូវវេទនាបៀតបៀនទ្រង់មិនមានទុក្ខក្តៅក្រហាយឡើយ អត់ទ្រាំបាន ។ បទថា អនាមន្តេត្វា បានដល់ ទ្រង់មិនឲ្យឧបដ្ឋាកដឹង ។ បទថា អនបលោកេត្វា គឺ ទ្រង់មិនប្រាប់លាភិក្ខុសង្ឃ ។ លោកអធិប្បាយថា មិនប្រទានឱវាទានុសាសនី ។ បទថា វីរិយេន បានដល់ ដោយសេចក្តីព្យាយាមខាងដើម និងដោយសេចក្តី

ព្យាយាមដែលសម្បយុត្តដោយផលសមាបត្តិ ។ បទថា បដិប្បណាមេត្វា គឺ បណ្តេញ ។ សូម្បីជីវិត ក៏ឈ្មោះថា ជីវិតសង្ខារ ក្នុងពាក្យថា ជីវិតសង្ខារនេះ ។ ជីវិតដែលធម៌ណាតាក់តែង ដល់ដាច់ ក៏បន្តតាំងទៅ សូម្បីធម៌ដែលជាផលសមាបត្តិនោះ ក៏ឈ្មោះថា ជីវិតសង្ខារ ។ ធម៌ គឺ ផលសមាបត្តិនោះ លោកប្រាថ្នាយកក្នុងទីនេះ ។ បទថា អធិដ្ឋាយ បាន ដល់ អធិដ្ឋានឲ្យប្រព្រឹត្តទៅហើយ ។ សេចក្តីសង្ខេបក្នុងសេចក្តីនេះ មាន ដូច្នេះថា តថាគតគប្បីចូលផលសមាបត្តិ ដែលអាចឲ្យជីវិតតាំងទៅបាន ។

សួរថា ក៏ព្រះមានព្រះភាគ ទ្រង់មិនចូលផលសមាបត្តិ ក្នុងកាល មុននេះឬ ។ ឆ្លើយថា ចូល ។ ប៉ុន្តែថា ផលសមាបត្តិនោះ ជាខណិក-សមាបត្តិ ។ ពិតណាស់ ខណិកសមាបត្តិ រមែងគ្របសង្កត់វេទនាចំពោះ ខាងក្នុងសមាបត្តិបានតែម្យ៉ាង ។ ពេលចេញចាកសមាបត្តិ វេទនារមែង គ្របសង្កត់រាងកាយទៀត ដូចសារាយដែលដាច់ព្រោះឈើ ឬក្បឿងធ្លាក់ ចុះទៅ ត្រឡប់គ្របទឹកដូចដើម ។ មួយទៀត សមាបត្តិរបស់អ្នកធ្វើពួក ៧ នៃរូប និងពួក ៧ នៃអរូប ឲ្យអស់ឫសគល់ជុះហើយ ចូលដោយ អំណាចនៃមហាវិបស្សនា ឈ្មោះថា រមែងគ្របសង្កត់បានដោយល្អ ។ ប្រៀបដូចសារាយដែលបុរសចុះទឹកហើយ យកដៃ និងជើងវាចចេញដោយ ល្អ ដល់វេលាយូរទើបនឹងគ្របទឹក យ៉ាងណា អ្នកដែលចេញចាកផល-សមាបត្តិនោះ អស់វេលាយូរ ទើបវេទនានឹងកើតឡើង ដូច្នោះ ។ ដូច្នោះ

ព្រះមានព្រះភាគ ទើបដូចជាទ្រង់តាំងវិបស្សនាថ្មីៗ ក្នុងព្រះមហាពោធិ-បល្ល័ង្កក្នុងថ្ងៃនោះ ទ្រង់ដាក់ចុះដោយអាការ ១៤ ធ្វើពួក ៧ នៃរូប ពួក ៧ នៃអរូប មិនឲ្យមានឫសគល់ មិនឲ្យដុះ ហើយទ្រង់មិនសោយវេទនា ដោយមហាវិបស្សនា ចូលសមាបត្តិដោយទ្រង់ប្រាថ្នាថា សូមវេទនាកុំកើតឡើងដល់អស់ ១០ ខែ ។ វេទនាដែលទ្រង់គ្របសង្កត់ដោយសមាបត្តិ ទើបមិនកើតឡើងដល់អស់វេលា ១០ ខែ ។ វេទនាដែលទ្រង់គ្របសង្កត់ដោយសមាបត្តិ ទើបមិនកើតឡើងដល់អស់វេលា ។

បទថា គិលានា វុដ្ឋិតោ បានដល់ ប្រឈួនហើយបាត់ទៀត ។ បទថា មធុរកជាតោ វិយ បានដល់ ដូចបុរសដេកផ្ងារលើលំពែងដែលកើតការៈធ្ងន់ និងរឹង (ភាពស្រយុតស្រយុង) ។ បទថា ន បក្ខាយន្តិ បានដល់ មិនច្បាស់ គឺ មិនប្រាកដដោយវាចាផ្សេងៗ ។ ដោយបទថា ធម្មាបិ មំ នប្បដិភន្តិ លោកសម្ដែងថា សូម្បីធម៌ គឺ សតិប្បដ្ឋាន មិនប្រាកដដល់យើង ។ តែធម៌ គឺ ព្រះបាលី ព្រះថេរៈស្ទាត់ជំនាញល្អហើយ ។ បទថា ឧទាហរតិ បានដល់ មិនប្រទានបច្ឆិមឱវាទ ។ ព្រះអានន្ទសំដៅយកបច្ឆិមឱវាទនោះ ។

បទថា អនន្តរំ អាពាហិរំ សេចក្ដីថា ព្រះមានព្រះភាគ ទ្រង់ត្រិះរិះថា តថាគតមិនធ្វើ ២ យ៉ាង ដោយធម៌ ឬបុគ្គល ហើយនឹងសម្ដែងធម៌ប៉ុណ្ណេះដល់បុគ្គលដទៃក៏ទេ ឈ្មោះថា ទ្រង់ធ្វើធម៌ឲ្យជាខាងក្នុង ។ ទ្រង់

ត្រិះរិះថា តថាគតនឹងសម្តែងធម៌ប៉ុណ្ណេះដល់បុគ្គលដទៃ ឈ្មោះថា ទ្រង់ធ្វើធម៌ខាងក្រៅ ។ មួយទៀត ទ្រង់ត្រិះរិះថា តថាគតនឹងសម្តែងដល់បុគ្គលនេះ ឈ្មោះថា ទ្រង់ធ្វើបុគ្គលខាងក្នុង ។ កាលទ្រង់ត្រិះរិះថា តថាគតនឹងមិនសម្តែងដល់បុគ្គលនេះ ឈ្មោះថា ទ្រង់ធ្វើបុគ្គលខាងក្រៅ ។ អធិប្បាយថា ទ្រង់មិនធ្វើយ៉ាងនោះសម្តែង ។ ដោយ បទថា អាចរិយមុដ្ឋិ ទ្រង់សម្តែងថា ឈ្មោះថា កណ្តាប់ដៃរបស់អាចារ្យ រមែងមានដល់សាស្តាខាងក្រៅព្រះពុទ្ធសាសនា ។ ពួកសាស្តាខាងក្រៅ មិនពោលដល់នរណាៗ ក្នុងវេលាជាកម្លោះ ដេកលើគ្រែសម្រាប់ស្លាប់ក្នុងវេលាបច្ឆិមវ័យ ក៏ពោលដល់អន្តេវាសិក ដែលទីស្រឡាញ់ពេញចិត្ត ដោយវិធីណា កិច្ចកម្មអ្វីដែលតថាគតបរិហារ តាំងទុកធ្វើជាក្តាប់ដៃថា តថាគតនឹងពោលពាក្យនេះ ក្នុងវេលាចាស់ជរា ក្នុងវេលាបច្ឆិមវ័យ រមែងមិនមានដល់តថាគត ដោយវិធីនោះ ។ បទថា អហំ ភិក្ខុសង្ឃំ សេចក្តីថា តថាគតប៉ុណ្ណោះនឹងបរិហារភិក្ខុសង្ឃ ។ បទថា មមុទ្ទេសិកោ សេចក្តីថា តថាគតជាទីពឹងនៃភិក្ខុសង្ឃនោះ ព្រោះអត្ថថា ភិក្ខុសង្ឃគប្បីអាងតថាគត ហេតុនោះ ភិក្ខុសង្ឃនោះ ឈ្មោះថា មានតថាគតជាទីពឹង ។ អធិប្បាយថា ភិក្ខុសង្ឃបូរលើកសរសើរតថាគតប៉ុណ្ណោះ ពេញចិត្តចំពោះតថាគត កាលតថាគតកន្លងផុតទៅ ឬមិនមានពួកភិក្ខុហើយ ឬមានការប្រព្រឹត្តទៅ ក៏ឬថា ភិក្ខុសង្ឃណាៗ នឹងមានសេចក្តីគិតដូចដែលពោលមកនេះ ។ បទថា ន ឯវំ ហោតិ

សេចក្តីថា សេចក្តីនោះមិនដូច្នោះ ព្រោះសេចក្តីប្រណែន និងសេចក្តីកំណាញ់ តថាគតកម្ចាត់ចេញហើយក្នុងពោធិបល្ល័ង្កនុ៎ះឯង ។ បទថា សត្តិ កាត់ជា សោ ត្តិ ។ បទថា អសីតិកោ ប្រែថា មានអាយុ ៨០ វស្សា ។ ពាក្យនេះ ត្រាស់កាលទ្រង់សម្តែងភាវៈដែលដល់បច្ឆិមវ័យដោយលំដាប់ ។ បទថា វេឡុមិស្សកេន បានដល់ អបដោយឫស្សីសម្រាប់ផុសផុល មានការចងអបកាំ កង់ជាដើម ។ បទថា មញ្ញេ បានដល់ ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដូចរទេះចាស់ ទៅបានដោយអបឫស្សី ។ លោកសម្តែងថា ព្រះតថាគតសម្រេចឥរិយាបថ ៤ ដោយគ្រឿងចង គឺ ព្រះអរហត្តផល ។ ឥឡូវនេះ កាលនឹងទ្រង់សម្តែងសេចក្តីនោះ ទើបត្រាស់ថា យស្មិំ អានន្ទ សមយេ ជាដើម ។

បណ្តាបទទាំងនោះ បទថា សព្វនិមិត្តានំ បានដល់ កលាបៈ មានរូបនិមិត្តជាដើម ។ បទថា ឯកច្ចានំ វេទនានំ បានដល់ វេទនាដែលជាលោកិយៈ ។ ដោយបទថា តស្មាតិហានន្ទ ទ្រង់សម្តែងថា ព្រោះហេតុសេចក្តីសប្បាយ រមែងមានដោយផលសមាបត្តិវិហារ ដូច្នោះ សូម្បីពួកភិក្ខុ ក៏ចូរនៅយ៉ាងនេះ ដើម្បីប្រយោជន៍ដល់សេចក្តីសុខចុះ ។ បទថា អត្តទីបា សេចក្តីថា ពួកអ្នកចូរធ្វើខ្លួនឲ្យជាទីពឹងអាស្រ័យ ដូចកោះកណ្តាលមហាសមុទ្រ ។ បទថា អត្តសរណា បានដល់ ចូរជាអ្នកមានខ្លួនជាគតិប៉ុណ្ណោះ កុំមានយ៉ាងដទៃជាគតិឡើយ ។ សូម្បីក្នុងបទថា ធម្មទីបា ធម្ម-

សរណា ក៏ន័យនេះដូចគ្នា ។ បទថា តមតគ្គេ មានធម៌នោះជាកំពូល ត អក្សរត្រង់កណ្តាល លោកពោលដោយបទសន្ធិ ។ លោកពោលអធិប្បាយថា ម្នាលអានន្ទ ពួកភិក្ខុរបស់តថាគតនោះ កាត់ការប្រកបដោយសភាពខ្ពស់បំផុតទាំងអស់ យ៉ាងនេះថា ពួកភិក្ខុទាំងនេះក៏ខ្ពង់ខ្ពស់ ទាំងនេះក៏ខ្ពង់ខ្ពស់ ហើយនឹងនៅក្នុងធម៌ដ៏ប្រសើរយ៉ាងក្រៃលែង គឺ ក្នុងភាវៈខ្ពង់ខ្ពស់ បានដល់ នឹងមានធម៌ដ៏ឧត្តមក្រៃលែងសម្រាប់ភិក្ខុទាំងនោះ ភិក្ខុពួកណាមួយ ជាអ្នកប្រាថ្នាការសិក្សា គឺ ភិក្ខុទាំងអស់នោះ មានសតិប្បដ្ឋាន ៤ ជាអារម្មណ៍ នឹងមានធម៌ដ៏ប្រសើរ ។ ទ្រង់សរុបទេសនា ឲ្យដល់កំពូល គឺ ព្រះអរហត្តនោះឯង ។

ចប់ កថាពណ៌នាទុតិយភាណវារ

## ពោលអំពី អគ្គសាវកនិព្វាន

[៩៤] *បទថា វេសាលិំ បិណ្ឌាយ ចាវិសិ ស្តេចចូលក្រុងវេសាលី ដើម្បីបិណ្ឌបាតសួរថា ស្តេចចូលទៅកាលណា ។ ឆ្លើយថា ក្នុងវេលាស្តេចចេញចាកឧក្កវេលគាមទៅកាន់ក្រុងវេសាលី ។ បានឮថា ព្រះមានព្រះភាគទ្រង់ចាំវស្សាហើយ ចេញចាកវេឡុវគាម ហើយស្តេចត្រឡប់ដោយផ្លូវដែលស្តេចមកហើយ ដោយពុទ្ធប្រាថ្នាថា នឹងស្តេចទៅកាន់ក្រុងសាវត្ថី ដល់ក្រុងសាវត្ថីដោយលំដាប់ ស្តេចចូលកាន់ព្រះជេតពន ។*

*ព្រះធម្មសេនាបតី ធ្វើវត្តដល់ព្រះមានព្រះភាគហើយ ចូលកាន់ទីសម្រាកពេលថ្ងៃ ។ កាលពួកអន្តេវាសិកធ្វើវត្តក្នុងព្រះជេតពននោះ ត្រឡប់ទៅហើយ លោកក៏បោសសំអាតទីសម្រាកពេលថ្ងៃ ក្រាលផ្ទាំងស្បែកលាងជើង អង្គុយចម្រើនសមាធិចូលផលសមាបត្តិ ។ គ្រាលោកចេញអំពីផលសមាបត្តិនោះតាមកំណត់ហើយ កើតបរិវិតក្កៈយ៉ាងនេះថា ព្រះពុទ្ធទាំងឡាយបរិនិព្វានមុន ឬព្រះអគ្គសាវកហ្ន៎ ។ ក៏ដឹងថា អគ្គសាវកមុន ។ ទើបត្រួតមើលអាយុសង្ខាររបស់ខ្លួន ។ ក៏ដឹងថា អាយុសង្ខាររបស់ខ្លួននឹងប្រព្រឹត្តទៅបានត្រឹមតែ ៧ ថ្ងៃប៉ុណ្ណោះ ។ ត្រិះរិះថា នឹងបរិនិព្វានទីណាហ្ន៎ ។ គិតរឿយៗ ទៅថា ព្រះរាហុលបរិនិព្វានក្នុងតាវត្តិង្ស ព្រះអញ្ញាកោណ្ឌញ្ញៈ ត្រង់ស្រះឆទ្ទន្ត យើងនឹងបរិនិព្វានក្នុងទីណា ។ ក៏កើត*

សតិប្រារព្ធមាតាឡើងថា មាតារបស់យើង សូម្បីជាមាតារបស់ព្រះអរហន្ត ៧ រូប ក៏មិនជ្រះថ្លាក្នុងព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ មាតានោះ មាន ឧបនិស្ស័យឬទេហ្ន៎ ក៏ពេកឃើញឧបនិស្ស័យនៃសោតាបត្តិមគ្គ ពិចារណា ថា មាតានឹងសម្រេចដោយទេសនារបស់អ្នកណា ក៏ដឹងថា នឹងសម្រេច ដោយទេសនារបស់យើង មិនមែនរបស់អ្នកដទៃ ក៏ប្រសិនបើថា យើង គប្បីជាអ្នកខ្វល់ខ្វាយតិចសោត មនុស្សទាំងឡាយក៏នឹងពោលទោសយើង ថា ព្រះសារីបុត្រជាទីពឹងបានសូម្បីដល់ជនដទៃៗ ពិតណាស់ ក្នុងថ្ងៃទេសនា សមចិត្តសូត្ររបស់លោក ទេវតាសែនកោដិ ក៏សម្រេចព្រះអរហត្ត ទេវតា ដែលសម្រេចមគ្គ ៣ រាប់មិនបាន និងក្នុងទីដទៃប្រាកដថា មានការ សម្រេចច្រើនណាស់ ម្យ៉ាងទៀត ព្រោះធ្វើចិត្តឲ្យជ្រះថ្លាក្នុងព្រះថេរៈ ត្រកូលដល់ ៨០,០០០ ត្រកូល កើតក្នុងសួគ៌ ឥឡូវនេះ ព្រះថេរៈមិនអាច កម្ចាត់សូម្បីត្រឹមតែសេចក្តីឃើញខុសរបស់មាតាបាន ព្រោះដូច្នោះ ទើប ដាក់ចិត្តថា យើងនឹងដោះមាតាចេញចាកមិច្ឆាទិដ្ឋិ ហើយនឹងបរិនិព្វានក្នុង បន្ទប់តូចដែលយើងកើត ត្រិះរិះតទៅទៀតថា យើងនឹងទូលលាព្រះមាន-ព្រះភាគទៅក្នុងថ្ងៃនេះឯង ទើបហៅព្រះចុន្ទត្ថេរមកថា មកទៅជាមួយគ្នា ចុះចុន្ទៈ អ្នកចូរប្រាប់ភិក្ខុបរិស័ទ ៥០០ រូប របស់យើងថា អាវុសោ លោកចូរកាន់បាត្រ និងចីវរ ព្រះធម្មសេនាបតី ប្រាថ្នានឹងទៅនាលក-គ្រាម ។ ព្រះថេរៈបានធ្វើយ៉ាងនោះ ។ ភិក្ខុរក្សាទុកដាក់សេនាសនៈ កាន់

បាត្រ ចីវរមកកាន់សម្នាក់ព្រះថេរៈ ។

ព្រះថេរៈក៏រក្សាទុកដាក់សេនាសនៈ បោសសំអាតទីសម្រាកពេលថ្ងៃ ឈរត្រង់ទ្វារសម្លឹងមើលទីសម្រាកពេលថ្ងៃ ត្រិះរិះថា ឥឡូវនេះជាការឃើញគ្រាចុងបង្អស់ មិនមានការត្រឡប់មក អ្នកដែលភិក្ខុ ៥០០ រូបហែហមហើយ ទើបចូលទៅគាល់ព្រះមានព្រះភាគ ថ្វាយបង្គំហើយ ក្រាបទូលជាពាក្យបង្ក្រងចំពោះព្រះមានព្រះភាគថា ៖

ឆិន្នោទានិ ភវិស្សាមិ លោកនាថ មហាមុនិ
គមនាគមនំ នត្ថិ បច្ឆិមា វន្ទនា អយំ ។
ជីវិតំ អប្បកំ មយ្ហំ ឥតោ សត្តាហមច្ចយេ
និក្ខិបេយ្យាមហំ ទេហំ ភារវោរោបនំ យថា ។
អនុជានាតុ មេ ភន្តេ "ភគវា" អនុជានាតុ សុគតោ
បរិនិព្វានកាលោ មេ ឱស្សដ្ឋោ អាយុសង្ខរោតិ ។

បពិត្រព្រះមហាមុនីលោកនាថ ឥឡូវនេះ ខ្ញុំព្រះអង្គកាត់អស់ហើយ មិនមានការទៅការមក នេះជាការថ្វាយបង្គំលាគ្រាចុងបង្អស់ ជីវិតរបស់ខ្ញុំព្រះអង្គតិច តទៅនេះកន្លងទៅ ៧ ថ្ងៃ ខ្ញុំព្រះអង្គនឹងដាក់ចោលផ្ទះ គឺ រាងកាយដូចដាក់ការៈចុះ សូមព្រះមានព្រះភាគមេត្តាអនុញ្ញាត សូមព្រះសុគតមេត្តាអនុញ្ញាត ដល់ខ្ញុំព្រះអង្គផងចុះ នេះជាវេលា

បរិនិព្វាន ខ្ញុំព្រះអង្គដាក់អាយុសង្ខារហើយព្រះអង្គ ។

ក៏ព្រោះហេតុដែលពួកមិច្ឆាទិដ្ឋិ ពេញចិត្តលើកទោសថា កាលព្រះមានព្រះភាគត្រាស់ថា ចូរបរិនិព្វានចុះ ក៏នឹងក្លាយជាថា ពណ៌នាគុណរបស់សេចក្តីស្លាប់ កាលត្រាស់ថា កុំបរិនិព្វានឡើយ ក៏នឹងក្លាយជាពោលគុណរបស់វដ្តសង្សារ ព្រោះដូច្នោះ ព្រះពុទ្ធទាំងឡាយ ទើបមិនត្រាស់សូម្បីពាក្យទាំងពីរ ។ ដោយហេតុនោះ ព្រះមានព្រះភាគត្រាស់នឹងលោកថា សារីបុត្រ អ្នកនឹងបរិនិព្វានទីណា ។ កាលព្រះថេរៈក្រាបទូលថា ក្នុងបន្ទប់តូច ក្នុងនាលកគ្រាម ដែនមគធៈ ខ្ញុំព្រះអង្គនឹងបរិនិព្វានក្នុងបន្ទប់នោះ ព្រះអង្គ ។ ទើបត្រាស់ថា សារីបុត្រ ឥឡូវនេះ អ្នកសម្គាល់កាលដ៏សមគួរចុះ វេលានេះ ការឃើញភិក្ខុដូច្នោះ សម្រាប់បងប្អូនរបស់លោក នឹងរកបានដោយក្រ ព្រោះដូច្នោះ អ្នកចូរសម្តែងធម៌ដល់បងប្អូនទាំងនោះចុះ ។

ព្រះថេរៈដឹងថា ព្រះសាស្តាទ្រង់មានព្រះបំណងនឹងឲ្យយើងសម្តែងឫទ្ធិផ្សេងៗ មុននឹងសម្តែងធម៌ ទើបថ្វាយបង្គំព្រះមានព្រះភាគ ហើយហោះកម្ពស់ ៧ ដើមត្នោត ត្រឡប់ចុះមកថ្វាយបង្គំ ហើយឈរកណ្តាលអាកាសកម្ពស់ ៧ ដើមត្នោត សម្តែងឫទ្ធិផ្សេងៗ ច្រើនយ៉ាង ហើយសម្តែងធម៌ ។ អ្នកនគរទាំងអស់ប្រជុំគ្នា ។ ព្រះថេរៈចុះមក ហើយថ្វាយបង្គំព្រះមានព្រះភាគ ក្រាបទូលថា ដល់វេលាទៅរបស់ខ្ញុំព្រះអង្គហើយ

ព្រះអង្គ ។ ព្រះមានព្រះភាគប្រថាប់លើធម្មាសនៈ ទ្រង់ព្រះត្រិះរិះថា នឹងឲ្យសារីបុត្រសម្តែងឫទ្ធិហើយ ទើបក្រោកអំពីធម្មាសនៈ ស្តេចបែរព្រះភ័ក្ត្រទៅកាន់ព្រះគន្ធកុដិ ហើយប្រថាប់ឈរលើបល្ល័ង្កកែវមណី ។ ព្រះថេរៈធ្វើប្រទក្សិណ ៣ ជុំ ហើយថ្វាយបង្គំក្នុងទិសទាំង ៤ ក្រាបទូលថា រាប់ថយអំពីកប្បនេះទៅ បាន ១ អសង្ខេយ្យ ១ សែនកប្ប ខ្ញុំព្រះអង្គបង្អោននៅទៀបបាទមូលរបស់ព្រះអនោមទស្សីសម្មាសម្ពុទ្ធ ប្រាថ្នានឹងជួបព្រះអង្គ សេចក្តីប្រាថ្នានោះរបស់ខ្ញុំព្រះអង្គសម្រេចហើយ ខ្ញុំព្រះអង្គឃើញព្រះអង្គហើយ នោះជាការឃើញគ្រាដំបូង នេះជាការឃើញគ្រាចុងក្រោយ នឹងមិនមានការឃើញព្រះអង្គទៀតឡើយ ហើយផ្គងអញ្ជលីដែលរុងរឿងដោយទសនខសមោធាន ហើយត្រឡប់ថយក្រោយទៅដរាបផុតទស្សនវិស័យ តាំងពីឥឡូវនេះទៅ ដែលឈ្មោះថា ការទៅការមកក្នុងឋានៈណាៗដោយអំណាចចុតិបដិសន្ធិមិនមាន ដូច្នេះហើយ ទើបថ្វាយបង្គំលាទៅ ។ ផែនមហាប្រថពីក៏ញ័រដរាបដល់ទឹកទ្រផែនដី ។ ព្រះមានព្រះភាគក៏ត្រាស់ចំពោះពួកភិក្ខុដែលឈរលោមព័ទ្ធនោះថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរទៅតាមបងប្រុសរបស់ពួកអ្នកចុះ ។ ភិក្ខុទាំងឡាយនាំគ្នាទៅដរាបដល់ខ្លោងទ្វារ ។ ព្រះថេរៈពោលថា ឈប់ចុះអ្នកមានអាយុ ពួកអ្នកចូរជាអ្នកមិនប្រមាទចុះ ហើយឲ្យភិក្ខុទាំងនោះត្រឡប់វិញ ចំណែកខ្លួនលោកក៏ទៅព្រមនឹងបរិស័ទ ។

ពួកមនុស្សក៏នាំគ្នាជាប់តាមនោះយំរៀបរាប់ថា ពីមុនលោកម្ចាស់ចារិកទៅក៏ត្រឡប់មក តែគ្រានេះទៅបាត់មិនត្រឡប់មក ។ ព្រះថេរៈពោលថា អ្នកមានអាយុ ពួកលោកកុំប្រមាទ សង្ខារទាំងឡាយក៏ជាយ៉ាងនេះឯង ហើយឲ្យមនុស្សទាំងនោះវិលត្រឡប់វិញ ។ គ្រានោះ ព្រះសារីបុត្រអនុគ្រោះមនុស្សរហូតដល់អស់ ៧ ថ្ងៃ ក្នុងចន្លោះផ្លូវ ដល់នាលកគ្រាមក្នុងវេលាល្ងាច ហើយឈប់សម្រាកត្រង់ដើមជ្រៃ ជិតទ្វារស្រុក ។

គ្រានោះ ក្មួយប្រុសរបស់ព្រះថេរៈឈ្មោះថា ឧបរេវតៈ ទៅក្រៅស្រុកជួបព្រះថេរៈចូលទៅរកហើយសំពះឈរ ។ ព្រះថេរៈនិយាយជាមួយក្មួយប្រុសថា យាយរបស់ឯងនៅក្នុងផ្ទះឬ ។ ក្មួយប្រុសក៏ឆ្លើយថា ព្រះករុណា ។ ព្រះថេរៈប្រាប់ថា ឯងចូរទៅប្រាប់ថា យើងមកទីនេះហើយ និងកាលយាយសួរថា ព្រោះហេតុអ្វី ចូរប្រាប់ថា បានឮថា លោកនឹងសម្រាកក្នុងស្រុកនេះមួយថ្ងៃ ចូរចាត់បន្ទប់តូចដែលយើងកើត និងចាត់ទីនៅសម្រាប់ភិក្ខុ ៥០០ រូប ។ ក្មួយទៅប្រាប់ថា លោកយាយ លោកអ៊ំនិមន្តមកហើយ ។ យាយសួរថា ឥឡូវនេះនៅឯណាចៅ ។ ឆ្លើយថា នៅជិតទ្វារស្រុក ក៏សួរថា មកតែមួយអង្គ ឬថា មានភិក្ខុដទៃមកផង ។ ចៅក៏ឆ្លើយថា មានភិក្ខុ ៥០០ រូបមកផង ។ កាលសួរថា មកធ្វើអ្វី ។ ចៅក៏ប្រាប់រឿងនោះ ។ នាងព្រាហ្មណីគិតថា ហេតុដូចម្តេចហ្ន៎ ទើបត្រូវបង្គាប់ឲ្យចាត់ស្ថានទីនៅសម្រាប់ភិក្ខុយ៉ាងច្រើនដល់ម្ល៉េះ គេបួសកាលកម្លោះ

ចង់មកជាគ្រហស្ថកាលចាស់ ទើបឲ្យចាត់បន្ទប់ដែលលោកបានកើត ឲ្យធ្វើទីនៅសម្រាប់ភិក្ខុ ៥០០ រូប អុជប្រទីបទុកទទួលព្រះថេរៈ ។ ព្រះថេរៈនឹងភិក្ខុទាំងឡាយ ឡើងទៅកាន់ប្រាសាទ ចូលទៅកាន់បន្ទប់ដែលកើត ហើយអង្គុយ និងបញ្ជូនភិក្ខុទាំងឡាយទៅដោយពោលថា ចូរនាំគ្នាទៅកាន់ទីនៅរបស់ពួកលោកចុះ ។ ពេលភិក្ខុទាំងឡាយទៅហើយ អាពាធខ្លាំងក្លាក៏កើតឡើងដល់ព្រះថេរៈ ។ រោគធ្លាក់លោហិតកើតវេទនាជិតស្លាប់ ។ ភាជនៈមួយគ្រង ភាជនៈមួយនាំចេញ ។ នាងព្រាហ្មណីគិតថា ការទៅនៃបុត្ររបស់យើងមិនជាទីពេញចិត្ត ក៏ឈរផ្អែកទ្វារបន្ទប់របស់ខ្លួន ។ ស្តេចមហារាជទាំង ៤ ពិចារណាថា ព្រះធម្មសេនាបតីនៅទីណា ក៏ដឹងថា ដេកលើគ្រែដែលបរិនិព្វាន ក្នុងបន្ទប់តូចកាលដែលលោកកើតក្នុងនាលកគ្រាម យើងនឹងទៅមើលជាបច្ឆិមទស្សនៈ ហើយនាំគ្នាមកឈរសំពះ ។ ព្រះថេរៈសួរថា លោកជាអ្នកណា ឆ្លើយថា បពិត្រលោកម្ចាស់ ពួកយើងជាស្តេចមហារាជ ។ សួរថា មកធ្វើអ្វី ។ ឆ្លើយថា មកជាគិលានុបដ្ឋាក ។ ព្រះថេរៈពោលដោយពាក្យថា ណ្ហើយចុះ គិលានុបដ្ឋាកមានហើយ លោកចូរទៅវិញចុះ ។ គ្រាស្តេចមហារាជទៅហើយ សក្កទេវរាជជាស្តេចទេវតាក៏មកដោយន័យនោះដូចគ្នា ។ កាលស្តេចសក្កៈយាងទៅហើយ ស្តេចសុយាមៈជាដើម និងស្តេចមហាព្រហ្មក៏នាំគ្នាមក ។ ព្រះថេរៈក៏ពោលនឹងទេវតា និងព្រហ្មទាំងនោះឲ្យទៅ យ៉ាងនោះដូចគ្នា ។

នាងព្រាហ្មណីឃើញពួកទេវតាមក និងទៅ គិតថា ពួកទាំងនោះជាអ្នកណាហ្ន៎ ទើបមកសំពះហើយសំពះទៀត នូវបុត្ររបស់យើង ហើយក៏ទៅ ទើបទៅកាន់ទ្វារបន្ទប់របស់ព្រះថេរៈ សួរថា អ្នកណាមក មានហេតុយ៉ាងណា ព្រះចុន្ទត្ថេរៈប្រាប់រឿងនោះ ហើយពោលថា មហាឧបាសិកាមកហើយ លោកម្ចាស់ ។ ព្រះថេរៈសួរថា ហេតុដូចម្ដេចទើបមកខុសវេលា ។ នាងព្រាហ្មណីឆ្លើយថា មកសួរសុខទុក្ខកូនឯង ហើយសួរថា លោកកូន តើពួកអ្នកណាមកពីដំបូង ។ ព្រះថេរៈឆ្លើយថា ឧបាសិកា ស្ដេចមហារាជទាំង ៤ មកពីដំបូង ។ នាងព្រាហ្មណីសួរថា លោកកូន កូនឯងជាធំជាងស្ដេចមហារាជទាំង ៤ ឬ ។ ឆ្លើយថា ឧបាសិកា ស្ដេចមហារាជទាំងនោះ ក៏ដូចអ្នកបាំរវត្ត ទ្រង់កាន់ព្រះខ័ណ្ឌរក្សា តាំងពីព្រះសាស្ដារបស់យើងទ្រង់ចុះចាប់បដិសន្ធិ ។ សួរថា គ្រាស្ដេចមហារាជទាំងនោះត្រឡប់ទៅហើយ អ្នកណាមកទៀតលោកកូន ។ ឆ្លើយថា សក្កទេវរាជជាស្ដេចទេវតា ។ សួរថា កូនឯងជាធំជាងស្ដេចសក្កទេវរាជឬ ។ ឆ្លើយថា ឧបាសិកា ស្ដេចសក្កៈនោះ ក៏ដូចសាមណេរកាន់វត្ថុ កាលព្រះសាស្ដារបស់យើងចុះអំពីតាវត្តិង្ស ក៏ទ្រង់កាន់បាត្រ និងចីវរចុះមក ។ សួរថា គ្រាស្ដេចសក្កៈនោះត្រឡប់ហើយ អ្នកណាមានពន្លឺអស្ចារ្យមកលោកកូន ។ ឆ្លើយថា ឧបាសិកា អ្នកនោះឈ្មោះស្ដេចមហាព្រហ្ម ជាន់សុទ្ធាវាស ទាំងជាអ្នកមានគុណបុណ្យ ទាំងជាគ្រូរបស់អ្នកម៉ែផងដែរ ។ សួរថា កូនឯង

ក៏នៅតែជាធំជាងស្តេចមហាព្រហ្មនោះទៀតឬ ។ ឆ្លើយថា ចម្រើនពរ ឧបាសិកា ។ បានឮថា ក្នុងថ្ងៃដែលព្រះសាស្តារបស់យើងប្រសូតិ ស្តេចមហាព្រហ្មទាំង ៤ នេះ ប្រើសំណាញ់មាសមកទទួលព្រះមហាបុរស គ្រានោះ នាងព្រាហ្មណីគិតថា បុត្ររបស់យើងនៅមានអានុភាពដល់ម្ល៉េះ ព្រះមានព្រះភាគ សាស្តារបស់បុត្រយើង នឹងមានអានុភាពច្រើនប៉ុនណាទៅហ្ន៎ ។ បីតិ ៥ យ៉ាង កើតឡើងផ្សាយទៅទូទាំងរាងកាយយ៉ាងឆាប់រហ័ស ។

ព្រះថេរៈគិតថា មាតារបស់យើងកើតបីតិសោមនស្ស ឥឡូវនេះជាវេលាសមគួរដែលនឹងសម្តែងធម៌ ទើបពោលថា មហាឧបាសិកាគិតទៅដល់ហេតុដូចម្តេច ។ នាងព្រាហ្មណីពោលថា បុត្ររបស់យើងមានគុណដល់ម្ល៉េះ ព្រះសាស្តារបស់បុត្រយើងនឹងមានគុណច្រើនប៉ុនណាទៅហ្ន៎ ដូច្នោះ ម៉ែទើបគិតយ៉ាងនេះលោកកូន ។ ព្រះថេរៈពោលថា មហាឧបាសិកា សម័យព្រះសាស្តារបស់យើងប្រសូតិ ចេញមហាភិនេស្រ្កមណ៍ ត្រាស់ដឹង និងប្រកាសព្រះធម្មចក្រ មុឺនលោកធាតុក៏ញាប់ញ័រ ដែលឈ្មោះថា អ្នកស្មើដោយសីល សមាធិ បញ្ញា វិមុត្តិ វិមុត្តិញ្ញាណទស្សនៈ មិនមាន ហើយពោលព្រះធម៌ទេសនាដែលប្រកបដោយព្រះពុទ្ធគុណយ៉ាងពិស្តារថា សូម្បីព្រោះហេតុនេះ ព្រះមានព្រះភាគអង្គនោះ ជាដើម ។ វេលាចប់ព្រះធម៌ទេសនារបស់បុត្រទីស្រឡាញ់ នាងព្រាហ្មណីក៏តាំងនៅក្នុងសោតាបត្តិផល ហើយពោលនឹងបុត្រថា បា ! ឧបតិស្សៈ

ហេតុអ្វី កូនឯងទើបបានធ្វើយ៉ាងនេះ កូនឯងមិនឲ្យអមតធម៌ឈ្មោះនេះដល់ម៉ែ រហូតដល់អស់វេលាដល់ត្រឹមនេះ ។

ព្រះថេរៈគិតថា ឥឡូវនេះតម្លៃទឹកដោះ ការបញ្ចុកបាយ ដែលនាងសារីព្រាហ្មណីមាតារបស់យើងបានឲ្យ ក៏បានតបស្នងសងដោយហេតុត្រឹមតែប៉ុណ្ណេះ ទើបប្រាប់នាងព្រាហ្មណី ដោយពោលថា ទៅចុះមហាឧបាសិកា ហើយសួរថា ជិតភ្លឺហើយឬនៅ ។ ឆ្លើយថា ជិតភ្លឺហើយលោកម្ចាស់ ។ ប្រាប់ថា បើយ៉ាងនោះ ចូរប្រជុំព្រះភិក្ខុសង្ឃចុះ ។ ឆ្លើយថា ព្រះសង្ឃប្រជុំគ្នាហើយលោកម្ចាស់ ។ ប្រាប់ទៀតថា ចូរលើកយើងឡើងឲ្យអង្គុយ ។ ព្រះចុន្ទៈក៏លើកឡើងឲ្យអង្គុយ ។ ព្រះថេរៈហៅភិក្ខុទាំងឡាយថា អ្នកដ៏មានអាយុ ពួកលោកនៅជាមួយយើងមកអស់ ៤៤ ឆ្នាំ មិនពេញចិត្តផ្លូវកាយកម្ម ឬវចីកម្មរបស់យើង យ៉ាងណា អ្នកមានអាយុ ចូរអត់នូវទោសនោះផង ។ ភិក្ខុទាំងឡាយពោលថា លោកម្ចាស់ ពួកយើងត្រាច់ទៅមិនលះបង់លោកម្ចាស់ ដូចស្រមោល ឈ្មោះថា កម្មដែលមិនពេញចិត្តសូម្បីត្រឹមនេះ រមែងមិនមានដល់ពួកយើង តែសូមលោកម្ចាស់ មេត្តាអត់នូវទោសដល់ពួកយើងផង ។ គ្រាពន្លឺអរុណប្រាកដ ព្រះថេរៈញ៉ាំងមហាប្រថពីឲ្យរញ្ជួយលាន់ឮកងរំពង ហើយបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ។ ទេវតា និងមនុស្សជាច្រើននាំគ្នាធ្វើសក្ការៈក្នុងស្ថានទីបរិនិព្វាន ។

ព្រះចុន្ទៈកាន់បាត្រ និងចីវរ និងសំពត់ខ្ចប់ព្រះធាតុទៅកាន់ព្រះ-

ជេតពន នាំព្រះអានន្ទត្ថេរចូលគាល់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគទ្រង់កាន់សំពត់តម្រងទឹកដែលខ្ចប់ព្រះធាតុ ពោលគុណរបស់ព្រះថេរៈ ដោយគាថា ៥០០ គាថា ទ្រង់បង្គាប់ឲ្យសាងព្រះធាតុចេតិយ បានប្រទានសញ្ញាដល់ព្រះអានន្ទត្ថេរ ដើម្បីស្តេចទៅកាន់ក្រុងរាជគ្រឹះ ។ ព្រះថេរៈក៏ប្រាប់ភិក្ខុទាំងឡាយ ។

ចំណែកព្រះមានព្រះភាគ មានភិក្ខុសង្ឃជាបរិវារ ស្តេចបានទៅកាន់ក្រុងរាជគ្រឹះ ។ ក្នុងវេលាស្តេចទៅកាន់ក្រុងរាជគ្រឹះនោះ ។ ព្រះមហាមោគ្គល្លានត្ថេរក៏បរិនិព្វាន ។ ព្រះមានព្រះភាគទ្រង់កាន់យកព្រះធាតុរបស់ព្រះមហាមោគ្គល្លាននោះ បង្គាប់ឲ្យសាងចេតិយហើយ ចេញចាកក្រុងរាជគ្រឹះ បែរព្រះភ័ក្ត្រទៅកាន់ទន្លេគង្គា ស្តេចដល់ស្រុកឧក្កវេលគ្រាមដោយលំដាប់ ។ ត្រង់មាត់ច្រាំងទន្លេគង្គា ក្នុងឧក្កវេលគ្រាមនោះ ទ្រង់មានព្រះភិក្ខុសង្ឃជាបរិវារប្រថាប់ក្នុងទីនោះ ទ្រង់សម្តែងព្រះសូត្រដែលជាប់ដោយការបរិនិព្វានរបស់ព្រះសារីបុត្រ និងព្រះមោគ្គល្លាន ចេញចាកឧក្កវេលគ្រាម ស្តេចដល់ក្រុងវេសាលី ។ កាលស្តេចចូលទៅយ៉ាងនោះ គ្រានោះព្រះមានព្រះភាគ ក្នុងវេលាព្រឹកបានទ្រង់អន្តរវាសកៈ កាន់បាត្រនិងចីវរ ស្តេចចូលទៅបិណ្ឌបាតក្នុងក្រុងវេសាលី ។ កថាសម្តែងតាមលំដាប់ក្នុងរឿងនេះ មានដូចពោលមកដូច្នេះ ។

ក្នុងពាក្យថា **និសីទនំ** នេះ លោកប្រាថ្នាយកផ្ទាំងស្បែក ។ ពាក្យថា

**ឧទេនចេតិយ** លោកពោលដល់វត្ត ដែលសាងត្រង់ទីចេតិយរបស់ឧទេនយក្ខ ។ សូម្បីក្នុងគោតមកចេតិយជាដើមក៏ន័យនេះដូចគ្នា ។ បទថា ភាវិតា ប្រែថា ចម្រើនហើយ ។ បទថា ពហុលីកតា ប្រែថា ធ្វើរឿយៗ ។ បទថា យានីកតា ប្រែថា ធ្វើដូចយានដែលទឹមហើយ ។ បទថា វត្ថុកតា ប្រែថា ធ្វើដូចផ្ទៃដី ព្រោះអត្ថថា ជាទីតាំង ។ បទថា អនុដ្ឋិតា ប្រែថា តម្កល់ទុកហើយ ។ បទថា បរិចិតា ប្រែថា បង្កើរទុកដោយជុំវិញ គឺធ្វើឲ្យចម្រើនដោយល្អ ។ បទថា សុសមារទ្ធា ប្រែថា ចាប់ផ្តើមដោយល្អ ។ ព្រះមានព្រះភាគ ត្រាស់ដោយមិនកំណត់ ដូចពោលមកដូច្នេះហើយ កាលនឹងទ្រង់សម្តែងមិនកំណត់ទៀត ទើបត្រាស់ថា តថាគតស្ស ជាដើម ។

គប្បីជ្រាបវិនិច្ឆ័យក្នុងរឿងនេះតទៅនេះ ៖

ពាក្យថា កប្បំ បានដល់ អាយុកប្ប ។ ព្រះតថាគតកាលធ្វើអាយុប្រមាណរបស់ពួកមនុស្ស ក្នុងកាលនោះៗ ឲ្យបរិបូណ៌គប្បីតាំងនៅ ។ បទថា កប្បាវសេសំ វា បានដល់ ច្រើនជាងមួយរយឆ្នាំ , ដែលត្រាស់ទុកថា អប្បំ វា ភិយ្យោ តិចជាង ១០០ ឆ្នាំ ឬច្រើនជាងនោះ ។ ចំណែកព្រះមហាសិវត្ថេរពោលថា ឈ្មោះថា ការបន្ទឹក្នុងឋានៈដែលមិនសមគួរនៃព្រះពុទ្ធទាំងឡាយមិនមាន ។ ពិតណាស់ ព្រះអង្គទ្រង់គ្របសង្កត់វេទនាស្មើរតែស្លាប់ ដែលកើតឡើងក្នុងវេឡុវគ្រាម សូម្បី ១០ ខែ

បាន យ៉ាងណា ក៏ទ្រង់ចូលសមាបត្តិនោះរឿយៗ ទ្រង់គ្របសង្កត់វេទនាបានដល់ ១០ ខែ ក៏គប្បីទ្រង់តាំងនៅបាន រហូតដល់អស់កប្បនេះបាន ដូច្នោះ ។ សួរថា ក៏ព្រោះហេតុអ្វី ព្រះអង្គទើបទ្រង់មិនតាំងនៅ ។ ឆ្លើយថា ព្រោះដែលឈ្មោះថា សរីរៈដែលមានចិត្តគ្រប់គ្រង ត្រូវវិរោធិ-ប្បច្ច័យ មានធ្មេញបាក់ជាដើម គ្របសង្កត់ សេចក្ដីពិត ព្រះពុទ្ធទាំងឡាយ មិនទាន់ដល់ការៈនៃវិរោធិប្បច្ច័យ មានធ្មេញបាក់ជាដើម រមែងបរិនិព្វាន ក្នុងវេលាដែលទ្រង់ជាទីស្រឡាញ់ ជាទីពេញចិត្តរបស់មហាជនតែម្យ៉ាង ។ មួយទៀត កាលព្រះមហាសាវកអ្នកត្រាស់ដឹងតាមព្រះពុទ្ធ បរិនិព្វានហើយ ក៏គប្បីតាំងនៅដូចដង្គត់ឈើមួយដើម ស្ដេចយាងទៅជាមួយភិក្ខុកម្មោះ និងសាមណេរជាបរិវារ ក៏ត្រូវគេមើលងាយថា មើលបរិស័ទទាំងឡាយ របស់ព្រះពុទ្ធ ។ ព្រោះដូច្នោះ ទើបទ្រង់មិនតាំងនៅ ។ សូម្បីកាលត្រូវពោលយ៉ាងនេះ ព្រះអង្គក៏នឹងទ្រង់ពេញព្រះទ័យ ។ ពាក្យថា អាយុកប្បោ នេះ លោកនិយាមទុកក្នុងអដ្ឋកថាហើយ ។

ក្នុងពាក្យថា យថា តំ មារេន បរិយុដ្ឋិតចិត្តោ នេះ ពាក្យថា តំ ត្រឹមតែជានិបាត ។ អធិប្បាយថា បុថុជ្ជនណាសូម្បីដទៃ ត្រូវមារបណ្ដាលចិត្ត គ្របសង្កត់ចិត្ត មិនគប្បីអាចនឹងដឹងច្បាស់បាន យ៉ាងណា ព្រះអានន្ទក៏មិនអាចដឹងច្បាស់ដូច្នោះដែរ ។ សេចក្ដីពិត មាររមែងបណ្ដាលចិត្តរបស់អ្នកដែលលះវិបល្លាស ៤ មិនទាន់បានគ្រប់ៗ ប្រការ ។ ព្រះថេរៈ

ក៏លះវិបល្លាស ៤ មិនទាន់បាន ដោយហេតុនោះ មារទើបគ្របសង្កត់ចិត្តលោក ។ សួរថា ក៏មារនោះកាលបណ្តាលចិត្ត ធ្វើយ៉ាងណា ។ ឆ្លើយថា មារសម្តែងអារម្មណ៍ គឺ រូប ឬឲ្យបានឮអារម្មណ៍ គឺ សំឡេងដែលគួរខ្លាច តពីនោះ ពួកសត្វឃើញរូប ឬបានឮសំឡេងនោះហើយ ក៏បាត់សតិហើយហាមាត់ ។ មារក៏ស៊កដៃចូលក្នុងមាត់របស់សត្វទាំងនោះ ហើយច្របាច់ហទយៈ ។ តពីនោះ ពួកសត្វក៏សន្ធប់ ។ តែសម្រាប់ព្រះថេរៈ ដូចម្តេច មារអាចស៊កដៃចូលក្នុងមាត់ព្រះថេរៈបាន បានតែសម្តែងអារម្មណ៍ដែលគួរខ្លាច ។ ព្រះថេរៈឃើញមារនោះ ក៏មិនដឹងច្បាស់ឱកាស គឺ និមិត្ត ។ សួរថា ព្រះមានព្រះភាគកាលទ្រង់ជ្រាប ត្រាស់ហៅដល់ ៣ ដង ដើម្បីប្រយោជន៍អ្វី ។ ឆ្លើយថា ដើម្បីទ្រង់ បន្ទោបង់សេចក្តីសោក ដោយការលើកទោសទុកខាងមុខថា កាលតថាគត ត្រូវអ្នកអង្វរថា ព្រះមានព្រះភាគមេត្តាតាំងនៅចុះព្រះអង្គ ។ អ្នកធ្វើមិនល្អយ៉ាងនោះ អ្នកធ្វើខុសយ៉ាងនេះ ។

## ពោលអំពីការអារាធនារបស់មារឲ្យព្រះមានព្រះបរិនិព្វាន

[៩៥] ឈ្មោះថា មារក្នុងពាក្យថា មារោ ចាបិមា នេះ ឈ្មោះថា **មារ** ព្រោះបង់សត្វទុកក្នុងសេចក្តីវិនាស ធ្វើឲ្យស្លាប់ ។ បទថា ចាបិមា ជាវេវចនៈរបស់ពាក្យថា **មារ** នុ៎ះឯង ។ ពិតមែន មារនោះ លោកហៅថា

មារ ព្រោះប្រកបដោយបាបធម៌ ។ សូម្បីពាក្យថា **កណ្ហ អន្តក នមុចិ បមត្តពន្ធុ** ក៏ជាឈ្មោះរបស់មារនោះដូចគ្នា ។ បទថា ភាសិតា ខោ បនេសា សេចក្តីថា ក៏មារនេះ ជាប់តាមមកតាំងពីពោធិមណ្ឌស្ថានក្នុងសប្តាហ៍ទី ៨ តាំងអំពីព្រះមានព្រះភាគទ្រង់សម្រេចសម្មាសម្ពោធិញ្ញាណពោលថា ព្រះមានព្រះភាគ ទ្រង់សម្រេចប្រយោជន៍របស់ព្រះអង្គ ដែលព្រះអង្គទ្រង់បំពេញព្រះបារមីមកដោយលំដាប់ហើយ ទ្រង់បានសម្រេចព្រះសម្ពោធិញ្ញាណហើយ ព្រះអង្គនឹងទ្រង់ត្រួតមើលលោកទៅ ហេតុដូចម្តេចទើបទូលអង្វរថា ឥឡូវនេះ សូមព្រះមានព្រះភាគទ្រង់បរិនិព្វានទៅក្នុងថ្ងៃនេះចុះ ព្រះអង្គ ។ តែព្រះមានព្រះភាគត្រាស់បដិសេធដល់មារនោះថា តថាគតនឹងមិនបរិនិព្វាន ដូច្នេះជាដើម ។ មារសំដៅយកសេចក្តីនោះ ទើបពោលថា ភាសិតា ខោ បនេសា ភន្តេ ជាដើម ។

បណ្តាបទទាំងនោះ បទថា វិយត្តា បានដល់ ឈ្លាសដោយមគ្គ ។ ភិក្ខុទាំងឡាយត្រូវណែនាំយ៉ាងនោះដូចគ្នា ក្លៀវក្លាក៏យ៉ាងនោះ ។ បទថា ពហុស្សុតា ឈ្មោះថា ពហុស្សូត ព្រោះមានសុតៈច្រើនដោយព្រះត្រៃបិដក ។ ឈ្មោះថា ធម្មធរ ព្រោះទ្រទ្រង់ធម៌នុ៎ះឯង ។ម្យ៉ាងទៀត គប្បីជ្រាបសេចក្តីក្នុងសេចក្តីនេះយ៉ាងនេះថា ជាពហុស្សូតដោយបរិយត្តិ ១ ជាពហុស្សូតដោយបដិវេធ ១ ឈ្មោះថា ធម្មធរ ព្រោះទ្រទ្រង់ធម៌ គឺបរិយត្តិ និងបដិវេធនុ៎ះឯង ។ បទថា ធម្មានុធម្មប្បដិបន្នា បានដល់

បដិបត្តិវិបស្សនាធម៌ ដែលសមគួរដល់អរិយធម៌ ។ បទថា សាមីចិប្បដិបន្នា បានដល់ បដិបត្តិបដិបទាដែលសមគួរ ។ បទថា អនុធម្មចារិនោ ប្រែថា មានប្រក្រតីប្រព្រឹត្តធម៌ដ៏សមគួរ ។ បទថា សកំ អាចរិយកំ បានដល់ វាទៈអាចារ្យរបស់ខ្លួន ។ ពាក្យទាំងអស់មានថា អាចិក្ខិស្សន្តិ ជាដើម ជាវេវចនៈរបស់គ្នានិងគ្នា ។ បទថា សហធម្មេន បានដល់ ពាក្យដែលមានហេតុមានការណ៍ ។ បទថា សប្បាដិហារិយំ សេចក្តីថា នឹងសម្តែងធម៌ ដរាបដល់ធម៌ដែលនាំសត្វចេញចាកទុក្ខ ។ បទថា ព្រហ្មចរិយំ បានដល់ សាសនព្រហ្មចរិយៈទាំងអស់ ដែលសង្គ្រោះដោយសិក្ខា ៣ ។ បទថា ឥទ្ធំ បានដល់ សម្រេចដោយអំណាចឈានជាដើម ។ បទថា ផីតំ បានដល់ ដល់សេចក្តីចម្រើនដែលដល់ព្រមដោយអភិញ្ញា ដូចផ្កាឈើដែលរីកពេញទីហើយជាដើម ។ បទថា វិត្ថារិកំ សេចក្តីថា បានដល់ផ្សាយទៅដោយប្រតិស្ឋានទៅក្នុងទិសាភាគនោះៗ ។ បទថា ពាហុជញ្ញំ បានដល់ ជនជាច្រើនដឹងច្បាស់ ចាក់ធ្លុះការត្រាស់ដឹងរបស់មហាជន ។ បទថា បុថុភូតំ បានដល់ ដល់សេចក្តីក្រាស់ណែនដោយអាការទាំងពួង ។ ក្រាស់ណែនយ៉ាងណា ។ ក្រាស់ណែនដរាបដល់ទេវតា និងមនុស្ស ប្រកាសដោយល្អហើយ អធិប្បាយថា ទេវតា និងមនុស្សដែលជាវិញ្ញូជន មានប្រមាណត្រឹមណា ទេវតា និងមនុស្សទាំងអស់នោះ ប្រកាសល្អហើយ ។

បទថា អប្បោស្សុក្កោ បានដល់ ប្រាសចាកសេចក្តីអាល័យ ។

ព្រះមានព្រះភាគត្រាស់ថា ម្នាលមារមានចិត្តបាប តាំងពីសប្តាហ៍ទី ៨ លោកត្រាច់ទៅមក អង្វរថា សូមព្រះមានព្រះភាគ សូមព្រះសុគតមេត្តាបរិនិព្វានឥឡូវនេះចុះព្រះអង្គ ។ ឥឡូវនេះ តាំងពីថ្ងៃនេះទៅ អ្នកចូរលើកឧស្សាហ៍ កុំព្យាយាមឲ្យតថាគតបរិនិព្វានឡើយ ។

## ទ្រង់ដាក់អាយុសង្ខារ

បទថា សតោ សម្បជានោ អាយុសង្ខារំ ឱស្សជ្ជិ សេចក្តីថា ព្រះមានព្រះភាគ ទ្រង់ធ្វើសតិតាំងមាំដោយល្អ កំណត់ដោយព្រះញាណដាក់អាយុសង្ខារ ។ ក្នុងទីនោះ ព្រះមានព្រះភាគ ទ្រង់មិនបានដាក់អាយុសង្ខារ ដូចយកដៃបោលដុំដី ។ ទ្រង់ព្រះចិន្តាថា ទ្រង់នឹងចូលសមាបត្តិមិនដាច់រយៈត្រឹមតែ ៣ ខែប៉ុណ្ណោះ តអំពីនោះនឹងមិនចូល ។ លោកសំដៅយកសេចក្តីនោះ ទើបពោលថា ឱស្សជ្ជិ បាឋៈថា ឧស្សជ្ជិ ដូច្នេះក៏មាន ។

បទថា មហាភូមិចាលោ បានដល់ មហាប្រថពីញាប់ញ័រ ។ បានឮថា គ្រានោះម៉ឺនលោកធាតុក៏ញាប់ញ័រ ។ បទថា ភឹសនកោ បានដល់កើតសេចក្តីគួរខ្លាច ។ បទថា ទេវទុន្ទុភិយោ ច ផលឹសុ បានដល់ ពួកស្គរទិព្វក៏បន្លឺសំឡេងលាន់ឮ ផ្គរក៏គ្រហឹមលាន់ឮខុសរដូវកាលហើយ ផ្លេកបន្ទោរ រន្ទះមិនមែនរដូវកាលក៏បញ្ចេញពន្លឺឆ្វេតឆ្វាត់ ។ លោកអធិប្បាយថា

ភ្លៀងធ្លាក់មួយស្របក់ ។

ក្នុងពាក្យថា ឧទានំ ឧទានេសិ សួរថា ទ្រង់ឧទានព្រោះហេតុអ្វី ។ ឆ្លើយថា ព្រោះបានឮថា ឈ្មោះថា អ្នកណាៗ នឹងគប្បីនិយាយថា ព្រះមានព្រះភាគ ត្រូវមារជាប់តាមទៅខាងក្រោយៗ អង្វរកកួនថា មេត្តាបរិនិព្វានចុះ ព្រះអង្គៗ ទ្រង់ដាក់អាយុសង្ខារមិនមែនព្រោះខ្លាច ទើបទ្រង់ថ្លែងព្រះឧទានដែលថ្លែងដោយកម្លាំងបីតិ ដើម្បីសម្តែងសេចក្តីនេះថា ឈ្មោះថា ពាក្យឧទាន រមែងមិនមានដល់អ្នកខ្លាចថា សូមមារកុំមានឱកាសឡើយ ។

[៩៦] ក្នុងឧទាននោះ ឈ្មោះថា តុល ព្រោះថ្លឹងកំណត់ដោយភាវៈដែលប្រចក្សរបស់សត្វមានឆ្កែស្រុក ឆ្កែព្រៃជាដើមទាំងអស់ ។ កម្មដែលថ្លឹងបាននោះ ដូចម្តេច ។ បានដល់ កម្មផ្នែកកាមាវចរ ។ ឈ្មោះថា **អតុលៈ** ព្រោះថ្លឹងមិនបាន ។ ឬលោកិយកម្មយ៉ាងដទៃ ដែលប្រៀបដូចនឹងកាមាវចកម្មនោះមិនមាន ។ កម្មដែលថ្លឹងមិនបាននោះយ៉ាងណា បានដល់ កម្មផ្នែកមហគ្គតៈ ។ មយ៉ាងទៀត កាមាវចរកម្ម រូបាវចរកម្ម ចាត់ជាតុលៈ អរូបាវចរកម្ម ចាត់ជាអតុលៈ ។ មយ៉ាងទៀត កម្មដែលមានវិបាកតិចឈ្មោះថា តុលៈ ដែលមានវិបាកច្រើន ឈ្មោះថា អតុលៈ ។ បទថា សម្ភវំ បានដល់ កម្មដែលធ្វើជាដុំ អធិប្បាយថា ធ្វើជាកងដែលជាហេតុកើត ។ បទថា ភវសង្ខារំ បានដល់ កម្មដែលតាក់តែងភពថ្មី ។ បទថា អវស្សជ្ជិ បានដល់ ធ្លាក់ចុះ ។ បទថា មុនិ បានដល់ អ្នកប្រាជ្ញ គឺ ព្រះពុទ្ធ ។

បទថា អជ្ឈត្តរតោ គឺ ត្រេកអរខាងក្នុងពិតប្រាកដ ។ បទថា សមាហិតោ គឺ តាំងមាំហើយ ដោយឧបចារសមាធិ និងអប្បនាសមាធិ ។ បទថា អភិន្ទិ កវចមិវ បានដល់ ទម្លាយកិលេស ដូចកោះ ។ បទថា អត្តសម្ភវំ បានដល់ កិលេសដែលកើតហើយក្នុងខ្លួន ។ លោកអធិប្បាយទុកថា ព្រះមុនីទ្រង់រួចផុតពីលោកិយកម្ម ពោលគឺ តុលកម្ម និងអតុលកម្ម ដែលបានឈ្មោះថា សម្ភវៈ ព្រោះអត្ថថា មានវិបាក ថាភវសង្ខារ ព្រោះអត្ថថា តាក់តែងភព និងទ្រង់ត្រេកអរខាងក្នុងតាំងមាំហើយ ទម្លាយកិលេស ដែលកើតក្នុងខ្លួន ដូចអ្នកចម្បាំងធំក្នុងសមរភូមិទម្លាយកោះ ដូច្នោះ ។

ន័យមួយទៀត បទថា តុលំ បានដល់ ថ្លឹង គឺ ពិចារណា ។ បទថា អតុលញ្ច សម្ភវំ បានដល់ ព្រះនិព្វាននិងភព ។ បទថា ភវសង្ខារំ បានដល់ កម្មដែលទៅកាន់ភព ។ បទថា អវស្សជ្ជិ មុនី សេចក្តីថា ព្រះមុនី គឺ ព្រះពុទ្ធទ្រង់ពិចារណាដោយន័យជាអាទិថា បញ្ចក្ខន្ធមិនទៀង ការរលត់បញ្ចក្ខន្ធ គឺ និព្វានជារបស់ទៀង ទ្រង់ឃើញទោសក្នុងភព និងអានិសង្សក្នុងនិព្វានហើយ ទ្រង់បណ្តោយតាមអរិយមគ្គ ដែលធ្វើនូវការអស់កម្ម ដែលលោកពោលទុកយ៉ាងនេះថា កម្មគ្រឿងកាត់តែងភព ដែលជាមូលនៃខន្ធទាំងឡាយនោះ ប្រព្រឹត្តទៅដើម្បីអស់កម្ម ដូច្នេះ ។ ព្រះអង្គទ្រង់ត្រេកអរខាងក្នុង តាំងមាំហើយ ទ្រង់ទម្លាយកិលេសដែលកើតក្នុងខ្លួន ដូចជាក្រោះ បានយ៉ាងណា ។ សេចក្តីពិត ព្រះមុនីនោះ ទ្រង់

ត្រេកអរខាងក្នុង ដោយអំណាចវិបស្សនា ទ្រង់តាំងមាំដោយអំណាចសមថៈ រួមសេចក្តីថា ព្រះអង្គទ្រង់ទម្លាយសំណាញ់ គឺ កិលេសទាំងអស់ ដែលជាគ្រឿងរួបរឹតអត្តភាពដូចក្រោះ ដែលបានឈ្មោះថា អត្តសម្ភវៈ ព្រោះកើតក្នុងខ្លួន ដោយកម្លាំងសមថៈ និងវិបស្សនា តាំងពីខាងដើម និងលះកម្ម ដោយការលះកិលេសយ៉ាងនេះថា កម្មដែលធ្វើដោយមិនមានកិលេសឈ្មោះថា នៅសល់ ព្រោះមិនមានបដិសន្ធិ ។ គប្បីជ្រាបថា ឈ្មោះថាសេចក្តីខ្លាចរបស់អ្នកលះកិលេសបានហើយមិនមាន ព្រោះដូច្នោះ ព្រះមុនីទ្រង់មិនខ្លាច ហើយទើបទ្រង់ដាក់អាយុសង្ខារ ព្រោះហេតុនោះ ទើបទ្រង់ថ្លែងឧទានដើម្បីឲ្យដឹងថា ទ្រង់មិនខ្លាច ។

## ពោលអំពី ការកក្រើកផែនដី

**[៩៨]** បទថា យំ មហាវាតា សេចក្តីថា ដោយសម័យណា ឬក្នុងសម័យណាខ្យល់ធំរមែងបក់ ។ បទថា មហាវាតា វាយន្តា បានដល់ធម្មតាថា **ខ្យល់ឧក្ខេបក** កាលកើតឡើង ក៏បក់នាំទឹកកម្រាស់ ៩៦០.០០០ យោជន៍ទៅ តពីនោះទឹកក៏តាំងនៅក្នុងអាកាស កាលទឹកធ្លាក់ចុះផែនដីក៏ធ្លាក់ចុះ ។ ខ្យល់ក៏ទ្រទឹកទុកទៀតដោយកម្លាំងរបស់ខ្លួន ដូចទឹកខាងក្នុងធម្មក្រក ។ តែទឹកនោះក៏បាញ់ឡើង ។ កាលទឹកប៉ោងឡើង ផែនដីក៏ប៉ោងឡើង ទឹកញ័រហើយ ក៏ធ្វើឲ្យផែនដីញ័រយ៉ាងនេះ ។ ការញ័ររបស់

ទឹក និងផែនដី រមែងមានមកជាបដល់សព្វថ្ងៃនេះ ដោយប្រការដូច្នេះ ។ តែការផតចុះ និងប៉ោងឡើង រមែងមិនប្រាកដ ព្រោះជារបស់ក្រាស់ ។

បទថា មហិទ្ធិកោ មហានុភាវោ សេចក្តីថា សមណៈ ឬព្រាហ្មណ៍ ឈ្មោះថា អ្នកមានឫទ្ធិច្រើន ព្រោះមានសេចក្តីសម្រេចច្រើន ឈ្មោះថា អ្នកមានអានុភាពច្រើន ព្រោះវត្ថុដែលនឹងបានទទួលច្រើន ។ បទថា បរិត្តា គឺ មានកម្លាំងតិច ។ បទថា អប្បមាណា បានដល់ អ្នកមានកម្លាំង ។ បទថា សោ ឥមំ បឋវិំ កម្បេតិ សេចក្តីថា លោកធ្វើឫទ្ធិឲ្យកើតហើយ កើតសេចក្តីសង្វេគ ដូចព្រះមហាមោគ្គល្លាន ឬកាលទ្រង់សាកល្បង រមែងធ្វើឲ្យផែនដីញ័រ ដូចសង្ឃរក្ខិតសាមណេរក្មួយព្រះមហានាគត្ថេរ ។

បានឮថា សមណេរនោះ ខណៈកោរសក់ប៉ុណ្ណោះ ក៏សម្រេចព្រះអរហត្ត គិតថា មានភិក្ខុណាៗ ទេហ្ន៎ ដែលធ្លាប់សម្រេចព្រះអរហត្តក្នុងថ្ងៃដែលបួសនុ៎ះឯង ហើយធ្វើវេជយន្តប្រាសាទឲ្យញ័រ ។ តពីនោះ ក៏ដឹងថា មិនមានអ្នកណា ទើបគិតថា យើងនឹងធ្វើឲ្យញ័រ រួចឈរលើកំពូលវេជយន្តប្រាសាទ ហើយប្រើជើងតន្ត្រំ ក៏មិនអាចធ្វើឲ្យញ័រដោយកម្លាំងនៃអភិញ្ញា ។ គ្រានោះ ពួកទេពកញ្ញារបស់ស្តេចសក្កៈ ក៏ពោលនឹងសាមណេរនោះថា កូនសង្ឃរក្ខិត កូនប្រាថ្នានឹងធ្វើវេជយន្តប្រាសាទឲ្យញ័រ ដោយសីសៈដែលមានក្លិនស្អុយប៉ុណ្ណោះ បាអើយ ប្រាសាទមានឱកាសតាំងនៅល្អហើយ កូនអាចធ្វើឲ្យញ័រយ៉ាងណាបាន ។ សាមណេររំលឹកថា

ទេវតាទាំងនេះ ចាំអកឡុកឡឺយដល់យើង តែយើងមិនទាន់បានអាចារ្យព្រះមហានាគត្ថេរអ្នកនៅប្រចាំសមុទ្រ អាចារ្យរបស់យើងនៅទីណាហ្ន៎ ដឹងថា អាចារ្យសាងទីពួនសម្ងំក្នុងទឹកទុកក្នុងមហាសមុទ្រ អង្គុយសម្រាកពេលថ្ងៃ ទើបទៅក្នុងទីនោះសំពះព្រះថេរៈហើយឈរ ។ តពីនោះ ព្រះថេរៈនិយាយចំពោះសាមណេរនោះថា បាសង្ឃរក្ខិត អ្នកឯងមិនទាន់បានសិក្សានឹងចូលទៅប្រយុទ្ធឬ ហើយសួរថា បាឯងមិនអាចធ្វើឲ្យវេជយន្តប្រាសាទញ័រឬ ។ ឆ្លើយថា ខ្ញុំព្រះករុណាមិនទាន់បានអាចារ្យនេះ លោកម្ចាស់ ។ លំដាប់នោះ ព្រះថេរៈទើបពោលនឹងសាមណេរនោះថា បាអើយ កាលបុគ្គលដូចបាឯងឲ្យញ័រមិនបាន អ្នកដទៃ គឺ អ្នកណាហ្ន៎ នឹងឲ្យញ័របាន បាឯងធ្លាប់ឃើញដុំអាចម៍គោអណ្តែតនៅលើផ្ទៃទឹកទេ ហើយពោលតទៅថា បាអើយ មនុស្សទាំងឡាយគេធ្វើនំអំបែង គេមិនចាប់ត្រង់កណ្តាល បាឯងចូរដឹង ដោយឧបមានេះ ។ សាមណេរពោលថា ព្រះករុណាលោកម្ចាស់ប្រាសាទនោះ នឹងវិលដោយអាការត្រឹមតែប៉ុណ្ណោះ ហើយអធិដ្ឋានថា សូមទឹកចូរមានរហូតដល់ឱកាសដែលប្រាសាទតាំងនៅ បែរមុខទៅកាន់វេជយន្តប្រាសាទ ។ ពួកទេពធីតាឃើញសាមណេរហើយ និយាយគ្នាថា សាមណេរអៀនខ្មាសម្តងហើយ នៅតែមកទៀត ។ ស្តេចសក្កទេវរាជត្រាស់ថា ពួកនាងកុំនិយាយនឹងបុត្ររបស់យើងឡើយ ឥឡូវនេះ លោកបានអាចារ្យហើយមួយរំពេចសោះ លោកនឹងធ្វើប្រាសាទឲ្យញ័របាន ។ សាមណេរ ប្រើម្រាម

ដើងជាន់កំពូលប្រាសាទ ។ ប្រាសាទក៏ឱនទ្រេតទៅទាំង ៤ ទិស ។ ពួកទេវតាស្រែកលាន់មាត់ថា បាអើយ មេត្តាឲ្យប្រាសាទតាំងនៅវិញចុះ ។ សាមណេរដាក់ប្រាសាទទុកក្នុងទីដើម ហើយឈរលើកំពូលប្រាសាទថ្លែងឧទានថា

យើងបួសថ្ងៃនេះ ក៏សម្រេចអាសវក្ខយៈថ្ងៃនេះ យើងធ្វើប្រាសាទឲ្យញ័រ ឱព្រះពុទ្ធ ទ្រង់មានព្រះគុណមហោឡារ ។

យើងបួសថ្ងៃនេះ ក៏សម្រេចអាសវក្ខយៈថ្ងៃនេះ យើងធ្វើប្រាសាទឲ្យញ័រថ្ងៃនេះ ឱព្រះធម៌មានព្រះគុណមហោឡារ ។

យើងបួសថ្ងៃនេះ ក៏សម្រេចអាសវក្ខយៈថ្ងៃនេះ យើងធ្វើប្រាសាទឲ្យញ័រថ្ងៃនេះ ឱព្រះសង្ឃមានព្រះគុណមហោ-ឡារ ។

ពាក្យដែលនឹងគប្បីពោលក្នុងរឿងផែនដីញ័រ ៦ ប្រការ ក្រៅអំពីនេះ លោកពោលទុកហើយក្នុងមហាបទានសូត្រ ។

ក្នុងហេតុផែនដីញ័រ ៨ ប្រការនេះ ដូចពោលមកនេះ ទី ១ ញ័រដោយធាតុកម្រើក , ទី ២ ញ័រដោយអានុភាពរបស់អ្នកមានឫទ្ធិ , ទី ៣ និងទី ៤ ញ័រដោយតេជនៃបុណ្យ , ទី ៥ ញ័រដោយអំណាចនៃញាណ , ទី ៦ ញ័រដោយអំណាចសាធុការ , ទី ៧ ញ័រដោយអំណាចភាពជាអ្នកមានករុណា , ទី ៨ ញ័រដោយការស្រែកយំ ។ កាលព្រះមហាសត្វចុះកាន់ព្រះគភ៌

ព្រះមាតា និងចេញអំពីព្រះគភ៌នោះ ផែនដីញ័រដោយអំណាចនៃបុណ្យរបស់ព្រះអង្គ ។ គ្រាត្រាស់ដឹងអភិសម្ពោធិញ្ញាណ ផែនដីញ័រដោយអំណាចព្រះញាណ ។ គ្រាប្រកាសព្រះធម្មចក្រ ផែនដីក៏ញ័ររញ្ជួយឡើងឲ្យសាធុការ ។ គ្រាដាក់អាយុសង្ខារ ផែនដីញ័ររញ្ជួយឡើងដោយសេចក្តីករុណា ទ្រាំការកម្រើកញ័រនៃចិត្តមិនបាន ក៏ញាប់ញ័រ ។ គ្រាបរិនិព្វានផែនដីក៏ត្រូវបន្ថែមដោយកម្លាំងការស្រែកយំ ក៏ញ័រ ។ ក៏សេចក្តីនេះ គប្បីជ្រាបដោយអំណាចទេវតាប្រចាំផែនដី ។ តែប្រការនេះ មិនមានដល់បឋវីធាតុ ដែលជាមហាភូតរូប ព្រោះមិនមានចេតនានោះឯង ។

បទថា ឥមេ ក្នុងពាក្យថា ឥមេ ខោ អានន្ទ អដ្ឋ ហេតូ នេះ ជាការបង្ហាញសេចក្តីដែលទ្រង់សម្តែងមកហើយ ។ ក៏ដោយហេតុត្រឹមតែប៉ុណ្ណេះ ព្រះអានន្ទកំណត់ថា ព្រះមានព្រះភាគ ទ្រង់ដាក់អាយុសង្ខារថ្ងៃនេះពិតប្រាកដ ។

## ពោលអំពី បរិសទ្យ ៨ ពួក

[៩៩] ចំណែកព្រះមានព្រះភាគ សូម្បីទ្រង់ជ្រាបថា ព្រះអានន្ទកំណត់បាន ក៏មិនប្រទានឱកាស ទ្រង់ប្រមូលហេតុទាំង ៨ សូម្បីយ៉ាងដទៃចូលទុកផង ទើបត្រាស់ថា អដ្ឋ ខោ ឥមា ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា អនេកសតំ ខត្តិយបរិសំ បានដល់

បរិស័ទ ដូចសមាគមព្រះបាទពិម្ពិសារ សមាគមព្រះញាតិ និងសមាគម ស្តេចលិច្ឆវីជាអាទិ ។ ពាក្យនេះ ប្រើបានសូម្បីក្នុងចក្រវាឡដទៃៗ ។ បទថា សល្លបិតបុព្វំ បានដល់ ធ្លាប់ធ្វើការសន្ទនាប្រាស្រ័យ ។ ពាក្យថា សាកច្ឆា បានដល់ ធ្លាប់ចូលរួមសូម្បីតែការសន្ទនាធម៌ ។ បទថា យាទិសកោ តេសំ វណ្ណោ សេចក្តីថា សមណព្រាហ្មណ៍ទាំងនោះ សម្បុរសខ្លះ សម្បុរខ្មៅខ្លះ សម្បុរពីរពណ៌ខ្លះ ព្រះសាស្តាមានព្រះឆវីលឿងដូចមាស ។ ក៏ពាក្យនេះ លោកពោលអាស្រ័យទ្រង់ទ្រាយ ។ ក៏សូម្បីទ្រង់ទ្រាយរបស់សមណព្រាហ្មណ៍ទាំងនោះ ប្រាកដត្រឹមតែម្យ៉ាងប៉ុណ្ណោះ ។ ចំណែកព្រះមានព្រះភាគមិនមែនដូចជនជាតិមិលក្ខៈ ទាំងទ្រង់មិនពាក់មណីកុណ្ឌល ប្រថាប់ដោយភេទរបស់ព្រះពុទ្ធប៉ុណ្ណោះ ។ ក៏សមណព្រាហ្មណ៍ទាំងនោះ រមែងឃើញថា ព្រះពុទ្ធអង្គមានទ្រង់ទ្រាយស្មើនឹងខ្លួន ។ បទថា យាទិសកោ តេសំ វណ្ណោ សេចក្តីថា សមណព្រាហ្មណ៍ទាំងនោះ មានសំឡេងដាច់ខ្លះ មានសំឡេងដូចឈើអន្លង់ខ្លះ មានសំឡេងដូចក្អែកខ្លះ ព្រះសាស្តាមានព្រះសូរសៀងដូចព្រហ្មប៉ុណ្ណោះ ។ តែពាក្យនេះ លោកពោលសំដៅដល់ភាសាដទៃ ។ សេចក្តីពិត សូម្បីបើថា ក្នុងបរិស័ទនោះ ព្រះសាស្តាប្រថាប់ត្រាស់លើរាជាសនៈ សមណព្រាហ្មណ៍ទាំងនោះ ក៏នឹងយល់ថា ថ្ងៃនេះព្រះរាជតម្រាស់ដោយព្រះសូរសៀងដ៏ពីរោះ ។ តែកាលព្រះមានព្រះភាគត្រាស់ហើយ ស្តេចចៀសទៅ សមណព្រាហ្មណ៍ទាំងនោះ

ឃើញព្រះរាជាស្តេចត្រឡប់មកទៀត ក៏កើតការពិចារណាត្រឡប់ថា បុគ្គលនេះជាអ្នកណាហ្ន៎ ។ បណ្តាបទទាំងនោះ បទថា កោ នុ ខោ អយំ សេចក្តីថា សមណព្រាហ្មណ៍ទាំងនោះ សូម្បីពិចារណាត្រឡប់យ៉ាងនេះ ក៏មិនដឹងថា បុគ្គលនេះជាអ្នកណា ត្រាស់ដោយភាសាមគធៈ ភាសាសីហឡៈ ដោយអាការល្វត់ល្វន់ ក្នុងទីនេះ ឥឡូវនេះ ក៏បាត់ទៅមួយរំពេច ជាទេវតា ឬអមនុស្ស ។ សួរថា ព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ដល់ពួកជនអ្នកមិនដឹងយ៉ាងនេះ ដើម្បីប្រយោជន៍អ្វី ។ ឆ្លើយថា ដើម្បីត្រូវការអប់រំពិតហើយ កាលបើដូច្នេះ ធម៌សូម្បីគេស្តាប់ហើយ ក៏នឹងជាបច្ច័យក្នុងអនាគតតែម្យ៉ាង ព្រោះហេតុនោះ ទ្រង់ប្រាថ្នាដល់អនាគត ទើបទ្រង់សម្តែង ។ គប្បីជ្រាបហេតុកើតនៃបរិស័ទទាំងឡាយ មានព្រាហ្មណ៍បរិស័ទច្រើនរយជាដើម ដោយអំណាចសោណទណ្ឌសមាគម និងកូដទន្តសមាគមជាដើម និងដោយអំណាចចក្រវាឡដទៃ ។

ក៏ព្រះមានព្រះភាគទ្រង់នាំបរិស័ទ ៨ នេះ មកដើម្បីអ្វី ? ដើម្បីសម្តែងភាពជាអ្នកមិនខ្លាច ។ បានឮថា ព្រះអង្គនាំបរិស័ទទាំងនេះមកត្រាស់យ៉ាងនេះថា អានន្ទ សេចក្តីខ្លាច ឬសេចក្តីកត់ស្លុត មិនមានដល់តថាគតអ្នកចូលទៅរកបរិស័ទទាំង ៨ នេះ ហើយសម្តែងធម៌ តែអ្នកណាហ្ន៎ គួរនឹងឲ្យកើតសេចក្តីយល់យ៉ាងនេះថា តថាគតឃើញមារតែម្នាក់ហើយគប្បីខ្លាច អានន្ទ តថាគតមិនខ្លាច មិនកត់ស្លុត មានសតិសម្បជញ្ញៈ ដាក់

អាយុសង្ខារ ដូច្នេះ ។

## ពោលអំពី អភិភាយតនៈ ៨

[១០០-១០១] បទថា អភិភាយតនានិ បានដល់ ហេតុគ្របសង្កត់ ។ គ្របសង្កត់អ្វី គ្របសង្កត់ធម៌ដែលជាសត្រូវខ្លះ អារម្មណ៍ខ្លះ ។ ការពិត ហេតុទាំងនោះ រមែងគ្របសង្កត់ធម៌ដែលជាសត្រូវ ព្រោះការៈដែលជាបដិបក្ខគ្រប់គ្រងអារម្មណ៍ ព្រោះជាបុគ្គលដ៏ក្រៃលែងដោយញាណ ។

ក៏ក្នុងពាក្យថា អជ្ឈត្តំ រូបសញ្ញី ដូច្នេះជាដើម បុគ្គលឈ្មោះថា មានសញ្ញាក្នុងរូបខាងក្នុង ដោយអំណាចបរិកម្មក្នុងរូបខាងក្នុង ។ ពិតណាស់ បុគ្គលកាលធ្វើបរិកម្មនីលកសិណក្នុងរូបខាងក្នុង រមែងធ្វើត្រង់សក់ ឬត្រង់ប្រមាត់ ឬត្រង់កែវភ្នែក កាលធ្វើបរិកម្មក្នុងបីតកសិណ រមែងធ្វើត្រង់ខ្លាញ់ខាប់លើសម្បុរស្បែក លើខ្នងដៃ លើជើង ឬត្រង់ឋានពណ៌លឿងរបស់កែវភ្នែក ។ កាលធ្វើបរិកម្មក្នុងលោហិតកសិណ ធ្វើសាច់ ឈាម អណ្តាត ឬត្រង់ឋានដែលមានពណ៌ក្រហមរបស់កែវភ្នែក ។ កាលធ្វើបរិកម្មក្នុងឱទាតកសិណ រមែងធ្វើត្រង់ឆ្អឹង ធ្មេញ ក្រចក ឬត្រង់ឋានដែលមានពណ៌សរបស់កែវភ្នែក តែបរិកម្មនោះ ដែលមានពណ៌ខៀវល្អ លឿងល្អ ក្រហមល្អ សល្អ ក៏ទេ រមែងមិនបរិសុទ្ធិមែនពិត ។

បទថា ឯកោ ពហិទ្ធា រូបានិ បស្សតិ សេចក្តីថា បរិកម្មនោះ

របស់បុគ្គលណា កើតឡើងខាងក្នុង តែនិមិត្តកើតខាងក្រៅ ។ បុគ្គលនោះ មានសេចក្តីសម្គាល់ថា រូបខាងក្នុង ដោយអំណាចបរិកម្មខាងក្នុង និង អប្បនាក្នុងខាងក្រៅយ៉ាងនេះ ហៅថា ឯកោ ពហិទ្ធា រូបានិ បស្សតិ បុគ្គលពួកមួយ ឃើញរូបខាងក្រៅ ។

បទថា បរិត្តានិ បានដល់ មិនចម្រើន ។ បទថា សុវណ្ណទុព្វណ្ណានិ ប្រែថា មានវណ្ណៈល្អ ឬវណ្ណៈអាក្រក់ ។ អភិភាយតនៈនេះ គប្បីជ្រាបថា លោកពោលទុកដោយអំណាចបរិត្តារម្មណ៍ ។ បទថា តានិ អភិភុយ្យ សេចក្តីថា អ្នកមានពោះធូរ បានបាយត្រឹមតែមួយវែក ទើបមកគិតថា នឹង លុមស៊ី ឬធ្វើនូវដុំពំនូតមួយ យ៉ាងណា បុគ្គលដែលក្រៃលែងដោយញាណ មានញាណខ្វាំងក្លា គិតថា នឹងគប្បីចូលសមាបត្តិក្នុងអារម្មណ៍បន្តិចបន្តួច ប៉ុណ្ណេះ នឹងលុមឬ ។ នេះមិនធួន់សម្រាប់យើង ហើយគ្របសង្កត់រូប ទាំងនោះ ចូលសមាបត្តិ ។ អធិប្បាយថា រមែងឲ្យដល់អប្បនាក្នុងអភិ-កាយតនៈនោះ ព្រមនឹងធ្វើនិមិត្តឲ្យកើតឡើងតែម្តង ។ ក៏ដោយបទថា ជានាមិ បស្សាមិ នេះ លោកពោលដល់ការរលឹកនៃបុគ្គលនោះ ។ ក៏ កាលចេញចាកសមាបត្តិ ការរលឹកនោះ ក៏មិនមានខាងក្នុងសមាបត្តិ ។ បទថា ឯវំសញ្ញី ហោតិ សេចក្តីថា មានសញ្ញាយ៉ាងនេះ ដោយសញ្ញាក្នុង ការលើកខ្លះ ដោយសញ្ញាក្នុងឈានខ្លះ ។ ពិតហើយ សញ្ញា ជាគ្រឿងគ្រប សង្កត់ រមែងមានដល់បុគ្គលនោះ សូម្បីខាងក្នុងសមាបត្តិ ។ ចំណែកសញ្ញា

ក្នុងការទឹក រមែងមាន កាលចេញចាកសមាបត្តិប៉ុណ្ណោះ ។

បទថា អប្បមាណានិ សេចក្ដីថា មានប្រមាណដែលចម្រើនហើយ គឺ ធំ ។ ចំណែកក្នុងបទថា អភិភុយ្យ នេះ ប្រៀបដូចបុរសអាចស៊ីបាយបានមួយចានពេញ ក៏នៅតែគិតថា របស់យ៉ាងដទៃចូរលើកទុក បាយនេះនឹងល្មមដល់យើងឬទេ មិនឃើញបាយនោះថា ច្រើនយ៉ាងណា បុគ្គលដែលក្រៃលែងដោយញាណ មានញាណចាស់ក្លាក៏ដូច្នោះដែរ គិតថា នឹងចូលឈានក្នុងអារម្មណ៍នេះបានឬ អារម្មណ៍នេះមិនមានប្រមាណក៏ទេ ទើបគ្របសង្កត់អារម្មណ៍ទាំងនោះ ចូលឈានដោយគិតថា ក្នុងការធ្វើឯកគ្គតា-ចិត្ត មិនលំបាកដល់យើងឡើយ ។ អធិប្បាយថា ឲ្យដល់អប្បនាក្នុងអារម្មណ៍នោះ ព្រមនឹងចិត្តុប្បាទ នុ៎ះឯង ។

បទថា អជ្ឈត្តំ រូបសញ្ញី សេចក្ដីថា វៀរចាកបរិកម្មសញ្ញាក្នុងរូបខាងក្នុង ព្រោះមិនទាន់បានឬព្រោះមិនត្រូវការ ។ បទថា ឯកោ ពហិទ្ធា រូបានិ បស្សតិ សេចក្ដីថា ទាំងបរិកម្ម ទាំងនិមិត្តរបស់អ្នកណា កើតឡើងក្នុងខាងក្នុងតែម្យ៉ាង អ្នកនោះមានសេចក្ដីសម្គាល់ថា អរូបខាងក្នុង ដោយអំណាចបរិកម្ម និងអប្បនាខាងក្រៅយ៉ាងនេះ ហៅថា ឯកោ ពហិទ្ធា រូបានិ បស្សតិ បុគ្គលពួកមួយ ឃើញរូបក្នុងខាងក្រៅ ។ សេចក្ដីដ៏សេសក្នុងពាក្យនោះ មានន័យដូចពោលហើយក្នុងអភិភាយតនៈទី ៤ នោះឯង ។

ក៏ក្នុងអភិភាយតនៈទាំង ៤ នេះ បរិត្តអភិភាយតនៈ មកដោយ

អំណាចវិតក្កចរិត , អប្បមាណអភិភាយតនៈ មកដោយអំណាចមោហចរិត សុវណ្ណអភិភាយតនៈ មកដោយអំណាចទោសចរិត , ទុព្វណ្ណអភិភាយតនៈ មកដោយអំណាចរាគចរិត ។ ពិតហើយ អភិភាយតនៈទាំងនេះ ជាសប្បាយ របស់អ្នកមានចរិតទាំងនេះ ។ សូម្បីអភិភាយតនៈជាសប្បាយនោះ ពោល ទុកពិស្តារហើយ ក្នុងចរិតនិទ្ទេស ក្នុងវិសុទ្ធិមគ្គ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងអភិភាយតនៈទី ៥ ជាដើម ដូចតទៅនេះ ៖

បទថា នីលានិ លោកពោលទុកដោយរួមទាំងអស់ ។ បទថា នីលវណ្ណានិ លោកពោលដោយវណ្ណៈ ។ បទថា នីលនិទស្សនានិ លោក ពោលដោយតួយ៉ាង (បង្ហាញឲ្យមើល) លោកអធិប្បាយថា វណ្ណៈ ដែល មិនលាយគ្នា ដែលមិនប្រាកដចន្លោះប្រហោង ប្រាកដជា មានពណ៌ខៀវ ដូចគ្នា ។ ចំណែកពាក្យថា នីលនិភាសានិ នេះ លោកពោលទុកដោយ អំណាចឱភាស ។ អធិប្បាយថា មានពន្លឺពណ៌ខៀវ គឺ ប្រកបដោយរស្មី ខៀវ ។ ដោយបទនេះ លោកសម្ដែងដល់វណ្ណៈទាំងនោះ បរិសុទ្ធ ។ ពិត ហើយ លោកពោលថា អភិភាយតនៈទាំង ៤ នេះ ទុកដោយវណ្ណៈបរិសុទ្ធ ប៉ុណ្ណោះ ។ បទថា ឧម្មាបុប្ផំ សេចក្ដីថា ពិតហើយ ផ្កាឈើនេះ ជិតស្និទ្ធ ទន់ល្មៃ សូម្បីដែលឃើញទាំងអស់គ្នាហើយ ក៏ជាពណ៌ខៀវនោះ ចំណែក ផ្កាកណ្ណិកាជាដើម ដែលឃើញទាំងអស់គ្នាហើយ ក៏ស ព្រោះដូច្នោះ លោកទើបកាន់យកផ្កាត្រកៀតនេះប៉ុណ្ណោះ ផ្កាកណ្ណិកា លោកមិនកាន់យក

ទេ ។ បទថា ពារាណសេយ្យកំ ប្រែថា ដែលកើតក្នុងក្រុងពារាណសី បានឮថា ក្នុងក្រុងពារាណសីនោះ ទាំងកប្បាសក៏ទន់ ទាំងអ្នកខាអំបោះ ទាំងជាងតម្បាញក៏ឆ្លាត ។ សូម្បីទឹកក៏ស្អាតស្និទ្ធ ព្រោះដូច្នោះ សំពត់នោះ ទើបរលោងទាំងពីរខាង គឺ ក្នុងខាងទាំងពីរក៏រលោង ប្រាកដជាទន់ស្និទ្ធ ។ សូម្បីក្នុងពាក្យថា បិតានិ ជាដើម ក៏គប្បីជ្រាបសេចក្តីដោយន័យនេះឯង ។ កាលនឹងកំណត់នីលកសិណ រមែងកំណត់និមិត្តក្នុងពណ៌ខៀវ ។ ក៏ការធ្វើកសិណក្តី ការបរិកម្មក្តី អប្បនាវិធីក្តី ក្នុងទីនេះមានជាអាទិថា បុប្ផស្មឹ វា វត្ថស្មឹ វា វណ្ណធាតុយា វា ទាំងអស់មានន័យដូចពោលទុកដោយពិស្តារហើយ ក្នុងវិសុទ្ធិមគ្គ ។

អភិភាយតនៈទាំង ៨ នេះ លោកនាំមក ក៏ដើម្បីសម្តែងដល់ភាពជាអ្នកមិនខ្វាច ។ បានឮថា ព្រះមានព្រះភាគ ត្រាស់អភិភាយតនៈសូម្បីទាំងនេះហើយ ទើបត្រាស់យ៉ាងនេះថា អានន្ទ សេចក្តីខ្វាច ឬសេចក្តីតក់ស្លុត មិនមានដល់តថាគតដែលកំពុងចូលសមាបត្តិ សូម្បីទាំងនេះ និងកំពុងចេញ អ្នកណាហ្ន៎គួរនឹងកើតការយល់យ៉ាងនេះថា តថាគតឃើញមារតែម្នាក់ គប្បីខ្វាច អានន្ទ តថាគតមិនខ្វាច មិនតក់ស្លុត មានសតិ-សម្បជញ្ញៈ ដាក់អាយុសង្ខារ ។

## ពោលអំពី វិមោក្ខ ៨ រឿងក្រុងមារ

កថាពោលអំពីរឿងវិមោក្ខ មានសេចក្តីងាយទាំងនោះ ។ វិមោក្ខ ៨ ទាំងនេះ លោកនាំមក ដើម្បីភាពជាអ្នកមិនខ្វាចដូចគ្នា ។ បានឮថា ព្រះមានព្រះភាគ គ្រាត្រាស់វិមោក្ខទាំងនេះហើយ ទើបត្រាស់យ៉ាងនេះថា ម្នាលអានន្ទ សេចក្តីខ្លាច ឬសេចក្តីតក់ស្លុត មិនមានដល់តថាគតដែលកំពុងចូលសមាបត្តិសូម្បីទាំងនេះ និងកំពុងចេញ ។ល។ ដាក់អាយុសង្ខារ ។

[១០២] សូម្បីឥឡូវនេះ ព្រះមានព្រះភាគក៏មិនប្រទានឱកាសដល់ព្រះអានន្ទត្ថេរឡើយ ទ្រង់ផ្តើមទេសនាសូម្បីយ៉ាងដទៃទៀត ដោយន័យមានជាអាទិថា ឯកមិទាហំ ជាដើម ។ បណ្តាបទទាំងនោះ បទថា បឋមាភិសម្ពុទ្ធោ បានដល់ ជាអ្នកត្រាស់ដឹងគ្រាដំបូងតែម្យ៉ាង គឺ ក្នុងសប្តាហ៍ទី ៨ ។ បទថា ឱស្សដ្ឋោ សេចក្តីថា លះបង់ ។ បានឮថា គ្រាពោលយ៉ាងនេះ ទើបពោលថា ព្រោះហេតុនោះ មុនលោកធាតុទើបកម្រើកញាប់ញ័រ ។

ពាក្យថា អលំ នេះ ជាពាក្យបដិសេធ ។ បទថា ពោធិ បានដល់ ចាក់ធ្លុះដោយមគ្គញាណ ៤ ។ ដោយបទថា សទ្ទហសិ ត្វំ លោកពោលថា អ្នកឈ្មោះថា តថាគត ពោលយ៉ាងនេះទេ ។ ដោយបទថា តស្មាតិហានន្ទ ព្រះមានព្រះភាគទ្រង់សម្តែងថា ព្រោះហេតុដែលអ្នកជឿពាក្យនេះ ដូច្នោះ ប្រការនេះ ទើបជាការធ្វើមិនល្អរបស់អ្នក ។

**[១០៣-១០៥]** ព្រះមានព្រះភាគផ្ដើមពាក្យថា ឯកមិទាហំ ជាដើម ដើម្បីនឹងលើកទោសរបស់ព្រះថេរៈតែម្នាក់ ដោយប្រការផ្សេងៗ ដើម្បីនឹងបន្ទោបង់សេចក្ដីសោកយ៉ាងនេះថា តថាគត មិនបានហៅអ្នកមកក្នុងទីនេះតែម្យ៉ាងប៉ុណ្ណោះទេ ។ សូម្បីក្នុងវេលាដទៃៗ តថាគត ក៏ហៅមកធ្វើនិមិត្តយ៉ាងគ្រោតគ្រាត អ្នកក៏មិនបានជ្រាបដឹងនិមិត្តសូម្បីនោះ នេះគឺជាសេចក្ដីខ្លាំងក្លាត់របស់អ្នកតែម្យ៉ាង ។

**[១០៦-១០៨]** បទថា បិយេហិ មនាបេហិ ភាពផ្សេងគ្នាដោយជាតិ ការលះបង់ ព្រោះមរណៈ ភាពជាយ៉ាងដទៃព្រោះភព (ប្រាសចាក) អំពីមាតា បិតា បងប្រុស បងស្រីជាដើម ។ ពាក្យថា តំ ក្នុងពាក្យថា តំ កុតេត្ថ លព្ភា ប្រែថា ព្រោះហេតុនោះ ។ អធិប្បាយថា ព្រោះនឹងត្រូវប្រាសចាកសត្វ និងសង្ខារ ដែលជាទីស្រឡាញ់ ដែលពេញចិត្តទាំងអស់ ដូច្នោះ តថាគតបំពេញបារមី ១០ ក្ដី សម្រេចសម្ពោធិញ្ញាណក្ដី ប្រកាសធម្មចក្រក្ដី សម្ដែងយមកប្បាដិហារ្យក្ដី ចុះអំពីទេវលោកក្ដី សរីរៈណាដែលកើតហើយ មានហើយ ត្រូវតាក់តែងហើយ មានការវិនាសទៅជាធម្មតារបស់សរីរៈ សូម្បីនៃព្រះតថាគតនោះកុំវិនាសទៅឡើយ ។ នុ៎ះ មិនមែនជាឋានៈដែលនឹងមានបាន ទាំងអ្នកស្រែកយំ ទាំងអ្នកគ្លួញត្អូរ ក៏អាចនឹងបានឋានៈយ៉ាងនោះ ។ បទថា បុន បច្ចាគមិស្សតិ សេចក្ដីថា វត្ថុដែលតថាគតលះបង់ហើយ បន្ទោបង់ហើយ វត្ថុនោះ ក៏នឹងត្រឡប់ប្រាកដ

ទៀតមិនបានទេ ។

បទថា យថយិទំ ព្រហ្មចរិយំ សេចក្តីថា គឺ សាសនព្រហ្មចរិយៈ ដែលសង្គ្រោះដោយសិក្ខា ៣ ។ បទថា អទ្ធនិយំ គឺ តាំងនៅយូរ ។ បទថា ចិរដ្ឋិតិកំ បានដល់ តម្កល់នៅយូរដោយអំណាចកើតយូរ ។ បទថា ចត្តារោ សតិបដ្ឋានា ជាដើម ទាំងអស់ លោកពោលទាំងជាលោកិយៈ និងលោកុត្តរៈ ។ ចំណែកការវិនិច្ឆ័យក្នុងពោធិបក្ខិយធម៌ទាំងនេះ លោកពោលទុកក្នុងបដិបទាញាណទស្សនវិសុទ្ធិនិទ្ទេស ក្នុងវិសុទ្ធិមគ្គដោយប្រការទាំងពួង ។ ពាក្យដ៏សេសក្នុងទីនេះ ងាយទាំងអស់នោះឯង ។

ចប់ កថាពណ៌នាតតិយភាណវារ

## ទ្រង់ទតក្រុងវេសាលីជាបច្ឆិមទស្សនៈ

[១០៩] *បទថា នាគាវលោកិតំ សេចក្ដីថា ដូចជាឆ្អឹងរបស់មហាជន យកចុងទល់ចុង តាំងនៅដូចអដ្ឋិរបស់ព្រះបច្ចេកពុទ្ធ ដែលជាប់គ្នាដូចកដំរី យ៉ាងណា អដ្ឋិរបស់ព្រះពុទ្ធមិនដូច្នោះទេ ។ សេចក្ដីថា អដ្ឋិរបស់ព្រះពុទ្ធជាប់គ្នាតែមួយដូចជាដុំមាស ព្រោះដូច្នោះ ក្នុងវេលាក្រឡេកមកក្រោយ ទើបមិនអាចងាកព្រះសុរងបាន ។ ស្ដេចដំរី ប្រាថ្នានឹងក្រឡេកមើលខាងក្រោយត្រូវងាកទៅទាំងខ្លួនយ៉ាងណា ព្រះមានព្រះភាគ ក៏ទ្រង់ងាកព្រះវរកាយទៅដូច្នោះ ។ តែពេលព្រះមានព្រះភាគ ប្រថាប់ឈរត្រង់ទ្វារព្រះនគរ ក៏ទ្រង់ព្រះចិន្ដាថា នឹងទស្សនាក្រុងវេសាលី ផែនមហាប្រថពីនេះដូចនឹងក្រាបទូលថា បពិត្រព្រះមានព្រះភាគ ព្រះអង្គទ្រង់បំពេញបារមីមកច្រើនសែនកោដិកប្ប ទ្រង់មិនបានធ្វើ គឺ ងាកព្រះសុរងក្រឡេកមើល ទើបប្រៀបដូចកង់ជី ធ្វើព្រះមានព្រះភាគ ឲ្យបែរព្រះភ័ក្ត្រឆ្ពោះទៅកាន់ក្រុងវេ-សាលី ។ លោកសំដៅយកសេចក្ដីនោះ ទើបពោលថា នាគាវលោកិតំនេះ ។*

*សួរថា ការទតទស្សនាក្រុងវេសាលី មិនមែនជាបច្ឆិមទស្សនៈតែម្យ៉ាងទេ ការទតទស្សនាសូម្បីក្នុងក្រុងសាវត្ថី ក្រុងរាជគ្រឹះ ក្រុងនាលន្ទា ស្រុកបាដលិគ្រាម កោដិគ្រាម និងនាទិកគ្រាម វេលាស្ដេចចេញចាកទីនោះៗ ទាំងអស់នោះ ក៏ជាបច្ឆិមទស្សនៈទាំងអស់មិនមែនឬ ហេតុអ្វីក្នុង*

ទីនោះ ៗ ទើបមិនជាការទតទស្សនាជានាគាវលោក (គឺជាបច្ឆិមទស្សនៈ) ។ ឆ្លើយថា ព្រោះមិនជាអស្ចារ្យ ។ ពិតហើយ ព្រះមានព្រះភាគ ត្រឡប់មកបែរមើលក្នុងទីនោះ សេចក្ដីនោះមិនគួរអស្ចារ្យ ព្រោះដូច្នោះ ទើបមិនឈ្មោះថា ទ្រង់ងាកព្រះវរកាយក្រឡេកមើល ។ មួយទៀត ពួកស្ដេចលិច្ឆវី ក្រុងវេសាលីជិតវិនាស នឹងវិនាសទៅក្នុង ៣ ឆ្នាំខាងមុខ ព្រោះដូច្នោះ ស្ដេចលិច្ឆវីទាំងនោះ ទើបសាងចេតិយឈ្មោះថា **នាគាបលោកិតចេតិយ** ជិតទ្វារព្រះនគរ នឹងបូជាចេតិយនោះដោយសក្ការៈ មានគ្រឿងក្រអូប និងផ្កាឈើជាដើម សេចក្ដីនោះក៏នឹងមានប្រយោជន៍ ដើម្បីសេចក្ដីសុខរហូតអស់កាលយូរ ព្រោះដូច្នោះ ទើបងាកព្រះវរកាយក្រឡេកមើល ដើម្បីអនុគ្រោះស្ដេចលិច្ឆវីទាំងនោះ ។

**[១១០-១១១]** បទថា ទុក្ខស្សន្តករោ បានដល់ ធ្វើទីបំផុតនៃវដ្ដទុក្ខ ។ បទថា ចក្ខុមា បានដល់ ទ្រង់មានចក្ខុ ដោយចក្ខុ ៥ ។ បទថា បរិនិព្វុតោ បានដល់ បរិនិព្វាន ដោយកិលេសបរិនិព្វាន ។

## ពោលអំពី មហាបទេសទាំង ៤

**[១១២]** បទថា មហាបទេសេ បានដល់ ក្នុងឱកាសធំ ឬក្នុងការអាងធំ ។ អធិប្បាយថា ហេតុធំដែលលោកពោលអាងអ្នកធំ ដូចព្រះពុទ្ធជាដើម ។

[១១៣-១១៦] បទថា អនភិនន្ទិតព្វំ គឺ ដែលអ្នកវែកញែកត្រេកអរឲ្យសាធុការ គួរស្តាប់មុនក៏ទេ ។ ពិតមែន កាលធ្វើយ៉ាងនេះ សូម្បីខាងក្រោយត្រូវឆ្លើយថា ប្រការនេះមិនសមរម្យ ក៏ឆ្លើយឆ្លងបានថា កាលមុនប្រការនេះជាធម៌ ឥឡូវនេះមិនជាធម៌ឬ ឈ្មោះថា មិនលះបង់លទ្ធិ ។ បទថា ន បដិក្កោសិតព្វំ សេចក្តីថា មិនគប្បីពោលមុនយ៉ាងនេះថា ជនពាលនេះ និយាយអ្វី ។ ក៏កាលត្រូវឆ្លើយថា នឹងមិននិយាយសូម្បីតែពាក្យដែលគួរនឹងនិយាយ ។ ដោយហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា អនភិនន្ទិត្វា អប្បដិក្កោសិត្វា ។ បទថា បទព្យញ្ជនានិ បានដល់ ព្យញ្ជនៈ ពោលគឺ បទ ។ បទថា សាធុកំ ឧគ្គហេត្វា បានដល់ កាន់យកដោយល្អថា លោកពោលបាលីទុកក្នុងទីនេះ ពោលសេចក្តីទុកក្នុងទីនេះ ពោលខាងដើម និងខាងចុង ទុកក្នុងទីនេះ ។ បទថា សុត្តេ ឱតារេតព្វានិ បានដល់ គប្បីសាកសួរក្នុងព្រះសូត្រ ។ បទថា វិនយេ សន្ទស្សេតព្វានិ បានដល់ ប្រៀបធៀបក្នុងព្រះវិន័យ ។

ក៏ក្នុងទីនេះ ដែលឈ្មោះថា **សូត្រ** បានដល់ វិន័យ ។ ដូចដែលលោកពោលទុកថា ហាមទុកក្នុងទីណា ហាមទុកក្នុងក្រុងសាវត្ថី ហាមទុកក្នុងសុត្តវិភង្គ (សុត្តៈក្នុងទីនេះសំដៅដល់វិន័យ) ដែលឈ្មោះវិន័យ បានដល់ ខន្ធកៈ ដូចដែលលោកពោលទុកថា កោសម្ពិយំ វិនយាតិសារេ ក្នុងរឿងល្មើសព្រះវិន័យ ( វិន័យក្នុងទីនេះសំដៅដល់ខន្ធកៈ ) ក្នុងក្រុងកោសម្ពី ។

កាលបើដូច្នេះ ឈ្មោះថា មិនកាន់យកវិន័យបិដក ។ ឈ្មោះថា កាន់យកព្រះវិន័យយ៉ាងនេះ គឺ ឧភតោវិភង្គ ឈ្មោះថា **សុត** , ខន្ធកបរិវារ ឈ្មោះថា **វិន័យ** ។ ន័យមួយទៀត កាន់យកបិដកទាំង ២ យ៉ាងនេះ គឺ សុត្តន្តបិដក ឈ្មោះថា ព្រះសូត្រ វិន័យបិដក ឈ្មោះថា វិន័យ ។ មយ៉ាងទៀត មុនដំបូង មិនកាន់យកបិដកទាំង ៣ សូម្បីយ៉ាងនេះ សុត្តន្តបិដក អភិធម្មបិដក ឈ្មោះថា សូត្រ វិន័យបិដក ឈ្មោះថា វិន័យ ធម្មតាពុទ្ធវចនៈ នរណាៗ ដែលឈ្មោះថា មិនមែនសូត្រក៏មាន គឺ ជាតក បដិសម្ភិទា និទ្ទេស សុត្តនិបាត ធម្មបទ ឧទាន ឥតិវុត្តកៈ វិមានវត្ថុ បេតវត្ថុ ថេរគាថា ថេរីគាថា អបទាន ។

ក៏ព្រះសុទិន្នត្ថេរ ជំទាស់ពាក្យនេះទាំងអស់ថា ព្រះពុទ្ធវចនៈ ឈ្មោះថា មិនមែនសូត្រមានហើយឬ ដូច្នេះហើយពោលថា បិដក ៣ ឈ្មោះថា សូត្រ ចំណែកវិន័យ ឈ្មោះថា ហេតុ ។ តពីនោះ កាលនឹងសម្តែងហេតុនោះ ទើបនាំសូត្រនេះមកអាងថា ម្នាលនាងគោតមី នាងគប្បីដឹងនូវធម៌ទាំងឡាយណា ធម៌ទាំងនោះ រមែងប្រព្រឹត្តទៅដើម្បីមានតម្រេក មិនប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេក , ប្រព្រឹត្តទៅដើម្បីប្រកបក្នុងទុក្ខ មិនប្រព្រឹត្តទៅដើម្បីប្រាសចាកទុក្ខ , ប្រព្រឹត្តទៅដើម្បីមានឧបាទាន មិនប្រព្រឹត្តទៅដើម្បីប្រាសចាកឧបាទាន , ប្រព្រឹត្តទៅដើម្បីសេចក្តីប្រាថ្នាច្រើន មិនប្រព្រឹត្តទៅដើម្បីសេចក្តីប្រាថ្នាតិច , ប្រព្រឹត្តទៅដើម្បីសេចក្តីមិនសន្តោស

មិនប្រព្រឹត្តទៅដើម្បីសេចក្តីសន្តោស , ប្រព្រឹត្តទៅដើម្បីសេចក្តីខ្ជិលច្រអូស មិនប្រព្រឹត្តទៅដើម្បីប្រារព្ធសេចក្តីព្យាយាម , ប្រព្រឹត្តទៅដើម្បីការសន្សំ មិនប្រព្រឹត្តទៅដើម្បីប្រាសចាកការសន្សំ , ប្រព្រឹត្តទៅដើម្បីការច្រឡូកច្រឡំដោយពួក មិនប្រព្រឹត្តទៅដើម្បីសេចក្តីស្ងាត់ចាកពួក ។ ម្នាលនាងគោតមី នាងគប្បីដឹងដោយចំណែកមួយថា នោះមិនមែនជាធម៌ នោះមិនមែនជាវិន័យ នោះមិនមែនជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តាទេ ។ ម្នាលគោតមី នាងគប្បីដឹងធម៌ទាំងឡាយណា ធម៌ទាំងនេះ រមែងប្រព្រឹត្តទៅដើម្បីប្រាសចាកតម្រេក មិនប្រព្រឹត្តទៅដើម្បីរាគៈ , ប្រព្រឹត្តទៅដើម្បីប្រាសចាកការប្រកបទុក្ខ មិនប្រព្រឹត្តទៅដើម្បីការប្រកបទុក្ខ , ប្រព្រឹត្តទៅដើម្បីប្រាសចាកឧបាទាន មិនប្រព្រឹត្តទៅដើម្បីមានឧបាទាន , ប្រព្រឹត្តទៅដើម្បីសេចក្តីប្រាថ្នាតិច មិនប្រព្រឹត្តទៅដើម្បីសេចក្តីប្រាថ្នាច្រើន , ប្រព្រឹត្តទៅដើម្បីសេចក្តីសន្តោស មិនប្រព្រឹត្តទៅដើម្បីមិនសន្តោស , ប្រព្រឹត្តទៅដើម្បីសេចក្តីស្ងាត់ចាកពួក មិនប្រព្រឹត្តទៅដើម្បីច្រឡូកច្រឡំដោយពួក , ប្រព្រឹត្តទៅដើម្បីប្រារព្ធសេចក្តីព្យាយាម មិនប្រព្រឹត្តទៅដើម្បីសេចក្តីខ្ជិលច្រអូស , ប្រព្រឹត្តទៅដើម្បីប្រាសចាកការសន្សំ មិនប្រព្រឹត្តទៅដើម្បីការសន្សំ ។ ម្នាលនាងគោតមី នាងគប្បីដឹងដោយចំណែកមួយថា នោះជាធម៌ នោះជាវិន័យ នេះជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តាហើយ ។ ព្រោះដូច្នោះ គប្បីជញ្ជាក់សួរក្នុងព្រះត្រៃបិដក ពុទ្ធវចនៈ ដែលឈ្មោះថា

សូត្រ គប្បីប្រៀបធៀបក្នុងហេតុ គឺ វិន័យ មានរាគៈជាដើម ដែលឈ្មោះថា វិន័យ សេចក្តីក្នុងប្រការនេះ មានដូចពោលមកដូច្នេះ ។

បទថា ន ចេវ សុត្តេ ឱតរន្តិ សេចក្តីថា បទព្យញ្ជនៈទាំងនោះ មិនមកក្នុងទីណាៗ តាមលំដាប់សូត្រ លើកមកពីចំណែក គុឡ្ហវេស្សន្តរៈ គុឡ្ហឧម្មគ្គៈ គុឡ្ហវិន័យ វេទល្លៈ និងបិដក នៅមានប្រាកដ ។ ពិតហើយ បទព្យញ្ជនៈដែលមកយ៉ាងនេះ តែមិនប្រាកដក្នុងការកម្ចាត់កិលេស មានរាគៈជាដើម ក៏គប្បីចោល ។ ដោយហេតុនោះ ព្រះមានព្រះភាគ ទើបត្រាស់ថា ភិក្ខុទាំងឡាយ ដូច្នោះ អ្នកគប្បីលះបង់សេចក្តីនោះចេញ ។ គប្បីជ្រាបសេចក្តីក្នុងទីគ្រប់កន្លែង ដោយឧបាយនេះ ។ ពាក្យថា ឥធំ ភិក្ខវេ ចតុត្ថំ មហាបទេសំ ធារេយ្យាថ សេចក្តីថា អ្នកគប្បីចងចាំឱកាសជាទីប្រតិស្ឋាននៃធម៌ទី ៤ នេះទុក ។

ក៏ក្នុងទីនេះគប្បីជ្រាបបកិណ្ណកៈដូច្នេះថា ក្នុងព្រះសូត្រ មានមហាប្រទេស ៤ ក្នុងខន្ធកៈ មានមហាប្រទេស ៤ បញ្ហាព្យាករណ៍ ៤ សុត្តៈ ១ សុត្តានុលោម ១ អាចរិយវាទ ១ អត្តនោមតិ ១ សង្គីតិ ៣ ។

ក្នុងបកិណ្ណកៈទាំងនោះ កាលដល់ការវិនិច្ឆ័យធម៌ថា នេះធម៌ នេះវិន័យ មហាបទេស ៤ ទាំងនេះ កាន់យកជាប្រមាណ សេចក្តីណាសមក្នុងមហាបទេស ៤ ទាំងនេះ សេចក្តីនោះគួរកាន់យក សេចក្តីក្រៅនេះសូម្បីរបស់អ្នកកាន់ខុស ក៏មិនគួរកាន់យក ។ កាលដល់ការវិនិច្ឆ័យសេចក្តី

ដែលគួរ និងមិនគួរថា វត្ថុនេះគួរ វត្ថុនេះមិនគួរ មហាបទេស ៤ ដែលត្រាស់ទុកក្នុងខន្ធកៈដោយន័យថា ៖

ម្នាលភិក្ខុទាំងឡាយ វត្ថុណាដែលតថាគតមិនបានហាមទុកថា វត្ថុនេះមិនគួរទេ បើរបស់នោះអនុលោមចូលរបស់មិនគួរ ឃាត់របស់គួររបស់នោះមិនគួរដល់អ្នកទាំងឡាយឡើយ ដូច្នេះជាដើម កាន់យកជាប្រមាណ ។ កថាវិនិច្ឆ័យមហាបទេសទាំងនោះ ពោលទុកក្នុងអដ្ឋកថាព្រះវិន័យ ឈ្មោះថា សមន្តប្បាសាទិកា ដោយន័យដែលពោលទុកក្នុងទីនោះគប្បីធ្វើសន្និដ្ឋានយ៉ាងនេះថា វត្ថុណាដែលចូលគ្នាបានទីងវត្ថុដែលគួរ វត្ថុនោះ គួរ ក្រៅពីនោះមិនគួរ ។

ឯកង្សព្យាករណីយបញ្ហា ១ វិភជ្ជព្យាករណីបញ្ហា ១ បដិបុច្ឆាព្យាករណីយបញ្ហា ១ ឋបនីយបញ្ហា ១ ទាំងនេះ ឈ្មោះថា បញ្ហាព្យាករណ៍ ៤ ។ ក្នុងបញ្ហាព្យាករណ៍ ៤ នោះ ត្រូវសួរថា ចក្ខុមិនទៀងឬគប្បីព្យាករណ៍មុនដោយចំណែកតែមួយថា មិនទៀង ព្រះករុណា ។ ក្នុងសោតៈជាដើម ក៏មានន័យនេះ ។ នេះឈ្មោះថា ឯកង្សករណីយបញ្ហា ។ ត្រូវសួរថា ចក្ខុឬ ឈ្មោះថា មិនទៀង ។ គប្បីចែកហើយ ព្យាករណ៍យ៉ាងនេះថា មិនមែនចក្ខុប៉ុណ្ណោះ សូម្បីតែសោតៈ ក៏មិនទៀង សូម្បីឃានៈ ក៏មិនទៀង ។ នេះឈ្មោះថា វិភជ្ជព្យាករណីយបញ្ហា ។ ត្រូវសួរថា ចក្ខុយ៉ាងណា សោតៈក៏ដូច្នោះ សោតៈយ៉ាងណា ចក្ខុក៏ដូច្នោះជាដើម ។

ទើបសាកសួរថា លោកសួរដោយអត្ថថាអ្វី កាលគេឆ្លើយថា សួរដោយអត្ថថា ឃើញ ទើបព្យាករណ៍ថា មិនមែន ។ កាលគេឆ្លើយថា សួរដោយអត្ថថា មិនទៀង ទើបព្យាករណ៍ថា មែន ។ នេះឈ្មោះថា បដិបុច្ឆាព្យាករណីយបញ្ហា ។ តែត្រូវសួរថា នោះក៏ជីវៈ នោះក៏សរីរៈ ជាដើម គប្បីឈប់ ដោយពោលថា សេចក្តីនេះ ព្រះមានព្រះភាគមិនព្យាករណ៍ ។ បញ្ហានេះ មិនគប្បីព្យាករណ៍ ។ នេះឈ្មោះថា ឋបនីយបញ្ហា ។ ដូច្នោះ កាលបញ្ហាមកដល់ដោយអាការនោះ បញ្ហាព្យាករណ៍ទាំង ៤ នេះ កាន់យកជាប្រមាណបាន ។ គប្បីព្យាករណ៍បញ្ហានោះ ដោយអំណាចបញ្ហាព្យាករណ៍ ៤ នេះ ។

ក៏បិដក ៣ ដែលលើកឡើងកាន់សង្គីតិ ៣ ឈ្មោះថា សុត្តៈ ក្នុងបកិណ្ណកៈ មានសុត្តៈជាដើម ។ សេចក្តីដែលចូលគ្នាបានជាមួយកប្បិយៈ ឈ្មោះថា សុត្តានុលោម ។ អដ្ឋកថា ឈ្មោះថា អាចរិយវាទ ។ បដិភាណរបស់ខ្លួន តាមសេចក្តីយកន័យស្មានៗ តាមសេចក្តីដឹង ឈ្មោះថា អត្តនោមតិ ។ ក្នុងបកិណ្ណកៈទាំងនោះ សុត្តៈ នរណាៗ ជំទាស់មិនបាន កាលជំទាស់សុត្តៈនោះ ក៏ស្មើនឹងជំទាស់ព្រះពុទ្ធផង ។ ចំណែកសេចក្តីដែលចូលជាមួយនឹងកប្បិយៈបាន គួរកាន់យកចំពោះសេចក្តីដែលសមនឹងសុត្តៈប៉ុណ្ណោះ ក្រៅពីនោះមិនគួរកាន់យក ។ សូម្បីអាចរិយវាទ ក៏គួរកាន់យកតែសេចក្តីដែលសមនឹងសុត្តៈប៉ុណ្ណោះ ក្រៅពីនោះមិនគួរកាន់យក ។

ចំណែកអត្តនោមតិ អន់ជាងគេទាំងអស់ ។ សូម្បីអត្តនោមតិនោះ ក៏គួរកាន់យកតែសេចក្តីដែលសមនឹងសុត្តៈប៉ុណ្ណោះ ក្រៅពីនោះមិនគួរកាន់យក ។

ក៏សង្គីតិមាន ៣ ទាំងនេះ គឺ បញ្ចសតិកសង្គីតិ (សង្គាយនាគ្រាទី ១) សត្តសតិកសង្គីតិ (លើកទី ២) សហស្សិកសង្គីតិ (លើកទី ៣) ។ សូម្បីសុត្តៈដែលមកក្នុងសង្គីតិ ៣ នោះ គួរកាន់យកជាប្រមាណ ។ ក្រៅពីនោះជាការដែលលោកតិះដៀល មិនគួរកាន់យក ។ ពិតហើយ បទព្យញ្ជនៈសូម្បីដែលចូលគ្នាបានក្នុងសុត្តៈនោះ គប្បីជ្រាបថា ចូលគ្នាមិនបានក្នុងព្រះសូត្រ និងប្រៀបគ្នាមិនបានក្នុងព្រះវិន័យ ។

## រឿងនាយចុន្ទកម្មារបុត្ត

**[១១៧]** បទថា កម្មារបុត្តស្ស បានដល់ កូនរបស់ជាងមាស ជំណាលមកថា បុត្ររបស់ជាងមាសនោះ ជាកុដុម្ពីធំ ជាអ្នកស្តុកស្តម្ភ ជាសោតាបន្ន ព្រោះឃើញព្រះមានព្រះភាគគ្រាដំបូងប៉ុណ្ណោះ បានសាងវត្តក្នុងសួនស្វាយរបស់ខ្លួនថ្វាយ ។ លោកសំដៅយកសួនស្វាយនោះទើបពោលថា អម្ពវនេ ។ បទថា សូករមទ្ទវំ បានដល់ **បវត្តមំសៈ** របស់ជ្រូកមួយដែលធំបំផុត មិនក្មេងពេក មិនចាស់ពេក ។ ន័យថា បវត្តមំសៈនោះ ទន់ល្អិត ។ អធិប្បាយថា ឲ្យចាត់បវត្តមំសៈនោះ ធ្វើឲ្យឆ្អិនយ៉ាងល្អ ។ អាចារ្យពួកមួយពោលថា ក៏ពាក្យថា សូករមទ្ទវៈនេះ ជា

ឈ្មោះរបស់បាយទន់ ដែលចាត់ផ្សំដោយបញ្ចគោរស (ទឹរ ទឹកដោះស្រស់ ឧធិ ទឹកដោះជូរ ឃតំ ទឹកដោះថ្លា តក្កំ ប្រេង និង នោធីតំ ជុំខ្លាញ់) និងសណ្តែក ដូចរបស់ផ្អិនឈ្មោះថា **គវបាន:** នំផ្សំទឹកដោះគោ ។ អាចារ្យពួកខ្លះពោលថា វិធីផ្សំរស ឈ្មោះថា សូករមទ្ទវ: ក៏សូករមទ្ទវ:នោះមកក្នុងរសាយតនសាស្ត្រ ។ សូករមទ្ទវ:នោះ នាយចុន្ទ:តាក់តែងតាមរសាយនវិធី ដោយបំណងថា ការបរិនិព្វាន នឹងមិនទាន់មានដល់ព្រះមានព្រះភាគ ។ តែពួកទេវតាក្នុងមហាទ្វីបទាំង ៤ ដែលមានទ្វីបតូច ២,០០០ ជាបរិវារ ដាក់ឱជាចុះក្នុងសូករមទ្ទវ:នោះ ។ ព្រះមានព្រះភាគ ទ្រង់បន្លឺសីហនាទនេះថា ឆាហន្តំ ដើម្បីអ្វី ។ ដើម្បីទ្រង់ដោះពាក្យស្តីបន្ទោសរបស់អ្នកដទៃ ។ ពិតហើយ ព្រះមានព្រះភាគ ស្តាប់ពាក្យរបស់ពួកដែលត្រូវការនឹងពោលថា ព្រះមានព្រះភាគមិនប្រទានសូករមទ្ទវ: ដែលព្រះអង្គសោយនៅសល់ ទាំងដល់ភិក្ខុ ទាំងដល់មនុស្សទាំងឡាយ បង្គាប់ឲ្យកប់ចោលក្នុងរណ្តៅ ធ្វើឲ្យវិនាសអស់ដូច្នេះ ទើបទ្រង់បន្លឺសីហនាទ ដើម្បីដោះពាក្យស្តីបន្ទោសរបស់ជនពួកដទៃ ដោយព្រះបំណងថា នឹងមិនមានឱកាសពោលស្តីបន្ទោសបាន ។

**[១១៨]** បទថា ភុត្តស្ស ច សូករមទ្ទវេន សេចក្តីថា អាពាធយ៉ាងខ្លាំងក្លា កើតឡើងដល់ព្រះអង្គអ្នកសោយ តែមិនមែនកើតព្រោះសូករមទ្ទវ:ដែលសោយជាបច្ច័យ ។ ក៏ប្រសិនបើថា ព្រះអង្គមិនសោយ ក៏នឹង

កើតអាពាធបាន ទើងជាអាពាធដ៏ខ្លាំងក្លាទៀតផង ។ តែព្រោះសោយភោជនដែលស្និទ្ធ ព្រះអង្គទើបមានទុក្ខវេទនាស្រាលខ្លះ ។ ដោយហេតុនោះឯង ព្រះអង្គទើបស្តេចពុទ្ធដំណើរទៅបាន ។ បទថា វិរេចមានោ បានដល់ ព្រះអង្គទ្រង់ធ្លាក់ព្រះលោហិតរឿយៗ ។ លោកពោលយ៉ាងនេះថា អវោច ក៏ដើម្បីប្រយោជន៍ដល់ការបរិនិព្វានក្នុងស្ថានទីដែលព្រះអង្គមានព្រះពុទ្ធបំណង ។ គប្បីជ្រាបសេចក្តីថា ក៏ព្រះធម្មសង្គាហកត្ថេរតាំងគាថាទាំងនេះទុក ។

សព្ទថា ឥង្ឃ ជានិបាតចុះក្នុងអត្ថថា ដាស់តឿន ។ បទថា អច្ឆោទកា ប្រែថា មានទឹកថ្លា ។ បទថា សាតោទកា ប្រែថា មានទឹកឆ្ងាញ់ ។ បទថា សីតោទកា ប្រែថា មានទឹកត្រជាក់ស្រេប ។ បទថា សេតោទកា ប្រែថា ប្រាសចាកភក់ ។ បទថា សុបតិត្ថា ប្រែថា មានកំពង់ល្អ ។

## ការសម្តែងខ្លួនជាឧបាសកនៃបុក្កុសមល្លក្សត្រ

[១២០] បទថា បុក្កុសោ ជាឈ្មោះរបស់បុត្រមល្លក្សត្រនោះ ។ បទថា មល្លបុត្តោ ប្រែថា បុត្ររបស់មល្លក្សត្រ ។ បានឮថា ពួកមល្លក្សត្រផ្លាស់ប្តូរគ្នាគ្រងរាជសម្បត្តិ ។ ដរាបណាវារៈរបស់មល្លក្សត្រពួកណាមិនទាន់មកដល់ ដរាបនោះ មល្លក្សត្រទាំងនោះ ក៏ធ្វើការធ្វើជំនួញ

ទៅ ។ ស្តេចបុក្កុសៈនេះ ក៏ធ្វើដំនួញដោយរទេះ ៥០០ ទុំះឯង កាល ខ្យល់បក់មកខាងមុខ ក៏ទៅខាងមុខ កាលខ្យល់បក់មកខាងក្រោយ ក៏បញ្ជូន ពួករទេះទៅខាងមុខ ខ្លួនឯង ទៅខាងក្រោយ ។ ក្នុងគ្រានោះ ខ្យល់បក់ ទៅខាងក្រោយ ព្រោះដូច្នោះ គេទើបបញ្ជូនពួករទេះទៅខាងមុខ អង្គុយ លើយានផ្ទុករតនៈទាំងអស់ ចេញចាកក្រុងកុសិនារា ធ្វើដំណើរទៅ សំដៅ ទៅក្រុងបាវា ។ ដោយហេតុនេះ លោកទើបពោលថា ដើរផ្លូវឆ្ងាយចាក ក្រុងកុសិនារា ទៅកាន់ក្រុងបាវា ។

បទថា អាឡារោ ជាឈ្មោះរបស់តាបសនោះ ។ បានឮថា តាបសនោះ មានរាងខ្ពស់ និងលឿង ព្រោះហេតុនោះ លោកទើបមាន ឈ្មោះថា អាឡារៈ ។ ពាក្យថា កាលាមោ បានដល់ គោត្រ ។ ពាក្យថា យត្រ ហិ នាម ស្មើនឹង យោហិ នាម ។ បទថា នេវ ឧក្ខតិ ប្រែថា មិន ឃើញ ។ តែលោកពោលពាក្យនេះទុកជាអនាគតកាល ព្រោះប្រកបនឹង យត្រ ស័ព្ទ ។ ពិតហើយ ពាក្យបែបនេះ ជាលក្ខណៈស័ព្ទក្នុងឋានៈដូច្នេះ ។ បទថា និច្ឆរន្តីសុ ប្រែថា យំស្រែក ។ បទថា អសនិយា ផលន្តិយា បានដល់ ស្រែកយំយ៉ាងខ្លាំងៗ ដូចរន្ទះបាញ់បែកខ្ទេកចេញជា ៩ ខ្សែ ។

សេចក្តីពិត រន្ទះបាញ់មាន ៩ ខ្សែ គឺ អសញ្ញា វិចក្កា សតេរា គគ្គរា កបិសីសា មច្ឆវិលោលិកា កុក្កុដកា ឧណ្ឌមណិកា និង សុក្ខាសនិ ។ បណ្តារន្ទះបាញ់ ៩ នោះ ៖

-រន្ទះបាញ់ដែលឈ្មោះថា អសញ្ញា ញុាំងបុគ្គលនៅក្នុងប្រទេសនោះប្រាសចាកសញ្ញា បាត់ស្មារតី ។

-រន្ទះឈ្មោះថា វិចក្កា មានសភាពដូចជាកងចក្រ ។

-រន្ទះឈ្មោះថា សតេរា ប្រាកដដូចក្តោងសំពៅ ដែលត្រដាងទុកត្រង់សសរក្តោង ។

-រន្ទះឈ្មោះថា គគ្គរា មានសំឡេងលាន់គ្រឹមៗ ដូចផ្គរលាន់ ។

-រន្ទះឈ្មោះថា កបិសីសា កាលធ្លាក់ដល់ដីហើយ ក៏ត្រឡប់ផ្ងារឡើង មានអាការដូចស្វាងើយមុខ សណ្ឋានរន្ទះនោះ មានអាការដូចក្បាលស្វា ។

-រន្ទះឈ្មោះថា មច្ឆវិលោលិកា កាលធ្លាក់ដល់ដីហើយ ក៏ស្ទុះឡើងទៅៗ មានអាការដូចជាត្រីលោតឡើង ។

-រន្ទះឈ្មោះថា កុក្កុដកា មានអាការប្រាកដដូចមាន់ទដាងស្លាប ។

-រន្ទះឈ្មោះថា ទណ្ឌមណិកា ប្រាកដដូចរូបផ្នាំង ដែលបុគ្គលព្យួរទុកត្រង់យាមនង្គ័ល ។

-រន្ទះឈ្មោះថា សុក្ខាសនិ ប្រាកដជាស្នើដ៏ក្តៅ ជាអណ្តាតភ្លើងធ្លាក់ចុះទីណា ក៏ឆេះទីនោះ ។

បទថា ទេវេ វស្សន្តេ បានដល់ គំរាមគ្រហឹមស្លូតៗ កាលភ្លៀងធ្លាក់ជារយៈៗ ។

---

-សេចក្តីប្រែ យកតាមសារត្ថសង្គហៈ ព្រោះមានសេចក្តីងាយស្តាប់ ។

[១២១] បទថា អាតុមាយំ សេចក្តីថា បានអាស្រ័យស្រុកអាតុមា ។ បទថា ភុសាគារេ បានដល់ រោងលានស្រូវ ។ បទថា ឯត្ថ សោ បានដល់ ពួកមហាជនដែលជំនុំគ្នា ព្រោះហេតុនេះ ។ បទថា ក្វ អហោសិ ជា កុហឹ អហោសិ ។ បទថា សោ តំ ភន្តេ ជា សោ ត្វំ ភន្តេ ។ បទថា សិង្គិវណ្ណំ បានដល់ មានពណ៌ដូចមាសសិង្គី ។ បទថា យុគមដ្ឋំ ប្រែថា ម៉ដ្ឋទាំងគូ ។ អធិប្បាយថា សំពត់ ១ គូ សាច់ល្អិត ។ បទថា ធារណីយំ បានដល់ គប្បីប្រដាប់ អធិប្បាយថា គប្បីដណ្តប់ម្តងៗ ។ ស្តេចបុក្កុសៈនោះ ប្រើចំពោះក្នុងថ្ងៃមហាស្រពប៉ុណ្ណោះ ក្នុងវេលាដទៃក៏ចោលទៅ ។ លោកសំដៅយកគូសំពត់មង្គលខ្ពង់ខ្ពស់ ទើបពោលទុកយ៉ាងនេះ ។ បទថា អនុកម្បំ ឧបាទាយ បានដល់ អាស្រ័យសេចក្តីអាណិតក្នុងយើង ។ បទថា អច្ឆាទេហិ នេះ ជាពាក្យទន់ភ្លន់ ។ អធិប្បាយថា ចូរឲ្យដល់តថាគតមួយផ្ទាំង អានន្ទមួយផ្ទាំង ។ សួរថា ក៏ព្រះថេរៈទទួលសំពត់នោះឬ ។ ឆ្លើយថា លោកទទួល ។ ព្រោះហេតុអ្វី ។ ព្រោះមានកិច្ចដល់ទីបំផុតហើយ ។ សេចក្តីពិត ព្រះអានន្ទនោះ ហាមលាភបែបនោះ បដិបត្តិនាទីឧបដ្ឋាកក៏ពិតមែន តែនាទីឧបដ្ឋាករបស់លោក នោះដល់ទីបំផុតហើយ ព្រោះដូច្នោះ លោកទើបបានទទួល ។ ឬថា ជនពួកណាគប្បីនិយាយយ៉ាងនេះថា ព្រះអានន្ទដែលនឹងមិនត្រេកអរ លោកឧបដ្ឋាកមករហូត ២៥ ឆ្នាំ មិនធ្លាប់បានអ្វីអំពីសម្នាក់របស់ព្រះមានព្រះភាគឡើយ ។ ព្រោះដូច្នោះ លោកទើបបាន

ទទួលដើម្បីកាត់ឱកាស របស់ជនទាំងនោះ ។ មួយទៀត ព្រះមានព្រះភាគ ក៏ទ្រង់ជ្រាបថា អានន្ទសូម្បីទទួល ក៏នឹងមិនប្រើដោយខ្លួនឯងគង់នឹងបូជាតថាគតប៉ុណ្ណោះ តែបុត្ររបស់មល្លៈក្សត្រ កាលបូជាអានន្ទ ក៏ស្មើនឹងបូជាព្រះសង្ឃផង កាលដូច្នេះ គំនរបុណ្យធំ ក៏នឹងមានដល់បុត្រមល្លៈក្សត្រនោះ ព្រោះដូច្នោះ ទើបទ្រង់ប្រោស ឲ្យថ្វាយព្រះថេរៈផ្ទាំងមួយ ។ ចំណែកព្រះថេរៈ ទើបបានទទួល ព្រោះហេតុនោះដូចគ្នា ។ បទថា ធម្មិយា កថាយ បានដល់ ការពោល អនុមោទនាវត្ថុទាន ។

[១២២] បទថា ភគវតោ កាយំ ឧបនាមិតំ បានដល់ ការពោលទុកដោយទំនងស្លៀកដណ្ដប់ ។ សូម្បីព្រះមានព្រះភាគ ទ្រង់ស្លៀកមួយផ្ទាំង ដណ្ដប់មួយផ្ទាំង អំពីគូសំពត់នោះ ។ បទថា ហតច្ចិកំ វិយ សេចក្ដីថា រងើកភ្លើងដែលប្រាសចាកអណ្ដាត រមែងរុងរឿងខាងក្នុងៗប៉ុណ្ណោះ តែពន្លឺនៃរងើកភ្លើងនោះ មិនមានខាងក្រៅយ៉ាងណា គូសំពត់ក៏ដូច្នោះដែរ ប្រាកដថា គ្មានពន្លឺខាងក្រៅ ។

សួរថា ក្នុងពាក្យថា ឥមេសុ ខោ អានន្ទ ទ្វីសុ កាលេសុ ហេតុណាកាយរបស់ព្រះតថាគត ទើបបរិសុទ្ធិយ៉ាងក្រៃលែងយ៉ាងនេះ ក្នុងកាលទាំង ២ នេះ ។ ឆ្លើយថា ព្រោះសេចក្ដីវិសេសនៃអាហារម្យ៉ាង ព្រោះសោមនស្សមានកម្លាំងម្យ៉ាង ។ ក្នុងកាលទាំង ២ នេះ ពួកទេវតាក្នុងសាកលចក្រវាឡ ដាក់ឱជាចុះក្នុងអាហារ ។ ក៏ភោជននោះធ្លាក់ដល់ផ្ទៃ ក៏បង្កើត

បសន្នរូប ។ ឥន្ទ្រិយដែលមានចិត្តជាទី ៦ ក៏រុងរឿងក្រៃលែង ព្រោះមាន រូប ដែលមានអាហារជាសមុដ្ឋានស្រស់ថ្លា ។ ក្នុងថ្ងៃដែលព្រះអង្គត្រាស់ ដឹង ទ្រង់រឭកថា កងកិលេសដែលតថាគតសន្សំមកច្រើនសែនកោដិកប្ប ថ្ងៃនេះ តថាគតលះបានហើយហ្ន៎ ទើបកើតសោមនស្សមានកម្លាំងឡើង ។ ចិត្តក៏ថ្លា ។ កាលចិត្តថ្លា លោហិតក៏ថ្លា ។ កាលលោហិតថ្លា ឥន្ទ្រិយ មានចិត្តជាទី ៦ ក៏រុងរឿងយ៉ាងក្រៃលែង ។ ក្នុងថ្ងៃបរិនិព្វាន ទ្រង់រំលឹក ថា ថ្ងៃនេះ ឥឡូវនេះ តថាគតនឹងចូលទៅកាន់នគរអមតមហាបរិនិព្វាន ដែលព្រះពុទ្ធច្រើនសែនព្រះអង្គចូលទៅហើយ ដូច្នេះ ទើបកើតសោមនស្ស មានកម្លាំងឡើង ។ ចិត្តក៏ថ្លា កាលចិត្តថ្លា លោហិតក៏ថ្លា កាលលោហិតថ្លា ឥន្ទ្រិយមានចិត្តជាទី ៦ ក៏រុងរឿងយ៉ាងក្រៃលែង ។ គប្បីជ្រាបថា ព្រះ វរកាយរបស់ព្រះតថាគតបរិសុទ្ធិយ៉ាងក្រៃលែង មានក្នុងកាលទាំង ២ នេះ ដោយអាហារ និងសោមនស្សមានកម្លាំង ដោយប្រការដូច្នេះ ។

បទថា ឧបវត្តនេ បានដល់ ក្នុងសាលវ័នត្រង់គល់ខាងកើត ។ បទថា អន្តរេ យមកសាលានំ គឺ ត្រង់ចន្លោះសាលព្រឹក្សទាំងគូ ។

**[១២៣]** គាថាថា សិង្គិវណ្ណំ ជាដើម លោកដាក់ទុកក្នុងពេល សង្គាយនា ។

**[១២៤]** គប្បីជ្រាបវិនិច្ឆ័យក្នុងគាថាថា គន្ត្វាន ច បិវិត្វា ច ជាដើមដូចតទៅនេះ ៖

បានឮថា ក្នុងកាលនោះ កាលព្រះមានព្រះភាគចុះស្រង់ទឹក អណ្ដើកត្រីខាងក្នុងទន្លេ និងជួរព្រៃមាត់ច្រាំងទាំង ២ ទាំងអស់ ក៏មានពណ៌ដូចមាសដែរ ។ បទថា អម្ពវនំ បានដល់ ចំការស្វាយមាត់ច្រាំងទន្លេនោះឯង ។ បទថា អាយស្មន្តំ ចុន្ទកំ សេចក្ដីថា បានឮថា ក្នុងខណៈនោះ ព្រះអានន្ទត្ថេរបត់សំពត់ស្រង់ទឹកនៅសល់ទុក ។ ព្រះចុន្ទត្ថេរ ក៏នៅក្នុងទីជិត ។ ព្រះមានព្រះភាគត្រាស់ហៅព្រះចុន្ទៈមកហើយ ។

**[១២៥]** សូម្បីគាថានេះថា គន្ត្វាន ពុទ្ធោ នទិកំ កកុធំ លោកដាក់ទុកក្នុងគ្រាសង្គីតិទី៣ឯង ។ បណ្ដាបទទាំងនោះ បទថា បវត្តា ភគវា ឥធ ធម្មេ សេចក្ដីថា ព្រះមានព្រះភាគទ្រង់ប្រកាសព្រះធម៌ក្នុងសាសនានេះ អធិប្បាយថា ទ្រង់ប្រកាសធម៌ ៨៤.០០០ ព្រះធម្មក្ខន្ធ ។ បទថា បមុខេ និសីទិ បានដល់ អង្គុយត្រង់ព្រះភក្ត្រព្រះសាស្ដា ។ ក៏ដោយពាក្យត្រឹមតែប៉ុណ្ណេះ ព្រះថេរៈមកដល់ហើយ ។ គ្រានោះឯងព្រះមានព្រះភាគត្រាស់ចំពោះព្រះអានន្ទដែលមកដល់ហើយយ៉ាងនេះ ។

**[១២៦]** បទថា តេ អលាភា បានដល់ លាភ ពោលគឺ អានិសង្សទាន ជាលាភរបស់អ្នកដទៃ មិនមែនលាភរបស់លោក ។ បទថា ទុល្លទ្ធំ បានដល់ ការបានអត្តភាពជាមនុស្ស សូម្បីដោយបុណ្យវិសេសក៏ចាត់ថា បានដោយក្រ ។ បទថា យស្ស តេ ស្មើនឹង យស្ស តវ លោកណា ។ ក្រៅអំពីបាយ ឬវត្ថុសោហ្មងយ៉ាងក្រៃលែង អ្នកណានឹងដឹងបាន

ព្រះតថាគត សោយបិណ្ឌបាតពេលក្រោយ យ៉ាងណា ហើយស្ដេចបរិ-និព្វាន ទានណាមួយ នឹងជាការដែលលោកឲ្យពិតប្រាកដ ។ បទថា លាភា បានដល់ ជាលាភ គឺ អានិសង្សក្នុងការឲ្យទាន ដែលមានក្នុងបច្ចុប្បន្ន ឬប្រព្រឹត្តទៅក្នុងសម្បរាយភព ។ បទថា សុលទ្ធំ បានដល់ ការបានអត្តភាពជាមនុស្ស គឺ លោកបានមកល្អហើយ ។ បទថា សមសមផលា ប្រែថា មានផលស្មើៗ គ្នា ដោយអាការទាំងពួង ។

សួរថា ព្រះតថាគតសរសើរបិណ្ឌបាតណា ដែលនាងសុជាតាថ្វាយ ហើយត្រាស់ដឹង បិណ្ឌបាតនោះ ព្រះអង្គសោយក្នុងវេលាដែលនៅមាន រាគៈ ទោសៈ និងមោហៈ , តែបិណ្ឌបាតនេះ ដែលនាយចុន្ទៈថ្វាយហើយ ព្រះអង្គសោយក្នុងវេលាដែលប្រាសចាករាគៈ ទោសៈ មោហៈ មិនមែនឬ តើដូចម្ដេច ? បានជាបិណ្ឌបាតទាំងពីរនេះ មានផលស្មើៗ គ្នា ឆ្លើយថា ព្រោះ**ស្មើគ្នាដោយការបរិនិព្វាន ស្មើគ្នាដោយការចូលសមាបត្តិ** និង**ស្មើគ្នាដោយការរឭកដល់** ។ ពិតណាស់ ព្រះមានព្រះភាគ សោយបិណ្ឌបាតដែលនាងសុជាតាថ្វាយហើយ ស្ដេចបរិនិព្វានដោយសឧបាទិសេសនិព្វាន-ធាតុ និងសោយបិណ្ឌបាតដែលនាយចុន្ទៈថ្វាយហើយ ស្ដេចបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ រួមសេចក្ដីថា **មានផលស្មើគ្នា ដោយការបរិ-និព្វាន** ។ ក៏ក្នុងថ្ងៃដែលព្រះអង្គត្រាស់ដឹង ព្រះអង្គទ្រង់ចូលសមាបត្តិរាប់បាន **ពីរលានបួនសែនកោដិ** សូម្បីក្នុងថ្ងៃស្ដេចបរិនិព្វាន ព្រះអង្គក៏ទ្រង់

ចូលសមាបត្តិទាំងអស់នោះ ។ រួមសេចក្តីថា មានផលស្មើគ្នាដោយសមាបត្តិស្មើគ្នា ។ ក្នុងកាលតមក នាងសុជាតា បានជ្រាបថា ពួកថា អ្នកដែលយើងឃើញនោះ មិនមែនរុក្ខទេវតា ជាព្រះពោធិសត្វ បានឮថា ព្រះពោធិសត្វនោះ ឆាន់បិណ្ឌបាតនោះហើយ ត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញាណ ព្រះអង្គតាំងនៅបានដោយបិណ្ឌបាតនោះ ៧ សប្តាហ៍ ។ កាលនាងបានស្តាប់ដូច្នោះ ក៏ពេកបានថា ជាលាភរបស់យើងហ្ន៎ ទើបកើតបីតិសោមនស្សយ៉ាងខ្លាំង ។ លុះតមក នាយចុន្ទៈបានស្តាប់ថា បានឮថា បិណ្ឌបាតគ្រាចុងក្រោយបង្អស់ដែលយើងថ្វាយ យើងបានកំពូលធម៌ហើយ បានឮថា ព្រះសាស្តាសោយបិណ្ឌបាតរបស់យើង ស្តេចបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ពេកបានថា ជាលាភរបស់យើងហ្ន៎ ទើបកើតសោមនស្សយ៉ាងខ្លាំង គប្បីជ្រាបថា មានផលស្មើគ្នាសូម្បីដោយការពេកដល់ស្មើគ្នាយ៉ាងនេះ ដោយប្រការដូច្នេះ ។

បទថា យសសំវត្តនិកំ បានដល់ ប្រព្រឹត្តទៅដើម្បីបរិវារ ។ បទថា អធិបតេយ្យសំវត្តនិកំ បានដល់ ប្រព្រឹត្តទៅដើម្បីភាពជាធំ ។

**[១២៧]** បទថា សញ្ញាមតោ បានដល់ អ្នកមានការសង្រួមដោយការសង្រួមក្នុងសីល ។ អធិប្បាយថា តាំងនៅក្នុងសំវរៈ ។ បទថា វេរំ ន ចីយតិ បានដល់ មិនបង្កពៀរទាំង ៥ ។ បទថា កុសលោ ច ជហាតិ ចាបកំ សេចក្តីថា ក៏បុគ្គលដែលឆ្លាតសម្បូរណ៍ដោយបញ្ញា រមែងលះបាប

អកុសលដ៏លាមក ដោយមិននៅសល់ដោយអរិយមគ្គ ។ បទថា រាគ-ទោសមោហក្ខយា និព្វុតោ សេចក្ដីថា អ្នកធ្លាតនោះ លះអកុសលដ៏លាមកនេះ ហើយនិព្វានដោយកិលេសនិព្វាន ព្រោះអស់កិលេស មានរាគៈជាដើម ដូច្នោះ ព្រះមានព្រះភាគ កាលទ្រង់ពិចារណាឃើញទក្ខិណារបស់នាយចុន្ទៈ និងទក្ខិណេយ្យសម្បត្តិរបស់ព្រះអង្គ ទើបទ្រង់ថ្លែងព្រះឧទានដោយប្រការដូច្នេះ ។

ចប់ កថាពណ៌នាចតុត្ថភាណវារ

## ពោលអំពី សាលៈទាំងគូ

**[១២៨]** ក្នុងពាក្យថា មហតា ភិក្ខុសង្ឃេន សទ្ធឹ នេះ ចំនួនរបស់ភិក្ខុទាំងឡាយកំណត់ពិតមិនបាន ។ ពេលបានជ្រាបថា ចាប់ផ្ដើមតាំងពីព្រះអង្គទ្រង់គ្របសង្កត់វេទនានៅឯវេឡុវគ្រាម មិនយូរឡើយ ព្រះមានព្រះភាគក៏នឹងបរិនិព្វាន បណ្ដាភិក្ខុដែលមកពីទីនោះៗ មិនមាន សូម្បីតែភិក្ខុមួយរូប ដែលឈ្មោះថា ចៀសទៅ ព្រោះដូច្នោះ ព្រះសង្ឃទើបមានចំនួនរាប់មិនបាន ។

បទថា ឧបវត្តនំ មល្លានំ សាលវនំ សេចក្ដីថា ព្រះមានព្រះភាគស្ដេចយាងចាកត្រើយម្ខាង នៃទន្លេហិរញ្ញវតី ឆ្ពោះកាន់សាលវនោទយាន ដូចចេញចាកត្រើយទន្លេកលម្ពនទី ទៅកាន់ថូបារាមតាមផ្លូវទ្វារវត្តរបស់ព្រះរាជមាតា ។ សាលវននោះ នៅក្នុងក្រុងកុសិនារា ដូចថូបារាមរបស់ក្រុងអនុរាធបុរី ។ ផ្លូវចូលព្រះនគរតាមទ្វារទិសទក្សិណពីថូបារាម បែរមុខទៅទិសខាងកើត ឈាងទៅទិសឧត្តរ យ៉ាងណា សាលវនចាកព្រះរាជឧទ្យាន បែរមុខទៅទិសខាងកើត ឈាងទិសឧត្តរ ដូច្នោះ សាលវននោះលោកទើបហៅថា **ឧបវត្តន** ផ្លូវកោង ។

បទថា អន្តរេ យមកសាលានំ ឧត្តរសីសកំ សេចក្ដីថា បានឮថាដើមសាលៈមួយជួរនៅខាងសីសៈព្រះដំណេក មួយជួរនៅខាងចុងព្រះបាទ ។ ក្នុងជួរដើមសាលៈនោះ ដើមសាលៈជំទង់មួយដើម នៅជិតខាងផ្នែកព្រះ-

សិរសា មួយដើមនៅជិតព្រះបាទ ។ម្យ៉ាងទៀត លោកពោលថា ដើមសាលៈដែលឈរដើមប្រកៀកគ្នានិងគ្នាដោយឫស ដើម បន្ទាប មែក និងស្លឹក ឈ្មោះថា យមកសាលៈ ។ ដោយបទថា មញ្ចកំ បញ្ញបេហិ លោកពោលថា បានឮថា ព្រះទេនផ្ទុំក្នុងព្រះរាជឧទ្យាននោះមាន ទ្រង់សំដៅដល់ព្រះទេននោះ ទ្រង់ត្រាស់ឲ្យក្រាល ។ សូម្បីព្រះថេរៈក៏ចាត់ព្រះទេននោះថ្វាយ ។ បទថា កិលន្តោស្មិ អានន្ទ និបជ្ជិស្សាមិ សេចក្តីថា សេចក្តីពិតក្នុងពាក្យនេះថា ៖

ត្រកូលដំរីឈ្មោះ គោចរី កលាបៈ គង្គេយ្យៈ បិង្គលៈ បព្វតេយ្យកៈ ហេមវតៈ តម្ពៈ មន្ទាកិនី ឧបោសថ ឆទ្ទន្តៈ ជាគម្រប់ ១០ ទាំងនេះ ជាកំពូលរបស់ដំរីទាំងឡាយ កម្លាំងយ៉ាងណារបស់ព្រះតថាគត **មានកម្លាំងស្មើនឹងកម្លាំងរបស់ដំរីប្រក្រតី ១ ពាន់កោដិ** ដោយន័យគុណបន្ថែមនឹង ១០ យ៉ាងនេះ គឺ កម្លាំងរបស់ដំរីប្រក្រតី ដែលហៅថា ដំរី គោចរី ១០ ស្មើនឹងកម្លាំងរបស់ដំរីត្រកូលកលាបៈ ១ ជាដើម កម្លាំងទាំងអស់នោះក៏អស់ទៅ ដូចទឹកដែលដាក់ចុះក្នុងថ្នាំងតម្រងទឹក តាំងពីវេលាដែលសោយបិណ្ឌបាតរបស់នាយចុន្ទៈ ។ តាំងពីនគរបាវាដល់នគរកុសិនារា ចម្ងាយផ្លូវ ៣ គាវុត ។ ក្នុងចន្លោះនេះ ព្រះមានព្រះភាគត្រូវប្រថាប់ សម្រាកដល់ ២៥ ដង ស្តេចមកដោយឧស្សាហ៍ធំ ស្តេចចូលកាន់សាលវ័ន ក្នុងវេលាល្ងាចព្រះអាទិត្យលិច ។ ព្រះរោគ ក៏មកលុបលាងកាយមិនមានរោគចេញ

អស់ ដោយប្រការដូច្នេះ ។ ដូចទ្រង់សម្តែងសេចក្តីនេះ កាលត្រាស់ព្រះវាចាឲ្យកើតសេចក្តីសង្វេគដល់សត្វលោកទាំងពួង ទើបត្រាស់ថា គិលន្តោស្មិ អានន្ទ និបជ្ជិស្សាមិ ម្នាលអានន្ទ តថាគតមានកាយលំបាកណាស់ តថាគតនឹងដេក ដូច្នេះ ។

សួរថា ក៏ព្រោះហេតុអ្វី ព្រះមានព្រះភាគ ទើបស្តេចមកក្នុងទីនេះ ដោយឧស្សាហ៍ធំ មិនអាចទៅបរិនិព្វានក្នុងទីដទៃឬ ។ ឆ្លើយថា មិនអាចទៅបរិព្វានក្នុងទីដទៃក៏ទេ តែស្តេចមកក្នុងទីនេះដោយហេតុ ៣ ប្រការ ។ ពិតហើយ ព្រះមានព្រះភាគទ្រង់ជ្រាបសេចក្តីនេះថា កាលតថាគតបរិនិព្វានក្នុងទីដទៃ **អត្តុប្បត្តិ** ហេតុកើតរឿងរបស់មហាសុទស្សនសូត្រនឹងមិនមាន តែកាលបរិនិព្វានក្នុងនគរកុសិនារា រហូតដល់បានសម្តែងសម្បត្តិ ដែលតថាគតគប្បីសោយក្នុងទេវលោក ដែលសោយហើយក្នុងមនុស្សលោក ប្រដាប់ដោយ ២ ភាណវារៈ ជនជាច្រើនស្តាប់ធម៌របស់តថាគតហើយ នឹងសម្គាល់កុសលថា គួរធ្វើ ។ មួយទៀត ទ្រង់ឃើញសេចក្តីដទៃទៀតថា កាលតថាគតបរិនិព្វានក្នុងទីដទៃ សុភទ្ទៈនឹងមិនបានចូលគាល់ ដោយសុភទ្ទៈនោះ ជាវេនេយ្យរបស់ព្រះពុទ្ធ មិនមែនជាវេនេយ្យរបស់ព្រះសាវក សាវកទាំងឡាយមិនអាចណែនាំសុភទ្ទៈនោះបាន ។ តែតថាគត បរិនិព្វានក្នុងនគរកុសិនារា សុភទ្ទៈនោះ ក៏នឹងចូលគាល់ សួរបញ្ហាបាន និងទីបំផុតការឆ្លើយបញ្ហា គេក៏នឹងតាំងនៅក្នុងសរណៈ បានបព្វជ្ជាឧបសម្បទ ក្នុង

សម្មាក់តថាគត ទទួលកម្មដ្ឋានហើយ នឹងសម្រេចព្រះអរហត្ត ជាបច្ឆិម-សាវក ក្នុងកាលតថាគតនៅមានជីវិត ។ ទ្រង់ឃើញសេចក្តីប្រការមួយទៀតថា កាលតថាគតបរិនិព្វានក្នុងទីដទៃ នឹងកើតជម្លោះ វិវាទគ្នាយ៉ាងធំក្នុងវេលាចែកព្រះធាតុ ទន្លេក៏នឹងហូរហៀរដោយឈាម តែកាលតថាគតបរិនិព្វានក្នុងនគរកុសិនារា ទោណព្រាហ្មណ៍នឹងរម្ងាប់ការវិវាទនោះ ហើយចែកព្រះធាតុទាំងឡាយ ។ គប្បីជ្រាបថា ព្រះមានព្រះភាគ ស្តេចមកក្នុងទីនេះដោយព្រះឧស្សាហ៍ធំយ៉ាងនេះ ក៏ដោយហេតុ ៣ ប្រការនេះ ។

ក្នុងពាក្យថា សីហសេយ្យំ ការដេក ៤ គឺ **កាមភោគិសេយ្យា បេតសេយ្យា សីហសេយ្យា តថាគតសេយ្យា** ។

ក្នុងសេយ្យាទាំង ៤ នោះ សេយ្យា ដែលត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ សត្វអ្នកបរិភោគកាម ដោយច្រើនដេកផ្អៀងខាងឆ្វេង នេះឈ្មោះថា **កាមភោគិសេយ្យា** ដោយថា សត្វអ្នកបរិភោគកាម ឈ្មោះថាដេកផ្អៀងខាងស្តាំដោយច្រើន មិនមាន ។

សេយ្យា ដែលត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ ដោយច្រើនពួកប្រេតដេកផ្ងារ នេះឈ្មោះថា **បេតសេយ្យា** សេចក្តីថា ព្រោះមានសាច់ និងឈាមតិច ពួកប្រេតត្រូវរាងឆ្អឹងរាំងខ្ទប់ មិនអាចដេកផ្អៀងតែម្ខាងបាន ទើបដេកផ្ងារតែម្យ៉ាង ។

**សេយ្យា** ដែលត្រាស់ទុកថា ម្នាលភិក្ខុទាំងឡាយ រាជសីហ៍ រាជា

នៃម្រឹគដេកផ្អៀងខាងស្តាំ ។ល។ មានចិត្តត្រេកអរ នេះឈ្មោះថា **សីហ-សេយ្យា** ។ សេចក្តីថា ព្រោះជាសត្វមានអំណាចច្រើន សីហៈជារាជានៃម្រឹគ ដេកដាក់ជើងមុខទាំងពីរទុកម្ខាង ដាក់ជើងក្រោយទាំងពីរទុកម្ខាង ស៊កកន្ទុយទុកត្រង់គល់ភ្លៅ កំណត់ការដាក់ជើងមុខក្រោយ និងកន្ទុយទុក ដាក់សីសៈទុកលើជើងមុខទាំង ២ សូម្បីដេកពេលថ្ងៃ កាលភ្ញាក់ ក៏ភ្ញាក់ដោយមិនតក់ស្លុត តែងើយសីសៈ ដែលដាក់ត្រួតជើងមុខជាដើម បើដាក់ខុសកន្លែងបន្តិច ក៏តូចចិត្តថា នេះមិនសមគួរដល់ជាតិ និងសេចក្តីក្លៀវក្លារបស់ខ្លួន ក៏ដេកក្នុងទីនោះទៀត មិនចេញទៅចាប់ចំណីតែកាលឃើញមិនខុសកន្លែង ក៏នឹងសប្បាយចិត្តថា នេះសមគួរដល់ជាតិនិងសេចក្តីក្លៀវក្លារបស់ខ្លួន ហើយក្រោកឡើង រលាស់បែបរាជសីហ៍រលាស់សុរង៍ក បន្លឺសីហនាទ ៣ ដង ហើយចេញទៅចាប់ចំណី ។

ចំណែកសេយ្យាក្នុងឈានទី ៤ លោកហៅថា **តថាគតសេយ្យា** ក្នុងសេយ្យាទាំងនោះ ក្នុងទីនេះសំដៅដល់សីហសេយ្យា សេចក្តីថា សីហ-សេយ្យានេះ ជាកំពូលសេយ្យា ព្រោះជាឥរិយាបថច្រើនដោយអំណាច ។

បទថា ចាទេន ចាទំ បានដល់ យកជើងឆ្វេងត្រួតលើជើងស្តាំ ។

បទថា ឧច្ចាធាយ បានដល់ តម្រួតលើគ្នា គឺ ដាក់ហួសគ្នាទៅបន្តិច ។ កាលយកថ្នាំងជើងត្រួតលើថ្នាំងជើង ឬយកជង្គង់ត្រួតលើជង្គង់ នឹងកើតវេទនាឡើង ចិត្តនឹងមិនមានអារម្មណ៍តែមួយ ការដេកមិនសប្បាយ តែ

កាលតម្រួតលើគ្នា ដោយមិនឲ្យត្រួតលើគ្នា វេទនានឹងមិនកើត ចិត្តមានអារម្មណ៍តែមួយ ការដេកនឹងសប្បាយ ព្រោះដូច្នោះ ទើបដេកយ៉ាងនេះ ។ តែក្នុងទីនេះ ព្រោះទ្រង់ចូលដល់អនុដ្ឋានសេយ្យា លោកទើបមិនពោលថា ទ្រង់មនសិការដល់ឧដ្ឋានសញ្ញា ។ ក៏ក្នុងទីនេះ គប្បីជ្រាបអនុដ្ឋាន ការមិនក្រោកឡើងដោយអំណាចព្រះសរីរកាយ ។ តែព្រះមានព្រះភាគទ្រង់មិនមានឱកាសនៃកវេង្គចិត្តផ្ទុំលក់រហូតដល់អស់រាត្រីនោះឡើយ ពិតហើយ ក្នុងបឋមយាម មានការសម្តែងធម៌ប្រោសពួកមល្លក្សត្រ , ក្នុងមជ្ឈិមយាមប្រោសសុភទ្ទៈ , ក្នុងបច្ឆិមយាមទ្រង់ឲ្យឱវាទភិក្ខុសង្ឃ , ក្នុងវេលាជិតភ្លឺស្តេចបរិនិព្វាន ។

**[១២៩]** បទថា សព្វផាលិផុល្លា សេចក្តីថា ដើមសាលៈទាំងគូមានផ្កាវីកស្គុះស្គាយដេរដាស់ទៅតាំងពីគល់ដើមរហូតដល់ចុង មិនមែនមានដើមសាលៈទាំងគូតែម្យ៉ាងប៉ុណ្ណោះ ដើមឈើសូម្បីទាំងអស់ ក៏បញ្ចេញផ្កាព្រោងព្រាត ដូចគ្នាទៅអស់ ។ មិនមែនតែក្នុងសួននោះតែម្យ៉ាងប៉ុណ្ណោះ សូម្បីក្នុងម៉ឺនចក្រវាឡទាំងអស់ ឈើផ្កាក៏បញ្ចេញផ្កា ឈើផ្លែក៏បញ្ចេញផ្លែ ។ ក្នុងដើមឈើគ្រប់ដើម មានខន្ធបទុមរីកត្រង់ដើម សាខាបទុមរីកត្រង់មែកទាំងឡាយ វល្លិ៍បទុមរីកត្រង់វល្លិ៍ អាកាសបទុមរីកលើអាកាស ទណ្ឌបទុម ជ្រែកផ្ទៃផែនដីឡើងមករីក ។ មហាសមុទ្រទាំងអស់ ដេរដាស់ទៅដោយឈូក ៥ ពណ៌ ព្រៃហិមពាន្តទំហំ ៣.០០០ យោជន៍ បានជាទី

រីកភាយក្រៃលែងណាស់ ដូចកន្ទុយសត្វក្ងោក ដែលត្រដាងជាប់គ្នាជាផ្ទាំង ដូចកម្រង និងចង្កោមផ្កាឈើ ជាប់គ្នាមិនមានចន្លោះ ដូចផ្កាឈើប្រដាប់សីសៈ ដែលចងជ្រៀតគ្នាយ៉ាងល្អ និងដូចប្រអប់ដែលមានផ្កាឈើពេញ ។ បទថា តេ តថាគតស្ស សរីរំ ឱកិរន្តិ សាលព្រឹក្សទាំងគូនោះ ត្រូវកម្មទេវតាអង្រួន ដើម មែក និងបង្កាប រោយចុះកាន់ព្រះសរីរៈព្រះមានព្រះភាគ គឺ រោយផ្កាចុះលើព្រះសរីរៈ ។ បទថា អជ្ឈោកិរន្តិ រោយភាយចុះ ដូចគ្នានឹងគ្រប ។ បទថា អភិប្បកិរន្តិ បានដល់ បាចសាចចុះញយៗ គឺ រឿយៗ ។

បទថា ទិព្វានិ បានដល់ ដែលកើតក្នុងនន្ទបោក្ខរណី ផ្កាមណ្ឌារវៈទាំងនោះ មានពណ៌ដូចជាមាស មានស្លឹកប្រមាណប៉ុនឆត្រស្លឹកឈើ ។ ជាប់រេណូប្រមាណនាឡិធំ មិនមែនផ្កាមណ្ឌារវតែម្យ៉ាងប៉ុណ្ណោះ ដែលជាទិព្វ សូម្បីយ៉ាងដទៃក៏ជាទិព្វ ដូចផ្កាបារិឆត្តក និងផ្ការលួសជាដើម បញ្ចុះប្រអប់មាសពេញ ដែលទេវតាអ្នកនៅត្រង់កណ្តាប់មាត់ចក្រវាឡក្តី ជាន់ត្រៃទសក្តី ក្នុងព្រហ្មលោកក្តី នាំចូលទៅ រមែងធ្លាក់ចុះអំពីអាកាស ។

បទថា តថាគតស្ស សរីរំ សេចក្តីថា មិនខ្ចាត់ខ្ចាយចេញក្នុងចន្លោះ មករោយភាយចំពោះព្រះសរីរៈនៃព្រះតថាគត ដោយត្របកកេសរ និងល្អងរេណូ ។

បទថា ទិព្វានិបិ ចន្ទនចុណ្ណានិ បានដល់ លំអិតចន្ទន៍របស់ពួក

ទេវតា ។ មិនមែនលំអិតចន្ទន៍ ដែលជារបស់ទេវតាប៉ុណ្ណោះ ជារបស់នាគសុបណ្ណ និងមនុស្សផង ។ មិនមែនលំអិតចន្ទន៍តែម្យ៉ាងប៉ុណ្ណោះ នៅមានកម្ទេចផង់គន្ធជាត ដែលជាទិព្វទាំងអស់ដូចជា ក្រឹស្នា និងចន្ទន៍ក្រហមជាដើម ។ លម្អងហរតាលផ្សាយឡើងប្រៀបដូចប្រាក់ និងមាស ដែលអប់ដោយក្លិនទិព្វទាំងអស់ ធ្លាក់ពេញហិបប្រាក់ និងមាសជាដើម ដែលទេវតានៅក្នុងកណ្ដាប់មាត់ចក្រវាឡជាដើម នាំចូលទៅ មិនពាល់កាយចេញក្នុងចន្លោះ រោយចុះកាន់ព្រះសរីរៈរបស់ព្រះតថាគត ដូចគ្នា ។

បទថា ទិព្វានិបិ តុរិយានិ បានដល់ គ្រឿងប្រគំរបស់ពួកទេវតា ។ មិនមែនតែគ្រឿងប្រគំទាំងនោះទេ នៅមានគ្រឿងប្រគំរបស់ពួកទេវតាក្នុងម៉ឺនចក្រវាឡ និងនាគ គ្រុឌ មនុស្ស ផ្សេងៗ ដោយប្រភេទសន្ទឹងខ្សែ ពាសស្បែកក្រាស់ និងប្រហោងគ្រប់ប្រភេទ គប្បីជ្រាបថា ប្រជុំគ្នាក្នុងចក្រវាឡតែមួយ នាំគ្នាលេងភ្លេងក្នុងអាកាស ។

បទថា ទិព្វានិបិ សង្គីតានិ សេចក្ដីថា បានឮថា ពួកទេវតាអ្នកមានអាយុវែង ឈ្មោះថា **វរុណ** ទេពវារុណទាំងនោះ ជ្រាបថា ព្រះមហាបុរសកើតក្នុងដែនដីមនុស្ស នឹងជាព្រះពុទ្ធ ហើយផ្ដើមក្រងកម្រងផ្កាដោយបំណងថា នឹងកាន់ទៅក្នុងថ្ងៃបដិសន្ធិ ។ និងទេវតានោះ កំពុងក្រងកម្រងផ្កា ជ្រាបថា ព្រះមហាបុរសកើតក្នុងគភ៌របស់មាតា ត្រូវសួរថា ពួកលោកក្រងកម្រងផ្កា ដើម្បីអ្នកណា ឆ្លើយថា នៅមិនទាន់សម្រេច ហើយ

ប្រាប់ថា ពួកយើងក្រងស្រេចហើយ នឹងយកទៅក្នុងថ្ងៃស្ដេចចេញចាកព្រះគភ៌ ហើយជ្រាបថា ទ្រង់ប្រសូតិចាកព្រះគភ៌ហើយ គិតថា នឹងទៅក្នុងថ្ងៃស្ដេចចេញមហាភិនេស្រ្កមណ៍ សូម្បីជ្រាបថា ព្រះមហាបុរសទ្រង់គ្រប់គ្រងផ្ទះ ២៩ វស្សា ហើយថ្ងៃនេះ ក៏ស្ដេចចេញមហាភិនេស្រ្កមណ៍ ហើយគិតថា នឹងទៅក្នុងថ្ងៃត្រាស់ដឹង ក៏ជ្រាបថា ទ្រង់ធ្វើសេចក្ដីព្យាយាមធំរហូតដល់អស់ ៦ វស្សា ថ្ងៃនេះក៏ត្រាស់ដឹងហើយ គិតថា នឹងទៅក្នុងថ្ងៃប្រកាសធម្មចក្រ សូម្បីជ្រាបទៀតថា ប្រថាប់ត្រង់ពោធិមណ្ឌស្ថាន ៧ សប្ដាហ៍ ស្ដេចទៅកាន់ឥសិបតនមិគទាយវ័ន ប្រកាសព្រះធម្មចក្រ ហើយគិតថា នឹងទៅថ្ងៃដែលទ្រង់សម្ដែងយមកបាដិហារ្យ ក៏ជ្រាបថា ថ្ងៃនេះទ្រង់ធ្វើយមកបាដិហារ្យរួចហើយ គិតថា នឹងទៅក្នុងថ្ងៃស្ដេចចុះអំពីទេវលោក ជ្រាបថា ថ្ងៃនេះក៏ស្ដេចចុះអំពីទេវលោកហើយ គិតថា នឹងទៅថ្ងៃទ្រង់ដាក់អាយុសង្ខារ ជ្រាបថា ថ្ងៃនេះក៏ទ្រង់ដាក់អាយុសង្ខារហើយ គិតថា នៅធ្វើមិនទាន់សម្រេច ក៏នឹងទៅក្នុងថ្ងៃបរិនិព្វាន ជ្រាបថា ថ្ងៃនេះព្រះមានព្រះភាគ ទ្រង់ផ្ទំដោយសីហសេយ្យាផ្ទៀងស្ដាំ ត្រង់ចន្លោះសាលៈទាំងគូ មានព្រះសតិសម្បជញ្ញៈ នឹងបរិនិព្វានវេលាជិតភ្លឺ មានសំឡេងសួរថា ពួកលោកក្រងកម្រងផ្កាដើម្បីអ្នកណា ក៏ពោលថា ដូចម្ដេចនេះថ្ងៃនេះឯង ព្រះមហាបុរសទ្រង់បដិសន្ធិក្នុងព្រះគភ៌របស់មាតា ថ្ងៃនេះក៏ចេញចាកព្រះគភ៌របស់មាតា ថ្ងៃនេះក៏ស្ដេចចេញមហាភិនេស្រ្កមណ៍ ថ្ងៃនេះ

ក៏ជាព្រះពុទ្ធ ថ្ងៃនេះក៏ប្រកាសព្រះធម្មចក្រ ថ្ងៃនេះក៏សម្ដែងយមកបាដិហារ្យ ថ្ងៃនេះក៏ស្ដេចចុះចាកទេវលោក ថ្ងៃនេះក៏ទ្រង់ដាក់អាយុសង្ខារ ជ្រាបថា ថ្ងៃនេះក៏ស្ដេចនឹងបរិនិព្វាន ព្រះអង្គគប្បីទ្រង់តាំងនៅត្រឹមខណៈហុតយាគូ ក្នុងថ្ងៃទី ២ ឬមិនមែនទេ ប្រការនេះ មិនសមគួរដល់ព្រះអង្គដែលទ្រង់បំពេញបារមី ១០ ហើយសម្រេចជាព្រះពុទ្ធ ចាំបាច់យើងត្រូវតែកាន់យកកម្រងផ្កាដែលនៅមិនបានសម្រេចមក កាលមិនបានឱកាសខាងក្នុងចក្រវាឡ ក៏បានបំពាក់លើកណ្ដាប់មាត់ចក្រវាឡ ហែទៅតាមកណ្ដាប់មាត់ចក្រវាឡ យកហស្ដផ្គុំនឹងហស្ដឲ្យក្រពុំ ប្រៀងប្រារព្ធព្រះរតនៈត្រៃ ប្រារព្ធមហាបុរិសលក្ខណៈ ៣២ ព្រះឆព្វណ្ណរង្សី ទសបារមី ជាតក ៥៥០ ព្រះពុទ្ធញាណ ១៤ ក្នុងទីបំផុតនៃព្រះពុទ្ធគុណនោះៗ ក៏ត្រូវលះបង់ទៅៗ ។ លោកអាស្រ័យសង្កេតៈនោះ ទើបពោលពាក្យនេះថា ធិព្វានិបិ សង្គីតានិ អន្តលិក្ខេ វជ្ជន្តិ តថាគតស្ស បូជាយ ដូច្នេះ ។

ក៏ឯព្រះមានព្រះភាគ ផ្ទំផ្ទៀងខាងស្ដាំ ចន្លោះដើមសាលព្រឹក្សទាំងគូ ទ្រង់ឃើញសេចក្ដីឧស្សាហ៍យ៉ាងធំ របស់បរិស័ទដែលប្រជុំគ្នាតាំងពីបឋវី ទៅទល់កណ្ដាប់មាត់ចក្រវាឡ និងតាំងពីកណ្ដាប់មាត់ចក្រវាឡទៅទល់ព្រហ្មលោក ទើបត្រាស់ប្រាប់ព្រះអានន្ទ ។ ដោយហេតុនោះ លោកទើបពោលថា អថខោ ភគវា អាយស្មន្តំ អានន្ទំ ។បេ។ តថាគតស្ស បូជាយ ។ គ្រាទ្រង់សម្ដែងមហាសក្ការៈយ៉ាងនេះហើយ កាលនឹងទ្រង់

សម្តែងភាពដែលព្រះអង្គជាអ្នកដែលបរិស័ទមិនសក្ការៈ ដោយមហាសក្ការៈ ទាំងនោះ ទើបត្រាស់ថា ន ខោ អានន្ទ ឯត្តាវតា ជាដើម ។

លោកអធិប្បាយទុកយ៉ាងនេះថា ម្នាលអានន្ទ តថាគតក្រាបនៅទៀបបាទមូលរបស់ព្រះពុទ្ធព្រះនាមថា ទីបង្ករ ប្រជុំធម៌ ៨ ប្រការ កាលនឹងធ្វើអភិនិហារ មិនមែនធ្វើអភិនិហារ ដើម្បីប្រយោជន៍ដល់កម្រងផ្កា របស់ក្រអូប និងគ្រឿងប្រគំ សង្គីតៈមិនមែនបំពេញបារមីទាំងឡាយ ដើម្បីប្រយោជន៍ដល់វត្ថុទាំងនោះ ព្រោះដូច្នោះ តថាគតមិនឈ្មោះថា គេបូជាហើយ ដោយការបូជាទាំងនេះឡើយ ។

សួរថា ក៏ព្រោះហេតុអ្វី ព្រះមានព្រះភាគទ្រង់សរសើរវិបាក ដែលសូម្បីព្រះពុទ្ធញាណក៏កំណត់មិនបាននៃការបូជា ដែលបុគ្គលកាន់យកត្រឹមតែផ្កាកប្បាសមួយផ្កា រឭកដល់ព្រះពុទ្ធគុណបូជាហើយ ទុកក្នុងទីដទៃ ក្នុងទីនេះ បែរជាទ្រង់ជំទាស់ការបូជាធំយ៉ាងនេះ ។ ឆ្លើយថា ព្រោះដើម្បីទ្រង់អនុគ្រោះបរិស័ទ ១ ដើម្បីប្រាថ្នានឹងឲ្យព្រះសាសនាតាំងនៅយឺនយូរ ១ ។

ពិតហើយ ព្រះមានព្រះភាគ បើមិនគប្បីជំទាស់យ៉ាងនោះសោតតទៅក្នុងអនាគត ពុទ្ធបរិស័ទក៏មិនត្រូវបំពេញសីល ក្នុងឋានៈដែលសីលមកដល់ នឹងមិនឲ្យសមាធិបរិបូរណ៍ ក្នុងឋានៈដែលសមាធិមកដល់ មិនឲ្យកាន់បន្ទប់ គឺ វិបស្សនា ក្នុងឋានៈដែលវិបស្សនាមកដល់ បបួលហើយបបួលទៀត នូវឧបដ្ឋាក ធ្វើការបូជាតែម្យ៉ាង ។ ពិតហើយ ឈ្មោះថា

អាមិសបូជានោះ មិនអាចនឹងធ្វើព្រះសាសនា សូម្បីក្នុងថ្ងៃមួយខ្វះ សូម្បីវេលាប្រមាណត្រឹមតែហុតយាគូម្តងខ្វះ ។ ពិតហើយ វិហារពាន់ ដូចមហាវិហារ ចេតិយពាន់ចេតិយ ដូចមហាចេតិយ ក៏តម្កល់ព្រះសាសនាទុកមិនបាន ។ បុណ្យអ្នកណាធ្វើទុក ក៏ជារបស់អ្នកនោះតែម្នាក់ ។ ចំណែកសម្មាបដិបត្តិ ឈ្មោះថា ការបូជាដែលសមគួរដល់ព្រះតថាគត ។ ជាការពិត បដិបត្តិបូជានោះ ឈ្មោះថា តាំងនៅហើយ អាចញុំាំងព្រះសាសនាទុកបាន ព្រោះដូច្នោះ ព្រះមានព្រះភាគ កាលនឹងទ្រង់សម្តែងបដិបត្តិបូជានោះ ទើបត្រាស់ថា យោ ខោ អានន្ទ ជាដើម ។

បណ្តាបទទាំងនោះ បទថា ធម្មានុធម្មប្បដិបន្នោ បានដល់ បដិបត្តិបុព្វភាគប្បដិបទា ដែលជាធម៌សមគួរ ។ ក៏បដិបទានុ៎ះឯង លោកហៅថា **សាមីចិ** ប្រពៃក្រៃលែង ព្រោះជាបដិបទាដែលសមគួរ ។ ឈ្មោះថា សាមីចិបដិបន្នោ ព្រោះបដិបត្តិធម៌ដ៏ប្រពៃក្រៃលែង ។ ឈ្មោះថា អនុធម្មចារី ព្រោះប្រព្រឹត្តបំពេញធម៌ដ៏សមគួរ ពោលគឺ បុព្វភាគប្បដិបទានោះឯង ។ ក៏សីល អាចារប្បញ្ញត្តិ ការសមាទានធុតង្គៈ សម្មាបដិបទាដល់គោត្រភូញាណ គប្បីជ្រាបថា បុព្វភាគប្បដិបទា ។ ព្រោះដូច្នោះ ភិក្ខុតាំងនៅក្នុងអគារវៈ ៦ ល្មើសព្រះបញ្ញត្តិ ចិញ្ចឹមជីវិតដោយអនេសនា ភិក្ខុនេះ ឈ្មោះថា មិនបដិបត្តិធម៌សមគួរដល់ធម៌ ចំណែកភិក្ខុណាមិនល្មើសសិក្ខាបទ ដែលទ្រង់បញ្ញត្តិហើយដល់ខ្លួនទាំងអស់ ដែលកម្រិត

ព្រំដែន និងខ្សែបន្ទាត់របស់ព្រះជិនស្រី សូម្បីមានប្រមាណតិច ភិក្ខុនេះ ឈ្មោះថា បដិបត្តិធម៌សមគួរដល់ធម៌ ។ សូម្បីក្នុងភិក្ខុនី ក៏ន័យនេះដូចគ្នា ។ ក៏ឧបាសកណាធ្វើវៀរវេរ ៥ អកុសលកម្មបថ ១០ ប្រព្រឹត្តទុកតម្កល់មាំ ឧបាសកនេះ ឈ្មោះថា មិនបដិបត្តិធម៌សមគួរដល់ធម៌ ។ ចំណែកឧបាសក បដិបត្តិឲ្យសម្បូរណ៍ក្នុងសរណៈ ៣ សីល ៥ សីល ១០ រក្សាឧបោសថ មួយខែ ៨ ដង ថ្វាយទាន បូជាដោយគ្រឿងក្រអូប បូជាដោយមាលា ទំនុកបម្រុងមាតាបិតា ទំនុកបម្រុងសមណព្រាហ្មណ៍ ឧបាសកនេះ ឈ្មោះថា ជាអ្នកបដិបត្តិធម៌សមគួរដល់ធម៌ សូម្បីក្នុងឧបាសិកា ក៏ន័យនេះដូចគ្នា ។

បទថា បរមាយ បូជាយ ប្រែថា ដោយបូជាខ្ពង់ខ្ពស់ ។ ព្រះមានព្រះភាគទ្រង់សម្ដែងទុកថា ពិតហើយ ឈ្មោះថា និរាមិសបូជានេះ អាចតម្កល់ព្រះសាសនារបស់តថាគតទុកបាន ។ ពិតណាស់ បរិស័ទ ៤ នេះ នឹងបូជាតថាគតដោយការបូជានេះ ត្រឹមណា សាសនារបស់តថាគត ក៏នឹងរុងរឿង ដូចព្រះច័ន្ទពេញវង់ រះឡើងកណ្ដាលផ្ទៃអាកាស ដូច្នោះ ។

## រឿង ឧបវាណភិក្ខុ

[១៣០] បទថា អបសារេសិ គឺ ចូរចេញទៅ ។ បទថា អបេហិ ប្រែថា ចូរចៀសចេញទៅ ។ ដោយព្រះតម្រាស់ តែមួយព្រះឱស្ឋប៉ុណ្ណោះ ព្រះថេរៈ ក៏ដាក់ផ្លិតស្លឹកត្នោតហើយឈរក្នុងទីម្ខាង ។ ព្រះមានព្រះភាគ

ទ្រង់សំដៅយក ការដែលព្រះអង្គមិនមានឧបដ្ឋាកប្រចាំក្នុងបឋមពោធិកាល ទើបត្រាស់ ពាក្យនេះថា ឧបដ្ឋាកោ ជាដើម ។ កាលព្រះថេរៈទូលយ៉ាង នេះថា នេះលោកម្ចាស់ឧបវាណៈ ព្រះអង្គ ។ ព្រះអានន្ទកំណត់ការដែល ព្រះឧបវាណៈមានកំហុសថា ណ្ហើយចុះ យើងនឹងក្រាបទូលសេចក្តីដែល ព្រះឧបវាណៈ

នោះ មិនមានកំហុស ព្រះមានព្រះភាគទើបត្រាស់ថា យេភុយ្យេន អានន្ទ ជាដើម ។ បណ្តាពាក្យទាំងនោះ ពាក្យថា យេភុយ្យេន នេះ លោកពោល សំដៅយកអសញ្ញីសត្វ និងអរូបទេវតាត្រូវព្រងើយ ។ បទថា អប្បដោ បានដល់ មិនសម្លឹស្ស ឬមិនបានពាល់ត្រូវ ។

បានឮថា ក្នុងចំណែកដែលជិតកៀកព្រះមានព្រះភាគ ទេវតាអ្នក មានស័ក្តិធំ និម្មិតអត្តភាពដ៏ល្អិតក្នុងឱកាសប៉ុនចុងពេមទ្រាយ ១០ៗ អង្គ ។ ខាងមុខនៃទេវតា ១០ អង្គៗ នោះ មានទេវតា ២០ អង្គៗ ។ ខាងមុខ ទេវតា ២០ អង្គៗ មានទេវតា ៣០ អង្គៗ ខាងមុខទេវតា ៣០ អង្គៗ មានទេវតា ៤០ អង្គៗ ខាងមុខទេវតា ៤០ អង្គៗ មានទេវតា ៥០ អង្គៗ ខាងមុខទេវតា ៥០ អង្គ មានទេវតាឈរគាល់ ៦០ អង្គៗ ទេវតាទាំងនោះ ជ្រៀតគ្នានិងគ្នាដោយដៃជើង ឬសំពត់ ។ មិនមានហេតុដែលនឹងគប្បី ពោលថា ចេញទៅកុំប្រៀតបៀតយើង ។ ទេវតាទាំងឡាយក៏ដូចគ្នា នឹងដែល ត្រាស់ទុកថា ម្នាលសារីបុត្រ ឯពួកទេវតាទាំងនោះ មានចំនួន ១០ អង្គខ្លះ

២០ អង្គុលិ៍ ៣០ អង្គុលិ៍ ៤០ អង្គុលិ៍ ៥០ អង្គុលិ៍ ៦០ អង្គុលិ៍ ឋិតនៅក្នុងឱកាសល្មមចាក់ដោយចុងដែកស្រួចបាន តែមិនប្រៀតបៀតដល់គ្នានឹងគ្នាឡើយ ។

បទថា ឱវារវេត្តោ គឺ ឈរបាំង ។ បានឮថា ព្រះថេរៈរាងធំដូចជាកូនដំរី ជណ្តប់សំពត់បង្សុកូល ក៏មើលទៅដូចធំសម្បើមណាស់ ។

បទថា តថាគតស្ស ឧស្សន្នាយ សេចក្តីថា ទេវតាទាំងឡាយ កាលមិនបានឃើញព្រះភក្ត្រព្រះមានព្រះភាគ ទើបតិះដៀលយ៉ាងនេះ ។ សួរថា ក៏ទេវតាទាំងនោះ មិនអាចមើលធ្លុះព្រះថេរៈឬ ។ ឆ្លើយថា មិនអាចទេ ។ ព្រោះថា ពួកទេវតាអាចមើលធ្លុះពួកបុថុជ្ជនបាន តែមើលធ្លុះពួកព្រះខីណាស្រពមិនបាន ទាំងមិនអាចចូលទៅជិតផង ។ ព្រោះព្រះថេរៈមានអានុភាពច្រើន មានអំណាចច្រើន ។ សួរថា ក៏ព្រោះហេតុអ្វីព្រះថេរៈទើបមានអំណាចច្រើន អ្នកដទៃមិនជាព្រះអរហន្តឬ ។ ឆ្លើយថា ព្រោះលោកជាអារក្ខទេវតានៅក្នុងចេតិយរបស់ព្រះពុទ្ធកស្សបៈ ។ បានឮមកថា កាលព្រះវិបស្សីសម្មាសម្ពុទ្ធបរិនិព្វានហើយ ជនទាំងឡាយបាននាំគ្នាសាងព្រះចេតិយមួយបញ្ចុះព្រះសារីរិកធាតុ សរីរៈដែលដូចគ្នានឹងដុំមាសតាន់ ។ ពិតហើយ ព្រះពុទ្ធដែលមានព្រះជន្មាយុវែង រមែងមានព្រះចេតិយតែមួយប៉ុណ្ណោះ មនុស្សទាំងឡាយប្រើផែនឥដ្ឋមាសបណ្តោយ ១ ហត្ថ ទទឹងមួយចំអាម កម្រាស់ ៨ ធ្នាប់ សាងព្រះចេតិយនោះ ភ្ជាប់ដោយហរិតាល និង

មនោសិលាជំនួសដី លាបដោយប្រេងល្ងជំនួសទឹក ហើយស្ថាបនាប្រមាណមួយយោជន៍ ។ តពីនោះ កុម្ភទេវតាក៏មួយយោជន៍ តពីនោះ ក៏អាកាសដ្ឋកទេវតា តពីនោះ ក៏ឧណ្ហវលាហកទេវតា តពីនោះ ក៏អព្ភវលាហកទេវតា តពីនោះ ក៏ទេវតាជាន់ចាតុម្មហារាជ តពីនោះ ទេវតាជាន់តាវត្តិង្ស ស្ថាបនាមួយយោជន៍ ។ ព្រះចេតិយទើបមាន ៧ យោជន៍ ដោយប្រការដូច្នេះ ។

កាលមនុស្សកាន់យកកម្រងផ្កា គ្រឿងក្រអូប និងសំពត់ជាដើមមក អារក្ខទេវតាទាំងឡាយ ក៏នាំគ្នាកាន់ផ្កាឈើមកបូជាព្រះចេតិយ ទាំងដែលមនុស្សទាំងនោះក៏បានឃើញ ។ កាលនោះ ព្រះថេរៈនេះ ជាព្រាហ្មណ៍មហាសាល កាន់សំពត់លឿងមួយផ្ទាំងទៅ ។ ទេវតាក៏ទទួលសំពត់អំពីដៃព្រាហ្មណ៍នោះទៅបូជាព្រះចេតិយ ។ ព្រាហ្មណ៍ឃើញដូច្នោះ ក៏មានចិត្តជ្រះថ្លាតាំងសេចក្ដីប្រាថ្នាថា ក្នុងអនាគតកាល សូម្បីយើងក៏នឹងជាអារក្ខទេវតាក្នុងព្រះចេតិយរបស់ព្រះពុទ្ធ បែបនេះ ដូច្នេះហើយ ចុតិអំពីអត្តភាពនោះ ក៏ទៅកើតក្នុងទេវលោក ។ កាលព្រាហ្មណ៍នោះត្រាច់អន្ទោលនៅក្នុងមនុស្សលោក និងទេវលោក ព្រះកស្សបៈដ៏មានព្រះភាគ ស្ដេចឧប្បត្តិក្នុងលោក ហើយបរិនិព្វាន ។ ព្រះធាតុសរីរៈរបស់ព្រះអង្គ ក៏មានតែមួយកន្ទែងប៉ុណ្ណោះ ។ មនុស្សទាំងឡាយនាំព្រះធាតុសរីរៈនោះ សាងព្រះចេតិយមួយយោជន៍ ។ ព្រាហ្មណ៍ ជាអារក្ខទេវតាក្នុងព្រះចេតិយនោះ កាលព្រះសាសនាអន្តរធានទៅ ក៏កើតក្នុងសួគ៌ ក្នុងកាលរបស់ព្រះមាន-

ព្រះភាគរបស់យើង ចុតិអំពីសួគ៌នោះហើយ ក៏បដិសន្ធិក្នុងត្រកូលធំ ចេញបួសហើយ សម្រេចព្រះអរហត្ត ។ គប្បីជ្រាបថា ព្រះថេរៈមានអំណាចច្រើន ព្រោះជាអារក្ខទេវតាក្នុងព្រះចេតិយមកហើយ ដោយប្រការដូច្នេះ ។

ដោយបទថា ទេវតា អានន្ទ ឧជ្ឈាយន្តិ ព្រះមានព្រះភាគទ្រង់សម្តែងថា ម្នាលអានន្ទ ពួកទេវតាតិះដៀល មិនមែនបុគ្គតថាគតមានកំហុសអ្វីដទៃទេ ។ បពិត្រព្រះអង្គ ហេតុដូចម្តេច ទើបពួកទេវតាទាំងឡាយធ្វើទុកក្នុងចិត្ត ។ ទូលសួរថា បពិត្រព្រះមានព្រះភាគ ព្រះអង្គត្រាស់ថា ពួកទេវតាតិះដៀល ក៏ពួកទេវតានោះយ៉ាងណា ទើបធ្វើទុកក្នុងចិត្ត ព្រះអង្គនឹងបញ្ឈប់ការបរិនិព្វានរបស់ព្រះអង្គឬ ។ កាលបើដូច្នោះ ព្រះមានព្រះភាគ កាលនឹងទ្រង់សម្តែងភាវៈដែលពួកទេវតាទាំងនោះ បញ្ឈប់មិនបានថា តថាគតមិនពោលហេតុនៃការបញ្ឈប់ ទើបត្រាស់ថា សន្តានន្ទ ជាដើម ។

បណ្តាបទទាំងនោះ បទថា អាកាសេ បឋវីសញ្ញិនិយោ បានដល់និម្មិតផែនដីក្នុងអាកាស មានការសម្គាល់ក្នុងអាកាសនោះថា ជាផែនដី ។ បទថា កន្ទន្តិ ប្រែថា ស្រែកយំ ។ បទថា ឆិន្នបាទំ វិយ បបតន្តិ បានដល់ រលំដួលចុះដូចជាច់ត្រង់ពាក់កណ្តាលខ្លួន ។ បទថា វិវដ្តន្តិ បានដល់ ដួលចុះរមៀលទៅ ។ ម្យ៉ាងទៀត រលំប្រមៀលទៅទីខាងមុខ ទីខាងក្រោយ ទីខាងឆ្វេង ទីខាងស្តាំ ហៅថា បម្រះននៀល ។ បទថា សន្តានន្ទ ទេវតា

បឋវិយំ បឋវីសញ្ញិនិយោ សេចក្តីថា បានឮថា ពួកទេវតាមិនអាចទប់ខ្លួននៅបានលើផែនដីប្រក្រតី ។ ពួកទេវតា រមែងលិចចុះក្នុងផែនដីនោះ ដូចហត្ថកព្រហ្ម ។ ដោយហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា ម្នាលហត្ថកៈ អ្នកចូរនិម្មិតនូវអត្តភាពយ៉ាងគ្រោតគ្រាត ។ ព្រោះដូច្នោះ លោកសំដៅយកពួកទេវតាដែលនិម្មិតផែនដីក្នុងផែនដី ទើបពោលថា ពួកទេវតាមានការសម្គាល់ក្នុងផែនដីថា ជាផែនដី ។ បទថា វីតរាគា បានដល់ ពួកទេវតាដែលជាព្រះអនាគាមី និងព្រះខីណាស្រព ដែលមានទោមនស្សលះបានហើយ ដូចគ្នានឹងសសរថ្ម ។

## ពណ៌នា សំវេជនីយដ្ឋាន ៤ កន្លែង

**[១៣១]** បទថា វស្សំ វុត្ថា សេចក្តីថា បានឮថា គ្រាពុទ្ធកាល ភិក្ខុប្រជុំគ្នា ២ ពេល គឺ ជិតចូលវស្សាដើម្បីទទួលកម្មដ្ឋាន ១ ចេញវស្សាហើយដើម្បីប្រាប់នូវគុណវិសេសដែលកើត ព្រោះការប្រកបរឿយៗនូវព្រះកម្មដ្ឋាន ដែលទទួលមកហើយ ១ ។ គ្រាព្រះពុទ្ធកាល យ៉ាងណា សូម្បីក្នុងកោះសីហឡៈក៏ដូច្នោះ ។ ភិក្ខុដែលនៅខាងត្រើយទន្លេគង្គាឯណោះ ប្រជុំគ្នាក្នុងលោហប្រាសាទ ភិក្ខុដែលនៅខាងត្រើយទន្លេគង្គាមួយទៀត ក៏

ប្រជុំគ្នាក្នុងតិស្សមហាវិហារ ។ ក្នុងភិក្ខុទាំង ២ ពួកនោះ ភិក្ខុដែលនៅខាងត្រើយទន្លេគង្គាឯណោះ កាន់យកអំបោសសម្រាប់បោសសម្រាមចោលហើយ ប្រជុំគ្នាក្នុងមហាវិហារ បូកកំបោរព្រះចេតិយ ចេញវស្សាហើយ ក៏មកប្រជុំគ្នាត្រង់លោហប្រាសាទ ធ្វើវត្តនៅក្នុងទីដែលសប្បាយ ចេញវស្សាហើយក៏មកសូត្របាលី និងអដ្ឋកថា ដែលខ្លួនជំនាញហើយក្នុងសាលារៀននិកាយទាំង ៥ ក្នុងលោហប្រាសាទ ។ ពិចារណាដល់ភិក្ខុដែលរៀនបាលីឬអដ្ឋកថា ខុសក្លាត់ថា លោករៀនក្នុងសំណាក់អ្នកណា ឲ្យកាន់យក ឲ្យត្រង់ ។ ចំណែកភិក្ខុដែលនៅម្ខាងទន្លេគង្គាទៀត ក៏ប្រជុំគ្នាក្នុងតិស្សមហាវិហារ បណ្តាភិក្ខុដែលប្រជុំគ្នា ២ ពេលយ៉ាងនេះ ភិក្ខុពួកណារៀនកម្មដ្ឋានមុនចូលវស្សា ទៅហើយត្រឡប់មកប្រាប់គុណវិសេស លោកសំដៅយកភិក្ខុបែបនោះ ទើបពោលថា បុព្វេ ភន្តេ វស្សំ វុត្ថា ជាដើម ។

បទថា មនោភាវនីយេ បានដល់ ឲ្យចម្រើនហើយ អប់រំហើយដោយចិត្ត អធិប្បាយថា ភិក្ខុពួកណាចម្រើន កពូនទូវមនោមនៈ បន្សាត់កិលេសដូចធូលី មានរាគៈជាដើមចោល ភិក្ខុបែបនោះ ។ បានឮថា ព្រះថេរៈដល់ព្រមដោយវត្ត ជួបភិក្ខុចាស់ ក៏មិនព្រមអង្គុយ ក្រោកទៅទទួលឆ័ត្រ បាត្រ ចីវរ និងគូសតាំងថ្វាយ កាលលោកអង្គុយក្នុងទីនោះហើយ ក៏ធ្វើវត្ត ចាត់សេនាសនៈថ្វាយ ជួបភិក្ខុថ្មី ក៏មិនទៅអង្គុយស្ងៀម ចូលទៅជិតៗ ព្រះថេរៈនោះ ប្រាថ្នាការមិនសាបសូន្យនៃវត្តបដិបត្តិនោះ ទើប

ពោលយ៉ាងនេះ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់ព្រះតម្រិះថា អានន្ទគិតថា យើងនឹងមិនបាន ជួបភិក្ខុដែលគួរចម្រើនចិត្ត ពេញ្ញីយចុះ តថាគតនឹងប្រាប់ស្ថានទីនឹងជួបភិក្ខុ ដែលគួរចម្រើនចិត្តដល់គេ ដែលគេមិនចាំបាច់ត្រូវត្រាច់ចរទៅមក ក៏នឹងអាចជួបភិក្ខុដែលគួរចម្រើនចិត្តបាន ដូច្នេះហើយទើបត្រាស់ថា ចត្តារិ មានិ ជាដើម ។

បណ្ដាបទទាំងនោះ បទថា សទ្ធស្ស សេចក្ដីថា វត្តទាំងអស់ មានចេតិយង្គណវត្តជាដើម ដែលលោកធ្វើតាំងពីព្រឹក រមែងប្រាកដដល់កុលបុត្រដែលមានចិត្តជ្រះថ្លាក្នុងព្រះពុទ្ធជាដើម អ្នកសម្បូរណ៍ដោយវត្ត ។ បទថា ទស្សនីយានិ បានដល់ គួរនឹងឃើញ គឺ គួរទៅដើម្បីឃើញ ។ បទថា សំវេជនីយានិ បានដល់ ឲ្យកើតសេចក្ដីស្លុតចិត្ត ។ បទថា ឋានានិ បានដល់ហេតុ ឬស្ថានទី ។ ពាក្យថា យេ ហិ កេចិ នេះ លោកពោលដើម្បីសម្ដែងដល់ការចារិកទៅក្នុងចេតិយដែលមានប្រយោជន៍ ។ បណ្ដាបទទាំងនោះ ដោយបទថា ចេតិយចារិកំ អាហិណ្ឌន្តា លោកសម្ដែងថា កាលមុនភិក្ខុណាបោសលានព្រះចេតិយ ក្នុងទីនោះ សំអាតអាសនៈ ស្រោចទឹកដើមពោធិ ហើយត្រាច់ទៅ ក្នុងភិក្ខុទាំងនោះ មិនចាំបាច់ត្រូវពោលឡើយ ។ ពួកភិក្ខុដែលចេញពីវត្តទៅ ដោយគិតថា នឹងទៅថ្វាយបង្គំព្រះចេតិយក្នុងវត្តឯណោះ មានចិត្តជ្រះថ្លា សូម្បីធ្វើកាលកិរិយាតាមផ្លូវ ក៏នឹងទៅកើតក្នុងសួគ៌ដោយមិនមានអន្តរាយឡើយ ។

## ពោលអំពី ការបដិបត្តិចំពោះមាតុគ្រាម

[១៣២] *ដោយបទថា អទស្សនំ អានន្ទ ទ្រង់សម្ដែងថា ការមិនឃើញមាតុគ្រាមសោះឡើយ ជាការបដិបត្តិដ៏សមគួរក្នុងទីនេះ ពិតហើយ ភិក្ខុបើកទ្វារ អង្គុយលើសេនាសនៈ ដរាបណាដែលមិនទាន់ឃើញមាតុគ្រាមមកឈរត្រង់មុខទ្វារ ដរាបនោះ ភិក្ខុនោះរមែងមិនកើតលោភៈ ចិត្តមិនញាប់ញ័រដោយចំណែកមួយប៉ុណ្ណោះ ។ តែកាលនៅកំពុងឃើញ ទាំង ២ យ៉ាងនោះ រមែងកើតមាន ។ ដោយហេតុនោះ ព្រះមានព្រះភាគទើបត្រាស់ថា អទស្សនំ អានន្ទ ដោយបទថា ទស្សនេ បន ភគវា សតិ កថំ ព្រះអានន្ទទូលសួរថា កាលឃើញក្នុងទីដែលភិក្ខុចូលទៅទទួលភិក្ខាជាដើម ភិក្ខុនឹងបដិបត្តិយ៉ាងណា គ្រានោះ ព្រះមានព្រះភាគត្រាស់ថា បុរសឈរកាន់ដាវ ពោលថា បើលោកនិយាយនឹងយើង យើងនឹងកាត់សីសៈលោកឲ្យដាច់ក្នុងទីនេះ ឬនាងយក្ខិនីឈរពោលថា បើលោកនិយាយនឹងយើង យើងនឹងភ្លក់សាច់លោកស៊ីក្នុងទីនេះ យ៉ាងនេះល្អជាង ព្រោះការវិនាសមានការនិយាយនោះជាបច្ច័យ រមែងមានតែក្នុងអត្តភាពមួយប៉ុណ្ណោះ មិនបានទៅសោយទុក្ខ ដែលកំណត់មិនបានក្នុងអបាយភូមិទាំងឡាយ ចំណែកកាលមានការចរចាប្រាស្រ័យជាមួយមាតុគ្រាម ការស្និទ្ធស្នាលក៏មាន កាលមានការស្និទ្ធស្នាល ទោសក៏មាន ភិក្ខុដែលមានចិត្តត្រូវរាគៈគ្របសង្កត់ ក៏ដល់*

ការវិនាសសីល ត្រូវទៅពេញក្នុងអបាយភូមិ ព្រោះដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ថា អនាលាបោ ដូច្នេះ ។ សមពិតដូចដែលលោកពោលទុកថា ៖

បុគ្គលគប្បីនិយាយជាមួយនឹងបុគ្គលមានដាវក្នុងដៃ ជាមួយ
និងបិសាច អន្ទ្បយជិតអាសេរ្ពិស អ្នកដែលត្រូវបុគ្គលមាន
ដាវ បិសាច អាសេរ្ពិស កម្ចាត់ហើយ រមែងមិនមានជីវិត
ភិក្ខុនិយាយជាមួយមាតុគ្រាមតែពីរនាក់ទល់គ្នា ក៏មិនមាន
ជីវិតដូចគ្នា ។

បទថា អាលបន្តេ បន សេចក្តីថា បើមាតុគ្រាមសួរ ថ្ងៃសូមសីល ប្រាថ្នានឹងស្តាប់ធម៌ សួរបញ្ហា ឬក៏មានកិច្ចកម្មដែលបព្វជិតត្រូវធ្វើដល់មាតុគ្រាមនោះ មាតុគ្រាមនោះ ក៏ត្រូវនិយាយនឹងភិក្ខុដែលមិននិយាយក្នុងវេលានោះយ៉ាងនេះថា ភិក្ខុអង្គនេះគួតទេដឹង ថ្ងង់ទេដឹង ឆាន់រួចហើយ អន្ទ្បយបិតមាត់ ព្រោះដូច្នោះ ភិក្ខុគប្បីនិយាយដោយពិត ។ ព្រះអានន្ទទូលសួរថា បពិត្រព្រះអង្គ កាលភិក្ខុនិយាយយ៉ាងនេះ គប្បីបដិបត្តិយ៉ាងណា ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់សំដៅយកព្រះឱវាទដែលថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរមក ត្រូវតាំងចិត្តគិតថា មាតាក្នុងស្ត្រីល្មមជាមាតា ត្រូវតាំងចិត្តថា បងប្អូនស្ត្រី ក្នុងស្ត្រីល្មមជាបងប្អូនស្ត្រី ត្រូវតាំងចិត្តគិតថា ជាកូនស្រី ក្នុងស្ត្រីល្មមជាកូនស្រី ។ ទើបត្រាស់ថា ម្នាលអានន្ទ គប្បីតាំងសតិទុក ។

[១៣៣] បទថា អត្បាវជា បានដល់ មិនពាក់ព័ន្ធ មិនរវើរវល់ ។ បទថា សទត្ថេ ឃដថ បានដល់ ព្យាយាមក្នុងព្រះអរហត្ត ដែលជាប្រយោជន៍ដ៏ខ្ពង់ខ្ពស់បំផុត ។ បទថា អនុយុញ្ជថ បានដល់ ចូរប្រកបរឿយៗ ដើម្បីសម្រេចអរហត្តនោះ ។ បទថា អប្បមត្តា បានដល់ មិនទៅប្រាសចាកសតិ ។ ឈ្មោះថា អ្នកមានព្យាយាម ព្រោះប្រកបដោយធម៌ដែលជាគ្រឿងដុតកិលេស គឺ សេចក្ដីព្យាយាម ។ ឈ្មោះថា មានខ្លួនបញ្ជូនទៅ គឺ មានចិត្តបញ្ជូនទៅ ព្រោះជាអ្នកមិនមានអាល័យក្នុងកាយ និងជីវិត ។ ដោយបទថា កថំ បន ភន្តេ ព្រះអានន្ទទូលសួរថា ជនទាំងនេះ មានក្សត្របណ្ឌិតជាដើម នឹងគប្បីបដិបត្តិយ៉ាងណា គេនឹងសាកសួរខ្ញុំព្រះអង្គដោយពិតថា លោកម្ចាស់អានន្ទ យើងខ្ញុំនឹងបដិបត្តិក្នុងសរីរៈរបស់ព្រះតថាគតយ៉ាងណា ខ្ញុំព្រះអង្គគប្បីឆ្លើយប្រាប់ពួកគេយ៉ាងណា ។ បទថា អហតេន វត្ថេន បានដល់ សំពត់ថ្មីដែលធ្វើក្នុងដែនកាសី មិនជ្រាបប្រេង ព្រោះសាច់ល្អិតម៉ត់ តែសំពត់សំឡីជ្រាប ព្រោះដូច្នោះ លោកទើបពោលថា វិហតេន កប្បាសេន ។ បទថា អយសាយ បានដល់ មាស ។ ក៏មាសលោកប្រាថ្នាយកថា អយសំ ក្នុងទីនេះ ។

## ពោលអំពី ថូបារហបុគ្គល ៤ ពួក

[១៣៤] សួរថា ក្នុងពាក្យថា រាជា ចក្កវត្តិ ហេតុអ្វី ទើបព្រះ-

មានព្រះភាគ អនុញ្ញាតការសាងសថូបដល់ព្រះរាជា ដែលនៅគ្រប់គ្រងផ្ទះ សុគតហើយ ទ្រង់មិនអនុញ្ញាតសម្រាប់ភិក្ខុដែលមានសីល ? ឆ្លើយថា ព្រោះមិនគួរអស្ចារ្យ ។ ពិតហើយ កាលទ្រង់អនុញ្ញាតសថូបសម្រាប់ភិក្ខុ បុថុជ្ជនក៏មិនមានឱកាសសម្រាប់សថូបទាំងឡាយ ក្នុងកោះសីហឡៈ សូម្បីក្នុងទីដ៏ទៃៗ ក៏ដូចគ្នា ព្រោះដូច្នោះ សថូបនោះ មិនគួរអស្ចារ្យ ព្រោះហេតុនោះ ទើបទ្រង់មិនអនុញ្ញាត ។ ស្តេចចក្រពត្តិកើតតែមួយព្រះអង្គប៉ុណ្ណោះ ដោយហេតុនោះ សថូបរបស់ព្រះអង្គទើបអស្ចារ្យ ។ ចំណែកភិក្ខុបុថុជ្ជនអ្នកមានសីល នឹងធ្វើសក្ការៈសូម្បីយ៉ាងធំ ដូចយ៉ាងភិក្ខុដែលបរិ-និព្វាន ក៏គួរដូចគ្នា ។

## ពោលអំពី គុណរបស់ព្រះអានន្ទ

**[១៣៥]** ចំណែករោងមូល លោកប្រាថ្នាយកថា វិហារក្នុងពាក្យថា វិហារនេះ ។ ចូលទៅកាន់វិហារនោះ ។ បទថា កបិសីសំ បានដល់ ឈើនេក ដែលតាំងនៅក្នុងទីចុងសន្ទះទ្វារ ។ បទថា រោទមានោ អដ្ឋាសិ សេចក្តីថា បានឮថា ព្រះអានន្ទគិតថា ព្រះសាស្តាត្រាស់ស្ថានទីនៅ ដែលឲ្យកើតសេចក្តីសង្វេគដល់យើង ត្រាស់ការចារិកទៅក្នុងចេតិយថា មានប្រយោជន៍ ត្រាស់ឆ្លើយបញ្ហារឿងដែលនឹងគប្បីបដិបត្តិក្នុងមាតុគ្រាម ត្រាស់ប្រាប់ការបដិបត្តិក្នុងសរីរៈរបស់ព្រះអង្គ ត្រាស់ថូបារហបុគ្គល ៤ ពួក

ថ្ងៃនេះព្រះមានព្រះភាគបរិនិព្វានហើយ ។ កាលលោកគិតយ៉ាងនេះហើយ ក៏កើតទោមនស្សយ៉ាងខ្លាំងក្លា ។ គ្រានោះ លោកបរិវិតក្កៈយ៉ាងនេះថា ឈ្មោះថា ការស្រែកយំក្នុងទីជិតព្រះមានព្រះភាគមិនជាសុខ យើងនឹងទៅក្នុងទីដទៃមួយ បន្ទោបង់សេចក្ដីសោកឲ្យស្រាលខ្លះ ។ លោកបានធ្វើដូចយ៉ាងនោះ ។ ដោយហេតុនោះ លោកទើបពោលថា ព្រះអានន្ទឈរស្រែកយំ ។ បទថា អហាញ្ច វតម្ហិ កាត់ជា អហំ ច វត អម្ហិ ។ បាលីថា អហំ វតម្ហិ ដូច្នេះក៏មាន ។ បទថា យោ មម អនុកម្បកោ គឺ អ្នកណាអនុគ្រោះទូន្មានប្រៀនប្រដៅយើង ។ បានឮមកថា តាំងពីថ្ងៃស្អែកនេះ ឥឡូវនេះ យើងនឹងថ្វាយទឹកសម្រាប់លាងព្រះភក្ត្រដល់អ្នកណា និងទឹកលាងព្រះបាទដល់អ្នកណា នឹងបដិបត្តិសេនាសនៈដល់អ្នកណា នឹងទទួលបាត្រ និងចីវររបស់អ្នកណា ចារិកទៅ ។

បទថា អាមន្តេសិ បានដល់ មិនឃើញព្រះថេរៈក្នុងចន្លោះ ទើបត្រាស់ហៅ ។ បទថា មេត្តេន កាយកម្មេន បានដល់ ដោយកាយកម្ម មានការថ្វាយទឹកលាងព្រះភក្ត្រជាដើម ដែលបដិបត្តិទៅដោយអំណាចចិត្តមានមេត្តា ។ បទថា ហិតេន បានដល់ ដែលធ្វើទៅដើម្បីសេចក្ដីចម្រើននៃប្រយោជន៍ ។ បទថា សុខេន បានដល់ ដែលធ្វើទៅដោយអំណាចសុខកាយ សុខចិត្ត ។ អធិប្បាយថា មិនមានទុក្ខកាយទុក្ខចិត្ត ។ បទថា អទ្វយេន បានដល់ មិនធ្វើឲ្យជា ២ ចំណែក ។ លោកអធិប្បាយថា ធ្វើ

ចំពោះមុខ មិនធ្វើកំបាំងមុខយ៉ាងណាមួយ ធ្វើកំបាំងមុខ មិនធ្វើចំពោះមុខយ៉ាងណាមួយ មិនធ្វើការបែងចែកយ៉ាងនោះ ។ បទថា អប្បមាណេន បានដល់ វៀរចាកប្រមាណ ។ ទ្រង់សម្តែងថា ពិតណាស់ សូម្បីចក្រវាឡចង្អៀតណាស់ សូម្បីភវគ្គព្រហ្មក៏ទាបណាស់ ព្រោះកាយកម្មដែលលោកធ្វើមក ។ បទថា មេត្តេន វចីកម្មេន បានដល់ វចីកម្ម មានការប្រាប់វេលាលាងព្រះភក្ត្រជាដើម ដែលបដិបត្តិទៅដោយអំណាចនៃចិត្តប្រកបមេត្តា ។ ម្យ៉ាងទៀត សូម្បីស្តាប់ឱវាទហើយទូលថា សាធុ ភន្តេ ប្រពៃហើយព្រះអង្គ ។ ចាត់ជាមេត្តាវចីកម្មដូចគ្នា ។ បទថា មេត្តេន មនោកម្មេន សេចក្តីថា ដោយមនោកម្ម ដែលបដិបត្តិពីព្រឹកព្រលឹម ហើយអង្គុយលើអាសនៈដ៏ស្ងាត់ ហើយបដិបត្តិយ៉ាងនេះថា សូមព្រះសាស្តា ព្រះអង្គកុំមានរោគ កុំមានទុក្ខបៀតបៀន ចូរស្តេចនៅជាសុខចុះ ។ ដោយពាក្យថា កតបុញ្ញោសិ ទ្រង់សម្តែងថា លោកជាអ្នកដល់ព្រមដោយអភិនិហារ (បុណ្យចាស់) រហូតអស់សែនកប្ប ។ ដោយបទថា កតបុញ្ញោម្ហិ ទ្រង់សម្តែងថា ដោយហេតុត្រឹមតែប៉ុណ្ណេះ លោកកុំដាក់ចិត្តប្រមាទ ដោយពិត ចូរប្រកបសេចក្តីព្យាយាមរឿយៗ លោកប្រកបសេចក្តីព្យាយាមរឿយៗ យ៉ាងនេះហើយ នឹងជាអ្នកមិនមានអាសវៈដោយឆាប់រហ័ស នឹងសម្រេចព្រះអរហត្តក្នុងវេលាសង្គាយនាធម៌ ក៏ការប្រតិបត្តិ ដែលលោកធ្វើចំពោះព្រះពុទ្ធដូចជា តថាគតឈ្មោះថា មិនមែនឥតផល ។ ក៏គ្រាត្រាស់យ៉ាងនេះហើយ

ទ្រង់ផ្ដើមពណ៌នាគុណរបស់ព្រះអានន្ទ ដូចជាផ្សាយទូទៅទាំងមហាបឋវី ដូចជាផ្សាយទូទៅទាំងអាកាស ដូចជាលើកឡើងកាន់កំពូលចក្រវាឡគីរី ដូចជាលើកភ្នំសិនេរុ ដូចជាចាប់អង្រួនដើមព្រីងធំ គ្រានោះឯង ព្រះមាន-ព្រះភាគ ទើបត្រាស់ហៅភិក្ខុទាំងឡាយ ។

ក្នុងព្រះបាលីនោះ ព្រោះហេតុអ្វី ព្រះមានព្រះភាគទើបមិនត្រាស់ថា យេបិតេ ភិក្ខវេ ឯតរហិ ។ ព្រោះព្រះពុទ្ធព្រះអង្គដទៃៗ មិនមាន ។ តែគប្បីជ្រាបពាក្យនោះ ដោយព្រះបាលីនេះថា ព្រះពុទ្ធអង្គដទៃៗ សូម្បីក្នុងចន្លោះនៃចក្រវាឡមិនមាន យ៉ាងណា ។ បទថា បណ្ឌិតោ ប្រែថា វាងវៃ ។ បទថា មេធាវី បានដល់ ឆ្លាតក្នុងធម៌មានខន្ធ ធាតុ និងអាយតនៈជាដើម ។

[១៣៦] បទថា ភិក្ខុបរិសា អានន្ទំ ឧបសង្កមាយ សេចក្ដីថា ជនពួកណា ប្រាថ្នានឹងគាល់ព្រះមានព្រះភាគ ចូលទៅរកព្រះថេរៈ និងជនពួកណាមក បានឮគុណរបស់ព្រះថេរៈថា បានឮថា ព្រះអានន្ទគួរជ្រះថ្លាសព្វទីកន្លែង គួរសរសើរ ជាពហុស្សូត អ្នកល្អក្នុងសង្ឃ លោកសំដៅយកជនទាំងនោះ ទើបពោលថា ភិក្ខុបរិស័ទចូលទៅជួបព្រះអានន្ទ ។ ក្នុងបទទាំងពួងក៏មានន័យនេះ ។ បទថា អត្តមនា ឈ្មោះថា មានចិត្តជារបស់ខ្លួន គឺមានចិត្តត្រេកអរ ព្រោះឃើញសមដោយការស្ដាប់មក ។ បទថា ធម្មំ បានដល់ ធម៌ គឺ បដិសណ្ឋារៈបែបនេះថា អ្នកមានអាយុ ល្មមទ្រាំបានឬ ល្មមប្រព្រឹត្តទៅបានឬ លោកចូរធ្វើកិច្ចដោយយោនិសោមនសិការ ចូរបំពេញ

អាចរិយវត្ត និងឧបជ្ឈាយវត្ត ។ ក្នុងធម៌ គឺ បដិសណ្ឋារៈនោះ មានការធ្វើដែលផ្សេងគ្នាក្នុងភិក្ខុនីទាំងឡាយដូច្នេះថា ភិក្ខុនី ទាំងឡាយ ៤ ពួក លោកសមាទានប្រព្រឹត្តគរុធម៌ ៨ ខ្លះទេឬ ។ កាលឧបាសកទាំងឡាយមក មិនធ្វើបដិសណ្ឋារយ៉ាងនេះថា លោកមិនមានអាពាធសិសៈឬ អវយវៈខ្លះឬ ។ តែនឹងធ្វើបដិសណ្ឋារៈយ៉ាងនេះថា លោក ឧបាសកទាំងឡាយ សរណៈ ៣ ដូចម្ដេច លោករក្សាសីល ៥ រក្សាសីល ឧបោសថមួយខែ ៨ ដង ចូរធ្វើវត្ត គឺ ការទំនុកបម្រុងមាតាបិតា ចូរបដិបត្តិសមណព្រាហ្មណ៍ អ្នកតាំងនៅក្នុងធម៌ ។ ក្នុងឧបាសិកាទាំងឡាយ ក៏ន័យនេះដូចគ្នា ។

ឥឡូវនេះ កាលនឹងទ្រង់ធ្វើការប្រៀបធៀបនឹងស្ដេចចក្រពត្តិចំពោះព្រះអានន្ទត្ថេរ ទើបត្រាស់ថា ចត្តារោមេ ភិក្ខវេ ជាដើម ។ បណ្ដាបទទាំងនោះ បទថា ខត្តិយា បានដល់ ជាតិជាក្សត្រអ្នកបានទទួលមុទ្ធាភិសេក និងមិនបានទទួលមុទ្ធាភិសេក ។ បានឮថា ក្សត្រទាំងនោះ ស្ដាប់ពាក្យពណ៌នាគុណរបស់ចក្រពត្តិនោះថា ធម្មតាថា ស្ដេចចក្រពត្តិល្អ គួរសរសើរគួរជ្រះថ្លា សញ្ចរទៅបានតាមអាកាស ឡើងគ្រងរាជ្យសម្បត្តិ ទ្រទ្រង់ធម៌ជាធម្មរាជាដូច្នេះ រមែងសប្បាយចិត្ត ក្នុងកាលបានឃើញ សមដោយបានឮព្រះគុណ ។ បទថា ភាសតិ បានដល់ ទ្រង់ធ្វើបដិសណ្ឋារៈថា បាអើយយ៉ាងណាហៅថា បំពេញរាជធម៌ យ៉ាងណាហៅថា រក្សាប្រពៃណី ។ តែក្នុងព្រាហ្មណ៍ទាំងឡាយ ទ្រង់ធ្វើបដិសណ្ឋារយ៉ាងនេះថា លោកអាចារ្យ

យ៉ាងណា ឈ្មោះថា បង្រៀនមន្ត ពួកសិស្សក៏រៀនមន្ត ពួកលោកចូរធ្វើទក្ខិណា សំពត់ ឬគោក្របាម ។ ក្នុងគហបតីទាំងឡាយ ទ្រង់ធ្វើបដិសណ្ឋារៈយ៉ាងនេះថា បាអើយ ពួកលោកមិនត្រូវបៀតបៀនដោយអាជ្ញា ឬដោយពន្ធដារអាករអំពីព្រះរាជាមានខ្វះឬ ភ្លៀងធ្លាក់ត្រូវតាមរដូវកាលទេ ស្រូវអង្ករសម្បូរណ៍ទេ ។ ក្នុងសមណៈទាំងឡាយ ក៏ទ្រង់ធ្វើបដិសណ្ឋារៈយ៉ាងនេះថា លោកម្ចាស់ បរិក្ខារសម្រាប់បព្វជិតរកបានងាយទេ ពួកលោកកុំប្រមាទក្នុងសមណធម៌ ។

## ពោលអំពី រាជធានីឈ្មោះកុសាវតី

**[១៣៧]** បទថា ខុទ្ទកនគរកេ បានដល់ នគរតូច ដែលចង្អៀតជានគរដែលត្រូវរីកចម្រើន ។ បទថា ឧជ្ជង្គលនគរកេ បានដល់ នគរដែលមានផែនដីមិនរាបស្មើ ។ បទថា សាខនគរកេ បានដល់ នគរតូចដូចជាសាខារបស់នគរធំដទៃ ដូចមែកតូចៗ របស់ដើមឈើទាំងឡាយដូច្នោះ ។ បទថា ខត្តិយមហាសាលា បានដល់ ព្រះមហាក្សត្រជាខត្តិយមហាសាល ។ ក្នុងបទទាំងពួងក៏ន័យនេះ ។ បណ្តាមហាសាលទាំងនោះ ដែលឈ្មោះថា **ខត្តិយមហាសាល** បានដល់ ពួកក្សត្រដែលរក្សាទ្រព្យទុករយកោដិខ្វះ ពាន់កោដិខ្វះ ចំណាយកហាបណៈប្រចាំថ្ងៃ មួយថ្ងៃ ១ រទេះ ពេលល្ងាចកហាបណៈចូលមកវិញមួយថ្ងៃ ២ រទេះ ។ ដែល

ឈ្មោះថា **ព្រាហ្មណមហាសាល** បានដល់ ពួកព្រាហ្មណ៍ដែលមានទ្រព្យ ៨០ កោដិ ចំណាយកហាបណៈទៅមួយថ្ងៃ ១ កុម្ភៈ ពេលល្ងាចទទួលចូលមកវិញមួយថ្ងៃ ១ រទេះ ។ ដែលឈ្មោះថា **គហបតីមហាសាល** បានដល់ ពួកគហបតី ដែលមានទ្រព្យសម្បត្តិ ៤០ កោដិ ចំណាយកហាបណៈរៀងរាល់ថ្ងៃ មួយថ្ងៃ ៥ អម្ពណៈ ពេលល្ងាចទទួលចូលមកវិញ មួយថ្ងៃ ១ កុម្ភៈ ។

បទថា មា ហេវំ អានន្ទ អវច បានដល់ អានន្ទ អ្នកកុំនិយាយយ៉ាងនោះ ។ ព្រះមានព្រះភាគត្រាស់ថា អ្នកមិនគួរនិយាយថា នគរនេះតូច សេចក្ដីពិត តថាគតមកកាន់នគរនេះ ដោយសេចក្ដីឧស្សាហ៍យ៉ាងធំ ដោយសេចក្ដីតស៊ូព្យាយាមយ៉ាងខ្លាំងក្លា ឈរ អង្គុយ ច្រើនដង ក៏ដើម្បីនឹងពោលដល់សម្បត្តិរបស់នគរនេះដោយពិត ទើបត្រាស់ថា ភូតបុព្វំ ជាដើម ។

បទថា សុភិក្ខា បានដល់ សម្បូរណ៍ដោយរបស់ទំពារ និងរបស់បរិភោគ ។ បទថា ហត្ថិសទ្ទេន សេចក្ដីថា កាលដំរីមួយស្រែកឡើង ដំរី ៨៤,០០០ ក៏ស្រែកតាម ដូច្នោះ កុសាវតីរាជធានី ទើបមិនស្ងាត់នូវសំឡេងដំរី ។ សំឡេងសេះក៏ដូចគ្នា ។ ក៏សត្វទាំងឡាយក្នុងរាជធានីនេះ មានបុណ្យ មានរថដែលទឹមដោយសេះសិន្ធព ៤ តាមគ្នានិងគ្នា សញ្ចរទៅក្នុងផ្លូវថ្នល់ ដូច្នោះ ទើបឈ្មោះថា មិនស្ងាត់ដោយសំឡេងរថ ។ មួយទៀត

គ្រឿងប្រគំ មានស្គរជាដើម ក្នុងនគរនោះ ក៏គោះរណ្តំគ្នាជានិច្ច ។ ដូច្នោះទើបឈ្មោះថា មិនស្ងាត់អំពីសំឡេងស្គរជាដើម ។ បណ្តាបទទាំងនោះ បទថា សម្មសទ្ទោ បានដល់ សំឡេងរគាំង ។ បទថា តាលសទ្ទោ បានដល់ សំឡេងត្នោតដែលគោះដោយដៃ និងគ្រាប់ត្នោតរាងបួនជ្រុង ។ អាចារ្យខ្លះពោលថា កូដភេរិសទ្ទោ សំឡេងកូងទ្រ ដូច្នេះក៏មាន ។ បទថា អសថ បិវថ ខាទថ ប្រែថា ចូរស៊ី ចូរផឹក ចូរទំពារ ។ ក៏ក្នុងរឿងនេះ មានសេចក្តីសង្ខេបដូច្នេះ ។ កុសាវតីរាជធានី មិនស្ងាត់ចាកសំឡេងទាំងទី ១០ នេះថា អញ្ជើញបរិភោគចុះ លោកដ៏ចម្រើន មានសំឡេងមិនដាច់ឡើយ ។ ព្រះមានព្រះភាគ ទ្រង់សម្តែងថា ក្នុងនគរដទៃៗ មានសំឡេងបែបនេះថា ពួកអ្នកចូរបោលសម្រាម ចូរកាន់ចប ចូរកាន់កន្ត្រក យើងនឹងទៅមួយយប់ ពួកអ្នកចូរកាន់កញ្ចប់អង្ករ ចូរកាន់កញ្ចប់បាយ ចូរឲ្យចាត់ចែងខែល និងអាវុធដូច្នេះ យ៉ាងណា ក្នុងកុសាវតីនេះ មិនមានសំឡេងបែបនេះ ដូច្នោះទេ ។ ក៏ត្រាស់ថា ចាកសំឡេងទី ១០ ដូច្នេះហើយ ទ្រង់បញ្ចប់មហាសុទស្សនសូត្រ ទាំងអស់ថា ម្នាលអានន្ទ កុសាវតីរាជធានី ហោមព័ទ្ធជុំវិញដោយកំពែង ៧ ជាន់ ទើបត្រាស់ថា គច្ឆ ត្វំ អានន្ទ ដូច្នេះជាដើម ។

បណ្តាបទទាំងនោះ បទថា អភិក្កមថ សេចក្តីថា ពួកលោកចូរឈានមកខាងមុខ ។ សួរថា ក៏ពួកមល្លក្សត្រនៃក្រុងកុសិនារា ទ្រង់មិន

ក្រាបថា ព្រះមានព្រះភាគស្ដេចមកទេឬ ។ ឆ្លើយថា ទ្រង់ក្រាប ។ ធម្មតាថា ក្នុងស្ថានទីដែលព្រះពុទ្ធទាំងឡាយស្ដេចយាងទៅ រមែងកោលាហលច្រើន ទាំងដែលស្ដេចមិនទាន់មក ក៏ព្រោះទ្រង់ប្រជុំគ្នាដោយករណីយ៍យ៉ាងណាមួយ ។ ព្រះមានព្រះភាគទ្រង់ក្រាបថា ពួកមល្លក្សត្រទាំងនោះមកហើយ នឹងត្រូវបាត់ឱកាសដែលឈរ ដែលអង្គុយ ថ្វាយដល់ភិក្ខុសង្ឃ ទើបបញ្ជូនព្រះអានន្ទទៅកាន់សម្នាក់របស់មល្លក្សត្រទាំងនោះ សូម្បីក្នុងវេលាដែលមិនគួរ ។ **នោ** អក្សរក្នុងពាក្យថា **អម្ហាកំ ច នោ** នេះ ត្រឹមតែជានិបាត ។ បទថា អឃាវិនោ បានដល់ អ្នកកើតទុក្ខ ។ បទថា ចេតោទុក្ខសមប្បិតា បានដល់ អ្នកពោរពេញដោយទោមនស្ស ។ បទថា កុលបរិវត្តសោ កុលបរិវត្តសោ ឋបេត្វា សេចក្ដីថា ពួកមល្លក្សត្រជាត្រកូលៗ គឺ សន្និបថា ត្រកូលជាចំណែកៗ ដោយនៅជួល់តែមួយរួមគ្នា និងប្រកផ្លូវតែមួយរួមគ្នា ។

## រឿងសុភទ្ទបរិព្វាជក

**[១៣៨]** បទថា សុភទ្ទោ ឆាម បរិព្វាជកោ បានដល់ បរិព្វាជកអ្នកស្លៀកដណ្ដប់សំពត់ អំពីត្រកូលឧទិច្ចព្រាហ្មណមហាសាល ។ បទថា កង្ខាធម្មោ បានដល់ ធម៌ គឺ សេចក្ដីងឿងឆ្ងល់ ។ សួរថា ក៏ព្រោះហេតុអ្វីសុភទ្ទបរិព្វាជកនោះ ទើបមានការគិតយ៉ាងនេះ ក្នុងថ្ងៃនេះ ។ ឆ្លើយថា

ព្រោះមានឧបនិស្ស័យយ៉ាងនោះ ។ បានឮថា អំពីមុនមានបងប្អូន ២ នាក់ក្នុងការបំពេញបុណ្យ ។ បងប្អូន ២ នាក់នោះ បានធ្វើស្រែរួមគ្នា ក្នុង ២ នាក់នោះ បងប្រុសគិតថា យើងនឹងថ្វាយទានស្រូវដ៏ប្រសើរមួយឆ្នាំ ៩ ដង ។ វេជ្ជសាបព្រោះ ថ្វាយគ្រាប់ដ៏ប្រសើរ ។ ក្នុងវេជ្ជស្រូវផើម ប្រឹក្សានឹងប្អូនប្រុសថា នឹងបកស្រូវផើមថ្វាយ ។ ប្អូនប្រុសប្រាប់ថា បងត្រូវការនឹងឲ្យស្រូវខ្ចីវិនាសឬ ។ បងប្រុសដឹងថា ប្អូនប្រុសមិនយល់ព្រម ទើបបែងចែកស្រែគ្នា បកស្រូវផើមដែលជាចំណែករបស់ខ្លួន រម្ងាស់យកទឹកដោះ ផ្សំដោយទឹកដោះថ្លា និងទឹកអំពៅ ។ ក្នុងវេជ្ជស្រូវលីងអំបុកបានក៏ឲ្យធ្វើអំបុកថ្វាយ ។ ក្នុងវេលាច្រូត ក៏បានថ្វាយបាយដ៏ប្រសើរ ។ ក្នុងវេលាចងកណ្ដាប់ ក៏បានថ្វាយបាយដ៏ប្រសើរក្នុងវេលាចងកណ្ដាប់ ។ ក្នុងវេលាធ្វើជាកណ្ដាប់ជាដើម ក៏បានថ្វាយបាយដ៏ប្រសើរក្នុងវេលាធ្វើកណ្ដាប់ ។ បាយដ៏ប្រសើរ ខណៈជញ្ជូនទុកក្នុងលាន ។ បាយដ៏ប្រសើរ ខណៈបោកបែន ។ បាយដ៏ប្រសើរ ក្នុងខណៈនៅក្នុងជង្រុក ។ បានថ្វាយទានដ៏ប្រសើរក្នុងស្រូវមួយឆ្នាំ ៩ ដង ដូចពោលមកនេះ ។ ចំណែកប្អូនប្រុស ធ្វើស្រែសម្រេចហើយ ទើបបានថ្វាយ ។ ក្នុងបងប្អូន ២ នាក់នោះ បងប្រុសកើតជាព្រះអញ្ញាកោណ្ឌញ្ញត្ថេរ ។ ព្រះមានព្រះភាគទ្រង់ពិចារណាមើលថា តថាគតនឹងគប្បីសម្ដែងធម៌ប្រោស ដល់អ្នកណាមុនហ្ន៎ ទើបទ្រង់ព្រះចិន្ដាថា ព្រះអញ្ញាកោណ្ឌញ្ញៈ បានថ្វាយទានដ៏ប្រសើរ ក្នុងស្រូវមួយឆ្នាំ ៩ ដង តថាគត

នឹងសម្តែងធម៌ដ៏ប្រសើរនេះ ដល់គេ ទើបទ្រង់សម្តែងប្រោសមុនអ្នកដទៃទាំងអស់ ។ លោកតាំងនៅក្នុងសោតាបត្តិផល ព្រមនឹងព្រហ្ម ១៨ កោដិ ។ ចំណែកប្អូនប្រុសពន្យាគិតយ៉ាងនេះ ក្នុងវេលាព្រះសាស្តាបរិនិព្វាន ព្រោះថ្វាយទានខាងក្រោយ ទើបបានជាអ្នកមានសេចក្តីប្រាថ្នានឹងគាល់ព្រះសាស្តា ។

បទថា មា ភគវន្តំ វិហេឋេសិ សេចក្តីថា បានឮថា ព្រះថេរៈយល់ថា ដែលឈ្មោះថា អន្យតិរ្ថិយ៍ទាំងនោះ ឃើញដល់ខ្លួនទាំងនោះ កាលព្រះមានព្រះភាគត្រាស់ច្រើនៗ ដើម្បីប្រយោជន៍ដល់ការដោះស្រាយបញ្ហានោះ ក៏ទ្រង់នឹងលំបាកទាំងផ្លូវកាយ និងវាចា សេចក្តីថា ដោយប្រក្រតីព្រះមានព្រះភាគទ្រង់លំបាកហើយ ទើបពោលយ៉ាងនេះ ។ បរិព្វាជកក៏តាមចិត្តព្រះថេរៈដោយគិតថា ភិក្ខុរូបនេះ មិនឲ្យឱកាសដល់យើងដែលត្រូវការប្រយោជន៍ ក៏បានតែតាមចិត្ត ទើបពោល ២-៣ ដង ។ បទថា អស្សោសិ ខោ សេចក្តីថា កាលព្រះថេរៈឈរនិយាយនៅជិតទ្វាររាំងននព្រះមានព្រះភាគ ទ្រង់បានឮដោយព្រះសោតតាមប្រក្រតី ។ ក៏ឯកាលឮហើយ ទើបត្រាស់ថា អលំ អានន្ទ ជាដើម ព្រោះព្រះអង្គស្តេចមកដោយឧស្សាហ៍ធំ ដើម្បីប្រោសសុភទ្ទៈនុ៎ះឯង ។ ស័ព្ទថា អលំ ក្នុងពាក្យថា អលំ អានន្ទ នោះ ជានិបាត ។ បានក្នុងអត្ថថា បដិសេធ ។ បទថា អញ្ញាបេក្ខោ វ ប្រែថា ជាអ្នកប្រាថ្នានឹងដឹង ។

បទថា អត្តញ្ញឹសុ បានដល់ ដឹងដូចដែលម្ចាស់លទ្ធិទាំងនោះបដិញ្ញា ។

លោកអធិប្បាយថា បដិញ្ញានោះ របស់ម្ចាស់លទ្ធិទាំងនោះ ជានិយ្យានិកៈ សោត ពួកគេទាំងអស់ក៏ដឹងទូទៅ បើបដិញ្ញារបស់ពួកគេមិនមែនជានិយ្យានិកៈ ពួកគេក៏មិនដឹង ព្រោះដូច្នោះ បដិញ្ញារបស់ម្ចាស់លទ្ធិទាំងនោះ ជានិយ្យានិកៈ ឬមិនជានិយ្យានិកៈ ។ សេចក្តីនៃបញ្ហានោះ មានយ៉ាងនេះប៉ុណ្ណោះ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់បដិសេធថា កុំឡើយ ព្រោះមិនជាឋានៈណាមួយ ព្រោះមិនមានឱកាសណាមួយ ដោយការត្រាស់ដល់សេចក្តី ដែលបដិញ្ញារបស់ម្ចាស់លទ្ធិទាំងនោះ មិនមែនជានិយ្យានិកៈ ទើបទ្រង់សម្តែងធម៌តែម្យ៉ាង ។ ព្រះមានព្រះភាគ ស្តេចមកដោយព្រះពុទ្ធបំណងថា ទ្រង់នឹងសម្តែងធម៌ប្រោសពួកមល្លក្សត្រពេលបឋមយាម សម្តែងធម៌ប្រោសសុភទ្ទៈពេលមជ្ឈិមយាម ទូន្មានភិក្ខុសង្ឃពេលបច្ឆិមយាម ស្តេចបរិនិព្វានក្នុងវេលាជិតភ្លឺ ។

បទថា សមណោបិ តត្ថ ន ឧបលព្ភតិ សេចក្តីថា ក្នុងធម្មវិន័យនោះ មិនមានសូម្បីសមណៈទី ១ គឺ ព្រះសោតាបន្ន សូម្បីសមណៈទី ២ គឺ ព្រះសកទាគាមី សូម្បីសមណៈទី ៣ គឺ ព្រះអនាគាមី សូម្បីសមណៈទី ៤ គឺ ព្រះអរហន្ត ក៏មិនមានក្នុងធម្មវិន័យនោះ ។ ព្រះមានព្រះភាគត្រាស់ដោយមិនកំណត់ទេសនាខាងដើម ឥឡូវនេះ កាលទ្រង់កំណត់សាសនារបស់ព្រះអង្គ ទើបត្រាស់ថា ឥមស្មឹ ខោ ជាដើម ។ បទថា សុញ្ញា បរប្បវាទា សមណេភិ សេចក្តីថា បរប្បវាទៈ ( លទ្ធិរបស់ម្ចាស់លទ្ធិ

ដទៃ ) សូន្យទទេចាកសមណៈ ១២ ពួក គឺ អ្នកផ្តើមវិបស្សនាដើម្បី ប្រយោជន៍ដល់មគ្គ ៤ រូប ៤ ពួក អ្នកតាំងនៅក្នុងមគ្គ ៤ ពួក អ្នកតាំងនៅក្នុងផល ៤ ពួក ។ បទថា ឥមេ ច សុភទ្ទ សេចក្តីថា ភិក្ខុទាំង ១២ ពួកនេះ ។ ក្នុងពាក្យថា សម្មា វិហារេយ្យុំ ព្រះសោតាបន្នប្រាប់ឋានៈ ដែលខ្លួនសម្រេចដល់អ្នកដទៃ ធ្វើអ្នកដទៃនោះឲ្យជាសោតាបន្ន ឈ្មោះថា នៅដោយប្រពៃ ។ ក្នុងព្រះសកទាគាមីជាដើម ក៏ន័យនេះ ។ ភិក្ខុតាំងនៅក្នុងសោតាបត្តិមគ្គធ្វើ សូម្បីអ្នកដទៃឲ្យជាអ្នកតាំងនៅក្នុងសោតាបត្តិមគ្គ ក៏ឈ្មោះថា នៅដោយប្រពៃ ។ ក្នុងភិក្ខុតាំងនៅក្នុងមគ្គដែលនៅសល់ ក៏ន័យនេះ ។ ភិក្ខុផ្តើមវិបស្សនា ដើម្បីសោតាបត្តិមគ្គ កំណត់កម្មដ្ឋានដែលខ្លួនស្ទាត់ជំនាញ សូម្បីធ្វើអ្នកដទៃ ឲ្យជាអ្នកផ្តើមវិបស្សនាដើម្បីសោតា-បត្តិមគ្គក៏ឈ្មោះថា នៅដោយប្រពៃ ។ ក្នុងភិក្ខុផ្តើមវិបស្សនាដើម្បីមគ្គដ៏សេស ក៏ន័យនេះ ។ លោកសំដៅយកសេចក្តីនេះ ទើបពោលថា សម្មា វិហារេយ្យុំ ។ បទថា អសុញ្ញោ លោកោ អរហន្តេហិ អស្ស សេចក្តីថា គប្បីមិនសាបសូន្យដូចព្រៃបបុស ព្រៃឈើបន្ទា ។

**[១៣៩]** បទថា ឯកូនតឹស វយសា បានដល់ ទ្រង់មានព្រះជន្មាយុ ២៩ វស្សាដោយវ័យ ។ ពាក្យថា យំ ក្នុងពាក្យថា យំ បព្វជ្ជឹ នេះ ត្រឹមតែជានិបាត ។ បទថា កឹ កុសលានុឯសី បានដល់ ទ្រង់ស្វែងរកថា អ្វីជាកុសល លោកប្រាថ្នាសព្វញ្ញុតញ្ញាណថា កុសល គឺអ្វី ក្នុងពាក្យថា កឹ

កុសលានុឯសី នោះ អធិប្បាយថា ទ្រង់ស្វែងរកសព្វញ្ញុតញ្ញាណនោះ ។ ដោយបទថា យតោ អហំ ទ្រង់សម្ដែងថា ចាប់ផ្ដើមតាំងពីកាលណា តែចន្លោះនេះ តថាគតបួសមកលើស ៥០ វស្សា ។ បទថា ញាយស្ស ធម្មស្ស បានដល់ ធម៌ គឺ អរិយមគ្គ ។ បទថា បទេសវត្តិ ប្រព្រឹត្តទៅក្នុងប្រទេស គឺសូម្បីក្នុងផ្លូវនៃវិបស្សនា ។ បទថា ឥតោ ពហិទ្ធា ខាងក្រៅសាសនារបស់តថាគត ។ បទថា សមណោបិ នត្ថិ សូម្បីសមណៈអ្នកបំពេញវិបស្សនា អ្នកនៅក្នុងផ្លូវនៃវិបស្សនាមិនមាន លោកអធិប្បាយថា សមណៈទី ១ សូម្បីជាសោតាបន្ន មិនមាន ។

[១៤០] បទថា យេ ឯត្ថ សេចក្ដីថា ភិក្ខុពួកណា ដែលព្រះសាស្ដាអភិសេក ដោយតេវាសិកាភិសេក ចំពោះព្រះភក្ត្រក្នុងព្រះសាសនានេះ ជាលាភរបស់ភិក្ខុទាំងនោះ ភិក្ខុទាំងនោះ បានល្អហើយ ។ បានឮថា ក្នុងលទ្ធិខាងក្រៅ អាចារ្យនិយាយជាមួយនឹងអន្តេវាសិកណាថា ចូរបព្វជ្ជាអ្នកនេះ ចូរឲ្យឱវាទប្រៀនប្រដៅអ្នកនេះ អន្តេវាសិកនោះ រមែងជាចំណែកអាចារ្យតាំងទុកក្នុងឋានៈរបស់ខ្លួន ព្រោះដូច្នោះ សេចក្ដីទាំងនេះថា ចូរបំបួសអ្នកនេះ ចូរឲ្យឱវាទប្រៀនប្រដៅអ្នកនេះ ជាលាភរបស់អន្តេវាសិកនោះ ។ សុភទ្ទបរិព្វាជក កាន់លទ្ធិខាងក្រៅនោះឯង ទើបពោលសូម្បីចំពោះព្រះថេរៈយ៉ាងនេះ ។

បទថា អលត្ថ ខោ ប្រែថា បានហើយយ៉ាងណា ។ បានឮថា ព្រះថេរៈ

នាំសុភទ្ទៈនោះ ទៅក្នុងទីមួយកន្លែង យកទឹកអំពីគណ្ឋោស្រោចសីសៈ ប្រាប់តចបញ្ចកកម្មដ្ឋាន កោរសក់ និងពុកមាត់ ឲ្យគ្រងសំពត់កាសាយៈ ឲ្យសរណៈ ហើយនាំទៅកាន់សម្នាក់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ឲ្យឧបសម្បទាហើយ ត្រាស់ប្រាប់កម្មដ្ឋាន ។ លោកទទួលកម្មដ្ឋានទុកហើយ អធិដ្ឋានចង្រ្កមក្នុងទីមួយកន្លែងនៃឧទ្យាន ប្រារព្ធសេចក្តីព្យាយាម ជម្រះវិបស្សនា សម្រេចអរហត្តព្រមដោយបដិសម្ភិទា ហើយមកថ្វាយបង្គំព្រះ-មានព្រះភាគ អង្គុយចុះ ។ លោកសំដៅយកឧបសម្បទាកម្មនោះ ទើបពោលថា អចិរូបសម្បន្នោ ខោ បន ជាដើម ។ ក៏ព្រះសុភទ្ទៈនោះ បានជាបច្ឆិមសក្ខិសាវករបស់ព្រះមានព្រះភាគនោះឯង ។ ពាក្យរបស់ព្រះសង្គីតិកាចារ្យថា ក្នុងបណ្តាសាវកទាំងនោះ អង្គណាបព្វជ្ជាកាលព្រះមានព្រះភាគ ទ្រង់នៅមានព្រះជន្ម ខាងក្រោយបានឧបសម្បទា រៀនកម្មដ្ឋានសម្រេចព្រះ-អរហត្តក្តី សូម្បីបានឧបសម្បទា កាលព្រះមានព្រះភាគទ្រង់នៅមានព្រះជន្ម ខាងក្រោយរៀនកម្មដ្ឋានសម្រេចអរហត្តក្តី សូម្បីរៀនកម្មដ្ឋាន កាលព្រះ-មានព្រះភាគទ្រង់នៅមានព្រះជន្ម ខាងក្រោយសម្រេចអរហត្តក្តី សូម្បីគ្រប់អង្គនោះ ក៏ឈ្មោះថា បច្ឆិមសក្ខិសាវក ។ ចំណែកសុភទ្ទៈនេះ បព្វជ្ជា-ឧបសម្បទា រៀនកម្មដ្ឋាន សម្រេចព្រះអរហត្ត កាលព្រះមានព្រះភាគទ្រង់នៅមានព្រះជន្ម ។

" ចប់កថា ពណ៌នាបឋមភាណវារ "

## ព្រះបច្ឆិមវាចាព្រះតថាគត

[១៤១] ឥឡូវនេះ ដើម្បីសម្ដែងការប្រទានព្រះឱវាទដល់ភិក្ខុសង្ឃដែលទ្រង់ផ្ដើមទុកនោះ ទើបពោលពាក្យថា អថ ខោ ភគវា ជាដើម ។ បណ្ដាបទទាំងនោះ បទថា ទេសិតោ បញ្ញត្តោ សេចក្ដីថា ទាំងធម៌ ក៏ទ្រង់សម្ដែងហើយ បញ្ញត្តិហើយ ទាំងវិន័យក៏ទ្រង់សម្ដែង បញ្ញត្តិហើយ ។ អធិប្បាយថា ឈ្មោះថា ទ្រង់បញ្ញត្តិ បានដល់ ទ្រង់តាក់តាំងហើយ ។ បទថា សោ វោ មមច្ចយេន បានដល់ ធម៌ និងវិន័យនោះ នឹងជាសាស្ដារបស់អ្នកទាំងឡាយ លុះអំណើះអំពីតថាគតទៅ ។

ពិតណាស់ តថាគតនៅមានព្រះជន្មនេះឯង សម្ដែងឧភតោវិភង្គ-វិន័យ ព្រមទាំងខន្ធកៈ បរិវារៈ ដល់អ្នកទាំងឡាយ ក្នុងវត្ថុដែលចាត់ទុកដោយអំណាចកងអាបត្តិទាំង ៧ ថា នេះអាបត្តិស្រាល នេះអាបត្តិធ្ងន់ នេះអាបត្តិដែលកែខៃបាន នេះអាបត្តិដែលកែខៃមិនបាន នេះអាបត្តិដែលជាលោកវជ្ជៈ នេះជាបណ្ណត្តិវជ្ជៈ នេះអាបត្តិចេញបានក្នុងសម្នាក់បុគ្គល នេះអាបត្តិចេញបានក្នុងសម្នាក់គណៈ នេះអាបត្តិចេញបានក្នុងសម្នាក់សង្ឃ ។ វិន័យបិដក សូម្បីទាំងអស់នោះ កាលតថាគតបរិនិព្វានហើយ នឹងធ្វើកិច្ចរបស់សាស្ដាដល់ពួកលោកឲ្យសម្រេច ។ម្យ៉ាងទៀត តថាគតនៅមានព្រះជន្មនេះឯង ក៏ចែកធម៌ទាំងនេះ សម្ដែងសុត្តន្តបិដកដោយអាការនោះថា ទាំងនេះជា សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ

៥ ពោជ្ឈង្គៈ ៧ អរិយមគ្គមានអង្គ ៨ សុត្តន្តបិដកសូម្បីទាំងអស់នោះ នឹងធ្វើកិច្ចជាសាស្តាដល់អ្នកទាំងឡាយឲ្យសម្រេច ។ មួយទៀត តថាគតតាំងនៅមានព្រះជន្មតាំងនៅនេះឯង ចែកធម៌ទាំងនេះ គឺ ខន្ធ ៥ អាយតនៈ ១២ ធាតុ ១៨ សច្ចៈ ៤ ឥន្ទ្រិយ ២២ ហេតុ ៩ អាហារ ៤ ផស្សៈ ៧ វេទនា ៧ សញ្ញា ៧ សញ្ចេតនា ៧ ចិត្ត ៧ សូម្បីក្នុងចិត្តនោះ , ធម៌ប៉ុណ្ណោះជាកាមាវចរ , ប៉ុណ្ណោះជារូបាវចរ , ប៉ុណ្ណោះជាអរូបាវចរ , ប៉ុណ្ណោះជាបរិយាបន្ន , ប៉ុណ្ណោះជាអបរិយាបន្ន , ប៉ុណ្ណោះជាលោកិយៈ , ប៉ុណ្ណោះជាលោកុត្តរៈ ហើយសម្តែងអភិធម្មបិដក ជាសមន្តប្បដ្ឋាន ២៤ ប្រដាប់មហាបដ្ឋានអនន្តន័យ អភិធម្មបិដកសូម្បីទាំងអស់ កាលតថាគតបរិនិព្វានហើយ នឹងធ្វើកិច្ចជាសាស្តាដល់អ្នកទាំងឡាយឲ្យសម្រេច ។

មួយទៀត ព្រះពុទ្ធវចនៈទាំងអស់នេះ ដែលតថាគតភាសិតហើយពោលហើយ តាំងអំពីត្រាស់ដឹង ដរាបដល់បរិនិព្វាន មានច្រើនប្រភេទយ៉ាងនេះ គឺ បិដក ៣ និកាយ ៥ អង្គ ៩ ៨៤.០០០ ព្រះធម្មក្ខន្ធ ។ ព្រះធម្មក្ខន្ធ ៨៤.០០០ ទាំងនេះ តាំងនៅដោយប្រការដូច្នេះ ។ ព្រះមានព្រះភាគ កាលទ្រង់សម្តែងហេតុជាច្រើនយ៉ាងនេះថា តថាគតនឹងបរិនិព្វានតែម្នាក់ឯង មួយវិញទៀត តថាគតឥឡូវនេះ ក៏ឲ្យឱវាទប្រៀនប្រដៅតែម្នាក់ឯងដូចគ្នា កាលតថាគតបរិនិព្វានហើយ ព្រះធម្មក្ខន្ធ ៨៤.០០០ ទាំងនេះ ក៏ជាឱវាទប្រៀនប្រដៅអ្នកទាំងឡាយ ទ្រង់ឲ្យឱវាទថា ធម៌វិន័យ

នោះ នឹងជាសាស្ដារបស់អ្នកទាំងឡាយ កាលតថាគតកន្លងទៅហើយ កាលទ្រង់សម្ដែងចារិតក្នុងអនាគតកាល ទើបត្រាស់ថា យថា ខោ បន ជាដើម ។

បណ្ដាបទទាំងនោះ បទថា សមុទាចរន្តិ បានដល់ រមែងពោល រមែងហៅ ។ បទថា ឆាមេន វា គោត្តេន វា បានដល់ នវកៈគប្បីហៅដោយឈ្មោះយ៉ាងនេះថា តិស្សៈ នាគៈ ឬដោយគោត្រយ៉ាងនេះថា កស្សបគោត្រ ឬដោយវាទៈថា អាវុសោ យ៉ាងនេះថា អាវុសោតិស្សៈ អាវុសោកស្សបៈ ។ បទថា ភន្តេតិ វា អាយស្មាតិ វា បានដល់ គប្បីហៅយ៉ាងនេះថា ភន្តេ តិស្សៈ , អាយស្មា តិស្សៈ ។

បទថា សមូហនតុ បានដល់ កាលបំណង ចូរដក ។ អធិប្បាយថា ប្រសិនបើថា ប្រាថ្នា ក៏គប្បីដកចេញ ។ សួរថា ក៏ព្រោះហេតុអ្វី ព្រះមានព្រះភាគ មិនត្រាស់ដោយចំណែកតែមួយថា ចូរដកចេញ តែត្រាស់ដោយពាក្យជាវិកប្ប ។ ឆ្លើយថា ព្រោះទ្រង់ឃើញកម្លាំងរបស់ព្រះមហាកស្សបៈ ។ ពិតហើយ ព្រះមានព្រះភាគទ្រង់ឃើញថា កាលត្រាស់ថា ចូរដកចេញ ព្រះមហាកស្សបៈនឹងមិនដកក្នុងវេលាធ្វើសង្គាយនា ព្រោះដូច្នោះ ទើបត្រាស់ទុកដោយពាក្យជាវិកប្បនុ៎ះឯង ។ រឿងតូច នឹងតូចដោយលំដាប់ មកក្នុងបញ្ចសតិកសង្គីតិដោយន័យជាដើមថា បណ្ដាព្រះថេរៈទាំងនោះ ព្រះថេរៈពួកខ្លះពោលយ៉ាងនេះថា វៀរបារាជិក ៤ ចេញ ក្រៅពីនោះ ក៏ជាអាបត្តិតូចៗ ។ ក៏ការវិនិច្ឆ័យក្នុងរឿងអាបត្តិតូច នឹងតូចដោយ

លំដាប់នេះ ពោលទុកហើយក្នុងអដ្ឋកថា ឈ្មោះសមន្តប្បាសាទិកា ។

ក៏អាចារ្យពួកខ្លះពោលថា ព្រះនាគសេនស្គាល់អាបត្តិតូច នឹងតូច ព្រោះត្រូវព្រះបាទមិលិន្ទត្រាស់សួរថា ព្រះនាគសេន អាបត្តិតូច តើដូចម្តេច អាបត្តិតូចតាមលំដាប់ តើដូចម្តេច ? ទូលឆ្លើយថា មហាបពិត្រ ទុក្កដ ជាអាបត្តិតូច ទុព្ភាសិតជាអាបត្តិតូចតាមលំដាប់ ។ ចំណែកព្រះមហាកស្សបត្ថេរ កាលមិនដឹងអាបត្តិតូច អាបត្តិតូចដោយលំដាប់នោះ ទើបប្រកាសថា អ្នកដ៏មានអាយុទាំងឡាយ សូមសង្ឃស្តាប់ខ្ញុំ សិក្ខាបទទាំងឡាយ របស់ពួកយើង ដែលជាចំណែករបស់គ្រហស្ថក៏មាន សូម្បីគ្រហស្ថទាំងឡាយក៏ដឹងថា សិក្ខាបទនេះ គួរដល់លោកទាំងឡាយដែលជាសមណសក្យបុត្រ សិក្ខាបទនេះ មិនគួរដល់លោកទាំងឡាយ ដែលជាសមណសក្យបុត្រ បើយើងនឹងដកសិក្ខាបទតូច នឹងតូចដោយលំដាប់ចេញ មនុស្សទាំងឡាយក៏នឹងពោលថា សិក្ខាបទ ដែលព្រះសមណគោតមបញ្ញត្តិទុកដល់សាវកទាំងឡាយនោះ បានត្រឹមតែមួយផ្សែងភ្លើង សាវកទាំងនេះ សិក្សាក្នុងសិក្ខាបទទាំងឡាយដរាបដែលព្រះសាស្តាតាំងនៅ ព្រោះព្រះសាស្តារបស់សាវកទាំងនេះបរិនិព្វានហើយ សង្ឃមិនគប្បីបញ្ញត្តិក្នុងសិក្ខាបទ ដែលទ្រង់មិនបានបញ្ញត្តិ មិនគប្បីដកក្នុងសិក្ខាបទ ដែលទ្រង់បញ្ញត្តិទុកហើយ គប្បីសមាទាន ប្រព្រឹត្តក្នុងសិក្ខាបទទាំងឡាយ ដែលទ្រង់បញ្ញត្តិទុកហើយ នេះជា **ញត្តិ** ។ លោកប្រកាសកម្មវាចាដូចពោលមកនេះ ។ សេចក្តីនោះ

មិនគួរកាន់យកយ៉ាងនេះ ក៏ព្រះនាគសេនពោលទុកយ៉ាងនោះ ដោយប្រាថ្នានឹងមិនឲ្យបរវាទីមានឱកាស ។ ព្រះមហាកស្សបត្ថេរ ប្រកាសកម្មវាចានេះ ក៏ដោយប្រាថ្នានឹងមិនឲ្យដកអាបត្តិតូច នឹងតូចដោយលំដាប់ ដូច្នេះឯង ។ សូម្បីរឿងព្រហ្មទណ្ឌ លោកក៏វិនិច្ឆ័យទុកហើយក្នុងអដ្ឋកថា ព្រះវិន័យឈ្មោះសមន្តបាសាទិកា ព្រោះមកហើយក្នុងបាលីសង្គីតិ ។

[១៤២] បទថា កង្ខា គឺ ផ្លូវបែកជាពីរ ។ បទថា វិមតិ គឺមិនអាចនឹងវិនិច្ឆ័យបាន ។ សេចក្តីសង្ខេបក្នុងសេចក្តីនេះ យ៉ាងនេះថា បុគ្គលណាគប្បីកើតសេចក្តីសង្ស័យថា ជាព្រះពុទ្ធ ឬមិនមែនព្រះពុទ្ធហ្ន៎ ជាព្រះធម៌ ឬមិនមែនព្រះធម៌ហ្ន៎ ជាព្រះសង្ឃ ឬមិនមែនព្រះសង្ឃហ្ន៎ ជាមគ្គ ឬមិនមែនមគ្គហ្ន៎ ជាបដិបទា ឬមិនមែនបដិបទាហ្ន៎ តថាគតនឹងពោលសេចក្តីនោះដល់អ្នកទាំងឡាយ ម្នាលភិក្ខុទាំងឡាយ អ្នកចូរសួរដូច្នេះ ។ បទថា សត្ថុគារវេនាបិ ន បុច្ឆេយ្យាថ សេចក្តីថា បើពួកលោកមិនសួរដោយសេចក្តីគោរពក្នុងសាស្តាយ៉ាងនេះថា ពួកយើងបួសក្នុងសម្នាក់នៃព្រះសាស្តា សូម្បីបច្ច័យ ៤ ក៏ជារបស់ព្រះសាស្តានៃពួកយើង ក៏មិនគួរនឹងធ្វើការសង្ស័យ រហូតដល់អស់កាលមានប្រមាណប៉ុណ្ណេះ ក្នុងថ្ងៃនេះ មិនគួរនឹងធ្វើការសង្ស័យក្នុងកាលខាងក្រោយ ។ បទថា សហាយកោបិ ភិក្ខវេ សហាយកស្ស អារោចេតុ ទ្រង់សម្តែងថា បណ្តាអ្នកទាំងឡាយ បុគ្គលណា សេពគប់គ្នានឹងភិក្ខុណា បុគ្គលនោះចូរប្រាប់ភិក្ខុនោះថា ខ្ញុំនឹង

ប្រាប់ដល់ភិក្ខុមួយរូប អ្នកទាំងឡាយស្តាប់ពាក្យភិក្ខុនោះហើយ នឹងអស់ការសង្ស័យគ្រប់រូប ។ បទថា ឯវំ បសន្នោ សេចក្តីថា ខ្ញុំជឿយ៉ាងនេះ ។ បទថា ញាណមេវ សេចក្តីថា ធ្វើភាពជាអ្នកអស់សេចក្តីសង្ស័យឲ្យប្រចក្សឈ្មោះថា សេចក្តីដឹងនុ៎ះឯងរបស់តថាគត ក្នុងសេចក្តីនេះ មិនមែនត្រឹមតែការជឿ ។ បទថា ឥមេសញ្ហិ អានន្ទ សេចក្តីថា បណ្តាភិក្ខុ ៥០០ រូបដែលអង្គុយ ខាងក្នុងវាំងននទាំងនេះ ។ បទថា យោ បច្ឆិមកោ សេចក្តីថា ភិក្ខុណា ទាបបំផុតដោយគុណ ។ លោកពោលសំដៅដល់ព្រះអានន្ទត្ថេរប៉ុណ្ណោះ ។

[១៤៣] បទថា អប្បមាទេន សម្បាទេថ សេចក្តីថា ចូរញ៉ាំងកិច្ចទាំងពួងឲ្យសម្រេចដោយសេចក្តីមិនប្រាសចាកសតិ ។ ដូច្នោះ ព្រះមានព្រះភាគ ទ្រង់ផ្ទំលើគ្រែបរិនិព្វាន ប្រទានព្រះឱវាទ ដែលប្រទាន ៤៥ វស្សារួមចុះក្នុងបទ គឺ សេចក្តីមិនប្រមាទតែម្យ៉ាងប៉ុណ្ណោះ ។ ក៏ពាក្យនេះថា បច្ឆិម វាចា ជាពាក្យរបស់ព្រះសង្គីតិកាចារ្យទាំងឡាយ ។

## ការបរិនិព្វាននៃព្រះមានព្រះភាគ

[១៤៤] តពីនេះទៅ ដើម្បីនឹងសម្តែងសេចក្តីដែលព្រះមានព្រះភាគទ្រង់ធ្វើបរិកម្មក្នុងកាលបរិនិព្វាន ទើបពោលពាក្យមានអាទិថា អថ ខោ ភគវា បឋមជ្ឈានំ ។

បណ្ដាបទទាំងនោះ បទថា បរិនិព្វុតោ ភន្តេ សេចក្ដីថា ព្រះអានន្ទ ឃើញព្រះមានព្រះភាគចូលនិរោធសមាបត្តិ មិនមានអស្សាសបស្សាសៈ ទើបសួរថា ព្រះមានព្រះភាគបរិនិព្វានហើយឬ ។ ព្រះអនុរុទ្ធឆ្លើយថា នៅទេអ្នកមានអាយុ ។ ព្រះថេរៈជ្រាបរឿងនោះ ។ បានឮថា ព្រះថេរៈចូលសមាបត្តិនោះៗ ព្រមជាមួយព្រះសាស្ដាទ្រង់ឯង ទើបដឹងថា ព្រះមានព្រះភាគចេញចាកនេវសញ្ញានាសញ្ញាយតនៈ ហើយប្រព្រឹត្តទៅ ឥឡូវនេះ ចូលនិរោធសមាបត្តិ ឈ្មោះថា ការធ្វើកាលៈខាងក្នុងនិរោធសមាបត្តិមិនមាន ។

ក្នុងព្រះបាលីនេះថា គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ចេញចាកសញ្ញាវេទយិតនិរោធ ចូលនេវសញ្ញានាសញ្ញាយតនៈ ។ល។ ចេញចាកតតិយជ្ឈាន ចូលចតុត្ថជ្ឈាន ព្រះមានព្រះភាគទ្រង់ចូលបឋមជ្ឈានក្នុងឋានៈ ២៤ ទុតិយជ្ឈានក្នុងឋានៈ ១៣ តតិយជ្ឈានក៏ដូចគ្នា ចូលចតុត្ថជ្ឈានក្នុងឋានៈ ១៥ ។ ចូលយ៉ាងណា ។ គឺ ចូលបឋមជ្ឈានក្នុងឋានៈ ២៤ ទាំងនេះ មានអសុភៈ ១០ អាការ ៣២ កសិណ ៨ មេត្តា ករុណា មុទិតា អានាបានស្សតិ បរិច្ឆេទាកាស ជាដើម ។ តែវៀរអាការ ៣២ និងអសុភៈ ១០ ចូលទុតិយជ្ឈានក្នុងឋានៈដ៏សេស ១៣ និងចូលតតិយជ្ឈានក្នុងឋានៈ ១៣ នោះដូចគ្នា ។ មួយទៀត ចូលចតុត្ថជ្ឈានក្នុងឋានៈ ១៥ ទាំងនេះ គឺ កសិណ ៨ ឧបេក្ខាព្រហ្មវិហារ អានាបានស្សតិ បរិច្ឆេទាកាស អរូប ៤ ។ ពោលដោយសង្ខេបប៉ុណ្ណេះ ។ តែព្រះមាន-

ព្រះភាគជាធម្មសាមី ស្ដេចចូលព្រះនគរ គឺ បរិនិព្វាន ស្ដេចចូលសមាបត្តិទាំងអស់រាប់បាន ម្ភៃបួនសែនកោដិ ហើយសោយសុខក្នុងសមាបត្តិទាំងនោះ ដូចបុគ្គលទៅកាន់ប្រទេសផ្សេងៗ បានជួបជនដែលជាញាតិដូច្នោះ ។

ក្នុងពាក្យនេះថា ព្រះមានព្រះភាគស្ដេចចេញចាកចតុត្ថជ្ឈាន ក្នុងលំដាប់មក ស្ដេចបរិនិព្វាន គឺ ក្នុងលំដាប់ទាំង ២ គឺ ក្នុងលំដាប់នៃឈាន ក្នុងលំដាប់នៃបច្ចវេក្ខណញ្ញាណ ។ ព្រះមានព្រះភាគចេញចាកឈានហើយចូលកាន់ភវង្គ ហើយបរិនិព្វានក្នុងចន្លោះនោះ ឈ្មោះថា ចន្លោះឈានក្នុងលំដាប់ ២ នោះ ។ ព្រះមានព្រះភាគ ស្ដេចចេញចាកឈានហើយពិចារណាអង្គឈានទៀត ចូលកាន់ភវង្គ ហើយបរិនិព្វានក្នុងចន្លោះនោះឯង ឈ្មោះថា ចន្លោះបច្ចវេក្ខណញ្ញាណ ។ សូម្បីទាំង ២ នេះ ក៏ឈ្មោះថាចន្លោះទាំងនោះ ។ ក៏ព្រះមានព្រះភាគចូលឈាន ស្ដេចចេញចាកឈានពិចារណាអង្គឈានហើយ បរិនិព្វានដោយភវង្គចិត្ត ជាអព្យាក្រិត ជាទុក្ខសច្ចៈ ។ សត្វពួកណាមួយ មិនថា ព្រះពុទ្ធ ឬព្រះសាវក យ៉ាងទាបស្រមោចខ្មៅ ស្រមោចក្រហម ត្រូវធ្វើកាលៈដោយភវង្គចិត្តដែលជាអព្យាក្រិត ជាទុក្ខសច្ចទាំងនោះឯង ។

[១៨៥] រឿងផែនដីធំញាប់ញ័រជាដើម មានន័យដូចពោលទុកហើយនោះឯង ។

[១៨៦] បទថា ភូតា បានដល់ សត្វទាំងឡាយ ។ បទថា អប្ប-

និបុគ្គលោ បានដល់ ប្រាសចាកបុគ្គលដែលប្រៀបធៀបបាន ។ បទថា ពលប្បត្តោ គឺ អ្នកដល់ទសពលញ្ញាណ ១០ ។

[១៤៧] បទថា ឧប្បាទវយធម្មិនោ បានដល់ មានការកើត និងរលត់ជាសភាវៈ ។ បទថា តេសំ វូបសមោ សេចក្ដីថា ការរម្ងាប់សង្ខារទាំងនោះ ក៏គឺ ព្រះនិព្វានដែលមិនមានបច្ច័យតាក់តែងមែនពិត ជាសុខ ។

[១៤៨] បទថា នាហុ អស្សាសបស្សាសោ គឺ មិនកើតអស្សាសបស្សាសៈ ។ បទថា អនេជោ ឈ្មោះថា អនេជៈ ព្រោះមិនមានកិលេសជាគ្រឿងញាប់ញ័រ គឺ តណ្ហា ។ បទថា សន្តិមារព្ភ បានដល់ ប្រារព្ធអាស្រ័យ សំដៅយកអនុបាទិសេសនិព្វាន បទថា យំ កាលមករិ អ្នកណាបានធ្វើកាលៈ ។ លោកអធិប្បាយថា អ្នកមានអាយុ ព្រះពុទ្ធជាមុនី គឺសាស្ដារបស់យើង ទ្រង់ប្រារព្ធសន្តិថា យើងនឹងដល់សន្តិបាន ទ្រង់ធ្វើកាលៈហើយ ឥឡូវនេះ ព្រះពុទ្ធជាមុនីព្រះអង្គនោះ មានចិត្តតាំងមាំ ដែលមិនមានអស្សាសបស្សាសៈ គឺ មិនមានការប្រព្រឹត្តទៅ ។ បទថា អសល្លីនេន គឺ ដោយចិត្តមិនរួញរា រីករាយល្អហើយ ។ បទថា វេទនំ អជ្ឈាវសយិ ទ្រង់គ្របសង្កត់វេទនាហើយ គឺ មិនសោប់សោល់ ប្រព្រឹត្តទៅតាមអំណាចរបស់វេទនា ។ បទថា វិមោក្ខោ បានដល់ រួចផុត មិនជាប់ទាក់ដោយធម៌អ្វីៗ ដល់ការមិនមានបញ្ញត្តិ ដោយប្រការទាំងពួង ដូចគ្នានឹងការរលត់នៃភ្លើងដែលឆេះសន្ធោសន្ធៅ ។

**[១៤៩]** លោកពោលថា គន្ធាសិ សំដៅយកផែនដីញាប់ញ័រ ដែលលោកពោលទុកក្នុងខាងក្រោយយ៉ាងនេះថា ផែនដីធញ្ញាប់ញ័រព្រមជាមួយការបរិនិព្វាន ។ ពិតហើយ ការញ័រនៃផែនដីនោះ ធ្វើឲ្យកើតការព្រឺរោមបះឡើង និងគួរតក់ស្លុត ។ បទថា សព្វាការវរូបេតេ ប្រែថា ចូលដល់ហេតុដ៏ប្រសើរទាំងពួង ។

**[១៥០]** បទថា អវីតរាគា បានដល់ បុថុជ្ជន ព្រះសោតាបន្ន និងព្រះសកទាគាមី ។ ពិតមែន បុថុជ្ជន ព្រះសោតាបន្ន និងព្រះសកទា-គាមីទាំងនោះ លះទោមនស្សមិនទាន់បាន ព្រោះដូច្នោះ លោកទាំងនោះផ្គងដៃទាំងពីរយំរៀបរាប់ ដាក់ដៃទាំងពីរទុកលើសីសៈស្រែកយំ ។ រឿងទាំងអស់ គប្បីជ្រាបដោយន័យមុននុ៎ះឯង ។

**[១៥១]** បទថា ឧជ្ឈាយន្តិ គឺ ទេវតាលើកទោស ហើយពោលថា លោកម្ចាស់ទាំងឡាយ មិនអាចអត់ទ្រាំសូម្បីចំពោះខ្លួនឯងបាន នឹងលួងលោមជនដ៏សេសបានយ៉ាងណា ។ បទថា កថំ ភូតា បន ភន្តេ អនុរុទ្ធ សេចក្តីថា លោកម្ចាស់ដ៏ចម្រើន ពួកទេវតាតើយ៉ាងណា ។ ព្រះអនុរុទ្ធកំណត់ថា ទេវតាទាំងនោះ នឹងមិនព្រមទទួលការបរិនិព្វានរបស់ព្រះសាស្តាបានឬ ។ តមក ដើម្បីនឹងសម្តែងការប្រព្រឹត្តទៅនៃទេវតាទាំងនោះ ព្រះថេរៈទើបពោលថា សន្តាវុសោ ជាដើម ។ ពាក្យនោះ មានសេចក្តីដូចពោលទុកហើយនោះឯង ។

បទថា រត្តាវសេសំ គឺ រាត្រីដែលនៅសល់វេលាបន្តិចបន្តួច ព្រោះបរិនិព្វានក្នុងវេលាជិតភ្លឺ ។ បទថា ធម្មិយា កថាយ គឺ មិនមានធម្មកថាដែលបែកចេញទៅយ៉ាងដទៃ ។ ប៉ុន្តែថា ព្រះថេរៈ ទាំងពីរញ៉ាំងវេលាឲ្យកន្លងទៅដោយកថាដែលជាប់ដោយមរណៈបែបនេះថា អ្នកមានអាយុទាំងឡាយ ស្តេចមច្ចុរាជនេះ មិនខ្មាសចំពោះព្រះសាស្តា ដែលមិនមានបុគ្គលប្រៀបផ្ទឹមក្នុងលោកព្រមទាំងទេវលោក ក៏នឹងចាំបាច់ពោលទៅថ្វីថា នឹងខ្មាសចំពោះលោកិយមហាជន ។ ក៏កាលព្រះថេរៈទាំងពីរពោលកថានោះ អរុណក៏រះឡើងដោយត្រឹមតែមួយភ្លែតប៉ុណ្ណោះ ។ បទថា អថខោ សេចក្តីថា កាលអរុណរះ ព្រះថេរៈ ក៏ពោលចំពោះព្រះថេរៈ ។

**[១៩២]** បទថា តេន ករណីយេន សេចក្តីថា ករណីយ៍ណា យ៉ាងនេះ គឺ នឹងគប្បីចាត់ចែងសក្ការៈ មានផ្កាឈើ និងគ្រឿងក្រអូបជាដើមក្នុងទីបរិនិព្វានយ៉ាងណាហ្ន៎ ។ នឹងគប្បីចាត់ចែងទីអង្គុយសម្រាប់ភិក្ខុ-សង្ឃយ៉ាងណា ។ នឹងគប្បីចាត់ចែងខាទនីយៈ ភោជនីយៈ យ៉ាងណា ។ អ្នកដែលដឹងរឿងព្រះមានព្រះភាគបរិនិព្វានហើយ នឹងគប្បីធ្វើ ពួកមល្លក្សត្រប្រជុំគ្នាដោយករណីយ៍ ដូច្នោះ ។

## ព្រះតថាគតសរសើរការបដិបត្តិ

បទថា សព្វតាឡ តាលាវចរំ បានដល់ គ្រឿងតូរ្យតន្ត្រីគ្រប់ប្រភេទ ។

បទថា សន្និបាតេថ សេចក្ដីថា វាយស្គរហៅប្រជុំ មល្លក្សត្រទាំងនោះ បាននាំគ្នាធ្វើយ៉ាងនោះ ។ បទថា មណ្ឌលមាលេ បានដល់ រោងបារាំធ្វើដោយសំពត់ ។ បទថា បដិយាទេន្តា គឺ ចាត់ចែង ។ បទថា ទក្ខិណេន ទក្ខិណំ គឺ ទិសាភាគផ្នែកខាងទក្សិណនៃព្រះនគរ ។ បទថា ពាហិរេន ពាហិរំ បានដល់ មិនចូលទៅខាងក្នុងព្រះនគរ នាំទៅខាងក្រៅ ដោយខាងក្រៅព្រះនគរនុ៎ះឯង ។ បទថា ទក្ខិណតោ នគរស្ស សេចក្ដីថា តាំងទុកក្នុងស្ថានទីដូចគ្នា នឹងទ្វារផ្នែកខាងទក្សិណរបស់ក្រុងអនុរាធបុរៈ ធ្វើសក្ការៈ សម្មានៈហើយ នឹងធ្វើឈាបនកិច្ចក្នុងស្ថានទី ដូចគ្នានឹងព្រះជេតពន ។

[១៥៣] បទថា អដ្ឋ មល្លបាមោក្ខា បានដល់ ពួកមល្លក្សត្រជំទង់មជ្ឈិមវ័យសម្បូរណ៍ដោយកម្លាំងពលំ ។ បទថា សីសំ ន្ហាតា បានដល់ ជម្រះសីសៈងូតទឹកហើយ ។ បទថា អាយស្មន្តំ អនុរុទ្ធំ សេចក្ដីថា ព្រះថេរៈតែម្នាក់ប្រាកដថា ជាអ្នកមានទិព្វចក្ខុ ព្រោះដូច្នោះ កាលព្រះថេរៈអង្គដទៃៗ សូម្បីមានពួកមល្លក្សត្រទាំងនោះ ក៏ហៅសួរចំពោះព្រះថេរៈដោយប្រាថ្នាថា ព្រះអនុរុទ្ធត្ថេរនេះ នឹងប្រាប់ដល់ពួកយើងបានច្បាស់លាស់ ។ បទថា កថំ បន ភន្តេ ទេវតានំ អធិប្បាយោ សេចក្ដីថា ពួកមល្លក្សត្រទូលសួរថា លោកម្ចាស់ កាលមុនពួកយើងដឹងសេចក្ដីប្រាថ្នារបស់ពួកយើង តែសេចក្ដីប្រាថ្នារបស់ពួកទេវតាជាយ៉ាងណា ។ ព្រះថេរៈកាលនឹងសម្ដែងសេចក្ដីប្រាថ្នារបស់ពួកមល្លក្សត្រប៉ុណ្ណោះ ទើបពោលថា

តុម្ហាកំ ទោ ជាដើម ។

ពាក្យថា **ចេតិយរបស់ពួកមល្លក្សត្រ** ឈ្មោះថា មកុដពន្ធនៈនេះ ជាឈ្មោះរបស់សាលាមង្គល ជាកន្លែងតែងព្រះអង្គរបស់ពួកមល្លក្សត្រ ។ ក៏សាលានេះ លោកហៅថា **ចេតិយ** ព្រោះអត្ថថា លោកសាងទុកយ៉ាងស្រស់ស្អាត ។ ក្នុងពាក្យថា យាវ សន្ធិសមលសង្កដិរា គឺ នេះទីតនៃផ្ទះឈ្មោះថា **សន្ធិ** អណ្តូងកម្ទាត់គំនរគូថ (រណ្តៅលាមក) ឈ្មោះថា **សមល** ទីចាក់សម្រាមឈ្មោះថា **សង្កដិរ** ។ បទថា ទិព្វេហិ ច មានុសកេហិ ច នច្ចេហិ សេចក្តីថា របាំ ការរាំរបស់ពួកទេវតាមានក្នុងខាងលើ របស់ពួកមនុស្សមានខាងក្រោម ។ ក្នុងការច្រៀងជាដើម ក៏ន័យនេះ ។ មួយទៀតក្នុងចន្លោះពួកទេវតា ក៏មានពួកមនុស្ស ក្នុងចន្លោះពួកមនុស្ស ក៏មានទេវតាទាំងទេវតា និងមនុស្ស បាននាំគ្នាទៅសក្ការៈបូជា សូម្បីដោយប្រការដូចពោលមកនេះ ។

បទថា មជ្ឈេន មជ្ឈំ នគរស្ស ហរិត្វា សេចក្តីថា កាលព្រះសរីរៈរបស់ព្រះមានព្រះភាគត្រូវគេនាំមកយ៉ាងនេះ ភរិយារបស់ពន្ធុលសេនាបតីឈ្មោះថា **មល្លិកា** ជ្រាបថា គេនាំព្រះសរីរៈរបស់ព្រះមានព្រះភាគមកក៏គិតថា យើងនឹងឲ្យគេនាំគ្រឿងប្រដាប់ ឈ្មោះ **មហាលតាបសាធន** ដូចគ្នានឹងគ្រឿងប្រដាប់របស់នាងវិសាខា ដែលយើងរក្សាទុកមិនបានប្រើប្រាស់មកតាំងពីស្វាមីរបស់ខ្លួនស្លាប់ទៅ នឹងបូជាព្រះសាស្តាដោយមហា-

លតាបសាធនៈនេះ ដូច្នេះហើយ ឲ្យធ្វើការសម្អាតមហាលតាបសាធនៈនោះ ជម្រះដោយទឹកក្រអូបហើយដាក់ទុកជិតទ្វារ ។ គេថា គ្រឿងប្រដាប់នោះ មាននៅក្នុងស្ថានទី ៣ កន្លែង គឺ នៅផ្ទះរបស់ស្ត្រីទាំងពីរនោះ (នាងវិសាខា និងនាងមល្លិកា) និងផ្ទះរបស់ចោរឈ្មោះថា ទេវនានិយៈ ។ ក៏នាងមល្លិកានោះ ពោលថា កាលព្រះសរីរៈរបស់ព្រះសាស្តាមកដល់ទ្វារហើយ កូនទាំងឡាយ ចូរដាក់ព្រះសរីរៈរបស់ព្រះសាស្តាចុះហើយ ពាក់គ្រឿងប្រដាប់នេះ លើព្រះសរីរៈរបស់ព្រះសាស្តា ។ គ្រឿងប្រដាប់នោះ ពាក់តាំងពីព្រះសិរសាដរាបទល់នឹងផ្ទៃព្រះបាទ ព្រះសរីរៈរបស់ព្រះមានព្រះភាគដែលមានព្រះឆវីវណ្ណដូចមាស ប្រដាប់ដោយមហាលតាបសាធនៈ ដែលធ្វើដោយរតនៈ ៧ ប្រការ ក៏រុងរឿងក្រៃលែងណាស់ ។ នាងមល្លិកានោះ ឃើញដូច្នោះហើយ ក៏មានចិត្តថ្លាផូរផង់ធ្វើសេចក្តីប្រាថ្នាថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គ នឹងត្រាច់ទៅក្នុងវដ្តសង្សារដរាបណា ដរាបនោះ កិច្ចដោយគ្រឿងប្រដាប់ចូរកុំបែកអំពីខ្ញុំព្រះអង្គ សូមឲ្យសរីរៈដូចគ្នានឹងគ្រឿងប្រដាប់ដែលពាក់ហើយជានិច្ចចុះ ។ គ្រានោះ ពួកស្តេចមល្លបាមោក្ខ លើកព្រះមានព្រះភាគ ព្រមដោយគ្រឿងមហាលតាបសាធនៈ ដែលធ្វើដោយរតនៈ ៧ ប្រការ ចេញផ្លូវទ្វារទិសបូព៌ា ដាក់ព្រះសរីរៈរបស់ព្រះមានព្រះភាគចុះក្នុងមកុដពន្ធនៈចេតិយរបស់ពួកមល្លក្សត្រផ្លូវខាងទិសបូព៌ានៃព្រះនគរ ។

## រឿងព្រះមហាកស្សបត្ថេរ

[១៥៤] បទថា ចាវាយ កុសិនារំ សេចក្ដីថា ព្រះមហាកស្សបៈ ដើរផ្លូវឆ្ងាយដោយបំណងថា នឹងត្រាច់ទៅបិណ្ឌបាតក្នុងនគរបាវា ហើយនឹងទៅកាន់នគរកុសិនារា ។ ក្នុងពាក្យថា **គង់ក្រោមម្លប់ឈើនេះ** តើហេតុអ្វី ទើបលោកមិនពោលថា សម្រាកពេលថ្ងៃ ។ ព្រោះលោកមិនអង្គុយដើម្បីត្រូវការនឹងសម្រាកពេលថ្ងៃ ។ សេចក្ដីពិត ពួកភិក្ខុបរិវាររបស់ព្រះថេរៈសុទ្ធតែចម្រើនដោយសេចក្ដីសុខ មានបុណ្យច្រើន លោកធ្វើដំណើរដោយជើងលើផែនដី ដែលដូចផ្ទាំងថ្មដ៏ក្ដៅ ក្នុងវេលាថ្ងៃត្រង់មានការលំបាក ។ ព្រះថេរៈឃើញភិក្ខុទាំងនោះ ក៏គិតថា ភិក្ខុទាំងឡាយមានការលំបាក ទាំងស្ថានទីៗ នឹងទៅ នៅឆ្ងាយ នឹងសម្រាកបន្តិចបន្តួចរម្ងាប់សេចក្ដីលំបាក ពេលល្ងាចដល់នគរកុសិនារា នឹងចូលគាល់ព្រះទសពល ទើបចៀងចូលចុះអំពីផ្លូវ ក្រាលសង្ឃាដិត្រង់គល់ឈើមួយកន្លែង ហើយយកទឹកអំពីគណ្ឌោលាបដៃ និងជើងឲ្យត្រជាក់ ហើយអង្គុយចុះ ។ សូម្បីពួកភិក្ខុបរិវាររបស់លោក ក៏អង្គុយត្រង់គល់ឈើ ញុំាងយោនិសោមនសិការក្នុងកម្មដ្ឋាន អង្គុយសរសើរគុណព្រះរតនត្រ័យ ។ ដូច្នោះលោកទើបមិនពោលថា សម្រាកពេលថ្ងៃ ។ ព្រោះអង្គុយដើម្បីត្រូវការបន្ទោបង់សេចក្ដីនឿយលំបាក ។

បទថា មណ្ឌារវបុប្ផំ គហេត្វា បានដល់ យកឈើដោតផ្កាមណ្ឌារវៈ

ប៉ុនថាសធំ កាន់មកដូចឆត្រ ។ បទថា អទ្ទសា ខោ បានដល់ ឃើញអាជីវកដើរមកពីចម្ងាយ ។ ក៏ឯគ្រាឃើញហើយ ព្រះថេរៈគិតថា នោះផ្កាមណ្ឌារវៈប្រាកដនៅក្នុងដៃរបស់អាជីវកនេះ ក៏ផ្កាមណ្ឌារវៈនោះ មិនប្រាកដក្នុងទីនៅរបស់មនុស្សឡើយ នឹងមាន ក៏ចំពោះកាលអ្នកមានឫទ្ធិខ្លះ ដែលលោកប្លែងឫទ្ធិ និងចំពោះកាលព្រះសព្វញ្ញូពោធិសត្វស្ដេចចុះកាន់ព្រះគភ៌របស់ព្រះមាតាជាដើម តែថ្ងៃនេះ អ្នកមានឫទ្ធិណាៗ ក៏មិនបានសម្ដែងឫទ្ធិនេះ ព្រះសាស្ដារបស់យើង ស្ដេចក៏មិនចុះកាន់ព្រះគភ៌របស់ព្រះមាតា ស្ដេចមិនបានចេញចាកព្រះគភ៌ ទាំងថ្ងៃនេះព្រះអង្គក៏មិនបានត្រាស់ដឹង មិនបានប្រកាសព្រះធម្មចក្រ មិនបានសម្ដែងយមកបាដិហារ្យ មិនបានស្ដេចចុះចាកទេវលោក ទ្រង់មិនបានដាក់អាយុសង្ខារ តែព្រះសាស្ដារបស់យើងទ្រង់ព្រះជរា នឹងស្ដេចបរិនិព្វានជាពិតហើយ ។ លំដាប់នោះ ព្រះថេរៈកើតចិត្តគិតថា នឹងសួរគេ ទើបត្រិះរិះថា បើយើងអង្គុយសួរ នឹងមិនគោរពក្នុងព្រះសាស្ដា ដូច្នេះហើយទើបក្រោកឡើង ដណ្ដប់បង្សុកូលចីវរពណ៌ផ្ទៃមេឃដែលព្រះទសពលប្រទាន ប្រៀបដូចស្ដេចដំរីឆទ្ទន្ត ចៀសចេញអំពីទីឈរ ដណ្ដប់ស្បែកកែវមណីដូច្នោះ លើកអញ្ជលីដែលរុងរឿងដោយទសនខៈសមោធានទុកលើសិរសា បែរមុខត្រង់ចំពោះអាជីវក ដោយគារវៈដែលធ្វើក្នុងព្រះសាស្ដា ពោលសួរថា អ្នកមានអាយុ លោកជ្រាបដំណឹងព្រះសាស្ដារបស់យើងដែរទេ ។

សួរថា ក៏ព្រះមហាកស្សបៈ ដឹងការបរិព្វានរបស់ព្រះសាស្តា ឬមិនដឹង ទើបសួរ ។ អាចារ្យពួកមួយពោលថា ការដឹងរបស់ព្រះខីណាស្រពទាំងឡាយ ត្រូវទាក់ទងនឹងអាវជ្ជនៈការនឹក ក៏ព្រះមហាកស្សបៈមិនដឹង ទើបសួរ ព្រោះលោកមិនបាននឹក ។ ព្រះថេរៈច្រើនដោយសមាបត្តិ ញុំាងជីវិតឲ្យប្រព្រឹត្តទៅ ដោយការច្រើនទៅដោយសមាបត្តិជានិច្ច ក្នុងទីនៅពេលយប់ ទីសម្រាកពេលថ្ងៃ ទីពួនសម្ងំ និងមណ្ឌបជាដើម ចូលស្រុកនៃត្រកូល ក៏ចូលសមាបត្តិគ្រប់មុខផ្ទះ ចេញចាកសមាបត្តិហើយ ទើបទទួលភិក្ខា គេថាព្រះថេរៈធ្វើសេចក្តីតាំងចិត្តយ៉ាងនេះថា ដោយអត្តភាព ចុងក្រោយនេះ យើងនឹងអនុគ្រោះមហាជន ជនពួកណាថ្វាយភិក្ខា ឬធ្វើសក្ការៈដោយគ្រឿងក្រអូប... និងផ្កាឈើជាដើមដល់យើង ទាននោះ របស់ជនទាំងនោះ ចូរមានផលច្រើន ដូច្នេះ ព្រោះដូច្នោះ លោកទើបមិនដឹង ព្រោះច្រើនទៅដោយសមាបត្តិ ។ ដូច្នោះ អាចារ្យពួកមួយទើបពោលថា លោកមិនដឹង ទើបសួរ ។ ពាក្យនោះមិនគួរកាន់យក ។ ព្រោះថា មិនមានហេតុដែលនឹងមិនដឹងក្នុងសេចក្តីនោះ ។ ការបរិនិព្វានរបស់ព្រះសាស្តា បានកំណត់ទុកច្បាស់ហើយដោយនិមិត្តទាំងឡាយ មានម៉ឺនលោកធាតុញាប់ញ័រជាដើម ព្រះថេរៈបានដឹង តែសួរដើម្បីឲ្យកើតសតិដល់ភិក្ខុទាំងឡាយ ដោយគិតថា ក៏ក្នុងបរិស័ទរបស់ព្រះថេរៈ ភិក្ខុពួកខ្លះក៏ធ្លាប់ឃើញព្រះមានព្រះភាគ ពួកខ្លះក៏មិនធ្លាប់ឃើញ បណ្តាភិក្ខុទាំងនោះ សូម្បីភិក្ខុពួកណាធ្លាប់ឃើញហើយ

ភិក្ខុទាំងនោះក៏នៅតែចង់ឃើញ សូម្បីភិក្ខុពួកណាមិនធ្លាប់ឃើញ ភិក្ខុទាំងនោះក៏ចង់ឃើញដូចគ្នា បណ្ដាភិក្ខុទាំងនោះ ភិក្ខុពួកណាមិនធ្លាប់ឃើញ ភិក្ខុទាំងនោះក៏ទៅ ព្រោះអន្ទះសាចង់ឃើញក្រៃលែងណាស់ សួរថា ព្រះមានព្រះភាគនៅទីណា ជ្រាបថា បរិនិព្វានហើយ ក៏នឹងមិនអាចទប់ស្មារតីឲ្យតាំងមាំបាន ចោលបាត្រ ចីវរ ស្លៀកសំពត់តែមួយផ្ទាំងខ្លះ ស្លៀកមិនល្អខ្លះ ដណ្ដប់មិនល្អខ្លះ គក់ទ្រូងស្រែកទ្រហោយំក្នុងទីនោះ មនុស្សទាំងឡាយនឹងសម្ដែងទោសដល់យើងថា ពួកភិក្ខុដែលកាន់បង្សុកូលចីវរិកង្គ-ធុតង្គ ដែលមកជាមួយព្រះមហាកស្សបៈ ស្រែកយំដោយខ្លួនឯង ដូចស្ត្រី ភិក្ខុទាំងនោះនឹងលួងលោមពួកយើងបានយ៉ាងណា ក៏ព្រៃធំនេះគង់នឹងសូន្យទទេ កាលភិក្ខុទាំងឡាយស្រែកយំខ្លាំងៗ ក្នុងទីនេះ ដែលឈ្មោះថា ទោសគង់នឹងមិនមាន ព្រោះដឹងរឿងជាមុន សូម្បីមានការសោកសៅ ក៏គង់នឹងធូរស្រាលខ្លះ ដូច្នេះ ។

បទថា អជ្ជ សត្តាហំ បរិនិព្វុតោ សមណោ គោតមោ ប្រែថា រាប់ដល់ថ្ងៃនេះ ព្រះសមណគោតមបរិនិព្វានបាន ៧ ថ្ងៃហើយ ។ បទថា តតោ មេ ឥទំ បានដល់ ផ្កាមន្ទារវៈនេះ ខ្ញុំរើសមកហើយពីស្ថានទីបរិនិព្វានរបស់ព្រះសមណគោតមនោះ ។

**[១៥៥]** បទថា សុភទ្ទោ នាម វុឌ្ឍបព្វជិតោ សេចក្ដីថា ពាក្យថា សុភទ្ទៈ ជាឈ្មោះរបស់ភិក្ខុនោះ តែព្រោះភិក្ខុនោះ បួសក្នុងវេលាចាស់

លោកទើបហៅថា **វុឌ្ឍបព្វជិត** ។ ក៏ព្រោះហេតុអ្វី សុភទ្ទៈភិក្ខុនោះ ទើបពោលយ៉ាងនេះ ។ ព្រោះអាឃាតក្នុងព្រះមានព្រះភាគ ។ បានឮថា សុភទ្ទៈភិក្ខុនេះ ធ្លាប់ជាជាងកោរកាត់ក្នុងក្រុងអាតុមានគរ ដែលមកក្នុងខន្ធកៈ បួសក្នុងវេលាចាស់ ជ្រាបថា កាលព្រះមានព្រះភាគស្តេចចេញចាកនគរកុសិនារា ទៅកាន់អាតុមានគរព្រមនឹងភិក្ខុ ២៥០ រូប ។ ព្រះមានព្រះភាគស្តេចកំពុងមក ទើបគិតថា នឹងធ្វើយាគូទានថ្វាយក្នុងវេលាស្តេចមក ទើបហៅបុត្រ ២ នាក់ ដែលត្រៀមខ្លួននឹងបួសជាសាមណេរ ប្រាប់ថា កូនអើយ គេថា ព្រះមានព្រះភាគព្រមទាំងព្រះភិក្ខុសង្ឃជាច្រើន ចំនួន ២៥០ រូប តោះកូន ចូរកាន់យកគ្រឿង មានកាំបិតកោរ ព្រមទាំងបំពង់ និងថង់ ហើយដើរទៅកាន់ផ្ទះជាលំដាប់ៗ ចូរប្រមូលអំបិលខ្លះ ប្រេងខ្លះ អង្ករខ្លះ ខាទនីយៈខ្លះ យើងនឹងធ្វើយាគូ ថ្វាយដល់ព្រះមានព្រះភាគ ដែលយាងមក ។ បុត្រ ២ នាក់នោះ ក៏បានធ្វើយ៉ាងនោះ ។

ពួកមនុស្សឃើញក្មេងទាំងនោះមានសំឡេងពីរោះ មានការវាងវៃខ្លះ ប្រាថ្នានឹងឲ្យធ្វើខ្លះ ប្រាថ្នានឹងមិនឲ្យធ្វើ តែក៏ឲ្យធ្វើគ្រប់គ្នា សួរថា កូនអើយ កូននឹងទៅទទួលក្នុងវេលាធ្វើឬ ។ ក្មេង ២ នាក់នោះប្រាប់ថា ពួកខ្ញុំមិនត្រូវការអ្វីដទៃ តែឪពុករបស់យើងប្រាថ្នានឹងថ្វាយយាគូទាន ក្នុងវេលាដែលព្រះមានព្រះភាគស្តេចមក ។

ពួកមនុស្សបានស្តាប់ដូច្នោះហើយ ក៏មិនជំទាស់ ព្រមឲ្យវត្ថុដែល

ក្មេងទាំង ២ នាក់នោះ អាចនាំទៅបានទាំងអស់ ដែលមិនអាចនាំទៅបាន ក៏បញ្ជូនបុរសឲ្យនាំទៅ ។ គ្រាព្រះមានព្រះភាគ ស្តេចមកកាន់អាតុមានគរទ្រង់ក៏ចូលទៅកាន់រោងបាយ ល្ងាចសុភទ្ទៈភិក្ខុក៏ទៅកាន់ចន្លោះស្រុកហៅមនុស្សមកប្រាប់ថា ឧបាសកឧបាសិកាទាំងឡាយ ខ្ញុំមិនបានទទួលអ្វីៗយ៉ាងដទៃអំពីសម្នាក់របស់លោកទាំងឡាយ អង្ករជាដើម ដែលក្មេងរបស់ខ្ញុំនាំមក ក៏គ្រប់ល្មមដល់សង្ឃ ពួកលោកចូរឲ្យត្រឹមតែអ្នកមកជួយកិច្ចការចុះ ។ សួរថា ពួកខ្ញុំនឹងធ្វើយ៉ាងណាលោកម្ចាស់ ។ សុភទ្ទៈភិក្ខុនិយាយថា ពួកលោកចូរកាន់យកវត្ថុនេះៗ ហើយឲ្យកាន់គ្រឿងឧបករណ៍ទាំងអស់ឲ្យធ្វើចង្ក្រានក្បែរជិតវិហារ ខ្លួនឯងស្លៀកកាសាវៈខ្មៅមួយផ្ទាំង ដណ្តប់មួយផ្ទាំង ហើយប្រាប់ថា ចូរធ្វើវត្ថុនេះ សញ្ជឹងគិតរហូតអស់ ១ យប់ លះបង់ទ្រព្យមួយសែន ឲ្យគេចាត់យាគូសម្រាប់ផឹកស៊ី និងទឹកឃ្មុំ ដុំស្ករអំពៅ ។ យាគូដែលគប្បីផឹកស៊ី ឈ្មោះថា យាគូសម្រាប់ស៊ីផឹក ។ របស់មានទឹកដោះថ្លា ទឹកឃ្មុំ ទឹកអំពៅ ត្រី សាច់ ផ្កាឈើ ផ្លែឈើ និងរសជាដើមយ៉ាងណាមួយ ឈ្មោះថា របស់ទំពារ ដាក់របស់ទំពារទាំងអស់ចុះក្នុងយាគូនោះ ។ គន្ធជាតិដែលក្រអូប ដែលគេប្រើលាបសីសៈ សម្រាប់អ្នកត្រូវការលេងកីឡាក៏មាន ។

លុះវេលាព្រឹកព្រលឹម ព្រះមានព្រះភាគបដិបត្តិព្រះសរីរកិច្ចហើយ មានភិក្ខុសង្ឃហែហម ស្តេចយាងទៅកាន់អាតុមានគរ ដើម្បីត្រាច់បិណ្ឌបាត ។

មនុស្សទាំងឡាយ ក៏ប្រាប់ដល់សុភទ្ទៈភិក្ខុនោះថា ព្រះមានព្រះភាគស្តេចកំពុងយាងចូលស្រុកបិណ្ឌបាត លោកចាត់យាគូទុកដើម្បីអ្នកណា ។ សុភទ្ទភិក្ខុនោះ ស្លៀកដណ្តប់សំពត់កាសាវៈខ្មៅទាំងនោះ យកដៃម្ខាងចាប់វែកនិងបោយ លុតជង្គង់ខាងស្តាំចុះលើផែនដី ថ្វាយបង្គំដូចព្រហ្ម ទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ មេត្តាទ្រង់ទទួលយាគូរបស់ខ្ញុំព្រះអង្គចុះ ។ លំដាប់នោះ ព្រះមានព្រះភាគ ត្រាស់សួរ និងទ្រង់ស្តាប់ពាក្យនោះហើយ ទ្រង់តិះដៀលព្រះសុភទ្ទៈវុឌ្ឍបព្វជិតនោះ ។ ព្រោះរឿងនោះ ទ្រង់បញ្ញត្តិ ២ សិក្ខាបទ គឺ សិក្ខាបទ ពោលអំពីការបំបួលក្នុងវត្ថុជាអកប្បិយៈ និងសិក្ខាបទថាដោយការរក្សាទុក គ្រឿងកាំបិតកោរ ដោយន័យដែលមកក្នុងខន្ធកៈថា ព្រះតថាគត សូម្បីទ្រង់ជ្រាប ក៏ទ្រង់សួរដូច្នេះជាដើម ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុដែលស្វែងរកភោជនកន្លងទៅដល់ច្រើនកោដិកប្ប ពួកអ្នកបរិភោគភោជន ដែលជាអកប្បិយៈរបស់ពួកលោក ដែលកើតឡើងមិនប្រកបដោយធម៌ នឹងត្រូវទៅកើតក្នុងអបាយទាំងឡាយ ច្រើនសែនអត្តភាព ចូរចៀសទៅ កុំមកអូសទាញ ដូច្នេះហើយស្តេចទ្រង់យាងទៅដើម្បីភិក្ខា សូម្បីភិក្ខុមួយរូប ក៏មិនបានទទួលអ្វីៗឡើយ ។

សុភទ្ទភិក្ខុខូចចិត្ត ក៏ចងអាឃាតក្នុងព្រះមានព្រះភាគថា ព្រះមាន-ព្រះភាគនេះយល់ថា តថាគតដឹងគ្រប់វត្ថុទើបត្រាច់ទៅ បើទ្រង់មិនប្រាថ្នា

នឹងទទួល ក៏គួរបញ្ជូនអ្នកឲ្យទៅប្រាប់ ដែលឈ្មោះថា អាហារដែលឆ្អិនហើយនេះ កាលនឹងតាំងនៅយូរបាន គប្បីតាំងនៅបានត្រឹមតែ ៧ ថ្ងៃ ពិតហើយ របស់នេះ នឹងគប្បីជារបស់ដែលយើងចាត់ទុករហូតអស់ជីវិត ព្រះអង្គក៏ទ្រង់ធ្វើឲ្យវិនាសអស់ ព្រះមានព្រះភាគនេះ ទ្រង់មិនប្រាថ្នាសេចក្តីល្អអំពីយើងសោះឡើយ ។ កាលព្រះទសពលទ្រង់នៅមានព្រះជន្ម ទើបមិនអាចពោលអ្វីៗ បាន ។ បានឮថា ព្រះសុភទ្ទៈនោះគិតយ៉ាងនេះថា ព្រះមហាបុរសនេះ បួសអំពីត្រកូលខ្ពស់ បើយើងនិយាយអ្វីទៅក៏នឹងទ្រង់គំរាមយើងតែម្នាក់ ។ លុះបានស្តាប់ថា ព្រះមានព្រះភាគអង្គនេះ បរិនិព្វានហើយក្នុងថ្ងៃនេះ ក៏រីករាយត្រេកអរដូចបានខ្យល់ដកដង្ហើម ទើបពោលយ៉ាងនេះ ។ ព្រះថេរៈស្តាប់ពាក្យនោះហើយ មិនបានសម្គាល់ថា ដូចជាត្រូវប្រហារត្រង់ហទយៈ ដូចជាមេឃប្រាសចាកពពកដាច់ធ្លាក់លើអម្បែងក្បាល ។ តែព្រះថេរៈកើតធម៌សង្វេគ ។ ព្រះមានព្រះភាគបរិនិព្វានបានត្រឹមតែ ៧ ថ្ងៃ សូម្បីថ្ងៃនេះ ព្រះសរីរៈរបស់ព្រះអង្គមានព្រះឆវីវណ្ណដូចមាសក៏កំពុងតាំងនៅ ។ កាកបាប ចម្រូងចម្រាស់ដ៏ធំ កើតឡើងរហ័សយ៉ាងនេះក្នុងព្រះសាសនាដែលព្រះមានព្រះភាគទ្រង់នាំមកដោយទុក្ខលំបាក ក៏បុគ្គលបាបនេះ កាលធំធាត់ បានអ្នកដទៃឃើញបាបនោះជាបក្ខពួក ក៏អាចនឹងធ្វើព្រះសាសនាឲ្យសាបសូន្យអន់ថយបាន ។

លំដាប់នោះ ព្រះថេរៈគិតថា បើយើងនឹងឲ្យស្តេចតានេះស្លៀកសំពត់

ចាស់ យកកម្ទេចផេះពោយសីសៈ បណ្តេញចេញទៅ ។ មនុស្សទាំងឡាយ ក៏នឹងនាំគ្នាលើកទោសពួកយើងថា កាលព្រះសរីរៈរបស់ព្រះសមណគោតម តាំងនៅ ពួកសាវកក៏វិវាទគ្នា ព្រោះដូច្នោះ យើងទើបអត់ទ្រាំទុកសិនក៏ធម៌ដែលទ្រង់សម្តែងហើយនោះ ប្រៀបដូចផ្កាឈើទាំងឡាយដែលត្រូវខ្យល់ រមែងខ្ចាត់ខ្ចាយទៅ យ៉ាងណា សិក្ខាបទ ១-២ សិក្ខាបទ ក្នុងវិន័យ ក៏នឹងវិនាស បញ្ហាវារៈ ១-២ វារៈ ក្នុងសូត្រក៏នឹងវិនាស ភូមិដទៃ ១-២ ភូមិ ក្នុងអភិធម្មក៏នឹងវិនាស ក្នុងកាលកន្លងទៅ ដោយអំណាចបុគ្គលអាក្រក់បែបនេះ ក៏ដូច្នោះដែរ ។ កាលឫសគល់វិនាសទៅយ៉ាងនេះ ពួកយើងក៏នឹងដូចជាបីសាច ។ ព្រោះដូច្នោះ យើងចាំបាច់ត្រូវសង្គាយនាព្រះធម៌-វិន័យ បើដូច្នេះ ធម៌នេះ វិន័យនេះ ក៏នឹងរឹងមាំដូចផ្កាឈើដែលរក្សាទុកដោយអំបោះដ៏ស្វិត ក៏ដើម្បីប្រយោជន៍យ៉ាងនេះ ព្រះមានព្រះភាគ ស្តេចទទួលយើងរហូតដល់អស់ផ្លូវចម្ងាយ ៣ គាវុត ប្រទានឧបសម្បទដោយឱវាទ ៣ ប្រការ ទ្រង់ប្តូរចីវរអំពីព្រះវរកាយ ត្រាស់បដិបទា ប្រៀបដូចដួងច័ន្ទដូចជាគ្រវីដៃក្នុងអាកាស ទ្រង់លើកតម្កើងយើងជា កាយសក្ខី (មានវិហារ-ធម៌ស្មើដោយព្រះអង្គ) ទ្រង់ប្រគល់ភាពជាសកលសាសនទាយាទ ៣ ដង ថា កាលភិក្ខុដូចយើងតាំងនៅ ភិក្ខុអាក្រក់នេះ នឹងមិនបានសេចក្តីចម្រើនក្នុងព្រះសាសនា ។ អធម៌មិនរុងរឿង ធម៌ក៏នឹងមិនសាបសូន្យអន់ថយ អវិន័យមិនរុងរឿង វិន័យក៏នឹងមិនសាបសូន្យអន់ថយ ចំណែកអធម្មវាទីមិន

មានកម្លាំង ចំណែកធម្មវាទីក៏នឹងមិនខ្សោយកម្លាំង ចំណែកអវិន័យវាទី មិនមានកម្លាំង ចំណែកវិន័យវាទីក៏នឹងមិនខ្សោយកម្លាំង ត្រឹមណា យើង ក៏នឹងសង្គាយនាធម៌ និងវិន័យត្រឹមនោះ ។ តពីនោះ ពួកភិក្ខុរូបរួមភិក្ខុ ដែលជាសភាគគ្នា ប្រហាក់ប្រហែលនឹងខ្លួន ក៏នឹងពោលវត្ថុដែលគួរ និង មិនគួរបាន បើដូច្នេះ ភិក្ខុអាក្រក់ នេះឯងក៏ប្រសព្វនិគ្គហៈ មិនអាចងើប ក្បាលបានទៀត ព្រះសាសនាក៏នឹងរឹងមាំ និងផ្សាយទូទៅ ។ ព្រះថេរៈ គិតថា យើងកើតចិត្តគិតយ៉ាងនេះ ក៏មិនអាចប្រាប់នរណាបានល្មួងលោម ភិក្ខុសង្ឃ ។ ព្រោះហេតុនោះ លោកទើបពោលថា អថខោ មហាកស្សបោ ។បេ។ នេតំ ឋានំ វិជ្ជតិ ដូច្នេះ ។

[១៩៦] បទថា ចិតកំ បានដល់ ចិតកាធារ ដែលធ្វើដោយឈើចន្ទន៍ ប្រដាប់ដោយរតនៈពីរពាន់ ។ បទថា អាលិម្បេស្សាម បានដល់ ជួយគ្នា ដុតភ្លើង ។ បទថា ន សក្កោន្តិ គឺ ជនទាំងឡាយ ៨ នាក់ខ្លះ ១៦ នាក់ខ្លះ កាន់គប់ភ្លើងជាគូៗ ដើម្បីបន្ទាត់ភ្លើង បក់ដោយស្លឹកត្នោត ផ្លុំដោយស្នប់ សូម្បីធ្វើការណ៍នោះៗ ក៏មិនអាចធ្វើឲ្យភ្លើងឆេះបាន ។ គប្បីជ្រាបវិនិច្ឆ័យ ក្នុងពាក្យថា ទេវតានំ អធិប្បាយោ នេះ ដូច្នេះ ។ បានឮថា ទេវតា ទាំងនោះ ជាទេវតាឧបដ្ឋាករបស់ព្រះថេរៈនុ៎ះឯង ។ សេចក្តីពិត ព្រោះចិត្ត ជ្រះថ្លាព្រះអសីតិមហាសាវក ឧបដ្ឋាក ៨០,០០០ ត្រកូល របស់ព្រះមហា សាវកទាំងនោះ ក៏ទៅកើតក្នុងសួគ៌ ។ លំដាប់នោះ ពួកទេវតាអ្នកមាន

ចិត្តជ្រះថ្លាក្នុងព្រះថេរៈហើយកើតក្នុងសួគ៌ មិនឃើញព្រះថេរៈក្នុងសមាគម នោះ គិតថា ព្រះថេរៈប្រចាំត្រកូលរបស់ពួកយើងចេញទៅទីណាហ្ន៎ ក៏ឃើញ លោកដើរនៅចន្លោះផ្លូវ ទើបនាំគ្នាអធិដ្ឋានថា កាលព្រះថេរៈប្រចាំត្រកូល របស់ពួកយើងមិនទាន់បានថ្វាយបង្គំព្រះសរីរៈរបស់ព្រះមានព្រះភាគ សូម ចិត្តកាធារកុំឆេះភ្លើងឡើយ ដូច្នេះ ។ ពួកមនុស្សស្តាប់រឿងនោះហើយ គិតថា គេថា ព្រះមហាកស្សបៈ ពោលថា នៃភិក្ខុ យើងនឹងថ្វាយបង្គំ ព្រះបាទរបស់ព្រះទសពល ព្រមនឹងភិក្ខុ ៥០០ រូប ដូច្នេះហើយ ទើបមក កាលមកមិនដល់ចិត្តកាធារ ភ្លើងក៏នឹងមិនឆេះ អ្នកដ៏ចម្រើន ភិក្ខុនោះជា ប្រកទណា ខ្មៅ ស ខ្ពស់ ទាប កាលភិក្ខុដូច្នេះតាំងនៅ ហេតុដូចម្តេចព្រះ ទសពល ទើបបរិនិព្វាន ដូច្នេះហើយ ពួកខ្លះកាន់គ្រឿងក្រអូប និងផ្កាឈើ ជាដើម ដើរតាមផ្លូវ ពួកខ្លះធ្វើផ្លូវឲ្យស្អាតល្អ ឈរចាំមើលផ្លូវដែលនឹង មក ។

ពាក្យថា អថខោ អាយស្មា មហាកស្សបោ យេន កុសិនារា ។បេ។ សិរសា វន្ទិ សេចក្តីថា បានឮថា ព្រះថេរៈធ្វើប្រទក្សិណចិត្តកាធារបណ្តើរ រំលឹកកំណត់ថា ត្រង់នេះព្រះសិរសា ត្រង់នេះព្រះបាទ ។ តពីនោះ ព្រះថេរៈក៏ឈរជិតព្រះបាទទាំងពីរ ចូលចតុត្ថជ្ឈាន ដែលជាបាទនៃអភិញ្ញា ចេញចាកឈានហើយ អធិដ្ឋានថា សូមព្រះយុគលបាទរបស់ព្រះទសពល ដែលប្រកបដោយចក្កលក្ខណៈ ព្រមដោយកាំ ១.០០០ ប្រតិស្ឋានចុះ ចូរ

ញែកគូសំពត់ ៥០០ គូ ព្រមទាំងជាន់សំឡី ម្សៅសមាស និងចិត្តកាធារ ឈើចន្ទន៍ចេញជា ២ ប្រហោង ប្រតិស្ឋានលើសិរសារបស់ខ្ញុំព្រះអង្គផង ចុះ ។ ព្រមដោយចិត្តអធិដ្ឋាន ព្រះយុគលបាទ ក៏ញែកគូសំពត់ ៥០០ គូ ជាដើមទាំងនោះផុសឡើងចេញមក ដូចជាព្រះចន្ទពេញវង់ចេញចាកចន្លោះ វលាហកៈ ដូច្នោះ ។ ព្រះថេរៈលូកដៃទាំង ២ ដូចផ្កាបទុមក្រហមដែលរីក ហើយ ចាប់ព្រះយុគលបាទរបស់ព្រះសាស្តា ដែលមានព្រះឆវីវណ្ណដូចមាស ដរាបដល់កព្រះបាទទុកមាំហើយ ប្រតិស្ឋានទុកលើសិរសាដ៏ប្រសើររបស់ ខ្លួន ។ ដោយហេតុនោះ លោកទើបពោលថា បញ្ចេញព្រះបាទ ថ្វាយបង្គំ ព្រះបាទរបស់ព្រះមានព្រះភាគដោយសិរសា ។

មហាជនឃើញសេចក្តីអស្ចារ្យដូច្នោះហើយ បន្លឺសីហនាទដ៏ទ្រហឹង ឡើងព្រមគ្នា បូជាដោយគ្រឿងក្រអូប និងផ្កាឈើជាដើម ហើយសំពះតាម សេចក្តីពេញចិត្ត ។ ក៏ល្មមពេលព្រះថេរៈ មហាជន និងភិក្ខុ ៥០០ រូប ទាំងនោះថ្វាយបង្គំហើយ ក៏មិនមានកិច្ចដែលនឹងត្រូវអធិដ្ឋានទៀត ។ ដោយ អំណាចការអធិដ្ឋានតាមប្រក្រតីប៉ុណ្ណោះ បាតព្រះយុគលបាទរបស់ព្រះ-មានព្រះភាគមានវណ្ណៈដូចទឹកល័ក្ត ផុតពីដៃរបស់ព្រះថេរៈហើយ មិនធ្វើ ឈើចន្ទន៍ជាដើមអ្វីឲ្យញ័រ ប្រតិស្ឋាននៅក្នុងទីដើម ។ ពិតណាស់ កាល ព្រះយុគលបាទរបស់ព្រះមានព្រះភាគចេញមក ឬចូលទៅ សរសៃសំឡីក្តី សរសៃសំពត់ក្តី តំណក់ប្រេងក្តី ចម្រៀកឈើក្តី មិនឃ្លាតចាកទីឡើយ

ទាំងអស់តាំងនៅដូចដើមនុ៎ះឯង ។ តែកាលព្រះយុគលបាទ របស់ព្រះ-តថាគតតាំងឡើងហើយក៏បាត់ក្លាមទៅ ដូចព្រះចន្ទ និងព្រះអាទិត្យអស្តង្គត មហាជននាំគ្នាស្រែកយំយ៉ាងទ្រហឹង គួរករុណាក្រៃលែងជាងកាលបរិនិព្វាន ទៅទៀត ។

ក៏ពាក្យថា សមយេវ ភគវតោ ចិតកោ បជ្ជលិ នេះ លោកពោល ដោយអំណាចមើលមិនឃើញនរណាៗ អ្នកព្យាយាមឲ្យឆេះភ្លើង ។ ក៏ ចិត្តកាធារនោះ ឆេះភ្លើងក្លាមតែម្តងដោយជុំវិញដោយអានុភាពរបស់ទេវតា ។ បទថា សរីរានេវ អវសិស្សិំសុ សេចក្តីថា កាលមុនបានឈ្មោះថា សរីរៈ ក៏ព្រោះតាំងនៅដោយគ្រោងឆ្អឹងតែម្យ៉ាង ឥឡូវនេះ លោកពោលថា សរីរៈ ទាំងអស់ខ្ចាត់ខ្ចាយទៅហើយ ។ អធិប្បាយថា ព្រះធាតុទាំងឡាយ ក៏ដូច ផ្កាម្លិះក្រពុំ ដូចកែវមុក្តាដែលច្នៃហើយ និងដូចកម្ទេចមាសនៅសល់ ។ ពិតហើយ សរីរៈរបស់ព្រះពុទ្ធដែលមានព្រះជន្មាយុវែងទាំងឡាយ រមែង ជាប់គ្នាជាដុំដូចទឹងដុំមាស ។ ចំណែកព្រះមានព្រះភាគ ទ្រង់អធិដ្ឋានព្រះធាតុ ឲ្យបែកជាបំណែក ថា តថាគតនៅបានមិនយូរ ក៏នឹងបរិនិព្វាន សាសនា របស់តថាគតមិនទាន់ផ្សាយច្រើនទៅក្នុងទីទាំងពួងទេ ព្រោះដូច្នោះ កាល តថាគតសូម្បីបរិនិព្វានហើយ មហាជនកាន់យកព្រះធាតុសូម្បីខ្នាតប៉ុនគ្រាប់ ស្ពៃ ធ្វើចេតិយក្នុងទីនៅរៀងៗ ខ្លួន ប្រតិបត្តិ ចូរមានសួគ៌ជាទីទៅក្នុងខាង មុខ ។ សួរថា ព្រះធាតុយ៉ាងណារបស់ព្រះអង្គ បែកជាបំណែក យ៉ាងណា

មិនបែកជាបំណែក ។ ឆ្លើយថា ព្រះធាតុ ៧ ទាំងនេះ គឺ ព្រះចង្កូមកែវ ៤ ព្រះដងកាំបិត ២ ព្រះឧណ្ហិស្ស ១ មិនបែកជាបំណែក ក្រៅនោះបែកជាបំណែក ។ បណ្ដាព្រះធាតុទាំងនោះ ព្រះធាតុតូចៗ ទាំងអស់មានខ្នាតប៉ុនគ្រាប់ស្ពៃ ។ ព្រះធាតុធំខ្នាតប៉ុនគ្រាប់អង្ករបាក់ពាក់កណ្ដាល ព្រះធាតុខ្នាតធំក្រៃលែងមានខ្នាតប៉ុនគ្រាប់សណ្ដែកបាយបាក់ពាក់កណ្ដាល ។

បទថា ឧទកធារា សេចក្ដីថា ទឹកខ្នាតចុងប៉ុនកដៃក្តី ខ្នាតប៉ុនស្មងជើងក្តី ខ្នាតប៉ុនដើមត្នោតក្តី ធ្លាក់អំពីអាកាសមករំលត់ ។ ពាក្យថា ឧទកំ សាលតោបិ នេះ លោកពោលសំដៅដើមសាលៈដែលដុះជុំវិញ ។ ទទឹកចេញពីចន្លោះដើម និងចន្លោះបង្កាបមែករបស់ដើមសាលៈទាំងនោះ រំលត់ភ្លើង ។ ចិតការធាររបស់ព្រះមានព្រះភាគខ្នាតធំ ។ ទទឹកខ្នាតប៉ុនយាមនង្គ័ល ជ្រែកដីដោយជុំវិញ ដូចនឹងភួងកែវផលឹកផុសឡើងគ្របចិតកា-ធារ ។ បទថា គន្ធោទកេន បានដល់ ទឹកក្រអូបច្រើនប្រភេទ ដែលគេដាក់ក្នុងថ្នាំងមាស ថ្នាំងប្រាក់ឲ្យពេញនាំមក ។ បទថា និព្វាបេសុំ សេចក្ដីថា ពួកមល្លក្សត្ររំលត់ចិត្តកាធាធាយដោយដំបង ៨ កំណាត់ ដែលធ្វើដោយមាស និងប្រាក់ ។ ក៏កាលភ្លើងកំពុងឆេះចិតកាធារនោះ អណ្ដាតភ្លើងក៏បាញ់ឡើងអំពីចន្លោះមែក បង្កាប និងស្លឹករបស់ដើមសាលៈ ដែលដុះជុំវិញ ។ ស្លឹក មែក ឬផ្កាមិនឆេះឡើយ ។ ទាំងស្រមោចក្រហម ទាំងស្វា ទាំងសត្វតូចៗ ត្រាច់ទៅតាមចន្លោះអណ្ដាតភ្លើង ។ ធម្មតាក្នុងទទឹកដែល

ធ្លាក់អំពីអាកាសក្តី ក្នុងទឹកដែលចេញពីដើមសាលៈក្តី ក្នុងទឹកដែលញែកផែនដីចេញមកក្តី គួរកាន់យកជាប្រមាណ ។

ក៏ឯគ្រាចិតកាធារលត់យ៉ាងនេះហើយ ពួកស្តេចមល្លៈក៏ឲ្យប្រោះព្រំដោយគន្ធជាតិ ៤ ប្រភេទ នៅសណ្ឋាគារភោយផ្កាឈើ មានលាជជាគម្រប់ ៥ ប្រក់ពិតានសំពត់ទុកខាងលើ ចងបន្ទោងដោយផ្កាយមាសជាដើម ព្យួរកម្រងក្រអូប កម្រងផ្កា និងកម្រងកែវ ឲ្យតន្ត្រីវាំងនន និងកន្ទេលផែងទុកសងខាងតាំងពីសណ្ឋាគារដ៏រាបដល់មណ្ឌលសាលា ដែលប្រដាប់សីសៈពោលគឺ មកុដពន្ធនៈ ហើយប្រក់ពិតានសំពត់ទុកខាងលើ បន្ទោងដោយផ្កាយមាសជាដើម ព្យួរកម្រងក្រអូប កម្រងផ្កា និងកម្រងកែវ សូម្បីក្នុងទីនោះ ឲ្យលើកទង់ ៥ ពណ៌ ដោយទង់ពណ៌មណី និងឫស្សី លោមពន្ទទង់ជ័យ និងទង់បដា ទុកដោយជុំវិញ តាំងដើមចេក និងថ្នាំងទឹកទុកតាមចិញ្ចើមថ្នល់ទាំងឡាយ ប្រោះទឹក ហើយពង្រាបផ្លូវ អុជប្រទីបមានជើងតម្កល់ម្សៅមាស ព្រមដោយព្រះធាតុទាំងឡាយ ទុកលើកដំរីដែលប្រដាប់ហើយ បូជាដោយកម្រងផ្កា និងគ្រឿងក្រអូបជាដើម លេងសាធុកីឡា នាំចូលទៅខាងក្នុងព្រះនគរ តម្កល់លើបល្ល័ង្កដែលធ្វើដោយរតនៈ ៧ ប្រការ ក្នុងសណ្ឋាគារបាំងស្វេតឆត្រទុកខាងលើ ។ លុះធ្វើដូច្នេះហើយ គ្រានោះពួកមល្លក្សត្រអ្នកនគរកុសិនារា ឲ្យទាហានកាន់លំពែងធ្វើជារបងការពារ ឲ្យទាហានកាន់ធ្នូជាកំពែងពន្ទទីសណ្ឋាគារ បូជាព្រះសរីរៈរបស់ព្រះមាន-

ព្រះភាគ ដោយការលេងរបាំ ច្រៀង ការប្រគុំ កម្រងផ្កា គ្រឿងក្រអូប រហូតដល់អស់ ៧ ថ្ងៃ បណ្ឌិតគប្បីជ្រាបដូចពោលមក ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា សត្តិបញ្ជរំ ករិត្វា បានដល់ ចាត់ពួកបុរសកាន់លំពែងលោមព័ទ្ធ ។ បទថា ធនុថាការំ បានដល់ ចាត់ពួកដំរីរៀងលំដាប់ពោះទល់គ្នា ព័ទ្ធជុំវិញទុកជាមុន តពីនោះ ចាត់ពួកសេះរៀងលំដាប់កទល់គ្នា តពីនោះ ចាត់ពួករថរៀងលំដាប់ ចុងស្ទៀតកង់រថទល់គ្នា ចាត់ពួកធ្នូរៀងលំដាប់តគ្នាព័ទ្ធជុំវិញទៀត ។ ពួកមល្លក្សត្រចាត់រក្សារហូតដល់អស់ទីប្រមាណមួយយោជន៍ដោយជុំវិញ ៧ ថ្ងៃ ធ្វើដូចជាកូនគោពាក់ក្រោះ ដោយប្រការដូច្នេះ ។

លោកសំដៅយកសេចក្តីនោះ ទើបពោលថា ធនុថាការំ បរិក្ខិ-ថាបេត្វា ដូច្នេះ ។ សួរថា ក៏ព្រោះហេតុអ្វី ពួកមល្លក្សត្រទាំងនោះ ទើបបានធ្វើដូច្នោះ ។ ឆ្លើយថា ក្នុង ២ សប្តាហ៍ដំបូងនេះ មល្លក្សត្រទាំងនោះធ្វើឱកាសដែលឈរ និងអង្គុយសម្រាប់ភិក្ខុសង្ឃ ចាត់ចែងរបស់ទំពាររបស់ធាន់ថ្វាយ មិនបានឱកាសលេងសាធុកីឡា ។ តពីនោះ មល្លក្សត្រទាំងនោះគិតគ្នាថា ពួកយើងនឹងលេងសាធុកីឡារហូតអស់ ១ សប្តាហ៍នេះ ។ សេចក្តីដែលនរណាៗ ដឹងថា ពួកយើងប្រមាទ ហើយមកកាន់យកព្រះធាតុទាំងឡាយចេញទៅ មិនជាឋានៈដែលនឹងប្រព្រឹត្តទៅបាន ព្រោះដូច្នោះ ពួកយើងនឹងត្រូវតាំងកងរក្សាទុក ហើយលេងកីឡា ។ ដោយហេតុនោះ មល្លក្សត្រ

ទាំងនោះ ទើបបានធ្វើដូច្នោះ ។

## រឿងព្រះចាទអជាតសត្តុជាដើម

**[១៥៧]** បទថា អស្សោសិ ខោ រាជា សេចក្តីថា ព្រះបាទអជាត-សត្រូវទ្រង់ជ្រាបរឿងហើយ ។ បានឮថា ពួកអាមាត្យរបស់ស្តេចគិតតាំងពីដំបូងតែម្តងថា ធម្មតាថា ព្រះសាស្តាបរិនិព្វានហើយ នរណាៗក៏មិនអាចនាំព្រះអង្គមកបាន តែមិនមានអ្នកស្មើដូចព្រះរាជារបស់យើងដោយសទ្ធារបស់បុថុជ្ជន បើព្រះរាជាអង្គនេះនឹងទ្រង់ស្តាប់ដោយទំនងនេះ ហឫទ័យរបស់ទ្រង់នឹងត្រូវបែក តែពួកយើងគួរប្រុងប្រយ័ត្នរក្សាព្រះរាជាទុកដូច្នេះ ។ អាមាត្យទាំងនោះ ទើបនាំម្ស៉ៅសមាស ៣ បញ្ចុះរបស់ផ្អាញ់ៗទុកពេញ នាំទៅកាន់រាជសម្នាក់ ក្រាបទូលថា បពិត្រទេវៈ ពួកខ្ញុំព្រះអង្គយល់សប្តិឃើញព្រះអង្គគួរស្លៀកសំពត់សំបកឈើពីរជាន់ ហើយផ្ទុំក្នុងម្ស៉ៅដែលពេញដោយរបស់ផ្អាញ់ៗ ៤ យ៉ាង ទុកតែប្រហោងដកដង្ហើម ដើម្បីកម្ចាត់ការយល់សប្តិនោះចេញ ព្រះរាជា ស្តាប់ពាក្យរបស់ពួកអាមាត្យអ្នកប្រាថ្នាល្អ ទ្រង់ត្រាស់ថា យើងធ្វើបាន ហើយទ្រង់បានធ្វើយ៉ាងនោះ ។ លំដាប់នោះ អាមាត្យម្នាក់ដោះគ្រឿងប្រដាប់ ហើយរំសាយសក់ឲ្យបែរមុខទៅទិសដែលព្រះសាស្តាបរិនិព្វាន ។ ផ្គងអញ្ជលីទូលព្រះរាជាថា ព្រះអង្គដែលឈ្មោះថា សត្វអ្នករួចផុតអំពីសេចក្តីស្លាប់មិនមានទេ ព្រះមានព្រះ-

ភាគអន្តនោះ ទ្រង់ជាអ្នកចម្រើនជន្មាយុ ជាចេតិយស្ថាន ជាបុញ្ញខេត្ត ជាព្រះទេនអភិសេក ជាសាស្តារបស់យើងទាំងឡាយ បរិនិព្វានហើយ ក្នុងនគរកុសិនារា ព្រះរាជាទ្រង់ស្តាប់ហើយ ក៏ដល់នូវវិសញ្ញីភាព (សន្លប់) បញ្ចេញចំហាយក្តៅក្នុងម្ស្សសដែលពេញដោយរបស់ធ្ងាញ់ ៤ យ៉ាង លំដាប់នោះ ពួកអាមាត្រក៏លើកព្រះអង្គឡើងអំពីម្ស្សសទី ១ នោះ ឲ្យផ្ទំក្នុងម្ស្សសទី ២ ។ ស្តេចត្រឡប់ភ្ញាក់ឡើង ត្រាស់សួរថា បាអើយ ពួកអ្នកនិយាយអ្វីហ្ន៎ ។ ក្រាបទូលថា ព្រះមហារាជ ព្រះសាស្តាបរិនិព្វានហើយ ក្រាបទូល ។ ព្រះរាជាក៏ត្រឡប់ទ្រង់វិសញ្ញីភាពទៀត បញ្ចេញចំហាយក្តៅក្នុងម្ស្សសដែលមានរបស់ធ្ងាញ់ ៤ យ៉ាង ។ លំដាប់នោះពួកអាមាត្រជួយគ្នាលើកព្រះរាជាឡើងអំពីម្ស្សសទី ២ នោះ ហើយឲ្យផ្ទំក្នុងម្ស្សសទី ៣ ។ ស្តេចទ្រង់ត្រឡប់ស្មារតីឡើងមក ត្រាស់សួរថា បាអើយ ពួកអ្នកនិយាយអ្វីហ្ន៎ ។ ក្រាបទូលថា ព្រះសាស្តាបរិនិព្វានហើយ ព្រះអង្គ ។ ព្រះរាជា ក៏ទ្រង់វិសញ្ញីភាពទៀត ។ គ្រានោះ ពួកអាមាត្រជួយគ្នាលើកព្រះអង្គឡើងឲ្យស្រង់ទឹក យកធ្នាំងទឹកជ្រួចទឹកចុះលើព្រះសិរសា ។

ព្រះរាជាទ្រង់ចាំបានហើយ ក្រោកចាកទីប្រថាប់រំសាយព្រះកេសាដែលមានវណ្ណៈហាក់បីដូចកែវមណី អប់ដោយគ្រឿងក្រអូប ទម្លាក់ខ្នងដែលមានវណ្ណៈដូចផែនមាស យកព្រះហស្តគក់ព្រះទ្រូង ចាប់ទ្រូងដែលមានវណ្ណៈដូចផ្លែបាសមាស ហាក់ដូចជានឹងសីកដោយម្រាមព្រះហស្តដ៏មូល

ក្រឡឹង ដែលមានវណ្ណៈដូចពន្លកកែវប្រវាឡ ទ្រង់ទួញយំ ស្តេចចុះទៅក្នុងចន្លោះថ្នល់ ដោយភេទរបស់អ្នកវិកលចរិត ស្តេចមាននាងរបាំដែលតែងខ្លួនហើយជាបរិវារ ស្តេចចេញចាកព្រះនគរទៅកាន់សួនស្វាយរបស់ពេទ្យជីវក ទតព្រះនេត្រក្នុងស្ថានទីដែលព្រះមានព្រះភាគប្រថាប់សម្តែងធម៌ បរិទេវនាការ ត្អូញត្អែររៀបរាប់ដដែលៗ ថា ព្រះមានព្រះភាគជាសព្វញ្ញូ ប្រថាប់សម្តែងធម៌ទីនេះ មិនមែនឬ ? ទ្រង់បន្ទោបង់សេចក្តីសោករបស់ខ្ញុំព្រះអង្គ ព្រះអង្គទ្រង់នាំសេចក្តីសោករបស់ខ្ញុំព្រះអង្គចេញទៅ បពិត្រ ព្រះមានព្រះភាគ ខ្ញុំព្រះអង្គមកកាន់សម្នាក់របស់ព្រះអង្គហើយ តែឥឡូវនេះ ព្រះអង្គមិនប្រទានសូម្បីពាក្យឆ្លើយឆ្លងដល់ខ្ញុំព្រះអង្គ និងត្រាស់ពាក្យជាដើម យ៉ាងនេះថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គស្តាប់មកក្នុងវេលាដទៃ មិនមែនឬ ? ថា ក្នុងវេលាបែបនោះ ព្រះអង្គមានភិក្ខុសង្ឃពួកធំជាបរិវារ ស្តេចចារិកទៅក្នុងភាគផែនដីជម្ពូទ្វីប តែឥឡូវនេះ ខ្ញុំព្រះអង្គក៏បានតែស្តាប់រឿងដែលមិនសមគួរ មិនគួរដល់ព្រះអង្គឡើយ ហើយទ្រង់រំលឹកព្រះគុណរបស់ព្រះមានព្រះភាគដោយគាថា ប្រមាណ ៦០ គាថា ទ្រង់ព្រះតម្រិះថា អ្វីៗ រមែងមិនសម្រេចបានដោយបរិទេវនាការរបស់យើង ចាំបាច់យើងនឹងឲ្យនាំព្រះបរមធាតុរបស់ព្រះទសពលមក ។ ទ្រង់ស្តាប់មកយ៉ាងនេះហើយ កាលទ្រង់បាត់វិសញ្ញីភាពជាដើម ហើយក៏បញ្ជូនទូតទៅ ។ លោកសំដៅយករឿងនោះ ទើបពោលថា អថ ខោ រាជា ជាអាទិ៍ ។

បណ្តាទាំងនោះ បទថា ទូតំ ចាហេសិ បានដល់ ទ្រង់បញ្ជូនទូត និងបណ្ណាការទៅ ។ ព្រះបាទអជាតសត្តុទ្រង់ព្រះតម្រិះថា បើពួកមល្លក្សត្រឲ្យក៏ជាការល្អ បើគេមិនឲ្យ យើងនឹងត្រូវនាំមកដោយឧបាយឲ្យបាន ដូច្នេះ ។ ទ្រង់ចាត់កងទ័ព ៤ ពួក ស្តេចចេញទៅដោយព្រះអង្គឯង ។ សូម្បីពួកស្តេចលិច្ឆវីជាដើម ក៏បញ្ជូនទូតទៅ ស្តេចចេញទៅដោយព្រះអង្គឯង ព្រមដោយកងទ័ព ៤ ពួក ដូចព្រះបាទអជាតសត្តុដូច្នោះ ។ បើមានពាក្យសួរថា បណ្តាស្តេចទាំងនោះ មល្លក្សត្រអ្នកនគរបាវា មានចម្ងាយជិតជាងគេទាំងអស់ នៅក្នុងនគរបាវាចម្ងាយ ៣ គាវុត អំពីនគរកុសិនារា សូម្បីព្រះមានព្រះភាគស្តេចយាងទៅនគរបាវាហើយ ស្តេចក៏យាងទៅកាន់នគរកុសិនារា បើដូច្នោះ ព្រោះហេតុអ្វី ពួកមល្លក្សត្រនគរបាវា ទើបស្តេចមិនមកជាមុន ។ ឆ្លើយថា ព្រោះថា ពួកស្តេចទាំងនោះ មានបរិវារច្រើនកាលធ្វើកិច្ចចំពោះបរិវារដ៏ច្រើន ទើបមកតាមក្រោយ ។ បទថា តេ សង្ឃេ គណេ ឯតទវោចុំ សេចក្តីថា ពួកស្តេច និងព្រាហ្មណ៍ទាំងអស់នោះ រួមជាអ្នកនគរ ៧ នគរ នាំគ្នាមកហើយ ប្រកាសពាក្យដាច់ខាតថា ពួកស្តេចមល្លៈនឹងឲ្យព្រះបរមធាតុដល់ពួកយើង ឬត្រូវច្បាំង ។ ហើយតាំងទ័ពឡោមព័ទ្ធនគរកុសិនារា ពួកស្តេចមល្លៈក៏បានពោលពាក្យឆ្លើយឆ្លងទៅថា ព្រះមានព្រះភាគស្តេចបរិនិព្វានក្នុងគាមខេត្តរបស់ពួកយើងនេះ ។

បានឮថា ស្តេចទាំងនោះត្រាស់យ៉ាងនេះថា ពួកយើងមិនបានបញ្ជូន

ដំណើងរបស់ព្រះសាស្តា ពួកយើងទៅក៏មិនបាននាំដំណើងមក តែព្រះសាស្តាស្តេចមកដោយព្រះអង្គឯង ទ្រង់បញ្ជូនដំណើងទៅត្រាស់បង្គាប់ឲ្យហៅពួកយើង ប្រសិនបើពួកលោក ក៏មិនឲ្យព្រះរតនៈដែលកើតក្នុងគាមខេត្តរបស់ពួកលោកដល់ពួកយើងដែរ ធម្មតាថា ព្រះរតនៈដែលស្មើដោយព្រះពុទ្ធរតនៈ មិនមានក្នុងលោក ព្រមទាំងទេវលោក ពួកយើងបានព្រះរតនៈដ៏ឧត្តុងឧត្តមបំផុតបែបនេះ នឹងមិនព្រមឲ្យ មានតែពួកលោកប៉ុណ្ណោះឬ ផឹកទឹកដោះអំពីរបស់មាតា ពួកយើងមិនបានផឹកឬ ។ ពួកលោកប៉ុណ្ណោះជាកូនប្រុស ពួកយើងមិនមែនជាកូនប្រុសឬ គឺ ដូចតែគ្នា ក៏ធ្វើអហំការបញ្ជូនសាសន៍ឆ្លើយឆ្លងគ្នា ប្រើមានះគម្រាមដល់គ្នានិងគ្នា ។ កាលបើមានការច្បាំងគ្នា ចំណែកពួកមល្លក្សត្រក្រុងកុសិនារា គួរបានជ័យជំនះ ។ ព្រោះហេតុអ្វី ? ព្រោះពួកទេវតាដែល នាំគ្នាមកដើម្បីបូជាព្រះបរមធាតុ ត្រូវជាបក្ខពួករបស់មល្លក្សត្រក្រុងកុសិនារាទាំងអស់ ។ តែក្នុងព្រះបាលីមកត្រឹមតែប៉ុណ្ណោះថា មល្លក្សត្រក្រុងកុសិនារា ពោលថា ព្រះមានព្រះភាគបរិនិព្វានក្នុងគាមខេត្តរបស់ពួកយើង ពួកយើង នឹងមិនព្រមឲ្យចំណែកនៃព្រះសរីរៈរបស់ព្រះមានព្រះភាគ ដូច្នេះ ។

## ការចែកព្រះបរមធាតុរបស់ព្រះមានព្រះភាគ

[១៥៨] បទថា ឯវំ វុត្តេ ទោណោ ព្រាហ្មណោ សេចក្តីថា ទោណព្រាហ្មណ៍ស្តាប់រឿងការវិវាទរបស់ក្សត្រ ព្រាហ្មណ៍ទាំងនោះហើយ ត្រិះរិះថា ពួកស្តេចទាំងនេះបង្ករវិវាទគ្នាក្នុងស្ថានទីព្រះមានព្រះភាគបរិនិព្វាន ៗ ជាការមិនសមគួរ ៗ ការឈ្លោះគ្នានេះ គួរនឹងល្មមប៉ុណ្ណឹងហើយ យើងចាំបាច់ត្រូវតែរម្ងាប់ការវិវាទគ្នានោះចេញ ដូច្នេះហើយ ក៏ទៅពោលសេចក្តីនេះ ដល់ពួកគណៈស្តេចទាំងនោះ ៗ ពោលថា យ៉ាងណា ? ទោណព្រាហ្មណ៍ឈរក្នុងទីទួល (ខ្ពស់) បានពោលគាថា ដែលឈ្មោះថា **ទោណគជ្ជិត** (ការបន្លឺរបស់ទោណព្រាហ្មណ៍) ប្រមាណ ២ ភាណវារៈ ៗ បណ្តាភាណវារៈទាំង ២ នោះ ភាណវារៈមុន ពួកស្តេចទាំងនោះមិនដឹងសូម្បីតែមួយបទ ៗ ចប់ភាណវារៈទី ២ ពួកស្តេចទាំងអស់និយាយគ្នាថា អ្នកដ៏ចម្រើននោះ មើលទៅដូចជាសំឡេងរបស់លោកអាចារ្យនេះៗ ហើយក៏នាំគ្នាស្ងាត់សំឡេង ៗ គេថា ក្នុងភាគផែនដីជម្ពូទ្វីប អ្នកដែលកើតក្នុងផ្ទះរបស់ត្រកូលដោយច្រើន ឈ្មោះថា មិនជាសិស្សរបស់ទោណព្រាហ្មណ៍នោះ មិនមានឡើយ ៗ គ្រានោះ ទោណព្រាហ្មណ៍ដឹងថា ស្តេចទាំងនោះស្តាប់ពាក្យរបស់ខ្លួនហើយនៅស្ងៀម ទើបបានពោលពាក្យដដែល បានពោល ២ គាថា នេះថា សុណន្តុ ភោន្តោ ជាដើម ៗ

បណ្ដាបទទាំងនោះ បទថា អម្ហាកំ ពុទ្ធោ ប្រែថា ព្រះពុទ្ធរបស់ពួកយើង ។ បទថា អហុ ខន្តិវាទោ សេចក្ដីថា ព្រះអង្គសូម្បីមិនទាន់សម្រេចពុទ្ធភូមិ ទ្រង់បំពេញបារមីទាំងឡាយ ទ្រង់មិនធ្វើសេចក្ដីក្រោធក្នុងអ្នកដទៃៗ បានធ្វើតែខន្តិតែម្យ៉ាង ទ្រង់សរសើរខន្តិតែម្យ៉ាង សម័យសោយព្រះជាតិជាខន្តិវាទិតាបស សម័យជាធម្មបាលកុមារ សម័យជាស្ដេចដំរីឆទ្ទន្ត សម័យជាស្ដេចនាគឈ្មោះភូរិទត្ត សម័យជាស្ដេចនាគឈ្មោះចម្បេយ្យកៈ សម័យជាស្ដេចនាគឈ្មោះសង្ខបាលៈ សម័យជាក្របីធំ និងក្នុងជាតកដទៃៗ ជាច្រើន ។ នឹងចាំបាច់ពោលទៅថ្វីឥឡូវនេះ ព្រះពុទ្ធរបស់ពួកយើងទ្រង់សម្រេចលក្ខណៈភាពជាអ្នករឹងមាំក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ មានព្រះវាទៈក្នុងរឿងខន្តិ ។ ការដែលពួកយើងនឹងមកប្រហារគ្នា ក្នុងហេតុរឿងចំណែកព្រះសរីរៈរបស់ព្រះអង្គដែលជាបុគ្គលខ្ពង់ខ្ពស់បំផុត ដូចដែលពោលមកនេះ មិនល្អឡើយ ។ ពាក្យថា ន ហិ សាធុយំ កាត់បទថា ន ហិ សាធុ អយំ ។ បទថា សរីរភាគេ ប្រែថា និមិត្តនៃចំណែករបស់ព្រះសរីរៈ អធិប្បាយថា ហេតុចំណែកនៃព្រះបរមធាតុ ។ បទថា សិយា សម្បហារោ លោកអធិប្បាយថា ការប្រហារគ្នាដោយអាវុធមិនល្អឡើយ ។ បទថា សព្វេវ ភោន្តោ សហិតា សេចក្ដីថា នៃលោកដ៏ចម្រើនទាំងឡាយ ពួកលោកទាំងអស់ចូររួបរួមគ្នា កុំបែកគ្នាឡើយ ។ បទថា សមគ្គា បានដល់ ចូរជាអ្នកព្រមព្រៀងគ្នា និយាយពាក្យជាមួយគ្នា សាមគ្គីគ្នា ផ្លូវកាយ និងផ្លូវវាចា

ចុះ ។ បទថា សម្មោទមានា បានដល់ ចូរជាអ្នករីករាយរកគ្នានិងគ្នា សូម្បីផ្លូវ ចិត្តចុះ ។ បទថា ករោមដ្ឋ ភាគេ សេចក្តីថា ចូរបែងចែកព្រះសរីរៈរបស់ព្រះមានព្រះភាគជា ៨ ចំណែក ។ បទថា ចក្ខុមតោ បានដល់ ព្រះពុទ្ធទ្រង់មានចក្ខុ ដោយចក្ខុ ៥ ។ ទោណព្រាហ្មណ៍បាន ពោលហេតុជាច្រើន ឲ្យយល់គ្នាថា មិនមែនពួកលោកតែមួយដែលជ្រះថ្លា សូម្បីមហាជនក៏ជ្រះថ្លា ជនទាំងនោះ អ្នកឈ្មោះថា មិនគួរនឹងបានចំណែក បែងចែកព្រះសរីរៈមិនមាន សូម្បីតែម្នាក់ ។

[១៥៩] បទថា តេសំ សង្ឃានំ គណានំ បដិស្សុណិត្វា សេចក្តីថា ព្រោះពួកគណៈដែលមកប្រជុំគ្នាអំពីទីនោះៗ ទាំងនោះ ព្រមស្តាប់ (យល់ព្រម) ទោណព្រាហ្មណ៍ ទើបបែងចែកព្រះសរីរៈរបស់ព្រះមានព្រះភាគជា ៨ ចំណែក ស្មើៗ គ្នា ។ លំដាប់សេចក្តីក្នុងរឿងនោះ មានដូច្នេះ ។

បានឮមកថា ព្រោះស្តេចទាំងនោះយល់ព្រម ទោណព្រាហ្មណ៍ ទើបបង្គាប់ឲ្យបើកម្ជូសមាស ។ ស្តេចទាំងឡាយក៏មកឈរត្រង់ម្ជូសមាសនុ៎ះឯង នាំគ្នាមើលឃើញព្រះបរមធាតុទាំងឡាយ មានវណ្ណៈប្រៀបដូចមាស នាំគ្នាយំរៀបរាប់ថា បពិត្រព្រះមានព្រះភាគជាសព្វញ្ញូ អំពីមុនខ្ញុំព្រះអង្គទាំងឡាយ បានឃើញព្រះសរីរៈរបស់ព្រះអង្គមានវណ្ណៈដូចមាស ប្រដាប់ដោយព្រះមហាបុរិសលក្ខណៈ ៣២ ប្រការ វិចិត្តដោយព្រះពុទ្ធរស្មី មានវណ្ណៈ ៦ ប្រការ ល្អរុងរឿងដោយព្រះអនុព្យញ្ជនៈ ៨០ ប្រការ តែឥឡូវ

នេះ ក៏នៅសល់តែព្រះបរមធាតុ មានវណ្ណៈដូចជាមាស បពិត្រព្រះមាន-ព្រះភាគ ការណ៍នេះមិនសមគួរដល់ព្រះអង្គឡើយ ។ សម័យនោះ សូម្បីទោណព្រាហ្មណ៍ដឹងថា ស្តេចទាំងនោះធ្វេសប្រហែស ក៏កាន់យកព្រះចង្កូមកែវខាងស្តាំ រក្សាទុកក្នុងសំពត់ជួតក្បាល ។ តមកខាងក្រោយ ទើបបែងចែកជា ៨ ចំណែកស្មើៗ គ្នា ព្រះបរមធាតុទាំងអស់ រួមបាន ១៦ នាឡិ ដោយនាឡិតាមប្រក្រតី ស្តេចមួយនគរៗ បាន ២ នាឡិគ្រប់គ្នា ។ ចំណែកកាលទោណព្រាហ្មណ៍កំពុងបែងចែកព្រះបរមធាតុនុ៎ះឯង ។ សក្កទេវរាជជាស្តេចទេវតាត្រួតមើលថា អ្នកណាហ្ន៎យកព្រះចង្កូមកែវខាងស្តាំ របស់ព្រះមានព្រះភាគ ដែលជាបច្ច័យនៃការត្រាស់រឿងសច្ចៈ ៤ ដើម្បីទ្រង់ប្រាថ្នាកាត់សេចក្តីសង្ស័យរបស់លោកព្រមទាំងទេវលោកទៅ ក៏ទ្រង់ឃើញថា ព្រាហ្មណ៍កាន់យកទៅ ។ ទ្រង់ត្រិះរិះថា សូម្បីព្រាហ្មណ៍ក៏មិនអាចធ្វើសក្ការៈដ៏គួរដល់ព្រះចង្កូមកែវបាន ចាំបាច់យើងនឹងកាន់យកព្រះ-ចង្កូមកែវនោះ ហើយទ្រង់កាន់យកអំពីសំពត់ជួតក្បាល បញ្ចុះទុកក្នុងប្រអប់មាស នាំទៅកាន់ទេវលោក ប្រតិស្ឋានទុកក្នុងព្រះចូឡាមណីចេតិយ ។ ចំណែកព្រាហ្មណ៍ លុះបែងចែកព្រះបរមធាតុហើយ មិនឃើញព្រះចង្កូមកែវ តែព្រោះខ្លួនកាន់យកដោយកិរិយានៃចោរ ទើបមិនអាចសូម្បីតែនឹងសួរថា អ្នកណាយកព្រះចង្កូមកែវរបស់យើងទៅ ។ ឃើញតែការលើកទោសក្នុងខ្លួនឯងថា អ្នកឯងប៉ុណ្ណោះបែងចែកព្រះបរមធាតុមិនមែនឬ ហេតុ

ដូចម្តេចអ្នកឯងមិនដឹងថា ព្រះបរមធាតុរបស់ខ្លួនមាននៅមុនហ្ន៎ ។ លំដាប់នោះ ព្រាហ្មណ៍គិតថា នាឡិមាសនេះ ក៏មានគតិដូចព្រះបរមធាតុ យើងនឹងធ្វើនាឡិមាស ដែលវាល់ព្រះបរមធាតុរបស់ព្រះតថាគតជាសថូប ហើយទើបទូលថា លោកដ៏ចម្រើនទាំងឡាយ មេត្តាប្រទាននាឡិនេះ ដល់ខ្ញុំព្រះអង្គចុះ ។

[១៦០] សូម្បីពួកស្តេចមោរិយៈ ក្រុងបិប្ផលិវ័ន ក៏បញ្ជូនទូតទៅត្រៀមការច្បាំង លើកចេញទៅ ដូចព្រះបាទអជាតសត្តុជាដើម ។

## ធាតុសារីរិកគាថា

[១៦១] ព្រះបាទអជាតសត្តុ ទ្រង់បានសាងព្រះសថូបបញ្ចុះព្រះសរីរៈរបស់ព្រះដ៏មានព្រះភាគ និងការធ្វើមហកម្មក្នុងក្រុងរាជគ្រឹះ ។ សួរថា ទ្រង់បានធ្វើយ៉ាងណា ? ឆ្លើយថា ទ្រង់បានធ្វើការមហកម្មតាំងពីក្រុងកុសិនារារហូតដល់ក្រុងរាជគ្រឹះ មានចម្ងាយផ្លូវ ២៥ យោជន៍ ។ ក្នុងចន្លោះនោះ ទ្រង់ឲ្យធ្វើផ្លូវទទឹង ៨ ឧសភៈ ពង្រាបដីឲ្យរាបស្មើ បន្ទាប់ឲ្យធ្វើការបូជាក្នុងផ្លូវ ២៥ យោជន៍ ដូចដែលពួកស្តេចមល្លៈបន្ទាប់ឲ្យធ្វើការបូជាចន្លោះមកុដពន្ធនចេតិយ និងសណ្ឋាគារ ទ្រង់ពង្រីកទៅក្នុងចន្លោះផ្សារ ក្រាលក្នុងទីគ្រប់កន្លែង ដើម្បីអនុគ្រោះដល់មនុស្សលោក ទ្រង់ឲ្យការពារព្រះបរមធាតុ ដែលបញ្ចុះទុកក្នុងម្ជូរសមាស ដោយរបងលំពែង

ឲ្យមនុស្សប្រជុំគ្នាជាបរិមណ្ឌល ៥០០ យោជន៍ ក្នុងដែនរបស់ព្រះអង្គ ។ មនុស្សទាំងនោះទទួលព្រះបរមធាតុ លេងសាធុកីឡា ចេញចាកក្រុងកុសិនារា ជួបឃើញផ្កាឈើមានពណ៌ហាក់បីដូចមាសក្នុងទីណាៗ ក៏បេះផ្កាឈើទាំងនោះក្នុងទីនោះៗ បូជាព្រះបរមធាតុក្នុងចន្លោះលំពែង វេលាផ្កាឈើទាំងនោះអស់ហើយក៏ដើរតទៅ កាលដល់ត្រង់ទីមនៃរថខាងក្រោយ ក៏នាំគ្នាលេងសាធុកីឡាមួយកន្លៃៗ ៧ ថ្ងៃ កាលមនុស្សទទួលព្រះបរមធាតុ នាំគ្នាមកដោយអាការយ៉ាងនេះ វេលាក៏កន្លងទៅ ៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ ។ ពួកមិច្ឆាទិដ្ឋិនាំគ្នាតិះដៀលថា តាំងពីព្រះសមណគោតមបរិនិព្វាន ពួកយើងក៏ក្រវល់ក្រវាយ ដោយការលេងសាធុកីឡា ដោយពលការ ការងាររបស់ពួកយើងវិនាសទៅអស់ហើយ ក៏ការក្តៅក្រហាយចិត្ត ទៅកើតក្នុងអបាយប្រមាណ ៨៦,០០០ នាក់ ។

ពួកព្រះខីណាស្រេព រឭកហើយឃើញថា មហាជនក្តៅក្រហាយចិត្ត នាំគ្នាកើតក្នុងអបាយ ហើយត្រិះរិះថា នឹងឲ្យស្តេចសក្កទេវរាជទ្រង់ធ្វើឧបាយនាំព្រះបរមធាតុមក ដូច្នេះ ទើបនាំគ្នាទៅកាន់សម្នាក់ស្តេចសក្កទេវរាជនោះ ទូលប្រាប់រឿងនោះ ហើយទូលថា ព្រះមហារាជ សូមទ្រង់មេត្តាធ្វើឧបាយនាំព្រះបរមធាតុមកចុះ ។ ស្តេចសក្កៈត្រាស់ថា លោកម្ចាស់ដែលឈ្មោះថា បុថុជ្ជនដែលមានសទ្ធាស្មើដោយព្រះបាទអជាតសត្តុមិនមានព្រះអង្គទ្រង់មិនជឿយើងទេ ក៏ប៉ុន្តែថា ខ្ញុំនឹងសម្តែងវត្ថុដែលគួរភ័យខ្លាច ។

ដូចមារដែលគួរភ័យខ្លាច នឹងប្រកាសឲ្យលាន់ឮ នឹងធ្វើជាអ្នកជម្លីញទៅទៀត ដូចមនុស្សខ្មោចចូល សូមលោកម្ចាស់ទូលថា មហាបពិត្រ ពួកអមនុស្ស គេក្រោធខឹង មេត្តាឲ្យនាំព្រះបរមធាតុទៅដោយរហ័ស ដោយឧបាយយ៉ាងនេះ ស្តេចលោកក៏នឹងទ្រង់ឲ្យនាំព្រះបរមធាតុទៅ ។ គ្រានោះឯង ស្តេចសក្កៈ ក៏បានទ្រង់ធ្វើវត្ថុគ្រប់យ៉ាងដូចពោលនោះ ចំណែកព្រះថេរៈទាំងឡាយក៏ ចូលទៅគាល់ព្រះរាជាទូលថា ថ្វាយព្រះពរ ពួកអមនុស្សគេក្រោធខឹង មេត្តា ឲ្យនាំព្រះបរមធាតុទៅចុះ ។ ព្រះរាជាត្រាស់ថា លោកម្ចាស់ ចិត្តរបស់ ញោមមិនទាន់អស់សេចក្តីត្រេកអរ តែបើដូច្នោះ ក៏នឹងឲ្យគេនាំព្រះបរម-ធាតុទៅ ។ ក្នុងថ្ងៃទី ៧ មនុស្សទាំងឡាយក៏នាំព្រះបរមធាតុមកដល់ ។ ព្រះរាជាទ្រង់ ទទួលព្រះបរមធាតុដែលមកដោយអាការយ៉ាងនោះ ទ្រង់សាង ព្រះស្ដូបទុកក្នុងក្រុងរាជគ្រឹះ និងទ្រង់ធ្វើមហាកម្ម សូម្បីពួកស្តេចពួក ដទៃៗ ក៏នាំទៅតាមសមគួរដល់កម្លាំងរៀងៗ ខ្លួន សាងព្រះស្ដូបទុកក្នុង ស្ថានរៀងៗ ខ្លួន ហើយធ្វើមហាកម្ម ។ បទថា ឯវមេតំ ភូតបុព្វំ សេចក្តី ថា ការបែងចែកព្រះបរមធាតុ និងការសាងព្រះស្ដូប ១០ កន្លែងនេះ ធ្លាប់មានមកហើយក្នុងជម្ពូទ្វីប ដោយប្រការដូច្នេះ ។ ខាងក្រោយ ព្រះ សង្គីតិកាចារ្យទាំងឡាយ ទើបពោលទុក ។

កាលនាំគ្នាស្ថាបនាព្រះស្ដូបដូច្នេះហើយ ព្រះមហាកស្សបត្ថេរឃើញ អន្តរាយរបស់ព្រះបរមធាតុទាំងឡាយ ទើបចូលទៅគាល់ព្រះបាទអជាតសត្តុ

ទូលថា ថ្វាយព្រះពរ គួររក្សាព្រះបរមធាតុទុកយ៉ាងនេះឯង ព្រះបាទអជាត-សត្តុត្រាស់ថា ល្អណាស់លោកម្ចាស់កិច្ចដោយការរក្សាព្រះបរមធាតុរបស់ញោម ចូរលើកទុកសិន តែញោមនឹងនាំព្រះបរមធាតុដ៏សេស មកបានយ៉ាងណា ។ ទូលថា ថ្វាយព្រះពរ ការនាំព្រះបរមធាតុមក មិនមែនភារៈរបស់មហាបពិត្រ តែជាភារៈរបស់ពួកអាត្មាភាព ។ ត្រាស់ថា ល្អណាស់លោកម្ចាស់ សូមលោកម្ចាស់មេត្តានាំព្រះបរមធាតុមកចុះ ញោមនឹងរក្សាទុក ។ ព្រះថេរៈវៀរទុកត្រឹមតែទីរាជត្រកូលនោះៗ បិទបាំងទុកព្រះបរម-ធាតុ ចំណែកដ៏សេសក៏នាំមក ។ ចំណែកព្រះបរមធាតុទាំងឡាយក្នុងរាមគ្រាម ពួកនាគថែរក្សាទុក ។ ព្រះថេរៈត្រិះរិះថា ការអន្តរាយរបស់ព្រះបរមធាតុទាំងនោះមិនមាន តទៅក្នុងអនាគតកាល មនុស្សទាំងឡាយនឹងរក្សាទុកក្នុងព្រះមហាចេតិយ នាមហាវិហារលង្កាទ្វីប ដូច្នេះ ហើយមិននាំព្រះបរមធាតុទាំងនោះមក នាំមកពីនគរទាំង ៧ ដ៏សេសប្រតិស្ឋានទុកក្នុងទិសខាងកើត ឈាងខាងត្បូងនៃក្រុងរាជគ្រឹះ អធិដ្ឋានថា ថ្មណាមាននៅក្នុងទីនេះ ថ្មនោះចូរអន្តរធានទៅ សូមឲ្យមានដីស្អាតល្អ សូមទឹកកុំជ្រាបឡើងមកដល់ ដូច្នេះ ។

ព្រះរាជា បង្គាប់ឲ្យជីកទីនោះ កកាយដីចេញពីទីនោះ រៀបឥដ្ឋជំនួស ត្រាស់បង្គាប់ឲ្យសាងចេតិយសម្រាប់ព្រះអសីតិមហាសាវក ។ អាចារ្យពួកខ្លះពោលថា សូម្បីកាលមានអ្នកសួរថា ព្រះរាជាបង្គាប់ឲ្យសាងអ្វីទុក

ក្នុងទីនេះ ធ្វើយថា ឲ្យសាងព្រះចេតិយសម្រាប់ព្រះមហាសាវកទាំងឡាយ ។ តែក្នុងទីនោះមានជម្រៅ ៨០ ហត្ថ បញ្ជាឲ្យក្រាលកម្រាលលោហៈទុកខាងក្រោម សាងប្រអប់ដែលធ្វើដោយឈើច័ន្ទលឿងជាដើម និងព្រះសថូប ទុកមួយកន្លែងៗ ៨ ។ គ្រានោះ ព្រះរាជាដាក់ព្រះបរមធាតុរបស់ព្រះ-មានព្រះភាគ ទុកក្នុងប្រអប់ចន្ទន៍លឿង ទ្រង់ដាក់ប្រអប់ចន្ទន៍លឿងនោះចុះក្នុងប្រអប់ចន្ទន៍លឿងមួយទៀត ហើយទ្រង់ដាក់ប្រអប់ចន្ទន៍លឿងសូម្បីនោះ ចុះក្នុងប្រអប់ចន្ទន៍លឿងមួយទៀត ដូចពោលមកដូច្នេះ ជាការទ្រង់រួមប្រអប់ ៨ ទុក ក្នុងស្ទឹកតែមួយគ្នា ដោយឧបាយយ៉ាងនោះឯង ទ្រង់ដាក់ប្រអប់ទាំង ៨ ប្រអប់នោះចុះ ក្នុងព្រះសថូបចន្ទន៍លឿង ៨ សថូប , ទ្រង់ដាក់សថូប ចន្ទន៍លឿងទាំង ៨ ចុះក្នុងប្រអប់ចន្ទន៍ក្រហម ៨ ប្រអប់ , ទ្រង់ដាក់ប្រអប់ច័ន្ទក្រហមទាំង ៨ ប្រអប់ ចុះក្នុងព្រះសថូបចន្ទន៍ក្រហម ៨ សថូប , ទ្រង់ដាក់សថូបចន្ទន៍ក្រហមទាំង ៨ សថូប ចុះក្នុងប្រអប់ភ្លុក , ទ្រង់ដាក់ប្រអប់ភ្លុកតាំង ៨ ប្រអប់ ចុះក្នុងសថូបភ្លុក ៨ សថូប , ហើយទ្រង់ ដាក់សថូបភ្លុកទាំង ៨ សថូប ចុះក្នុងប្រអប់រតនៈសុទ្ធ ៨ ប្រអប់ , ទ្រង់ដាក់ប្រអប់រតនៈសុទ្ធ ៨ ប្រអប់ ចុះក្នុងសថូបរតនៈសុទ្ធ ៨ សថូប , ទ្រង់ដាក់សថូបរតនៈសុទ្ធ ៨ សថូប ចុះក្នុងប្រអប់មាស ៨ ប្រអប់ , ទ្រង់ដាក់ប្រអប់មាស ៨ ប្រអប់ ចុះក្នុងសថូបមាស ៨ សថូប , ទ្រង់ដាក់សថូបមាស ៨ សថូប ចុះក្នុងប្រអប់ប្រាក់ ៨ ប្រអប់ , ទ្រង់

ដាក់ប្រអប់ប្រាក់ ៨ ប្រអប់ ចុះក្នុងសដូបប្រាក់ ៨ សដូប , ទ្រង់ដាក់សដូបប្រាក់ ៨ សដូប ចុះក្នុងប្រអប់មណី ៨ ប្រអប់ , ទ្រង់ដាក់ប្រអប់មណី ៨ ប្រអប់ ចុះក្នុងសដូបមណី ៨ សដូប , ទ្រង់ដាក់សដូបមណី ៨ សដូប ចុះក្នុងប្រអប់កែវទទឹម ៨ ប្រអប់ , ហើយទ្រង់ដាក់ប្រអប់កែវទទឹមចុះ ក្នុងកែវទទឹម ៨ សដូប , ទ្រង់ដាក់សដូបកែវទទឹម ៨ សដូប ចុះក្នុងប្រអប់កែវប្រវាឡ ៨ ប្រអប់ , ហើយទ្រង់ដាក់ប្រអប់កែវប្រវាឡ ៨ ប្រអប់ ចុះក្នុងសដូបហើយកែវប្រវាឡ ៨ សដូប , ទ្រង់ដាក់សដូបកែវប្រវាឡ ៨ សដូប ចុះក្នុងប្រអប់កែវផលឹក ៨ ប្រអប់ , ហើយទ្រង់ដាក់ប្រអប់កែវ ចុះក្នុងសដូបកែវផលឹក ៨ សដូប ។

ចេតិយកែវផលឹកមានមុនចេតិយទាំងអស់ កាន់យកជាប្រមាណនៃចេតិយក្នុងថូបារាម ។ លើចេតិយកែវផលឹកនោះ បញ្ជាឲ្យសាងផ្ទះធ្វើដោយរតនៈសុទ្ធ ។ លើផ្ទះរតនៈនោះ ឲ្យសាងផ្ទះធ្វើដោយមាស ទុកលើផ្ទះមាសនោះ ឲ្យសាងផ្ទះដោយប្រាក់ ទុកលើផ្ទះប្រាក់នោះ ឲ្យសាងផ្ទះធ្វើដោយស្ពាន់ ទុកលើផ្ទះស្ពាន់នោះ រោយគ្រាប់ខ្សាច់ធ្វើដោយរតនៈទាំងអស់ ចាក់រោយផ្កាឈើទឹក ផ្កាឈើគោក ១.០០០ ផ្កា បន្ទាប់ឲ្យសាងជាតក ៥៥០ ជាតក ព្រះអសីតិមហាថេរៈ ព្រះបាទសុទ្ធោទនមហារាជ ព្រះនាងមហាមាយាទេវី សហជាតទាំង ៧ ទាំងអស់ដូចពោលមកនេះ ធ្វើដោយមាសទាំងអស់ ។ បន្ទាប់ឲ្យតាំងឆ្នាំងទឹកពេញ ដែលធ្វើដោយមាស និងប្រាក់

មួយមុខៗ ៥០០ ឆ្នាំង ឲ្យលើកទង់មាស ៥០០ ឲ្យធ្វើប្រទីបមាស ៥០០ ប្រទីបប្រាក់ ៥០០ ទ្រង់ដាក់សរសៃសំពត់សំបកឈើទុកក្នុងប្រទីបទាំងនោះ បញ្ចុះប្រេងក្រអូប ។ គ្រានោះ លោកព្រះមហាកស្សបៈ អធិដ្ឋានថា កម្រងផ្កាកុំស្វិត ក្លិនក្រអូបកុំបាត់ ប្រទីបកុំរលត់ ហើយឲ្យចារឹកអក្សរទុកក្នុងផែនមាសថា សូម្បីក្នុងអនាគតកាលគ្រាព្រះកុមារព្រះនាមថា **អសោក** នឹងគ្រប់គ្រងរាជ្យសម្បត្តិ ជាព្រះបាទអសោកមហារាជ ទ្រង់នឹងធ្វើព្រះបរម-ធាតុទាំងនេះឲ្យផ្សាយច្រើនទៅ ដូច្នេះ ។ ព្រះរាជាទ្រង់យកគ្រឿងប្រដាប់ទាំងអស់បូជា ទ្រង់បិទទ្វារហើយស្តេចចេញទៅតាំងពីដំបូង ។ ស្តេចគ្រាបិទទ្វារស្អាន់ហើយ ទ្រង់ប្រថាប់ត្រាកូនសោរទុកត្រង់ខ្សែចង ទ្រង់ដាក់ដុំកែវមណីមួយដុំធំទុកត្រង់ទីនោះឯង បន្ទាប់ឲ្យចារឹកអក្សរទុកថា ក្នុងអនាគតកាល ស្តេចផែនដីដែលទុរគត ចូរកាន់យកកែវមណីប៉ុណ្ណោះ ធ្វើសក្ការៈព្រះបរមធាតុទាំងឡាយហោង ។

ស្តេចសក្កៈទេវរាជ ហៅវិស្សុកម្មទេវបុត្រមក បន្ទាប់ដោយព្រះតម្រាស់ថា បាអើយ ព្រះបាទអជាតសត្តុ ទ្រង់រក្សាព្រះបរមធាតុហើយ អ្នកចូរតាំងកងទ័ពរក្សាការណ៍នោះទុកចុះ ។ វិស្សុកម្មទេវបុត្រមកប្រកបរូបយន្តមានគ្រោងឆ្អឹងរាងកាច រូបឈើ (តុក្កតាយន្ត) កាន់ព្រះខ័នពណ៌កែវផលឹក ក្នុងបន្ទប់ព្រះបរមធាតុ កម្រើកខ្លួនបានរហ័សដូចខ្យល់ ។ វិស្សុកម្មទេវបុត្រប្រកបរូបយន្តហើយ ធ្វើស្នៀតគន្លឹះទុកត្រង់ទីតែមួយប៉ុណ្ណោះ

យកសិលាព័ទ្ធទុកដោយជុំវិញ ដោយអាការដូចផ្ទះសាងដោយឥដ្ឋ ខាងលើបិទដោយផ្ទាំងសិលាតែមួយ រោយធូលី ហើយធ្វើផែនដីឲ្យរាប ហើយប្រតិស្ឋានសជូបថ្មទុកលើទីនោះ ។ កាលការរក្សាព្រះបរមធាតុសម្រេចរៀបរយយ៉ាងនេះហើយ ឯព្រះថេរៈតាំងនៅដរាបដល់អស់អាយុ ក៏បរិនិព្វាន ចំណែកព្រះរាជាក៏ស្ដេចទៅតាមយថាកម្ម ពួកមនុស្សទាំងនោះ ក៏ស្លាប់ទៅ ។

តមកខាងក្រោយ កាលអសោកកុមារគ្រប់គ្រងរាជ្យសម្បត្តិ ជាព្រះធម៌រាជា ព្រះនាមថា អសោក ទ្រង់ទទួលព្រះបរមធាតុទាំងនោះទុកហើយ ទ្រង់បានធ្វើឲ្យមានការផ្សព្វផ្សាយយ៉ាងច្រើន ។ ទ្រង់ធ្វើឲ្យផ្សព្វ-ផ្សាយច្រើន យ៉ាងណា ? ព្រះបាទអសោកនោះ អាស្រ័យនិគ្រោធសាមណេរ ទ្រង់មានសេចក្ដីជ្រះថ្លាក្នុងព្រះសាសនា បញ្ជាឲ្យសាងវិហារ ៨៤.០០០ វិហារហើយ ត្រាស់សួរភិក្ខុសង្ឃថា ញោមឲ្យសាងវិហារ ៨៤.០០០ វិហារហើយ នឹងបានព្រះបរមធាតុមកពីណាហ្ន៎ លោកម្ចាស់ ។ ភិក្ខុសង្ឃទូលថា ថ្វាយព្រះពរ ពួកអាត្មាភាពបានឮមកថា ឈ្មោះថាទីរក្សាព្រះបរមធាតុមាននៅ តែមិនជ្រាបថា នៅទីណា ។ ព្រះរាជាឲ្យរើព្រះចេតិយក្នុងក្រុងរាជគ្រឹះ ក៏មិនជួប ទ្រង់ឲ្យធ្វើព្រះចេតិយល្អដូចដើមហើយទ្រង់នាំបរិស័ទ ៤ គឺ ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ទៅកាន់ក្រុងវេសាលី សួរឲ្យក្នុងទីនោះក៏មិនបាន ក៏ទៅកាន់ក្រុងកបិលពស្ដុ សួរឲ្យ

ក្នុងទីនោះក៏មិនបាន ហើយទៅកាន់រាមគ្រាម ពួកនាគក្នុងរាមគ្រាម ក៏មិនព្រមឲ្យរើព្រះចេតិយ ។ ចបដែលធ្លាក់ត្រូវព្រះចេតិយ ក៏ត្រូវកាច់បំបាក់ជាកំណាត់តូចៗ ខ្ទេចខ្ទី ។ ដោយអាការយ៉ាងនេះ សូម្បីក្នុងទីនោះក៏មិនបាន ក៏ទៅកាន់ក្រុងអល្លកប្បៈ វេដ្ឋទីបៈ បាវា កុសិនារា ក្នុងទីគ្រប់កន្លែងដូចពោលមកនេះ រើព្រះចេតិយ ហើយ ក៏មិនបានព្រះបរមធាតុឡើយ គ្រាធ្វើចេតិយទាំងនោះឲ្យល្អដូចដើមហើយ ក៏ត្រឡប់ទៅកាន់ក្រុងរាជគ្រឹះទៀត ទ្រង់ប្រជុំបរិស័ទ ៤ ទើបត្រាស់សួរថា អ្នកណាធ្លាប់បានឮថា ទីរក្សាព្រះបរមធាតុក្នុងទីឈ្មោះឯណោះ មានដែរទេ ។ ក្នុងទីប្រជុំនោះ ព្រះថេរៈមួយរូប អាយុ ១២០ ឆ្នាំ ពោលថា អាត្មាភាពក៏មិនដឹងថា ទីរក្សាព្រះបរមធាតុនៅត្រង់ទីនោះ តែកាលពីអាត្មាភាពអាយុ ៧ ខួប ព្រះមហាថេរៈបិតា ឲ្យអាត្មាភាពកាន់ហិបកម្រងផ្កា ពោលថា មកនេះសាមណេរ ចន្លោះជន្លត់ឈើត្រង់ឯណោះ មានសថូបថ្ម យើងនាំគ្នាទៅទីនោះចុះ ហើយទៅបូជា លោកនិយាយថា សាមណេរ គួរពិចារណាទីត្រង់នេះ ។ ថ្វាយព្រះពរ អាត្មាភាពដឹងប៉ុណ្ណេះ ព្រះរាជាត្រាស់ថា ទីនុ៎ះឯង ហើយបង្គាប់ឲ្យកាត់ជន្លត់ឈើ ហើយនាំសថូបថ្ម និងធូលីចេញ ក៏ទ្រង់ឃើញផែនដីបូកកំបោរនៅទីនោះ តពីនោះទ្រង់ទម្លាយកំបោរបូក និងដុំឥដ្ឋ ហើយស្តេចកាន់បរិវេណតាមលំដាប់ ទតឃើញខ្សាច់រតនៈ ៧ ប្រការ និងរូបឈើ (តុក្កតាយន្ត) កាន់ដាវ ដើរវិលទៅមក ស្តេចបង្គាប់ឲ្យពួកមនុស្ស

ចេះមន្តខ្វាចមក សូម្បីឲ្យធ្វើការសែនបួនសួនហើយ ក៏មិនឃើញទីបំផុត ខាងដើមខាងចុងឡើយ ទើបទ្រង់នមស្ការទេវតាទាំងឡាយ ហើយត្រាស់ថា ខ្ញុំទទួលព្រះបរមធាតុទាំងនេះហើយ បញ្ចុះទុកក្នុងវិហារ ៨៤.០០០ វិហារ នឹងធ្វើសក្ការៈ សូមទេវតាកុំធ្វើអន្តរាយដល់ខ្ញុំឡើយ ។

ស្តេចសក្កៈទេវរាជ ស្តេចចារិកទៅទ្រង់ឃើញព្រះចៅអសោកនោះហើយ ហៅវិស្សុកម្មទេវបុត្រមកបង្គាប់ថា បាអើយ ព្រះធម្មរាជាអសោកនឹងទ្រង់នាំព្រះបរមធាតុទៅ ព្រោះដូច្នោះ បាឯងចូរចុះទៅកាន់បរិវេណទម្លាយរូបឈើ (តុក្កតាយន្ត) ចេញ វិស្សុកម្មទេវបុត្រនោះ ក៏ប្លែងភេទជាក្មេងអ្នកស្រុកទុកជុក ៥ កញ្ចុំ ឈរកាន់ធ្នូត្រង់ព្រះភ័ក្ត្ររបស់ព្រះរាជាហើយទូលថា ខ្ញុំនឹងនាំទៅ មហារាជ ។ ព្រះរាជាត្រាស់ថា នាំទៅចុះបា ។ វិស្សុកម្មទេវបុត្រ ចាប់សរបាញ់ត្រង់ទីចំណងតុក្កតាយន្តនោះឯង ធ្វើឲ្យគ្រប់យ៉ាងអន្តរាយទៅ ។ គ្រានោះ ព្រះរាជាទ្រង់កាន់ត្រាកូនសោរ ដែលជាប់នៅត្រង់ខ្សែចង ទតឃើញដុំកែវមណី និងឃើញអក្សរចារឹកថា ក្នុងអនាគតកាល ស្តេចផែនដីដែលទុរគត កាន់យកកែវមណីដុំនេះហើយ ចូរធ្វើសក្ការៈព្រះបរមធាតុទាំងឡាយ ទ្រង់ក្រោធថា មិនគួរនិយាយមើលងាយព្រះរាជាដូចជាយើងថា ស្តេចផែនដីក្រលំបាក ដូច្នេះ ហើយទ្រង់គោះដដែលៗ ឲ្យទ្វាររបើក ស្តេចចូលទៅខាងក្នុងផ្ទះប្រទីបដែលអុជទុក កាល ២១៨ ឆ្នាំ ក៏នៅតែឆេះយ៉ាងនោះឯង ផ្កាឈូកសក៏ដូចនាំមកដាក់ទុកខណៈ

នោះឯង កម្រាលផ្កាឈើក៏ដូចក្រាលទុកខណៈនោះឯង គ្រឿងក្រអូបក៏ដូចគេកិនដាក់ទុកកាលអម្បាញ់មិញនេះឯង ។ ព្រះរាជាទ្រង់កាន់ផែនមាសទ្រង់អានថា តទៅក្នុងអនាគតកាល គ្រាកុមារព្រះនាមថា អសោក នឹងគ្រប់គ្រងរាជ្យសម្បត្តិ ជាព្រះធម្មរាជាព្រះនាមថា អសោក ទ្រង់នឹងធ្វើព្រះបរមធាតុទាំងនេះ ឲ្យផ្សាយទៅកាន់ទីច្រើនដូច្នេះ ហើយត្រាស់ថា លោកដ៏ចម្រើន លោកម្ចាស់មហាកស្សបត្ថេរឃើញខ្លួនយើងហើយ ទ្រង់លើកព្រះហស្តឆ្វេងទះនឹងព្រះហស្តស្តាំ ។ ស្តេចវៀរត្រឹមតែព្រះបរមធាតុដែលគ្របបិទទុកក្នុងទីនោះ ទ្រង់ធ្វើព្រះបរមធាតុដ៏សេសទាំងអស់មកហើយបិទទ្វារព្រះបរមធាតុទុកដូចដើម ទ្រង់ធ្វើទីគ្រប់កន្លែងឲ្យជាប្រក្រតី ដូចដើមហើយ បញ្ជាឲ្យប្រតិស្ឋានបាសាណចេតិយទុកខាងលើ ទ្រង់បញ្ចុះព្រះ-បរមធាតុទុកក្នុងវិហារ ៨៤.០០០ វិហារ ទ្រង់សំពះព្រះមហាថេរៈ ហើយត្រាស់សួរថា លោកម្ចាស់ ញោមជាទាយាទក្នុងព្រះពុទ្ធសាសនាបានទេ ? ព្រះមហាថេរៈទូលថា ថ្វាយព្រះពរ មហាបពិត្រនៅជាអ្នកខាងក្រៅរបស់ព្រះសាសនា នឹងជាទាយាទដូចម្តេចទៅ ។ ត្រាស់សួរថា ក៏ញោមបរិច្ចាគទ្រព្យដល់ ៩៦ កោដិ ឲ្យសាងវិហារទុកដល់ ៨៤.០០០ វិហារ មិនទាន់ជាទាយាទ អ្នកដទៃណាហ្ន៎នឹងជាទាយាទ ។ និយាយថា សូមថ្វាយព្រះពរ មហាបពិត្រ បានឈ្មោះថា ជាបច្ចយទាយក ក៏អ្នកណាបំបួសបុត្រ ឬធីតារបស់ខ្លួន អ្នកនេះទើបនឹងឈ្មោះថា ជាទាយាទរបស់ព្រះសាសនា ។

ស្តេចទើបឲ្យព្រះឱរស និងព្រះធីតាបួស ។ គ្រានោះ ព្រះថេរៈទាំងឡាយ ទូលព្រះអង្គថា សូមថ្វាយព្រះពរ ឥឡូវនេះ មហាបពិត្រជាទាយាទក្នុងព្រះសាសនាហើយ ។

បទថា ឯវមេតំ ភូតបុព្វំ សេចក្តីថា សូម្បីការរក្សាព្រះបរមធាតុក្នុងអតីតកាលនេះ ធ្លាប់មានមកហើយក្នុងភាគផែនដីជម្ពូទ្វីប ដោយប្រការដូច្នេះ ។ សូម្បីការកសង្គាយនាគ្រាទី ៣ ក៏ដាក់បទនេះទុក ។

**[១៦២]** ក៏គាថា ជាដើមថា អដ្ឋទោណំ ចក្ខុមតោ សរីរំ ជាដើមនេះ ព្រះថេរៈអ្នកសីហឡទ្វីប ពោលទុកហើយនោះឯង ។

ចប់ អដ្ឋកថា មហាបរិនិព្វានសូត្រ ទី ៣

ការពណ៌នាសេចក្តីនៃមហាវគ្គ

ដែលមាន ៣ សូត្រ ក៏ចប់ស្រេចហើយដែរ ។

សុមង្គលវិលាសិនី ទីឃនិកាយ តតិយភាគ មហាវគ្គ

១៦

រួមព្រះសូត្រដែលមានក្នុងវគ្គនេះគឺ

មហាបទានសូត្រ ១ មហានិទានសូត្រ ១ មហាបរិនិព្វានសូត្រ ១

រួមជា ៣ សូត្រ ។

# នាមសប្បុរសជន

## ចូលរួមជាធម្មទាន

-ឧបាសក ហេ អេន ឧបាសិកា កាំង ប៉ោទៀង ............................ 50 $

-ឧបាសក អ៊ីវ ភីរុណ ឧបាសិកា ឈឺ មីកុល ............................ 50 $

-ឧបាសិកា ឱក វាសនា ព្រមទាំងម្តាយ ......................... ៤០.០០០៛០០

-ឧបាសិកា ប៊ូ សៀកលីវ ប្រមទាំងបុត្តនិងចៅ ..................... ៥០.០០០៛០០

-ណុំា ពេទ្យធ្មេញ ....................... ៤០.០០០៛០០

-ក្រុមញាតិឧបាសិកា កែន ណារ៉ន ....................... ១៣៥.០០០៛០០

និង 10 $

